# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# អង្គុត្តរនិកាយ  តិកនិបាត
# ទុតិយភាគ
# ៤១



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

## AŃGUTTARANIKĀYA

## TIKANIPĀTA

## DUTIYABHĀGA

## 41

**សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី**
**សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា**

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ ៥០០ ឆ្នាំថ្លាយ ក្រោយអំពីការរំលត់ព្រះខន្ធ ចូលកាន់ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេសអ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំៗ តែងតែបានទទួលយកមកតម្កល់ ទុកធ្វើជាគ្រឹះ ដើម្បី ធ្វើការស្រាវ ជ្រាវសិក្សា ស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា ( ពុទ្ធធម៌ ) ។ កាលដើម ឡើយគេនាំគ្នា កត់ត្រាលើ ស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈ ក៏មាន លុះចំណេរតមកក៏បាននាំគ្នា បោះពុម្ពលើក្រដាស ចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ន នេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេស ម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើប យើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុប មិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំ ក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេច ព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួល ពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមឌ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

Printed and donated for free distribution by
**The Corporate Body of the Buddha Educational Foundation**
11F., 55 Hang Chow South Road Sec 1, Taipei, Taiwan, R.O.C.
Tel: 886-2-23951198 , Fax: 886-2-23913415
Email: overseas@budaedu.org
Website:http://www.budaedu.org
**This book is strictly for free distribution, it is not for sale.**
**សំរាប់ជាធម្មទានតែប៉ុណ្ណោះ**

# សេចក្តីណែនាំក្នុងការអាន

១) *ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។*

*ឧទាហរណ៍*

*-ពាក្យខ្មែរៈ* **សម្ល** *ក្នុងពាក្យនេះ ព្យញ្ជនៈ* **ល** *គឺជាជើងរបស់ព្យញ្ជនៈ* **ម** *ដូច្នេះពាក្យនេះគឺ* **សម្ល** *។*

*-ពាក្យបាលីៈ* **តស្ស** *គឺ* **តស្ស** *។*

២) *ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្តេចព្រះសង្ឃរាជជោតញ្ញាណោ* (**ជួន-ណាត**) *ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។*

៣) *ចំពោះ* **សង្ខិតច្រាប់ពាក្យខុស-ត្រូវ** *ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។*

# សុត្តន្តបិដក

## អង្គុត្តរនិកាយ    តិកនិបាត

## ទុតិយភាគ

៤១

ព.    ស.    ២៤៩៦

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស តិកនិបាតោ

## ទុតិយោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បឋមបណ្ណាសកេ ពាលវគ្គោ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច យានិ កានិចិ ភិក្ខវេ ភយានិ ឧប្បជ្ជន្តិ សព្វានិ តានិ ពាលតោ ឧប្បជ្ជន្តិ នោ បណ្ឌិតតោ យេ កេចិ ឧបទ្ទវា ឧប្បជ្ជន្តិ សព្វេ តេ ពាលតោ ឧប្បជ្ជន្តិ នោ បណ្ឌិតតោ យេ កេចិ ឧបសគ្គា ឧប្បជ្ជន្តិ សព្វេ តេ ពាលតោ ឧប្បជ្ជន្តិ នោ បណ្ឌិតតោ ។

# សុត្តន្តបិដក

# អង្គុត្តរនិកាយ តិកនិបាត

# ទុតិយភាគ

*សូមនមស្ការព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។*

## បឋមបណ្ណាសក ពាលវគ្គ

[១] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់សម្រេចឥរិយាបថ ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកគហបតី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលតបព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភ័យទាំងឡាយណាមួយកើតឡើង ភ័យទាំងអស់នោះ តែងកើតអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ឧបទ្រព (ចង្រៃ) ទាំងឡាយណាមួយកើតឡើង ឧបទ្រពទាំងអស់នោះ តែងកើតឡើងអំពីជនពាល មិនមែនកើត អំពីបណ្ឌិតទេ ឧបស័គ្គ (សេចក្តីទើសទាក់) ទាំងឡាយណាមួយកើតឡើង ឧបស័គ្គទាំងអស់នោះ តែងកើតឡើងអំពីជនពាល មិនមែនកើតអំពីបណ្ឌិតឡើយ ។*

សេយ្យថាបិ ភិក្ខវេ នឡាគារា វា តិណាគារា វា អគ្គិ មុត្តោ កូដាគារានិបិ ឌហតិ ឧល្លិត្តាវលិត្តានិ និវាតានិ ផុសិតគ្គឡានិ បិហិតវាតបានានិ ឯវមេវ ខោ ភិក្ខវេ យានិ កានិចិ ភយានិ ឧប្បជ្ជន្តិ សព្វានិ តានិ ពាលតោ ឧប្បជ្ជន្តិ នោ បណ្ឌិតតោ យេ កេចិ ឧបទ្ទវា ឧប្បជ្ជន្តិ សព្វេ តេ ពាលតោ ឧប្បជ្ជន្តិ នោ បណ្ឌិតតោ យេ កេចិ ឧបសគ្គា ឧប្បជ្ជន្តិ សព្វេ តេ ពាលតោ ឧប្បជ្ជន្តិ នោ បណ្ឌិតតោ ។ ឥតិ ខោ ភិក្ខវេ សប្បដិ-ភយោ ពាលោ អប្បដិភយោ បណ្ឌិតោ សឧបទ្ទវោ ពាលោ អនុបទ្ទវោ បណ្ឌិតោ សឧបសគ្គោ ពាលោ អនុបសគ្គោ បណ្ឌិតោ នត្ថិ ភិក្ខវេ បណ្ឌិតតោ ភយំ នត្ថិ បណ្ឌិតតោ ឧបទ្ទវោ នត្ថិ បណ្ឌិតតោ ឧបសគ្គោ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ យេហិ តីហិ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ តេ តយោ ធម្មេ អភិនិវជ្ជេត្វា

ម្នាលភិក្ខុទាំងឡាយ ភ្លើងតែងឆេះរាលអំពីផ្ទះបបុសឬផ្ទះស្មៅ មកឆេះផ្ទះកំពូលទាំងឡាយ ដែលគេលាបទាំងខាងក្នុង ទាំងខាងក្រៅ មិនមានខ្យល់ចូល មានសន្ទះទ្វារដ៏ជិត ស្និទ្ធ មានបង្អួចបិទជិតបាន ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភ័យទាំងឡាយណាមួយកើតឡើង ភ័យទាំងអស់នោះ តែងកើតឡើងអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ឧបទ្រពទាំងឡាយណាមួយកើតឡើង ឧបទ្រពទាំងអស់នោះ តែងកើតឡើងអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ឧបស័គ្គទាំងឡាយណាមួយកើតឡើង ឧបស័គ្គទាំងអស់នោះ តែងកើតអំពីជនពាល មិនមែនកើតអំពីបណ្ឌិតទេ ក៏ដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ជនពាលប្រកបដោយភ័យដ៏ពន្លឹក បណ្ឌិតមិនមានភ័យដ៏ពន្លឹកទេ ជនពាលប្រកបដោយឧបទ្រព បណ្ឌិតមិនមានឧបទ្រពទេ ជនពាលប្រកបដោយឧបស័គ្គ បណ្ឌិតមិនមានឧបស័គ្គទេ ។ ម្នាលភិក្ខុទាំងឡាយ ភ័យមិនមានមកអំពីបណ្ឌិត ឧបទ្រពមិនមានមកអំពីបណ្ឌិត ឧបស័គ្គមិនមានមកអំពីបណ្ឌិតទេ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះគួរអ្នកទាំងឡាយសិក្សាយ៉ាងនេះថា បុគ្គលប្រកបដោយធម៌ ៣ យ៉ាងណាដែលគេគួរស្គាល់បានថាជាពាលបុគ្គលដែលវៀរធម៌ទាំង ៣ យ៉ាងនោះ

យេហិ តីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោ តេ តយោ ធម្មេ សមាទាយ វត្តិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[២] កម្មលក្ខណោ ភិក្ខវេ ពាលោ កម្មលក្ខណោ បណ្ឌិតោ អបទានសោភណី[១] បញ្ញា ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ។ កតមេហិ តីហិ ។ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោ ។ កតមេហិ តីហិ ។ កាយសុចរិតេន វចីសុចរិតេន មនោសុចរិតេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ យេហិ តីហិ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ តេ តយោ ធម្មេ អភិនិវជ្ជេត្វា យេហិ តីហិ ធម្មេហិ សមន្នាគតោ

១ អបទានេ សោភតីតិបិ បាឋោ ។

ហើយប្រកបដោយធម៌ ៣ ណា ដែលគេគួរស្គាល់បានថាជាបណ្ឌិត ពួកយើងនឹងប្រព្រឹត្ត សមាទានធម៌ទាំង ៣ នោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង ។

[២] ម្នាលភិក្ខុទាំងឡាយ ជនពាលមានកម្មជាលក្ខណៈ បណ្ឌិតក៏មានកម្មជាលក្ខណៈ ប្រាជ្ញាតែងមានសេចក្តីរុងរឿងក្នុងការប្រព្រឹត្តមិនដាច់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងគួរសម្គាល់បានថាជាជនពាល ។ ធម៌ ៣ តើដូចម្តេច ។ គឺ កាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោ-ទុច្ចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ៣ នេះឯង ដែលគួរសម្គាល់បានថាជាជនពាល ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ គួរសម្គាល់បានថាជាបណ្ឌិត ។ ធម៌ ៣ តើដូចម្តេច ។ គឺ កាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ទាំង ៣ នេះឯង ដែលគួរសម្គាល់បានថាជាបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា បុគ្គលប្រកបដោយធម៌ ៣ ណា ដែលគួរសម្គាល់បានថាជាជនពាល បុគ្គលវៀរធម៌ទាំង ៣ នោះ ហើយប្រកបដោយធម៌ ៣ ណា

បណ្ឌិតោ វេទិតព្វោ តេ តយោ ធម្មេ សមាទាយ វត្តិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[៣] តីណីមានិ ភិក្ខវេ ពាលស្ស ពាល-លក្ខណានិ ពាលនិមិត្តានិ ពាលាបទានានិ ។ កតមានិ តីណិ ។ ឥធ ភិក្ខវេ ពាលោ ទុច្ចិន្តិត-ចិន្តី ច ហោតិ ទុព្ភាសិតភាសី ទុក្កតកម្មការី ។ នោ ចេ តំ ភិក្ខវេ ពាលោ ទុច្ចិន្តិតចិន្តី ច អភវិស្ស ទុព្ភាសិតភាសី ទុក្កតកម្មការី កេន នំ បណ្ឌិតា ជានេយ្យុំ ពាលោ អយំ ភវំ អសប្បុរិសោតិ ។ យស្មា ច ខោ ភិក្ខវេ ពាលោ ទុច្ចិន្តិតចិន្តី ច ហោតិ ទុព្ភា-សិតភាសី ទុក្កតកម្មការី តស្មា នំ បណ្ឌិតា ជានន្តិ ពាលោ អយំ ភវំ អសប្បុរិសោតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ ពាលស្ស ពាលលក្ខណានិ ពាលនិមិត្តានិ ពាលាបទានានិ ។ តីណីមានិ ភិក្ខវេ បណ្ឌិតស្ស បណ្ឌិតលក្ខណានិ បណ្ឌិតនិមិត្តានិ បណ្ឌិតាបទានានិ ។ កតមានិ តីណិ ។

ដែលគួរសម្គាល់បានថាជាបណ្ឌិតយើងទាំងឡាយ នឹងសមាទានប្រព្រឹត្តធម៌ទាំង ៣ នោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង ។

[៣] ម្នាលភិក្ខុទាំងឡាយ ពាលលក្ខណៈ[១] ពាលនិមិត្ត[២] ពាលាបទាន[៣] របស់បុគ្គលពាលនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ជនពាលក្នុងលោកនេះ អ្នកគិតគំនិតអាក្រក់ ១ អ្នកនិយាយសម្តីអាក្រក់ ១ អ្នកធ្វើអំពើអាក្រក់ ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើជនពាលមិនបានគិតគំនិតអាក្រក់ក្តី មិនបាននិយាយសម្តីអាក្រក់ក្តី មិនបានធ្វើអំពើអាក្រក់ក្តីទេ បណ្ឌិតទាំងឡាយ គប្បីស្គាល់បុគ្គលនោះថា អ្នកដ៏ចម្រើននេះជាជនពាល ជាអសប្បុរស ដូចម្តេចបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះជនពាលជាអ្នកគិតគំនិតអាក្រក់ផង ជាអ្នកនិយាយសម្តីអាក្រក់ផង ជាអ្នកធ្វើអំពើអាក្រក់ផង បានជាបណ្ឌិតទាំងឡាយ ស្គាល់បុគ្គលនោះថា អ្នកដ៏ចម្រើននេះជាជនពាល ជាអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ពាលលក្ខណៈ ពាលនិមិត្ត ពាលាបទាន នៃជនពាល ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតលក្ខណៈ[៤] បណ្ឌិតនិមិត្ត [៥]បណ្ឌិតាបទាន[៦] របស់បុគ្គលជាបណ្ឌិតនេះ មាន ៣ យ៉ាង ។ ៣ យ៉ាង តើដូចម្តេច ។

---

១ គ្រឿងសម្គាល់របស់បុគ្គលពាល ។ ២ ហេតុរបស់បុគ្គលពាល ។ ៣ ចរិតរបស់បុគ្គលពាល ។ ៤ គ្រឿងសម្គាល់របស់បុគ្គលជាបណ្ឌិត ។ ៥ ហេតុរបស់បុគ្គលជាបណ្ឌិត ។ ៦ ចរិតរបស់បុគ្គលជាបណ្ឌិត ។

៨



ឥធ ភិក្ខវេ បណ្ឌិតោ សុចិន្តិតចិន្តី ច ហោតិ សុភាសិតភាសី សុកតកម្មការី ។ នោ ចេ តំ ភិក្ខវេ បណ្ឌិតោ សុចិន្តិតចិន្តី ច អភវិស្ស សុភាសិតភាសី សុកតកម្មការី កេន នំ បណ្ឌិតា ជានេយ្យុំ បណ្ឌិតោ អយំ ភវំ សប្បុរិសោតិ ។ យស្មា ច ខោ ភិក្ខវេ បណ្ឌិតោ សុចិន្តិតចិន្តី ច ហោតិ សុភាសិតភាសី សុកតកម្មការី តស្មា នំ បណ្ឌិតា ជានន្តិ បណ្ឌិតោ អយំ ភវំ សប្បុរិសោតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ បណ្ឌិតស្ស បណ្ឌិតលក្ខណានិ បណ្ឌិតនិមិត្តានិ បណ្ឌិតាបទានានិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ យេហិ តីហិ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ តេ តយោ ធម្មេ អភិនិវជ្ជេត្វា យេហិ តីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោ តេ តយោ ធម្មេ សមាទាយ វត្តិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ[(១)] ។

---

១ ឱ. ម. បោឋកេ តស្មាតិហ ភិក្ខវេ ។ ល ។ សិក្ខិតព្វន្តីតិ បាឋោ ន ទិស្សន្តិ ។

បឋមបណ្ណាសក ពាលវគ្គ

ម្នាលភិក្ខុទាំងឡាយ បណ្ឌិតក្នុងលោកនេះ ជាអ្នកគិតគំនិតល្អ ១ និយាយសម្តីល្អ ១ ធ្វើអំពើល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបណ្ឌិត ជាអ្នកមិនបានគិតគំនិតល្អផង មិនបាននិយាយសម្តីល្អផង មិនបានធ្វើអំពើល្អផងទេ បណ្ឌិតទាំងឡាយ គប្បីស្គាល់បុគ្គលនោះថា អ្នកដ៏ចម្រើននេះ ជាបណ្ឌិត ជាសប្បុរស ដូចម្តេចបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះបណ្ឌិតជាអ្នកគិតគំនិតល្អផង និយាយសម្តីល្អផង ធ្វើអំពើល្អផង បានជាបណ្ឌិតទាំងឡាយ ស្គាល់បុគ្គលនោះថា អ្នកដ៏ចម្រើននេះ ជាបណ្ឌិត ជាសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតលក្ខណៈ បណ្ឌិតនិមិត្ត បណ្ឌិតាបទាន របស់បុគ្គលជាបណ្ឌិត ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះអ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះថា បុគ្គលប្រកបដោយធម៌ ៣ ណា ដែលស្គាល់បានថាជាជនពាល បុគ្គលវៀរធម៌ទាំង ៣ នោះ ហើយប្រកបដោយធម៌ ៣ ណា ដែលស្គាល់បានថាជាបណ្ឌិត យើងទាំង-ឡាយ នឹងសមាទានប្រព្រឹត្តធម៌ទាំង ៣ យ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះចុះ ។

៦



[៤] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ។ កតមេហិ តីហិ ។ អច្ចយំ អច្ចយតោ ន បស្សតិ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ ន បដិ-ករោតិ បរស្ស ខោ បន អច្ចយំ ទេសេន្តស្ស យថាធម្មំ ន បដិគ្គណ្ហាតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោ ។ កតមេហិ តីហិ ។ អច្ចយំ អច្ចយតោ បស្សតិ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ បរស្ស ខោ បន អច្ចយំ ទេសេន្តស្ស យថាធម្មំ បដិគ្គណ្ហាតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោតិ ។

[៥] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ។ កតមេហិ តីហិ ។ អយោនិសោ បញ្ហំ កត្តា ហោតិ អយោនិសោ បញ្ហំ វិស្សជ្ជេតា ហោតិ

[៤] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងដែលសម្គាល់បានថាជាជនពាល ។ ធម៌ ៣ តើដូចម្តេច ។ គឺបុគ្គលមិនឃើញទោសរបស់ខ្លួនតាមទោស ១ លុះឃើញទោសតាមទោសហើយ មិនសម្តែងទោសឲ្យសមគួរតាមធម៌ ១ ទុកជាសម្តែងទោសរបស់ខ្លួនប្រាប់បុគ្គលដទៃហើយ ក៏មិនទទួលទោសឲ្យសមគួរតាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ នេះឯង ដែលគប្បីដឹងបានថាជាជនពាល ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ គប្បីដឹងបានថាជាបណ្ឌិត ។ ធម៌ ៣ តើដូចម្តេច ។ គឺបុគ្គលឃើញទោសរបស់ខ្លួនតាមទោស ១ លុះឃើញទោសតាមទោសហើយ ក៏សម្តែងទោសឲ្យសមគួរតាមធម៌ ១ លុះសម្តែងទោសប្រាប់បុគ្គលដទៃហើយ ក៏ទទួលទោសឲ្យសមគួរ តាមធម៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ នេះឯង ដែលគប្បីដឹងបានថាជាបណ្ឌិត ។

[៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង គប្បីដឹងបានថាជាជនពាល ។ ធម៌ ៣ តើដូចម្តេច ។ គឺ ជាអ្នកតាក់តែងនូវប្រស្នាដោយមិនត្រូវទំនង ១ ជាអ្នកដោះស្រាយប្រស្នាដោយមិនត្រូវទំនង ១

បរស្ស ខោ បន យោនិសោ បញ្ហំ វិស្សជ្ជិតំ បរិមណ្ឌលេហិ បទព្យញ្ជនេហិ សិលិដ្ឋេហិ ឧប-គតេហិ នាព្ភានុមោទិតា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោ ។ កតមេហិ តីហិ ។ យោនិសោ បញ្ហំ កត្តា ហោតិ យោនិសោ បញ្ហំ វិស្សជ្ជេតា ហោតិ បរស្ស ខោ បន យោនិសោ បញ្ហំ វិស្សជ្ជិតំ បរិមណ្ឌលេហិ បទព្យញ្ជនេហិ សិលិដ្ឋេហិ ឧបគតេហិ អព្ភានុមោទិតា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោតិ ។

[៦] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ។ កតមេហិ តីហិ ។ អកុសលេន កាយកម្មេន អកុសលេន វចីកម្មេន អកុសលេន មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោ ។

បើអ្នកដទៃដោះស្រាយប្រស្នាដោយត្រូវទំនងហើយ ក៏មិនសរសើរដោយបទនិងព្យញ្ជនៈ ជាបរិមណ្ឌលស្រួលបរិបូណ៌ឡើយ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ នេះឯង ដែលគួរស្គាល់បានថាជាជនពាល ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ គួរស្គាល់បានថាជាបណ្ឌិត ។ ធម៌ ៣ តើដូចម្តេច ។ គឺ ជាអ្នកតាក់តែងប្រស្នាដោយត្រូវទំនង ១ ជាអ្នកដោះស្រាយប្រស្នាដោយត្រូវទំនង ១ បើអ្នកដទៃដោះប្រស្នាដោយត្រូវទំនងហើយ ក៏សរសើរ ដោយបទនិងព្យញ្ជនៈជាបរិ-មណ្ឌលស្រួលបរិបូណ៌ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ នេះឯង ដែលគួរស្គាល់បានថាជាបណ្ឌិត ។

[៦] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងគួរស្គាល់បានថាជាជនពាល ។ ធម៌ ៣ តើដូចម្តេច ។ គឺកាយកម្មជាអកុសល ១ វចីកម្មជាអកុសល ១ មនោកម្មជាអកុសល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ នេះឯង ដែលគប្បីដឹងបានថាជាជនពាល ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ គប្បីដឹងបានថាជាបណ្ឌិត ។

កតមេហិ តីហិ ។ កុសលេន កាយកម្មេន កុសលេន វចីកម្មេន កុសលេន មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោតិ ។

[៧] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ។ កតមេហិ តីហិ ។ សាវជ្ជេន កាយកម្មេន សាវជ្ជេន វចីកម្មេន សាវជ្ជេន មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោ ។ កតមេហិ តីហិ ។ អនវជ្ជេន កាយកម្មេន អនវជ្ជេន វចីកម្មេន អនវជ្ជេន មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោតិ ។

[៨] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ។ កតមេហិ តីហិ ។ សព្យាបជ្ឈេន កាយកម្មេន សព្យាបជ្ឈេន វចីកម្មេន សព្យាបជ្ឈេន មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ពាលោ វេទិតព្វោ ។

ធម៌ ៣ តើដូចម្តេច ។ គឺកាយកម្មជាកុសល ១ វចីកម្មជាកុសល ១ មនោកម្មជាកុសល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង ដែលគប្បីដឹងបានថាជាបណ្ឌិត ។

[៧] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង គួរស្គាល់បានថាជាជនពាល ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ គឺ កាយកម្មប្រកបដោយទោស ១ វចីកម្មប្រកបដោយទោស ១ មនោកម្មប្រកបដោយទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ នេះឯងដែលគប្បីដឹងបានថាជាជនពាល ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ គួរស្គាល់បានថាជាបណ្ឌិត ។ ធម៌ ៣ តើដូចម្តេច ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមានទោស ១ មនោកម្មមិនមានទោស ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង ដែលគប្បីដឹងបានថាជាបណ្ឌិត ។

[៨] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងគួរស្គាល់បានថាជាជនពាល ។ ធម៌ ៣ តើដូចម្តេច ។ គឺ កាយកម្មប្រកបដោយសេចក្តីបៀតបៀន ១ វចីកម្មប្រកបដោយសេចក្តីបៀតបៀន ១ មនោកម្មប្រកបដោយសេចក្តីបៀតបៀន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង ដែលគប្បីដឹងបានថាជាជនពាល ។

តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោ ។ កតមេហិ តីហិ ។ អព្យាបជ្ជេន កាយ-កម្មេន អព្យាបជ្ជេន វចីកម្មេន អព្យាបជ្ជេន មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ យេហិ តីហិ ធម្មេហិ សមន្នា-គតោ ពាលោ វេទិតព្វោ តេ តយោ ធម្មេ អភិ-និវជ្ជេត្វា យេហិ តីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ វេទិតព្វោ តេ តយោ ធម្មេ សមាទាយ វត្តិស្សាមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[៩] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងគួរស្គាល់បានថាជាបណ្ឌិត ។ ធម៌ ៣ តើដូចម្តេច ។ គឺ កាយកម្មមិនមានសេចក្តីបៀតបៀន ១ វចីកម្មមិនមានសេចក្តីបៀតបៀន ១ មនោកម្មមិនមានសេចក្តីបៀតបៀន ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ នេះឯងដែលគប្បីដឹងបានថាជាបណ្ឌិត ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា បុគ្គលប្រកបដោយធម៌ ៣ ណា ដែលគួរស្គាល់ថាជាជនពាល បុគ្គលបានវៀរបង់នូវធម៌ ៣ នោះ ហើយប្រកបដោយធម៌ ៣ ណាដែលគួរស្គាល់បានថាជាបណ្ឌិត យើងទាំងឡាយនឹងសមាទាន ប្រព្រឹត្តនូវធម៌ទាំង ៣ នោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះចុះ ។

[៩] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ជាអ្នកមិនឈ្លាសវៃ ជាអសប្បុរសប្រកបដោយធម៌៣យ៉ាង រមែងរក្សាខ្លួនដែលមានទីពឹងជីកគាស់ចោលហើយ មានទីពឹងបំផ្លាញចោលហើយ ប្រកបដោយទោសផង

សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កាតមេហិ តីហិ ។ កាយ-ទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នា-គតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុប-ហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ ។ កាតមេហិ តីហិ ។ កាយសុចរិតេន វចីសុចរិតេន មនោសុចរិតេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតីតិ ។

ប្រកបដោយសេចក្តីតិះដៀល របស់វិញ្ញូជនទាំងឡាយផង បាននូវបាបច្រើនផង ។ ធម៌ ៣ យ៉ាងតើដូចម្តេច ។ គឺកាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ជាអ្នកមិនឈ្លាសវៃ ជាអសប្បុរសប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងរក្សាខ្លួនដែលមានទីពឹងជីកគាស់ចោលហើយ មានទីពឹងបំផ្លាញចោលហើយ ជាអ្នកប្រកបដោយទោសផង ប្រកបដោយសេចក្តីតិះដៀល របស់វិញ្ញូជនទាំងឡាយផង បាននូវបាបច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតមានប្រាជ្ញាឈ្លាសវៃ ជាសប្បុរសប្រកបដោយធម៌ ៣ យ៉ាង រមែងរក្សាខ្លួនដែលមានទីពឹងមិនបានជីកគាស់ចោល មានទីពឹងមិនបានបំផ្លាញចោល ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀល អំពីវិញ្ញូជនទាំងឡាយផង បាននូវបុណ្យច្រើនផង ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ គឺកាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតមានប្រាជ្ញាឈ្លាសវៃ ជាសប្បុរសប្រកបដោយធម៌ ៣ នេះឯង រមែងរក្សាខ្លួនដែលមានទីពឹងមិនបានជីកគាស់ចោល មានទីពឹងមិនបានបំផ្លាញចោល ជាអ្នកមិនមានទោសផង មិនមានសេចក្តីតិះដៀល អំពីវិញ្ញូជនទាំងឡាយផង បាននូវបុណ្យច្រើនផង ។

បឋមបណ្ណាសកេ ពាលវគ្គោ

[១០] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ តយោ មលេ អប្បហាយ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ តីហិ ។ ទុស្សីលោ ច ហោតិ ទុស្សីល្យមលញ្ចស្ស អប្បហីនំ ហោតិ ឥស្សុកី ច ហោតិ ឥស្សាមលញ្ចស្ស អប្បហីនំ ហោតិ មច្ឆរី ច ហោតិ មច្ឆេរមលញ្ចស្ស អប្បហីនំ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ឥមេ តយោ មលេ អប្បហាយ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ តយោ មលេ បហាយ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ តីហិ ។ សីលវា ច ហោតិ ទុស្សីល្យមលញ្ចស្ស បហីនំ ហោតិ អនិស្សុកី ច ហោតិ ឥស្សាមលញ្ចស្ស បហីនំ ហោតិ អមច្ឆរី ច ហោតិ មច្ឆេរមលញ្ចស្ស បហីនំ ហោតិ ។

[១០] ម្នាលភិក្ខុទាំងឡាយ បើបុគ្គលពាល ប្រកបដោយធម៌ ៣ យ៉ាង មិនលះបង់នូវមន្ទិល ៣ យ៉ាងទេ នឹងធ្លាក់ក្នុងនរក ដូចជាគេនាំយកទៅទំលាក់ ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ គឺជាអ្នកទ្រុស្តសីល ទាំងមិនលះបង់មន្ទិល គឺភាវៈទ្រុស្តសីល ១ ជាអ្នកច្រណែន ទាំងមិនលះបង់មន្ទិលគឺសេចក្តីច្រណែន ១ជាអ្នកកំណាញ់ ទាំងមិនលះបង់មន្ទិលគឺសេចក្តីកំណាញ់ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលប្រកបដោយធម៌ ៣ យ៉ាងនេះឯង មិនលះបង់មន្ទិល ៣ យ៉ាងនេះឯង តែងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតប្រកបដោយធម៌ ៣ យ៉ាង លះបង់នូវមន្ទិល ៣ យ៉ាង ដូចជាគេនាំយកទៅតម្កល់ទុកក្នុងស្ថានសួគ៌ ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ គឺជាអ្នកមានសីល ទាំងលះបង់មន្ទិលគឺភាវៈទ្រុស្តសីល ១ ជាអ្នកមិនច្រណែន ទាំងលះបង់នូវមន្ទិលគឺ សេចក្តីច្រណែន ១ ជាអ្នកមិនមានកំណាញ់ ទាំងលះបង់នូវមន្ទិលគឺសេចក្តីកំណាញ់ ១ ។

១២



ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ឥមេ តយោ មលេ បហាយ យថាភតំ និក្ខិត្តោ ឯវំ សក្កេតិ ។

ពាលវគ្គោ បឋមោ ។

## តស្សុទ្ទានំ

ភយលក្ខណា ចិន្តា ច
អច្ចយញ្ច អយោនិសោ
អកុសលញ្ច សាវជ្ជំ
សព្យាបជ្ឈំ ខតំ មលន្តិ ។

ម្នាលភិក្ខុទាំងឡាយ បណ្ឌិតប្រកបដោយធម៌ ៣ យ៉ាងនេះ លះបង់នូវមន្ទិល ៣ យ៉ាងនេះឯង ដូចជាគេនាំយកទៅតម្កល់ទុក ក្នុងស្ថានសួគ៌ ។

ចប់ ពាលវគ្គទី ១ ។

# ឧទ្ទាននៃពាលវគ្គនោះគឺ

សម្តែងអំពីភ័យ ១ លក្ខណៈ ១ គំនិត ១ ទោស ១
ខុសទំនង ១ អកុសល ១ ប្រកបដោយទោស ១
ប្រកបដោយសេចក្តីបៀតបៀន ១ មានទីពឹងដីក
គាស់ចោល ១ មន្ទិល ១ ។

# រថការវគ្គោ

[១១] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ញាតកោ ភិក្ខុ ពហុជនាហិតាយ បដិបន្នោ ហោតិ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ កតមេហិ តីហិ ។ អននុលោមិកេ កាយកម្មេ សមាទបេតិ អននុលោមិកេ វចីកម្មេ សមាទបេតិ អននុលោមិកេសុ ធម្មេសុ សមាទបេតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ញាតកោ ភិក្ខុ ពហុជនាហិតាយ បដិបន្នោ ហោតិ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ញាតកោ ភិក្ខុ ពហុជនហិតាយ បដិបន្នោ ហោតិ ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានំ ។ កតមេហិ តីហិ ។ អនុលោមិកេ កាយកម្មេ សមាទបេតិ អនុលោមិកេ វចីកម្មេ សមាទបេតិ អនុលោមិកេសុ ធម្មេសុ សមាទបេតិ ។

# រថការវគ្គ

[១១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកេរ្តិ៍ឈ្មោះប្រកបដោយធម៌ ៣ យ៉ាងជាអ្នកប្រតិបត្តិ ដើម្បីមិនជាគុណដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាគុណ ដើម្បីជាទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ៣ យ៉ាង តើដូចម្ដេច ។ គឺភិក្ខុបបួលអ្នកផងក្នុងកាយកម្ម ដែលមិនសមគួរ ១ បបួលក្នុងវចីកម្ម ដែលមិនសមគួរ ១ បបួលក្នុងធម៌ទាំងឡាយ[១] ដែលមិនសមគួរ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកេរ្តិ៍ឈ្មោះ ប្រកបដោយធម៌ ៣ នេះឯង រមែងប្រតិបត្តិ ដើម្បីមិនជាគុណដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាគុណ ដើម្បីជាទុក្ខ ដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកេរ្តិ៍ឈ្មោះ ប្រកបដោយធម៌ ៣ យ៉ាង ជាអ្នកប្រតិបត្តិ ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណ ដើម្បីសេចក្ដីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។ ធម៌ ៣ យ៉ាង តើដូចម្ដេច ។ គឺភិក្ខុបបួលអ្នកផងក្នុងកាយកម្ម ដែលសមគួរ ១ បបួលក្នុងវចីកម្ម ដែលសមគួរ ១ បបួលក្នុងធម៌ទាំងឡាយ ដែលសមគួរ ១ ។

---

១ សំដៅយកមនោកម្ម ។ (អដ្ឋកថា) ។

ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ញាតកោ ភិក្ខុ ពហុជនហិតាយ បដិបន្នោ ហោតិ ពហុជនសុខាយ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ ។

[១២] តីណីមានិ ភិក្ខវេ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស[១] យាវជីវំ សរណីយានិ ភវន្តិ ។ កតមានិ តីណិ ។ យស្មឹ ភិក្ខវេ បទេសេ រាជា ខត្តិយោ មុទ្ធាភិសិត្តោ[២] ជាតោ ហោតិ ឥទំ ភិក្ខវេ បឋមំ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស យាវជីវំ សរណីយំ ហោតិ ។ បុន ចបរំ ភិក្ខវេ យស្មឹ បទេសេ រាជា ខត្តិយោ មុទ្ធាភិសិត្តោ ហោតិ ឥទំ ភិក្ខវេ ទុតិយំ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស យាវជីវំ សរណីយំ ហោតិ ។ បុន ចបរំ ភិក្ខវេ យស្មឹ បទេសេ រាជា ខត្តិយោ មុទ្ធាភិសិត្តោ សង្គាមំ អភិវិជិនិត្វា វិជិតសង្គាមោ តមេវ សង្គាមសីសំ អជ្ឈាវសតិ

---

១ ឱ. មុទ្ធាវសិត្តស្ស ។ ២ មុទ្ធាវសិត្តោ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានកេរ្តិ៍ឈ្មោះ ប្រកបដោយធម៌ ៣ យ៉ាងនេះឯង ជាអ្នកប្រតិបត្តិ ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីជាប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតានិងមនុស្សទាំងឡាយ ។

[១២] ម្នាលភិក្ខុទាំងឡាយ ហេតុទាំងឡាយដែលព្រះរាជា ជាក្សត្រិយ៍បានមុទ្ធាភិសេកហើយ នៅតែរលឹកចាំបានរហូតដល់អស់ព្រះជន្មនេះ មាន ៣ យ៉ាង ។ ហេតុ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេក ទ្រង់ព្រះសម្ភពក្នុងប្រទេសណា នេះជាហេតុទី ១ ដែលព្រះរាជា ជាក្សត្រិយ៍បានមុទ្ធាភិសេកហើយ នៅតែរលឹកចាំបានរហូតដល់អស់ព្រះជន្ម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះរាជា ជាក្សត្រិយ៍បានមុទ្ធាភិសេក ក្នុងប្រទេសណា នេះជាហេតុទី ២ ដែលព្រះរាជា ជាក្សត្រិយ៍បានមុទ្ធាភិសេកហើយ នៅតែរលឹកចាំបានរហូតដល់អស់ព្រះជន្ម ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះរាជាជាក្សត្រិយ៍ ដែលបានមុទ្ធាភិសេកហើយ ទ្រង់ផ្ចាញ់សង្គ្រាម បានឈ្នះសង្គ្រាមហើយ ទ្រង់គ្រប់គ្រងទីសង្គ្រាមនោះឯង ក្នុងប្រទេសណា

ឥទំ ភិក្ខវេ តតិយំ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស យាវជីវំ សរណីយំ ហោតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស យាវជីវំ សរណីយានិ ភវន្តិ ។ ឯវមេវ ខោ ភិក្ខវេ តីណីមានិ ភិក្ខុស្ស យាវជីវំ សរណីយានិ ភវន្តិ ។ កតមានិ តីណិ ។ យស្មឹ ភិក្ខវេ បទេសេ ភិក្ខុ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោ ហោតិ ឥទំ ភិក្ខវេ បឋមំ ភិក្ខុស្ស យាវជីវំ សរណីយំ ហោតិ ។ បុន ចបរំ ភិក្ខវេ យស្មឹ បទេសេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនីបដិបទាតិ យថាភូតំ បជានាតិ ឥទំ ភិក្ខវេ ទុតិយំ ភិក្ខុស្ស យាវជីវំ សរណីយំ ហោតិ ។ បុន ចបរំ ភិក្ខវេ យស្មឹ បទេសេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ

នេះជាហេតុទី ៣ ដែលព្រះរាជា ជាក្សត្រិយ៍បានមុទ្ធាភិសេកហើយ នៅតែរលឹកចាំបានរហូតដល់អស់ព្រះជន្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ នេះឯង ដែលព្រះរាជា ជាក្សត្រិយ៍បានមុទ្ធាភិសេកហើយ នៅតែរលឹកចាំបានរហូតដល់អស់ព្រះជន្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំងឡាយដែលភិក្ខុគួររលឹករហូតដល់អស់ជីវិត ឲ្យដូចជាព្រះមហាក្សត្រិយ៍នោះ នេះមាន ៣ យ៉ាង ។ ហេតុ ៣ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកោរសក់កោរពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះចូលកាន់ផ្នួស ក្នុងប្រទេសណា ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ១ ដែលភិក្ខុគួររលឹករហូតដល់អស់ជីវិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុដឹងច្បាស់តាមពិតថា នេះទុក្ខ ដឹងច្បាស់តាមពិតថា នេះហេតុឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះធម៌ជាគ្រឿងរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់សេចក្ដីរលត់ទុក្ខ ក្នុងប្រទេសណា ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ២ ដែលភិក្ខុគួររលឹករហូតដល់អស់ជីវិត ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុបានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញារបស់ខ្លួនឯងនាបច្ចុប្បន្ន ក្នុងប្រទេសណា

ឥទំ ភិក្ខវេ តតិយំ ភិក្ខុស្ស យាវជីវំ សរណីយំ ហោតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ ភិក្ខុស្ស យាវជីវំ សរណីយានិ ភវន្តីតិ ។

[១៣] តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ និរាសោ អាសំសោ វិគតាសោ ។ កតមោ ច ភិក្ខវេ បុគ្គលោ និរាសោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ នីចេ កុលេ បច្ចាជាតោ ហោតិ ចណ្ឌាលកុលេ វា វេណកុលេ វា នេសាទកុលេ វា រថការកុលេ វា បុក្កុសកុលេ វា ទលិទ្ទេ អប្បន្នបានភោជនេ កសិរវុត្តិកេ យត្ថ កសិរេន ឃាសច្ឆាទោ លព្ភតិ ។ សោ ច ហោតិ ទុព្វណ្ណោ ទុទ្ទសិកោ ឱកោដិមកោ ពហ្វាពាធោ កាណោ វា កុណី វា ខញ្ជោ វា បក្ខហតោ វា ន លាភី អន្នស្ស បានស្ស វត្ថស្ស យានស្ស មាលាគន្ធវិលេបនស្ស សេយ្យាវសថប្បទីបេយ្យស្ស ។

ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៣ ដែលភិក្ខុគួររលឹករហូតដល់អស់ជីវិត ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះឯង ដែលភិក្ខុគួរតែរលឹកចាំបានរហូតដល់អស់ជីវិត ។

[១៣] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ មានប្រាកដក្នុងលោក ។ បុគ្គល ៣ ពួកតើដូចម្ដេច ។ គឺបុគ្គលមិនមានសេចក្ដីប្រាថ្នា ១ មានសេចក្ដីប្រាថ្នា ១ ប្រាសចាកសេចក្ដីប្រាថ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានសេចក្ដីប្រាថ្នា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកកើតក្នុងត្រកូលទាប គឺត្រកូលចណ្ឌាល ត្រកូលអ្នកត្បាញផែង ត្រកូលអ្នកនេសាទ ត្រកូលអ្នកធ្វើរថ ត្រកូលអ្នកចោលសម្រាម ឬ ត្រកូលអ្នកកម្សត់ដែលមានបាយនិងទឹកនិងភោជនតិច ប្រព្រឹត្តចិញ្ចឹមជីវិតលំបាក ជាត្រកូលដែលរកអាហារសម្រាប់បរិភោគនិងសំពត់សម្រាប់ស្លៀកដណ្ដប់ បានដោយលំបាក ។ បុគ្គលនោះសោតមានសម្បុរអាក្រក់ អ្នកផងមិនចង់ពិតពិលរមិលមើល ជាមនុស្សតឿ មានជំងឺច្រើន ខ្វាក់ម្ខាង ក្ញែង ខ្ចក ឬមានអវយវៈម្ខាងពិការ ជាអ្នកមិនបានបាយទឹកសំពត់យានផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក លំនៅ និងគ្រឿងប្រទីប ។

១៧



សោ សុណាតិ ឥត្ថន្នាមោ កិរ ខត្តិយោ ខត្តិយេហិ ខត្តិយាភិសេកេន អភិសិត្តោតិ ។ តស្ស ន ឯវំ ហោតិ កទាស្សុ[១] នាម មំបិ ខត្តិយា ខត្តិយាភិសេកេន អភិសិញ្ចិស្សន្តីតិ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ និរាសោ ។ កតមោ ច ភិក្ខវេ បុគ្គលោ អាសំសោ ។ ឥធ ភិក្ខវេ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស ជេដ្ឋោ បុត្តោ ហោតិ អភិសេកេន[២] អនភិសិត្តោ អចលប្បត្តោ[៣] ។ សោ សុណាតិ ឥត្ថន្នាមោ កិរ ខត្តិយោ ខត្តិយេហិ ខត្តិយាភិសេកេន អភិសិត្តោតិ ។ តស្ស ឯវំ ហោតិ កទាស្សុ នាម មំបិ ខត្តិយា ខត្តិយាភិសេកេន អភិសិញ្ចិស្សន្តីតិ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ អាសំសោ ។ កតមោ ច ភិក្ខវេ បុគ្គលោ វិគតាសោ ។ ឥធ ភិក្ខវេ រាជា ហោតិ ខត្តិយោ មុទ្ធាភិសិត្តោ ។ សោ សុណាតិ ឥត្ថន្នាមោ កិរ ខត្តិយោ ខត្តិយេហិ ខត្តិយាភិសេកេន អភិសិត្តោតិ ។ តស្ស ន ឯវំ ហោតិ

១ ឱ. កុទស្សុ ។ ម. កុទាស្សុ ។ ២ ឱ. ម. អភិសេកោ ។ ៣ ឱ. មចលបត្តោ ។ ឥទដ្ឋកថាយម្បិ ឦទិសោយេវ ។

បុគ្គលនោះ ឮដំណឹងថា ក្សត្រិយ៍ទ្រង់ព្រះនាមនេះ ពួកក្សត្រិយ៍បានអភិសេកដោយខត្តិយាភិសេកហើយ ។ បុគ្គលនោះ រមែងមិនត្រិះរិះយ៉ាងនេះថា កាលណាហ្ន៎ ពួកក្សត្រិយ៍នឹងអភិសេកអញដោយខត្តិយាភិសេកផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមិនមានសេចក្តីប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសេចក្តីប្រាថ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ព្រះរាជបុត្រច្បង របស់ខត្តិយរាជ ដែលបានមុទ្ធាភិសេកហើយ ជារាជកុមារដែលគេមិនទាន់អភិសេក ដោយរាជាភិសេកនៅឡើយទេ តែព្រះរាជកុមារមិនមានញាប់ញ័រ (ចង់បាន) ។ ព្រះរាជបុត្រនោះ ឮដំណឹងថា ព្រះខត្តិយរាជព្រះនាមនេះ ពួកក្សត្រិយ៍បានអភិសេក ដោយខត្តិយាភិសេកហើយ ។ ព្រះរាជបុត្រនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលណាហ្ន៎ ពួកក្សត្រិយ៍នឹងអភិសេកអញ ដោយខត្តិយាភិសេកផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានសេចក្តីប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលប្រាសចាកសេចក្តីប្រាថ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ខត្តិយរាជក្នុងលោកនេះ បានមុទ្ធាភិសេកហើយ ។ ព្រះរាជាអង្គនោះ ឮដំណឹងថា ខត្តិយរាជព្រះនាមនេះ ពួកក្សត្រិយ៍បានអភិសេក ដោយខត្តិយា-ភិសេកហើយ ។ ព្រះរាជាអង្គនោះ មិនមានព្រះរាជតម្រិះយ៉ាងនេះថា

កទាស្សុ នាម មំបិ ខត្តិយា ខត្តិយាភិសេកេន អភិសិញ្ចិស្សន្តីតិ ។ តំ កិស្ស ហេតុ ។ យា ហិស្ស ភិក្ខវេ បុព្វេ អនភិសិត្តស្ស អភិសេកាសា សាស្ស បដិប្បស្សទ្ធា ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ វិគតាសោ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឯវមេវ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា ភិក្ខូសុ ។ កតមេ តយោ ។ និរាសោ អាសំសោ វិគតាសោ ។ កតមោ ច ភិក្ខវេ បុគ្គលោ និរាសោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ទុស្សីលោ ហោតិ បាបធម្មោ អសុចិ សង្កស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្សមណោ សមណប្បដិញ្ញោ អព្រហ្មចារី ព្រហ្មចារិប្បដិញ្ញោ អន្តោបូតិ អវស្សុតោ កសម្ពុជាតោ ។

កាលណាហ្ន៎ ពួកក្សត្រិយ៍នឹងអភិសេកអញ ដោយខត្តិយាភិសេកផង ។ ដំណើរនោះ តើព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះសេចក្តីប៉ុនប៉ងក្នុងរាជាភិសេកណារបស់ព្រះរាជា ដែលមិនទាន់អភិសេកក្នុងកាលមុននោះ សេចក្តីប៉ុនប៉ងក្នុងរាជាភិសេក របស់ព្រះរាជាអង្គនោះៗ បានស្ងប់ព្រះរាជហឫទ័យហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលប្រាសចាកសេចក្តីប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះឯង មានប្រាកដក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកមានប្រាកដក្នុងពួកភិក្ខុ ក៏យ៉ាងនោះដែរ ។ បុគ្គល ៣ ពួក តើដូចម្តេច ។ គឺបុគ្គលមិនមានសេចក្តីប្រាថ្នា ១ មានសេចក្តីប្រាថ្នា ១ ប្រាសចាកសេចក្តីប្រា-ថ្នា ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនមានសេចក្តីប្រាថ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានអំពើមិនល្អ មានមារយាទគួរឲ្យអ្នកផងរង្កៀស ជាអ្នកបិទបាំងបាបកម្មទុក មិនមែនជាសមណៈ តែប្តេជ្ញាខ្លួនថាជាសមណៈ មិនប្រព្រឹត្តព្រហ្មចារ្យ តែប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តព្រហ្មចារ្យ ជាអ្នកស្អុយខាងក្នុង មានចិត្តទទឹកដោយរាគៈ មានជាតិដ៏ជ្រោកជ្រាក ។

សោ សុណាតិ ឥត្ថន្នាមោ កិរ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ តស្ស ន ឯវំ ហោតិ កទាស្សុ នាម អហម្បិ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សាមីតិ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ និរាសោ ។ កតមោ ច ភិក្ខវេ បុគ្គលោ អាសំសោ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ កល្យាណធម្មោ ។ សោ សុណាតិ ឥត្ថន្នាមោ កិរ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោ-វិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ តស្ស ឯវំ ហោតិ កទាស្សុ នាម អហម្បិ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ

បុគ្គលនោះ ពុងដំណឹងថា ភិក្ខុឈ្មោះនេះ ធ្វើឲ្យជាក់ច្បាស់ បានដល់ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ន ។ បុគ្គលនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលណាហ្ន៎ អាត្មាអញនឹងធ្វើឲ្យជាក់ច្បាស់ បានដល់ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯងនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ននេះផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមិនមានសេចក្តីប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានប្រាថ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះជាអ្នកមានសីល មានធម៌ល្អ ។ ភិក្ខុនោះ ពុងដំណឹងថា ភិក្ខុឈ្មោះនេះ បានធ្វើឲ្យជាក់ច្បាស់ បានដល់ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ន ។ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលណាហ្ន៎ អាត្មាអញនឹងធ្វើឲ្យជាក់ច្បាស់ បានដល់ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង នូវចេតោវិមុត្តិ

បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សាមីតិ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ អាសំសោ ។ កតមោ ច ភិក្ខវេ បុគ្គលោ វិគតាសោ ។ ឥធ ភិក្ខវេ ភិក្ខុ អរហំ ហោតិ ខីណាសវោ ។ សោ សុណាតិ ឥត្ថន្នាមោ កិរ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតីតិ ។ តស្ស ន ឯវំ ហោតិ កទាស្សុ នាម អហម្បិ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សាមីតិ ។ តំ កិស្ស ហេតុ ។ យា ហិស្ស ភិក្ខវេ បុព្វេ អវិមុត្តស្ស វិមុត្តាសា សាស្ស បដិប្បស្សទ្ធា ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ វិគតាសោ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា ភិក្ខូសូតិ ។

បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានសេចក្តីប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រាសចាកសេចក្តីប្រាថ្នា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអរហន្តខីណាស្រព ។ ភិក្ខុនោះឮដំណឹងថា ភិក្ខុឈ្មោះនេះ បានធ្វើឲ្យជាក់ច្បាស់បានដល់ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ក្នុងបច្ចុប្បន្ន ។ ភិក្ខុនោះមិនមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលណាហ្ន៎ អាត្មាអញនឹងធ្វើឲ្យជាក់ច្បាស់បានដល់ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ក្នុងបច្ចុប្បន្នផង ។ ដំណើរនោះ តើព្រោះហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ព្រោះសេចក្តីប៉ុនប៉ងនូវវិមុត្តិណារបស់ភិក្ខុ ដែលមិនទាន់មានវិមុត្តិក្នុងកាលមុន សេចក្តីប៉ុនប៉ងនូវវិមុត្តិរបស់ភិក្ខុនោះៗ បានស្ងប់ស្ងាត់ចិត្តហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលប្រាសចាកសេចក្តីប្រាថ្នា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៣ នេះឯង មានប្រាកដក្នុងពួកភិក្ខុ ។

[១៤] យោបិ សោ ភិក្ខវេ រាជា ចក្កវត្តី ធម្មិកោ ធម្មរាជា សោបិ នាម អរាជកំ ចក្កំ បវត្តេតីតិ[១] ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច កោ បន ភន្តេ រញ្ញោ ចក្កវត្តិស្ស ធម្មិកស្ស ធម្មរញ្ញោ រាជាតិ[២] ។ ធម្មោ ភិក្ខូតិ ភគវា អវោច ឥធ ភិក្ខុ រាជា ចក្កវត្តី ធម្មិកោ ធម្មរាជា ធម្មំយេវ និស្សាយ ធម្មំ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ អបចាយមានោ ធម្មទ្ធជោ ធម្មកេតុ ធម្មាធិបតេយ្យោ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហតិ អន្តោជនស្មឹ ។ បុន ចបរំ ភិក្ខុ រាជា ចក្កវត្តី ធម្មិកោ ធម្មរាជា ធម្មំយេវ និស្សាយ ធម្មំ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ អបចាយមានោ ធម្មទ្ធជោ

១ ម. សោបិ រាជា តំ ចក្កំ បវត្តេតីតិ ។ ២ ម. ធម្មរញ្ញោ ចក្កន្តិ ។

[១៤] ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិអង្គណា ប្រកបដោយធម៌[១] ទ្រង់ធម៌[២] ស្តេចអង្គនោះ ទ្រង់ញុំាងចក្រដែលមិនមែនជារបស់ស្តេចឲ្យប្រព្រឹត្តទៅ ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះ មានភិក្ខុ ១ រូប ក្រាបទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ចក្ររបស់ស្តេចចក្រពត្តិ ប្រកបដោយធម៌ ទ្រង់ធម៌ តើដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់តបថា ម្នាលភិក្ខុ ចក្រនោះក៏គឺ ធម៌[៣] ដូច្នេះ រួចទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ ក្នុងលោកនេះ ស្តេចចក្រពត្តិ ប្រកបដោយធម៌ ទ្រង់ធម៌ ទ្រង់អាស្រ័យធម៌តែមួយយ៉ាង ធ្វើសក្ការៈចំពោះធម៌ គោរពធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាទង់យស យកធម៌ជាអធិបតី ចាត់ចែងនូវការរក្សាទប់ទល់គ្រប់គ្រងប្រកបដោយធម៌ ចំពោះជនខាងក្នុង ម្នាលភិក្ខុ មួយទៀត ស្តេចចក្រពត្តិ ប្រកបដោយធម៌ ទ្រង់ធម៌ ទ្រង់អាស្រ័យធម៌ តែមួយយ៉ាង ធ្វើសក្ការៈចំពោះធម៌ គោរពធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ

---

១ ប្រកបដោយកុសលកម្មបថទាំង ១០ ។ ២ ញុំាងមហាជនឲ្យត្រេកអរដោយកុសលកម្មបថ ១០ ។ ៣ សំដៅយកកុសលកម្មបថ ។ អដ្ឋកថា ។

ធម្មកេតុ ធម្មាធិបតេយ្យោ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហតិ ខត្តិយេសុ អនុយន្តេសុ ពលកាយស្មឹ ព្រាហ្មណគហបតិកេសុ នេគមជានបទេសុ សមណ-ព្រាហ្មណេសុ មិគបក្ខីសុ ។ ស ខោ សោ ភិក្ខុ រាជា ចក្កវត្តី ធម្មិកោ ធម្មរាជា ធម្មំយេវ និស្សាយ ធម្មំ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ អបចាយមានោ ធម្មទ្ធជោ ធម្មកេតុ ធម្មាធិបតេយ្យោ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហិត្វា អន្តោជនស្មឹ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហិត្វា ខត្តិយេសុ អនុយន្តេសុ ពលកាយស្មឹ ព្រាហ្មណគហបតិកេសុ នេគមជានបទេសុ សមណ-ព្រាហ្មណេសុ មិគបក្ខីសុ ធម្មេនេវ ចក្កំ បវត្តេតិ ។ តំ ហោតិ ចក្កំ អប្បដិវត្តិយំ កេនចិ មនុស្ស-ភូតេន បច្ចត្ថិកេន បាណិនា ។ ឯវមេវ ខោ ភិក្ខុ តថាគតោ អរហំ សម្មាសម្ពុទ្ធោ ធម្មិកោ ធម្មរាជា ធម្មំយេវ និស្សាយ ធម្មំ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ អបចាយមានោ

យកធម៌ជាទង់យស យកធម៌ជាអធិបតី ចាត់ចែងនូវការរក្សាទប់ទល់ គ្រប់គ្រងប្រកបដោយធម៌ ចំពោះពួកក្សត្រិយ៍ អ្នកចុះចូល ពួកពល ពួកព្រាហ្មណ៍គហបតី ពួកអ្នកនិគម អ្នកជនបទ ពួកសមណព្រាហ្មណ៍ និងពួកម្រឹគបក្សី ។ ម្នាលភិក្ខុ លុះស្តេចចក្រពត្តិ ប្រកបដោយធម៌ ទ្រង់ធម៌ អង្គនោះឯង អាស្រ័យធម៌តែមួយយ៉ាង ធ្វើសក្ការៈចំពោះធម៌ គោរពធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាទង់យស យកធម៌ជាអធិបតី ចាត់ចែងនូវការរក្សាទប់ទល់ គ្រប់គ្រងប្រកបដោយធម៌ ចំពោះជនខាងក្នុង ចាត់ចែងនូវការរក្សាទប់ទល់ គ្រប់គ្រងប្រកបដោយធម៌ ចំពោះពួកក្សត្រិយ៍ អ្នកចុះចូល ពួកពល ពួកព្រាហ្មណ៍គហ-បតី ពួកអ្នកនិគម ជនបទ ពួកសមណព្រាហ្មណ៍ និងពួកម្រឹគបក្សី ទើបញ៉ាំងចក្រឲ្យប្រព្រឹត្តតាមធម៌កើត ។ ចក្រនោះ មនុស្សណាមួយ ជាសត្រូវធ្វើបដិវត្តដោយដៃពុំបានឡើយ ។ ម្នាលភិក្ខុ សេចក្តីនេះ មានដូចជាព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ប្រកបដោយធម៌[១] ទ្រង់ធម៌[២] អាស្រ័យធម៌តែមួយយ៉ាង ធ្វើសក្ការៈចំពោះធម៌ គោរពធម៌ កោតក្រែងធម៌

---

១ ប្រកបដោយនវលោកុត្តរធម៌ ។ ២ ព្រះអង្គញ៉ាំងមហាជនឲ្យរីករាយ ដោយនវលោកុត្តរធម៌ ។ អដ្ឋកថា ។

២៣

បឋមបណ្ណាសកេ រថការវគ្គោ

ធម្មទ្ធជោ ធម្មកេតុ ធម្មាធិបតេយ្យោ ធម្មិកំ រក្ខាវ-រណគុត្តឹ សំវិទហតិ កាយកម្មស្មឹ ឯវរូបំ កាយកម្មំ សេវិតព្វំ ឯវរូបំ កាយកម្មំ ន សេវិតព្វន្តិ ។ បុន ចបរំ ភិក្ខុ តថាគតោ អរហំ សម្មា-សម្ពុទ្ធោ ធម្មិកោ ធម្មរាជា ធម្មំយេវ និស្សាយ ធម្មំ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ អបចាយមានោ ធម្មទ្ធជោ ធម្មកេតុ ធម្មាធិប-តេយ្យោ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហតិ វចីកម្មស្មឹ ឯវរូបំ វចីកម្មំ សេវិតព្វំ ឯវរូបំ វចីកម្មំ ន សេវិតព្វន្តិ ។ បុន ចបរំ ភិក្ខុ តថាគតោ អរហំ សម្មាសម្ពុទ្ធោ ធម្មិកោ ធម្មរាជា ធម្មំយេវ និស្សាយ ធម្មំ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ អបចាយមានោ ធម្មទ្ធជោ ធម្មកេតុ ធម្មាធិបតេយ្យោ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហតិ មនោកម្មស្មឹ ឯវរូបំ មនោកម្មំ សេវិតព្វំ ឯវរូបំ មនោកម្មំ ន សេវិតព្វន្តិ ។ ស ខោ សោ ភិក្ខុ តថាគតោ

យកធម៌ជាទង់ជ័យ យកធម៌ជាទង់យស យកធម៌ជាអធិបតី ចាត់ចែងនូវការរក្សាទប់ទល់ គ្រប់គ្រងប្រកបដោយធម៌ ចំពោះកាយកម្មថា កាយកម្មបែបនេះគួរសេព កាយកម្មបែបនេះមិនគួរសេពឡើយ ។ ម្នាលភិក្ខុ មួយទៀត ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ប្រកបដោយធម៌ ទ្រង់ធម៌អាស្រ័យធម៌តែមួយយ៉ាង ធ្វើសក្ការៈ ចំពោះធម៌ គោរពធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាទង់យស យកធម៌ជាអធិបតី ចាត់ចែងនូវការរក្សាទប់ទល់ គ្រប់គ្រងប្រកបដោយធម៌ ចំពោះវចីកម្មថា វចីកម្មបែបនេះគួរសេព វចីកម្មបែបនេះមិនគួរសេពឡើយ ។ ម្នាលភិក្ខុ មួយទៀត ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ប្រកបដោយធម៌ ទ្រង់ធម៌ អាស្រ័យធម៌តែមួយយ៉ាង ធ្វើសក្ការៈចំពោះធម៌ គោរពធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាទង់យស យកធម៌ជាអធិបតី ចាត់ចែងនូវការរក្សាទប់ទល់ គ្រប់គ្រងប្រកបដោយធម៌ ចំពោះមនោកម្មថា មនោកម្មបែបនេះគួរសេព មនោកម្មបែបនេះ មិនគួរសេពឡើយ ។ ម្នាលភិក្ខុ ព្រះតថាគតនោះឯង

អរហំ សម្មាសម្ពុទ្ធោ ធម្មិកោ ធម្មរាជា ធម្មំយេវ និស្សាយ ធម្មំ សក្ករោន្តោ ធម្មំ គរុករោន្តោ ធម្មំ អបចាយមានោ ធម្មទ្ធជោ ធម្មកេតុ ធម្មាធិបតេយ្យោ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហិត្វា កាយកម្មស្មឹ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហិត្វា វចីកម្មស្មឹ ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហិត្វា មនោកម្មស្មឹ ធម្មេនេវ អនុត្តរំ ធម្មចក្កំ បវត្តេតិ ។ តំ ហោតិ ចក្កំ អប្បដិវត្តិយំ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ ។

[១៤] ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ភូតបុព្វំ ភិក្ខវេ រាជា អហោសិ បចេតនោ[១] នាម ។ អថខោ ភិក្ខវេ រាជា បចេតនោ រថការំ អាមន្តេសិ

១ ម. សចេតនោ ។

ជាអរហន្តសម្មាសម្ពុទ្ធ ប្រកបដោយធម៌ ទ្រង់ធម៌ អាស្រ័យនូវធម៌តែមួយយ៉ាង ធ្វើសក្ការៈចំពោះធម៌ គោរពធម៌ កោតក្រែងធម៌ យកធម៌ជាទង់ជ័យ យកធម៌ជាទង់យស យកធម៌ជាអធិបតី ចាត់ចែងនូវការរក្សាទប់ទល់គ្រប់គ្រងប្រកបដោយធម៌ ចំពោះកាយកម្ម ចាត់ចែងនូវការរក្សាទប់ទល់គ្រប់គ្រងប្រកបដោយធម៌ ចំពោះវចីកម្ម ចាត់ចែងនូវការរក្សាទប់ទល់គ្រប់គ្រងប្រកបដោយធម៌ ចំពោះមនោកម្ម ញុំាងធម្មចក្រដ៏ប្រសើរឲ្យប្រព្រឹត្តទៅ តាមធម៌នុ៎ះឯង ។ ចក្កនោះសមណៈឬព្រាហ្មណ៍ ទេវតាមារព្រហ្មឬអ្នកណាមួយក្នុងលោក ធ្វើបដិវត្តពុំបានឡើយ ។

[១៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគបានត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលតបព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះដ៏មានព្រះភាគត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយមក មានព្រះរាជា ១ ព្រះអង្គ ព្រះនាមបចេតនៈ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ព្រះបាទបចេតនៈ ទ្រង់ត្រាស់ទៅនឹងជាងរថម្នាក់ថា

២៨

បឋមបណ្ណាសកេ រថការវគ្គោ

ឥតោ មេ សម្ម រថការ ឆន្នំ មាសានំ អច្ចយេន សង្គាមោ ភវិស្សតិ សក្ខសិ មេ សម្ម រថការ នវំ ចក្កយុគំ កាតុន្តិ ។ សក្កោមិ ទេវាតិ ខោ ភិក្ខវេ រថការោ រញ្ញោ បចេតនស្ស បច្ចស្សោសិ ។ អថខោ ភិក្ខវេ រថការោ ឆហិ មាសេហិ ឆារត្តូនេហិ ឯកំ ចក្កំ និដ្ឋាបេសិ ។ អថខោ ភិក្ខវេ រាជា បចេតនោ រថការំ អាមន្តេសិ ឥតោ មេ សម្ម រថការ ឆន្នំ ទិវសានំ អច្ចយេន សង្គាមោ ភវិស្សតិ និដ្ឋិតំ នវំ ចក្កយុគន្តិ ។ ឥមេហិ ខោ ទេវ ឆហិ មាសេហិ ឆារត្តូនេហិ ឯកំ ចក្កំ និដ្ឋិតន្តិ ។ សក្ខសិ បន មេ សម្ម រថការ ឥមេហិ ឆហិ ទិវសេហិ ទុតិយំ ចក្កំ និដ្ឋាបេតុន្តិ ។ សក្កោមិ ទេវាតិ ខោ ភិក្ខវេ រថការោ រញ្ញោ បចេតនស្ស បច្ចស្សោសិ ។ អថខោ ភិក្ខវេ រថការោ ឆហិ ទិវសេហិ ទុតិយំ ចក្កំ និដ្ឋាបេត្វា នវំ ចក្កយុគំ អាទាយ យេន រាជា បចេតនោ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ បចេតនំ ឯតទវោច

ម្នាលជាងរថជាសម្លាញ់ អំណឹះទៅ ៦ ខែអំពីខែនេះ យើងនឹងមានសង្គ្រាម ម្នាលជាងរថសម្លាញ់ អ្នកអាចធ្វើចក្រ ១ គូយ៉ាងថ្មីឲ្យយើងបានឬទេ ។ ម្នាលភិក្ខុទាំងឡាយ ជាងរថបានក្រាបបង្គំទូលតបព្រះបាទបចេតនៈថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គអាចធ្វើបាន ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ជាងរថធ្វើចក្រឲ្យសម្រេចបានតែម្ខាង ក្នុងវេលា ៦ ខែខ្វះ ៦ រាត្រី ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រះបាទបចេតនៈ ទ្រង់ត្រាស់ប្រាប់ជាងធ្វើរថថា ម្នាលជាងរថសម្លាញ់ កន្លងទៅ ៦ ថ្ងៃអំពីថ្ងៃនេះ យើងនឹងមានសង្គ្រាម ចក្រ ១ គូយ៉ាងថ្មី អ្នកធ្វើសម្រេចហើយឬ ។ សូមទ្រង់ព្រះមេត្តាប្រោស ធ្វើអស់ ៦ ខែខ្វះ ៦ រាត្រីនេះឯង ហើយបានតែចក្រម្ខាង ។ ម្នាលជាងរថសម្លាញ់ ចុះអ្នកអាចធ្វើចក្រ ទី ២ ឲ្យសម្រេចត្រឹមតែ ៦ ថ្ងៃនេះបានឬទេ ។ ម្នាលភិក្ខុទាំងឡាយ ជាងរថបានទទួលតបព្រះឱង្ការព្រះបាទបចេតនៈថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គអាចធ្វើបាន ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ជាងរថធ្វើចក្រទី ២ ឲ្យសម្រេចត្រឹមតែ ៦ ថ្ងៃ រួចនាំយកចក្រទាំង ១ គូយ៉ាងថ្មី (នោះ) ចូលទៅគាល់ព្រះបាទបចេតនៈ លុះចូលទៅដល់ហើយ ទើបក្រាបបង្គំទូលព្រះបាទបចេតនៈ យ៉ាងនេះថា

ឥទន្តេ នេវ នវំ ចក្កយុគំ និដ្ឋិតន្តិ ។ យញ្ច តេ ឥទំ សម្ម រថការ ចក្កំ ឆហិ មាសេហិ និដ្ឋិតំ ឆារត្តូនេហិ យញ្ច តេ ឥទំ ចក្កំ ឆហិ ទិវសេហិ និដ្ឋិតំ ឥមេសំ កឹ នានាករណំ នេសំ កិញ្ចិ(១) នានាករណំ បស្សាមីតិ ។ អត្ថេសំ(២) ទេវ នានា-ករណំ បស្សតុ ទេវោ នានាករណន្តិ ។ អថខោ ភិក្ខវេ រថការោ យំ តំ ចក្កំ ឆហិ ទិវសេហិ និដ្ឋិតំ តំ បវត្តេសិ ។ តំ បវត្តិតំ សមានំ យាវតិកា អភិសង្ខារស្ស គតិ តាវតិកំ គន្ត្វា ចិង្គុលាយិត្វា ភូមិយំ បបតិ ។ យំ បន តំ ចក្កំ ឆហិ មាសេហិ និដ្ឋិតំ ឆារត្តូនេហិ តំ បវត្តេសិ ។ តំ បវត្តិតំ សមានំ យាវតិកា អភិសង្ខារស្ស គតិ តាវតិកំ គន្ត្វា អក្ខាហតំ មញ្ញេ អដ្ឋាសិ ។ កោ នុ ខោ សម្ម រថការ ហេតុ កោ បច្ចយោ

១ ឱ. នេសំ នាហំ កិញ្ចិ ។ ម. នេសំ អហំ កិញ្ចិ ។ ២ ឱ. អត្ថិ នេសំ ។

សូមទ្រង់ព្រះមេត្តាប្រោស នេះហើយចក្រ ១ គូយ៉ាងថ្មីរបស់ព្រះករុណាខ្ញុំព្រះអង្គធ្វើសម្រេចហើយ ។ ព្រះបាទបចេតនៈទ្រង់ត្រាស់សួរថា អើជាងរថសម្លាញ់ ចក្រណាដែលអ្នកធ្វើឲ្យសម្រេចអស់ ៦ ខែ ខ្វះ ៦ រាត្រីក្តី ចក្រណាដែលអ្នកធ្វើឲ្យសម្រេចត្រឹមតែ ៦ ថ្ងៃក្តី ចក្រទាំង ២ នេះ មានដំណើរផ្សេងគ្នាដូចម្តេច យើងមិនទាន់យល់ការណ៍ផ្សេងគ្នានៃចក្រទាំង ២ នុ៎ះ ថាដូចម្តេចឡើយ ។ បពិត្រព្រះសម្មតិទេព ការណ៍ផ្សេងគ្នានៃចក្រទាំង ២ នុ៎ះមាន សូមទ្រង់ចាំទតការណ៍ផ្សេងគ្នា (នោះ) ចុះ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ជាងរថបង្វិលចក្រដែលធ្វើឲ្យសម្រេចអស់ត្រឹមតែ ៦ ថ្ងៃឲ្យវិលទៅ ។ កាលចក្រនោះវិលទៅក៏ទៅកាន់ទីអស់កំណត់ត្រឹមតែមួយវិលប៉ុណ្ណោះ ហើយត្រឡប់ដួលលើផែនដី ។ រួចទើបជាងរថបង្វិលចក្រដែលធ្វើឲ្យសម្រេចអស់ ៦ ខែ ខ្វះ ៦ រាត្រី ឲ្យវិលទៅម្តងទៀត ។ កាលចក្រនោះវិលទៅ ក៏ទៅកាន់ទីអស់កំណត់ត្រឹមតែមួយកម្លាំងបង្វិលប៉ុណ្ណោះ ហើយក៏នៅនឹងថ្កល់ហាក់ដូចជាខ្ចាស់ត្រង់ភ្ជៅ ។ ព្រះបាទបចេ-តនៈត្រាស់សួរថា ម្នាលជាងរថសម្លាញ់ ចុះហេតុដូចម្តេច បច្ច័យដូចម្តេច

២៧



យមិទំ ចក្កំ ឆហិ ទិវសេហិ និដ្ឋិតំ តំ បវត្តិតំ សមានំ យាវតិកា អភិសង្ខារស្ស គតិ តាវតិកំ គន្ត្វា ចិង្គុលាយិត្វា ភូមិយំ បបតិ ។ កោ បន សម្ម រថការ ហេតុ កោ បច្ចយោ យមិទំ ចក្កំ ឆហិ មាសេហិ និដ្ឋិតំ ឆារត្តូនេហិ តំ បវត្តិតំ សមានំ យាវតិកា អភិ-សង្ខារស្ស គតិ តាវតិកំ គន្ត្វា អក្ខាហតំ មញ្ញេ អដ្ឋាសីតិ ។ យមិទំ ទេវ ចក្កំ ឆហិ ទិវសេហិ និដ្ឋិតំ តស្ស នេមិបិ សវង្កា សទោសា សកសាវា អរាបិ សវង្កា សទោសា សកសាវា នាភិបិ សវង្កា សទោសា សកសាវា ។ តំ នេមិយាបិ សវង្កត្តា សទោសត្តា សកសាវត្តា អរានំបិ សវង្កត្តា សទោសត្តា សកសាវត្តា នាភិយាបិ សវង្កត្តា សទោសត្តា សកសាវត្តា បវត្តិតំ សមានំ យាវតិកា អភិសង្ខារស្ស គតិ តាវតិកំ គន្ត្វា ចិង្គុលាយិត្វា ភូមិយំ បបតិ ។

បានជាចក្រណា ដែលអ្នកធ្វើឲ្យសម្រេចត្រឹមតែ ៦ ថ្ងៃ ចក្រនោះដែលអ្នកបង្វិលទៅ ក៏ទៅកាន់ទីអស់កំណាត់ត្រឹមតែមួយវិលប៉ុណ្ណោះ ហើយត្រឡប់ដួលចុះលើផែនដី ។ ម្នាលជាងរថសម្លាញ់ ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាចក្រណា ដែលអ្នកធ្វើឲ្យសម្រេចអស់ ៦ ខែ ខ្វះ ៦ រាត្រី ចក្រនោះដែលអ្នកបង្វិលទៅ ក៏ទៅកាន់ទីអស់កំណាត់ត្រឹមតែមួយវិលប៉ុណ្ណោះ ហើយក៏តាំងនៅនឹងថ្កល់ ហាក់ដូចជាខ្ចាស់ត្រង់ភ្ញៅ ។ ជាងរថក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ចក្រណាដែលធ្វើឲ្យសម្រេចត្រឹម ៦ ថ្ងៃ ចក្រនោះឯង មានខ្នងកង់វៀច ពករវេចវេុប មានជាប់ស្រោយផង កាំក៏វៀច ពករវេចវេុប មានជាប់ស្រោយផង ដុំវៀច មានពករវេចវេុប មានជាប់ស្រោយផង ។ ចក្រនោះដែលខ្ញុំព្រះអង្គបង្វិល ក៏វិលទៅកាន់ទីអស់កំណាត់ត្រឹមតែមួយកម្លាំងបង្វិលប៉ុណ្ណោះ ហើយត្រឡប់ដួលលើផែនដី ព្រោះមានខ្នងកង់វៀច ពករវេចវេុប មានជាប់ស្រោយផង ព្រោះកាំវៀច ពករវេចវេុប មានជាប់ស្រោយផង ព្រោះដុំវៀច មានពករវេចវេុប ជាប់ស្រោយផង ។

យំ បន ទេវ(១) ចក្កំ ឆហិ មាសេហិ និដ្ឋិតំ ឆារត្តូនេហិ តស្ស នេមិបិ អវង្កា អទោសា អកសាវា អារាបិ អវង្កា អទោសា អកសាវា នាភិបិ អវង្កា អទោសា អកសាវា ។ តំ នេមិយាបិ អវង្កត្តា អទោសត្តា អកសាវត្តា អារានំបិ អវង្កត្តា អទោសត្តា អកសាវត្តា នាភិយាបិ អវង្កត្តា អទោសត្តា អក-សាវត្តា បវត្តិតំ សមានំ យាវតិកា អភិសង្ខារស្ស គតិ តាវតិកំ គន្ត្វា អក្ខាហតំ មញ្ញេ អដ្ឋាសីតិ ។ សិយា ខោ បន ភិក្ខវេ តុម្ហាកំ ឯវមស្ស អញ្ញោ នូន តេន សមយេន សោ រថការោ អហោសីតិ ។ ន ខោ បនេតំ ភិក្ខវេ ឯវំ ទដ្ឋព្វំ ។ អហំ តេន សមយេន សោ រថការោ អហោសឹ ។ តទាហំ ភិក្ខវេ កុសលោ ទារុវង្កានំ ទារុទោសានំ ទារុកសាវានំ ។ ឯតរហិ ខោ បនាហំ ភិក្ខវេ អរហំ សម្មាសម្ពុទ្ធោ

---

១ ឱ. ម. យំ បន តំ ទេវ ។

បពិត្រព្រះសម្មតិទេព ចំណែកចក្រណា ដែលធ្វើឲ្យសម្រេចអស់ ៦ ខែ ខ្វះ ៦ រាត្រី ចក្រនោះមានខ្នងកង់មិនវៀច មិនមានពករដិបរដុប មិនមានស្រាយផង មានកាំមិនវៀច មិនមានពករដិបរដុប មិនមានស្រាយផង មានដុំមិនវៀច មិនមានពករដិបរដុប មិនមានស្រាយផង ។ ចក្រនោះដែលខ្ញុំព្រះអង្គបង្វិល ក៏វិលទៅកាន់ទីអស់កំណាត់ត្រឹមតែមួយកម្លាំងបង្វិលប៉ុណ្ណោះ ហើយនៅគាំង ហាក់ដូចជាខ្ចាស់ត្រង់ភ្លៅ ព្រោះមានខ្នងកង់មិនវៀច មិនមានពករដិបរដុប មិនមានស្រាយ ព្រោះមានកាំមិនវៀច មិនមានពករដិបរដុបមិនមានស្រាយ ព្រោះមានដុំមិនវៀច មិនមានពករដិបរដុបមិនមានស្រាយផង ។ ម្នាលភិក្ខុទាំងឡាយ គំនិតរបស់អ្នកទាំងឡាយ ទំនងជាយល់យ៉ាងនេះថា ជាងរថនោះ ក្នុងសម័យនោះគឺអ្នកដទៃផ្សេងដោយពិត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មិនត្រូវយល់ដំណើរនោះយ៉ាងនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ជាងរថនោះ ក្នុងសម័យនោះគឺតថាគតហ្នឹងឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងកាលនោះ តថាគតជាអ្នកចេះស្គាល់ពួកឈើវៀច ឈើមានពករដិបរដុប ឈើមានស្រាយ ។ ម្នាលភិក្ខុទាំងឡាយ លុះតថាគតបានជាអរហន្តសម្មាសម្ពុទ្ធ ក្នុងកាលឥឡូវនេះ

២៩

បឋមបណ្ណាសកេ រថការវគ្គោ

កុសលោ កាយវង្កំ កាយទោសំ កាយកសាវំ កុសលោ វចីវង្កំ វចីទោសំ វចីកសាវំ កុសលោ មនោវង្កំ មនោទោសំ មនោកសាវំ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា កាយវង្កោ អប្បហីនោ កាយទោសោ កាយកសាវោ វចីវង្កោ អប្បហីនោ វចីទោសោ វចីកសាវោ មនោវង្កោ អប្បហីនោ មនោទោសោ មនោកសាវោ ឯវំ បបតិតា តេ ភិក្ខវេ ឥមស្មា ធម្មវិនយា សេយ្យថាបិ តំ ចក្កំ ឆហិ ទិវសេហិ និដ្ឋិតំ ។ យស្ស កស្សចិ ភិក្ខវេ ភិក្ខុស្ស វា ភិក្ខុនិយា វា កាយវង្កោ បហីនោ កាយទោសោ កាយកសាវោ វចីវង្កោ បហីនោ វចីទោសោ វចីកសាវោ មនោវង្កោ បហីនោ មនោទោសោ មនោកសាវោ ឯវំ បតិដ្ឋិតា តេ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ សេយ្យថាបិ តំ ចក្កំ ឆហិ មាសេហិ និដ្ឋិតំ ឆារត្តូនេហិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ កាយវង្កំ បជហិស្សាម

ជាអ្នកយល់ស្គាល់ក្នុងកាយវៀច កាយមានពក កាយមានស្រោយ ជាអ្នកយល់ស្គាល់ក្នុងពាក្យវៀច ពាក្យមានពក ពាក្យមានស្រោយ ជាអ្នកយល់ស្គាល់ក្នុងមនោវៀច មនោមានពក មនោមានស្រោយ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុ ឬ ភិក្ខុនីណាមួយ មិនបានលះបង់កាយវៀច កាយមានពក កាយមានស្រោយ មិនបានលះបង់ពាក្យវៀច ពាក្យមានពក ពាក្យមានស្រោយ មិនបានលះបង់ចិត្តវៀច ចិត្តមានពក ចិត្តមានស្រោយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ឬ ភិក្ខុនីទាំងនោះ ឈ្មោះថា រលំចាកធម៌វិន័យនេះយ៉ាងនេះឯង ដូចជាចក្រដែលធ្វើឲ្យសម្រេចត្រឹម ៦ ថ្ងៃនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឬភិក្ខុនីណាមួយ បានលះបង់កាយវៀច កាយមានពក កាយមានស្រោយ បានលះបង់ពាក្យវៀច ពាក្យមានពក ពាក្យមានស្រោយ បានលះបង់ចិត្តវៀច ចិត្តមានពក ចិត្តមានស្រោយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុឬភិក្ខុនីទាំងនោះ ឈ្មោះថាតាំងនៅក្នុងធម៌វិន័យនេះយ៉ាងនេះឯង ដូចចក្រដែលធ្វើអស់ ៦ ខែ ខ្វះ ៦ រាត្រីទើបស្រេចនោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំង-ឡាយ គប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ នឹងលះបង់កាយវៀច

កាយទោសំ កាយកសាវំ វចីវង្កំ បជហិស្សាម វចី-ទោសំ វចីកសាវំ មនោវង្កំ បជហិស្សាម មនោទោសំ មនោកសាវន្តិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[១៦] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អបណ្ណកប្បដិបទំ បដិបន្នោ ហោតិ យោនិ ចស្ស អារទ្ធា ហោតិ អាសវានំ ខយាយ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ ភិក្ខុ ឥន្ទ្រិ-យេសុ គុត្តទ្វារោ ហោតិ ភោជនេ មត្តញ្ញូ ហោតិ ជាគរិយំ អនុយុត្តោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោតេន សទ្ទំ សុត្វា ។ បេ ។

កាយមានពក កាយមានស្រាយ នឹងលះបង់ពាក្យវៀច ពាក្យមានពក ពាក្យមានស្រាយ នឹងលះបង់ចិត្តវៀច ចិត្តមានពក ចិត្តមានស្រាយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង ។

[១៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង ឈ្មោះថាអ្នកប្រតិបត្តិនូវសេចក្តីប្រតិបត្តិមិនខុស ទាំងហេតុក៏ឈ្មោះថា លោកបានផ្តង ដើម្បីឲ្យអស់អាសវៈទាំងឡាយ ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ១ ជាអ្នកដឹងប្រមាណក្នុងភោជន ១ ជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រលឹក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយភ្នែកហើយ តែជាអ្នកមិនបានក្តូចកាន់នូវនិមិត្ត មិនបានក្តូចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្សដែលជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមនូវចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ បានឮសំឡេងដោយត្រចៀកហើយ ។ បេ ។

ឃានេន គន្ធំ ឃាយិត្វា ។ បេ ។ ជិវ្ហាយ រសំ សាយិត្វា ។ បេ ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។ បេ ។ មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ភោជនេ មត្តញ្ញូ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា

បានផុំក្លិនដោយច្រមុះហើយ ។ បេ ។ បានជញ្ជក់ជញ្ជាបរសដោយអណ្តាតហើយ ។ បេ ។ បានពាល់ត្រូវនូវផោដ្ឋព្វៈ ដោយកាយហើយ ។ បេ ។ បានដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ តែជាអ្នកមិនបានក្តួចកាន់នូវនិមិត្ត មិនបានក្តួចកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក គប្បីគ្របសង្កត់នូវបុគ្គល ដែលមិនបានសង្រួមនូវមនិន្ទ្រិយនុ៎ះ ព្រោះហេតុតែ មិនបានសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងមនិន្ទ្រិយ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងឈ្មោះថាភិក្ខុជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកដឹងប្រមាណក្នុងភោជន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានពិចារណាដោយឧបាយនៃប្រាជ្ញា បរិភោគនូវអាហារដោយគិតថា មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង មិនមែនដើម្បីប្រដាប់ មិនមែនដើម្បីស្អិតស្អាងទេ គ្រាន់តែដើម្បីឲ្យតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅ ដើម្បីកម្ចាត់បង់នូវសេចក្តីលំបាក

ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ភោជនេ មត្តញ្ញូ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ជាគរិយំ អនុយុត្តោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ទិវសំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា បឋមំ យាមំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា មជ្ឈិមំ យាមំ ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេតិ ចាទេន ចាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា

ដើម្បីអនុគ្រោះព្រហ្មចរិយធម៌ អាត្មាអញនឹងកម្ចាត់បង់នូវវេទនាចាស់ផង មិនឲ្យវេទនាថ្មីកើតឡើងបានផង ការប្រព្រឹត្តទៅនៃឥរិយាបថ ៤ ក្តី ការមិនមានទោសគឺមិនខ្ជិលច្រអូសក្តី ការនៅជាសុខក្តី នឹងមានដល់អាត្មាអញដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ភិក្ខុជាអ្នកដឹងប្រមាណក្នុងភោជន ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រលឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងធ្វើចិត្តឲ្យស្អាតចាកអាវរណីយធម៌ (ធម៌ជាគ្រឿងរារាំង) ដោយការចង្រ្កម ដោយការអង្គុយអស់ ១ ថ្ងៃ រមែងធ្វើចិត្តឲ្យស្អាតចាកអាវរណីយធម៌ ដោយការចង្រ្កម ដោយការអង្គុយ អស់បឋមយាមនៃរាត្រី សម្រេចនូវសីហសេយ្យាសន៍ ផ្អៀងទៅខាងស្តាំ អស់មជ្ឈិមយាមនៃរាត្រី តម្រួតជើងលើជើង ប្រកបដោយសតិសម្បជញ្ញៈ ធ្វើទុកក្នុងចិត្តនូវសេចក្តីសម្គាល់ថា នឹងក្រោក

រត្តិយា បច្ឆិមំ យាមំ បច្ចុដ្ឋាយ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ជាគរិយំ អនុយុត្តោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អបណ្ណកប្បដិបទំ បដិបន្នោ ហោតិ យោនិ ចស្ស អារទ្ធា ហោតិ អាសវានំ ខយាយាតិ ។

[១៧] តយោមេ ភិក្ខវេ ធម្មា អត្តព្យាពាធាយបិ សំវត្តន្តិ បរព្យាពាធាយបិ សំវត្តន្តិ ឧភយព្យាពាធាយបិ សំវត្តន្តិ ។ កតមេ តយោ ។ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មា អត្តព្យាពាធាយបិ សំវត្តន្តិ បរព្យាពាធាយបិ សំវត្តន្តិ ឧភយព្យាពាធាយបិ សំវត្តន្តិ ។ តយោមេ ភិក្ខវេ ធម្មា នេវ អត្តព្យាពាធាយ សំវត្តន្តិ ន បរព្យាពាធាយ សំវត្តន្តិ ន ឧភយព្យាពាធាយ សំវត្តន្តិ ។ កតមេ តយោ ។

ហើយក៏ក្រោក ក្នុងបច្ឆិមយាមនៃរាត្រី ធ្វើចិត្តឲ្យស្អាតចាកអាវរណីយធម៌ ដោយការចង្រ្កម ដោយការអង្គុយ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ឈ្មោះថា ភិក្ខុជាអ្នកប្រកបរឿយៗ នូវការភ្ញាក់រលឹក ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ឈ្មោះថា អ្នកប្រតិបត្តិនូវសេចក្តីប្រតិប័ទមិនខុស ទាំងហេតុក៏ឈ្មោះថា លោកបានផ្តងដើម្បីឲ្យអស់អាសវៈទាំងឡាយ ។

[១៧] ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនឯងផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំង ២ ផង ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ គឺ កាយទុច្ចរិត ១ វចីទុច្ចរិត ១ មនោទុច្ចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះឯង តែងប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនឯងផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង ប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំង ២ ផង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនឯងផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំង ២ ផង ។ ធម៌ ៣ តើដូចម្តេច ។

កាយសុចរិតំ វចីសុចរិតំ មនោសុចរិតំ ។ ឥមេ ខោ ភិក្ខវេ តយោ ធម្មា នេវ អត្តព្យាពាធាយ សំវត្តន្តិ ន បរព្យាពាធាយ សំវត្តន្តិ ន ឧភយ-ព្យាពាធាយ សំវត្តន្តីតិ ។

[១៨] សចេ វោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ នេវលោកុបបត្តិយា អាវុសោ សមណោ គោតមោ ព្រហ្មចរិយំ វុស្សតីតិ ។ ននុ តុម្ហេ ភិក្ខវេ ឯវំ បុដ្ឋា អដ្ដិយេយ្យាថ ហរាយេយ្យាថ ជិគុច្ឆេយ្យាថាតិ ។ ឯវំ ភន្តេ ។ ឥតិ កិរ តុម្ហេ ភិក្ខវេ ទិព្វេន អាយុនា អដ្ដិយថ ហរាយថ ជិគុច្ឆថ ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អធិបតេយ្យេន អដ្ដិយថ ហរាយថ ជិគុច្ឆថ ។ បគេវ ខោ បន ភិក្ខវេ តុម្ហេហិ កាយទុច្ចរិតេន អដ្ដិយិតព្វំ ហរាយិតព្វំ ជិគុច្ឆិតព្វំ វចីទុច្ចរិតេន... មនោទុច្ចរិតេន អដ្ដិយិតព្វំ ហរាយិតព្វំ ជិគុច្ឆិតព្វន្តិ ។

គឺ កាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ នេះឯង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនខ្លួនឯងផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលដទៃផង មិនប្រព្រឹត្តទៅ ដើម្បីបៀតបៀនបុគ្គលទាំង ២ ផង ។

[១៨] ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជកជាអន្យតិរ្ថិយ សួរអ្នកទាំងឡាយ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ព្រះសមណគោតម ប្រព្រឹត្តព្រហ្មចរិយធម៌ ដើម្បីទៅកើតក្នុងទេវលោកឬ ។ ម្នាលភិក្ខុទាំង-ឡាយ បើបរិព្វាជកជាអន្យតិរ្ថិយ សួរយ៉ាងនេះ អ្នកទាំងឡាយ ជិនឆ្អន់ ធុញទ្រាន់ ខ្ពើមរអើមដែរឬ ។ ព្រះករុណាព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយ ជិនឆ្អន់ ធុញទ្រាន់ ខ្ពើមរអើម អាយុទិព្វ សម្បុរទិព្វ សេចក្ដីសុខទិព្វ យសទិព្វ ជិនឆ្អន់ ធុញទ្រាន់ ខ្ពើមរអើម ភាពជាអធិបតីជាទិព្វ ដោយប្រការដូច្នេះហើយ ។ ម្នាលភិក្ខុទាំងឡាយ បើម៉្លោះទៅហើយ អ្នកទាំងឡាយ គប្បីជិនឆ្អន់ ធុញទ្រាន់ ខ្ពើមរអើម នឹងកាយទុច្ចរិត នឹងវចីទុច្ចរិត... គប្បីជិនឆ្អន់ ធុញទ្រាន់ ខ្ពើមរអើមនឹងមនោទុច្ចរិត ។

[១៩] តីហិ ភិក្ខវេ អង្គេហិ សមន្នាគតោ ចាបណិកោ អភព្វោ អនធិគតំ វា ភោគំ អធិគន្តុំ អធិគតំ វា ភោគំ ផាតិកាតុំ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ ចាបណិកោ បុព្វណ្ហសមយំ ន សក្កច្ចំ កម្មន្តំ អធិដ្ឋាតិ មជ្ឈន្តិកសមយំ ន សក្កច្ចំ កម្មន្តំ អធិដ្ឋាតិ សាយណ្ហសមយំ ន សក្កច្ចំ កម្មន្តំ អធិដ្ឋាតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ អង្គេហិ សមន្នាគតោ ចាបណិកោ អភព្វោ អនធិគតំ វា ភោគំ អធិគន្តុំ អធិគតំ វា ភោគំ ផាតិកាតុំ ។ ឯវមេវ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អភព្វោ អនធិគតំ វា កុសលំ ធម្មំ អធិគន្តុំ អធិគតំ វា កុសលំ ធម្មំ ផាតិកាតុំ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ ភិក្ខុ បុព្វណ្ហសមយំ ន សក្កច្ចំ សមាធិនិមិត្តំ អធិដ្ឋាតិ មជ្ឈន្តិកសមយំ ន សក្កច្ចំ សមាធិនិមិត្តំ អធិដ្ឋាតិ សាយណ្ហសមយំ ន សក្កច្ចំ សមាធិនិមិត្តំ អធិដ្ឋាតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ

[១៩] ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារប្រកបដោយអង្គ ៣ ជាអ្នកមិនគួរបានភោគៈដែលមិនទាន់បានផង មិនគួរធ្វើភោគៈដែលរកបានហើយឲ្យចម្រើនឡើងផង ។ អង្គ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារក្នុងលោកនេះ មិនចាត់ចែងការងារ ដោយយកចិត្តទុកដាក់ ក្នុងបុព្វណ្ហសម័យ ១ មិនចាត់ចែងការងារ ដោយយកចិត្តទុកដាក់ក្នុងមជ្ឈន្តិកសម័យ ១ មិនចាត់ចែងការងារ ដោយយកចិត្តទុកដាក់ក្នុងសាយណ្ហសម័យ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារប្រកបដោយអង្គ ៣ នេះឯង រមែងមិនគួរបានភោគៈដែលមិនទាន់បានផង មិនគួរធ្វើភោគៈដែលបានមកហើយឲ្យចម្រើនឡើងផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៣ មិនគួរបានកុសលធម៌ដែលមិនទាន់បានផង មិនគួរធ្វើកុសលធម៌ដែលកើតហើយ ឲ្យចម្រើនឡើងផង ក៏យ៉ាងនោះដែរ ។ ធម៌ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនអធិដ្ឋានសមាធិនិមិត្ត ដោយយកចិត្តទុកដាក់ក្នុងបុព្វណ្ហសម័យ ១ មិនអធិដ្ឋានសមាធិនិមិត្ត ដោយយកចិត្តទុកដាក់ក្នុងមជ្ឈន្តិកសម័យ ១ មិនអធិដ្ឋានសមាធិនិមិត្តដោយយកចិត្តទុកដាក់ក្នុងសាយណ្ហសម័យ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៣ នេះឯង

ភិក្ខុ អភព្វោ អនធិគតំ វា កុសលំ ធម្មំ អធិគន្តុំ អធិគតំ វា កុសលំ ធម្មំ ផាតិកាតុំ ។ តីហិ ភិក្ខវេ អង្គេហិ សមន្នាគតោ អាបណិកោ ភព្វោ អនធិគតំ វា ភោគំ អធិគន្តុំ អធិគតំ វា ភោគំ ផាតិកាតុំ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ អាបណិកោ បុព្វណ្ហសមយំ សក្កច្ចំ កម្មន្តំ អធិដ្ឋាតិ មជ្ឈន្តិកសមយំ សក្កច្ចំ កម្មន្តំ អធិដ្ឋាតិ សាយណ្ហសមយំ សក្កច្ចំ កម្មន្តំ អធិដ្ឋាតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ អង្គេហិ សមន្នាគតោ អាបណិកោ ភព្វោ អនធិគតំ វា ភោគំ អធិគន្តុំ អធិគតំ វា ភោគំ ផាតិកាតុំ ។ ឯវមេវ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ អនធិគតំ វា កុសលំ ធម្មំ អធិគន្តុំ អធិគតំ វា កុសលំ ធម្មំ ផាតិកាតុំ ។ កតមេហិ តីហិ ។

មិនគួរបានកុសលធម៌ដែលមិនទាន់បានផង មិនគួរធ្វើកុសលធម៌ដែលបានហើយ ឲ្យចម្រើនឡើងផង ។ ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារប្រកបដោយអង្គ ៣ ទើបគួរបាននូវភោគៈដែលមិនទាន់បានមកផង គួរធ្វើភោគៈដែលបានមកហើយ ឲ្យចម្រើនឡើងផង ។ អង្គ ៣ តើដូចម្ដេច ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកផ្សារក្នុងលោកនេះ ចាត់ចែងការងារ ដោយយកចិត្តទុកដាក់ក្នុងបុព្វណ្ហសម័យ ១ ចាត់ចែងការងារដោយយកចិត្តទុកដាក់ក្នុងមជ្ឈន្តិក-សម័យ ១ ចាត់ចែងការងារ ដោយយកចិត្តទុកដាក់ក្នុងសាយណ្ហសម័យ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារប្រកបដោយអង្គទាំង ៣ នេះឯង ទើបគួរបាននូវភោគៈដែលមិនទាន់បានផង គួរធ្វើភោគៈដែលរកបានមកហើយ ឲ្យចម្រើនឡើងផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង គួរបានកុសលធម៌ដែលមិនទាន់បានផង គួរធ្វើកុសលធម៌ដែលបានហើយ ឲ្យចម្រើនឡើងផង ក៏យ៉ាងនោះដែរ ។ ធម៌ ៣ យ៉ាង តើដូចម្ដេច ។

ឥធ ភិក្ខវេ ភិក្ខុ បុព្វណ្ហសមយំ សក្កច្ចំ សមាធិនិមិត្តំ អធិដ្ឋាតិ មជ្ឈន្តិកសមយំ សក្កច្ចំ សមាធិនិមិត្តំ អធិដ្ឋាតិ សាយណ្ហសមយំ សក្កច្ចំ សមាធិនិមិត្តំ អធិដ្ឋាតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភព្វោ អនធិគតំ វា កុសលំ ធម្មំ អធិគន្តុំ អធិគតំ វា កុសលំ ធម្មំ ផាតិកាតុន្តិ ។

[២០] តីហិ ភិក្ខវេ អង្គេហិ សមន្នាគតោ បាបណិកោ នចិរស្សេវ មហន្តត្តំ វេបុល្លត្តំ បាបុណាតិ ភោគេសុ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ បាបណិកោ ចក្ខុមា ច ហោតិ វិធុរោ ច និស្សយសម្បន្នោ ច ។ កថញ្ច ភិក្ខវេ បាបណិកោ ចក្ខុមា ហោតិ ។ ឥធ ភិក្ខវេ បាបណិកោ បណិយំ[១] ជានាតិ ឥទំ បណិយំ[១] ឯវំ កីតំ ឯវំ វិក្កាយមានំ ឯត្តកំ មូលំ ភវិស្សតិ ឯត្តកោ ឧទ្រយោតិ ។ ឯវំ ខោ ភិក្ខវេ បាបណិកោ ចក្ខុមា ហោតិ ។ កថញ្ច ភិក្ខវេ បាបណិកោ វិធុរោ ហោតិ ។

---

១ ម. បាបណិយំ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ អធិដ្ឋានសមាធិនិមិត្ត ដោយយកចិត្តទុកដាក់ក្នុងបុព្វណ្ហសម័យ ១ អធិដ្ឋានសមាធិនិមិត្ត ដោយយកចិត្តទុកដាក់ក្នុងមជ្ឈន្តិកសម័យ ១ អធិដ្ឋានសមាធិនិមិត្ត ដោយយកចិត្តទុកដាក់ក្នុងសាយណ្ហសម័យ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៣ នេះឯង ទើបគួរបានកុសលធម៌ ដែលមិនទាន់បានផង គួរធ្វើកុសលធម៌ដែលបានហើយ ឲ្យចម្រើនឡើងផង ។

[២០] ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារប្រកបដោយអង្គ ៣ មិនយូរប៉ុន្មាន រមែងដល់នូវការចម្រើន បរិបូណ៌ក្នុងភោគៈ ។ អង្គ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារក្នុងលោកនេះ ជាអ្នកមានបញ្ញាចក្ខុ ១ មានព្យាយាមដ៏ប្រសើរ ១ សម្បូណ៌ដោយទីពឹង ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារដែលមានបញ្ញាចក្ខុ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារក្នុងលោកនេះ រមែងស្គាល់ទំនិញថា ទំនិញនេះ អញទិញមកថ្លៃប៉ុណ្ណេះ កាលបើអញលក់ទៅវិញថ្លៃប៉ុណ្ណេះ នឹងបានតម្លៃត្រឹមប៉ុណ្ណេះ នឹងបានចំណេញប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯងហៅថា អ្នកផ្សារមានបញ្ញា-ចក្ខុ ។ ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារមានព្យាយាមដ៏ប្រសើរ តើដូចម្តេច ។

ឥធ ភិក្ខវេ ចាបណិកោ កុសលោ ហោតិ បណិយំ កេតុញ្ច វិក្កេតុញ្ច ។ ឯវំ ខោ ភិក្ខវេ ចាបណិកោ វិធុរោ ហោតិ ។ កថញ្ច ភិក្ខវេ ចាប-ណិកោ និស្សយសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ចាបណិកោ យេ តេ គហបតី វា គហបតិបុត្តា វា អឌ្ឍា មហទ្ធនា មហាភោគា តេ នំ ឯវំ ជានន្តិ អយំ ខោ ភវំ ចាបណិកោ ចក្ខុមា ច វិធុរោ ច បដិពលោ បុត្តទារញ្ច បោសេតុំ អម្ហាកញ្ច កាលេន កាលំ អនុប្បទាតុន្តិ ។ តេ នំ ភោគេហិ និបតន្តិ[១] ឥតោ សម្ម ចាបណិក ភោគេ ហរិត្វា[២] បុត្តទារញ្ច បោសេហិ អម្ហាកញ្ច កាលេន កាលំ អនុប្បទេហីតិ ។ ឯវំ ខោ ភិក្ខវេ ចាបណិកោ និស្សយសម្បន្នោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ អង្គេហិ សមន្នាគតោ ចាបណិកោ នចិរស្សេវ មហន្តត្តំ វេបុល្លត្តំ ចាបុណាតិ ភោគេសុ ។ ឯវមេវ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ នចិរស្សេវ មហន្តត្តំ វេបុល្លត្តំ ចាបុណាតិ កុសលេសុ ធម្មេសុ ។

១ ឱ. និមន្តន្តិ ។ ២ ឱ. ករិត្វា ។

ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារក្នុងលោកនេះ រមែងឆ្លៀវឆ្លាសក្នុងការទិញទំនិញផង លក់ទំនិញផង ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ហៅថា អ្នកផ្សារមានព្យាយាមដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកផ្សារសម្បូណ៌ដោយទីពឹង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារក្នុងលោកនេះ រមែងមានពួកគហបតី ឬគហបតិបុត្រ ដែលស្តុកស្តម្ភមានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន ស្គាល់អ្នកផ្សារនោះយ៉ាងនេះថា អ្នកផ្សារដ៏ចម្រើននេះ មានបញ្ញាចក្ខុផង មានព្យាយាមដ៏ប្រសើរផង ជាអ្នកអង់អាចដើម្បីរក្សាកូនប្រពន្ធផង ដើម្បីផ្តល់នូវទ្រព្យដល់យើងមួយដងមួយកាលបានផង ។ គហបតី ឬគហបតិបុត្រទាំងនោះ អញ្ជើញអ្នកផ្សារនោះដោយភោគៈទាំងឡាយថា ម្នាលអ្នកផ្សារសម្លាញ់ ចូរអ្នកយកភោគៈអំពីនេះ ទៅចិញ្ចឹមកូនប្រពន្ធចុះ ចូរផ្តល់នូវទ្រព្យដល់យើងមួយដងមួយកាលផងចុះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ហៅថា អ្នកផ្សារសម្បូណ៌ដោយទីពឹង ។ ម្នាលភិក្ខុទាំងឡាយ អ្នកផ្សារប្រកបដោយអង្គទាំង ៣ នេះឯង មិនយូរប៉ុន្មាន រមែងដល់នូវការចម្រើនបរិបូណ៌ក្នុងភោគៈ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ មិនយូរប៉ុន្មាន គង់ដល់នូវការចម្រើន បរិបូណ៌ក្នុងកុសលធម៌ក៏យ៉ាងនោះដែរ ។

កតមេហិ តីហិ ។ ឥធ ភិក្ខវេ ភិក្ខុ ចក្ខុមា ច ហោតិ វិធុរោ ច និស្សយសម្បន្នោ ច ។ កថញ្ច ភិក្ខវេ ភិក្ខុ ចក្ខុមា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ... អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ចក្ខុមា ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ វិធុរោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ[១] ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ វិធុរោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ និស្សយសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ យេ តេ ភិក្ខូ ពហុស្សុតា អាគតាគមា ធម្មធរា

---

១ ឱ. ម. ឧប្បាទាយ ។

ធម៌ ៣ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានបញ្ញាចក្ខុ ១ មានព្យាយាមដ៏ប្រសើរ ១ សម្បូណ៌ដោយទីពឹង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានបញ្ញាចក្ខុ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងដឹងច្បាស់តាមពិតថា នេះទុក្ខ... ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ហៅថា ភិក្ខុមានបញ្ញាចក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានព្យាយាមដ៏ប្រសើរ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកតាំងផ្ដើមសេចក្ដីព្យាយាម ដើម្បីលះបង់អកុសលធម៌ ធ្វើកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្ដីប្រឹងប្រែងដ៏មុតមាំ មិនបោះបង់ព្យាយាម ក្នុងកុសលធម៌ទាំង-ឡាយ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ហៅថា ភិក្ខុមានព្យាយាមដ៏ប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកសម្បូណ៌ដោយទីពឹង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រមែងបានពួកភិក្ខុដែលមានសេចក្ដីចេះដឹងច្រើន ចេះចាំស្ទាត់ក្នុងនិកាយ ជាអ្នកទ្រទ្រង់ធម៌

វិនយធរា មាតិកាធរា សោ តេ កាលេន កាលំ ឧបសង្កមិត្វា បរិបុច្ឆតិ បរិបញ្ហតិ ឥទំ ភន្តេ កថំ ឥមស្ស កោ អត្ថោតិ ។ តស្ស តេ អាយស្មន្តោ អវិវដញ្ចេវ វិវរន្តិ អនុត្តានីកតញ្ច ឧត្តានីករោន្តិ អនេកវិហិតេសុ ច កង្ខដ្ឋានីយេសុ ធម្មេសុ កង្ខំ បដិវិនោទេន្តិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ និស្សយ-សម្បន្នោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ នចិរស្សេវ មហន្តត្តំ វេបុល្លត្តំ ចាបុណាតិ កុសលេសុ ធម្មេសូតិ ។

រថការវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

ញាតកោ សរណីយោ ភិក្ខុ
ចក្កវត្តី បចេតនោ
អបណ្ណកត្តា ទេវោ ច
ទ្វេ ចាបណិកេន ចាតិ ។

ទ្រទ្រង់វិន័យ ទ្រទ្រង់មាតិកា ភិក្ខុនោះក៏ចូលទៅជណ្តឹង សាកសួរពួកភិក្ខុទាំងនោះ មួយដងមួយកាលថា បពិត្រព្រះករុណាដ៏ចម្រើន កិច្ចនេះតើដូចម្តេច ប្រយោជន៍នៃកិច្ចនេះ តើដូចម្តេច ។ ចំណែកលោកមានអាយុទាំងនោះ ក៏បើកនូវសេចក្តីដ៏កំបាំងផង ធ្វើឲ្យរាក់នូវសេចក្តីដែលជ្រៅផង បន្ទោបង់នូវសេចក្តីសង្ស័យ ក្នុងធម៌ដែលគួរសង្ស័យ ដ៏ច្រើនប្រការផង ដល់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ហៅថា ភិក្ខុសម្បូណ៌ដោយទីពឹង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៣ នេះឯងហើយ មិនយូរប៉ុន្មាន គង់ដល់នូវសេចក្តីចម្រើនបរិបូណ៌ ក្នុងកុសលធម៌ទាំងឡាយ ។

ចប់ រថការវគ្គ ទី ២ ។

# ឧទ្ទាននៃរថការវគ្គនោះគឺ

សម្តែងអំពីភិក្ខុមានកេរ្តិ៍ឈ្មោះ ១ ហេតុដែលស្តេចគប្បីរលឹក ១ ភិក្ខុ ១ ស្តេចចក្រពត្តិ ១ ព្រះបាទបចេតនៈ ១ ភិក្ខុប្រតិបត្តិអបណ្ណកប្បដិបទា ១ អន្យតិរ្ថិយថាព្រះសម្ពុទ្ធប្រព្រឹត្តដើម្បីកើតក្នុងទេវលោក ១ អ្នកផ្សារប្រកបដោយធម៌ ៣ មាន ២ លើក ។

# បុគ្គលវគ្គោ

[២១] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ អាយស្មា ច សវិដ្ឋោ[១] អាយស្មា ច មហាកោដ្ឋិតោ[២] យេនាយស្មា សារីបុត្តោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សវិដ្ឋំ អាយស្មា សារីបុត្តោ ឯតទវោច តយោមេ អាវុសោ សវិដ្ឋ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ។ ឥមេ ខោ អាវុសោ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឥមេសំ អាវុសោ តិណ្ណំ បុគ្គលានំ កតមោ តេ បុគ្គលោ ខមតិ អភិក្កន្តតរោ ច បណីតតរោ ច ។ តយោមេ អាវុសោ សារីបុត្ត បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។

១ ម. សមិទ្ធោ ។ ២ ម. មហាកោដ្ឋិកោ ។

# បុគ្គលវគ្គ

[២១] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះសវិដ្ឋៈដ៏មានអាយុ និងព្រះមហាកោដ្ឋិតៈមានអាយុ ចូលទៅរកព្រះសារីបុត្តដ៏មានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ជាមួយនឹងព្រះសា-រីបុត្តមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសវិដ្ឋៈមានអាយុ អង្គុយក្នុងទីដ៏សមគួររួចហើយ ព្រះសារីបុត្តមានអាយុ បានពោលដូច្នេះថា ម្នាលអាវុសោសវិដ្ឋៈ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួក តើដូចម្ដេច ។ គឺកាយសក្ខិ (មានកាយជាបន្ទាល់) ១ ទិដ្ឋិប្បត្ត (ដល់ដោយទិដ្ឋិ គឺបញ្ញា) ១ សទ្ធាវិមុត្ត (រួចចាកកិលេសដោយសទ្ធា) ១ ។ ម្នាលអាវុសោ បុគ្គល ៣ ពួកនេះឯង រមែងមាននៅក្នុងលោក ។ ម្នាលអាវុសោ បុគ្គល ៣ ពួកនេះ បុគ្គលដូចម្ដេច ដែលល្អជាងនិងឧត្តមជាង ដែលគាប់ចិត្តលោក ។ ម្នាលអាវុសោសារីបុត្ត បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួកតើដូចម្ដេច ។

កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ។ ឥមេ ខោ អាវុសោ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឥមេសំ អាវុសោ តិណ្ណំ បុគ្គលានំ យ្វាយំ បុគ្គលោ សទ្ធាវិមុត្តោ អយំ មេ បុគ្គលោ ខមតិ ឥមេសំ តិណ្ណំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច ។ តំ កិស្ស ហេតុ ។ ឥមស្សាវុសោ បុគ្គលស្ស សទ្ធិន្ទ្រិយំ អធិមត្តន្តិ ។ អថខោ អាយស្មា សារីបុត្តោ អាយស្មន្តំ មហា-កោដ្ឋិតំ ឯតទវោច តយោមេ អាវុសោ កោដ្ឋិត បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ។ ឥមេ ខោ អាវុសោ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឥមេសំ អាវុសោ តិណ្ណំ បុគ្គលានំ កតមោ តេ បុគ្គលោ ខមតិ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ តយោមេ អាវុសោ សារីបុត្ត បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។

គឺកាយសក្ខិ ១ ទិដ្ឋិប្បត្ត ១ សទ្ធាវិមុត្ត ១ ។ ម្នាលអាវុសោ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ ម្នាលអាវុសោ បណ្តាបុគ្គល ៣ ពួកនេះ បុគ្គលណា ជាសទ្ធាវិមុត្ត បុគ្គលទាំង ៣ ពួកនេះ បុគ្គលនេះល្អជាង និងឧត្តមជាង រមែងគាប់ចិត្តខ្ញុំ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអាវុសោ ដ្បិតថា សទ្ធិន្ទ្រិយរបស់បុគ្គលនេះ មានប្រមាណច្រើនក្រៃពេក ។ លំដាប់នោះឯង ព្រះសារីបុត្តមានអាយុ បានពោលនឹងព្រះមហាកោដ្ឋិតៈ មានអាយុដូច្នេះថា ម្នាលអាវុសោ កោដ្ឋិតៈ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួកតើដូចម្តេច ។ គឺកាយសក្ខិ ១ ទិដ្ឋិប្បត្ត ១ សទ្ធាវិមុត្ត ១ ។ ម្នាលអាវុសោ បុគ្គល ៣ ពួកនេះឯង រមែងមាននៅក្នុងលោក ។ ម្នាលអាវុសោ បណ្តាបុគ្គល ៣ ពួកនេះ បុគ្គលដូចម្តេច ដែលល្អជាងគេ និងឧត្តមជាងគេ ដែលគាប់ចិត្តលោក ។ ម្នាលអាវុសោ សារីបុត្ត បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។

៤៣



កតមេ តយោ ។ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធា-វិមុត្តោ ។ ឥមេ ខោ អាវុសោ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឥមេសំ អាវុសោ តិណ្ណំ បុគ្គលានំ យ្វាយំ បុគ្គលោ កាយសក្ខី អយំ មេ បុគ្គលោ ខមតិ ឥមេសំ តិណ្ណំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច ។ តំ កិស្ស ហេតុ ។ ឥមស្សាវុសោ បុគ្គលស្ស សមាធិន្ទ្រិយំ អធិមត្តន្តិ ។ អថខោ អាយស្មា មហាកោដ្ឋិតោ អាយស្មន្តំ សារីបុត្តំ ឯតទវោច តយោមេ អាវុសោ សារីបុត្ត បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ កាយសក្ខី ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ។ ឥមេ ខោ អាវុសោ តយោ បុគ្គលា សន្តោ សំវិជ្ជមានោ លោកស្មឹ ។ ឥមេសំ អាវុសោ តិណ្ណំ បុគ្គលានំ កតមោ តេ បុគ្គលោ ខមតិ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ តយោមេ អាវុសោ កោដ្ឋិត បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ កាយសក្ខី

បុគ្គល ៣ ពួកតើដូចម្តេច ។ គឺកាយសក្ខិ ១ ទិដ្ឋិប្បត្ត ១ សទ្ធាវិមុត្ត ១ ។ ម្នាលអាវុសោ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ ម្នាលអាវុសោ បណ្តាបុគ្គល ៣ ពួកនេះ បុគ្គលណា ជាកាយសក្ខិ បុគ្គលទាំង ៣ ពួកនេះ បុគ្គលនេះល្អជាង និងឧត្តមជាង រមែងគាប់ចិត្តខ្ញុំ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអាវុសោ ដ្បិតថា សមាធិន្ទ្រិយរបស់បុគ្គលនេះ មានប្រមាណច្រើនក្រៃពេក ។ លំដាប់នោះ ព្រះមហាកោដ្ឋិតៈដ៏មានអាយុ បានពោលនឹងព្រះសារីបុត្តមានអាយុដូច្នេះថា ម្នាលអាវុសោសារីបុត្ត បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួកតើដូចម្តេច ។ គឺកាយសក្ខិ ១ ទិដ្ឋិប្បត្ត ១ សទ្ធាវិមុត្ត ១ ។ ម្នាលអាវុសោ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ ម្នាលអាវុសោ បណ្តាបុគ្គលទាំង ៣ ពួកនេះ បុគ្គលដូចម្តេច ដែលល្អជាងគេ នឹងឧត្តមជាងគេ ដែលគាប់ចិត្តលោក ។ ម្នាលអាវុសោ កោដ្ឋិតៈ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួក តើដូចម្តេច ។ គឺកាយសក្ខិ ១

ទិដ្ឋិប្បត្តោ សទ្ធាវិមុត្តោ ។ ឥមេ ខោ អាវុសោ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឥមេសំ អាវុសោ តិណ្ណំ បុគ្គលានំ យ្វាយំ បុគ្គលោ ទិដ្ឋិប្បត្តោ អយំ មេ បុគ្គលោ ខមតិ ឥមេសំ តិណ្ណំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ច ។ តំ កិស្ស ហេតុ ។ ឥមស្សាវុសោ បុគ្គលស្ស បញ្ញិន្ទ្រិយំ អធិមត្តន្តិ ។ អថខោ អាយស្មា សារីបុត្តោ អាយស្មន្តំ ច សវិដ្ឋំ អាយស្មន្តំ ច មហាកោដ្ឋិតំ ឯតទវោច ព្យាកតំ ខោ អាវុសោ អម្ហេហិ សព្វេហេវ យថាសកំ បដិភាណំ អាយាមាវុសោ យេន ភគវា តេនុបសង្កមិស្សាម ឧបសង្កមិត្វា ភគវតោ ឯតមត្ថំ អារោចេស្សាម យថា នោ ភគវា ព្យាករិស្សតិ តថា នំ ធារេស្សាមាតិ ។ ឯវមាវុសោតិ ខោ អាយស្មា ច សវិដ្ឋោ អាយស្មា ច មហាកោដ្ឋិតោ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។

ទិដ្ឋិប្បត្ត ១ សទ្ធាវិមុត្ត ១ ។ ម្នាលអាវុសោ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ ម្នាលអាវុសោ បណ្តាបុគ្គល ៣ ពួកនេះ បុគ្គលណាជាទិដ្ឋិប្បត្ត បុគ្គលទាំង ៣ ពួកនេះ បុគ្គលនេះល្អជាង និងឧត្តមជាង រមែងគាប់ចិត្តខ្ញុំ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលអាវុសោ ដ្បិតថា បញ្ញិន្ទ្រិយរបស់បុគ្គលនេះ មានប្រមាណច្រើនក្រៃពេក ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុ បានពោលនឹងព្រះសវិដ្ឋៈមានអាយុផង នឹងព្រះមហាកោដ្ឋិតៈមានអាយុផង ដូច្នេះថា ម្នាលអាវុសោ បដិភាណ (ប្រាជ្ញាវាងវៃ) ដែលយើងទាំងអស់គ្នាព្យាករ ទៅតាមអធ្យាស្រ័យរបស់ខ្លួន ម្នាលអាវុសោមក ពួកយើងនឹងចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ នឹងក្រាបបង្គំទូលសួរសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគ ព្រះមានព្រះភាគនឹងទ្រង់ព្យាករដល់យើងយ៉ាងណា យើងនឹងចាំសេចក្តីនោះទុកយ៉ាងនោះ ។ ព្រះសវិដ្ឋៈមានអាយុ និងព្រះមហាកោដ្ឋិតៈដ៏មានអាយុ ទទួលស្តាប់ពាក្យព្រះសារីបុត្តមានអាយុថា ករុណាអាវុសោ ។

អថខោ អាយស្មា ច សារីបុត្តោ អាយស្មា ច សវិដ្ឋោ អាយស្មា ច មហាកោដ្ឋិតោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា សារីបុត្តោ យាវតកោ អហោសិ អាយស្មតា ច សវិដ្ឋេន អាយស្មតា ច មហាកោដ្ឋិតេន សទ្ធឹ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។ នេត្ថ សារីបុត្ត សុករំ ឯកំសេន ព្យាកាតុំ អយំ ឥមេសំ តិណ្ណំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។ ឋានំ ហេតំ សារីបុត្ត វិជ្ជតិ យ្វាយំ បុគ្គលោ សទ្ធាវិមុត្តោ ស្វាយំ អរហត្តាយ បដិបន្នោ យ្វាយំ បុគ្គលោ កាយសក្ខី ស្វាយំ សកទាគាមី វា អនាគាមី វា យោ ចាយំ បុគ្គលោ ទិដ្ឋិប្បត្តោ សោបស្ស[១] សកទាគាមី វា អនាគាមី វា ។ នេត្ថ សារីបុត្ត សុករំ ឯកំសេន ព្យាកាតុំ អយំ ឥមេសំ តិណ្ណំ បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។

១ ម. សោយំ ។

លំដាប់នោះ ព្រះសារីបុត្តមានអាយុ ព្រះសវិដ្ឋៈមានអាយុ និងព្រះមហាកោដ្ឋិតៈមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលពាក្យដែលចរចាជាមួយនឹងព្រះសវិដ្ឋៈមានអាយុ និងព្រះមហាកោដ្ឋិតៈមានអាយុ តាំងពីដើមទាំងអស់នោះ ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលសារីបុត្ត ក្នុងដំណើរនុ៎ះ បុគ្គលមិនងាយនឹងព្យាករ ដោយដាច់ខាតថា បណ្ដាបុគ្គលទាំង ៣ ពួកនេះ បុគ្គលនេះល្អជាង និងឧត្ដមជាង ដូច្នេះទេ ។ ម្នាលសារីបុត្ត ហេតុនុ៎ះ រមែងមានដោយពិតថា បុគ្គលណាជាសទ្ធាវិមុត្តបុគ្គលនោះប្រតិបត្តិ ដើម្បីអរហត្តមគ្គ បុគ្គលណា ជាកាយសក្ខី បុគ្គលនោះ ជាសកទាគាមី ឬជា អនាគាមី មួយទៀត បុគ្គលណាជាទិដ្ឋិប្បត្ត បុគ្គលនោះជា សកទាគាមី ឬជាអនាគាមីក៏មាន ។ ម្នាលសារីបុត្ត ក្នុងដំណើរនុ៎ះ បុគ្គលមិនងាយព្យាករ ដោយដាច់ខាតថា បណ្ដាបុគ្គលទាំង ៣ ពួកនេះ បុគ្គលនេះ ល្អជាង និងឧត្ដមជាង ដូច្នេះទេ ។

ឋានំ ហេតំ សារីបុត្ត វិជ្ជតិ យ្វាយំ បុគ្គលោ
កាយសក្ខី ស្វាយំ អរហត្តាយ បដិបន្នោ យ្វាយំ
បុគ្គលោ សទ្ធាវិមុត្តោ ស្វាយំ សកទាគាមី វា
អនាគាមី វា យោចាយំ បុគ្គលោ ទិដ្ឋិប្បត្តោ សោបស្ស
សកទាគាមី វា អនាគាមី វា ។ នខ្វេត្ថ សារីបុត្ត
សុករំ ឯកំសេន ព្យាកាតុំ អយំ ឥមេសំ តិណ្ណំ
បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។
ឋានំ ហេតំ សារីបុត្ត វិជ្ជតិ យ្វាយំ បុគ្គលោ ទិដ្ឋិ-
ប្បត្តោ ស្វាយំ អរហត្តាយ បដិបន្នោ យ្វាយំ បុគ្គលោ
សទ្ធាវិមុត្តោ ស្វាយំ សកទាគាមី វា អនាគាមី វា
យោចាយំ បុគ្គលោ កាយសក្ខី សោបស្ស សក-
ទាគាមី វា អនាគាមី វា ។ នខ្វេត្ថ សារីបុត្ត
សុករំ ឯកំសេន ព្យាកាតុំ អយំ ឥមេសំ តិណ្ណំ
បុគ្គលានំ អភិក្កន្តតរោ ច បណីតតរោ ចាតិ ។

ម្នាលសារីបុត្ត ហេតុនុ៎ះ រមែងមានដោយពិតថា បុគ្គលណា ជាកាយសក្ខិ បុគ្គលនោះ ប្រតិបត្តិដើម្បីអរហត្តមគ្គ បុគ្គលណា ជាសទ្ធាវិមុត្ត បុគ្គលនោះ ជាសកទាគាមី ឬជាអនាគាមី មួយទៀត បុគ្គលណាជា ទិដ្ឋិប្បត្ត បុគ្គលនោះ ជាសកទាគាមី ឬជាអនាគាមីក៏មាន ។ ម្នាលសារីបុត្ត ក្នុងដំណើរនុ៎ះ បុគ្គលមិនងាយនឹងព្យាករ ដោយដាច់ខាតថា បណ្តាបុគ្គលទាំង ៣ ពួកនេះ បុគ្គលនេះល្អជាង និងឧត្តមជាង ដូច្នេះទេ ។ ម្នាលសារីបុត្ត ហេតុនុ៎ះ រមែងមានដោយពិតថា បុគ្គលណា ជាទិដ្ឋិប្បត្ត បុគ្គលនោះ ប្រតិបត្តិដើម្បីអរហត្តមគ្គ បុគ្គលណា ជាសទ្ធាវិមុត្ត បុគ្គលនោះ ជាសកទាគាមី ឬអនាគាមី មួយវិញទៀត បុគ្គលណា ជាកាយសក្ខិ បុគ្គលនោះ ជាសកទាគាមី ឬអនាគាមីក៏មាន ។ ម្នាលសារីបុត្ត ក្នុងដំណើរនុ៎ះ បុគ្គលមិនងាយនឹងព្យាករ ដោយដាច់ខាតថា បណ្តាបុគ្គលទាំង ៣ ពួកនេះ បុគ្គលនេះល្អជាង និងឧត្តមជាង ដូច្នេះទេ ។

បឋមបណ្ណាសកេ បុគ្គលវគ្គោ

[២២] តយោមេ ភិក្ខវេ គិលានា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ ឥធ ភិក្ខវេ ឯកច្ចោ គិលានោ លភន្តោ វា សប្បាយានិ ភោជនានិ អលភន្តោ វា សប្បាយានិ ភោជនានិ លភន្តោ វា សប្បាយានិ ភេសជ្ជានិ អលភន្តោ វា សប្បាយានិ ភេសជ្ជានិ លភន្តោ វា បដិរូបំ ឧបដ្ឋាកំ អលភន្តោ វា បដិរូបំ ឧបដ្ឋាកំ នេវ វុដ្ឋាតិ តម្ហា អាពាធា ។ ឥធ បន ភិក្ខវេ ឯកច្ចោ គិលានោ លភន្តោ វា សប្បាយានិ ភោជនានិ អលភន្តោ វា សប្បាយានិ ភោជនានិ លភន្តោ វា សប្បាយានិ ភេសជ្ជានិ អលភន្តោ វា សប្បាយានិ ភេសជ្ជានិ លភន្តោ វា បដិរូបំ ឧបដ្ឋាកំ អលភន្តោ វា បដិរូបំ ឧបដ្ឋាកំ វុដ្ឋាតិ តម្ហា អាពាធា ។ ឥធ បន ភិក្ខវេ ឯកច្ចោ គិលានោ លភន្តោ[១] សប្បាយានិ ភោជនានិ នោ អលភន្តោ លភន្តោ[១] សប្បាយានិ ភេសជ្ជានិ នោ អលភន្តោ

---

១ ម. ឥមេសុ វារេសុ លភន្តោវ ឥតិ បាឋោ ទិស្សតិ ។

[២២] ម្នាលភិក្ខុទាំងឡាយ អ្នកជំងឺ ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ អ្នកជំងឺ ៣ ពួកដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកជំងឺពួកខ្លះក្នុងលោកនេះ បានភោជនជាទីសប្បាយក្តី មិនបានភោជនជាទីសប្បាយក្តី បានភេសជ្ជៈជាទីសប្បាយក្តី មិនបានភេសជ្ជៈជាទីសប្បាយក្តី បានឧបដ្ឋាកដ៏សមគួរក្តី មិនបានឧបដ្ឋាកដ៏សមគួរក្តី ក៏នៅតែមិនសះស្បើយចាកជំងឺនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ម្យ៉ាងទៀត អ្នកជំងឺពួកខ្លះក្នុងលោកនេះ បានភោជនជាទីសប្បាយក្តី មិនបានភោជនជាទីសប្បាយក្តី បានភេសជ្ជៈជាទីសប្បាយក្តី មិនបានភេសជ្ជៈជាទីសប្បាយក្តី បានឧបដ្ឋាកដ៏សមគួរក្តី មិនបានឧបដ្ឋាកដ៏សមគួរក្តី ក៏រមែងសះស្បើយចាកជំងឺនោះបាន ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អ្នកជំងឺពួកខ្លះក្នុងលោកនេះ បានភោជនជាទីសប្បាយ មិនមែនជាមិនបានភោជនជាទីសប្បាយទេ បានភេសជ្ជៈជាទីសប្បាយ មិនមែនជាមិនបានភេសជ្ជៈជាទីសប្បាយទេ

លភន្តោ[១] បដិរូបំ ឧបដ្ឋាកំ នោ អលភន្តោ វុដ្ឋាតិ តម្ហា អាពាធា ។ តត្រ ភិក្ខវេ យ្វាយំ គិលានោ លភន្តោ សប្បាយានិ ភោជនានិ នោ អលភន្តោ លភន្តោ សប្បាយានិ ភេសជ្ជានិ នោ អលភន្តោ លភន្តោ បដិរូបំ ឧបដ្ឋាកំ នោ អលភន្តោ វុដ្ឋាតិ តម្ហា អាពាធា ឥមំ ខោ ភិក្ខវេ គិលានំ បដិច្ច គិលានភត្តំ អនុញ្ញាតំ គិលានភេសជ្ជំ អនុញ្ញាតំ គិលានុបដ្ឋាកោ អនុញ្ញាតោ ឥមញ្ច បន ភិក្ខវេ គិលានំ បដិច្ច អញ្ញេបិ គិលានា ឧបដ្ឋាតព្វា[២] ។ ឥមេ ខោ ភិក្ខវេ តយោ គិលានា សន្តោ សំវិជ្ជមានា លោកស្មឹ ។ ឯវមេវ ខោ ភិក្ខវេ តយោមេ គិលានុបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ លភន្តោ វា តថាគតំ ទស្សនាយ

១ ម. ឥមេសុ វារេសុ លភន្តោ វ ឥតិ បាឋោ ទិស្សតិ ។ ២ ម. ឧបដ្ឋាបេតព្វា ។

បានឧបដ្ឋាកដ៏សមគួរ មិនមែនជាមិនបានឧបដ្ឋាកដ៏សមគួរទេ ទើបសះស្បើយចាកជំងឺនោះបាន ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាអ្នកជំងឺទាំង ៣ ពួកនោះ អ្នកជំងឺណា បានភោជនជាទីសប្បាយ មិនមែនជាមិនបានភោជនជាទីសប្បាយទេ បានភេសជ្ជៈជាទីសប្បាយ មិនមែនជាមិនបានភេសជ្ជៈជាទីសប្បាយទេ បានឧបដ្ឋាកដ៏សមគួរ មិនមែនជាមិនបានឧបដ្ឋាកដ៏សមគួរទេ ទើបសះស្បើយចាកជំងឺនោះបាន ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតគិលានភត្ត (អាហារសម្រាប់អ្នកជំងឺ) អនុញ្ញាតគិលានភេសជ្ជៈ (ថ្នាំរក្សាជំងឺ) អនុញ្ញាតគិលានុបដ្ឋាក (អ្នកថែជំងឺ) ព្រោះអាស្រ័យអ្នកជំងឺនេះឯង ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ព្រោះអាស្រ័យអ្នកជំងឺនេះ សូម្បីអ្នកជំងឺទាំងឡាយឯទៀតៗ ភិក្ខុគួរថែរក្សាដែរ ។ ម្នាលភិក្ខុទាំងឡាយ អ្នកជំងឺ ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងហ្នឹងដែរ បុគ្គល ៣ ពួកនេះប្រៀបដូចអ្នកជំងឺ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួកតើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ បានឃើញព្រះតថាគតក្ដី

៤៩

បឋមបណ្ណាសកេ បុគ្គលវគ្គោ

អលភន្តោ វា តថាគតំ ទស្សនាយ លភន្តោ វា តថាគតប្បវេទិតំ ធម្មវិនយំ សវនាយ អលភន្តោ វា តថាគតប្បវេទិតំ ធម្មវិនយំ សវនាយ នេវ ឱក្កមតិ និយាមំ កុសលេសុ ធម្មេសុ សម្មត្តំ ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ លភន្តោ វា តថាគតំ ទស្សនាយ អលភន្តោ វា តថាគតំ ទស្សនាយ លភន្តោ វា តថាគតប្បវេទិតំ ធម្មវិនយំ សវនាយ អលភន្តោ វា តថាគតប្បវេទិតំ ធម្មវិនយំ សវនាយ ឱក្កមតិ និយាមំ កុសលេសុ ធម្មេសុ សម្មត្តំ ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ លភន្តោ តថាគតំ ទស្សនាយ នោ អលភន្តោ លភន្តោ តថាគតប្បវេទិតំ ធម្មវិនយំ សវនាយ នោ អលភន្តោ ឱក្កមតិ និយាមំ កុសលេសុ ធម្មេសុ សម្មត្តំ ។ តត្រ ភិក្ខវេ យ្វាយំ បុគ្គលោ លភន្តោ តថាគតំ ទស្សនាយ នោ អលភន្តោ លភន្តោ តថាគតប្បវេទិតំ ធម្មវិនយំ សវនាយ

មិនបានឃើញព្រះតថាគតក្តី បានស្តាប់ធម៌វិន័យដែលព្រះតថាគតសម្តែងហើយក្តី មិនបានស្តាប់ធម៌វិន័យដែលព្រះតថាគតសម្តែងហើយក្តី រមែងចុះស៊ប់កាន់សេចក្តីនិយមដ៏គាប់ប្រសើរ ក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ បានឃើញព្រះតថាគតក្តី មិនបានឃើញព្រះតថាគតក្តី បានស្តាប់ធម៌វិន័យដែលព្រះតថាគតសម្តែងហើយក្តី មិនបានស្តាប់ធម៌វិន័យដែលព្រះតថាគតសម្តែងហើយក្តី រមែងចុះស៊ប់កាន់សេចក្តីនិយមដ៏គាប់ប្រសើរ ក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ បានឃើញព្រះតថាគត មិនមែនជាមិនបានឃើញទេ បានស្តាប់ធម៌វិន័យដែលព្រះតថាគតសម្តែងហើយ មិនមែនជាមិនបានស្តាប់ទេ រមែងចុះស៊ប់កាន់សេចក្តីនិយមដ៏គាប់ប្រសើរ ក្នុងកុសលធម៌ទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំង ៣ ពួកនោះ បុគ្គលណាបានឃើញព្រះតថាគត មិនមែនជាមិនបានឃើញទេ បានស្តាប់ធម៌វិន័យដែលព្រះតថាគតសម្តែងហើយ

ជោ អលភន្តោ ឱក្កមតិ និយាមំ កុសលេសុ ធម្មេសុ សម្មត្តំ ឥមំ ខោ ភិក្ខវេ បុគ្គលំ បដិច្ច ធម្មទេសនា អនុញ្ញាតា ឥមញ្ច បន ភិក្ខវេ បុគ្គលំ បដិច្ច អញ្ញេសំបិ ធម្មោ ទេសេតព្វោ ។ ឥមេ ខោ ភិក្ខវេ តយោ គិលានុបមា បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[២៣] តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរោតិ ។ សោ សព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈំ លោកំ ឧបបជ្ជតិ តមេនំ សព្យាបជ្ឈំ លោកំ ឧបបន្នំ[១] សមានំ សព្យាបជ្ឈា ផស្សា ផុសន្តិ ។ សោ សព្យាបជ្ឈេហិ ផស្សេហិ ផុដ្ឋោ សមានោ សព្យាបជ្ឈំ វេទនំ វេទិយតិ ឯកន្តទុក្ខំ

---

១ ឱ. ឧប្បន្នំ ។

មិនមែនជាមិនបានស្តាប់ទេ រមែងចុះស៊ប់កាន់សេចក្តីនិយមដ៏គាប់ប្រសើរ ក្នុងកុសលធម៌ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ធម្មទេសនាដែលព្រះតថាគតអនុញ្ញាតហើយ ព្រោះអាស្រ័យបុគ្គលនេះ ម្នាលភិក្ខុទាំងឡាយមួយវិញទៀត ធម៌ដែលព្រះតថាគត គប្បីសម្តែងដល់ភិក្ខុទាំងឡាយឯទៀតសោតក៏ព្រោះអាស្រ័យបុគ្គលនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៣ ពួកនេះ មានសេចក្តីប្រៀបដូចអ្នកជំងឺ រមែងមាននៅក្នុងលោក ។

[២៣] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រមូលមកនូវកាយសង្ខារប្រកបដោយទុក្ខ ប្រមូលមកនូវវចីសង្ខារប្រកបដោយទុក្ខ ប្រមូលមកនូវមនោសង្ខារប្រកបដោយទុក្ខ ។ បុគ្គលនោះ លុះប្រមូលមកនូវកាយសង្ខារប្រកបដោយទុក្ខ ប្រមូលមកនូវវចីសង្ខារប្រកបដោយទុក្ខ ប្រមូលមកនូវមនោសង្ខារប្រកបដោយទុក្ខហើយ រមែងចូលទៅកាន់លោកប្រកបដោយទុក្ខ ផស្សៈដែលប្រកបដោយទុក្ខទាំងឡាយ រមែងពាល់ត្រូវនូវបុគ្គលដែលចូលទៅកាន់លោកប្រកបដោយទុក្ខនោះ ។ បុគ្គលនោះ កាលដែលផស្សៈប្រកបដោយទុក្ខពាល់ត្រូវហើយ រមែងទទួលវេទនាប្រកបដោយទុក្ខមានទុក្ខតែម្យ៉ាង

៤១



សេយ្យថាបិ សត្តា នេរយិកា ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ អព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរោតិ អព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរោតិ អព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរោតិ ។ សោ អព្យាបជ្ឈំ កាយសង្ខារំ អភិសង្ខរិត្វា អព្យាបជ្ឈំ វចីសង្ខារំ អភិសង្ខរិត្វា អព្យាបជ្ឈំ មនោសង្ខារំ អភិសង្ខរិត្វា អព្យាបជ្ឈំ លោកំ ឧបបជ្ជតិ ។ តមេនំ អព្យាបជ្ឈំ លោកំ ឧបបន្នំ សមានំ អព្យាបជ្ឈា ផស្សា ផុសន្តិ ។ សោ អព្យាបជ្ឈេហិ ផស្សេហិ ផុដ្ឋោ សមានោ អព្យាបជ្ឈំ វេទនំ វេទិយតិ ឯកន្តសុខំ សេយ្យថាបិ ទេវា សុភកិណ្ហា ។ ឥធ បន ភិក្ខវេ ឯកច្ចោ បុគ្គលោ សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ កាយសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ វចីសង្ខារំ អភិសង្ខរោតិ សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ មនោសង្ខារំ អភិសង្ខរោតិ ។

ដូចពួកសត្វដែលកើតក្នុងនរក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រមូលមកនូវកាយសង្ខារ មិនប្រកបដោយទុក្ខ ប្រមូលមកនូវវចីសង្ខារ មិនប្រកបដោយទុក្ខ ប្រមូលមកនូវមនោសង្ខារ មិនប្រកបដោយទុក្ខ ។ បុគ្គលនោះ លុះប្រមូលមកនូវកាយសង្ខារ មិនប្រកបដោយទុក្ខ ប្រមូលមកនូវវចីសង្ខារ មិនប្រកបដោយទុក្ខ ប្រមូលមកនូវមនោសង្ខារ មិនប្រកបដោយទុក្ខហើយ រមែងចូលទៅកាន់លោកដែលមិនប្រកបដោយទុក្ខ ។ ផស្សៈទាំងឡាយ ដែលមិនប្រកបដោយទុក្ខ ពាល់ត្រូវនូវបុគ្គលដែលចូលទៅកាន់លោក មិនប្រកបដោយទុក្ខនោះ ។ បុគ្គលនោះ កាលដែលផស្សៈ មិនប្រកបដោយទុក្ខពាល់ត្រូវហើយ រមែងទទួលវេទនា មិនប្រកបដោយទុក្ខ មានសុខតែម្យ៉ាង ដូចទេវតាជាន់សុភកិណ្ហៈ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រមូលមកនូវកាយសង្ខារ ប្រកបដោយទុក្ខខ្លះ ឥតមានទុក្ខខ្លះ ប្រមូលមកនូវវចីសង្ខារ ប្រកបដោយទុក្ខខ្លះ ឥតមានទុក្ខខ្លះ ប្រមូលមកនូវមនោសង្ខារ ប្រកបដោយទុក្ខខ្លះ ឥតមានទុក្ខខ្លះ ។

សោ សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ កាយសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ វចីសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ មនោសង្ខារំ អភិសង្ខរិត្វា សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ លោកំ ឧបបជ្ជតិ ។ តមេនំ សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ លោកំ ឧបបន្នំ សមានំ សព្យាបជ្ឈាបិ អព្យាបជ្ឈាបិ ផស្សា ផុសន្តិ ។ សោ សព្យាបជ្ជេហិបិ អព្យាបជ្ជេហិបិ ផស្សេហិ ផុដ្ឋោ សមានោ សព្យាបជ្ឈម្បិ អព្យាបជ្ឈម្បិ វេទនំ វេទិយតិ វោកិណ្ណសុខទុក្ខំ[១] សេយ្យថាបិ មនុស្សា ឯកច្ចេ ច ទេវា ឯកច្ចេ ច វិនិបាតិកា ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[២៤] តយោមេ ភិក្ខវេ បុគ្គលា បុគ្គលស្ស ពហុការា[២] ។ កតមេ តយោ ។ យំ ភិក្ខវេ បុគ្គលំ អាគម្ម បុគ្គលោ ពុទ្ធំ សរណំ គតោ ហោតិ ធម្មំ សរណំ គតោ ហោតិ សង្ឃំ សរណំ គតោ ហោតិ អយំ ភិក្ខវេ បុគ្គលោ ឥមស្ស បុគ្គលស្ស ពហុការោ ។

១ ឱ. វោ កិណ្ណំ សុខទុក្ខំ ។ ២ ម. ពហុបការា ។

បុគ្គលនោះ លុះប្រមូលមកនូវកាយសង្ខារ ប្រកបដោយទុក្ខខ្លះ ឥតមានទុក្ខខ្លះ ប្រមូលមកនូវវចីសង្ខារ ប្រកបដោយទុក្ខខ្លះ ឥតមានទុក្ខខ្លះ ប្រមូលមកនូវមនោសង្ខារ ប្រកបដោយទុក្ខខ្លះ ឥតមានទុក្ខខ្លះហើយ រមែងចូលទៅកាន់លោកប្រកបដោយទុក្ខខ្លះ ឥតមានទុក្ខខ្លះ ។ ផស្សៈទាំងឡាយដែលប្រកបដោយទុក្ខខ្លះ ឥតមានទុក្ខខ្លះ រមែងពាល់ត្រូវនូវបុគ្គលដែលចូលទៅកាន់លោក ប្រកបដោយទុក្ខខ្លះ ឥតមានទុក្ខខ្លះនោះ ។ បុគ្គលនោះកាលដែលផស្សៈប្រកបដោយទុក្ខខ្លះ ឥតមានទុក្ខខ្លះ ពាល់ត្រូវហើយ រមែងទទួលវេទនា ប្រកបដោយទុក្ខខ្លះ ឥតមានទុក្ខខ្លះ មានសុខនិងទុក្ខប្រឡូកប្រឡំគ្នា ដូចមនុស្សនិងទេវតាពួកខ្លះ វិនិបាតពួកខ្លះ[១] ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។

[២៤] ម្នាលភិក្ខុទាំងឡាយ បុគ្គល (ជាអាចារ្យ) មាន ៣ ពួកនេះ មានឧបការៈច្រើនដល់បុគ្គល (ជាសិស្ស) ។ បុគ្គល ៣ ពួកតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ព្រោះអាស្រ័យបុគ្គលណា ម្នាលភិក្ខុទាំង-ឡាយ បុគ្គលនេះឈ្មោះថា មានឧបការៈច្រើន ដល់បុគ្គលនេះ ។

១ វេមានិកប្រេត ។ (អដ្ឋកថា) ។

៤៣



បុន ចបរំ ភិក្ខវេ យំ បុគ្គលំ អាគម្ម បុគ្គលោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខ-សមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោ-ធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ អយំ ភិក្ខវេ បុគ្គលោ ឥមស្ស បុគ្គលស្ស ពហុការោ ។ បុន ចបរំ ភិក្ខវេ យំ បុគ្គលំ អាគម្ម បុគ្គលោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ អយំ ភិក្ខវេ បុគ្គលោ ឥមស្ស បុគ្គលស្ស ពហុការោ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា បុគ្គលស្ស ពហុការា ។ ឥមេហិ ច បន ភិក្ខវេ តីហិ បុគ្គលេហិ ឥមស្ស បុគ្គលស្ស នត្ថញ្ញោ បុគ្គលោ ពហុការតរោតិ[១] វទាមិ ។ ឥមេសញ្ច បន ភិក្ខវេ តិណ្ណំ បុគ្គលានំ ឥមិនា បុគ្គលេន ន សុប្បដិការំ វទាមីតិ យទិទំ អភិវាទន-បច្ចុដ្ឋានអញ្ជលិកម្មសាមីចិកម្មចីវរបិណ្ឌបាតសេនាសនគិលាន-បច្ចយភេសជ្ជបរិក្ខារានុប្បទានេនាតិ ។

១ ម. ពហុបការោតិ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីកើតឡើងនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះជាសេចក្ដីរលត់ទៅនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ព្រោះអាស្រ័យបុគ្គលណា ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះហៅថា មានឧបការៈច្រើនដល់បុគ្គលនេះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តនៅ ព្រោះអាស្រ័យបុគ្គលណា ម្នាលភិក្ខុទាំងឡាយ បុគ្គលនេះឈ្មោះថា មានឧបការៈច្រើនដល់បុគ្គលនេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះឈ្មោះថា មានឧបការៈច្រើនដល់បុគ្គល ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត តថាគតពោលថា បុគ្គលឯទៀត មានឧបការៈច្រើនដល់បុគ្គលនេះ លើសជាងបុគ្គលទាំង ៣ ពួកនេះទៅទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត តថាគតពោលថា បុគ្គលនេះមិនងាយនឹងតបគុណដល់បុគ្គលទាំង ៣ ពួកនេះ ដោយការថ្វាយបង្គំ ការក្រោកទទួល ការធ្វើអញ្ជលិកម្ម សាមីចិកម្ម និងការប្រគេនចីវរ បិណ្ឌបាត សេនាសនៈ និងគ្រឿងបរិក្ខារជាបច្ច័យដល់អ្នកជំងឺបានទេ ។

[២៥] តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ អរុកូបមចិត្តោ បុគ្គលោ វិជ្ជូបមចិត្តោ បុគ្គលោ វជិរូបមចិត្តោ បុគ្គលោ ។ កតមោ ច ភិក្ខវេ អរុកូបមចិត្តោ បុគ្គលោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ កោធនោ ហោតិ ឧបាយាសពហុលោ អប្បម្បិ វុត្តោ សមានោ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ សេយ្យថាបិ[១] ភិក្ខវេ ទុដ្ឋារុកោ កដ្ឋេន វា កឋលាយ វា ឃដ្ដិតោ ភិយ្យោសោ មត្តាយ អាសវំ[២] ទេតិ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ កោធនោ ហោតិ ឧបាយាសពហុលោ អប្បម្បិ វុត្តោ សមានោ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ អយំ វុច្ចតិ ភិក្ខវេ អរុកូបមចិត្តោ បុគ្គលោ ។ កតមោ ច ភិក្ខវេ វិជ្ជូបមចិត្តោ បុគ្គលោ ។

---

១ ឱ. សេយ្យថាបិ នាម ទុដ្ឋារុកោ ។ ២ ម. អស្សវំ ។

[២៩] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួក តើដូចម្តេច ។ គឺបុគ្គលមានចិត្តប្រៀបដូចដំបៅចាស់ ១ បុគ្គលមានចិត្តប្រៀបដូចផ្លេកបន្ទោរ ១ បុគ្គលមានចិត្តប្រៀបដូចពេជ្រ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានចិត្តប្រៀបដូចដំបៅចាស់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកក្រោធច្រើនដោយសេចក្តីតានតឹង សូម្បីគេពោលតែបន្តិចបន្តួច ក៏ជាប់ចិត្តក្រោធព្យាបាទ ប្រកាន់រឹងត្អឹង ធ្វើសេចក្តីក្រោធ ទោសៈនិងសេចក្តីមិនសប្បាយចិត្តឲ្យកើតប្រាកដឡើង ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដំបៅចាស់ ដែលត្រូវប៉ះទង្គិចដោយកំណាត់ឈើឬអំបែង រមែងក្លាយឡើងលើសប្រមាណមានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកក្រោធ ច្រើនដោយសេចក្តីតានតឹង សូម្បីគេពោលតែបន្តិចបន្តួច ក៏ចាប់ចិត្តក្រោធ ព្យាបាទ ប្រកាន់រឹងត្អឹង ធ្វើសេចក្តីក្រោធ ទោសៈនិងសេចក្តីមិនសប្បាយចិត្តឲ្យកើតប្រាកដឡើង ក៏មានឧបមេយ្យដូច្នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានចិត្តប្រៀបដូចដំបៅចាស់ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានចិត្តប្រៀបដូចផ្លេកបន្ទោរ តើដូចម្តេច ។

៥៤



ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ សេយ្យថាបិ ភិក្ខវេ ចក្ខុមា បុរិសោ រត្តន្ធការតិមិសាយ វិជ្ជន្តរិកាយ រូបានិ បស្សេយ្យ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ... អយំ ទុក្ខ-និរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ អយំ វុច្ចតិ ភិក្ខវេ វិជ្ជូបមចិត្តោ បុគ្គលោ ។ កតមោ ច ភិក្ខវេ វជិរូបមចិត្តោ បុគ្គលោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ សេយ្យថាបិ ភិក្ខវេ វជិរស្ស នត្ថិ កិញ្ចិ អភេជ្ជំ មណិ វា បាសាណោ វា

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុជាទីកើតឡើងនៃទុក្ខ ដឹងច្បាស់តាមពិតថា នេះជាសេចក្ដីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសមានចក្ខុ គប្បីឃើញនូវរូបទាំងឡាយ ក្នុងខណៈដែលមានផ្លេកបន្ទោរភ្លែតៗ ក្នុងវេលាយប់ងងឹតសូន្យឈឹងយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ... ដឹងច្បាស់តាមពិតថា នេះបដិបទា ជាដំណើរទៅកាន់ទីរំលត់ទុក្ខ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានចិត្តប្រៀបដូចផ្លេកបន្ទោរ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានចិត្តប្រៀបដូចពេជ្រ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្នសម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាវត្ថុអ្វីមួយគឺកែវមណី ឬ ថ្ម ជាវត្ថុដែលពេជ្របំបែកចេញមិនបាននោះ មិនមានឡើយ

ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ អាសវានំ ខយា... ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ វជិរូបមចិត្តោ បុគ្គលោ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[២៦] តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ អត្ថិ ភិក្ខវេ បុគ្គលោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ អត្ថិ ភិក្ខវេ បុគ្គលោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ អត្ថិ ភិក្ខវេ បុគ្គលោ សក្កត្វា គរុកត្វា សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ ។ កតមោ ច ភិក្ខវេ បុគ្គលោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ហីនោ ហោតិ សីលេន សមាធិនា បញ្ញាយ ឯវរូបោ ភិក្ខវេ បុគ្គលោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ អញ្ញត្រ អនុទយា អញ្ញត្រ អនុកម្បា ។

យ៉ាងណា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ព្រោះអស់អាសវៈទាំងឡាយសម្រេចសម្រាន្តនៅ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា បុគ្គលមានចិត្តប្រៀបដូចពេជ្រ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។

[២៦] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេមិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ១ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលដែលគេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព ហើយទើបសេព គប់រក ចូលទៅអង្គុយជិត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលគេមិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកសាបសូន្យចាកសីល សមាធិ បញ្ញា ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ គេមិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត លើកលែងតែមានសេចក្តីអាណិត ឬលើកលែងតែមានសេចក្តីអនុគ្រោះចេញ ។

## ៤៧



កតមោ ច ភិក្ខវេ បុគ្គលោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សទិសោ ហោតិ សីលេន សមាធិនា បញ្ញាយ ឯវរូបោ ភិក្ខវេ បុគ្គលោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ ។ តំ កិស្ស ហេតុ ។ សីលសាមញ្ញគតានំ សតំ សីលកថា ច នោ ភវិស្សតិ សា ច នោ បវត្តនី ភវិស្សតិ សា ច នោ ផាសុ ភវិស្សតិ សមាធិសាមញ្ញគតានំ សតំ សមាធិកថា ច នោ ភវិស្សតិ សា ច នោ បវត្តនី ភវិស្សតិ សា ច នោ ផាសុ ភវិស្សតិ បញ្ញាសាមញ្ញគតានំ សតំ បញ្ញាកថា ច នោ ភវិស្សតិ សា ច នោ បវត្តនី ភវិស្សតិ សា ច នោ ផាសុ ភវិស្សតីតិ ។ តស្មា ឯវរូបោ បុគ្គលោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ ។ កតមោ ច ភិក្ខវេ បុគ្គលោ សក្កត្វា គរុកត្វា សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ ។

ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលគេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកស្មើគ្នា ដោយសីល សមាធិ បញ្ញា ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ដែលគេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះគេគិតថា សីលកថា របស់ពួកសប្បុរសអ្នកមានសីលស្មើគ្នានឹងមានដល់ពួកយើងផង សីលកថានោះ នឹងមានសេចក្តីចម្រើនដល់ពួកយើងផង សីលកថានោះ នឹងនាំឲ្យបានសុខដល់ពួកយើងផង សមាធិកថា របស់ពួកសប្បុរស អ្នកមានសមាធិស្មើគ្នា នឹងមានដល់ពួកយើងផង សមាធិកថានោះ នឹងមានសេចក្តីចម្រើនដល់ពួកយើងផង សមាធិកថានោះ នឹងនាំឲ្យបានសេចក្តីសុខដល់ពួកយើងផង បញ្ញា-កថារបស់ពួកសប្បុរស អ្នកមានបញ្ញាស្មើគ្នា នឹងមានដល់ពួកយើងផង បញ្ញាកថានោះ នឹងមានសេចក្តីចម្រើនដល់ពួកយើងផង បញ្ញាកថានោះ នឹងនាំឲ្យបានសេចក្តីសុខដល់ពួកយើងផង ។ ហេតុនោះ បុគ្គលមានសភាពយ៉ាងនេះ ដែលគេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលគេគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរពហើយទើបសេពគប់ ចូលទៅអង្គុយជិត តើដូចម្តេច ។

៩៨ ភិក្ខវេ ឯកច្ចោ បុគ្គលោ អធិកោ ហោតិ សីលេន សមាធិនា បញ្ញាយ ឯវរូបោ ភិក្ខវេ បុគ្គលោ សក្កត្វា គរុកត្វា សេវិតព្វោ ភជិតព្វោ បយិរុ-ចាសិតព្វោ ។ តំ កិស្ស ហេតុ ។ ឥតិ អបរិ-បូរំ វា សីលក្ខន្ធំ បរិបូរេស្សាមិ បរិបូរំ វា សីល-ក្ខន្ធំ តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមិ អបរិបូរំ វា សមាធិក្ខន្ធំ បរិបូរេស្សាមិ បរិបូរំ វា សមាធិក្ខន្ធំ តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមិ អបរិបូរំ វា បញ្ញាខន្ធំ បរិបូរេស្សាមិ បរិបូរំ វា បញ្ញាខន្ធំ តត្ថ តត្ថ បញ្ញាយ អនុគ្គហេស្សាមីតិ ។ តស្មា ឯវរូបោ បុគ្គលោ សក្កត្វា គរុកត្វា សេវិតព្វោ ភជិតព្វោ បយិរុចាសិតព្វោ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

និហីយតិ បុរិសោ និហីនសេវី
ន ច ហាយេថ កទាចិ តុល្យសេវី
សេដ្ឋមុបនមំ ឧទេតិ ខិប្បំ
តស្មា អត្តនោ ឧត្តរឹ ភជេថាតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកលើសដោយសីល សមាធិ បញ្ញា ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ដែលគួរធ្វើសក្ការៈ ធ្វើសេចក្ដីគោរព ហើយទើបសេពគប់ ចូលទៅអង្គុយជិត ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះគេគិតថា អាត្មាអញនឹងបំពេញសីលក្ខន្ធ ដែលមិនទាន់បរិបូណ៌ ឲ្យបរិបូណ៌ឡើងផង នឹងអនុគ្រោះសីលក្ខន្ធ ដែលបរិបូណ៌ហើយក្នុងទីនោះៗ ដោយបញ្ញាផង នឹងបំពេញសមាធិក្ខន្ធ ដែលមិនទាន់បរិបូណ៌ ឲ្យបរិបូណ៌ឡើងផង នឹងអនុគ្រោះសមាធិក្ខន្ធដែលបរិបូណ៌ហើយ ក្នុងទីនោះៗ ដោយបញ្ញាផង នឹងបំពេញបញ្ញាខន្ធដែលមិនទាន់បរិបូណ៌ ឲ្យបរិបូណ៌ឡើងផង នឹងអនុគ្រោះបញ្ញាខន្ធដែលបរិបូណ៌ហើយក្នុងទីនោះៗ ដោយបញ្ញាផង ។ ហេតុនោះ បុគ្គលមានសភាពយ៉ាងនេះ ដែលគេគួរធ្វើសក្ការៈ ធ្វើសេចក្ដីគោរព ហើយទើបសេពគប់ ចូលទៅអង្គុយជិត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។

បុរសអ្នកសេពគប់បុគ្គលថោកទាប រមែងសាបសូន្យ បើសេពគប់បុគ្គលស្មើគ្នា មិនគប្បីសាបសូន្យ ក្នុងកាលណាឡើយ បើបុរសចូលទៅគប់រកបុគ្គលដែលប្រសើរ (ជាងខ្លួន) រមែងចម្រើនឆាប់ ព្រោះហេតុនោះ បុរសគួរគប់នឹងបុគ្គលដែលប្រសើរលើសខ្លួន (ទើបប្រសើរ) ។

បឋមបណ្ណាសកេ បុគ្គលវគ្គោ

[២៧] តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ អត្ថិ ភិក្ខវេ បុគ្គលោ ជិគុច្ឆិតព្វោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ អត្ថិ ភិក្ខវេ បុគ្គលោ អជ្ឈុបេក្ខិតព្វោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ អត្ថិ ភិក្ខវេ បុគ្គលោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ ។ កតមោ ច ភិក្ខវេ បុគ្គលោ ជិគុច្ឆិតព្វោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ទុស្សីលោ ហោតិ បាបធម្មោ អសុចិ សំកស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្សមណោ សមណប្បដិញ្ញោ អព្រហ្មចារី ព្រហ្មចារិប្បដិញ្ញោ អន្តោបូតិ អវស្សុតោ កសម្ពុជាតោ ។ ឯវរូបោ ភិក្ខវេ បុគ្គលោ ជិគុច្ឆិតព្វោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ ។ តំ កិស្ស ហេតុ ។

[២៧] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួកតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេគួរខ្ពើម មិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេគួរព្រងើយកន្តើយ មិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលគេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលគួរខ្ពើម មិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក មិនស្អាត មានកិរិយាមារយាទប្រកបដោយសេចក្តីរង្កៀស មានការលាក់លៀមទុក មិនមែនជាសមណៈ ប្តេជ្ញាថាជាសមណៈ មិនមែនជាព្រហ្មចារី ប្តេជ្ញាថាជាព្រហ្មចារី ស្អុយខាងក្នុង មានចិត្តជោកជាំដោយរាគៈ មានចិត្តជ្រោកជ្រាក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ឈ្មោះថាជាបុគ្គលដែលគេគួរខ្ពើម មិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ។ ដំណើរនោះ ព្រោះហេតុអ្វី ។

កិញ្ចាបិ ភិក្ខវេ ឯវរូបស្ស បុគ្គលស្ស ន ទិដ្ឋា-
នុគតឹ អាបជ្ជតិ អថខោ នំ បាបកោ កិត្តិសទ្ទោ
អព្ភុគ្គច្ឆតិ បាបមិត្តោ បុរិសបុគ្គលោ បាបសហាយោ
បាបសម្បវង្កោតិ ។ សេយ្យថាបិ ភិក្ខវេ អហិ
គូថគតោ កិញ្ចាបិ ន ឌំសតិ[១] អថខោ នំ មក្ខេតិ
ឯវមេវ ខោ ភិក្ខវេ កិញ្ចាបិ ឯវរូបស្ស បុគ្គលស្ស
ន ទិដ្ឋានុគតឹ អាបជ្ជតិ អថខោ នំ បាបកោ
កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ បាបមិត្តោ បុរិសបុគ្គលោ
បាបសហាយោ បាបសម្បវង្កោតិ ។ តស្មា ឯវរូបោ
បុគ្គលោ ជិគុច្ឆិតព្វោ ន សេវិតព្វោ ន ភជិតព្វោ
ន បយិរុបាសិតព្វោ ។ កតមោ ច ភិក្ខវេ
បុគ្គលោ អជ្ឈុបេក្ខិតព្វោ ន សេវិតព្វោ ន
ភជិតព្វោ ន បយិរុបាសិតព្វោ ។ ឥធ ភិក្ខវេ
ឯកច្ចោ បុគ្គលោ កោធនោ ហោតិ ឧបាយាស-
ពហុលោ អប្បម្បិ វុត្តោ សមានោ អភិសជ្ជតិ

១ ឱ. ម. ឌស្សតិ ។ ម. បស្សតិ ។

ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលមិនលុះទៅតាមដំណើរទិដ្ឋិ របស់បុគ្គលមានសភាពយ៉ាងនេះ ក៏ពិតមែនហើយ ប៉ុន្តែថាបុគ្គលនោះ គង់មានកិត្តិសព្ទដ៏លាមកល្បីឡើងថា បុរសបុគ្គលមានមិត្តអាក្រក់ មានសំឡាញ់អាក្រក់ មានគូកនអាក្រក់ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាពស់លូនទៅក្នុងលាមក ទុកជាមិនចឹកក៏ពិតមែន ប៉ុន្តែថាលាមកគង់ប្រឡាក់ពស់នោះ មិនខានយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលុះទៅតាមដំណើរទិដ្ឋិរបស់បុគ្គលមានសភាពយ៉ាងនេះ ក៏ពិតមែន ប៉ុន្តែថា បុគ្គលនោះមានកិត្តិស័ព្ទដ៏លាមកល្បីឡើងថា បុរសបុគ្គលមានមិត្តអាក្រក់ មានសំឡាញ់អាក្រក់ មានគូកនអាក្រក់ក៏យ៉ាងនោះដែរ ។ ព្រោះហេតុនោះ បុគ្គលមានសភាពយ៉ាងនេះ ឈ្មោះថា ជាបុគ្គលដែលគេគួរខ្ពើម មិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលគេគួរព្រងើយកន្តើយ មិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកក្រោធច្រើនដោយសេចក្តីតានតឹង សូម្បីគេនិយាយតែបន្តិចបន្តួច ក៏ជាប់ចិត្ត

កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច ចាតុករោតិ ។ សេយ្យថាបិ ភិក្ខវេ ទុដ្ឋារុកោ កដ្ឋេន វា កឋលាយ វា ឃដ្ដិតោ ភិយ្យោសោ មត្តាយ អាសវំ ទេតិ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ កោធនោ ហោតិ ឧបាយាសពហុលោ អប្បម្បិ វុត្តោ សមានោ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ សេយ្យ-ថាបិ ភិក្ខវេ តិណ្ឌុកាលាតំ កដ្ឋេន វា កឋលាយ វា ឃដ្ដិតំ[១] ភិយ្យោសោ មត្តាយ ចិចិដាយតិ ចិដិចិដាយតិ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ កោធនោ ហោតិ ឧបាយាស-ពហុលោ អប្បម្បិ វុត្តោ សមានោ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ សេយ្យថាបិ ភិក្ខវេ គូថកូបោ កដ្ឋេន វា កឋលាយ វា ឃដ្ដិតោ

១ ម. ឃដិតោ ។

ក្រោធ ព្យាបាទ ប្រកាន់រឹងត្អឹងធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនសប្បាយចិត្ត ឲ្យប្រាកដឡើង ។ ម្នាលភិក្ខុទាំងឡាយ ដូចជាដំបៅចាស់ដែលត្រូវប៉ះទង្គិច ដោយកំណាត់ឈើ ឬអំបែង រមែងក្លាយឡើង លើសប្រមាណយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះជាអ្នកក្រោធ ច្រើនដោយសេចក្តីតានតឹង សូម្បីគេនិយាយតែបន្តិចបន្តួច ក៏ជាប់ចិត្ត ក្រោធ ព្យាបាទ ប្រកាន់រឹងត្អឹង ធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនសប្បាយចិត្ត ឲ្យប្រាកដឡើងយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ដូចជាអង្កត់ភ្លើងឧសដង្កោ ដែលគេកៀសដោយកំណាត់ឈើ ឬអំបែង រមែងធ្វើសំឡេងឮចិចិដៈ[១] ធ្វើសំឡេងឮចិដិចិដៈ ដោយក្រៃលែងលើសប្រមាណយ៉ាងណា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកក្រោធ ច្រើនដោយសេចក្តីតានតឹង សូម្បីគេនិយាយបន្តិចបន្តួចក៏ជាប់ចិត្តក្រោធ ព្យាបាទ ប្រកាន់រឹងត្អឹង ធ្វើសេចក្តីក្រោធ ទោសៈ និងសេចក្តីមិនសប្បាយចិត្តឲ្យប្រាកដឡើង ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំង-ឡាយ ដូចជារណ្តៅ លាមកដែលបុគ្គលត្ពឹះ ដោយកំណាត់ឈើឬអំបែង

---

១ សំឡេងផ្ទុះប្រែះៗ ព្រូសរងើកចេញ ។

៦២



ភិយ្យោសោ មត្តាយ ទុគ្គន្ធោ ហោតិ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ កោធនោ ហោតិ ឧបាយាសពហុលោ អប្បម្បិ វុត្តោ សមានោ អភិសជ្ជតិ កុប្បតិ ព្យាបជ្ជតិ បតិត្ថីយតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។ ឯវរូបោ ភិក្ខវេ បុគ្គលោ អជ្ឈុបេក្ខិតព្វោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ ។ តំ កិស្ស ហេតុ ។ អក្កោសេយ្យបិ មំ បរិភា-សេយ្យបិ មំ អនត្ថម្បិ មំ ករេយ្យាតិ ។ តស្មា ឯវរូបោ បុគ្គលោ អជ្ឈុបេក្ខិតព្វោ ន សេវិតព្វោ ន ភជិតព្វោ ន បយិរុបាសិតព្វោ ។ កតមោ ច ភិក្ខវេ បុគ្គលោ សេវិតព្វោ ភជិតព្វោ បយិរុបាសិ-តព្វោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សីលវា ហោតិ កល្យាណធម្មោ ។ ឯវរូបោ ភិក្ខវេ បុគ្គលោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ ។

រមែងមានក្លិនស្អុយដោយក្រៃលែងលើសប្រមាណ យ៉ាងណា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកក្រោធ ច្រើនដោយសេចក្ដីតានតឹង សូម្បីតែគេនិយាយបន្តិចបន្តួច ក៏ជាប់ចិត្តក្រោធ ព្យាបាទ ប្រកាន់រឹងត្អឹង ធ្វើសេចក្ដីក្រោធ ទោសៈ និងសេចក្ដីមិនសប្បាយចិត្តឲ្យប្រាកដឡើង ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ឈ្មោះថា ជាបុគ្គលដែលគេគួរព្រងើយកន្តើយ មិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះគេគិតថា ជន(នេះ) គប្បីជេរអាត្មាអញខ្លះ ផ្ដាសាអាត្មាអញខ្លះ ធ្វើអាត្មាអញឲ្យខូចប្រយោជន៍ខ្លះ ។ ព្រោះហេតុនោះ បុគ្គលមានសភាពយ៉ាងនេះ ឈ្មោះថា ជាបុគ្គលដែលគេគួរព្រងើយកន្តើយ មិនគួរសេព មិនគួរគប់រក មិនគួរចូលទៅអង្គុយជិត ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលដែលគេគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ មានសីល មានកល្យាណធម៌ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះឈ្មោះថា ជាបុគ្គលគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ។

តំ កិស្ស ហេតុ ។ កិញ្ចាបិ ភិក្ខវេ ឯវរូបស្ស បុគ្គលស្ស ន ទិដ្ឋានុគតឹ អាបជ្ជតិ អថខោ នំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ កល្យាណមិត្តោ បុរិសបុគ្គលោ កល្យាណសហាយោ កល្យាណ-សម្បវង្កោតិ ។ តស្មា ឯវរូបោ បុគ្គលោ សេវិតព្វោ ភជិតព្វោ បយិរុបាសិតព្វោ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

និហីយតិ បុរិសោ និហីនសេវី
ន ច ហាយេថ កទាចិ តុល្យសេវី
សេដ្ឋមុបនមំ[១] ឧទេតិ ខិប្បំ
តស្មា អត្តនោ ឧត្តរឹ ភជេថាតិ ។

[២៨] តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ គូថភាណី បុប្ផភាណី មធុភាណី ។

---
១ ម. សេដ្ឋមុន្នមំ ។

ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនលុះទៅតាមដំណើរទិដ្ឋិរបស់បុគ្គលមានសភាពយ៉ាងនេះ ក៏ពិតមែន ប៉ុន្តែបុគ្គលនោះ គង់មានកិត្តិស័ព្ទដ៏ពីរោះល្បីឡើងថា បុរសបុគ្គលមានមិត្តល្អ មានសំឡាញ់ល្អ មានគូកនល្អ ។ ព្រោះហេតុនោះ បុគ្គលមានសភាពយ៉ាងនេះ ឈ្មោះថាជាបុគ្គលគួរសេព គួរគប់រក គួរចូលទៅអង្គុយជិត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។

បុរសអ្នកសេពគប់បុគ្គលថោកទាប រមែងសាបសូន្យ បើសេពគប់បុគ្គលស្មើគ្នា មិនគប្បីសាបសូន្យ ក្នុងកាលណាឡើយ បុរសចូលទៅគប់រកបុគ្គលប្រសើរ (ជាងខ្លួន) រមែងចម្រើនឆាប់ ព្រោះហេតុនោះ បុរសគួរគប់រកនឹងបុគ្គលដ៏ប្រសើរលើសខ្លួន (ទើបប្រសើរ) ។

[២៨] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួក តើដូចម្ដេច ។ គឺបុគ្គលមានសម្ដីស្អុយដូចលាមក ១ បុគ្គលមានសម្ដីក្រអូបដូចផ្កា ១ បុគ្គលមានសម្ដីផ្អែមដូចទឹកឃ្មុំ ១ ។

កតមោ ច ភិក្ខវេ បុគ្គលោ គូថភាណី ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សភាគតោ វា បរិសគតោ វា ញាតិមជ្ឈគតោ វា បូគមជ្ឈគតោ វា រាជកុលមជ្ឈគតោ វា អភិនីតោ សក្ខិ បុដ្ឋោ ឯហម្ភោ[១] បុរិស យំ ជានាសិ[២] តំ វទេហីតិ ។ សោ អជានំ វា អាហ[៣] ជានាមីតិ ជានំ វា អាហ ន ជានាមីតិ អបស្សំ វា អាហ បស្សាមីតិ បស្សំ វា អាហ ន បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា អាមិសកិញ្ចិក្ខហេតុ វា សម្បជានមុសាភាសិតា ហោតិ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ គូថភាណី ។ កតមោ ច ភិក្ខវេ បុគ្គលោ បុប្ផភាណី ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សភាគតោ វា បរិសគតោ វា ញាតិ-មជ្ឈគតោ វា បូគមជ្ឈគតោ វា រាជកុលមជ្ឈគតោ វា អភិនីតោ សក្ខិ បុដ្ឋោ ឯហម្ភោ បុរិស

---

១ ឱ. ឯវម្ភោ ។ ២ ឱ. ជនាសិ ។ ៣ ម. អហំ ។

ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសម្តីស្អុយដូចលាមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ទៅកាន់សភា(ទីប្រជុំ)ក្តី ទៅក្នុងបរិសទ្យក្តី ទៅក្នុងកណ្តាលញាតិក្តី ទៅក្នុងកណ្តាលពួកសេនាក្តី ទៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំទៅធ្វើជាសាក្សីហើយសួរថា ម្នាលបុរសដ៏ចម្រើន អ្នកចូលមកនេះ អ្នកដឹងហេតុណា ចូរនិយាយហេតុនោះ ។ បុរសនោះ កាលមិនដឹងនិយាយថា ខ្ញុំដឹងក្តី កាលដឹងនិយាយថា ខ្ញុំមិនដឹងក្តី កាលមិនឃើញនិយាយថា ខ្ញុំឃើញក្តី កាលឃើញនិយាយថា ខ្ញុំមិនឃើញក្តី ជាអ្នកពោលពាក្យកុហក ដោយដឹងខ្លួន ព្រោះហេតុតែខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុសំណូកបន្តិចបន្តួចក្តី ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានសម្តីស្អុយដូចលាមក ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានសម្តីក្រអូបដូចផ្កា តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ទៅកាន់សភា(ទីប្រជុំ)ក្តី ទៅក្នុងបរិសទ្យក្តី ទៅក្នុងកណ្តាលញាតិក្តី ទៅក្នុងកណ្តាលពួកសេនាក្តី ទៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំទៅធ្វើជាសាក្សីហើយសួរថា ម្នាលបុរសដ៏ចម្រើន

យំ ជានាសិ តំ វទេហីតិ ។ សោ អជានំ វា អាហ ន ជានាមីតិ ជានំ វា អាហ ជានាមីតិ អបស្សំ វា អាហ ន បស្សាមីតិ បស្សំ វា អាហ បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា អាមិស-កិញ្ចិក្ខហេតុ វា ន សម្បជានមុសាភាសិតា ហោតិ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ បុប្ផភាណី ។ កតមោ ច ភិក្ខវេ បុគ្គលោ មធុភាណី ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេឡា កណ្ណសុខា បេមនិយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ មធុភាណី ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

អ្នកចូរមកនេះ អ្នកដឹងហេតុណា ចូរនិយាយហេតុនោះ ។ បុរសនោះ កាលមិនដឹងនិយាយថា ខ្ញុំមិនដឹងក្តី កាលដឹងនិយាយថា ខ្ញុំដឹងក្តី កាលមិនឃើញនិយាយថា ខ្ញុំមិនឃើញក្តី កាលឃើញនិយាយថា ខ្ញុំឃើញក្តី ជាអ្នកមិនពោលពាក្យកុហក ដោយដឹងខ្លួន ព្រោះតែខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុតែសំណូក បន្តិចបន្តួចក្តី ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានសម្តីក្រអូបដូចផ្កា ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុគ្គលមានសម្តីផ្អែមដូចទឹកឃ្មុំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ លះបង់វាចាអាក្រក់ វៀរចាកវាចាអាក្រក់ សម្តីណា ជាសម្តីឥតទោស ជាសុខដល់ត្រចៀក គួរជាទីស្រឡាញ់ ជ្រាបចូលទៅក្នុងដួងចិត្ត ជាសម្តីអ្នកក្រុងដែលជាទីពេញចិត្តនៃជនច្រើន ជាទីគាប់ចិត្តនៃជនច្រើន ជាអ្នកពោលនូវសម្តី មានសភាពដូច្នោះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានសម្តីផ្អែមដូចទឹកឃ្មុំ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។

[២៩] តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ អន្ធោ ឯកចក្ខុ ទ្វិចក្ខុ ។ កតមោ ច ភិក្ខវេ បុគ្គលោ អន្ធោ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស តថារូបំ ចក្ខុ ន ហោតិ យថារូបេន ចក្ខុនា អនធិគតំ វា ភោគំ អធិគច្ឆេយ្យ អធិ-គតំ វា ភោគំ ផាតឹ ករេយ្យ តថារូបម្បិស្ស ចក្ខុ ន ហោតិ យថារូបេន ចក្ខុនា កុសលា-កុសលេ ធម្មេ ជានេយ្យ សាវជ្ជានវជ្ជេ ធម្មេ ជានេយ្យ ហីនប្បណីតេ ធម្មេ ជានេយ្យ កណ្ហសុក្ក-សប្បដិភាគេ ធម្មេ ជានេយ្យ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ អន្ធោ ។ កតមោ ច ភិក្ខវេ បុគ្គលោ ឯកចក្ខុ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស តថារូបំ ចក្ខុ ហោតិ យថារូបេន ចក្ខុនា អនធិគតំ វា ភោគំ អធិគច្ឆេយ្យ អធិគតំ វា ភោគំ ផាតឹ ករេយ្យ

[២៩] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួកតើដូចម្តេច ។ គឺបុគ្គលខ្វាក់ ១ បុគ្គលមានភ្នែកម្ខាង ១ បុគ្គលមានភ្នែកទាំងពីរខាង ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្វាក់តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ គប្បីបាននូវភោគៈដែលខ្លួនមិនធ្លាប់បានក្តី គប្បីធ្វើនូវភោគៈដែលខ្លួនបានហើយឲ្យចម្រើនឡើងក្តី ដោយចក្ខុមានសភាពយ៉ាងណា ចក្ខុមានសភាពយ៉ាងនោះមិនមានឡើយ មួយទៀត បុគ្គលគប្បីដឹងនូវពួកធម៌ ជាកុសលនិងអកុសល ដឹងពួកធម៌ដែលមានទោស និងឥតទោស ដឹងពួកធម៌ថោកទាបនិងឧត្តម ដឹងពួកធម៌ដែលមានចំណែកជាទំនាស់គ្នាដោយអំណាចធម៌ខ្មៅនិងធម៌ស ដោយចក្ខុមានសភាពយ៉ាងណា សូម្បីចក្ខុមានសភាពយ៉ាងនោះ ក៏មិនមានដល់បុគ្គលនោះដែរ ម្នាលភិក្ខុទាំងឡាយ នេះហៅថាបុគ្គលខ្វាក់ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានភ្នែកម្ខាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ គប្បីបានភោគៈដែលខ្លួនមិនធ្លាប់បានក្តី គប្បីធ្វើភោគៈដែលខ្លួនបានហើយ ឲ្យចម្រើនឡើងក្តី ដោយចក្ខុមានសភាពយ៉ាងណា ចក្ខុមានសភាពយ៉ាងនោះ រមែងមាន ។

តថារូបម្បិស្ស ចក្ខុ ន ហោតិ យថារូបេន ចក្ខុនា កុសលាកុសលេ ធម្មេ ជានេយ្យ សាវជ្ជានវជ្ជេ ធម្មេ ជានេយ្យ ហីនប្បណីតេ ធម្មេ ជានេយ្យ កណ្ហសុក្កសប្បដិភាគេ ធម្មេ ជានេយ្យ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ ឯកចក្ខុ ។ កតមោ ច ភិក្ខវេ បុគ្គលោ ទ្វិចក្ខុ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស តថារូបំ ចក្ខុ ហោតិ យថារូបេន ចក្ខុនា អនធិគតំ វា ភោគំ អធិគច្ឆេយ្យ អធិគតំ វា ភោគំ ផាតឹ ករេយ្យ តថារូបម្បិស្ស ចក្ខុ ហោតិ យថារូបេន ចក្ខុនា កុសលាកុសលេ ធម្មេ ជានេយ្យ សាវជ្ជានវជ្ជេ ធម្មេ ជានេយ្យ ហីនប្បណីតេ ធម្មេ ជានេយ្យ កណ្ហសុក្កសប្បដិ-ភាគេ ធម្មេ ជានេយ្យ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ ទ្វិចក្ខុ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

ប៉ុន្តែបុគ្គលនោះ គប្បីដឹងពួកធម៌ជាកុសលនិងអកុសល ដឹងពួកធម៌មានទោស និងឥតទោស ដឹងពួកធម៌ដែលថោកទាបនិងឧត្តម ដឹងពួកធម៌ដែលមានចំណែកជាទំនាស់គ្នា ដោយអំណាចធម៌ខ្មៅនិងធម៌ស ដោយចក្ខុមានសភាពយ៉ាងណា សូម្បីចក្ខុមានសភាពយ៉ាងនោះ ក៏មិនមានឡើយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានភ្នែកម្ខាង ។ ម្នាលភិក្ខុទាំង-ឡាយ ចុះបុគ្គលមានភ្នែកទាំងពីរខាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ គប្បីបាននូវភោគៈដែលខ្លួនមិនធ្លាប់បានក្តី ធ្វើនូវភោគៈដែលខ្លួនបានហើយឲ្យចម្រើនឡើងក្តី ដោយចក្ខុមានសភាពយ៉ាងណា ចក្ខុមានសភាពយ៉ាងនោះក៏មាន មួយទៀត បុគ្គលនោះ គប្បីដឹងពួកធម៌ ជាកុសលនិងអកុសល ដឹងពួកធម៌មានទោសនិងឥតទោស ដឹងពួកធម៌ថោកទាបនិងឧត្តម ដឹងពួកធម៌ដែលមានចំណែកជាទំនាស់គ្នា ដោយអំណាចធម៌ខ្មៅ និងធម៌ស ដោយចក្ខុមានសភាពយ៉ាងណា សូម្បីចក្ខុមានសភាពយ៉ាងនោះក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានចក្ខុទាំងពីរខាង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។

ន ចេវ ភោគា តថារូបា
ន ច បុញ្ញានិ កុព្វតិ[១]
ឧភយត្ថ កលិគ្គហោ
អន្ធស្ស ហតចក្ខុនោ ។
អថាបរាយមក្ខាតោ
ឯកចក្ខុ ច បុគ្គលោ
ធម្មាធម្មេន សំសដ្ឋោ[២]
ភោគានិ បរិយេសតិ
ថេយ្យេន កូដកម្មេន
មុសាវាទេន ចូភយំ
កុសលោ ហោតិ សំហាតុំ[៣]
កាមភោគី ច មាណវោ
ឥតោ សោ និរយំ គន្ត្វា
ឯកចក្ខុ វិហញ្ញតិ ។
ទ្វិចក្ខុ បន អក្ខាតោ
សេដ្ឋោ បុរិសបុគ្គលោ
ធម្មលទ្ធេហិ ភោគេហិ

១ ម. ក្រុព្វតិ ។ ២ ម. ធម្មាធម្មេន សដ្ឋោតិ ។ ៣ ឱ. ម. សំឃាតុំ ។

ភោគៈទាំងឡាយ មានសភាពដូច្នោះ មិនមានដល់បុគ្គលខ្វាក់ឡើយ បុគ្គលខ្វាក់មិនដែលធ្វើបុណ្យទាំងឡាយទេ ការចាប់ខុស ចំពោះប្រយោជន៍ទាំងពីរ រមែងមានដល់បុគ្គលខ្វាក់ខូចចក្ខុ ។ មួយទៀត បុគ្គលដែលហៅថា មានភ្នែកម្ខាងនេះ ជាអ្នកប្រឡូកប្រឡំ ដោយកុសលធម៌និងអកុសលធម៌ ស្វែងរកភោគៈទាំងឡាយ ដោយថេយ្យចិត្ត ជាអ្នកឈ្លាសប្រមូលមក នូវអំពើទាំងពីរ ដោយកូដកម្ម[១] ផង ដោយការពោលពាក្យកុហកផង ជាមនុស្សបរិភោគកាម បុគ្គលដែលមានចក្ខុតែម្ខាងនោះ លុះរំលាយខន្ធ អំពីលោកនេះហើយ ទៅកាន់នរករងទុក្ខខ្លោចផ្សា ។ ចំណែកខាងបុរសបុគ្គល ដែលហៅថា មានចក្ខុទាំងពីរខាង ជាអ្នកប្រសើរ ដោយភោគៈទាំងឡាយ ដែលខ្លួនបានមកដោយធម៌

១ អំពើកៀចក្រាញ ឬ អំពើកោង ។

ឧដ្ឋានាជិកតំ ជនំ
ជនាតិ សេដ្ឋសង្កប្បោ
អព្យគ្គមនសោ នរោ
ឧបេតិ ភទ្ទកាំ ឋានំ
យត្ថ គន្ត្វា ន សោចតិ ។
អន្ធញ្ច ឯកចក្ខុញ្ច
អារកា បរិវជ្ជយេ
ទ្វិចក្ខុំ បន សេវេថ
សេដ្ឋំ បុរិសបុគ្គលន្តិ ។

[៣០] តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ អវកុជ្ជបញ្ញោ បុគ្គលោ ឧច្ឆង្គបញ្ញោ[១] បុគ្គលោ បុថុបញ្ញោ បុគ្គលោ ។ កតមោ ច ភិក្ខវេ អវកុជ្ជបញ្ញោ បុគ្គលោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អារាមំ គន្តា ហោតិ អភិក្ខណំ ភិក្ខូនំ សន្តិកេ ធម្មស្សវនាយ តស្ស ភិក្ខូ ធម្មំ ទេសេន្តិ

១ ម. ឧច្ចង្គបញ្ញោ ។

ឲ្យទ្រព្យដែលខ្លួនរកបាន ដោយសេចក្តីព្យាយាម
មានតម្រិះដ៏ប្រសើរ ជាជនមានចិត្តឥតសង្ស័យ រមែង
ចូលទៅកាន់ស្ថានដ៏ចម្រើន ដែលខ្លួនបានទៅហើយ
មិនសោកសៅ បុគ្គលគប្បីវៀរ មនុស្សខ្វាក់ផង
មនុស្សមានភ្នែកម្ខាងផង អំពីចម្ងាយហើយគប្បីសេព
គប់បុរសបុគ្គលដ៏ប្រសើរ មានភ្នែកទាំងពីរខាងចុះ ។

[៣០] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួក តើដូចម្តេច ។ គឺបុគ្គលមានប្រាជ្ញាដូចជាក្អមផ្កាប់ ១ បុគ្គលមានប្រាជ្ញាដូចថ្នក់លេច ១ បុគ្គលមានប្រាជ្ញាដ៏ទូលាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានប្រាជ្ញាដូចក្អមផ្កាប់ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ទៅកាន់អារាម ស្តាប់ធម៌ក្នុងសំណាក់នៃពួកភិក្ខុរឿយ ៗ ពួកភិក្ខុសម្តែងធម៌

អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសាន-កល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេន្តិ សោ តស្មឹ អាសនេ និសិន្នោ តស្សា កថាយ នេវាទឹ មនសិករោតិ ន មជ្ឈំ មនសិករោតិ ន បរិយោសានំ មនសិករោតិ វុដ្ឋិតោបិ តម្ហា អាសនា តស្សា កថាយ នេវាទឹ មនសិករោតិ ន មជ្ឈំ មនសិករោតិ ន បរិយោសានំ មនសិករោតិ ។ សេយ្យថាបិ ភិក្ខវេ កុម្ភោ និក្កុជ្ជោ តត្រ ឧទកំ អាសិត្តំ វិវដ្ដតិ នោ សណ្ឋាតិ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ អារាមំ គន្តា ហោតិ អភិក្ខណំ ភិក្ខូនំ សន្តិកេ ធម្មស្សវនាយ តស្ស ភិក្ខូ ធម្មំ ទេសេន្តិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានក-ល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេន្តិ សោ តស្មឹ អាសនេ និសិន្នោ តស្សា កថាយ នេវាទឹ មនសិករោតិ ន មជ្ឈំ មនសិករោតិ ន បរិយោសានំ មនសិករោតិ

មានលម្អបទខាងដើម មានលម្អបទកណ្តាល មានលម្អបទខាងចុង ប្រ-កាសព្រហ្មចរិយៈប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ដល់បុគ្គលនោះ បុគ្គលនោះ កាលអង្គុយលើអាសនៈនោះ ក៏មិនធ្វើទុកក្នុងចិត្តត្រង់ខាងដើម មិនធ្វើទុកក្នុងចិត្តត្រង់កណ្តាល មិនធ្វើទុកក្នុងចិត្តត្រង់ខាងចុងនៃកថានោះ សូម្បីក្រោកពីអាសនៈនោះហើយ ក៏មិនធ្វើទុកក្នុងចិត្តត្រង់ខាងដើម ត្រង់កណ្តាលនិងខាងចុងនៃកថានោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាក្អមផ្កាប់ ទឹកដែលគេចាក់ទៅលើក្អមនោះ ក៏ហូរចេញអស់ទៅ មិនដក់នៅបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ទៅកាន់អារាម ស្តាប់ធម៌ក្នុងសំណាក់ នៃភិក្ខុទាំងឡាយរឿយៗ ភិក្ខុទាំងឡាយក៏សំ-ដែងធម៌មានលម្អបទខាងដើម មានលម្អបទកណ្តាល មានលម្អបទខាងចុងហើយប្រកាសព្រហ្មចរិយៈប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ដល់បុគ្គលនោះ បុគ្គលនោះ កាលដែលអង្គុយលើអាសនៈនោះ ក៏មិនធ្វើទុកក្នុងចិត្តត្រង់ខាងដើម មិនធ្វើទុកក្នុងចិត្តត្រង់កណ្តាល មិនធ្វើទុកក្នុងចិត្តត្រង់ខាងចុង នៃកថានោះ

វុដ្ឋិតោបិ តម្ហា អាសនា តស្សា កថាយ នេវាទឹ មនសិករោតិ ន មជ្ឈំ មនសិករោតិ ន បរិយោសានំ មនសិករោតិ អយំ វុច្ចតិ ភិក្ខវេ អវកុជ្ជបញ្ញោ បុគ្គលោ ។ កតមោ ច ភិក្ខវេ ឧច្ឆង្គបញ្ញោ បុគ្គលោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អារាមំ គន្តា ហោតិ អភិក្ខណំ ភិក្ខូនំ សន្តិកេ ធម្មស្សវនាយ តស្ស ភិក្ខូ ធម្មំ ទេសេន្តិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេន្តិ សោ តស្មឹ អាសនេ និសិន្នោ តស្សា កថាយ អាទិម្បិ មនសិករោតិ មជ្ឈម្បិ មនសិករោតិ បរិយោសានម្បិ មនសិករោតិ វុដ្ឋិតោ[១] តម្ហា អាសនា តស្សា កថាយ នេវាទឹ មនសិករោតិ ន មជ្ឈំ មនសិករោតិ ន បរិយោសានំ មនសិករោតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសស្ស ឧច្ឆង្គេ នានាខជ្ជកានិ អាកិណ្ណានិ តិលា តណ្ឌុលា មោទកា ពទរា សោ តម្ហា អាសនា វុដ្ឋហន្តោ

១ ឱ. ម. ឯត្ថន្តរេ ចខោតិ បទំ អត្ថិ ។

ទុកជាក្រោកឡើងអំពីអាសនៈនោះហើយ ក៏នៅតែមិនធ្វើទុកក្នុងចិត្តត្រង់ខាងដើម មិនធ្វើទុកក្នុងចិត្តត្រង់កណ្តាល មិនធ្វើទុកក្នុងចិត្តត្រង់ខាងចុងនៃកថានោះ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានប្រាជ្ញាដូចជាក្អមផ្កាប់ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានប្រាជ្ញាដូចថ្នក់លេច តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ទៅកាន់អារាមស្តាប់ធម៌ក្នុងសំណាក់ភិក្ខុទាំងឡាយរឿយៗ ភិក្ខុទាំង-ឡាយ ក៏សម្តែងធម៌ មានលម្អបទខាងដើម មានលម្អបទកណ្តាល មានលម្អបទខាងចុង ប្រកាសព្រហ្មចរិយៈប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈដ៏បរិសុទ្ធបរិបូណ៌ទាំងអស់ដល់បុគ្គលនោះ បុគ្គលនោះកាលអង្គុយលើអាសនៈនោះធ្វើទុកក្នុងចិត្តត្រង់ខាងដើមផង ធ្វើទុកក្នុងចិត្តត្រង់កណ្តាលផង ធ្វើទុកក្នុងចិត្តត្រង់ខាងចុងផង នៃកថានោះដែរ តែលុះក្រោកចេញអំពីអាសនៈនោះទៅហើយ ក៏មិនធ្វើទុកក្នុងចិត្តត្រង់ខាងដើម មិនធ្វើទុកក្នុងចិត្តត្រង់កណ្តាល មិនធ្វើទុកក្នុងចិត្តត្រង់ខាងចុងនៃកថានោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបង្អែមផ្សេងៗ ដែលលាយច្រឡំគ្នាគឺមានល្ង អង្ករ នំម្សៅផ្លៃពុទ្រា ក្នុងថ្នក់លេចនៃបុរស បុរសនោះកាលក្រោកអំពីអាសនៈនោះ

សតិសម្មោសា បកិរេយ្យ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ អារាមំ គន្តា ហោតិ អភិក្ខណំ ភិក្ខូនំ សន្តិកេ ធម្មស្សវនាយ តស្ស ភិក្ខូ ធម្មំ ទេសេន្តិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោ- សានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេន្តិ សោ តស្មឹ អាសនេ និសិន្នោ តស្សា កថាយ អាទិម្បិ មនសិករោតិ មជ្ឈម្បិ មនសិករោតិ បរិយោសានម្បិ មនសិករោតិ វុដ្ឋិតោបិ តម្ហា អាសនា តស្សា កថាយ នេវាទឹ មនសិករោតិ ន មជ្ឈំ មនសិករោតិ ន បរិយោសានំ មនសិករោតិ អយំ វុច្ចតិ ភិក្ខវេ ឧច្ឆង្គប្បញ្ញោ បុគ្គលោ ។ កតមោ ច ភិក្ខវេ បុថុប្បញ្ញោ បុគ្គលោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អារាមំ គន្តា ហោតិ អភិក្ខណំ ភិក្ខូនំ សន្តិកេ ធម្មស្សវនាយ

ក៏ជ្រុះរាត់រាយ ព្រោះភ្លេចស្មារតី យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ទៅកាន់អារាមស្តាប់ធម៌ក្នុងសំណាក់ភិក្ខុទាំង-ឡាយរឿយៗ ភិក្ខុទាំងឡាយក៏សម្តែងធម៌មានលម្អបទខាងដើម មានលម្អបទកណ្តាល មានលម្អបទខាងចុង ប្រកាសព្រហ្មចរិយធម៌ ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ដល់បុគ្គលនោះ បុគ្គលនោះ កាលអង្គុយលើអាសនៈនោះ ក៏ធ្វើទុកក្នុងចិត្តត្រង់ខាងដើមផង ធ្វើទុកក្នុងចិត្តត្រង់កណ្តាលផង ធ្វើទុកក្នុងចិត្តត្រង់ខាងចុងផងនៃកថានោះ លុះក្រោកអំពីអាសនៈនោះទៅ ក៏មិនធ្វើទុកក្នុងចិត្តត្រង់ខាងដើម មិនធ្វើទុកក្នុងចិត្តត្រង់កណ្តាល មិនធ្វើទុកក្នុងចិត្តត្រង់ខាងចុង នៃកថានោះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានប្រាជ្ញាដូចជាថ្នក់លេច ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានប្រាជ្ញាដ៏ទូលាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ទៅកាន់អារាម ស្តាប់ធម៌ក្នុងសំណាក់ភិក្ខុទាំងឡាយរឿយ ៗ

៧៣



តស្ស ភិក្ខូ ធម្មំ ទេសេន្តិ អាទិកល្យាណំ មជ្ឈេ-
កល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ
កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេន្តិ សោ
តស្មឹ អាសនេ និសិន្នោ តស្សា កថាយ អាទិម្បិ
មនសិករោតិ មជ្ឈម្បិ មនសិករោតិ បរិយោសានម្បិ
មនសិករោតិ វុដ្ឋិតោបិ តម្ហា អាសនា តស្សា
កថាយ អាទិម្បិ មនសិករោតិ មជ្ឈម្បិ
មនសិករោតិ បរិយោសានម្បិ មនសិករោតិ ។
សេយ្យថាបិ ភិក្ខវេ កុម្ភោ ឧក្កុជ្ជោ តត្រ ឧទកំ
អាសិត្តំ សណ្ឋាតិ នោ វិវដ្ដតិ ឯវមេវ ខោ ភិក្ខវេ
ឥធេកច្ចោ បុគ្គលោ អារាមំ គន្តា ហោតិ
អភិក្ខណំ ភិក្ខូនំ សន្តិកេ ធម្មស្សវនាយ តស្ស
ភិក្ខូ ធម្មំ ទេសេន្តិ អាទិកល្យាណំ មជ្ឈេកល្យាណំ
បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវល-
បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេន្តិ សោ

ភិក្ខុទាំងឡាយ ក៏សម្តែងធម៌មានលម្អបទខាងដើម មានលម្អបទកណ្តាល មានលម្អបទខាងចុង ប្រកាសព្រហ្មចរិយៈ ប្រកបដោយអត្ថ ប្រកបដោយព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ដល់បុគ្គលនោះ បុគ្គលនោះ កាលអង្គុយលើអាសនៈនោះ ក៏ធ្វើទុកក្នុងចិត្តត្រង់ខាងដើមផង ធ្វើទុកក្នុងចិត្តត្រង់កណ្តាលផង ធ្វើទុកក្នុងចិត្តត្រង់ខាងចុងផង នៃកថានោះ ទុកជាក្រោកអំពីអាសនៈនោះទៅហើយ ក៏នៅតែធ្វើទុកក្នុងចិត្តត្រង់ខាងដើមផង ធ្វើទុកក្នុងចិត្តត្រង់កណ្តាលផង ធ្វើទុកក្នុងចិត្តត្រង់ខាងចុងផង នៃកថានោះទៀត ។ ម្នាលភិក្ខុទាំងឡាយ ដូចជាក្អមផ្ងារ ទឹកដែលគេចាក់ក្នុងក្អមនោះ ក៏ដក់នៅមិនហូរចេញទៅបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ទៅកាន់អារាម ស្តាប់ធម៌ក្នុងសំណាក់ភិក្ខុទាំងឡាយរឿយៗ ភិក្ខុទាំងឡាយក៏សម្តែងធម៌មានលម្អបទខាងដើម មានលម្អបទកណ្តាល មានលម្អបទខាងចុង ប្រកាសព្រហ្មចរិយៈ ប្រកបដោយអត្ថ ប្រ-កបដោយព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ដល់បុគ្គលនោះ បុគ្គលនោះ

តស្មឹ អាសនេ និសិន្នោ តស្សា កថាយ អាទិម្បិ មនសិករោតិ មជ្ឈម្បិ មនសិករោតិ បរិយោសានម្បិ មនសិករោតិ វុដ្ឋិតោបិ តម្ហា អាសនា តស្សា កថាយ អាទិម្បិ មនសិករោតិ មជ្ឈម្បិ មនសិករោតិ បរិយោសានម្បិ មនសិករោតិ អយំ វុច្ចតិ ភិក្ខវេ បុថុប្បញ្ញោ បុគ្គលោ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

អវកុជ្ជប្បញ្ញោ បុរិសោ
ទុម្មេធោ អវិចក្ខណោ
អភិក្ខណំបិ ចេ ហោតិ
គន្តា ភិក្ខូន សន្តិកេ
អាទឹ កថាយ មជ្ឈញ្ច
បរិយោសានញ្ច តាទិសោ
ឧគ្គហេតុំ ន សក្កោតិ
បញ្ញា ហិស្ស ន វិជ្ជតិ ។
ឧច្ឆង្គប្បញ្ញោ បុរិសោ

កាលអង្គុយលើអាសនៈនោះ ក៏ធ្វើទុកក្នុងចិត្តត្រង់ខាងដើមផង ធ្វើទុកក្នុងចិត្តត្រង់កណ្តាលផង ធ្វើទុកក្នុងចិត្តត្រង់ខាងចុងផង នៃកថានោះ ទុកជាក្រោកអំពីអាសនៈនោះហើយ ក៏នៅតែធ្វើទុកក្នុងចិត្តត្រង់ខាងដើម ធ្វើទុកក្នុងចិត្តត្រង់កណ្តាល ធ្វើទុកក្នុងចិត្តត្រង់ខាងចុងនៃកថានោះទៀត ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលមានប្រាជ្ញាដ៏ទូលាយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។

បុរសមានប្រាជ្ញាដូចក្អមផ្កាប់ គឺជាអ្នកឥតប្រាជ្ញា ឥតសេចក្តីពិចារណា បុរសមានសភាពដូច្នោះ ទុកជាចូលទៅកាន់សំណាក់ភិក្ខុទាំងឡាយ សូម្បីរឿយ ៗ ក៏មិនអាចដើម្បីរៀនធម៌ត្រង់ខាងដើម ត្រង់កណ្តាល ត្រង់ខាងចុងនៃកថា (នោះ) បាន ព្រោះថាប្រាជ្ញាមិនមានដល់បុគ្គលនោះឡើយ ។ បុរសមានប្រាជ្ញាដូចថ្នក់លេច

សេយ្យោ ឯតេន វុច្ចតិ
អភិក្ខណំបិ ចេ ហោតិ
គន្ត្វា ភិក្ខូន សន្តិកេ
អាឌី កាថាយ មជ្ឈញ្ច
បរិយោសានញ្ច តាទិសោ
និសិន្នោ អាសនេ តស្មឹ
ឧគ្គហេត្វាន ព្យញ្ជនំ
វុឌ្ឍិតោ នប្បជានាតិ
គហិតំ ហិស្ស[១] មុស្សតិ ។
បុថុប្បញ្ញោ ច បុរិសោ
សេយ្យោ ឯតេន[២] វុច្ចតិ
អភិក្ខណំបិ ចេ ហោតិ
គន្ត្វា ភិក្ខូន សន្តិកេ

១ ឱ. ម. គហិតម្បិស្ស ។ ២ ឱ. ឯតេហិ ។

តថាគតពោលថា ប្រសើរជាង បុរសមានប្រាជ្ញា ដូចជាក្អមផ្កាប់ទុំះ បុរសមានសភាពដូច្នោះ បើ ទុកជាចូលទៅកាន់សំណាក់នៃភិក្ខុទាំងឡាយ សូម្បី រឿយ ៗ អង្គុយលើអាសនៈនោះ រៀនធម៌ខាងដើម ត្រង់កណ្ដាល ត្រង់ខាងចុង នៃកថា ( នោះ ) បានដែរ តែលុះក្រោកចេញទៅ ក៏កំណត់ចាំព្យញ្ជនៈមិនបាន ព្រោះថា បុរសនោះ ភ្លេចព្យញ្ជនៈដែលខ្លួនរៀន ហើយ ។ ចំណែកខាង បុរសមានប្រាជ្ញាដ៏ទូលាយ តថាគតពោលថា ប្រសើរជាង បុរសមានប្រាជ្ញាដូច ថ្នក់លេចទុំះ បុរសមានសភាពដូច្នោះ កាលបើចូល ទៅកាន់សំណាក់នៃភិក្ខុទាំងឡាយ សូម្បីរឿយ ៗ

អាទឹ កាថាយ មជ្ឈញ្ច
បរិយោសានញ្ច តាទិសោ
និសិន្នោ អាសនេ តស្មឹ
ឧក្កហេត្វាន ព្យញ្ជនំ
ធារេតិ សេដ្ឋសង្កប្បោ
អព្យក្កមនសោ[១] នរោ
ធម្មានុធម្មប្បដិបន្នោ
ទុក្ខស្សន្តករោ សិយាតិ ។

បុគ្គលវគ្គោ តតិយោ ។

## តស្សុទ្ទានំ

សវិដ្ឋតិលានសង្ខារា[២]
ពហុការា វជិរេន ច
សេវិជិគុច្ឆគូថភាណី
អន្ធោ ច អវកុជ្ជិតាតិ ។

---

១ ឱ. អព្យគ្គមានសោ ។ ២ ម. សេដ្ឋគិលានសង្ខារា ។

អង្គុយលើអាសនៈនោះ រៀនធម៌ត្រង់ខាងដើម ត្រង់កណ្ដាល ត្រង់ខាងចុង នៃកថា (នោះ) ចាំទុកនូវព្យញ្ជនៈបាន ជាជនមានតម្រិះដ៏ប្រសើរ មានចិត្តឥតសង្ស័យ ជាអ្នកប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ គប្បីធ្វើនូវទីបំផុតនៃទុក្ខបាន ។

ចប់ បុគ្គលវគ្គ ទី ៣ ។

## ឧទ្ទាននៃបុគ្គលវគ្គនោះគឺ

ពោលអំពីព្រះសវិដ្ឋត្ថេរ ១ អំពីអ្នកជំងឺ ១ អំពីសង្ខារ ១ អំពីបុគ្គលមានឧបការៈច្រើន ១ អំពីបុគ្គល ប្រៀបដូចពេជ្រជាដើម ១ អំពីបុគ្គលគួរសេពគប់ជាដើម ១ អំពីបុគ្គលគួរខ្ពើមជាដើម ១ អំពីបុគ្គលមានសម្ដីស្អុយដូចលាមកជាដើម ១ អំពីបុគ្គលខ្វាក់ជាដើម ១ អំពីបុគ្គលមានប្រាជ្ញា (ដូចក្អម) ផ្កាប់ជាដើម ១ ។

# ទេវទូតវគ្គោ

[៣១] សព្រហ្មកានិ ភិក្ខវេ តានិ កុលានិ យេសំ បុត្តានំ មាតាបិតរោ អជ្ឈាគារេ បូជិតា ហោន្តិ សបុព្វាចរិយកានិ ភិក្ខវេ តានិ កុលានិ យេសំ បុត្តានំ មាតាបិតរោ អជ្ឈាគារេ បូជិតា ហោន្តិ សាហុនេយ្យកានិ[១] ភិក្ខវេ តានិ កុលានិ យេសំ បុត្តានំ មាតាបិតរោ អជ្ឈាគារេ បូជិតា ហោន្តិ ។ ព្រហ្មាតិ ភិក្ខវេ មាតាបិតុន្នំ ឯតំ អធិវចនំ បុព្វាចរិយាតិ ភិក្ខវេ មាតាបិតុន្នំ ឯតំ អធិវចនំ អាហុនេយ្យាតិ ភិក្ខវេ មាតាបិតុន្នំ ឯតំ អធិវចនំ ។ តំ កិស្ស ហេតុ ។ ពហុការា ភិក្ខវេ មាតាបិតរោ បុត្តានំ អាបាទកា បោសកា ឥមស្ស លោកស្ស ទស្សេតារោតិ ។

ព្រហ្មាតិ មាតាបិតរោ
បុព្វាចរិយាតិ វុច្ចរេ
អាហុនេយ្យា ច បុត្តានំ
បជាយ អនុកម្បកា ។

---

១ ម. អាហុនេយ្យានិ ។

# ទេវទូតវគ្គ

[៣១] ម្នាលភិក្ខុទាំងឡាយ កូនរបស់ត្រកូលទាំងឡាយណា បានបូជាមាតាបិតា ក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងនោះឈ្មោះថា ប្រកបដោយព្រហ្ម ម្នាលភិក្ខុទាំងឡាយ កូនរបស់ត្រកូលទាំងឡាយណាបានបូជាមាតាបិតា ក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងនោះឈ្មោះថា ប្រកបដោយបុព្វាចារ្យ (អាចារ្យដើម) ម្នាលភិក្ខុទាំងឡាយ កូនរបស់ត្រកូលទាំងឡាយណា បានបូជាមាតាបិតាក្នុងផ្ទះរបស់ខ្លួន ត្រកូលទាំងនោះឈ្មោះថា ប្រកបដោយអាហុនេយ្យ (អ្នកគួរទទួលរបស់ដែលកូនប្រុសស្រីបូជា) ។ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រហ្មនុ៎ះ ជាឈ្មោះមាតាបិតា ម្នាលភិក្ខុទាំងឡាយ ពាក្យថា បុព្វាចារ្យនុ៎ះ ជាឈ្មោះមាតាបិតា ម្នាលភិក្ខុទាំងឡាយ ពាក្យថា អាហុនេយ្យនុ៎ះ ជាឈ្មោះមាតាបិតា ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះមាតាបិតាជាអ្នកមានឧបការៈច្រើន ជាអ្នកបីបាច់ រក្សាចិញ្ចឹមកូន ជាអ្នកឲ្យកូនបានឃើញលោកនេះ ។

មាតាបិតាលោកហៅថា ព្រហ្មផង ថា បុព្វាចារ្យ
ផង ថា អាហុនេយ្យផង របស់កូនទាំង-
ឡាយ ព្រោះជាអ្នកអនុគ្រោះនូវពពួកសត្វ ។

តស្មាហិ នេ នមស្សេយ្យ
សក្ករេយ្យាថ បណ្ឌិតោ
អន្នេន អថ បានេន
វត្ថេន សយនេន ច
ឧច្ឆាទនេន ន្ហាបនេន
បាទានំ ធោវនេន ច
តាយ បរិចរិយាយ
មាតាបិតូសុ បណ្ឌិតា
ឥធេវ នំ បសំសន្តិ
បេច្ច សគ្គេ បមោទតីតិ ។

[៣៤] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិ-វាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច

ព្រោះហេតុនោះ បណ្ឌិតត្រូវតែនមស្ការធ្វើសក្ការៈ
មាតាបិតាទាំងនោះ ដោយបាយ ទឹក សំពត់ ទីដេក
គ្រឿងដុសខាត់ទឹកងូតនិងទឹកលាងជើង បណ្ឌិត
រមែងសរសើរកូននោះ ព្រោះការបម្រើមាតាបិតានោះ
ក្នុងលោកនេះ (កូននោះ) លុះលះលោកនេះ ទៅកាន់
បរលោករមែងរីករាយ ក្នុងស្ថានសួគ៌ ។

[៣២] លំដាប់នោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគដូច្នេះថា

សិយា នុខោ ភន្តេ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា ឥមស្មិញ្ច សវិញ្ញាណកេ កាយេ អហង្ការមមង្ការមានានុសយា នាស្សុ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា នាស្សុ យញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ឧបសម្បជ្ជ វិហរតោ អហង្ការមមង្ការមានានុសយា ន ហោន្តិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ឧបសម្បជ្ជ វិហរេយ្យាតិ ។ សិយា អានន្ទ ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា ឥមស្មិញ្ច សវិញ្ញាណកេ កាយេ អហង្ការមមង្ការមានានុសយា នាស្សុ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា នាស្សុ យញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ឧបសម្បជ្ជ វិហរតោ អហង្ការមមង្ការមានានុសយា ន ហោន្តិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ឧបសម្បជ្ជ វិហរេយ្យាតិ ។

បពិត្រព្រះអង្គដ៏ចម្រើន បើអហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ មិនមានក្នុងកាយប្រកបដោយវិញ្ញាណនេះផង អហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ មិនមានក្នុងនិមិត្តទាំងអស់ ឰដ៏ខាងក្រៅផង អហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ មិនមានដល់ភិក្ខុដែលដល់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិណា ភិក្ខុគប្បីដល់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ សម្រេចសម្រាន្តនៅយ៉ាងណា ការបាននូវសមាធិ មានសភាពយ៉ាងនោះ គប្បីមានដល់ភិក្ខុដែរឬ ។ ម្នាលអានន្ទ បើអហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ មិនមានក្នុងកាយដែលប្រកបដោយវិញ្ញាណនេះផង អហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ មិនមានក្នុងនិមិត្តទាំងអស់ ឰដ៏ខាងក្រៅផង អហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ មិនមានដល់ភិក្ខុដែលដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិណា ភិក្ខុគប្បី ដល់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ សម្រេចសម្រាន្តនៅ យ៉ាងណា ការបាននូវសមាធិ មានសភាពយ៉ាងនោះ គប្បីមានដល់ភិក្ខុដែរ

យថាកថំ បន ភន្តេ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា ឥមស្មិញ្ច សវិញ្ញាណកេ កាយេ អហង្ការមមង្ការមានានុសយា នាស្សុ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា នាស្សុ យញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ឧបសម្បជ្ជ វិហរតោ អហង្ការមមង្ការមានានុសយា ន ហោន្តិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ឧបសម្បជ្ជ វិហរេយ្យាតិ ។ ឥធានន្ទ ភិក្ខុនោ ឯវំ ហោតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ សព្វសង្ខារសមថោ សព្វូបធិប្បដិនិស្សគ្គោ តណ្ហាក្ខយោ វិរាគោ និរោធោ និព្វានន្តិ ។ ឯវំ ខោ[១] អានន្ទ សិយា ភិក្ខុនោ តថារូបោ សមាធិប្បដិលាភោ យថា ឥមស្មិញ្ច សវិញ្ញាណកេ កាយេ អហង្ការមមង្ការមានានុសយា នាស្សុ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា នាស្សុ យញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ឧបសម្បជ្ជ វិហរតោ អហង្ការមមង្ការមានានុសយា ន ហោន្តិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ឧបសម្បជ្ជ វិហរេយ្យ[២] ។

---

១ ម. ឯវមេវ ខោ ។ ២ ឱ. ម. វិហរេយ្យាតិ ។

បពិត្រព្រះអង្គដ៏ចម្រើន អហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ មិនមានក្នុងកាយ ប្រកបដោយវិញ្ញាណនេះផង អហង្ការទិដ្ឋិ មមង្ការ-តណ្ហានិងមានានុស័យ មិនមានក្នុងនិមិត្តទាំងអស់ ឰដ៏ខាងក្រៅផង អហង្ការទិដ្ឋិមមង្ការតណ្ហានិងមានានុស័យ មិនមានដល់ភិក្ខុដែលបាននូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ សម្រេចសម្រាន្តនៅយ៉ាងណា ការបាននូវសមាធិ មានសភាពយ៉ាងនោះ គប្បីមានដល់ភិក្ខុ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានសេចក្តីត្រិះរិះដូច្នេះថា ធម្មជាតដែលហៅថា ស្ងប់ ធម្មជាតដែលហៅថា ឧត្តមនោះ គឺការស្ងប់រម្ងាប់សង្ខារទាំងអស់ ការលះបង់ឧបធិទាំងអស់ ការអស់តណ្ហា ការប្រាសចាករាគៈ ការរលត់ គឺព្រះនិព្វានហ្នឹងឯង ។ ម្នាលអានន្ទ អហង្ការទិដ្ឋិ មមង្ការតណ្ហានិងមា-នានុស័យ មិនមានក្នុងកាយប្រកបដោយវិញ្ញាណនេះផង អហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ មិនមានក្នុងនិមិត្តទាំងអស់ ឰដ៏ខាងក្រៅផង អហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ មិនមានដល់ភិក្ខុដែលបាននូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិណា ភិក្ខុគប្បីបាននូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិនោះ សម្រេចសម្រាន្តនៅ យ៉ាងណា ការបាននូវសមាធិ មានសភាពយ៉ាងនោះ គប្បីមានដល់ភិក្ខុ យ៉ាងនេះឯង ។

ឥទញ្ច បន មេតំ អានន្ទ សន្ធាយ ភាសិតំ បារាយនេ បុណ្ណកបញ្ហេ

សង្ខាយ លោកស្មិំ បរោបរានិ[១]
យស្សិញ្ជិតំ នត្ថិ កុហិញ្ចិ លោកេ
សន្តោ វិធូមោ អនិឃោ និរាសោ
អតារិ សោ ជាតិជរន្តិ ព្រូមីតិ ។

[៣៣] អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សារីបុត្តំ ភគវា ឯតទវោច សង្ខិត្តេនបិ ខោ អហំ សារីបុត្ត ធម្មំ ទេសេយ្យំ វិត្ថារេនបិ ខោ អហំ សារីបុត្ត ធម្មំ ទេសេយ្យំ សង្ខិត្តវិត្ថារេនបិ ខោ អហំ សារីបុត្ត ធម្មំ ទេសេយ្យំ ធម្មស្ស អញ្ញាតារោ ច ទុល្លភាតិ ។ ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ យំ ភគវា សង្ខិត្តេនបិ ធម្មំ ទេសេយ្យ វិត្ថារេនបិ ធម្មំ ទេសេយ្យ សង្ខិត្តវិត្ថារេនបិ ធម្មំ ទេសេយ្យ ភវិស្សន្តិ ធម្មស្ស អញ្ញាតារោតិ ។

១ ឱ. បរោវរានិ ។

ម្នាលអានន្ទ ពាក្យថា

បុគ្គលណាដឹងច្បាស់នូវរបស់ខ្ពួននិងរបស់ជនដទៃ ក្នុង
លោក រមែងមិនមានសេចក្តីញាប់ញ័រ ក្នុងអារម្មណ៍
នីមួយទេ តថាគតពោលថា បុគ្គលនោះស្ងប់រម្ងាប់ប្រាស
ចាកផ្សែងគឺ ទុច្ចរិត មិនមានសេចក្តីទុក្ខ មិនមានតណ្ហា
បានឆ្លងជាតិនិងជរាហើយ ដូច្នេះនេះ

ដែលតថាគតពោលហើយ ក្នុងបុណ្ណកប្បញ្ហា បរាយនវគ្គ សំដៅហេតុនុ៎ះឯង ។

[៣៣] គ្រានោះ ព្រះសារីបុត្តមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលសារីបុត្ត តថាគតសម្តែងធម៌ដោយបំប្រួញខ្លះ ម្នាលសារីបុត្ត តថាគតគួរសម្តែងធម៌ ដោយពិស្តារខ្លះ ម្នាលសារីបុត្ត តថាគតគួរសម្តែងធម៌ទាំងបំប្រួញទាំងពិស្តារខ្លះ ដ្បិតថាពួកបុគ្គលអ្នកយល់ធម៌ រកបានដោយកម្រ ។ បពិត្រព្រះមានព្រះភាគ ជាកាលគួរនឹងសម្តែងធម៌នុ៎ះហើយ បពិត្រព្រះសុគត ជាកាលគួរនឹងសម្តែងធម៌នុ៎ះហើយ ប្រសិនបើព្រះមានព្រះភាគ សម្តែងធម៌ដោយសង្ខេបក្តី សម្តែងធម៌ដោយពិស្តារក្តី សម្តែងធម៌ទាំងសង្ខេបទាំងពិស្តារក្តី ពួកអ្នកយល់ធម៌

តស្មាតិហ សារីបុត្ត ឯវំ សិក្ខិតព្វំ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ អហង្ការមមង្ការមានា-នុសយា ន ភវិស្សន្តិ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ភវិស្សន្តិ យញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ឧបសម្បជ្ជ វិហរតោ អហង្ការ-មមង្ការមានានុសយា ន ហោន្តិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ឧបសម្បជ្ជ វិហរិស្សាមាតិ ។ ឯវញ្ហិ តេ សារីបុត្ត សិក្ខិតព្វំ ។ យតោ ខោ សារីបុត្ត ភិក្ខុនោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ អហង្ការមមង្ការ-មានានុសយា ន ហោន្តិ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តិ យញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ឧបសម្បជ្ជ វិហរតោ អហង្ការមមង្ការមានានុសយា ន ហោន្តិ តញ្ច ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ សារីបុត្ត ភិក្ខុ អច្ឆេជ្ជិ តណ្ហំ វិវដ្ដយិ សញ្ញោជនំ សម្មាមានាភិសមយា អន្តមកាសិ ទុក្ខស្ស

គង់នឹងមាន ។ ម្នាលសារីបុត្ត ហេតុនោះ ភិក្ខុក្នុងសាសនានេះ ត្រូវសិក្សាយ៉ាងនេះថា អហង្ការទិដ្ឋិមមង្ការតណ្ហានិងមានានុស័យនិងមិនមានក្នុងកាយប្រកបដោយវិញ្ញាណនេះផង អហង្ការទិដ្ឋិ មមង្ការតណ្ហានឹងមានានុស័យនឹងមិនមានក្នុងនិមិត្តទាំងអស់ឰដ៏ខាងក្រៅផង អហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ មិនមានដល់ភិក្ខុដែលបានចេតោវិមុត្តិនិងបញ្ញាវិមុត្តិណាយើងនឹងបាននូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ សម្រេចសម្រាន្តនៅ ។ ម្នាលសារីបុត្ត អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលសារីបុត្ត កាលណាភិក្ខុមិនមានអហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ ក្នុងកាយប្រកបដោយវិញ្ញាណនេះផង មិនមានអហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ ក្នុងនិមិត្តទាំងអស់ឰដ៏ខាងក្រៅផង អហង្ការទិដ្ឋិ មមង្ការតណ្ហានិងមានានុស័យ មិនមានដល់ភិក្ខុ ដែលបានចេតោវិមុត្តិ និងបញ្ញាវិមុត្តិណា ភិក្ខុរមែងបាននូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិនោះ សម្រេចសម្រាន្តនៅ ។ ម្នាលសារីបុត្ត ភិក្ខុនេះតថាគតហៅថា បានផ្តាច់ផ្តិលនូវតណ្ហា គាស់រំលើងនូវសំយោជនៈ បានធ្វើនូវទីបំផុតទុក្ខ ព្រោះត្រាស់ដឹងនូវកិរិយាលះបង់មានះ ដោយឧបាយដ៏ល្អ

ឥធញ្ច បន មេតំ សារីបុត្ត សន្ធាយ ភាសិតំ បារាយនេ ឧទយប្បញ្ហេ

បហានំ កាមសញ្ញានំ(១) ទោមនស្សាន ចូភយំ
ថីនស្ស ច បនូទនំ កុក្កុច្ចានំ(២) និវារណំ
ឧបេក្ខាសតិសំសុទ្ធំ ធម្មតក្កបុរេជវំ
អញ្ញាវិមោក្ខំ បព្រូមិ អវិជ្ជាយប្បភេទនន្តិ(៣) ។

[៣៤] តីណិមានិ ភិក្ខវេ និទានានិ កម្មានំ សមុទយាយ ។ កតមានិ តីណិ ។ លោភោ និទានំ កម្មានំ សមុទយាយ ទោសោ និទានំ កម្មានំ សមុទយាយ មោហោ និទានំ កម្មានំ សមុទយាយ ។ យំ ភិក្ខវេ លោភប្បកតំ កម្មំ លោភជំ លោភនិទានំ លោភសមុទយំ យត្ថស្ស អត្តភាវោ និព្វត្តតិ តត្ថ តំ កម្មំ វិបច្ចតិ យត្ថ តំ កម្មំ វិបច្ចតិ តត្ថ តស្ស កម្មស្ស វិបាកំ បដិសំវេទេតិ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ(៤) វា អបរេ វា បរិយាយេ ។ យំ ភិក្ខវេ ទោសប្បកតំ កម្មំ ទោសជំ ទោសនិទានំ

១ ឱ. កាមច្ឆន្ទានំ ។ ២ ម. កុក្កុច្ចាយ ។ ៣ ម. អវិជ្ជាយបនោទនន្តិ ។ ៤ ឱ. ម. ទិដ្ឋេ វា ធម្មេ ឧបបជ្ជេ វា ។

ម្នាលសារីបុត្តពាក្យថា

តថាគតសម្ដែងនូវការលះបង់កាមសញ្ញានិងទោមនស្ស ទាំងពីរផង នូវការបន្ទោបង់ថីនៈផង នូវការហាមឃាត់កុក្កុច្ចៈផង នូវធម៌ដ៏ស្អាត ដោយឧបេក្ខានឹងសតិផង នូវប្រធាននៃសេចក្ដីត្រិះរិះធម៌ផង នូវការរួចស្រឡះដោយអរហត្តផលផង ថាជាការទម្លាយបង់នូវអវិជ្ជា

ដូច្នេះនេះ ដែលតថាគតពោលហើយ ក្នុងឧទយប្បញ្ហាបារាយនវគ្គ សំដៅហេតុនេះឯង ។

[៣៤] ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៣ នេះ ជាហេតុឲ្យកើតកម្ម ។ ធម្មជាត ៣ តើដូចម្ដេច ។ គឺលោភៈ ជាហេតុឲ្យកើតកម្ម ១ ទោសៈ ជាហេតុឲ្យកើតកម្ម ១ មោហៈ ជាហេតុឲ្យកើតកម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ កម្មណាដែលបុគ្គលធ្វើព្រោះលោភៈ កើតអំពីលោភៈ មានលោភៈជាហេតុ មានលោភៈជាដែនកើត អត្តភាពបុគ្គលនោះកើតក្នុងទីណា កម្មនោះរមែងឲ្យផលក្នុងទីនោះ កម្មនោះឲ្យផលក្នុងទីណា បុគ្គលរមែងទទួលផលនៃកម្មនោះ ក្នុងទីនោះ គឺអត្តភាពជាបច្ចុប្បន្ន ឬអត្តភាពដែលកើតបន្ទាប់ ឬអត្តភាពដទៃដែលអន្ទោលតទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ កម្មណាដែលបុគ្គលធ្វើហើយព្រោះទោសៈ កើតអំពីទោសៈ មានទោសៈជាហេតុ

ទោសសមុទយំ យត្ថស្ស អត្តភាវោ និព្វត្តតិ តត្ថ តំ កម្មំ វិបច្ចតិ យត្ថ តំ កម្មំ វិបច្ចតិ តត្ថ តស្ស កម្មស្ស វិបាកំ បដិសំវេទេតិ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ វា អបរេ វា បរិយាយេ ។ យំ ភិក្ខវេ មោហប្បកតំ កម្មំ មោហជំ មោហនិទានំ មោហសមុទយំ យត្ថស្ស អត្តភាវោ និព្វត្តតិ តត្ថ តំ កម្មំ វិបច្ចតិ យត្ថ តំ កម្មំ វិបច្ចតិ តត្ថ តស្ស កម្មស្ស វិបាកំ បដិសំ-វេទេតិ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ វា អបរេ វា បរិយាយេ ។ សេយ្យថាបិ ភិក្ខវេ ពីជានិ អខណ្ឌានិ អបូតីនិ អវាតាតបហតានិ សារាទានិ សុខសយិតានិ សុក្ខេត្តេ សុបរិកម្មកតាយ ភូមិយា និក្ខិត្តានិ ទេវោ ច សម្មាធារំ អនុប្បវេច្ឆេយ្យ ឯវស្សុ តានិ ភិក្ខវេ ពីជានិ វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ អាបជ្ជេយ្យុំ ។

មានទោសៈជាបច្ច័យ អត្តភាពរបស់បុគ្គលនោះ កើតក្នុងទីណា កម្មនោះ រមែងឲ្យផលក្នុងទីនោះ កម្មនោះឲ្យផលក្នុងទីណា បុគ្គលរមែងទទួលផលរបស់កម្មនោះ ក្នុងទីនោះ គឺអត្តភាពជាបច្ចុប្បន្នក្តី អត្តភាពដែលកើតបន្ទាប់ក្តី អត្តភាពដទៃដែលអន្ទោលតទៅទៀតក្តី ។ ម្នាលភិក្ខុទាំងឡាយ កម្មណា ដែលបុគ្គលធ្វើដោយមោហៈ កើតអំពីមោហៈ មានមោហៈជាហេតុ មានមោហៈជាបច្ច័យ អត្តភាពរបស់បុគ្គលនោះ កើតក្នុងទីណា កម្មនោះ រមែងឲ្យផលក្នុងទីនោះ កម្មនោះ រមែងឲ្យផលក្នុងទីណា បុគ្គលរមែងទទួលផលរបស់កម្មនោះ ក្នុងទីនោះ គឺអត្តភាពជាបច្ចុប្បន្នក្តី អត្តភាពដែលកើតបន្ទាប់ក្តី អត្តភាពដទៃដែលអន្ទោលតទៅទៀតក្តី ។ ម្នាលភិក្ខុទាំងឡាយ ដូចពូជដែលមិនបែក មិនស្អុយ មិនខូចដោយខ្យល់និងកម្តៅថ្ងៃ ប្រកបដោយខ្លឹមសារ (ជាគ្រាប់មានសាច់ពេញលេញ) គេទុកដាក់ស្រួលបួល ដែលបុគ្គលសាបព្រោះលើទីដែលភ្ជួររាស់ល្អ ក្នុងស្រែមានជីរជាតិ ភ្លៀងសោតក៏ផ្តល់ធារទឹកដោយស្រួល ម្នាលភិក្ខុទាំងឡាយ បើពូជទាំងនោះសមប្រកបយ៉ាងនេះ ដល់នូវការលូតលាស់ ដុះដាលបែកគុម្ព យ៉ាងណាមិញ ។

ឯវមេវ ខោ ភិក្ខវេ យំ លោភប្បកតំ កម្មំ លោភជំ លោភនិទានំ លោភសមុទយំ យត្ថស្ស អត្តភាវោ និព្វត្តតិ តត្ថ តំ កម្មំ វិបច្ចតិ យត្ថ តំ កម្មំ វិបច្ចតិ តត្ថ តស្ស កម្មស្ស វិបាកំ បដិសំវេទេតិ ទិដ្ឋេវ ធម្មេ ឧបបជ្ជេ វា អបរេ វា បរិយាយេ ។ យំ ទោសប្បកតំ កម្មំ ។ បេ ។ យំ មោហប្បកតំ កម្មំ ។ បេ ។ អបរេ វា បរិយាយេ ។ ឥមានិ ខោ ភិក្ខវេ តីណិ និទានានិ កម្មានំ សមុទយាយ ។

[៣៤] តីណីមានិ ភិក្ខវេ និទានានិ កម្មានំ សមុទយាយ ។ កតមានិ តីណិ ។ អលោភោ និទានំ កម្មានំ សមុទយាយ អទោសោ និទានំ កម្មានំ សមុទយាយ អមោហោ និទានំ កម្មានំ សមុទយាយ ។ យំ ភិក្ខវេ អលោភប្បកតំ កម្មំ អលោភជំ អលោភនិទានំ អលោភសមុទយំ លោភេ វិគតេ ឯវំ តំ កម្មំ បហីនំ ហោតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវំ កតំ អាយតឹអនុប្បាទធម្មំ ។

ម្នាលភិក្ខុទាំងឡាយ កម្មណាដែលបុគ្គលធ្វើ ព្រោះលោភៈ កើតអំពីលោភៈ មានលោភៈជាហេតុ មានលោភៈជាបច្ច័យ អត្តភាពរបស់បុគ្គលនោះកើតក្នុងទីណា កម្មនោះរមែងឲ្យផល ក្នុងទីនោះ កម្មនោះឲ្យផលក្នុងទីណា បុគ្គលរមែងទទួលផលរបស់កម្មនោះក្នុងទីនោះ គឺអត្តភាពក្នុងបច្ចុប្បន្នក្តី អត្តភាពដែលកើតបន្ទាប់ក្តី អត្តភាពដទៃដែលអន្ទោលតទៅក្តី ។ កម្មណាដែលបុគ្គលធ្វើព្រោះទោសៈ ។ បេ ។ កម្មណាដែលបុគ្គលធ្វើព្រោះមោហៈ ។ បេ ។ ក្នុងអត្តភាពដទៃដែលអន្ទោលតទៅក្តី ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៣ នេះឯង ជាហេតុឲ្យកើតកម្មទាំងឡាយ ក៏យ៉ាងនោះដែរ ។

[៣៥] ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៣ នេះ ជាហេតុឲ្យកើតកម្មទាំងឡាយ ។ ធម្មជាត ៣ តើដូចម្តេច ។ គឺអលោភៈ ជាហេតុឲ្យកើតកម្មទាំងឡាយ ១ អទោសៈ ជាហេតុឲ្យកើតកម្មទាំងឡាយ ១ អមោហៈ ជាហេតុឲ្យកើតកម្មទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ កម្មណាដែលបុគ្គលធ្វើ ព្រោះអលោភៈ កើតអំពីអលោភៈ មានអលោភៈជាហេតុ មានអលោភៈជាបច្ច័យ បើសេចក្តីលោភ មិនមានហើយ កម្មនោះឈ្មោះថា បុគ្គលបានលះបង់យ៉ាងនេះ ជាកម្មមានឫសគល់ផ្តាច់ផ្តិលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើមិនឲ្យមានពូជ ជាកម្មមិនកើត តទៅទៀតជាធម្មតា ។

យំ ភិក្ខវេ អទោសប្បកតំ កម្មំ អទោសជំ អទោសនិទានំ អទោសសមុទយំ ទោសេ វិគតេ ឯវំ តំ កម្មំ បហីនំ ហោតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវំ កតំ អាយតឹអនុប្បាទធម្មំ ។ យំ ភិក្ខវេ អមោហប្បកតំ កម្មំ អមោហជំ អមោហនិទានំ អមោហសមុទយំ មោហេ វិគតេ ឯវំ តំ កម្មំ បហីនំ ហោតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវំ កតំ អាយតឹអនុប្បាទធម្មំ ។ សេយ្យថាបិ ភិក្ខវេ ពីជានិ អខណ្ឌានិ អបូតីនិ អវាតាតបហតានិ សារាទានិ សុខសយិតានិ តានិ បុរិសោ អគ្គិនា ឌហេយ្យ អគ្គិនា ឌហិត្វា មសឹ ករេយ្យ មសឹ កត្វា មហាវាតេ វា ឱផុនេយ្យ នទិយា វា សីឃស្សោតាយ បវាហេយ្យ ឯវស្សុ តានិ ភិក្ខវេ ពីជានិ ឧច្ឆិន្នមូលានិ តាលាវត្ថុកតានិ អនភាវំ កតានិ អាយតឹអនុប្បាទធម្មានិ ឯវមេវ ខោ ភិក្ខវេ

ម្នាលភិក្ខុទាំងឡាយ កម្មណាដែលបុគ្គលធ្វើព្រោះអទោសៈ កើតអំពីអទោសៈ មានអទោសៈជាហេតុ មានអទោសៈជាបច្ច័យ កាលបើទោសៈមិនមានហើយ កម្មនោះឈ្មោះថា បុគ្គលបានលះបង់យ៉ាងនេះ ជាកម្មមានឫសផ្តាច់ផ្តិលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើមិនឲ្យមានពូជ ជាកម្មមិនកើតតទៅទៀត ជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ កម្មណាដែលបុគ្គលធ្វើព្រោះអមោហៈ កើតអំពីអមោហៈ មានអមោហៈជាហេតុ មានអមោហៈជាបច្ច័យ កាលបើមោហៈមិនមានហើយ កម្មនោះឈ្មោះថា បុគ្គលបានលះបង់ហើយយ៉ាងនេះ ជាកម្មមានឫសគល់ផ្តាច់ផ្តិលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស ជាកម្មមិនកើតតទៅទៀតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ដូចជាពូជដែលមិនបែក មិនស្អុយ មិនវិនាសដោយខ្យល់និងកម្តៅថ្ងៃ ប្រកបដោយខ្លឹមសារ គេទុកដាក់ល្អ បុរសគប្បីដុតនូវពូជនោះដោយភ្លើង ដុតដោយភ្លើងរួចហើយ ធ្វើជាធ្យូងម៉ត់ ធ្វើជាធ្យូងម៉ត់រួចហើយ ក៏បាចទៅក្នុងខ្យល់ដ៏ខ្លាំងក្តី បណ្តែតក្នុងស្ទឹងដែលមានខ្សែទឹកហូរត្របាញ់ក្តី ម្នាលភិក្ខុទាំងឡាយ បើពូជទាំងនោះ ត្រូវគេបំផ្លាញយ៉ាងនេះមុខជានឹងមានកំណើតផ្តាច់ផ្តិល ធ្វើមិនឲ្យកើតទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស ជាពូជមិនកើតតទៅទៀតជាធម្មតា យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះដែរ

យំ អលោភប្បកតំ កម្មំ អលោភជំ អលោភនិទានំ អលោភសមុទយំ លោភេ វិគតេ ឯវំ តំ កម្មំ បហីនំ ហោតិ ឧច្ឆិន្នមូលំ តាលាវត្ថុកតំ អនភាវំ កតំ អាយតឹអនុប្បាទធម្មំ ។ យំ អទោសប្បកតំ កម្មំ ។ បេ ។ យំ អមោហប្បកតំ កម្មំ ។ បេ ។ អនភាវំ កតំ អាយតឹអនុប្បាទធម្មំ ។ ឥមានិ ខោ ភិក្ខវេ តីណិ និទានានិ កម្មានំ សមុទយាយាតិ ។

លោភជំ ទោសជញ្ចេវ
មោហជញ្ចាបវិទ្ទសុ[១]
យន្តេន បកតំ កម្មំ
អប្បំ វា យទិ វា ពហុំ
ឥធេវ តំ វេទនីយំ
វត្ថុំ អញ្ញំ ន វិជ្ជតិ
តស្មា លោភញ្ច ទោសញ្ច
មោហញ្ចាបិ ស វិទ្ទសុ
វិជ្ជំ ឧប្បាទយំ ភិក្ខុ
សព្វា ទុគ្គតិយោ ជហេតិ ។

១ ម. លោភជ ទោសជំ កម្មំ មោហជំ វា អវិទ្ទសុ ។

កម្មណាដែលបុគ្គលធ្វើព្រោះអលោភៈ កើតអំពីអលោភៈ មានអលោភៈជាហេតុ មានអលោភៈជាបច្ច័យ កាលបើលោភៈមិនមានហើយ កម្មនោះឈ្មោះថា បុគ្គលបានលះបង់ហើយយ៉ាងនេះ ជាកម្មមានឫសគល់ផ្តាច់ផ្តិលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស ជាកម្មមិនកើតតទៅទៀតជាធម្មតា ។ កម្មណាដែលបុគ្គលធ្វើ ព្រោះអទោសៈ ។ បេ ។ កម្មណាដែលបុគ្គលធ្វើ ព្រោះអមោហៈ ។ បេ ។ ធ្វើឲ្យវិនាស ជាកម្មមិនកើតតទៅទៀតជាធម្មតា ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាត ៣ នេះឯងជាហេតុឲ្យកើតកម្មទាំងឡាយ ។

បុគ្គលពាលជាអ្នកមិនដឹងច្បាស់នូវកម្ម ដែលកើតអំពីលោភៈផង កើតអំពីទោសៈផង កើតអំពីមោហៈផង
កម្មណាដែលបុគ្គលនោះធ្វើហើយ ទោះតិចក្តី ច្រើនក្តី
បុគ្គលនោះត្រូវរងកម្មនោះ ក្នុងអត្តភាពនេះឯង វត្ថុដទៃមិនមានទេ ហេតុនោះភិក្ខុ (ណា) ជាអ្នកដឹង (រមែងមិនធ្វើនូវកម្មដែលកើតអំពី) លោភៈផង ទោសៈផង
មោហៈផង (ភិក្ខុនោះ) ឈ្មោះថាញុំាងវិជ្ជាឲ្យកើតឡើង ហើយលះបង់នូវទុគ្គតិទាំងអស់បាន ។

[៣៦] ឯកំ សមយំ ភគវា អាឡវិយំ វិហរតិ គោមគ្គេ សឹសបាវនេ បណ្ណសន្ថរេ ។ អថខោ ហត្ថកោ អាឡវកោ ជង្ឃាវិហារំ អនុចង្កមមានោ អនុវិចរមានោ អទ្ទស ភគវន្តំ គោមគ្គេ សឹសបាវនេ បណ្ណសន្ថរេ និសិន្នំ ទិស្វាន យេន ភគវា តេនុបសង្កមិ ឧប-សង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ហត្ថកោ អាឡវកោ ភគវន្តំ ឯតទវោច កច្ចិ ភន្តេ ភគវា សុខមសយិត្ថាតិ[១] ។ ឯវំ កុមារ សុខមសយិត្ថំ យេ ច បន លោកេ សុខំ សេន្តិ អហំ តេសំ អញ្ញតរោតិ ។ សីតា ភន្តេ ហេមន្តិកា រត្តិ អន្តរដ្ឋកោ ហិមបាតសមយោ ខរា គោកណ្ដកហតា ភូមិ តនុកោ បណ្ណសន្ថរោ វិរឡានិ រុក្ខស្ស បត្តានិ សីតានិ កាសាយានិ វត្ថានិ សីតោ ច វេរម្ភវាតោ វាតិ អថ ច បន ភគវា ឯវមាហ ឯវំ កុមារ សុខមសយិត្ថំ

១ ម. សុខំ សយិត្ថាតិ ។

[៣៦] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់លើកម្រាលស្លឹកឈើ ដែលជ្រុះក្នុងព្រៃធ្នង់ ជិតផ្លូវគោ ក្នុងដែនអាឡវី ។ លំដាប់នោះឯង ព្រះរាជកុមារព្រះនាមហត្ថកអាឡវក ត្រាច់ទៅមកដើម្បីសម្រួលព្រះជង្ឃា ក៏បានឃើញព្រះមានព្រះភាគទ្រង់គង់លើកម្រាលស្លឹកឈើក្នុងព្រៃធ្នង់ ជិតផ្លូវគោ លុះឃើញហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគហើយគង់ក្នុងទីសមគួរ ។ លុះហត្ថក-អាឡវក គង់ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់ផ្ទំស្រួលទេឬ ។ ម្នាលកុមារ យ៉ាងហ្នឹងហើយ តថាគតបានសិងស្រួលហើយ ពួកជនណាដេកស្រួលក្នុងលោក បណ្ដាជនទាំងនោះ តថាគតក៏ជាអ្នកសិងស្រួលមួយនឹងគេដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន រាត្រីក្នុងហេមន្តរដូវត្រជាក់ កាលក្នុង ៨ ថ្ងៃជាចន្លោះ (ខែមាឃនិងខែផល្គុន) ជាសម័យធ្លាក់ទឹកសន្សើម ផែនដីដែលត្រូវក្រចកជើងគោ ជាន់ខ្ទង់រដិបរដុបក៏រឹង កម្រាលស្លឹកឈើក៏ស្ដើង អស់ទាំងស្លឹកឈើក៏រង្វើល សំពត់កាសាយៈក៏ត្រជាក់ ខ្យល់វល់ដ៏ត្រជាក់ក៏បក់មក កាលបើយ៉ាងហ្នឹង ម្ដេចក៏ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលកុមារ យ៉ាងហ្នឹងហើយ តថាគតបានសិងស្រួលហើយ ។

យេ ច បន លោកេ សុខំ សេន្តិ អហំ តេសំ អញ្ញតរោតិ ។ តេនហិ កុមារ តំ យេវេត្ថ បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ ។ តំ កឹ មញ្ញសិ កុមារ ឥធស្ស គហបតិស្ស វា គហបតិបុត្តស្ស វា កូដាគារំ ឧល្លិត្តាវលិត្តំ និវាតំ ផុសិតគ្គឡំ បិហិតវាតបានំ តត្រស្ស បល្លង្កោ គោណកត្ថតោ បដិកត្ថតោ បដលិកត្ថតោ កទលិមិគបវរបច្ចត្ថរណោ សឧត្តរច្ឆទោ ឧភតោ លោហិតកុបធានោ តេលប្បទីបោ ចេត្ថ ឈាយេយ្យ[១] ចតស្សោ បជាបតិយោ មនាបមនាបេន បច្ចុបដ្ឋិតា អស្សុ ។ តំ កឹ មញ្ញសិ កុមារ សុខំ វា សោ សយេយ្យ នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ សុខំ សោ ភន្តេ សយេយ្យ យេ ច លោកេ សុខំ សេន្តិ សោ តេសំ អញ្ញតរោតិ ។

១ ម. ជាលេយ្យ ។

ពួកជនណាដេកស្រួលក្នុងលោក បណ្ដាជនទាំងនោះតថាគតក៏ជាអ្នកសិង ស្រួលមួយនឹងគេដែរ ។ ម្នាលកុមារ បើដូច្នោះ តថាគតនឹងសួរ អ្នកក្នុង ដំណើរនុ៎ះ ថាបើអ្នកគាប់ចិត្តយ៉ាងណា គប្បីព្យាករនូវដំណើរនោះយ៉ាង នោះចុះ ។ ម្នាលកុមារ អ្នកសម្គាល់ហេតុនោះដូចម្ដេច គហបតីឬគហបតិ-បុត្រក្នុងលោកនេះ មានផ្ទះកំពូលបូកលាបខាងក្នុង ទាំងបូកលាបខាងក្រៅ ខ្យល់ចូលមិនរួច មានទ្វារដ៏ជិត មានបង្អួចបិទជិតក្នុងផ្ទះនោះ មានបល្ល័ង្ក ក្រាលដោយកម្រាលគោណកៈ ក្រាលដោយកម្រាលបដិកៈ ក្រាលដោយ កម្រាលបដលិកៈមានកម្រាលដ៏ប្រសើរ ជាវិការនៃស្បែកឈ្លូស[១] មាន ខ្នើយក្រហមទាំងពីរខាង ព្រមទាំងពិតានក្រហមទាំងប្រទីបប្រេងក៏ឆេះភ្លឺ ក្នុងផ្ទះនោះ មានប្រពន្ធ ៤ នាក់ នៅផ្គត់ផ្គង់បម្រើ ដោយសេចក្ដីគាប់ ចិត្ត ។ ម្នាលកុមារ អ្នកសម្គាល់ហេតុនោះដូចម្ដេច បុគ្គលនោះ គួរដេកជា សុខឬទេ ឬអ្នកមានសេចក្ដីយល់ ក្នុងដំណើរនុ៎ះដូចម្ដេច ។ បពិត្រព្រះ អង្គដ៏ចម្រើន បុគ្គលនោះគួរដេកជាសុខ ពួកជនណាដេកជាសុខ ក្នុង លោក បណ្ដាជនទាំងនោះ អ្នកនោះជាអ្នកដេកជាសុខមួយនឹងគេដែរ ។

---

១. ឈ្មោះកម្រាលទាំងអស់នេះ បានប្រែក្នុងសៀវភៅទី ១៤ ទំព័រ ១៦ រួចហើយ ។

តំ កឹ មញ្ញសិ កុមារ អបិនុ តស្ស គហបតិស្ស វា គហបតិបុត្តស្ស វា ឧប្បជ្ជេយ្យុំ រាគជា បរិឡាហា កាយិកា វា ចេតសិកា វា យេហិ សោ រាគជេហិ បរិឡាហេហិ បរិឌយ្ហមានោ ទុក្ខំ សយេយ្យាតិ ។ ឯវំ ភន្តេ[១] ។ យេហិ ខោ សោ កុមារ គហបតិ វា គហបតិបុត្តោ វា រាគជេហិ បរិឡាហេហិ បរិឌយ្ហមានោ ទុក្ខំ សយេយ្យ សោ រាគោ តថាគតស្ស បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ តស្មាហំ សុខមសយិត្ថំ ។ តំ កឹ មញ្ញសិ កុមារ អបិនុ តស្ស គហបតិស្ស វា គហបតិបុត្តស្ស វា ឧប្បជ្ជេយ្យុំ ទោសជា បរិឡាហា ។ បេ ។ មោហជា បរិឡាហា កាយិកា វា ចេតសិកា វា យេហិ សោ មោហជេហិ បរិឡាហេហិ បរិឌយ្ហមានោ ទុក្ខំ សយេយ្យាតិ ។ ឯវំ ភន្តេ ។ យេហិ ខោ សោ កុមារ គហបតិ វា គហបតិបុត្តោ វា មោហជេហិ បរិឡាហេហិ បរិឌយ្ហមានោ ទុក្ខំ សយេយ្យ

១ ម. ឯវំ ភន្តេតិ ។

ម្នាលកុមារ អ្នកសម្គាល់ហេតុនោះ ដូចម្តេច គហបតីឬគហបតិបុត្រនោះ កើតសេចក្តីរសាប់រសល់ផ្សាយទៅក្នុងកាយក្នុងចិត្ត ដែលបណ្តាលអំពីរាគៈ គហបតីឬគហបតិបុត្រនោះ ត្រូវសេចក្តីរសាប់រសល់ដែលបណ្តាលអំពីរាគៈណា ពោលរាល តើត្រូវដេកជាទុក្ខឬទេ ។ យ៉ាងហ្នឹងហើយព្រះអង្គ ។ ម្នាលកុមារ គហបតីឬគហបតិបុត្រនោះត្រូវសេចក្តីរសាប់-រសល់ ដែលបណ្តាលអំពីរាគៈណា ពោលរាលត្រូវដេកជាទុក្ខ រាគៈនោះតថាគតបានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យកើតទៀត ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាសមិនឲ្យមានទីកើតតទៅទៀតជាធម្មតា ហេតុនោះទើបតថាគតបានសិងជាសុខ ម្នាលកុមារ អ្នកសម្គាល់ហេតុនោះដូចម្តេច គហបតីឬគហបតិបុត្រកើតសេចក្តីរសាប់រសល់ដែលបណ្តាលអំពីទោសៈ ។ បេ ។ កើតសេចក្តីរសាប់រសល់ផ្សាយទៅក្នុងកាយក្នុងចិត្ត ដែលបណ្តាលអំពីមោហៈ បុគ្គលនោះត្រូវសេចក្តីរសាប់រសល់ដែលបណ្តាលអំពីមោហៈណា ពោលរាល តើត្រូវដេកជាទុក្ខឬទេ ។ យ៉ាងហ្នឹងហើយព្រះអង្គ ។ ម្នាលកុមារ គហបតី ឬគហបតិបុត្រនោះត្រូវសេចក្តីរសាប់រសល់ ដែលបណ្តាលអំពីមោហៈណា ពោលរាល ត្រូវដេកជាទុក្ខ

៩១



សោ មោហោ តថាគតស្ស បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ តស្មាហំ សុខមសយិត្ថន្តិ ។

សព្វទា វេ សុខំ សេតិ
ព្រាហ្មណោ បរិនិព្វុតោ
យោ ន លិម្បតិ កាមេសុ
សីតិភូតោ និរូបធិ
សព្វា អាសត្តិយោ ឆេត្វា
វិនេយ្យ ហទយេ ទរំ
ឧបសន្តោ សុខំ សេតិ
សន្តឹ បប្បុយ្យ[1] ចេតសោតិ

១ ម. អប្បេយ្យ ។

មោហៈនោះ តថាគតលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់ហើយ ធ្វើមិនឲ្យកើតទៀត ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស មិនឲ្យមានទីកើតតទៅទៀតជាធម្មតា ហេតុនោះ ទើបតថាគតបានសិង់ជាសុខ ។

អ្នកណាមានបាបបន្សាត់ចោល រំលត់ទុក្ខហើយ រមែងដេកជាសុខសព្វកាល បុគ្គលណាមិនជាប់ជំពាក់ក្នុងកាមទាំងឡាយ មានសេចក្តីត្រជាក់ មិនមានឧបធិក្កិ-លេស បានផ្តាច់បង់នូវតណ្ហាទាំងអស់ បន្ទោបង់នូវសេចក្តីក្រវល់ក្រវាយ ក្នុងហឫទ័យ បុគ្គលស្ងប់រមែងដេកជាសុខដល់នូវការស្ងប់នៃចិត្តបាន ។

[៣៧] តីណីមានិ ភិក្ខវេ ទេវទូតានិ ។ កតមានិ តីណិ ។ ឥធ ភិក្ខវេ ឯកច្ចោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ ។ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ តមេនំ ភិក្ខវេ និរយបាលា នានាពាហាសុ គហេត្វា យមស្ស រញ្ញោ ទស្សេន្តិ អយំ ទេវ បុរិសោ អមេត្តេយ្យោ អបេត្តេយ្យោ អសាមញ្ញោ អព្រហ្មញ្ញោ ន កុលេ ជេដ្ឋាបចាយី ឥមស្ស ទេវោ ទណ្ឌំ បណេតូតិ ។ តមេនំ ភិក្ខវេ យមោ រាជា បឋមំ ទេវទូតំ សមនុយុញ្ជតិ សមនុគ្គាហតិ សមនុភាសតិ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ បឋមំ ទេវទូតំ បាតុភូតន្តិ ។ សោ ឯវមាហ នាទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ ឥត្ថឹ វា បុរិសំ វា អសីតិកំ វា

[៣៧] ម្នាលភិក្ខុទាំងឡាយ ទេវទូតនេះ មាន ៣ ពួក ។ ទេវទូត ៣ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ បុគ្គលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅខាងមុខ តែងកើតក្នុងប្រេត អសុរកាយ តិរច្ឆាន នរក ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុគ្គលនោះត្រង់ដើមដៃទាំងពីរ នាំទៅថ្វាយដល់យមរាជដោយពាក្យថា បពិត្រលោក បុរសនេះប្រព្រឹត្តខុសក្នុងមាតា ប្រព្រឹត្តខុសក្នុងបិតា ប្រព្រឹត្តខុសក្នុងសមណៈ ប្រព្រឹត្តខុសក្នុងខីណាសវព្រាហ្មណ៍ មិនកោតខ្លាចបុគ្គលជាធំក្នុងត្រកូល សូមលោកដាក់អាជ្ញាដល់បុរសនេះ ។ ម្នាលភិក្ខុទាំងឡាយ យមរាជដេញដោលចោទសាកសួរទេវទូតទី ១ ចំពោះបុរសនោះថា ម្នាលបុរសដ៏ចម្រើន អ្នកបានឃើញទេវទូតទី ១ ដែលកើតប្រាកដក្នុងពួកមនុស្សឬទេ ។ បុរសនោះក៏ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ យមរាជ ពោលទៅនឹងបុរសនោះ យ៉ាងនេះថាម្នាលបុរសដ៏ចម្រើន អ្នកបានឃើញស្រីឬប្រុសដែលមានអាយុ៨០ក្តី

នវុតិកំ វា វស្សសតិកំ វា ជាតិយា ជិណ្ណំ គោបានសិវង្កំ ភោគ្គំ ទណ្ឌបរាយនំ បវេធមានំ គច្ឆន្តំ អាតុរំ គតយោព្វនំ ខណ្ឌទន្តំ បលិតកេសំ វិលូនំ ខលិតសិរំ វលិតំ[១] តិលកាហតគត្តន្តិ ។ សោ ឯវមាហ អទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស តស្ស តេ វិញ្ញុស្ស សតោ មហល្លកស្ស ន ឯតទហោសិ អហំបិ ខោម្ហិ ជរាធម្មោ ជរំ អនតីតោ ហន្ទាហំ កល្យាណំ ករោមិ កាយេន វាចាយ មនសាតិ ។ សោ ឯវមាហ នាសក្ខិស្សំ[២] ភន្តេ បមាទស្សំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស បមាទវតាយ ន កល្យាណមកាសិ កាយេន វាចាយ មនសា តគ្ឃ តំ[៣] អម្ភោ បុរិស តថា ករិស្សន្តិ យថាតំ បមត្តំ តំ ខោ បនេតំ បាបកម្មំ នេវ មាតរា កតំ ន បិតរា កតំ

---

១ ឱ. ខលិតំ សិរោ វលិតំ ។ ២ ឱ. ម. នាហំ សក្ខិស្សំ ។ ៣ ឱ. ត្វំ ។

អាយុ ៩០ ក្តី អាយុ ១០០ ឆ្នាំក្តី គ្រាំគ្រាដោយជាតិ ទោរដូចជាបង្កង់ មានខ្នងកោង មានឈើច្រត់នាំមុខ ដើរញ័រញ័រ រសាប់រសល់ព្រោះជរា មានវ័យកន្លងហើយ ធ្មេញបាក់ សក់ស្កូវ មានក្បាលធក មានក្បាលទំពែក មានស្បែកជ្រីវ មានខ្លួនដាសដោយប្រជ្រុយ ក្នុងពួកមនុស្សដែរឬទេ ។ បុរសនោះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញហើយ ។ ម្នាលភិក្ខុទាំងឡាយ យមរាជពោលនឹងបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកឯងជាមនុស្សដឹងក្តី មានស្មារតី ចាស់ហើយ តែមិនមានគំនិតយ៉ាងនេះថា អាត្មាអញក៏មានសេចក្តីគ្រាំគ្រាជាធម្មតា មិនកន្លងសេចក្តីគ្រាំគ្រាបានឡើយ បើដូច្នោះគួរអាត្មាអញធ្វើសេចក្តីល្អដោយកាយ វាចា ចិត្ត ។ បុរសនោះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាច (នឹកឃើញទៅហើយ) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានជាប្រហែសទៅហើយ ។ ម្នាលភិក្ខុទាំងឡាយ យមរាជពោលនឹងបុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកមិនបានធ្វើនូវអំពើល្អដោយកាយ វាចា ចិត្ត ព្រោះតែសេចក្តីប្រហែស ម្នាលបុរសដ៏ចម្រើន ពួកនិរយបាលនឹងធ្វើទោសអ្នក តាមអំពើដែលអ្នកប្រហែសហើយនោះឯង អំពើបាបនោះឯង មិនមែនមាតាធ្វើ មិនមែនបិតាធ្វើ

ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន ទេវតាហិ កតំ ន សមណព្រាហ្មណេហិ កតំ អថខោ តយាវេតំ បាបកម្មំ កតំ ត្វញ្ញេវ តស្ស វិបាកំ បដិសំវេ-ទិស្សសីតិ[១] ។ តមេនំ ភិក្ខវេ យមោ រាជា បឋមំ ទេវទូតំ សមនុយុញ្ជិត្វា សមនុគ្គាហិត្វា សមនុភាសិត្វា ទុតិយំ ទេវទូតំ សមនុយុញ្ជតិ សមនុគ្គាហតិ សមនុ-ភាសតិ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ ទុតិយំ ទេវទូតំ បាតុភូតន្តិ ។ សោ ឯវមាហ នាទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ ឥត្ថឹ វា បុរិសំ វា អាពាធិកំ ទុក្ខិតំ ពាឡ្ហគិលានំ សកេ មុត្តករីសេ បលិបន្នំ សេមានំ អញ្ញេហិ វុដ្ឋាបិ-យមានំ[២] អញ្ញេហិ សំវេសិយមានន្តិ ។ សោ ឯវមាហ អទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស តស្ស តេ វិញ្ញុស្ស សតោ មហល្លកស្ស ន ឯតទហោសិ

១ ឱ. បដិសំវេទិយសីតិ ។ ២ ម. សេយ្យមានំ អញ្ញេហិ វុដ្ឋាបិយមានំ ។ ឱ. អញ្ញេហិ ច វុដ្ឋាបិយមានំ ។

មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនពួកមិត្តនិងអាមាត្យធ្វើ មិនមែនពួកញាតិនិងសាលោហិតធ្វើ មិនមែនពួកទេវតាធ្វើ មិនមែនពួកសមណៈនិងព្រាហ្មណ៍ធ្វើទេ អំពើអាក្រក់នោះ អ្នកឯងធ្វើជាប្រាកដ អ្នកឯងនឹងទទួលផលនៃអំពើអាក្រក់នោះ ។ ម្នាលភិក្ខុទាំងឡាយ យមរាជដេញដោលចោទសាកសួរទេវទូតទី ១ ចំពោះបុរសនោះហើយ ក៏ដេញដោលចោទសាកសួរទេវទូតទី ២ ថា នែបុរសដ៏ចម្រើន អ្នកបានឃើញទេវទូតទី ២ កើតប្រាកដក្នុងពួកមនុស្សឬទេ ។ បុរសនោះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ យមរាជពោលនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកបានឃើញស្រីក្តី ប្រុសក្តី មានអាពាធដល់នូវសេចក្តីទុក្ខឈឺធ្ងន់ ដេកប្រឡាក់ក្នុងមូត្រនិងករីសខ្លួន ដែលពួកជនដទៃគ្រាហ៍ឲ្យក្រោក ពួកជនដទៃផ្តេកឲ្យដេកក្នុងពួកមនុស្សដែរឬទេ ។ បុរសនោះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញហើយ ។ ម្នាលភិក្ខុទាំងឡាយ យមរាជពោលនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកឯងជាមនុស្សដឹងក្តីចាស់ហើយ ក៏នៅតែឥតមានគំនិតដូច្នេះថា

អហំបិ ខោម្ភោ ព្យាធិធម្មោ ព្យាធឹ អនតីតោ ហន្ទាហំ កល្យាណំ ករោមិ កាយេន វាចាយ មនសាតិ ។ សោ ឯវមាហ នាសក្ខិស្សំ ភន្តេ បមាទស្សំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស បមាទវតាយ ន កល្យាណមកាសិ កាយេន វាចាយ មនសា តគ្ឃ តំ អម្ភោ បុរិស តថា ករិស្សន្តិ យថាតំ បមត្តំ តំ ខោ បនេតំ បាបកម្មំ នេវ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន ទេវតាហិ កតំ ន សមណព្រាហ្មណេហិ កតំ អថខោ តយាវេតំ បាបកម្មំ កតំ ត្វញ្ញេវ តស្ស វិបាកំ បដិសំវេទិស្សសីតិ ។ តមេនំ ភិក្ខវេ យមោ រាជា ទុតិយំ ទេវទូតំ សមនុយុញ្ជិត្វា សមនុគ្គាហិត្វា សមនុភាសិត្វា តតិយំ ទេវទូតំ សមនុយុញ្ជតិ សមនុគ្គាហតិ សមនុភាសតិ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ តតិយំ ទេវទូតំ បាតុភូតន្តិ ។

អញមានព្យាធិជាធម្មតា មិនកន្លងព្យាធិបានឡើយ គួរតែអាត្មាអញធ្វើល្អដោយកាយ វាចា ចិត្ត ។ បុរសនោះ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានជាមិនអាច (នឹកឃើញទៅហើយ) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានជាប្រហែសទៅហើយ ។ ម្នាលភិក្ខុទាំងឡាយ យមរាជពោលនឹងបុរសនោះ យ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកមិនបានធ្វើកុសលដោយកាយ វាចា ចិត្ត ព្រោះសេចក្តីធ្វេសប្រហែស នែបុរសដ៏ចម្រើន អើពួកនិរយបាលនឹងធ្វើទោសអ្នកតាមអំពើដែលអ្នកប្រហែសហើយនោះ អំពើអាក្រក់នោះឯង មិនមែនមាតាធ្វើ មិនមែនបិតាធ្វើ មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនពួកមិត្តនិងអាមាត្យធ្វើ មិនមែនពួកញាតិនិងសាលោហិតធ្វើ មិនមែនពួកទេវតាធ្វើ មិនមែនពួកសមណៈនិងព្រាហ្មណ៍ធ្វើទេ អំពើអាក្រក់នោះអ្នកឯងធ្វើជាប្រាកដ អ្នកនឹងទទួលផលនៃអំពើអាក្រក់នោះ ។ ម្នាលភិក្ខុទាំងឡាយ លុះយមរាជដេញដោលចោទសាកសួរទេវទូត ទី ២ ចំពោះបុរសនោះហើយ ក៏ដេញដោលចោទសាកសួរទេវទូតទី ៣ ថា ម្នាលបុរសដ៏ចម្រើន អ្នកបានឃើញទេវទូត ទី ៣ កើតប្រាកដក្នុងពួកមនុស្សខ្លះឬទេ ។

សោ ឯវមាហ នាទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស ន ត្វំ អទ្ទស មនុស្សេសុ ឥត្ថឹ វា បុរិសំ វា ឯកាហមតំ វា ទ្វីហមតំ វា តីហមតំ វា ឧទ្ធុមាតកំ វិនីលកំ វិបុព្វកជាតន្តិ ។ សោ ឯវមាហ អទ្ទសំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស តស្ស តេ វិញ្ញុស្ស សតោ មហល្លកស្ស ន ឯតទហោសិ អហំបិ ខោម្ហិ មរណធម្មោ មរណំ អនតីតោ ហន្ទាហំ កល្យាណំ ករោមិ កាយេន វាចាយ មនសាតិ ។ សោ ឯវមាហ នាសក្ខិស្សំ ភន្តេ បមាទស្សំ ភន្តេតិ ។ តមេនំ ភិក្ខវេ យមោ រាជា ឯវមាហ អម្ភោ បុរិស បមាទវតាយ ន កល្យាណមកាសិ កាយេន វាចាយ មនសា តគ្ឃ តំ អម្ភោ បុរិស តថា ករិស្សន្តិ យថាតំ បមត្តំ តំ ខោ បនេតំ បាបកម្មំ នេវ មាតរា កតំ

បុរសនោះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ យមរាជពោលនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកបានឃើញស្រីក្តី ប្រុសក្តី ដែលស្លាប់ ១ ថ្ងៃក្តី ស្លាប់ ២ ថ្ងៃក្តី ស្លាប់ ៣ ថ្ងៃក្តី ជាអសុភហើមប៉ោងមានសម្បុរខៀវ មានខ្ទុះហូរចេញ ក្នុងពួកមនុស្សដែរឬទេ ។ បុរសនោះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឃើញហើយ ។ ម្នាលភិក្ខុទាំងឡាយ យមរាជពោលនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកឯងជាមនុស្សដឹងក្តីចាស់ហើយ នៅតែមិនមានសេចក្តីត្រិះរិះដូច្នេះថា អាត្មាអញមានសេចក្តីស្លាប់ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបាន គួរតែអាត្មាអញធ្វើល្អដោយកាយ វាចា ចិត្ត ។ បុរសនោះក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានជាមិនអាច (នឹកឃើញទៅហើយ) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានជាប្រហែសធ្វេសទៅហើយ ។ ម្នាលភិក្ខុទាំង-ឡាយ យមរាជពោលនឹងបុរសនោះយ៉ាងនេះថា ម្នាលបុរសដ៏ចម្រើន អ្នកមិនបានធ្វើកុសលដោយកាយ វាចា ចិត្ត ព្រោះសេចក្តីប្រហែសធ្វេស អើបុរសដ៏ចម្រើន មុខជាពួកនិរយបាលនឹងធ្វើទោសអ្នកតាមអំពើដែលអ្នកប្រហែសហើយនោះ អំពើអាក្រក់នោះឯង មិនមែនមាតាធ្វើ

ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន ទេវតាហិ កតំ ន សមណព្រាហ្មណេហិ កតំ អថខោ តយាវេតំ បាបកម្មំ កតំ ត្វញ្ញេវ តស្ស វិបាកំ បដិសំវេទិស្សសីតិ ។ តមេនំ ភិក្ខវេ យមោ រាជា តតិយំ ទេវទូតំ សមនុយុញ្ជិត្វា សមនុគ្គាហិត្វា សមនុភាសិត្វា តុណ្ហី ហោតិ ។ តមេនំ ភិក្ខវេ និរយបាលា បញ្ចវិធពន្ធនំ នាម កម្មករណំ ករោន្តិ តត្តំ អយោខីលំ ហត្ថេ គមេន្តិ តត្តំ អយោខីលំ ទុតិយស្មឹ ហត្ថេ គមេន្តិ តត្តំ អយោខីលំ បាទេ គមេន្តិ តត្តំ អយោខីលំ ទុតិយស្មឹ បាទេ គមេន្តិ តត្តំ អយោខីលំ មជ្ឈេឧរស្មឹ គមេន្តិ ។ សោ តត្ថ ទុក្ខា តិព្វា ខរា កដុកា វេទនា វេទិយតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។ តមេនំ ភិក្ខវេ និរយបាលា សំវេសិត្វា កុឋារីហិ(១) តច្ឆន្តិ ។

១ ម. សំកឡ្សិត្វា កុធារីហិ ។

មិនមែនបិតាធ្វើ មិនមែនបងប្អូនប្រុសធ្វើ មិនមែនបងប្អូនស្រីធ្វើ មិនមែនពួកមិត្តនិងអាមាត្យធ្វើ មិនមែនពួកញាតិនិងសាលោហិតធ្វើ មិនមែនពួកទេវតាធ្វើ មិនមែនពួកសមណព្រាហ្មណ៍ធ្វើទេ ប្រាកដជាអ្នកឯងធ្វើអំពើអាក្រក់នោះ អ្នកឯងនឹងទទួលយកផល នៃអំពើអាក្រក់នោះ ។ ម្នាលភិក្ខុទាំងឡាយ លុះយមរាជ ដេញដោលចោទសាកសួរទេវទូតទី ៣ ហើយក៏ស្ងៀម ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលធ្វើកម្មករណ៍ ដែលហៅថាចំណង ៥ ប្រការចំពោះបុរសនោះ គឺបោះដែកគោលដ៏ក្តៅទៅត្រង់ដៃ បោះដែកគោលដ៏ក្តៅទៅត្រង់ដៃទី ២ បោះដែកគោលដ៏ក្តៅទៅត្រង់ជើង បោះដែកគោលដ៏ក្តៅទៅត្រង់ជើងទី ២ បោះដែកគោលដ៏ក្តៅត្រង់កណ្តាលទ្រូង ។ បុរសនោះទទួលវេទនាដ៏ក្លា ក្តៅក្រហាយ ក្នុងនរកនោះ អំពើអាក្រក់នោះមិនទាន់អស់ ដរាបណា មិនទាន់ធ្វើមរណកាល ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលផ្តេកបុរសនោះ ចាំងដោយដឹងទាំងឡាយ ។

សោ តត្ថ ទុក្ខា តិព្វា ខរា កដុកា វេទនា វេទិយតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។ តមេនំ ភិក្ខវេ និរយបាលា ឧទ្ធំបាទំ អធោសិរំ ឋបេត្វា[១] វាសីហិ តច្ឆន្តិ... តមេនំ ភិក្ខវេ និរយបាលា រថេ យោជេត្វា អាទិត្តាយ ភូមិយា សម្បជ្ជលិតាយ សញ្ជោតិភូតាយ សារេន្តិបិ បច្ចាសារេន្តិបិ[២]... តមេនំ ភិក្ខវេ និរយបាលា មហន្តំ អង្គារបព្វតំ អាទិត្តំ សម្បជ្ជលិតំ សញ្ជោតិភូតំ អារោបេន្តិបិ ឱរោបេន្តិបិ... តមេនំ ភិក្ខវេ និរយបាលា ឧទ្ធំបាទំ អធោសិរំ គហេត្វា តត្តាយ លោហកុម្ភិយា បក្ខិបន្តិ អាទិត្តាយ សម្បជ្ជលិតាយ សញ្ជោតិភូតាយ ។ សោ តត្ថ ផេណុទ្ទេហកំ បច្ចតិ ។ សោ តត្ថ ផេណុទ្ទេហកំ បច្ចមានោ សកិំបិ ឧទ្ធំ គច្ឆតិ សកិំបិ អធោ គច្ឆតិ សកិំបិ តិរិយំ គច្ឆតិ ៕

១ ម. គហេត្វា ។ ២ ម. ហារន្តិបិ បច្ចាហារន្តិបិ ។

បុរសនោះ ក៏ទទួលទុក្ខវេទនាដ៏ក្លារឹង ផ្សាខ្លោច ក្នុងនរកនោះ អំពើអាក្រក់នោះមិនទាន់អស់ ដរាបណា មិនទាន់ធ្វើមរណកាល ដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុរសនោះបញ្ឈរឲ្យមានជើងឡើងលើ ក្បាលចុះក្រោមច្រាស់នឹងកាំបិតព្រាទាំងឡាយ... ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលទឹមបុរសនោះនឹងរថបរទៅមកលើផែនដីដែលមានភ្លើងឆេះ រុងរឿងសន្ធោសន្ធៅ... ម្នាលភិក្ខុទាំងឡាយ ពួកនិរយ-បាលឲ្យបុរសនោះ ឡើងចុះភ្នំរងើកភ្លើងដ៏ធំ ដែលភ្លើងកំពុងឆេះប្រាលផ្សោសន្ធោសន្ធៅ... ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុរសនោះបញ្ឈរជើងឡើងលើ ក្បាលចុះក្រោម បោះទៅក្នុងខ្ទះលោហៈដ៏ក្តៅដែលឆេះប្រាលផ្សោសន្ធោសន្ធៅ ។ បុរសនោះត្រូវបាបកម្មស្ងោរនៅក្នុងខ្ទះលោហៈនោះ ផុលឡើងដូចជាពពុះទឹក ។ កាលបុរសនោះត្រូវបាបកម្មស្ងោរនៅក្នុងខ្ទះលោហៈនោះ ផុលឡើង ដូចជាពពុះទឹក ជួនណាពុះខ្ពោលឡើងលើម្តង លិចចុះក្រោមម្តង ជួនណាទៅទទឹងម្តង ។

សោ តត្ថ ទុក្ខា តិព្វា ខរា កដុកា វេទនា វេទិយតិ ន ច តាវ កាលំ ករោតិ យាវ ន តំ បាបកម្មំ ព្យន្តីហោតិ ។ តមេនំ ភិក្ខវេ និរយបាលា មហានិរយេ បក្ខិបន្តិ ។ សោ ខោ បន ភិក្ខវេ មហានិរយោ

ចតុក្កណ្ណោ ចតុទ្វារោ
វិភត្តោ ភាគសោ មិតោ
អយោបាការបរិយន្តោ
អយសា បដិកុជ្ជិតោ
តស្ស អយោមយា ភូមិ
ជលិតា តេជសា យុតា
សមន្តា យោជនសតំ
ផរិត្វា តិដ្ឋតិ សព្វទា ។

ភូតបុព្វំ ភិក្ខវេ យមស្ស រញ្ញោ ឯតទហោសិ យេ កិរ ភោ លោកេ បាបកានិ កម្មានិ ករោន្តិ

បុរសនោះ ក៏ទទួលវេទនាជាទុក្ខដ៏ក្លារឹង ក្តៅក្រហាយ ក្នុងនរកនោះ អំពើអាក្រក់មិនទាន់អស់ ដរាបណា ក៏មិនទាន់ធ្វើមរណកាលដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ទើបពួកនិរយបាល បោះបុរសនោះទៅក្នុងមហានរក (មហាអវីចិ) ។ ម្នាលភិក្ខុទាំងឡាយ ឯមហានរកនោះឯង

មានជ្រុង ៤ មានទ្វារ ៤ ដែលកម្មចែកហើយ ដោយ

ចំណែក វាស់ដោយចំណែក មានកំពែងដែកព័ទ្ធជុំវិញ

ប្រក់ដោយដែក ផែនដីរបស់នរកនោះ សុទ្ធតែដែក

ប្រាលផ្លោ ប្រកបដោយភ្លើងផ្សាយទៅអស់ ១០០

យោជន៍ជុំវិញ តាំងនៅសព្វ ៗ កាល ។

ម្នាលភិក្ខុទាំងឡាយ ធ្លាប់មានរឿងមកថា យមរាជ មានសេចក្តីត្រិះរិះ ដូច្នេះថា ម្នាលអ្នកដ៏ចម្រើន ឮថាពួកសត្វណា ធ្វើអំពើអាក្រក់ក្នុងលោក

តេ ឯវរូបា វិវិធា កម្មការណា ការេន្តិ អហោ វតាហំ មនុស្សត្តំ លភេយ្យំ តថាគតោ ច លោកេ ឧប្បជ្ជេយ្យ អរហំ សម្មាសម្ពុទ្ធោ តញ្ចាហំ ភគវន្តំ បយិរុបាសេយ្យំ សោ ច ភគវា ធម្មំ ទេសេយ្យ តស្ស ចាហំ ភគវតោ ធម្មំ អាជានេយ្យន្តិ ។ តំ ខោ បនាហំ ភិក្ខវេ ន អញ្ញស្ស សមណស្ស វា ព្រាហ្មណស្ស វា សុត្វា ឯវំ វទាមិ អបិច ខោ ភិក្ខវេ យទេវ មេ សាមំ ញាតំ សាមំ ទិដ្ឋំ សាមំ វិទិតំ តទេវាហំ វទាមីតិ ។

ចោទិតា ទេវទូតេហិ
យេ បមជ្ជន្តិ មាណវា
តេ ទីឃរត្តំ សោចន្តិ
ហីនកាយូបគា នរា ។
យេ ច ខោ ទេវទូតេហិ
សន្តោ សប្បុរិសា ឥធ
ចោទិតា នប្បមជ្ជន្តិ
អរិយធម្មេ កុទាចនំ

ពួកសត្វនោះត្រូវពួកនិរយបាលធ្វើកម្មករណ៍ផ្សេងៗ មានសភាពយ៉ាងនេះ អើហ្ន៎ សូមឲ្យអាត្មាអញបានកើតជាមនុស្ស សូមឲ្យព្រះតថាគតអរហន្ត សម្មាសម្ពុទ្ធ កើតក្នុងលោក អាត្មាអញសោត គប្បីបានអង្គុយជិត ព្រះដ៏មានព្រះភាគនោះ គប្បីសម្តែងធម៌ អាត្មាអញ គប្បីយល់ធម៌ របស់ព្រះមានព្រះភាគនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងបានឮនូវហេតុនោះ អំពីសំណាក់នៃសមណៈ ឬព្រាហ្មណ៍ដទៃ ហើយសម្តែងយ៉ាងនេះក៏ទេ ម្នាលភិក្ខុទាំងឡាយ ប្រាកដជាតថាគតបានសម្តែងហេតុនោះឯង ដែលតថាគតដឹងដោយខ្លួនឯង ឃើញដោយខ្លួនឯង យល់ជាក់ច្បាស់ដោយខ្លួនឯង ។

មាណពណា ដែលទេវទូតដាស់តឿនហើយ នៅតែ
ប្រហែសធ្វេស មាណពនោះ ទៅកើតក្នុងពួកថោក
ទាប រមែងសោកសង្រេងអស់រាត្រីវែង ។ នរជនណា
ជាសប្បុរស ស្ងប់ទុក្ខក្នុងលោកនេះ ដែលទេវទូតដាស់
តឿនហើយ មិនប្រហែសធ្វេសក្នុងអរិយធម៌ក្នុងកាលខ្លះ

ឧបាទានេ ភយំ ទិស្វា
ជាតិមរណសម្ភវេ
អនុបាទា វិមុច្ចន្តិ
ជាតិមរណសង្ខយេ
តេ ខេមប្បត្តា សុខិតា[១]
ទិដ្ឋធម្មាភិនិព្វុតា
សព្វវេរភយាតីតា
សព្វទុក្ខំ ឧបច្ចគុន្តិ ។

[៣៨] អដ្ឋមិយំ ភិក្ខវេ បក្ខស្ស ចតុន្នំ មហារាជានំ អមច្ចា បារិសជ្ជា ឥមំ លោកំ អនុវិចរន្តិ កច្ចិ ពហូ មនុស្សា មនុស្សេសុ មេត្តេយ្យា បេត្តេយ្យា សាមញ្ញា ព្រហ្មញ្ញា កុលេជេដ្ឋាបចាយិនោ ឧបោសថំ ឧបវសន្តិ បដិជាគរោន្តិ បុញ្ញានិ ករោន្តីតិ ។ ចាតុទ្ទសិយំ ភិក្ខវេ បក្ខស្ស ចតុន្នំ មហារាជានំ បុត្តា ឥមំ លោកំ អនុវិចរន្តិ កច្ចិ ពហូ មនុស្សា មនុស្សេសុ

១ ម. តេ ខេមប្បត្តា សុខិនោ ។

ឃើញភ័យក្នុងឧបាទាន ជាដែនកើតនៃជាតិនិងមរណៈ រមែងរួចស្រឡះ ព្រោះមិនប្រកាន់ ក្នុងការអស់ជាតិនិងមរណៈ នរជននោះ ដល់នូវសេចក្តីក្សេមនិងសុខ រលត់កិលេស ក្នុងបច្ចុប្បន្ន កន្លងបង់នូវពៀរនិងភ័យទាំងអស់ កន្លងនូវសេចក្តីទុក្ខ ទាំងអស់បាន ។

[៣៨] ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃទី ៨ នៃបក្ខ ពួកអាមាត្យជាបរិសទ្យរបស់ស្តេចធំទាំង ៤ តែងដើរត្រួតលោកនេះ ដោយគិតថា បណ្តាមនុស្សទាំងឡាយ គង់មានពួកមនុស្សជាច្រើន ជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ កោតក្រែងបុគ្គលជាធំ ក្នុងត្រកូល រក្សាបកតិឧបោសថ រក្សាបដិជាគរឧបោសថ ធ្វើបុណ្យទាំងឡាយខ្លះដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃទី ១៤ នៃបក្ខ ពួករាជបុត្ររបស់ស្តេចធំទាំង ៤ តែងដើរត្រួតលោកនេះ ដោយគិតថា បណ្តាមនុស្សទាំងឡាយ គង់មានពួកមនុស្សជាច្រើន

មេត្តេយ្យា បេត្តេយ្យា សាមញ្ញា ព្រហ្មញ្ញា កុលេជេដ្ឋាបចាយិនោ ឧបោសថំ ឧបវសន្តិ បដិជាគរោន្តិ បុញ្ញានិ ករោន្តីតិ ។ តេនហុ ភិក្ខវេ ឧបោសថេ បណ្ណរសេ ចត្តារោ មហា-រាជានោ សាមញ្ញេវ ឥមំ លោកំ អនុវិចរន្តិ កច្ចិ ពហូ មនុស្សា មនុស្សេសុ មេត្តេយ្យា បេត្តេយ្យា សាមញ្ញា ព្រហ្មញ្ញា កុលេជេដ្ឋាបចា-យិនោ ឧបោសថំ ឧបវសន្តិ បដិជាគរោន្តិ បុញ្ញានិ ករោន្តីតិ ។ សចេ ភិក្ខវេ អប្បកា ហោន្តិ មនុស្សា មនុស្សេសុ មេត្តេយ្យា បេត្តេយ្យា សាមញ្ញា ព្រហ្មញ្ញា កុលេជេដ្ឋាបចាយិនោ ឧបោ-សថំ ឧបវសន្តិ បដិជាគរោន្តិ បុញ្ញានិ ករោន្តីតិ ។ តមេនំ ភិក្ខវេ ចត្តារោ មហារាជានោ ទេវានំ តាវត្តឹសានំ សុធម្មាយំ សភាយំ សន្និសិន្នានំ សន្និបតិតានំ អារោចេន្តិ អប្បកា ខោ មារិសា មនុស្សា មនុស្សេសុ មេត្តេយ្យា បេត្តេយ្យា សាមញ្ញា ព្រហ្មញ្ញា កុលេជេដ្ឋាបចាយិនោ

ជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ កោតក្រែងបុគ្គលជាធំ ក្នុងត្រកូល រក្សាបកតិឧបោសថ ធ្វើបដិជាគរឧបោសថ ធ្វើបុណ្យទាំងឡាយខ្លះដែរឬ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃបណ្ណរសី-ឧបោសថនោះ ពួកស្តេចធំទាំង ៤ តែងដើរត្រួតមើលលោកនេះខ្លួនឯង ដោយគិតថា បណ្តាមនុស្សទាំងឡាយ គង់មានពួកមនុស្សជាច្រើន ជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ កោតក្រែងបុគ្គលជាធំ ក្នុងត្រកូល រក្សាបកតិឧបោសថ ធ្វើបដិជាគរឧបោសថ ធ្វើបុណ្យទាំងឡាយខ្លះដែរឬ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាមនុស្សទាំងឡាយ បើពួកមនុស្ស ជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ កោតក្រែងបុគ្គលជាធំ ក្នុងត្រកូល រក្សាបកតិឧបោសថ ធ្វើបដិជាគរឧបោសថ ធ្វើបុណ្យទាំងឡាយមានតិចគ្នា ។ ម្នាលភិក្ខុទាំងឡាយ ស្តេចធំទាំង ៤ ប្រាប់ដំណឹងនោះ ដល់ពួកទេវតាស្ថានតាវត្តិង្ស ដែលអង្គុយប្រជុំគ្នា ក្នុងសាលាសុធម្មាថា នៃអ្នកនិទ៌ុក្ខទាំងឡាយ បណ្តាមនុស្សទាំងឡាយ ពួកមនុស្សជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍

ឧបោសថំ ឧបវសន្តិ បដិជាគរោន្តិ បុញ្ញានិ ករោន្តីតិ ។ តេន[១] ភិក្ខវេ ទេវា តាវត្តឹសា អនត្តមនា ហោន្តិ ទិព្វា វត ភោ កាយា បរិហាយិស្សន្តិ បរិបូរេស្សន្តិ អសុរកាយាតិ ។ សចេ បន ភិក្ខវេ ពហូ ហោន្តិ មនុស្សា មនុស្សេសុ មេត្តេយ្យា បេត្តេយ្យា សាមញ្ញា ព្រហ្មញ្ញា កុលេជេដ្ឋាបចាយិនោ ឧបោសថំ ឧបវសន្តិ បដិជាគរោន្តិ បុញ្ញានិ ករោន្តីតិ ។ តមេនំ ភិក្ខវេ ចត្តារោ មហារាជានោ ទេវានំ តាវត្តឹសានំ សុធម្មាយំ សភាយំ សន្និសិន្នានំ សន្និបតិតានំ អារោចេន្តិ ពហូ ខោ មារិសា មនុស្សា មនុស្សេសុ មេត្តេយ្យា បេត្តេយ្យា សាមញ្ញា ព្រហ្មញ្ញា កុលេជេដ្ឋាបចាយិនោ ឧបោសថំ ឧបវសន្តិ បដិជាគរោន្តិ បុញ្ញានិ ករោន្តីតិ ។ តេន ភិក្ខវេ ទេវា តាវត្តឹសា អត្តមនា ហោន្តិ ទិព្វា វត ភោ កាយា បរិបូរិស្សន្តិ បរិហាយិស្សន្តិ អសុរកាយាតិ ។

១ ឱ. តេនហិ ។ ម. តេន ខោ ។

កោតក្រែងបុគ្គលជាធំ ក្នុងត្រកូល រក្សាបកតិឧបោសថ ធ្វើបដិជាគរ-ឧបោសថ ធ្វើកុសលទាំងឡាយតិចគ្នាណាស់ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ពួកតាវត្តិង្សទេវតាតូចចិត្តថា ម្នាលអ្នកដ៏ចម្រើន ពួកទេវតានឹងសាបសូន្យ ពួកអសុរនឹងកុះករ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាមនុស្សទាំងឡាយ បើពួកមនុស្ស ជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ កោតក្រែងបុគ្គលជាធំ ក្នុងត្រកូល រក្សាបកតិឧបោសថ ធ្វើបដិជាគរឧបោសថ ធ្វើបុណ្យទាំងឡាយ មានចំនួនច្រើនគ្នា ។ ម្នាលភិក្ខុទាំងឡាយ ស្តេចធំទាំង ៤ តែងប្រាប់ដំណឹងនោះដល់តាវត្តិង្សទេវតា ដែលអង្គុយប្រជុំក្នុងសាលាឈ្មោះសុធម្មាថា ម្នាលអ្នកនិទ៌ុក្ខទាំងឡាយ បណ្តាមនុស្សទាំងឡាយ ពួកមនុស្សជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ កោតក្រែងបុគ្គលជាធំ ក្នុងត្រកូល រក្សាបកតិឧបោសថ ធ្វើបដិជាគរឧបោសថ ធ្វើបុណ្យទាំង-ឡាយច្រើនគ្នា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ពួកតាវត្តិង្ស-ទេវតា មានសេចក្តីពេញចិត្តថា ម្នាលអ្នកដ៏ចម្រើន ពួកទេវតានឹងកុះករ ពួកអសុរនឹងសាបសូន្យ ។

[៣៩] ភូតបុព្វំ ភិក្ខវេ សក្កោ ទេវានមិន្ទោ ទេវេ តាវតឹសេ អនុនយមានោ តាយំ វេលាយំ ឥមំ គាថំ អភាសិ

ចាតុទ្ទសឹ បញ្ចទសឹ
យា ច បក្ខស្ស អដ្ឋមី
ចាដិហារិយបក្ខញ្ច
អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសេយ្យ
យោបស្ស មាទិសោ នរោតិ ។

សា ខោ បនេសា ភិក្ខវេ សក្កេន ទេវានមិន្ទេន គាថា ទុគ្គីតា ន សុគីតា ទុព្ភាសិតា ន សុភាសិតា ។ តំ កិស្ស ហេតុ ។ សក្កោ ហិ ភិក្ខវេ ទេវានមិន្ទោ អវីតរាគោ អវីតទោសោ អវីតមោហោ ។ យោ ច ខោ សោ ភិក្ខវេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ

[៣៩] ម្នាលភិក្ខុទាំងឡាយ ធ្លាប់មានរឿងមក កាលសក្កទេវរាជជាធំជាងពួកទេវតា ដាស់តឿនក្រើនរំលឹកពួកតាវត្តិង្សទេវតា បានពោលគាថានេះ ក្នុងពេលនោះថា

នរៈណាដូចជាយើង នរៈនោះ ត្រូវរក្សាឧបោសថ
ប្រកបដោយអង្គ ៨ ក្នុងតិថីទី ១៤ ផង តិថីទី ១៥ ផង
ទី ៨ នៃបក្ខ ផង បាដិហារិយបក្ខ ផង

ម្នាលភិក្ខុទាំងឡាយ គាថានោះឯង ដែលសក្កៈជាធំជាងទេវតា ច្រៀងទាស់ហើយ មិនមែនច្រៀងត្រូវទេ ពោលទាស់ហើយ មិនមែនពោលត្រូវទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះសក្កជាធំជាងពួកទេវតា មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ។ ម្នាលភិក្ខុទាំងឡាយ លុះតែភិក្ខុណាជាអរហន្តខីណាស្រព នៅចប់ព្រហ្មចារ្យហើយ មានកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ

អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញា-វិមុត្តោ តស្ស ខោ ឯតំ ភិក្ខុនោ[១] កល្លំ វចនាយ

ចាតុទ្ទសី បញ្ចទសី
យា ច បក្ខស្ស អដ្ឋមី
ចាដិហារិយបក្ខញ្ច
អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសេយ្យ
យោបស្ស មាទិសោ នរោតិ ។

តំ កិស្ស ហេតុ ។ សោ ហិ ភិក្ខវេ ភិក្ខុ វីតរាគោ វីតទោសោ វីតមោហោតិ ។ ភូតបុព្វំ ភិក្ខវេ សក្កោ ទេវានមិន្ទោ ទេវេ តាវតឹសេ អនុនយមានោ តាយំ វេលាយំ ឥមំ គាថំ អភាសិ

១ ឱ. ឯតំ ភិក្ខវេ ភិក្ខុនោ ។ ម. ឯវំ ភិក្ខវេ ភិក្ខុនោ ។

សម្រេចអរហត្តហើយ អស់សំយោជនៈក្នុងភពហើយ ជាអ្នកផុត

ស្រឡះព្រោះដឹងនូវហេតុ ភិក្ខុនោះឯងទើបគួរពោលនូវគាថានោះថា

នរៈណាប្រាកដដូចជាយើង នរៈនោះត្រូវរក្សាឧបោសថ

ប្រកបដោយអង្គ ៨ ក្នុងតិថីទី ១៤ ផង ទី ១៥ ផង

ទី ៨ នៃបក្ខផង បាដិហារិយបក្ខផង ។

ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុនោះ ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ។ ម្នាលភិក្ខុទាំងឡាយ ធ្លាប់មានរឿងមក កាលសក្កទេវរាជ ជាធំជាងពួកទេវតាជាស់តឿន ពួកតាវត្តិង្សទេវតា បានពោលគាថានេះ ក្នុងពេលនោះថា

ចាតុទ្ទសី បញ្ចទសី
យា ច បក្ខស្ស អដ្ឋមី
បាដិហារិយបក្ខញ្ច
អដ្ឋង្គសុសមាគតំ
ឧបោសថំ ឧបវសេយ្យ
យោបស្ស មាទិសោ នរោតិ ។

សា ខោ បនេសា ភិក្ខវេ សក្កេន ទេវានមិន្ទេន គាថា ទុគ្គីតា ន សុគីតា ទុព្ភាសិតា ន សុភាសិតា ។ តំ កិស្ស ហេតុ ។ សក្កោ ហិ ភិក្ខវេ ទេវានមិន្ទោ អបរិមុត្តោ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ អបរិមុត្តោ ទុក្ខស្មាតិ វទាមិ ។ យោ ច ខោ សោ ភិក្ខវេ ភិក្ខុ អរហំ ខីណាសវោ វុសិតវា កតករណីយោ ឱហិតភារោ អនុប្បត្តសទត្ថោ បរិក្ខីណភវសំយោជនោ សម្មទញ្ញាវិមុត្តោ តស្ស ខោ ឯតំ ភិក្ខុនោ កល្លំ វចនាយ

នរៈណាប្រាកដដូចជាយើង នរៈនោះ ត្រូវរក្សា ឧបោសថ ប្រកបដោយអង្គ ៨ ក្នុងតិថីទី ១៤ ផង ទី ១៥ ផង ទី ៨ នៃបក្ខផង បាដិហារិយបក្ខ ផង ។

ម្នាលភិក្ខុទាំងឡាយ គាថានោះសក្កទេវរាជជាធំ ជាងទេវតា ច្រៀងទាស់ហើយ មិនមែនច្រៀងត្រូវទេ ពោលទាស់ហើយ មិនមែនពោលត្រូវទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះសក្កៈជាធំជាងទេវតាមិនទាន់ផុតចាកជាតិ ជរា មរណៈ សោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្ដីតានតឹង តថាគតហៅថា មិនទាន់ផុតចាកទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ លុះតែភិក្ខុជាអរហន្តខីណាស្រព នៅចប់ព្រហ្មចារ្យហើយ មានកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ បានសម្រេចអរហត្តហើយ មានសំយោជនៈក្នុងភពអស់ហើយ រួចស្រឡះហើយ ព្រោះដឹងនូវហេតុ ភិក្ខុនោះទើបគួរពោលនូវគាថានោះថា

ចាតុទ្ទសី  បញ្ចទសី
យា  ច  បក្ខស្ស  អដ្ឋមី
បាដិហារិយបក្ខញ្ច
អដ្ឋង្គសុសមាគតំ
ឧបោសថំ  ឧបវសេយ្យ
យោបស្ស  មាទិសោ  នរោតិ  ។

តំ កិស្ស ហេតុ ។ សោ ហិ ភិក្ខវេ ភិក្ខុ បរិមុត្តោ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុត្តោ ទុក្ខស្មាតិ វទាមីតិ ។

[៤០] សុខុមាលោ អហំ ភិក្ខវេ បរមសុខុ-មាលោ អច្ចន្តសុខុមាលោ ។ មម សុទំ ភិក្ខវេ បិតុ និវេសនេ បោក្ខរណិយោ ការិតា ហោន្តិ ឯកត្ថ សុទំ ភិក្ខវេ ឧប្បលំ វប្បតិ ឯកត្ថ បទុមំ ឯកត្ថ បុណ្ឌរីកំ យាវទេវ មមត្ថាយ ។ ន ខោ បនស្សាហំ ភិក្ខវេ កាសិកំ ចន្ទនំ ធារេមិ កាសិកំ សុ មេ តំ ភិក្ខវេ វេឋនំ ហោតិ

នរៈណាប្រាកដដូចជាយើង នរៈនោះ ត្រូវរក្សាឧបោសថប្រកបដោយអង្គ ៨ ក្នុងតិថីទី ១៤ ផង ទី ១៥ ផង ទី ៨ នៃបក្ខផង បាដិហារិយបក្ខផង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុនោះ រួចស្រឡះចាកជាតិ ជរា មរណៈ សោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីតានតឹង តថាគតហៅថា រួចស្រឡះចាកទុក្ខ ។

[៤០] ម្នាលភិក្ខុទាំងឡាយ តថាគតធ្លាប់សុខដ៏ក្រៃលែង ធ្លាប់សុខជាទីបំផុត ។ ម្នាលភិក្ខុទាំងឡាយ ព្រះបិតាតថាគត ទ្រង់ឲ្យជីកស្រះបោក្ខរណី ក្នុងព្រះរាជនិវេសន៍ ទ្រង់ឲ្យដាំឧប្បលខៀវមួយកន្លែង ឈូកស មួយកន្លែង ឈូកក្រហម មួយកន្លែង ប្រយោជន៍ ដល់តថាគតប៉ុណ្ណោះឯង ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនមែនទ្រទ្រង់ត្រឹមតែលម្អិតខ្លឹមចន្ទន៍ ក្នុងដែនកាសី[១] ប៉ុណ្ណោះទេ ម្នាលភិក្ខុទាំងឡាយ ឈ្នួតរបស់តថាគត ក៏មកពីដែនកាសី

១ សំដៅយករបស់ដែលល្អិតល្អប្រសើរបំផុត ។ អដ្ឋកថា ។

កាសិកា កញ្ចុកា កាសិកំ និវាសនំ កាសិកោ ឧត្តរាសង្គោ ។ រត្តិន្ទិវំ ខោ បន សុ មេ តំ ភិក្ខវេ សេតច្ឆត្តំ ធារិយតិ មា នំ[១] សីតំ វា ឧណ្ហំ វា រជោ វា តិណំ វា ឧស្សាវោ វាតិ ។ តស្ស មយ្ហំ ភិក្ខវេ តយោ បាសាទា អហេសុំ ឯកោ ហេមន្តិកោ ឯកោ គិម្ហិកោ ឯកោ វស្សិកោ ។ សោ ខោ អហំ ភិក្ខវេ វស្សិកេ បាសាទេ វស្សិកេ ចត្តារោ មាសេ និប្បុរិសេហិ តុរិយេហិ បរិចារិយមានោ[២] ន ហេដ្ឋាបាសាទំ ឱរោហាមិ ។ យថា ខោ បន ភិក្ខវេ អញ្ញេសំ និវេសនេសុ ទាសកម្មករបោរិសស្ស កណាជកំ ភោជនំ ទីយតិ ពិលង្គទុតិយំ ឯវមេវស្សុ មេ ភិក្ខវេ បិតុ និវេសនេ ទាសកម្មករបោរិសស្ស សាលិមំសោទនោ ទីយតិ ។

១ ឱ. ម. មា នំ ផុសិ ។ ២ ឱ. បរិវារិយមានោ ។

អាវនិងសំពត់ទទូរ ក៏មកពីដែនកាសី សំពត់ស្បៀក ក៏មកពីដែនកាសី សំពត់បង់ក ក៏មកពីដែនកាសី ។ ម្នាលភិក្ខុទាំងឡាយ គេបាំងស្វេតច្ឆត្រឲ្យតថាគត ទាំងយប់ទាំងថ្ងៃ ដោយការពារមិនឲ្យត្រជាក់ក្តី ក្តៅក្តី ធូលីក្តី ស្មៅក្តី ទឹកសន្សើមក្តី ប៉ះត្រូវតថាគតនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះមានប្រាសាទ ៣ គឺប្រាសាទដែលសម្រាប់នៅក្នុងរដូវត្រជាក់ ១ សម្រាប់នៅក្នុងរដូវក្តៅ ១ សម្រាប់នៅក្នុងរដូវភ្លៀង ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតមានគេបម្រើដោយតូរ្យតន្ត្រីមិនលាយដោយប្រុសអស់ ៤ ខែ ក្នុងវស្សានរដូវ ក្នុងប្រាសាទសម្រាប់រដូវភ្លៀង មិនដែលចុះមកខាងក្រោមប្រាសាទ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលំនៅទាំងឡាយ របស់ពួកជនដទៃ គេឲ្យបាយចុងអង្ករដែលមានទឹកជ្រក់ជាគម្រប់ពីរដល់ទាសៈ និងអ្នកធ្វើការងារ និងបុរសអ្នកអាស្រ័យចិញ្ចឹមជីវិតយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ចំណែកក្នុងនិវេសនស្ថានរបស់ព្រះបិតាតថាគត គេឲ្យបាយអង្ករស្រូវសាលីនិងសាច់ដល់ទាសៈ និងអ្នកធ្វើការ និងបុរសអ្នកអាស្រ័យចិញ្ចឹមជីវិត តែយ៉ាងហ្នឹងឯង ។

តស្ស មយ្ហំ ភិក្ខវេ ឯវរូបាយ ឥទ្ធិយា សមន្នា-គតស្ស ឯវរូបេន ច អច្ចន្តសុខុមាលេន ឯតទ-ហោសិ អស្សុតវា ខោ បុថុជ្ជនោ អត្តនា ជរាធម្មោ សមានោ ជរំ អនតីតោ បរំ ជិណ្ណំ ទិស្វា អដ្ដិយតិ ហរាយតិ ជិគុច្ឆតិ អត្តានំយេវ អតិសិត្វា ។ អហំបិ ខោម្ហិ ជរាធម្មោ ជរំ អនតីតោ អហញ្ចេវ ខោ បន ជរាធម្មោ សមានោ ជរំ អនតីតោ បរំ ជិណ្ណំ ទិស្វា អដ្ដិយេយ្យំ ហរាយេយ្យំ ជិគុច្ឆេយ្យំ ន មេ តំ អស្ស បដិរូបន្តិ តស្ស មយ្ហំ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតោ យោ យោព្វនេ យោព្វនមទោ សោ សព្វសោ បហីយិ ។ អស្សុតវា ខោ បុថុជ្ជនោ អត្តនា ព្យាធិធម្មោ សមានោ ព្យាធឹ អនតីតោ បរំ ព្យាធិតំ ទិស្វា អដ្ដិយតិ ហរាយតិ ជិគុច្ឆតិ អត្តានំយេវ អតិសិត្វា ។

ម្នាលភិក្ខុទាំងឡាយ តថាគតនោះ ប្រកបដោយឫទ្ធិ មានសភាពយ៉ាង នេះផង ដោយសេចក្តីសុខ ដ៏ក្រៃលែងយ៉ាងនេះផង មានសេចក្តី ត្រិះរិះដូច្នេះថា បុថុជ្ជន ដែលមិនបានរៀនសូត្រ មានជរាជាធម្មតា មិនកន្លងនូវជរាឡើយ លុះឃើញអ្នកដទៃគ្រាំគ្រារំលងខ្លួនឯងទៅ នឿយ ណាយ ជិនឆ្អន់ ខ្ពើមរអើម (នឹងអ្នកដទៃវិញ) ចំណែកអាត្មាអញ មាន ជរាជាធម្មតាដែរ មិនកន្លងជរាបានឡើយ បើអាត្មាអញ មានជរាជាធម្មតា មិនកន្លងជរាទៅបានឡើយ លុះឃើញអ្នកដទៃហើយ នឿយណាយ ជិនឆ្អន់ ខ្ពើមរអើម ហេតុនោះ មិនសមគួរដល់អាត្មាអញទេ ម្នាលភិក្ខុ ទាំងឡាយ តថាគតនោះពិចារណាឃើញច្បាស់ដូច្នេះហើយ ក៏លះបង់ នូវសេចក្តីស្រវឹង ក្នុងវ័យទាំងអស់ ។ បុថុជ្ជនមិនបានរៀនសូត្រខ្លួនឯង មានព្យាធិជាធម្មតា មិនកន្លងនូវព្យាធិទៅបាន លុះឃើញអ្នកដទៃមាន ព្យាធិរំលងខ្លួនឯងទៅ នឿយណាយ ជិនឆ្អន់ ខ្ពើមរអើម (អ្នកដទៃវិញ)។

អហំបិ ខោម្ហិ ព្យាធិធម្មោ ព្យាធឹ អនតីតោ អហញ្ចេវ ខោ បន ព្យាធិធម្មោ សមានោ ព្យាធឹ អនតីតោ បរំ ព្យាធិតំ ទិស្វា អដ្ដីយេយ្យំ ហរាយេយ្យំ ជិគុច្ឆេយ្យំ ន មេតំ អស្ស បដិរូបន្តិ តស្ស មយ្ហំ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតោ យោ អារោគ្យមទោ សោ សព្វសោ បហីយិ ។ អស្សុតវា ខោ បុថុជ្ជនោ អត្តនា មរណធម្មោ សមានោ មរណំ អនតីតោ បរំ មតំ ទិស្វា អដ្ដីយតិ ហរាយតិ ជិគុច្ឆតិ អត្តានំយេវ អតិសិត្វា ។ អហំបិ ខោម្ហិ មរណធម្មោ មរណំ អនតីតោ អហញ្ចេវ ខោ បន មរណធម្មោ សមានោ មរណំ អនតីតោ បរំ មតំ ទិស្វា អដ្ដីយេយ្យំ ហរាយេយ្យំ ជិគុច្ឆេយ្យំ ន មេតំ អស្ស បដិរូបន្តិ តស្ស មយ្ហំ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតោ យោ ជីវិតេ ជីវិតមទោ សោ សព្វសោ បហីយីតិ ។

សូម្បីអាត្មាអញ ក៏មានព្យាធិជាធម្មតាដែរ មិនកន្លងព្យាធិបាន បើអាត្មាអញ មានព្យាធិជាធម្មតា មិនកន្លងព្យាធិទៅបាន លុះឃើញអ្នកដទៃមានព្យាធិហើយ នឿយណាយ ជិនឆ្អន់ ខ្ពើមរអើម ហេតុនោះ មិនសមគួរដល់អាត្មាអញទេ ម្នាលភិក្ខុទាំងឡាយ តថាគតនោះកាលពិចារណាឃើញដូច្នេះ ក៏លះបង់សេចក្តីស្រវឹង ព្រោះមិនមានរោគដោយប្រការទាំងពួង ។ បុថុជ្ជនដែលមិនបានរៀនសូត្រខ្លួនឯង មានមរណៈជាធម្មតា មិនកន្លងមរណៈទៅបាន លុះឃើញអ្នកដទៃស្លាប់រំលងខ្លួនឯងទៅ នឿយណាយ ជិនឆ្អន់ ខ្ពើមរអើម (បុគ្គលដទៃវិញ) ។ អាត្មាអញ ក៏មានមរណៈជាធម្មតាដែរ មិនកន្លងមរណៈបាន ប្រសិនបើអាត្មាអញ មានមរណៈជាធម្មតាដែរ មិនកន្លងមរណៈបានទេ លុះឃើញអ្នកដទៃស្លាប់ហើយ ក៏នឿយណាយ ជិនឆ្អន់ ខ្ពើមរអើម ហេតុនោះក៏មិនសមគួរដល់អាត្មាអញទេ ម្នាលភិក្ខុទាំងឡាយ កាលតថាគតនោះពិចារណាឃើញដូច្នេះ សេចក្តីស្រវឹងព្រោះជីវិតនោះក៏បាត់ទៅ ដោយប្រការទាំងពួង ។

តយោមេ ភិក្ខវេ មទា ។ កតមេ តយោ ។ យោព្វនមទោ អារោគ្យមទោ ជីវិតមទោ ។ យោព្វនមទមត្តោ វា ភិក្ខវេ អស្សុតវា បុថុជ្ជនោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ ។ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ អារោគ្យមទមត្តោ វា ភិក្ខវេ អស្សុតវា បុថុជ្ជនោ ។ បេ ។ ជីវិតមទមត្តោ វា ភិក្ខវេ អស្សុតវា បុថុជ្ជនោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ ។ សោ កាយេន ទុច្ចរិតំ ចរិត្វា វាចាយ ទុច្ចរិតំ ចរិត្វា មនសា ទុច្ចរិតំ ចរិត្វា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ យោព្វនមទមត្តោ វា ភិក្ខវេ ភិក្ខុ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ អារោគ្យមទមត្តោ វា ភិក្ខវេ ភិក្ខុ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតិ

ម្នាលភិក្ខុទាំងឡាយ សេចក្តីស្រវឹងនេះ មាន ៣ យ៉ាង ។ សេចក្តីស្រវឹង ៣ យ៉ាងតើអ្វីខ្លះ ។ គឺស្រវឹងព្រោះវ័យ ១ ស្រវឹងព្រោះមិនមានរោគ ១ ស្រវឹងព្រោះជីវិត ១ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនដែលមិនបានរៀនសូត្រ ស្រវឹង ដោយសេចក្តីស្រវឹងព្រោះវ័យ តែងប្រព្រឹត្តទុច្ចរិត ដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ បុថុជ្ជននោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាប្រេត តិរច្ឆាន អសុរកាយនរក ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនដែលមិនបានរៀនសូត្រ ស្រវឹងដោយសេចក្តីស្រវឹងព្រោះមិនមានរោគ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនដែលមិនបានរៀនសូត្រ ស្រវឹងដោយសេចក្តីស្រវឹង ព្រោះជីវិត តែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិត ដោយចិត្ត ។ បុថុជ្ជននោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិត ដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាប្រេត តិរច្ឆាន អសុរកាយ នរក ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុស្រវឹងដោយសេចក្តីស្រវឹងព្រោះវ័យក្តី តែងលាសិក្ខាត្រឡប់មក កាន់ភេទដ៏ថោកទាប ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្រវឹងដោយសេចក្តីស្រវឹង ព្រោះមិនមានរោគក្តី តែងលាសិក្ខាវិលត្រឡប់មក កាន់ភេទដ៏ថោកទាប

ជីវិតមទមត្តោ វា ភិក្ខវេ ភិក្ខុ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តតីតិ ។

ព្យាធិធម្មា ជរាធម្មា
អថោ មរណធម្មិនោ
យថា ធម្មា តថា សន្តា
ជិគុច្ឆន្តិ បុថុជ្ជនា ។
អហញ្ចេតំ ជិគុច្ឆេយ្យំ
ឯវំ ធម្មេសុ បាណិសុ
ន មេតំ បដិរូបស្ស
មម ឯវំវិហារិនោ ។
សោហំ ឯវំ វិហរន្តោ
ញត្វា ធម្មំ និរូបធឹ
អារោគ្យេ យោព្វនស្មិញ្ច
ជីវិតស្មិញ្ច យោ មទោ
សព្វេ មទេ អភិភោស្មិ[១]
នេក្ខម្មំ ទដ្ឋុ ខេមតោ ។

---

១ ម. អភិតោស្មិ ។ និក្ខមេ ទុដ្ឋុ ខេមតំ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្រវឹង ដោយសេចក្តីស្រវឹងព្រោះជីវិតក្តី តែងលាសិក្ខាហើយត្រឡប់មក កាន់ភេទដ៏ថោកទាប ។

ពួកបុថុជ្ជន មានព្យាធិជាធម្មតា មានជរាជាធម្មតា មានមរណៈជាធម្មតា ធម្មតា (ខ្លួន) យ៉ាងណា ក៏ត្រូវតែមានយ៉ាងនោះ តែខ្ពើម (បុគ្គលដទៃ) ។ ប្រសិនបើតថាគត ខ្ពើមរអើមនូវហេតុនោះ ក្នុងសត្វទាំងឡាយដែលមានធម្មតា យ៉ាងនេះ សេចក្តីខ្ពើមរអើមនោះមិនសមគួរដល់តថាគត ដែលនៅយ៉ាងនោះទេ ។ កាលតថាគត កំពុងនៅ យ៉ាងនេះ បានដឹងនូវធម៌ដែលមិនមានឧបធិ ក៏បានគ្របសង្កត់សេចក្តីស្រវឹងព្រោះមិនមានរោគ ព្រោះវ័យ ព្រោះជីវិតទាំងពួងបាន ព្រោះឃើញនូវនេក្ខម្មដោយសេចក្តីក្សេម ។

តស្ស មេ អហុ ឧស្សាហោ
និព្វានំ អភិបស្សតោ
នាហំ ភព្វោ ឯតរហិ
កាមានិ បដិសេវិតុំ
អនិវត្តិ ភវិស្សាមិ
ព្រហ្មចរិយបរាយណោតិ ។

[៤១] តីណិមានិ ភិក្ខវេ អាធិបតេយ្យានិ ។ កតមានិ តីណិ ។ អត្តាធិបតេយ្យំ លោកាធិបតេយ្យំ ធម្មាធិបតេយ្យំ ។ កតមញ្ច ភិក្ខវេ អត្តាធិបតេយ្យំ ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ន ខោ បនាហំ ចីវរហេតុ អគារស្មា អនគារិយំ បព្វជិតោ ន បិណ្ឌបាតហេតុ ន សេនាសនហេតុ ន ឥតិភវាភវហេតុ អគារស្មា អនគារិយំ បព្វជិតោ អបិច ខោម្ហិ ឱតិណ្ណោ ជាតិយា ជរាមរណេន[១] សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ

១ ម. ជរាយ មរណេន ។

កាលតថាគតនោះ ឃើញច្បាស់នូវព្រះនិព្វាន ក៏កើតឧស្សាហ៍ តថាគតមិនគួរដើម្បីសេពនូវកាមទាំងឡាយក្នុងកាលឥឡូវនេះទេ នឹងមិនត្រឡប់មករក(កាម) វិញទេ មានព្រហ្មចារ្យប្រព្រឹត្តទៅខាងមុខ ។

[៤១] ម្នាលភិក្ខុទាំងឡាយ អាធិបតេយ្យ (ភាពជាធំ) នេះ មាន ៣ យ៉ាង ។ អាធិបតេយ្យ ៣ យ៉ាង តើអ្វីខ្លះ ។ គឺអត្តាធិបតេយ្យ ១ លោកាធិបតេយ្យ ១ ធម្មាធិបតេយ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ អត្តាធិបតេយ្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះនៅក្នុងព្រៃក្តី នៅជិតគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី រមែងពិចារណាឃើញច្បាស់យ៉ាងនេះថា អាត្មាអញមិនមែនចេញចាកផ្ទះមកបួស ព្រោះហេតុតែចីវរទេ មិនមែនព្រោះហេតុតែបិណ្ឌបាតទេ មិនមែនព្រោះហេតុតែសេនាសនៈទេ មិនមែនចេញចាកផ្ទះមកបួស ព្រោះហេតុតែភពតូចភព[១]ធំទេ ក៏អាត្មាអញជាបុគ្គលដែលជាតិ ជរា មរណៈ សោក ខ្សឹកខ្សួល ទុក្ខទោមនស្ស ចង្អៀតចង្អល់ គ្របសង្កត់

១ សំដៅយករបស់ដែលថ្លៃថ្លាយ៉ាងល្មមនិងថ្លៃថ្លាយ៉ាងវិសេស ។ អដ្ឋកថា ។

ទុក្ខោតិណ្ណោ ទុក្ខបរេតោ អប្បេវនាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ អហាញ្ចេវ ខោ បន យាទិសកេ(១) កាមេ ឱហាយ អគារស្មា អនគារិយំ បព្វជិតោ តាទិសកេ វា កាមេ បរិយេសេយ្យំ តតោ វា បាបិដ្ឋតរំ(២) ន មេតំ អស្ស បដិរូបន្តិ ។ សោ ឥតិ បដិ-សញ្ចិក្ខតិ អារទ្ធំ ខោ បន មេ វីរិយំ ភវិស្សតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បមុដ្ឋា បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គន្តិ ។ សោ អត្តានំយេវ អាធិបតេយ្យំ(៣) ករិត្វា អកុសលំ បជហាតិ កុសលំ ភាវេតិ សាវជ្ជំ បជហាតិ អនវជ្ជំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ អត្តាធិបតេយ្យំ ។ កតមញ្ច ភិក្ខវេ លោកាធិបតេយ្យំ ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ន ខោ បនាហំ ចីវរហេតុ អគារស្មា អនគារិយំ បព្វជិតោ ន បិណ្ឌបាតហេតុ

---

១ ម. ឯត្តន្តរេ វាតិ បាហោ ទិស្សតិ ។ ២ ឱ. បាបិដ្ឋតរោ ។ ម. បាបិដ្ឋតរេ ។ ៣ ម. អធិបតឹ ។

ត្រូវទុក្ខគ្របសង្កត់ មានទុក្ខប្រព្រឹត្តទៅខាងមុខ ធ្វើម្តេចហ្ន៎ គប្បីធ្វើទីបំផុតគំនរទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ អាត្មាអញសោត បានលះបង់កាមបែបណាហើយ ចេញចាកផ្ទះមកបួស គប្បីស្វែងរកនូវកាមបែបនោះក្តី នូវអំពើអាក្រក់ខ្លាំងជាងកាមទាំងនោះក្តី ការនោះមិនសមគួរដល់អាត្មាអញទេ ។ ភិក្ខុនោះ តែងពិចារណាដូច្នេះថា អាត្មាអញនឹងប្រារព្ធព្យាយាមមិនឲ្យធូរថយ នឹងប្រុងស្មារតី មិនឲ្យវង្វេងភ្លាត់ ឲ្យកាយ[១] ស្ងប់រម្ងាប់ មិនឲ្យសោប់សល់ ឲ្យចិត្តតម្កល់មាំមានអារម្មណ៍តែមួយ ។ ភិក្ខុនេះធ្វើខ្លួនឯងឲ្យជាអាធិបតេយ្យហើយ រមែងលះបង់អកុសល ចម្រើនកុសល លះបង់អំពើដែលប្រកបដោយទោស ចម្រើនតែអំពើដែលមិនមានទោស រក្សាខ្លួនឲ្យស្អាត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអត្តាធិបតេយ្យ ។ ម្នាលភិក្ខុទាំងឡាយ លោកាធិបតេយ្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះនៅក្នុងព្រៃក្តី នៅជិតគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី រមែងពិចារណាដូច្នេះថា អាត្មាអញមិនមែនចេញចាកផ្ទះមកបួស ព្រោះហេតុតែចីវរទេ មិនមែនព្រោះហេតុតែបិណ្ឌបាតទេ

---

១ សំដៅយកទាំងនាមកាយទាំងករជកាយ ។ អដ្ឋកថា ។

១១៤



ន សេនាសនហេតុ ន ឥតិភវាភវហេតុ អគារស្មា អនគារិយំ បព្វជិតោ អបិច ខោម្ហិ ឱតិណ្ណោ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោតិណ្ណោ ទុក្ខ-បរេតោ អប្បេវនាម ឥមស្ស កេវលស្ស ទុក្ខ-ក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ អហញ្ចេវ ខោ បន ឯវំ បព្វជិតោ សមានោ កាមវិតក្កំ វា វិតក្កេយ្យំ ព្យាបាទវិតក្កំ វា វិតក្កេយ្យំ វិហឹសាវិតក្កំ វា វិតក្កេយ្យំ មហា ខោ បនាយំ លោកសន្និវាសោ មហន្តស្មឹ ខោ បន លោកសន្និវាសេ សន្តិ សមណព្រាហ្មណា ឥទ្ធិមន្តោ ទិព្វចក្ខុកា បរចិត្តវិទុនោ តេ ទូរតោបិ បស្សន្តិ អាសន្នាបិ ន ទិស្សន្តិ ចេតសាបិ ចិត្តំ បជានន្តិ តេបិ មំ ឯវំ ជានេយ្យុំ បស្សថ ភោ ឥមំ កុលបុត្តំ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ សមានោ វោកិណ្ណោ វិហរតិ បាបកេហិ អកុសលេហិ ធម្មេហីតិ ។

មិនមែនព្រោះហេតុតែសេនាសនៈទេ មិនមែនចេញចាកផ្ទះមកបួស ព្រោះហេតុតែកពតូចកពធំទេ ក៏អាត្មាអញ ជាបុគ្គលដែលជាតិ ជរា មរណៈ សោក សេចក្តីខ្សឹកខ្សួល ទុក្ខ ទោមនស្ស សេចក្តីចង្អៀតចង្អល់គ្របសង្កត់ ត្រូវទុក្ខគ្របសង្កត់ មានសេចក្តីទុក្ខប្រព្រឹត្តទៅខាងមុខ ធ្វើម្តេចហ្ន៎ គប្បីធ្វើទីបំផុតគំនរទុក្ខទាំងអស់នេះ ឲ្យប្រាកដបាន ។ អាត្មាអញ បួសយ៉ាងនេះហើយ ត្រិះរិះកាមវិតក្កៈក្តី ត្រិះរិះព្យាបាទ-វិតក្កៈក្តី ត្រិះរិះវិហឹសាវិតក្កៈក្តី លោកសន្និវាសនេះសោតក៏ធំ ទោះក្នុងលោកសន្និវាសធំមែន ក៏គង់មានសមណព្រាហ្មណ៍ជាអ្នកមានឫទ្ធិ មានទិព្វចក្ខុ ដឹងចិត្តបុគ្គលដទៃ ពួកសមណព្រាហ្មណ៍ទាំងនោះ រមែងឃើញអំពីចម្ងាយ ទោះនៅជិតក៏មិនប្រាកដ រមែងដឹងច្បាស់នូវចិត្តដោយចិត្ត ពួកសមណព្រាហ្មណ៍ទាំងនោះ គង់ដឹងអាត្មាអញយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកមើលកុលបុត្រនេះចេញចាកផ្ទះមកបួស ដោយសទ្ធាហើយ នៅតែច្របូកច្របល់ ដោយធម៌ជាអកុសលដ៏លាមក ។

ទេវតាបិ ខោ សន្តិ[១] ឥទ្ធិមន្តិនិយោ ទិព្វចក្ខុកា បរចិត្តវិទុនិយោ តា ទូរតោបិ បស្សន្តិ អាសន្នាបិ ន ទិស្សន្តិ ចេតសាបិ ចិត្តំ បជានន្តិ តាបិ មំ ឯវំ ជានេយ្យុំ បស្សថ ភោ ឥមំ កុលបុត្តំ សទ្ធា អគារស្មា អនគារិយំ បព្វជិតោ សមានោ វោកិណ្ណោ វិហរតិ បាបកេហិ អកុសលេហិ ធម្មេហីតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អារទ្ធំ ខោ បន មេ វីរិយំ ភវិស្សតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បមុដ្ឋា បស្សទ្ធោ កាយោ អសារទ្ធោ[២] សមាហិតំ ចិត្តំ ឯកគ្គន្តិ ។ សោ លោកំយេវ អាធិបតេយ្យំ ករិត្វា អកុសលំ បជហតិ កុសលំ ភាវេតិ សាវជ្ជំ បជហតិ អនវជ្ជំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ លោកាធិបតេយ្យំ ។ កតមញ្ច ភិក្ខវេ ធម្មាធិបតេយ្យំ ។ ឥធ ភិក្ខវេ ភិក្ខុ

---

១ ម. ទេវតាបិខោ ទិស្សន្តិ ។ ២ ឱ. អសារទ្ធោ ហោតិ ។

ម្យ៉ាងទៀត គង់មានពួកទេវតាដែលមានឫទ្ធិ មានទិព្វចក្ខុដឹងចិត្តបុគ្គលដទៃ ពួកទេវតាទាំងនោះ តែងឃើញអំពីចម្ងាយ ទោះនៅជិតក៏មិនប្រាកដ រមែងដឹងចិត្តដោយចិត្ត ពួកទេវតាទាំងនោះ គង់ដឹងអាត្មាអញយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន សូមអ្នកមើលកុលបុត្រនេះ ចេញចាកផ្ទះមកបួសដោយសទ្ធាហើយ នៅតែច្របូកច្របល់ ដោយធម៌ជាអកុសលដ៏លាមក ។ ភិក្ខុនោះពិចារណាដូច្នេះថា អាត្មាអញនឹងប្រារព្ធព្យាយាម មិនឲ្យធូរថយ នឹងប្រុងសតិ មិនឲ្យវង្វេងភ្លេច ឲ្យកាយស្ងប់រម្ងាប់ មិនឲ្យធូរថយ ឲ្យចិត្តតម្កល់មាំ មានអារម្មណ៍តែមួយ ។ លុះភិក្ខុនោះប្រារព្ធលោកឲ្យជាអាធិបតេយ្យហើយ តែងលះបង់អកុសល ចម្រើនកុសល លះបង់អំពើដែលប្រកបដោយទោស ចម្រើនតែអំពើដែលមិនមានទោស រក្សាខ្លួនឲ្យស្អាត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា លោកាធិបតេយ្យ ។ ម្នាលភិក្ខុទាំងឡាយ ធម្មាធិបតេយ្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ

អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ ន ខោ បនាហំ ចីវរហេតុ អគារស្មា អនគារិយំ បព្វជិតោ ន បិណ្ឌបាតហេតុ ន សេនាសនហេតុ ន ឥតិភវាភវហេតុ អគារស្មា អនគារិយំ បព្វជិតោ អបិច ខោម្ហិ ឱតិណ្ណោ ជាតិយា ជរាមរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ទុក្ខោ-តិណ្ណោ ទុក្ខបរេតោ អប្បេវនាម ឥមស្ស កេវលស្ស ទុក្ខក្ខន្ធស្ស អន្តកិរិយា បញ្ញាយេថាតិ ។ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ សន្តិ ខោ បន[1] សព្រហ្មចារី ជានំ បស្សំ វិហរន្តិ ។ អហញ្ចេវ ខោ បន ឯវំ ស្វាក្ខាតេ ធម្មវិនយេ បព្វជិតោ សមានោ កុសីតោ វិហរេយ្យំ បមត្តោ ន មេតំ អស្ស បដិរូបន្តិ ។

១ ឱ. សន្តិ ខោ បន មេ ។

នៅក្នុងព្រៃក្តី នៅជិតគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងពិចារណា ដូច្នេះថា អាត្មាអញមិនមែនចេញចាកផ្ទះមកបួស ព្រោះហេតុតែចីវរទេ មិនមែនព្រោះហេតុតែបិណ្ឌបាតទេ មិនមែនព្រោះហេតុតែសេនាសនៈទេ មិនមែនចេញចាកផ្ទះមកបួស ព្រោះហេតុតែភពតូចភពធំទេ ក៏អាត្មាអញ ជាបុគ្គលដែលជាតិ ជរា មរណៈ សោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស ចង្អៀតចង្អល់ គ្របសង្កត់ ត្រូវទុក្ខគ្របសង្កត់ មានទុក្ខប្រព្រឹត្តទៅខាងមុខ ធ្វើម្តេចហ្ន៎ គប្បីធ្វើទីបំផុតគំនរទុក្ខទាំងអស់នេះឲ្យប្រាកដបាន ។ ធម៌ដែល ព្រះមានព្រះភាគ ទ្រង់ត្រាស់ល្អហើយ ជាធម៌ដែលអរិយបុគ្គលឃើញ ច្បាស់ដោយខ្លួនឯង ឲ្យផលមិនរង់ចាំកាល គួរនឹងហៅបុគ្គលដទៃឲ្យចូល មកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជនគប្បី ដឹងច្បាស់ចំពោះខ្លួន ។ គង់មានសព្រហ្មចារីបុគ្គលដឹងឬឃើញដែរ ។ អាត្មាអញបួសក្នុងធម៌វិន័យ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងល្អហើយ យ៉ាងនេះត្រឡាំង ទៅជាអ្នកខ្ជិលប្រហែសធ្វេស ហេតុនោះមិនសមគួរទេ ។

សោ ឥតិ បដិសញ្ចិក្ខតិ អារទ្ធំ ខោ បន មេ វីរិយំ ភវិស្សតិ អសល្លីនំ ឧបដ្ឋិតា សតិ អប្ប-មុដ្ឋា[១] បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គន្តិ ។ សោ ធម្មំយេវ អាធិបតេយ្យំ ករិត្វា អកុសលំ បជហតិ កុសលំ ភាវេតិ សាវជ្ជំ បជហតិ អនវជ្ជំ ភាវេតិ សុទ្ធំ អត្តានំ បរិហរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ធម្មាធិបតេយ្យំ ។ ឥមានិ ខោ ភិក្ខវេ តីណិ អាធិបតេយ្យានីតិ ។

នត្ថិ លោកេ រហោ នាម
បាបកម្មំ បកុព្វតោ[២]
អត្តា តេ បុរិស[៣] ជានាតិ
សច្ចំ វា យទិ វា មុសា
កល្យាណំ វត ភោ សក្ខិ
អត្តានំ អតិមញ្ញសិ
យោ សន្តំ អត្តនិ បាបំ
អត្តនំ បរិគូហសិ

១ ឱ. ម. អសម្មុដ្ឋា ។ ២ ម. បក្រុព្វតោ ។ ៣ ម. តេ បុរិមំ ។

ភិក្ខុនោះតែងពិចារណាដូច្នេះថា អាត្មាអញនឹងប្រារព្ធព្យាយាម មិនឲ្យធូរថយ នឹងប្រុងស្មារតី មិនឲ្យវង្វេងភ្លេច ឲ្យកាយស្ងប់រម្ងាប់ មិនឲ្យរសាប់រសល់ ឲ្យចិត្តតម្កល់មាំ មានអារម្មណ៍តែមួយ ។ ភិក្ខុនោះ ប្រារព្ធធម៌ហ្នឹងឯងឲ្យជាអាធិបតេយ្យ ហើយលះបង់អកុសល ចម្រើនតែកុសល លះបង់អំពើប្រកបដោយទោស ចម្រើនអំពើដែលមិនមានទោស រក្សាខ្លួនឲ្យស្អាត ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ធម្មាធិបតេយ្យ ។ ម្នាលភិក្ខុទាំងឡាយ អាធិបតេយ្យមាន ៣ យ៉ាងនេះឯង ។

ជម្មតាបុគ្គលអ្នកធ្វើអំពើអាក្រក់ ក្នុងលោក មិនដែល
កំបាំងទេ ម្នាលបុរស ខ្លួនអ្នកឯង រមែងដឹងថាពិតឬ
មិនពិត (ខ្លួនឯង) ម្នាលអ្នកដ៏ចម្រើន អ្នកឯងជាសាក្សី
ចំពោះខ្លួនយ៉ាងល្អ អ្នកឯងផ្ចាញ់ផ្ចាល់ខ្លួនឯង បើអ្នកឯង
បិទបាំងអំពើអាក្រក់ ដែលមានក្នុងខ្លួននោះឯងហើយ

បស្សន្តិ នេវា ច តថាគតា ច
លោកស្មឹ ពាលំ វិសមំ ចរន្តំ
តស្មា ហិ អត្តាធិបកោ[១] សតោ ចរេ
លោកាធិបោ ច និបកោ ច ឈាយី
ធម្មាធិបោ ច អនុធម្មចារី
ន ហីយតិ សច្ចបរក្កមោ មុនិ
បសយ្ហ មារំ អភិភុយ្យ អន្តកំ
យោ ច ផុសី ជាតិខយំ បធានវា
សោ តាទិសោ លោកវិទូ សុមេធោ
សព្វេសុ ធម្មេសុ អតម្មយោ មុនីតិ ។

ទេវទូតវគ្គោ ចតុត្ថោ ។

# តស្សុទ្ទានំ

ព្រហ្មា អានន្ទសារីបុត្តោ
និទានំ ហត្ថកេន ច
ទូតា ទុវេ ច រាជានោ
សុខុមាលោ អធិបតេយ្យេន ចាតិ ។

១ ម. អត្តាធិបតេយ្យោ ច ។

*ទេវតាទាំងឡាយនិងព្រះតថាគតទាំងឡាយ រមែងឃើញបុគ្គលពាល ដែលប្រព្រឹត្តខុសក្នុងលោក ហេតុនោះ បុគ្គល ត្រូវមានខ្លួនជាធំ ប្រុងស្មារតីប្រព្រឹត្តផង មានលោកជាធំ ទាំងមានប្រាជ្ញាចាស់ មានឈានផង មានធម៌ជាធំទាំងប្រព្រឹត្តតាមធម៌ផង ជាអ្នកប្រាជ្ញមានព្យាយាមទៀងទាត់ រមែងមិនថោកថយ បុគ្គលណា មានព្យាយាមញាំញីគ្របសង្កត់មារជាអ្នកបំផ្លាញ រមែងសម្រេចនូវព្រះនិព្វានជាទីអស់ទៅនៃជាតិ បុគ្គលបែបនោះ ជាអ្នកជ្រាបច្បាស់នូវលោក មានប្រាជ្ញាល្អ ជាអ្នកប្រាជ្ញ មិនមានចំណង់ ក្នុងធម៌ទាំងអស់ ។*

ចប់ ទេវទូតវគ្គទី ៤ ។

# ឧទ្ទាននៃទេវទូតវគ្គនោះគឺ

*មាតាដូចជាព្រហ្ម ១ សូត្រ រឿងព្រះអានន្ទ ១ សូត្រ រឿងព្រះសារីបុត្ត ១ សូត្រ ហេតុនៃកម្ម ១ សូត្រ ហត្ថកៈ ១ សូត្រ ទេវទូត ១ សូត្រ ទេវរាជ ២ សូត្រ ពោធិសត្វធ្លាប់សុខ ១ សូត្រ អាធិបតេយ្យ ១ សូត្រ ។*

# ចូឡវគ្គោ

[៤២] តិណ្ណំ ភិក្ខវេ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ។ កតមេសំ តិណ្ណំ ។ សទ្ធាយ ភិក្ខវេ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ។ ទេយ្យធម្មស្ស ភិក្ខវេ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ។ ទក្ខិណេយ្យានំ ភិក្ខវេ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតិ ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ សម្មុខីភាវា សទ្ធោ កុលបុត្តោ ពហុំ បុញ្ញំ បសវតីតិ ។

[៤៣] តីហិ ភិក្ខវេ ឋានេហិ សទ្ធោ បសន្នោ វេទិតព្វោ ។ កតមេហិ តីហិ ។ សីលវន្តានំ ទស្សនកាមោ ហោតិ សទ្ធម្មំ សោតុកាមោ ហោតិ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគោ បយតបាណិ វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ឋានេហិ សទ្ធោ បសន្នោ វេទិតព្វោតិ ។

# ចូឡវគ្គ

[៤២] ម្នាលភិក្ខុទាំងឡាយ កុលបុត្រមានសទ្ធា រមែងបានបុណ្យច្រើន ព្រោះមានរបស់ ៣ ក្នុងទីចំពោះមុខ ។ របស់ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រមានសទ្ធា រមែងបានបុណ្យច្រើន ព្រោះមានសទ្ធាក្នុងទីចំពោះមុខ ១ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រមានសទ្ធា រមែងបានបុណ្យច្រើន ព្រោះមានទេយ្យធម៌ក្នុងទីចំពោះមុខ ១ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រមានសទ្ធា រមែងបានបុណ្យច្រើន ព្រោះមានទក្ខិណេយ្យបុគ្គលក្នុងទីចំពោះមុខ ១ ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រមានសទ្ធា តែងបានបុណ្យច្រើន ព្រោះមានរបស់ ៣ នេះឯងក្នុងទីចំពោះមុខ ។

[៤៣] ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសទ្ធាជ្រះថ្លា បណ្ឌិតត្រូវដឹងដោយហេតុ ៣ យ៉ាង ។ ហេតុ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺបុគ្គលនោះចង់ឃើញបុគ្គលមានសីល ១ ចង់ស្តាប់ព្រះសទ្ធម្ម ១ មានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិល នៅគ្រប់គ្រងផ្ទះ មានការលះរួចហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះ ជាអ្នកគួរដល់ស្នូម ជាអ្នកត្រេកអរក្នុងការឲ្យ និងការចែករំលែក ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសទ្ធាជ្រះថ្លា បណ្ឌិតត្រូវដឹងដោយហេតុ ៣ យ៉ាងនេះ ។

១២១



ឧស្សុនការាមោ សីលវតំ
សទ្ធម្មំ សោតុមិច្ឆតិ
វិនេយ្យ មច្ឆេរមលំ
សវេ សទ្ធោតិ វុច្ចតីតិ ។

[៤៤] តយោ ភិក្ខវេ អត្ថវសេ សម្បស្សមានេន អលមេវ បរេសំ ធម្មំ ទេសេតុំ ។ កតមេ តយោ ។ យោ ធម្មំ ទេសេតិ សោ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច យោ ធម្មំ សុណាតិ សោ អត្ថប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច យោ ចេវ ធម្មំ ទេសេតិ យោ ច ធម្មំ សុណាតិ ឧភោ អត្ថប្បដិសំវេទិនោ ច ហោន្តិ ធម្មប្បដិសំវេទិនោ ច ។ ឥមេ ខោ ភិក្ខវេ តយោ អត្ថវសេ សម្បស្សមានេន អលមេវ បរេសំ ធម្មំ ទេសេតុន្តិ ។

[៤៥] តីហិ ភិក្ខវេ ឋានេហិ កថា បវត្តនី ហោតិ ។ កតមេហិ តីហិ ។ យោ ធម្មំ ទេសេតិ សោ

បុគ្គលណា ចង់ឃើញពួកបុគ្គលមានសីល ចង់ស្តាប់ព្រះសទ្ធម្ម កម្ចាត់បង់នូវមន្ទិលគឺសេចក្តីកំណាញ់ បុគ្គលនោះឯងហៅថា អ្នកមានសទ្ធា ។

[៤៨] ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលឃើញអំណាចប្រយោជន៍ ៣ យ៉ាង ទើបគួរសម្តែងធម៌ដល់បុគ្គលដទៃ ។ អំណាចប្រយោជន៍ ៣ យ៉ាង តើដូចម្តេច ។ បុគ្គលអ្នកសម្តែងធម៌នោះ ជាអ្នកយល់អដ្ឋកថា ទាំងយល់បាលី ១ បុគ្គលអ្នកស្តាប់ធម៌នោះ ជាអ្នកយល់អដ្ឋកថា និងយល់បាលី ១ បុគ្គលអ្នកសម្តែងធម៌និងបុគ្គលអ្នកស្តាប់ធម៌ ទាំងពីរនាក់ ជាអ្នកយល់អដ្ឋ-កថា ទាំងយល់បាលី ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលយល់អំណាចប្រយោជន៍ ៣ យ៉ាងនេះឯង ទើបគួរសម្តែងធម៌ដល់បុគ្គលដទៃបាន ។

[៤៩] ម្នាលភិក្ខុទាំងឡាយ សម្តីដែលប្រព្រឹត្តទៅស្រួល ដោយហេតុ ៣ យ៉ាង ។ ហេតុ ៣ យ៉ាង តើដូចម្តេច ។ គឺបុគ្គលអ្នកសម្តែងធម៌

អត្តប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច យោ ធម្មំ សុណាតិ សោ អត្តប្បដិសំវេទី ច ហោតិ ធម្មប្បដិសំវេទី ច យោ ចេវ ធម្មំ ទេសេតិ យោ ច ធម្មំ សុណាតិ ឧភោ អត្តប្បដិសំវេទិនោ ច ហោន្តិ ធម្មប្បដិសំវេទិនោ ច ។ ឥមេហិ ខោ ភិក្ខវេ តីហិ ឋានេហិ កថា បវត្តនី ហោតីតិ ។

[៤៦] តីណីមានិ ភិក្ខវេ បណ្ឌិតប្បញ្ញត្តានិ សប្បុរិសប្បញ្ញត្តានិ ។ កតមានិ តីណិ ។ ទានំ ភិក្ខវេ បណ្ឌិតប្បញ្ញត្តំ សប្បុរិសប្បញ្ញត្តំ បព្វជ្ជា ភិក្ខវេ បណ្ឌិតប្បញ្ញត្តា សប្បុរិសប្បញ្ញត្តា មាតា-បិតុន្នំ ភិក្ខវេ ឧបដ្ឋានំ បណ្ឌិតប្បញ្ញត្តំ សប្បុរិ-សប្បញ្ញត្តំ ។ ឥមានិ ខោ ភិក្ខវេ តីណិ បណ្ឌិតប្បញ្ញត្តានិ សប្បុរិសប្បញ្ញត្តានីតិ ។

បានយល់អដ្ឋកថាទាំងយល់បាលី ១ បុគ្គលអ្នកស្តាប់ធម៌នោះ បានយល់អដ្ឋកថា ទាំងយល់បាលី ១ បុគ្គលអ្នកសម្តែងធម៌និងបុគ្គលអ្នកស្តាប់ធម៌ទាំងពីរនាក់ ជាអ្នកយល់អដ្ឋកថា ទាំងយល់បាលី ១ ។ ម្នាលភិក្ខុទាំងឡាយ សម្តីដែលប្រព្រឹត្តទៅស្រួល ដោយហេតុ ៣ យ៉ាងនេះឯង ។

[៤៦] ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះ ដែលបណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ ។ ហេតុ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទានជាគុណជាត ដែលបណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ ១ ម្នាលភិក្ខុទាំងឡាយ បព្វជ្ជាជាគុណជាតិ ដែលបណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ ១ មាតាបិតុបដ្ឋាន (ការបម្រើមាតាបិតា) ជាគុណជាត ដែលបណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ ១ ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះឯង ជាគុណជាតដែលបណ្ឌិតបញ្ញត្តហើយ ដែលសប្បុរសបញ្ញត្តហើយ ។

សត្តិ ទានំ ឧបញ្ញត្តំ
អហឹសា សញ្ញមោ ទមោ
មាតាបិតុឧបដ្ឋានំ
សន្តានំ ព្រហ្មចារិនំ
សតំ ឯតានិ ឋានានិ
យានិ សេវេថ បណ្ឌិតោ
អរិយោ ទស្សនសម្បន្នោ
ស លោកំ ភជតេ សិវន្តិ ។

[៤៧] យំ ភិក្ខវេ សីលវន្តោ បព្វជិតា គាមំ វា និគមំ វា ឧបនិស្សាយ វិហរន្តិ តត្ថ មនុស្សា តីហិ ឋានេហិ ពហុំ បុញ្ញំ បសវន្តិ ។ កតមេហិ តីហិ ។ កាយេន វាចាយ មនសា ។ យំ ភិក្ខវេ សីលវន្តោ បព្វជិតា គាមំ វា និគមំ វា ឧបនិស្សាយ វិហរន្តិ តត្ថ មនុស្សា ឥមេហិ តីហិ ឋានេហិ ពហុំ បុញ្ញំ បសវន្តីតិ ។

ទានជាគុណជាត ដែលពួកសប្បុរសបញ្ញត្តហើយ ការមិនបៀតបៀន ការសង្រួម ការទូន្មានខ្លួនជាគុណ-ជាត ដែលសប្បុរសបញ្ញត្តហើយ ការបម្រើមាតាបិតាជាគុណជាត ដែលសប្បុរសបញ្ញត្តហើយ បណ្ឌិតជាអ្នកប្រសើរ ប្រកបដោយសេចក្ដីយល់ឃើញ គួរប្រតិបត្តិនូវហេតុ របស់សប្បុរស ជាអ្នកស្ងប់ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ បណ្ឌិតនោះ រមែងទៅកាន់ទេវលោកជាទីក្សេម ។

[៤៧] ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតជាអ្នកមានសីល ចូលទៅនៅអាស្រ័យស្រុកឬនិគមណា ពួកមនុស្សក្នុងស្រុកឬនិគមនោះ រមែងបានបុណ្យច្រើន ដោយហេតុ ៣ ប្រការ ។ ហេតុ ៣ ប្រការ តើដូចម្ដេច ។ គឺកាយ ១ វាចា ១ ចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកបព្វជិតជាអ្នកមានសីល ចូលទៅនៅអាស្រ័យស្រុកឬនិគមណា ពួកមនុស្សក្នុងស្រុកឬនិគមនោះ រមែងបានបុណ្យច្រើន ដោយហេតុ ៣ ប្រការនេះ ។

[៤៨] តីណីមានិ ភិក្ខវេ សង្ខតស្ស សង្ខត-លក្ខណានិ ។ កាតមានិ តីណិ ។ ឧប្បាទោ បញ្ញាយតិ វយោ បញ្ញាយតិ ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ សង្ខតស្ស សង្ខតលក្ខណានីតិ ។

[៤៩] តីណីមានិ ភិក្ខវេ អសង្ខតស្ស អសង្ខត-លក្ខណានិ ។ កាតមានិ តីណិ ។ ន ឧប្បាទោ បញ្ញាយតិ ន វយោ បញ្ញាយតិ ន ឋិតស្ស អញ្ញថត្តំ បញ្ញាយតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ អសង្ខតស្ស អសង្ខតលក្ខណានីតិ ។

[៥០] ហិមវន្តំ ភិក្ខវេ បព្វតរាជំ និស្សាយ មហាសាលា តីហិ វឌ្ឍីហិ វឌ្ឍន្តិ ។ កាតមាហិ តីហិ ។ សាខាបត្តបលាសេន វឌ្ឍន្តិ តចបប្បដិកាយ វឌ្ឍន្តិ ផេគ្គុសារេន វឌ្ឍន្តិ ។

[៤៨] ម្នាលភិក្ខុទាំងឡាយ សង្ខត[1]លក្ខណៈរបស់សង្ខត[2]ធម៌នេះ មាន ៣ យ៉ាង ។ សង្ខតលក្ខណៈ ៣ យ៉ាងតើដូចម្ដេច ។ គឺការកើត រមែងប្រាកដ ១ ការបែកធ្លាយ រមែងប្រាកដ ១ ការប្រែប្រួលនៃសភាវៈ ដែលតាំងនៅ រមែងប្រាកដ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះជាសង្ខត-លក្ខណៈរបស់សង្ខតធម៌ទាំង ៣ យ៉ាង ។

[៤៩] ម្នាលភិក្ខុទាំងឡាយ អសង្ខតលក្ខណៈ នៃអសង្ខតធម៌នេះ មាន ៣ យ៉ាង ។ អសង្ខតលក្ខណៈ ៣ យ៉ាងតើដូចម្ដេច ។ គឺការកើត មិនប្រាកដ ១ ការបែកធ្លាយ មិនប្រាកដ ១ ការប្រែប្រួលនៃសភាវៈ ដែលតាំងនៅ មិនប្រាកដ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាអសង្ខត-លក្ខណៈ របស់អសង្ខតធម៌ទាំង ៣ យ៉ាង ។

[៥០] ម្នាលភិក្ខុទាំងឡាយ ឈើធំអាស្រ័យស្ដេចភ្នំឈ្មោះហិមវន្ត រមែងចម្រើនដោយសេចក្ដីចម្រើន ៣ យ៉ាង ។ សេចក្ដីចម្រើន ៣ យ៉ាង តើដូចម្ដេច ។ គឺចម្រើនដោយមែកស្លឹកនិងត្រួយ ១ ចម្រើន ដោយសម្បកនិងក្រមរ ១ ចម្រើនដោយស្រាយនិងខ្លឹម ១ ។

១-២ របស់ដែលបច្ច័យប្រជុំតាក់តែងឡើង រមែងមាន ៣ យ៉ាង ។ អដ្ឋកថា ។

ហិមវន្តំ ភិក្ខវេ បព្វតរាជំ និស្សាយ មហាសាលា ឥមាហិ តីហិ វឌ្ឍីហិ វឌ្ឍន្តិ ។ ឯវមេវ ខោ ភិក្ខវេ សទ្ធំ កុលបតឹ និស្សាយ អន្តោជនោ តីហិ វឌ្ឍីហិ វឌ្ឍតិ ។ កតមាហិ តីហិ ។ សទ្ធាយ វឌ្ឍតិ សីលេន វឌ្ឍតិ បញ្ញាយ វឌ្ឍតិ ។ សទ្ធំ ភិក្ខវេ កុលបតឹ និស្សាយ អន្តោជនោ ឥមាហិ តីហិ វឌ្ឍីហិ វឌ្ឍតីតិ ។

យថាបិ បព្វតោ សេលោ
អរញ្ញស្មឹ ព្រហាវនេ
តំ រុក្ខា ឧបនិស្សាយ
វឌ្ឍន្តេតេ វនប្បតី
តថេវ សីលសម្បន្នំ
សទ្ធំ កុលបតឹ ឥធ
ឧបនិស្សាយ វឌ្ឍន្តិ
បុត្តទារា ច ពន្ធវា
អមច្ចា ញាតិសង្ឃា ច
យេ ចស្ស អនុជីវិនោ

ម្នាលភិក្ខុទាំងឡាយ ឈើធំអាស្រ័យស្តេចភ្នំឈ្មោះហិមវន្ត រមែងចម្រើន ដោយសេចក្តីចម្រើន ៣ យ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ជនខាងក្នុង អាស្រ័យម្ចាស់ត្រកូល ដែលមានសទ្ធា រមែងចម្រើនដោយសេចក្តីចម្រើន ៣ យ៉ាង ។ ការចម្រើន ៣ យ៉ាង តើដូចម្តេច ។ គឺចម្រើនដោយសទ្ធា ១ ចម្រើនដោយសីល ១ ចម្រើនដោយបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ជនខាងក្នុង អាស្រ័យម្ចាស់ត្រកូល ដែលមានសទ្ធា រមែងចម្រើនដោយ សេចក្តីចម្រើន ៣ យ៉ាងនេះឯង ។

ភ្នំដ៏ហើយដោយថ្ម ពួកឈើជាច្បងក្នុងព្រៃ រមែងចម្រើន
ព្រោះអាស្រ័យភ្នំនោះ ក្នុងព្រៃធំជាអរញ្ញស្ថានយ៉ាងណាមិញ
កូនប្រពន្ធផង ផៅពង្សផង ពួកអមាត្យផង ពួកញាតិផង
ពួកជនដែលរស់នៅ ដោយសារជននោះផង រមែងចម្រើន
ព្រោះអាស្រ័យម្ចាស់ត្រកូល ដែលបរិបូណ៌ដោយសីល

តាទិស្ស សីលវតោ សីលំ
ចាគំ សុចរិតានិ ច
បស្សមានានុកុព្វន្តិ
យេ ភវន្តិ វិចក្ខណា[១]
ឥធ ធម្មំ ចរិត្វាន
មគ្គំ សុគតិគាមិនំ
នន្ទិនោ ទេវលោកស្មឹ
មោទន្តិ កាមកាមិនោតិ ។

[៤១] តីហិ ភិក្ខវេ ឋានេហិ អាតប្បំ ករណីយំ ។ កតមេហិ តីហិ ។ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ អាតប្បំ ករណីយំ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ អាតប្បំ ករណីយំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសនាយ

១ ម. អត្ថមត្ថំ វិចក្ខណា ។

មានសទ្ធាក្នុងលោកនេះក៏យ៉ាងនោះដែរ ។ ជនទាំងនោះឃើញសីលផង ចាគៈផង សុចរិតផង របស់ម្ចាស់ត្រកូលដែលមានសីលនោះហើយ រមែងប្រព្រឹត្តតាមពួកជនអ្នកមានប្រាជ្ញាឈ្លាសនោះ លុះប្រព្រឹត្តធម៌ ដែលជាផ្លូវជាទីទៅកាន់សុគតិក្នុងលោកនេះ ហើយជាអ្នកមានសេចក្តីប្រាថ្នា ក្នុងកាមមានសេចក្តីត្រេកអរ រមែងរីករាយ ក្នុងទេវលោក ។

[៩១] ម្នាលភិក្ខុទាំងឡាយ ភិក្ខុគួរធ្វើព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ដោយហេតុ ៣ យ៉ាង ។ ហេតុ ៣ យ៉ាងដូចម្តេចខ្លះ ។ គឺភិក្ខុគួរធ្វើនូវព្យាយាម ដើម្បីញុំាងអកុសលដ៏លាមក ដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបាន ១ គួរធ្វើព្យាយាម ដើម្បីញុំាងកុសលធម៌ ដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ១ គួរធ្វើព្យាយាម ដើម្បីអត់សង្កត់នូវវេទនាមានក្នុងសរីរៈដែលកើតឡើងហើយ ទ្រាំបានដោយលំបាក ក្លៀវក្លាក្រហល់ក្រហាយ មិនឆ្ងាញ់ មិនគាប់ចិត្ត ជាវេទនាផ្តិលផ្តាច់ជីវិត ១

អាតប្បំ ករណីយំ[១] យតោ ខោ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ អាតប្បំ ករោតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ អាតប្បំ ករោតិ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសនាយ អាតប្បំ ករោតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អាតាបី និបកោ សតោ សម្មា ទុក្ខស្ស អន្តកិរិយាយាតិ ។

[៤២] តីហិ ភិក្ខវេ អង្គេហិ សមន្នាគតោ មហាចោរោ សន្ធិម្បិ ឆិន្ទតិ និល្លោបម្បិ ហរតិ ឯកាគារិកម្បិ ករោតិ បរិបន្ថេបិ តិដ្ឋតិ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ មហាចោរោ វិសមនិស្សិតោ ច ហោតិ គហននិស្សិតោ ច ហោតិ ពលវនិស្សិតោ ច ហោតិ ។ កថញ្ច ភិក្ខវេ មហាចោរោ វិសមនិស្សិតោ ហោតិ ។ ឥធ ភិក្ខវេ មហាចោរោ នទីវិទុគ្គំ វា និស្សិតោ ហោតិ បព្វតវិសមំ វា ។

១ ឱ. ម. ឯត្ថន្តរេ ឥមេហិ តីហិ ឋានេហិ អាតប្បំ ករណីយន្តិ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុធ្វើព្យាយាម ដើម្បីញ៉ាំងអកុសលធម៌ដ៏លាមក ដែលមិនទាន់កើតឡើងមិនឲ្យកើតឡើងបាន ធ្វើព្យាយាម ដើម្បីញ៉ាំងកុសលធម៌ដែលមិនទាន់កើតឡើង ឲ្យកើតឡើងបាន ធ្វើព្យាយាមអត់សង្កត់នូវវេទនា មានក្នុងសរីរៈដែលកើតឡើងហើយ អត់ទ្រាំលំបាកដ៏ក្លៀវក្លាក្រហល់ក្រហាយ មិនឆ្ងាញ់ មិនពេញចិត្ត ជាវេទនាផ្ដិលផ្ដាច់នូវជីវិត ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះឈ្មោះថា មានព្យាយាមដុតកម្ដៅកិលេស មានបញ្ញា មានស្មារតី ដើម្បីធ្វើនូវទីបំផុតទុក្ខដោយប្រពៃបាន ។

[៥២] ម្នាលភិក្ខុទាំងឡាយ មហាចោរដែលប្រកបដោយអង្គ ៣ រមែងកាត់នូវទីតនៃផ្ទះខ្លះ ប្លន់ធំខ្លះ ប្លន់ផ្ទះមួយខ្លះ ចាំស្កាត់ក្នុងផ្លូវខ្លះ ។ អង្គ ៣ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរ ក្នុងលោកនេះ អាស្រ័យទីដែលមិនស្មើ ១ អាស្រ័យព្រៃញាតស្បាត ១ អាស្រ័យអ្នកមានកម្លាំង ១ ។ ម្នាលភិក្ខុទាំងឡាយ មហាចោរអាស្រ័យទីដែលមិនស្មើ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ អាស្រ័យទីជាចន្លោះកោះនៃទន្លេខ្លះ អាស្រ័យនូវភ្នំមិនស្មើខ្លះ ។

ឯវំ ខោ ភិក្ខវេ មហាចោរោ វិសមនិស្សិតោ ហោតិ ។ កថញ្ច ភិក្ខវេ មហាចោរោ គហននិស្សិតោ ហោតិ ។ ឥធ ភិក្ខវេ មហាចោរោ តិណគហនំ វា និស្សិតោ ហោតិ រុក្ខគហនំ វា រោធំ វា[១] មហាវនសណ្ឌំ វា ។ ឯវំ ខោ ភិក្ខវេ មហាចោរោ គហននិស្សិតោ ហោតិ ។ កថញ្ច ភិក្ខវេ មហាចោរោ ពលវនិស្សិតោ ហោតិ ។ ឥធ ភិក្ខវេ មហាចោរោ រាជានំ វា រាជមហាមត្តានំ វា និស្សិតោ ហោតិ តស្ស ឯវំ ហោតិ សចេ មំ កោចិ កិញ្ចិ វក្ខតិ ឥមេ មេ រាជានោ វា រាជមហាមត្តា វា បរិយោទាយ អត្ថំ ភណិស្សន្តីតិ ។ សចេ នំ កោចិ កិញ្ចិ អាហ ត្យាស្ស រាជានោ វា រាជមហាមត្តា វា បរិយោទាយ អត្ថំ ភណន្តិ ។ ឯវំ ខោ ភិក្ខវេ មហាចោរោ ពលវនិស្សិតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ អង្គេហិ សមន្នាគតោ មហាចោរោ សន្ធិម្បិ ឆិន្ទតិ និល្លោបម្បិ ហរតិ ឯកាគារិកម្បិ ករោតិ បរិបន្ថេបិ តិដ្ឋតិ ។

---
១ ឱ. គេធំ វា ។ បេ ។

ម្នាលភិក្ខុទាំងឡាយ មហាចោរអាស្រ័យនូវទីមិនស្មើយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មហាចោរជាអ្នកអាស្រ័យព្រៃញាតស្បាត តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ មហាចោរក្នុងលោកនេះ អាស្រ័យនូវព្រៃស្បាតស្មៅខ្លះ ព្រៃស្បាតឈើខ្លះ ត្រើយប្រាំងខ្លះ ដងព្រៃធំខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មហាចោរជាអ្នកអាស្រ័យព្រៃញាតស្បាតយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ មហាចោរអាស្រ័យអ្នកមានកម្លាំង តើដូចម្ដេច ។ ម្នាលភិក្ខុទាំង-ឡាយ មហាចោរក្នុងលោកនេះ អាស្រ័យស្ដេចឬរាជមហាមាត្យ មហា-ចោរនោះ មានសេចក្ដីសង្ឃឹមដូច្នេះថា បើបុគ្គលណាមួយប្ដឹងអ្វីៗ ពីអញ ពួកស្ដេចឬពួករាជមហាមាត្យទាំងនេះ មុខជានឹងពោលបន្ទ្រប់ឲ្យអញមិនខាន ។ បើបុគ្គលណាប្ដឹងអ្វីៗ ពីចោរនោះ ពួកស្ដេចឬពួករាជមហា-មាត្យនោះ រមែងពោលបន្ទ្រប់បុគ្គលនោះ ។ ម្នាលភិក្ខុទាំង-ឡាយ មហាចោរអាស្រ័យអ្នកមានកម្លាំងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មហាចោរដែលប្រកបដោយអង្គ ៣ យ៉ាងនេះឯង រមែងកាត់នូវទីតខ្លះ ប្លន់ធំខ្លះ ប្លន់ផ្ទះតែមួយខ្លះ នៅចាំស្កាត់ក្នុងផ្លូវខ្លះ ។

ឯវមេវ ខោ ភិក្ខវេ តីហិ ធម្មេហិ[១] សមន្នាគតោ ពាលោ ភិក្ខុ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ ពាលោ ភិក្ខុ វិសម-និស្សិតោ ច ហោតិ គហននិស្សិតោ ច ពលវនិស្សិតោ ច ។ កថញ្ច ភិក្ខវេ ពាលោ ភិក្ខុ វិសមនិស្សិតោ ហោតិ ។ ឥធ ភិក្ខវេ ពាលោ ភិក្ខុ វិសមេន កាយ-កម្មេន សមន្នាគតោ ហោតិ វិសមេន វចីកម្មេន សមន្នាគតោ ហោតិ វិសមេន មនោកម្មេន សមន្នាគតោ ហោតិ ។ ឯវំ ខោ ភិក្ខវេ ពាលោ ភិក្ខុ វិសមនិស្សិតោ ហោតិ ។ កថញ្ច ភិក្ខវេ ពាលោ ភិក្ខុ គហននិស្សិតោ ហោតិ ។ ឥធ ភិក្ខវេ ពាលោ ភិក្ខុ មិច្ឆាទិដ្ឋិកោ ហោតិ អន្តគ្គាហិ-កាយ ទិដ្ឋិយា សមន្នាគតោ[២] ។ ឯវំ ខោ ភិក្ខវេ ពាលោ ភិក្ខុ គហននិស្សិតោ ហោតិ ។ កថញ្ច ភិក្ខវេ ពាលោ ភិក្ខុ ពលវនិស្សិតោ ហោតិ ។

១ ម. អង្គេហិ ។ ២ ឱ. ម. សមន្នាគតោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានមារយាទអាក្រក់ដែលប្រកបដោយធម៌ ៣ ក៏យ៉ាងនោះដែរ រមែងរក្សាខ្លួនដែលគាស់រំលើងបំផ្លាញគុណ ជាអ្នកប្រកបដោយទោសធំផង ប្រកបដោយទោសតូចផង ដែលពួកវិញ្ញូជនត្រូវតិះដៀលផង រមែងទទួលបាបច្រើនផង ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រក់ក្នុងសាសនានេះ អាស្រ័យអំពើមិនស្មើ ១ អាស្រ័យសេចក្តីយល់ដ៏សាំញ៉ាំ ១ អាស្រ័យអ្នកមានកម្លាំង ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រក់អាស្រ័យអំពើមិនស្មើ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រក់ក្នុងសាសនានេះ ប្រកបដោយកាយកម្មមិនស្មើផង ប្រកបដោយវចីកម្មមិនស្មើផង ប្រកបដោយមនោកម្មមិនស្មើផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រក់អាស្រ័យអំពើមិនស្មើយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រក់អាស្រ័យសេចក្តីយល់ដ៏សាំញ៉ាំ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រក់ក្នុងសាសនានេះ ជាអ្នកយល់ខុស ប្រកបដោយអន្តគ្គាហិកាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រក់អាស្រ័យសេចក្តីយល់ដ៏សាំញ៉ាំយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រក់អាស្រ័យអ្នកមានកម្លាំង តើដូចម្តេច ។

ឥធ ភិក្ខវេ បាបភិក្ខុ រាជានំ វា រាជមហាមត្តានំ វា និស្សិតោ ហោតិ តស្ស ឯវំ ហោតិ សចេ មំ កោចិ កិញ្ចិ វក្ខតិ ឥមេ មេ រាជានោ វា រាជមហាមត្តា វា បរិយោទាយ អត្ថំ ភណិស្សន្តីតិ ។ សចេ នំ កោចិ កិញ្ចិ អាហ ត្យាស្ស រាជានោ វា រាជមហាមត្តា វា បរិយោទាយ អត្ថំ ភណន្តិ ។ ឯវំ ខោ ភិក្ខវេ បាបភិក្ខុ ពលវនិស្សិតោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ បាបភិក្ខុ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតីតិ ។

ចូឡវគ្គោ បញ្ចមោ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រក់ក្នុងសាសនានេះ បានអាស្រ័យស្តេច ឬរាជមហាមាត្យ ភិក្ខុអាក្រក់នោះតែងមានសេចក្តីត្រិះរិះយ៉ាងនេះថា បើអ្នកណាមួយ ចោទប្រកាន់អ្វីអំពីអញ ព្រះរាជាទាំងឡាយនេះ ឬពួករាជមហាមាត្យទាំងនេះ នឹងពោលសេចក្តីបន្ទ្របឲ្យអញ ។ បើបុគ្គលណាមួយ ចោទប្រកាន់តិចតួចអំពីភិក្ខុនោះ ព្រះរាជាឬរាជមហាមាត្យទាំងនោះ តែងពោលសេចក្តីបន្ទ្របបុគ្គលនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអាក្រក់អាស្រ័យអ្នកមានកម្លាំងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានមារយាទអាក្រក់ដែលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងរក្សាខ្លួនដែលគាស់រំលើងបំផ្លាញគុណ ជាអ្នកប្រកបដោយទោសធំផង ប្រកបដោយទោសតូចផង ដែលពួកវិញ្ញូជន ត្រូវតិះដៀលផង រមែងទទួលបាបច្រើនផង ។

ចប់ ចូឡវគ្គ ទី ៥ ។

១៣១

បឋមបណ្ណាសកេ ចូឡវគ្គោ

# តស្សុទ្ទានំ

## សម្មុខិដ្ឋានប្បច្ចយវត្តំ

## បរេសំ បណ្ឌិតសីលញ្ច

## សង្ខតំ បព្វតាតប្បំ

## មហាចោរនេក្ខារសាតិ(១) ។

បឋមោ បណ្ណាសកោ សមត្តោ ។

---

១ ម. សម្មុខិដ្ឋានបវត្តិ បរេសំ បណ្ឌិតំ សីលវំ សង្ខារបព្វតាតប្បំ មហាចោរេន តេទសាតិ ។

បឋមបណ្ណាសក ចូឡវគ្គ

# ឧទ្ទាននៃចូឡវគ្គនោះ គឺ

អំពីរបស់ ៣ ចំពោះមុខ ១ សូត្រ សទ្ធាត្រូវដឹងដោយហេតុបី ១ សូត្រ អំណាចប្រយោជន៍ ១ សូត្រ សម្តីប្រព្រឹត្តទៅស្រួល ១ សូត្រ បណ្ឌិតបញ្ញត្ត ២ សូត្រ ភិក្ខុមានសីល ១ សូត្រ សង្ខតធម៌ ១ សូត្រ អសង្ខតធម៌ ១ សូត្រ ឈើធំអាស្រ័យភ្នំ ១ សូត្រ ព្យាយាម ១ សូត្រ មហាចោរ ១ សូត្ររួមជា ១១ សូត្រ ។

ចប់ បឋមបណ្ណាសក ។

# ទុតិយបណ្ណាសកោ

## ព្រាហ្មណវគ្គោ

[៤៣] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ទ្វេ ព្រាហ្មណា ជិណ្ណា វុឌ្ឍា មហល្លកា អទ្ធគតា វយោអនុប្បត្តា វីសវស្សសតិកា ជាតិយា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ព្រាហ្មណា ភគវន្តំ ឯតទវោចុំ មយមស្សុ ភោ គោតម ព្រាហ្មណា ជិណ្ណា វុឌ្ឍា មហល្លកា អទ្ធគតា វយោអនុប្បត្តា វីសវស្សសតិកា ជាតិយា តេ ចម្ហ អកតកល្យាណា អកតកុសលា អកតភីរុត្តាណា ឱវទតុ នោ ភវំ គោតមោ អនុសាសតុ នោ ភវំ គោតមោ យំ អម្ហាកំ អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។

# ទុតិយបណ្ណាសក

## ព្រាហ្មណវគ្គ

[៥៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានព្រាហ្មណ៍ ២ នាក់ជរា មានវ័យចម្រើន ចាស់ មានវ័យកន្លង ចូលដល់បច្ឆិមវ័យតាំងពីកើតមកបាន ១២០ ឆ្នាំហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលរាក់ទាក់ជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររាក់ទាក់ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍ទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ បានទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំជាព្រាហ្មណ៍ ជរា មានវ័យចម្រើនហើយ ចាស់ កន្លងវ័យចូលដល់បច្ឆិមវ័យតាំងពីកើតមកបាន ១២០ ឆ្នាំហើយ តែយើងខ្ញុំទាំងនោះ មិនបានធ្វើសេចក្តីល្អ មិនបានធ្វើកុសល មិនបានធ្វើទីពឹង ដើម្បីការពារភ័យ សូមព្រះគោតមដ៏ចម្រើន ទូន្មានយើងខ្ញុំ សូមព្រះគោតមដ៏ចម្រើន ប្រៀនប្រដៅពួកយើងខ្ញុំ ដើម្បីប្រយោជន៍ដើម្បីសុខ ដល់យើងខ្ញុំអស់កាលយូរ ។

តគ្ឃ តុម្ហេ ព្រាហ្មណា ជិណ្ណា វុឌ្ឍា មហល្លកា អទ្ធគតា វយោអនុប្បត្តា វីសវស្សសតិកា ជាតិយា តេ ចត្ថ[១] អកតកល្យាណា អកតកុសលា អកតភីរុត្តាណា ឧបនីយតិ ខោ អយំ ព្រាហ្មណា លោកោ ជរាយ ព្យាធិនា មរណេន ឯវំ ឧបនីយមានេ ខោ ព្រាហ្មណា លោកេ ជរាយ ព្យាធិនា មរណេន យោ ឥធ កាយេន សញ្ញមោ វាចាយ សញ្ញមោ មនសា សញ្ញមោ តំ តស្ស បេតស្ស តាណញ្ច លេណញ្ច ទីបញ្ច សរណញ្ច បរាយនញ្ចាតិ ។

ឧបនីយតិ ជីវិតមប្បមាយុំ
ជរូបនីតស្ស ន សន្តិ តាណា
ឯតំ ភយំ មរណេ បេក្ខមានោ
បុញ្ញានិ កយិរាថ សុខាវហានិ ។

---

១ ម. តេ ជេដ្ឋា ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា អើអ្នកទាំងឡាយជាព្រាហ្មណ៍ជរា មានវ័យចម្រើនហើយ ចាស់កន្លងវ័យ ចូលដល់បច្ឆិមវ័យ តាំងពីកើតមកបាន ១២០ ឆ្នាំហើយ តែថាអ្នកទាំងនោះ មិនបានធ្វើសេចក្ដីល្អ មិនបានធ្វើកុសល មិនបានធ្វើទីពឹង ដើម្បីការពារភ័យ ម្នាលព្រាហ្មណ៍ទាំងឡាយ សត្វលោកនេះដែលជរា ព្យាធិ មរណៈបញ្ជូន[១]តៗ គ្នា ម្នាលព្រាហ្មណ៍ទាំងឡាយ កាលបើសត្វលោកដែលជរា ព្យាធិ មរណៈបញ្ជូនតៗ គ្នាយ៉ាងនេះ សេចក្ដីសង្រួមដោយកាយ សេចក្ដីសង្រួមដោយវាចា សេចក្ដីសង្រួមដោយចិត្តណា ពីឥឡូវនេះទៅ បុណ្យដែលកើតអំពីសេចក្ដីសង្រួមនោះជាទីជ្រកកោនផង ជាទីពួនផង ជាទីពឹងផង ជាទីរឭកផង ជាទីសង្ឃឹមផង របស់បុគ្គលអ្នកទៅកាន់បរលោកនោះ ។

ជីវិតគឺអាយុមានប្រមាណតិច ដែលជរាបញ្ជូន
ត ៗ គ្នា ទីពឹងទាំងឡាយ មិនមានដល់បុគ្គល
ដែលជរាបញ្ជូនត ៗ គ្នាទៅ កាលបើបុគ្គលឃើញ
ភ័យក្នុងមរណៈនុ៎ះ គួរធ្វើនូវបុណ្យទាំងឡាយ
ដែលជាហេតុនាំមកនូវសេចក្ដីសុខ ។

---

១ សត្វលោកដែលជាតិបញ្ជូនទៅឲ្យជរាៗ បញ្ជូនទៅឲ្យព្យាធិៗ បញ្ជូនទៅឲ្យមរណៈៗ បញ្ជូនទៅឲ្យជាតិវិញ ។

យេន កាយេន សញ្ញមោ
វាចាយ ឧទ ចេតសា
តំ តស្ស បេតស្ស សុខាយ ហោតិ
យំ ជីវមានោ បករោតិ បុញ្ញន្តិ។

[៤៨] អថខោ ទ្វេ ព្រាហ្មណា ជិណ្ណា វុឌ្ឍា មហល្លកា អទ្ធគតា វយោអនុប្បត្តា វីសវស្សសតិកា ជាតិយា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ព្រាហ្មណា ភគវន្តំ ឯតទវោចុំ មយមស្សុ ភោ គោតម ព្រាហ្មណា ជិណ្ណា វុឌ្ឍា មហល្លកា អទ្ធគតា វយោអនុប្បត្តា វីសវស្សសតិកា ជាតិយា តេ ចម្ហ អកតកល្យាណា អកតកុសលា អកតភីរុត្តាណា ឱវទតុ នោ ភវំ គោតមោ អនុសាសតុ នោ ភវំ គោតមោ យំ អម្ហាកំ អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ ។

សេចក្តីសង្រួមដោយកាយវាចាចិត្តណា តាំង
ពីឥឡូវនេះទៅ បុណ្យដែលកើតអំពីការសង្រួម
នោះ រមែងប្រព្រឹត្តទៅ ដើម្បីជាសុខដល់បុគ្គល
ដែលទៅកាន់បរលោកនោះ (ព្រោះហេតុនោះ)
កាលបើបុគ្គលរស់នៅ គួរតែធ្វើបុណ្យ ។

[៥៤] គ្រានោះឯង ព្រាហ្មណ៍ ២ នាក់ ជរា មានវ័យចម្រើនហើយ ចាស់កន្លងវ័យ ចូលដល់បច្ឆិមវ័យ តាំងពីកើតមកបាន ១២០ ឆ្នាំហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយ ក្នុងទីដ៏សមគួរ ។ លុះព្រាហ្មណ៍ទាំងនោះអង្គុយ ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន យើងជាព្រាហ្មណ៍ជរា មានវ័យចម្រើនហើយ ចាស់កន្លងវ័យហើយចូលដល់បច្ឆិមវ័យតាំងពីកើតមកបាន១២០ឆ្នាំហើយ តែយើងទាំងនោះ មិនបានធ្វើសេចក្តីល្អ មិនបានធ្វើកុសល មិនបានធ្វើទីពឹងការពារភ័យសោះ សូមព្រះគោតមដ៏ចម្រើន ទូន្មានយើងខ្ញុំព្រះអង្គ សូមព្រះគោតមដ៏ចម្រើន ប្រៀនប្រដៅយើងខ្ញុំព្រះអង្គ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់យើងខ្ញុំព្រះអង្គអស់កាលដ៏យូរ ។

តត្ថ តុម្ហេ ព្រាហ្មណា ជិណ្ណា វុឌ្ឍា មហល្លកា អទ្ធគតា វយោអនុប្បត្តា វីសវស្សសតិកា ជាតិយា តេ ចត្ថ អកតកល្យាណា អកតកុសលា អកតភីរុត្តាណា អាទិត្តោ ខោ អយំ ព្រាហ្មណា លោកោ ជរាយ ព្យាធិនា មរណេន ឯវំ អាទិត្តេ ខោ ព្រាហ្មណា លោកេ ជរាយ ព្យាធិនា មរណេន យោ ឥធ កាយេន សញ្ញមោ វាចាយ សញ្ញមោ មនសា សញ្ញមោ តំ តស្ស បេតស្ស តាណញ្ច លេណញ្ច ទីបញ្ច សរណញ្ច បរាយណញ្ចាតិ ។

អាទិត្តស្មឹ អគារស្មឹ
យំ នីហរតិ ភាជនំ
តំ តស្ស ហោតិ អត្ថាយ
នោ ច យំ តត្ថ ឌយ្ហតិ
ឯវមាទិត្តកោ លោកោ
ជរាយ មរណេន ច
នីហរេថេវ ទានេន
ទិន្នំ ហោតិ សុនីហតំ[១] ។

១ ម. សុនិព្ភតំ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា អើអ្នកទាំងឡាយ ជាព្រាហ្មណ៍ជរា មានវ័យចម្រើនហើយ ចាស់កន្លងវ័យ ចូលដល់បច្ឆិមវ័យ តាំងពីកើតមក បាន ១២០ ឆ្នាំហើយ តែថាអ្នកទាំងនោះ មិនបានធ្វើសេចក្តីល្អ មិនបាន ធ្វើកុសល មិនបានធ្វើទីពឹងការពារភ័យសោះ ម្នាលព្រាហ្មណ៍ទាំង-ឡាយ សត្វលោកនេះ ក្តៅក្រហាយព្រោះជរា ព្យាធិ មរណៈ ម្នាល ព្រាហ្មណ៍ទាំងឡាយ កាលបើសត្វលោកក្តៅក្រហាយ ព្រោះជរា ព្យាធិ មរណៈយ៉ាងនេះហើយ សេចក្តីសង្រួមដោយកាយ សេចក្តីសង្រួមដោយ វាចា សេចក្តីសង្រួមដោយចិត្តណា តាំងពីឥឡូវនេះទៅ បុណ្យ (ដែល កើតអំពីសេចក្តីសង្រួម) នោះជាទីជ្រកកោនផង ជាទីពួនផង ជាទីពឹងផង ជាទីរឭកផង ជាទីសង្ឃឹមផង របស់បុគ្គលដែលទៅកាន់បរលោកនោះ ។

កាលបើផ្ទះ ត្រូវភ្លើងឆេះ ជនម្ចាស់ផ្ទះតែងជញ្ជូន ភាជន៍ណា ចេញផុត (អំពីផ្ទះ ឬទ្រព្យណា ក្នុងផ្ទះនោះ (ដែលគេជញ្ជូនចេញហើយ) ភ្លើងឆេះមិនបាន ទ្រព្យ នោះ រមែងបានជាប្រយោជន៍របស់គេ យ៉ាងណា សត្វលោក ដែលត្រូវភ្លើងគឺជរានិងមរណៈឆាបឆេះ គួរប្រញាប់ជញ្ជូនចេញឲ្យផុត (អំពីផ្ទះគឺរាងកាយ) ដោយការឲ្យទាន (ព្រោះថា) ទានដែលគេឲ្យហើយ ឈ្មោះថា បានជញ្ជូនដោយល្អ ក៏យ៉ាងនោះដែរ ។

យោគ កាយេន សញ្ញមោ
វាចាយ ឧទ ចេតសា
តំ តស្ស បេតស្ស សុខាយ ហោតិ
យំ ជីវមានោ បករោតិ បុញ្ញន្តិ ។

[៥៥] អថខោ អញ្ញតរោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្មណោ ភគវន្តំ ឯតទវោច សន្ទិដ្ឋិកោ ធម្មោ សន្ទិដ្ឋិកោ ធម្មោតិ ភោ គោតម វុច្ចតិ ។ កិត្តាវតា នុ ខោ ភោ គោតម សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ រត្តោ ខោ ព្រាហ្មណ រាគេន អភិភូតោ បរិយាទិន្នចិត្តោ អត្តព្យាពាធាយបិ ចេតេតិ បរព្យាពាធាយបិ ចេតេតិ

ការសង្រួមដោយកាយ វាចា ចិត្តណា ពីឥឡូវនេះទៅ
បុណ្យ (ដែលកើតមកអំពីការសង្រួម) នោះ រមែង
កើតសុខដល់បុគ្គលដែលទៅកាន់បរលោក ហើយនោះ
ហេតុនោះ កាលបើបុគ្គលរស់នៅ គួរតែធ្វើបុណ្យ ។

[៥៥] គ្រានោះឯង មានព្រាហ្មណ៍ម្នាក់ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ជាមួយនឹងព្រះមានព្រះភាគ ។ បេ ។ លុះព្រាហ្មណ៍នោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គតែងសម្តែងថា ធម៌ដែលបុគ្គលឃើញច្បាស់ ដោយខ្លួនឯង ធម៌ដែលបុគ្គលឃើញច្បាស់ ដោយខ្លួនឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលបុគ្គលឃើញច្បាស់ ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងចិត្តរបស់ខ្លួនបាន ដែលពួកអ្នកប្រាជ្ញគប្បីឃើញ ចំពោះខ្លួន តើដោយហេតុដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលត្រេកអរ ដែលរាគៈគ្របសង្កត់ មានចិត្តប្រកាន់មាំ តែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ

ឧភយព្យាពាធាយបិ ចេតេតិ ចេតសិកំបិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ រាគេ បហីនេ នេវ អត្តព្យាពាធាយបិ ចេតេតិ ន បរព្យាពាធាយបិ ចេតេតិ ន ឧភយព្យាពាធាយបិ ចេតេតិ ន ចេតសិកំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ ឯវំបិ ខោ ព្រាហ្មណ សន្ទិដ្ឋិកោ ធម្មោ ហោតិ... ទុដ្ឋោ ខោ ព្រាហ្មណ ទោសេន អភិភូតោ បរិយាទិន្នចិត្តោ អត្តព្យាពាធាយបិ ចេតេតិ បរព្យាពាធាយបិ ចេតេតិ ឧភយព្យាពាធាយបិ ចេតេតិ ចេតសិកំបិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ ទោសេ បហីនេ នេវ អត្តព្យាពាធាយបិ ចេតេតិ ន បរព្យាពាធាយបិ ចេតេតិ ន ឧភយព្យាពា-ធាយបិ ចេតេតិ ន ចេតសិកំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ ឯវំបិ ខោ ព្រាហ្មណ សន្ទិដ្ឋិកោ ធម្មោ ហោតិ... មូឡ្ហោ ខោ ព្រាហ្មណ មោហេន អភិភូតោ បរិយាទិន្នចិត្តោ អត្តព្យាពាធាយបិ ចេតេតិ

គិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃខ្លះ ក៏រមែងរងទុក្ខទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះបង់រាគៈហើយ បុគ្គលរមែងមិនគិតដើម្បីបៀតបៀនខ្លួនឯងផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃផង រមែងមិនរងទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះឯងហើយឈ្មោះថាធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង... ម្នាលព្រាហ្មណ៍បុគ្គលប្រទូស្ត ដែលទោសៈគ្របសង្កត់ មានចិត្តប្រកាន់មាំ តែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃខ្លះ ក៏រមែងទទួលទុក្ខ ទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះទោសៈបានហើយ បុគ្គលតែងមិនគិត ដើម្បីបៀតបៀនខ្លួនឯងផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃផង រមែងមិនទទួលទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះហើយឈ្មោះថា ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង... ម្នាលព្រាហ្មណ៍ បុគ្គលវង្វេងដែលមោហៈគ្របសង្កត់ មានចិត្តប្រកាន់មាំ តែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ

បរព្យាពាធាយបិ ចេតេតិ ឧភយព្យាពាធាយបិ ចេតេតិ ចេតសិកំបិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ មោហេ បហីនេ នេវ អត្តព្យាពាធាយបិ ចេតេតិ ន បរព្យាពាធាយបិ ចេតេតិ ន ឧភយព្យាពាធាយបិ ចេតេតិ ន ចេតសិកំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ ឯវំបិ ខោ ព្រាហ្មណ សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

[៥៦] អថខោ អញ្ញតរោ ព្រាហ្មណបរិព្វាជកោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្មណបរិព្វាជកោ ភគវន្តំ ឯតទវោច សន្ទិដ្ឋិ-កោ ធម្មោ សន្ទិដ្ឋិកោ ធម្មោតិ ភោ គោតម វុច្ចតិ ។

គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃខ្លះ ក៏រមែងទទួលទុក្ខទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះមោហៈហើយ បុគ្គលមិនគិតដើម្បីបៀតបៀនខ្លួនឯងផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃផង រមែងមិនទទួលទុក្ខទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះហើយ ឈ្មោះថា ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងចិត្តរបស់ខ្លួនបាន ដែលវិញ្ញូជនគប្បីដឹងច្បាស់ដោយខ្លួនឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើនចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណគមន៍ ស្មើដោយជីវិតតាំងអំពីថ្ងៃនេះជាដើមទៅ ។

[៥៦] គ្រានោះឯង មានព្រាហ្មណ៍បរិព្វាជកម្នាក់ ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះព្រាហ្មណ៍បរិព្វាជកនោះអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គតែងសម្តែងថាធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង ។

១៣៩



កិត្តាវតា នុ ខោ ភោ គោតម សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ រត្តោ ខោ ព្រាហ្មណ រាគេន អភិភូតោ បរិយាទិន្នចិត្តោ អត្តព្យាពាធាយបិ ចេតេតិ បរព្យាពាធាយបិ ចេតេតិ ឧភយព្យាពាធាយបិ ចេតេតិ ចេតសិកំបិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ រាគេ បហីនេ នេវ អត្តព្យាពាធាយបិ ចេតេតិ ន បរព្យាពាធាយបិ ចេតេតិ ន ឧភយព្យាពាធាយបិ ចេតេតិ ន ចេតសិកំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ រត្តោ ខោ ព្រាហ្មណ រាគេន អភិភូតោ បរិយាទិន្នចិត្តោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ ។ រាគេ បហីនេ នេវ កាយេន ទុច្ចរិតំ ចរតិ ន វាចាយ ទុច្ចរិតំ ចរតិ ន មនសា ទុច្ចរិតំ ចរតិ ។ រត្តោ ខោ ព្រាហ្មណ រាគេន អភិភូតោ

បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលបុគ្គលឃើញច្បាស់ ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរហៅបុគ្គលដទៃ ឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុក ក្នុងចិត្តរបស់ខ្លួន ដែលពួកវិញ្ញូជនគប្បីដឹងច្បាស់ដោយខ្លួនឯង តើដោយហេតុដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលត្រេកអរដែលរាគៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃខ្លះ ក៏រមែងទទួលទុក្ខទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះបង់រាគៈបានហើយ បុគ្គលរមែងមិនគិត ដើម្បីបៀតបៀនខ្លួនឯងផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃផង រមែងមិនទទួលទុក្ខ ទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលព្រាហ្មណ៍ បុគ្គលត្រេកអរដែលរាគៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើលះបង់រាគៈហើយ បុគ្គលរមែងមិនប្រព្រឹត្តទុច្ចរិតដោយកាយ មិនប្រព្រឹត្តទុច្ចរិតដោយវាចា មិនប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ ម្នាលព្រាហ្មណ៍ បុគ្គលត្រេកអរដែលរាគៈគ្របសង្កត់

បរិយាទិន្នចិត្តោ អត្តត្ថំបិ យថាភូតំ នប្បជានាតិ បរត្ថំបិ យថាភូតំ នប្បជានាតិ ឧភយត្ថំបិ យថាភូតំ នប្បជានាតិ ។ រាគេ បហីនេ អត្តត្ថំបិ យថាភូតំ បជានាតិ បរត្ថំបិ យថាភូតំ បជានាតិ ឧភយត្ថំបិ យថាភូតំ បជានាតិ ។ ឯវំបិ ខោ ព្រាហ្មណ សន្ទិដ្ឋិកោ ធម្មោ ហោតិ... ទុដ្ឋោ ខោ ព្រាហ្មណ ។ បេ ។ មូឡ្ហោ ខោ ព្រាហ្មណ មោហេន អភិភូតោ បរិយាទិន្នចិត្តោ អត្តព្យាពាធាយបិ ចេតេតិ បរព្យាពាធាយបិ ចេតេតិ ឧភយព្យាពាធាយបិ ចេតេតិ ចេតសិកំបិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ មោហេ បហីនេ នេវ អត្តព្យាពាធាយបិ ចេតេតិ ន បរព្យាពាធាយបិ ចេតេតិ ន ឧភយព្យាពាធាយបិ ចេតេតិ ន ចេតសិកំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ មូឡ្ហោ ខោ ព្រាហ្មណ មោហេន អភិភូតោ

មានចិត្តប្រកាន់មាំ រមែងមិនដឹងនូវប្រយោជន៍របស់ខ្លួនតាមពិតខ្លះ មិនដឹងនូវប្រយោជន៍របស់បុគ្គលដទៃតាមពិតខ្លះ មិនដឹងនូវប្រយោជន៍ខ្លួនឯងនិងអ្នកដទៃតាមពិតខ្លះ ។ កាលបើលះបង់រាគៈបានហើយ បុគ្គលរមែងដឹងនូវប្រយោជន៍របស់ខ្លួនតាមពិតផង ដឹងនូវប្រយោជន៍របស់អ្នកដទៃតាមពិតផង ដឹងនូវប្រយោជន៍ខ្លួននិងអ្នកដទៃតាមពិតផង ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះឯងហើយឈ្មោះថា ធម៌ដែលបុគ្គលឃើញច្បាស់ដោយខ្លួនឯង... ម្នាលព្រាហ្មណ៍ បុគ្គលប្រទូស្ត ។ បេ ។ ម្នាលព្រាហ្មណ៍ បុគ្គលវង្វេងដែលមោហៈ គ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃខ្លះ ក៏រមែងទទួលទុក្ខទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះបង់មោហៈបានហើយ បុគ្គលរមែងមិនគិតដើម្បីបៀតបៀនខ្លួនឯងផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃផង រមែងមិនទទួលទុក្ខទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលព្រាហ្មណ៍ បុគ្គលវង្វេងដែលមោហៈគ្របសង្កត់

១៤១



បរិយាទិន្នចិត្តោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ ។ មោហេ បហីនេ នេវ កាយេន ទុច្ចរិតំ ចរតិ ន វាចាយ ទុច្ចរិតំ ចរតិ ន មនសា ទុច្ចរិតំ ចរតិ ។ មូឡ្ហោ ខោ ព្រាហ្មណ មោហេន អភិភូតោ បរិយាទិន្នចិត្តោ អត្តត្ថំបិ យថាភូតំ នប្បជានាតិ បរត្ថំបិ យថាភូតំ នប្បជានាតិ ឧភយត្ថំបិ យថាភូតំ នប្បជានាតិ ។ មោហេ បហីនេ អត្តត្ថំបិ យថាភូតំ បជានាតិ បរត្ថំបិ យថាភូតំ បជានាតិ ឧភយត្ថំបិ យថាភូតំ បជានាតិ ។ ឯវំ ខោ ព្រាហ្មណ សន្ទិដ្ឋិកោ ធម្មោ ហោតិ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

មានចិត្តប្រកាន់មាំ រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ កាលបើលះមោហៈបានហើយ បុគ្គលរមែងមិនប្រព្រឹត្តទុច្ចរិតដោយកាយ មិនប្រព្រឹត្តទុច្ចរិតដោយវាចា មិនប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ ម្នាលព្រាហ្មណ៍ បុគ្គលវង្វេងដែលមោហៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងមិនដឹងនូវប្រយោជន៍របស់ខ្លួនតាមពិតខ្វះ មិនដឹងនូវប្រយោជន៍របស់បុគ្គលដទៃតាមពិតខ្វះ មិនដឹងនូវប្រយោជន៍ខ្លួនឯងនិងអ្នកដទៃតាមពិតខ្វះ ។ កាលបើលះមោហៈបានហើយ បុគ្គល រមែងដឹងនូវប្រយោជន៍របស់ខ្លួនតាមពិតផង ដឹងនូវប្រយោជន៍អ្នកដទៃតាមពិតផង ដឹងនូវប្រយោជន៍ខ្លួននិងអ្នកដទៃតាមពិតផង ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះឯង ឈ្មោះថា ធម៌ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុក ក្នុងចិត្តរបស់ខ្លួនបាន ដែលពួកវិញ្ញូជនគប្បីដឹងច្បាស់ដោយខ្លួនឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសកអ្នកដល់នូវសរណគមន៍ស្មើដោយជីវិតតាំងអំពីថ្ងៃនេះជាដើមទៅ ។

[៩៧] អថខោ ជានុស្សោណី ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ ជានុស្សោណី ព្រាហ្មណោ ភគវន្តំ ឯតទវោច សន្ទិដ្ឋិកំ និព្វានំ សន្ទិដ្ឋិកំ និព្វានន្តិ ភោ គោតម វុច្ចតិ ។ កិត្តាវតា នុ ខោ ភោ គោតម សន្ទិដ្ឋិកំ និព្វានំ ហោតិ អកាលិកំ ឯហិបស្សិកំ ឱបនយិកំ បច្ចត្តំ វេទិតព្វំ វិញ្ញូហីតិ ។ រត្តោ ខោ ព្រាហ្មណ រាគេន អភិភូតោ បរិយាទិន្នចិត្តោ អត្តព្យាពាធាយបិ ចេតេតិ បរព្យាពាធាយបិ ចេតេតិ ឧភយព្យាពាធាយបិ ចេតេតិ ចេតសិកំបិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ រាគេ បហីនេ នេវ អត្តព្យាពាធាយបិ ចេតេតិ ន បរព្យាពាធាយបិ ចេតេតិ ន ឧភយព្យាពាធាយបិ ចេតេតិ ន ចេតសិកំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។

[៥៧] គ្រានោះឯង ព្រាហ្មណ៍ឈ្មោះជានុស្សោណិ ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះជានុស្សោណិព្រាហ្មណ៍អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ព្រះអង្គតែងសម្តែងថា ព្រះនិព្វានដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ព្រះនិព្វានជាធម្មជាតដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រះនិព្វានជាធម្មជាតដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុក ក្នុងចិត្តរបស់ខ្លួនបាន ដែលវិញ្ញូជនទាំងឡាយ គប្បីដឹងច្បាស់ដោយខ្លួនឯង តើដោយហេតុដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បុគ្គលត្រេកអរដែលរាគៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃខ្លះ ក៏រមែងទទួលទុក្ខទោមនស្សប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះរាគៈបានហើយ បុគ្គលរមែងមិនគិតដើម្បីបៀតបៀនខ្លួនផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃផង រមែងមិនទទួលទុក្ខទោមនស្ស ដែលប្រព្រឹត្តទៅក្នុងចិត្ត ។

ឯវំបិ ខោ ព្រាហ្មណ សន្ទិដ្ឋិកំ និព្វានំ ហោតិ... ទុដ្ឋោ ខោ ព្រាហ្មណ ។ បេ ។ មូឡ្ហោ ខោ ព្រាហ្មណ មោហេន អភិភូតោ បរិយាទិន្នចិត្តោ អត្តព្យាពាធាយបិ ចេតេតិ បរព្យាពាធាយបិ ចេតេតិ ឧភយព្យាពាធាយបិ ចេតេតិ ចេតសិកំបិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ មោហេ បហីនេ នេវ អត្តព្យាពាធាយបិ ចេតេតិ ន បរព្យាពាធាយបិ ចេតេតិ ន ឧភយព្យាពាធាយបិ ចេតេតិ ន ចេតសិកំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ ឯវំ ខោ ព្រាហ្មណ សន្ទិដ្ឋិកំ និព្វានំ ហោតិ... យតោ ខោ អយំ ព្រាហ្មណ អនវសេសំ រាគក្ខយំ បដិសំវេទេតិ អនវសេសំ ទោសក្ខយំ បដិសំវេទេតិ អនវសេសំ មោហក្ខយំ បដិសំវេទេតិ ។ ឯវំ ខោ ព្រាហ្មណ សន្ទិដ្ឋិកំ និព្វានំ ហោតិ អកាលិកំ ឯហិបស្សិកំ ឱបនយិកំ បច្ចត្តំ វេទិតព្វំ វិញ្ញូហីតិ ។

ម្នាលព្រាហ្មណ៍ យ៉ាងនេះឯងហើយ ព្រះនិព្វានឈ្មោះថាជាធម្មជាត ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង... ម្នាលព្រាហ្មណ៍ បុគ្គលប្រទូស្ត ។ បេ ។ ម្នាលព្រាហ្មណ៍ បុគ្គលវង្វេងដែលមោហៈគ្របសង្កត់ មានចិត្តប្រកាន់មាំ រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃខ្លះ ក៏រមែងទទួលទុក្ខ ទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្ត ។ កាលបើលះបង់មោហៈហើយ បុគ្គលរមែងមិនគិតដើម្បីបៀតបៀនខ្លួនឯងផង មិនគិតដើម្បីបៀតបៀនអ្នកដទៃផង មិនគិតដើម្បីបៀតបៀនខ្លួនឯងនិងអ្នកដទៃផង រមែងមិនទទួលទុក្ខ ទោមនស្សដែលប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះឯងហើយព្រះនិព្វាន ឈ្មោះថា ជាធម្មជាតដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង... ម្នាលព្រាហ្មណ៍ បុគ្គលនេះ ទទួលនូវការអស់រាគៈឥតសេសសល់ ទទួលនូវការអស់ទោសៈឥតសេសសល់ ទទួលនូវការអស់មោហៈឥតសេសសល់ ។ ម្នាលព្រាហ្មណ៍ យ៉ាងនេះឯងហើយព្រះនិព្វានឈ្មោះថាជាធម្មជាតដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងចិត្តរបស់ខ្លួន ដែលពួកវិញ្ញូជនគប្បីដឹងច្បាស់ដោយខ្លួនឯង ។

អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

[៤៨] អថខោ អញ្ញតរោ ព្រាហ្មណមហាសាលោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ព្រាហ្មណមហាសាលោ ភគវន្តំ ឯតទវោច សុតម្មេតំ ភោ គោតម បុព្វកានំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយប្បាចរិយានំ ភាសមានានំ បុព្វស្សុទំ អយំ លោកោ អវីចិ មញ្ញេ ផុដោ ហោតិ[១] មនុស្សេហិ កុក្កុដសម្បាទិកា[២] គាមនិគមជនបទរាជធានិយោតិ ។ កោនុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យេនេតរហិ មនុស្សានំ ខយោ ហោតិ តនុត្តំ បញ្ញាយតិ គាមាបិ អគាមា ហោន្តិ និគមាបិ អនិគមា ហោន្តិ នគរាបិ អនគរា ហោន្តិ ជនបទាបិ អជនបទា ហោន្តីតិ ។ ឯតរហិ ព្រាហ្មណា មនុស្សា

១ ឱ. ម. អហោសីតិ ទិស្សតិ ។ ២ ឱ. ម. កុក្កុដសម្បាតិកា ។

បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិតតាំងពីថ្ងៃនេះជាដើមទៅ ។

[៥៨] គ្រានោះឯង មានព្រាហ្មណ៍មហាសាលម្នាក់ ចូលទៅគាល់ព្រះមានព្រះភាគ ។ បេ ។ លុះព្រាហ្មណ៍មហាសាលនោះ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យនេះអំពីពួកព្រាហ្មណ៍ជាន់មុន មានវ័យចម្រើន ចាស់ជាអាចារ្យតៗ គ្នាមកនិយាយថា កាលពីដើម លោកនេះពេញពាសដោយពួកមនុស្ស ហាក់ដូចជាអវីចិមហានរក ស្រុកនិគមជនបទ រាជធានី (ជិតៗ គ្នា) ល្មមចម្ងាយមាន់ហើរដល់ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យពួកមនុស្សក្នុងកាលឥឡូវនេះអស់ទៅ តិចទៅ ស្រុកទៅជាមិនមែនស្រុក និគមទៅជាមិនមែននិគម នគរទៅជាមិនមែននគរ ជនបទទៅជាមិនមែនជនបទ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពួកមនុស្សឥឡូវនេះ

អធម្មរាគរត្តា វិសមលោភាភិភូតា មិច្ឆាធម្មបរេតា តេ អធម្មរាគរត្តា វិសមលោភាភិភូតា មិច្ឆា-ធម្មបរេតា តិណ្ហានិ សត្ថានិ គហេត្វា អញ្ញមញ្ញស្ស ជីវិតា វោរោបេន្តិ តេន ពហូ មនុស្សា កាលំ ករោន្តិ ។ អយំបិ ខោ ព្រាហ្មណ ហេតុ អយំ បច្ចយោ យេនេតរហិ មនុស្សានំ ខយោ ហោតិ តនុត្តំ បញ្ញាយតិ គាមាបិ អគាមា ហោន្តិ និគមាបិ អនិគមា ហោន្តិ នគរាបិ អនគរា ហោន្តិ ជន-បទាបិ អជនបទា ហោន្តិ ។ បុន ចបរំ ព្រាហ្មណ ឯតរហិ មនុស្សា អធម្មរាគរត្តា វិសមលោភាភិភូតា មិច្ឆាធម្មបរេតា តេសំ អធម្មរាគរត្តានំ វិសមលោភា-ភិភូតានំ មិច្ឆាធម្មបរេតានំ ទេវោ ន សម្មាធារំ អនុប្បវេច្ឆតិ តេន ទុព្ភិក្ខំ ហោតិ ទុស្សស្សំ សេតដ្ឋិកំ សលាកាវុត្តំ តេន ពហូ មនុស្សា កាលំ ករោន្តិ ។ អយំបិ ខោ ព្រាហ្មណ ហេតុ អយំ បច្ចយោ យេនេតរហិ មនុស្សានំ ខយោ ហោតិ តនុត្តំ បញ្ញាយតិ គាមាបិ អគាមា ហោន្តិ

ត្រេកអរក្នុងអធម្មរាគៈ ត្រូវវិសមលោភៈគ្របសង្កត់ ត្រូវមិច្ឆាធម៌រួបរឹត កាលបើមនុស្សទាំងនោះ ត្រេកអរក្នុងអធម្មរាគៈ ត្រូវវិសមលោភៈគ្របសង្កត់ ត្រូវមិច្ឆាធម៌រួបរឹតហើយ ក៏ចាប់យកសស្ត្រាដ៏មុតផ្តាច់ជីវិតគ្នានិងគ្នា ហេតុនោះ បានជាពួកមនុស្សដ៏ច្រើន ក៏ធ្វើមរណៈកាល ។ ម្នាលព្រាហ្មណ៍ នេះជាហេតុ នេះជាបច្ច័យ ដែលនាំពួកមនុស្សក្នុងកាលឥឡូវនេះអស់ទៅ តិចទៅ ស្រុកទៅជាមិនមែនស្រុក និគមទៅជាមិនមែននិគម នគរទៅជាមិនមែននគរ ជនបទទៅជាមិនមែនជនបទ ។ ម្នាលព្រាហ្មណ៍ មួយទៀត ពួកមនុស្សឥឡូវនេះ ត្រេកអរក្នុងអធម្មរាគៈ ត្រូវវិសមលោភៈគ្របសង្កត់ ត្រូវមិច្ឆាធម៌រួបរឹត កាលបើពួកមនុស្សទាំងនោះ ត្រេកអរក្នុងអធម្មរាគៈ ត្រូវវិសមលោភៈគ្របសង្កត់ ត្រូវមិច្ឆាធម៌រួបរឹត ភ្លៀងក៏មិនបង្អុរនូវមេទឹកដោយប្រពៃ ហេតុនោះ បានជាកើតទុព្ភិក្ស សំទូងមិនល្អ ក្រាស៊ី ស្កកស្គំ ហេតុនោះ បានជាពួកមនុស្សដ៏ច្រើន ធ្វើមរណកាល ។ ម្នាលព្រាហ្មណ៍ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យពួកមនុស្សឥឡូវនេះអស់ទៅ តិចទៅ ស្រុកទៅជាមិនមែនស្រុក

និគមាបិ អនិគមា ហោន្តិ នគរាបិ អនគរា ហោន្តិ ជនបទាបិ អជនបទា ហោន្តិ ។ បុន ចបរំ ព្រាហ្មណ ឯតរហិ មនុស្សា អធម្មរាគរត្តា វិសមលោភា-ភិភូតា មិច្ឆាធម្មបរេតា តេសំ អធម្មរាគរត្តានំ វិសមលោភាភិភូតានំ មិច្ឆាធម្មបរេតានំ យក្ខា វាឡេ អមនុស្សេ ឱស្សជ្ជន្តិ តេន ពហូ មនុស្សា កាលំ ករោន្តិ ។ អយំបិ ខោ ព្រាហ្មណ ហេតុ អយំ បច្ចយោ យេនេតរហិ មនុស្សានំ ខយោ ហោតិ តនុត្តំ បញ្ញាយតិ គាមាបិ អគាមា ហោន្តិ និគមាបិ អនិគមា ហោន្តិ នគរាបិ អនគរា ហោន្តិ ជនបទាបិ អជនបទា ហោន្តីតិ ។ អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

*និគមទៅជាមិនមែននិគម នគរទៅជាមិនមែននគរ ជនបទទៅជាមិនមែនជនបទ ។ ម្នាលព្រាហ្មណ៍ មួយទៀត ពួកមនុស្សឥឡូវនេះ ត្រេកអរក្នុងអធម្មរាគៈ ត្រូវវិសមលោភៈគ្របសង្កត់ ត្រូវមិច្ឆាធម៌របរឹត កាលបើពួកមនុស្សទាំងនោះត្រេកអរក្នុងអធម្មរាគៈ ត្រូវវិសមលោភៈគ្របសង្កត់ ត្រូវមិច្ឆាធម៌របរឹតហើយ យក្ខទាំងឡាយ ក៏លែងពួកអមនុស្សដ៏កាច (ឲ្យចាប់) ហេតុនោះ បានជាមនុស្សដ៏ច្រើន ធ្វើមរណកាល ។ ម្នាលព្រាហ្មណ៍ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យពួកមនុស្សឥឡូវនេះអស់ទៅ តិចទៅ ស្រុកទៅជាមិនមែនស្រុក និគមទៅជាមិនមែននិគម នគរទៅជាមិនមែននគរ ជនបទទៅជាមិនមែនជនបទ ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណគមន៍ស្មើដោយជីវិតតាំងអំពីថ្ងៃនេះជាដើមទៅ ។*

ទុតិយបណ្ណាសកេ ព្រាហ្មណវគ្គោ

[៤៩] អថខោ វច្ឆគោត្តោ[១] បរិព្វាជកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វច្ឆគោត្តោ បរិព្វាជកោ ភគវន្តំ ឯតទវោច សុតម្មេតំ ភោ គោតម សមណោ គោតមោ ឯវមាហ មយ្ហមេវ ទានំ ទាតព្វំ នាញ្ញេសំ ទានំ ទាតព្វំ មយ្ហមេវ សាវកានំ ទានំ ទាតព្វំ នាញ្ញេសំ សាវកានំ ទានំ ទាតព្វំ មយ្ហមេវ ទិន្នំ មហប្ផលំ នាញ្ញេសំ ទិន្នំ មហប្ផលំ មយ្ហមេវ សាវកានំ ទិន្នំ មហប្ផលំ នាញ្ញេសំ សាវកានំ ទិន្នំ មហប្ផលន្តិ ។ យេតេ ភោ គោតម ឯវមាហំសុ សមណោ គោតមោ ឯវមាហ មយ្ហមេវ ទានំ ទាតព្វំ នាញ្ញេសំ ទានំ ទាតព្វំ មយ្ហមេវ សាវកានំ ទានំ ទាតព្វំ

១ ម. វច្ឆបុត្តោ ។

[៥៩] គ្រានោះឯង វច្ឆគោត្តបរិញ្វាជក ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយនិងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវច្ឆគោត្តបរិញ្វាជក អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យនេះថា ព្រះសមណគោតម ត្រាស់យ៉ាងនេះថា បុគ្គលគួរឲ្យទាន ដល់តថាគត មិនគួរឲ្យទានដល់ពួកជនដទៃឡើយ បុគ្គលគួរឲ្យទានដល់ពួកសាវ័កតថាគត មិនគួរឲ្យទានដល់ពួកសាវ័កគ្រូដទៃឡើយ ទានដែលបុគ្គលឲ្យដល់តថាគតហើយ មានផលច្រើន ទានដែលបុគ្គលឲ្យដល់ពួកជនដទៃ មិនមានផលច្រើនទេ ទានដែលបុគ្គលឲ្យដល់ពួកសាវ័ក នៃតថាគត មានផលច្រើន ទានដែលបុគ្គលឲ្យដល់ពួកសាវ័ករបស់គ្រូដទៃ មិនមានផលច្រើនទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកជនណានិយាយយ៉ាងនេះថា ព្រះសមណគោតម ត្រាស់យ៉ាងនេះថា បុគ្គលគួរឲ្យទានដល់តថាគតតែមួយយ៉ាង មិនគួរឲ្យទានដល់ពួកជនដទៃឡើយ បុគ្គលគួរឲ្យទានដល់ពួកសាវ័ករបស់តថាគតតែមួយយ៉ាង

នាញ្ញេសំ សាវកានំ ទានំ ទាតព្វំ មយ្ហមេវ ទិន្នំ មហប្ផលំ នាញ្ញេសំ ទិន្នំ មហប្ផលំ មយ្ហមេវ សាវកានំ ទិន្នំ មហប្ផលំ នាញ្ញេសំ សាវកានំ ទិន្នំ មហប្ផលន្តិ ។ កច្ចិ តេ ភោតោ គោតមស្ស វុត្តវាទិនោ ន ច ភវន្តំ គោតមំ អភូតេន អព្ភាចិក្ខន្តិ ធម្មស្ស ចានុធម្មំ ព្យាករោន្តិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហំ ឋានំ អាគច្ឆតិ អនព្ភក្ខាតុកាមា ហិ មយំ ភវន្តំ គោតមន្តិ ។ យេ តេ វច្ឆ ឯវមាហំសុ សមណោ គោតមោ ឯវមាហ មយ្ហមេវ ទានំ ទាតព្វំ ។ បេ ។ នាញ្ញេសំ សាវកានំ ទិន្នំ មហប្ផលន្តិ ន មេ តេ វុត្តវាទិនោ អព្ភាចិក្ខន្តិ ច បន មំ តេ អសតា អភូតេន យោ ខោ វច្ឆ បរំ ទានំ ទទន្តំ វារេតិ សោ តិណ្ណំ អន្តរាយករោ ហោតិ តិណ្ណំ បារិបន្ថិកោ ។

មិនគួរឲ្យទានដល់ពួកសាវ័ករបស់ពួកគ្រូដទៃឡើយ ទានដែលបុគ្គលឲ្យដល់តថាគត មានផលច្រើន ទានដែលបុគ្គលឲ្យដល់ពួកជនដទៃ មិនមានផលច្រើនទេ ទានដែលបុគ្គលឲ្យដល់ពួកសាវ័កតថាគត មានផលច្រើន ទានដែលបុគ្គលឲ្យដល់ពួកសាវ័ករបស់ពួកគ្រូដទៃ មិនមានផលច្រើនឡើយ ។ ពួកជនទាំងនោះឈ្មោះថា និយាយតាមពាក្យដែលព្រះគោតមដ៏ចម្រើនពោលហើយ មិននិយាយបង្កាច់ ព្រះគោតមដ៏ចម្រើន ដោយពាក្យមិនពិតទាំងឈ្មោះថាព្យាករ នូវធម៌សមគួរដល់ធម៌ លំនាំនៃពាក្យប្រកបដោយហេតុនីមួយ មិនមកកាន់ឋានៈ ដែលគប្បីតិះដៀលទេឬ ព្រោះយើងមិនមានប្រាថ្នា ដើម្បីនិយាយបង្កាច់ព្រះគោតមដ៏ចម្រើនទេ ។ ម្នាលវច្ឆៈ ពួកជនណា និយាយយ៉ាងនេះថា ព្រះសមណគោតម ត្រាស់យ៉ាងនេះថា បុគ្គលត្រូវឲ្យទានដល់តថាគតតែមួយយ៉ាង ។ បេ ។ ទានដែលបុគ្គលឲ្យដល់ពួកសាវ័ករបស់ពួកគ្រូដទៃ មិនមានផលច្រើនទេ ពួកជនទាំងនោះឈ្មោះថា មិននិយាយតាមពាក្យដែលតថាគតពោលហើយ មួយទៀត ពួកជនទាំងនោះឈ្មោះថា និយាយបង្កាច់តថាគតដោយពាក្យមិនទៀង មិនពិត ម្នាលវច្ឆៈ អ្នកណា ហាមឃាត់បុគ្គលដទៃកំពុងឲ្យទាន អ្នកនោះឈ្មោះថា ធ្វើអន្តរាយដល់ជន ៣ នាក់ ឈ្មោះថា បៀតបៀនដល់ជន ៣ នាក់ ។

កាតមេសំ តិណ្ណំ ។ ជាយកស្ស បុញ្ញន្តរាយករោ ហោតិ បដិគ្គាហកានំ លាភន្តរាយករោ ហោតិ បុព្វេវ ខោ បនស្ស អត្តា ខតោ ច ហោតិ ឧបហតោ ច ។ យោ ខោ វច្ឆ បរំ ទានំ ទទន្តំ វារេតិ សោ ឥមេសំ តិណ្ណំ អន្តរាយករោ ហោតិ តិណ្ណំ ចារិបន្ថិកោ ។ អហំ ខោ បន វច្ឆ ឯវំ វទាមិ យេបិ តេ ចន្ទនិកាយ វា ឱលិគ្គល្លេ វា បាណា តត្របិ យោ ថាលិធោវនំ វា សរាវធោវនំ វា ឆឌ្ឌេតិ យេ តត្ថ បាណា តេ តេន យាបេន្តូតិ តតោនិទានំ អហំ វច្ឆ បុញ្ញស្ស អាគមំ វទាមិ កោ បន វាទោ មនុស្សភូតេ ។ អបិចាហំ វច្ឆ សីលវតោ ទិន្នំ មហប្ផលំ វទាមិ នោ តថា ទុស្សីលេ ។ សោ ច ហោតិ បញ្ចង្គវិប្បហីនោ បញ្ចង្គសមន្នាគតោ ។ កាតមានិ បញ្ចង្គានិ បហីនានិ ហោន្តិ ។ កាមច្ឆន្ទោ បហីនោ ហោតិ ព្យាបាទោ បហីនោ ហោតិ ថីនមិទ្ធំ បហីនំ ហោតិ ឧទ្ធច្ចកុក្កុច្ចំ បហីនំ ហោតិ វិចិកិច្ឆា បហីនា ហោតិ ។

ដល់ជន ៣ នាក់ដូចម្តេច ។ គឺជាអ្នកធ្វើឲ្យអន្តរាយបុណ្យរបស់ទាយក ១ ធ្វើឲ្យអន្តរាយលាភរបស់បដិគ្គាហកៈទាំងឡាយ ១ គាស់រំលើងគុណរបស់ខ្លួនឯង កម្ចាត់គុណរបស់ខ្លួនផង ដែលមានក្នុងកាលមុន ១ ។ ម្នាលវច្ឆៈ អ្នកណាហាមឃាត់បុគ្គលដទៃកំពុងឲ្យទាន អ្នកនោះឈ្មោះថា ធ្វើអន្តរាយដល់ជនទាំង ៣ នាក់នេះ បៀតបៀនដល់ជនទាំង ៣ នាក់នេះ ។ ម្នាលវច្ឆៈ ចំណែកខាងតថាគត ពោលយ៉ាងនេះថា សូម្បីពួកសត្វមានជីវិតណា ដែលនៅក្នុងអណ្តូងស្មោកគ្រោកក្តី រណ្តៅស្មោកគ្រោកក្តី ជនណាចាក់នូវទឹកលាងចានក្តី ទឹកលាងផ្តាំងក្តី ក្នុងទីស្មោកគ្រោកនោះ ដោយគិតថា ពួកសត្វណាមានក្នុងទីស្មោកគ្រោកនោះ សត្វទាំងនោះ ចូរញ៉ាំងជីវិតឲ្យរស់នៅ ដោយកាកអាហារនោះចុះ ម្នាលវច្ឆៈ គ្រាន់តែប៉ុណ្ណឹងទេ តថាគតហៅថា ហេតុជាទីមកនៃបុណ្យ ចាំបាច់ពោលទៅថ្វីដល់ពួកមនុស្ស ។ ម្នាលវច្ឆៈ តថាគតគ្រាន់តែពោលថា ទានដែលឲ្យដល់បុគ្គលមានសីល មានផលច្រើន ដល់បុគ្គលទ្រុស្តសីល មិនដូច្នោះទេ ។ ព្រោះបុគ្គលមានសីលនោះ លះអង្គ ៥ ប្រកបដោយអង្គ ៥ ។ លះអង្គ ៥ ដូចម្តេច ។ គឺជាអ្នកលះកាមច្ឆន្ទៈ ១ លះព្យាបាទៈ ១ លះថីនមិទ្ធៈ ១ លះឧទ្ធច្ចកុក្កុច្ចៈ ១ លះវិចិកិច្ឆា ១ ។

ឥមានិ បញ្ចង្គានិ បហីនានិ ហោន្តិ ។ កតមេហិ បញ្ចង្គេហិ សមន្នាគតោ ហោតិ ។ អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន សមាធិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន បញ្ញាក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិក្ខន្ធេន សមន្នាគតោ ហោតិ អសេក្ខេន វិមុត្តិ-ញាណទស្សនក្ខន្ធេន សមន្នាគតោ ហោតិ ។ ឥមេហិ បញ្ចង្គេហិ សមន្នាគតោ ហោតិ ។ ឥតិ បញ្ចង្គ-វិប្បហីនេ បញ្ចង្គសមន្នាគតេ ទិន្នំ មហប្ផលន្តិ វទាមីតិ ។

ឥតិ កណ្ហាសុ សេតាសុ
រោហិណីសុ ហរីសុ វា
កម្មាសាសុ សរូបាសុ
គោសុ បារេវតាសុ វា
យាសុ កាសុចិ ឯតាសុ
ទន្តោ ជាយតិ បុង្គវោ
ធោរយ្ហោ ពលសម្បន្នោ

នេះឈ្មោះថា លះអង្គ ៥ ។ បុគ្គលប្រកបដោយអង្គ ៥ តើដូចម្តេច ។ គឺជាអ្នកប្រកបដោយសីលក្ខន្ធជាអសេក្ខៈ ១ ប្រកបដោយសមាធិក្ខន្ធជាអសេក្ខៈ ១ ប្រកបដោយបញ្ញាខន្ធជាអសេក្ខៈ ១ ប្រកបដោយវិមុត្តិក្ខន្ធជាអសេក្ខៈ ១ ប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធជាអសេក្ខៈ ១ ។ បុគ្គលប្រកបដោយអង្គទាំង ៥ នេះ ។ តថាគតពោលថា ទានដែលបុគ្គលឲ្យចំពោះបុគ្គលអ្នកលះអង្គ ៥ ប្រកបដោយអង្គ ៥ មានផលច្រើន ដោយប្រការដូច្នេះ ។

គោឈ្មោល កើតក្នុងពួកមេគោណាមួយ ទោះសម្បុរ
ខ្មៅក្តី សក្តី ក្រហមក្តី លឿងក្តី ពព្រុសក្តី មានរូប
រាងស្រដៀងនឹងកូនរាក្តី ប្រផេះក្តី ដែលគេបង្ហាត់
បានបត់ ជាគោសម្រាប់ដឹកនាំ បរិបូណ៌ ដោយកម្លាំង

កល្យាណជវនិក្កមោ
តមេវ ភារេ យុញ្ជន្តិ
នាស្ស វណ្ណំ បរិក្ខរេ
ឯវមេវ មនុស្សេសុ
យស្មឹ កស្មិញ្ចិ ជាតិយំ
ខត្តិយេ ព្រាហ្មណេ វេស្សេ
សុទ្ទេ ចណ្ឌាលបុក្កុសេ
យាសុ កាសុចិ ឯតាសុ
ទន្តោ ជាយតិ សុព្វតោ
ធម្មដ្ឋោ សីលសម្បន្នោ
សច្ចវាទី ហិរីមនោ
បហីនជាតិមរណោ
ព្រហ្មចរិយស្ស កេវលី
បន្នភារោ វិសំយុត្តោ
កតកិច្ចោ អនាសវោ
បារគូ សព្វធម្មានំ

ទុតិយបណ្ណាសកព្រាហ្មណវគ្គ

មានសន្ទុះល្អ គេទឹមគោនោះក្នុងរទេះ គេមិនបានគិតគូរដល់ពណ៌សម្បុរនៃគោនោះឡើយ យ៉ាងណាមិញ បុគ្គលល្អ កើតក្នុងត្រកូលណាមួយ ទោះជាក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី វេស្សៈក្តី សុទ្ទៈក្តី ចណ្ឌាលក្តី បុក្កុសៈក្តីដែលបានទូន្មានចិត្ត ឲ្យប្រាសចាកកិលេស ស្ថិតនៅក្នុងធម៌បរិបូណ៌ដោយសីល និយាយពាក្យសច្ចៈមានចិត្តប្រកបដោយហិរិ លះជាតិនិងមរណៈ បរិបូណ៌ដោយព្រហ្មចារ្យ មានភារៈដាក់ចុះហើយ ប្រាសចាករាគៈមានសោឡសកិច្ចធ្វើស្រេចហើយ មិនមានអាសវៈជាអ្នកដល់ត្រើយ[១] នៃធម៌ទាំងអស់[២]

---

១ សំដៅយកត្រើយ ៦ គឺត្រើយគឺអភិញ្ញា ១ បហានៈ ១ ឈាន ១ ភាវនា ១ សច្ឆិកិរិយា ១ សមាបត្តិ ១ ។ ២ សំដៅយកខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ ។ អដ្ឋកថា ។

អនុបាទាយ និព្វុតោ
តស្មឹ វេ វិរជេ ខេត្តេ
វិបុលា ហោតិ ទក្ខិណា ។
ពាលា ច អវិជានន្តា
ទុម្មេធា អស្សុតាវិនោ
ពហិទ្ធា ទេន្តិ ទានានិ
ន ហិ សន្តេ ឧបាសរេ ។
យេ ច សន្តេ ឧបាសេន្តិ
សប្បញ្ញេ ធីរសម្មតេ
សទ្ធា ច នេសំ សុគតេ
មូលជាតា បតិដ្ឋិតា
ទេវលោកញ្ច តេ យន្តិ
កុលេ វា ឥធ ជាយរេ
អនុបុព្វេន និព្វានំ
អធិគច្ឆន្តិ បណ្ឌិតាតិ ។

មិនប្រកាន់មាំ ប្រាសចាកកម្តៅគឺកិលេស ទាន ដែលបុគ្គលឲ្យហើយក្នុងខេត្ត ដែលប្រាសចាក ធូលី មានរាគៈជាដើមនោះឯង ជាទានមានផល ធំទូលាយ ក៏យ៉ាងនោះដែរ ។ ចំណែកខាងពួក បុគ្គលពាល អប្បប្រាជ្ញាមិនបានរៀនសូត្រ មិនស្គាល់ (បុញ្ញក្ខេត្ត) រមែងឲ្យទានខាងក្រៅ (ពុទ្ធសាសនា) មិនដែលចូលទៅជិតពួកសប្បុរស ។ បើពួកបុគ្គល ណាចូលទៅជិតពួកសប្បុរស ជាអ្នកមានប្រាជ្ញា សន្មតថាជាអ្នកប្រាជ្ញ សទ្ធាជាឫសគល់របស់ពួក បុគ្គលនោះ ស្ថិតនៅក្នុងព្រះសុគត បុគ្គលទាំងនោះ រមែងទៅកាន់ទេវលោកឬក៏កើតក្នុងត្រកូល (មាន ត្រកូលក្សត្រិយ៍ជាដើម) នាលោកនេះ ជាពួកបណ្ឌិត សម្រេចនូវព្រះនិព្វានតាមលំដាប់ ។

[៦០] អថខោ តិកណ្ណោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ តិកណ្ណោ ព្រាហ្មណោ ភគវតោ សម្មុខា តេវិជ្ជានំ សុទំ ព្រាហ្មណានំ វណ្ណំ ភាសតិ ឯវម្បិ តេវិជ្ជា ព្រាហ្មណា ឥតិបិ តេវិជ្ជា ព្រាហ្មណាតិ ។ យថាកថំ បន ព្រាហ្មណ ព្រាហ្មណា ព្រាហ្មណំ តេវិជ្ជំ បញ្ញាបេន្តីតិ ។ ឥធ ភោ គោតម ព្រាហ្មណោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគ្គហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុ-បក្កុដ្ឋោ ជាតិវាទេន អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃណ្ដុកេដុភានំ សាក្ខរប្ប-ភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ

[៦០] គ្រានោះឯង តិកណ្ណព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យគួររីករាយនិងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះតិកណ្ណព្រាហ្មណ៍អង្គុយក្នុងទីសមគួរហើយ ក៏និយាយសរសើរព្រាហ្មណ៍ទាំងឡាយ អ្នកបានវិជ្ជា ៣ ចំពោះព្រះភក្ត្រព្រះមានព្រះភាគថា ពួកព្រាហ្មណ៍បានវិជ្ជា ៣ យ៉ាងនេះ ពួកព្រាហ្មណ៍បានវិជ្ជា ៣ ដូច្នេះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ចុះពួកព្រាហ្មណ៍ បញ្ញត្តព្រាហ្មណ៍អ្នកបានវិជ្ជា ៣ ដោយប្រការយ៉ាងណា ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ក្នុងលោកនេះ ជាឧភតោសុជាត (មានជាតិល្អទាំងពីរខាង) គឺអំពីមាតាផង អំពីបិតាផង កើតអំពីផ្ទៃដ៏បរិសុទ្ធស្អាត ដែលបុគ្គលមិនរង្កៀស មិនតិះដៀលដោយពោលអំពីជាតិបរិសុទ្ធស្អាត ដែលបុគ្គលមិនរង្កៀស មិនតិះដៀលដោយពោលអំពីជាតិបានដរាបអំពីជួរជីតាគម្រប់ ៧ ជាអ្នករាយមន្ត ចេះចាំមន្ត ជាអ្នកដល់ត្រើយនៃត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុនិងកេដុភៈព្រមទាំងអក្ខរប្បភេទ គឺសិក្ខានិងនិរុត្តិ មានគម្ពីរឥតិហាសៈជាគម្រប់ ៥ ជាអ្នក ចេះបទនិងវេយ្យាករណ៍

លោកាយតមហាបុរិសលក្ខណេសុ អនវយោតិ ។ ឯវំ ខោ ភោ គោតម ព្រាហ្មណា ព្រាហ្មណំ តេវិជ្ជំ បញ្ញាបេន្តីតិ ។ អញ្ញថា ខោ ព្រាហ្មណ ព្រាហ្មណា ព្រាហ្មណំ តេវិជ្ជំ បញ្ញាបេន្តិ អញ្ញថា ច បន អរិយស្ស វិនយេ តេវិជ្ជោ ហោតីតិ ។ យថាកថំ បន ភោ គោតម អរិយស្ស វិនយេ តេវិជ្ជោ ហោតិ សាធុ មេ ភវំ គោតមោ តថា ធម្មំ ទេសេតុ យថា អរិយស្ស វិនយេ តេវិជ្ជោ ហោតីតិ ។ តេនហិ ព្រាហ្មណ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ តិកណ្ណោ ព្រាហ្មណោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច ឥធ ព្រាហ្មណ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្ប-សាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ

ជាអ្នកមិនឱនថយគឺស្ទាត់ជំនាញ ក្នុងលោកាយតសាស្ត្រនិងមហាបុរិស-លក្ខណសាស្ត្រ ។ បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍បញ្ញត្ត ព្រាហ្មណ៍អ្នកបានវិជ្ជា ៣ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ ពួកព្រាហ្មណ៍បញ្ញត្តព្រាហ្មណ៍អ្នកបានវិជ្ជា ៣ ដោយឡែក ឯវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈដោយឡែក ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈ តើដូចម្ដេច វិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈយ៉ាងណា សូមព្រះគោតមដ៏ចម្រើន មេត្តាសម្ដែងធម៌យ៉ាងនោះដល់ខ្ញុំព្រះអង្គ ។ ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូរប្រុងស្ដាប់ ប្រុងធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្ដែង ។ តិកណ្ណព្រាហ្មណ៍ទទួលស្ដាប់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈ មានបីតិនិងសុខកើតអំពីវិវេក សម្រេចសម្រាន្តនៅ ព្រោះស្ងប់វិតក្កៈវិចារៈក៏ចូលដល់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្ដីជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈវិចារៈ

សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញាណាយ ចិត្តំ អភិនិន្នាមេតិ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ

មានតែបីតិនិងសុខកើតអំពីសមាធិ សម្រេចសម្រាន្តនៅ ព្រោះប្រាសចាក បីតិផង ជាអ្នកព្រងើយកន្តើយ មានសតិសម្បជញ្ញៈផង ទទួលសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលដែលបានតតិយជ្ឈាននោះថាប្រកបដោយឧបេក្ខាមានស្មារតី មានកិរិយានៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា ក៏ចូលកាន់តតិយជ្ឈាននោះសម្រេចសម្រាន្តនៅ ព្រោះលះបង់សុខផង លះបង់ទុក្ខផង អស់សោមនស្សទោមនស្ស ក្នុងកាលមុនផង ក៏ចូលកាន់ចតុត្ថជ្ឈាន មានអារម្មណ៍មិនជាទុក្ខ មិនជាសុខ មានសតិដ៏បរិសុទ្ធដោយឧបេក្ខាសម្រេចសម្រាន្តនៅ ។ កាលបើចិត្ត តាំងខ្ជាប់ខ្ជួន បរិសុទ្ធស្អាត មិនមានកិលេសប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តមិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះរឭកឃើញនូវខន្ធ ដែលសត្វអាស្រ័យនៅក្នុងកាលមុនជាច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ

វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ អយមស្ស បឋមា វិជ្ជា អធិគតា ហោតិ អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។

២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១០០០ ជាតិខ្លះ ១០០.០០០ ជាតិខ្លះ រឭកអស់សំវដ្តកប្បជាច្រើន វិវដ្តកប្បជាច្រើន សំវដ្តវិវដ្តកប្បជាច្រើនក៏បានថា អាត្មាអញបានកើត ក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញនោះ ច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងភពឯណោះ ដែលកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ អាត្មាអញនោះ លុះច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងភពនេះ ភិក្ខុនោះរឭកបាននូវខន្ធដែលខ្លួននៅ ក្នុងកាលមុនជាច្រើនប្រការព្រមទាំងអាការៈ គឺសម្បុរនិងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះនិងគោត្រដោយប្រការដូច្នេះ ។ នេះជាវិជ្ជាទី ១ ដែលភិក្ខុនោះបានសម្រេចហើយ អវិជ្ជាក៏បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើង (ជាផល) សមគួរដល់ភិក្ខុមិនមានសេចក្តីប្រមាទ មានសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន ។

១៩៧



សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតុបក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្ត-មានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ។ ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន

កាលបើចិត្ត តាំងខ្ជាប់ខ្ជួន បរិសុទ្ធស្អាត មិនមានកិលេស ប្រាសចាក ឧបក្កិលេស ជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តមិនញាប់ញ័រយ៉ាង នេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅ ដើម្បីសត្តានំ ចុតូបបាតញ្ញាណ ភិក្ខុនោះ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងចក្ខុជារបស់មនុស្សធម្មតា រមែងឃើញពួកសត្វដែលកំពុងច្យុត ដែលកំពុងកើត ដឹងច្បាស់នូវពួក សត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មាន គតិអាក្រក់ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ ពួកសត្វនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយៈទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់អំពើមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក អើហ្ន៎ ឯពួកសត្វទាំងអម្បាលនេះ បានប្រកបដោយកាយ-សុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនតិះដៀល ព្រះអរិយៈទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់អំពើជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ភិក្ខុនោះ មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងចក្ខុរបស់មនុស្សធម្មតា

១៩៨



សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មុបគេ សត្តេ បជានាតិ ។ អយមស្ស ទុតិយា វិជ្ជា អធិគតា ហោតិ អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតុបក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។

រមែងឃើញពួកសត្វ ដែលច្យុត ដែលកើត ក៏ដឹងច្បាស់នូវពួកសត្វ ថោកទាបឧត្តម មានសម្បុរល្អ សម្បុរអាក្រក់ មានគតិល្អ គតិអាក្រក់ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនដោយប្រការដូច្នេះ ។ នេះជាវិជ្ជាទី ២ ដែលភិក្ខុនោះបានសម្រេចហើយ អវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើង (ជាផល) សមគួរដល់ភិក្ខុអ្នកមិនប្រមាទ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន ។ កាលបើចិត្ត តាំងខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តមិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ ភិក្ខុនោះដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាបដិបទានាំឲ្យបានដល់នូវសេចក្តីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាអាសវៈទាំងឡាយ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះជាសេចក្តីរលត់អាសវៈ ដឹងច្បាស់តាមពិតថា នេះជាបដិបទានាំឲ្យដល់នូវសេចក្តីរលត់អាសវៈ ។

តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ អយមស្ស តតិយា វិជ្ជា អធិគតា ហោតិ អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោតិ ។

អនុច្ចាវចសីលស្ស
និបកស្ស ច ឈាយិនោ
ចិត្តំ យស្ស វសីភូតំ
ឯកគ្គំ សុសមាហិតំ
តំ វេ តមោនុទំ ធីរំ
តេវិជ្ជំ មច្ចុហាយិនំ
ហិតំ ទេវមនុស្សានំ
អាហុ សព្វប្បហាយិនំ
តីហិ វិជ្ជាហិ សម្បន្នំ
អសម្មូឡ្ហវិហារិនំ

កាលភិក្ខុនោះដឹងយ៉ាងនេះឃើញយ៉ាងនេះ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតស្រឡះចាកភវាសវៈផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈផង កាលបើចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញ បានប្រព្រឹត្តស្រេចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ នេះជាវិជ្ជាទី ៣ ដែលភិក្ខុនោះ បានសម្រេចហើយ អវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើង (ជាផល) សមគួរដល់ភិក្ខុអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន ។

ចិត្តរបស់បុគ្គលណា មានសីលមិនខ្ពស់ទាប មានប្រាជ្ញាចាស់ក្លា អ្នកដុតកម្តៅកិលេស ជាចិត្តជំស្ទាត់មានអារម្មណ៍តែមួយតាំងខ្ជាប់ខ្ជួន (ដោយអារម្មណ៍) ពួកអ្នកប្រាជ្ញហៅបុគ្គលនោះ ថាជាអ្នកបន្ទោបង់នូវងងឹត ជាអ្នកប្រាជ្ញបានវិជ្ជា ៣ លះបង់មច្ចុ ជាប្រយោជន៍ដល់ទេវតានិងមនុស្ស លះបង់នូវបាបធម៌ទាំងអស់ បរិបូណ៌ដោយវិជ្ជា ៣ មានកិរិយានៅដោយសេចក្តីមិនភាន់ច្រឡំ

ពុទ្ធំ អន្តិមសារីរំ[១]
តំ នមស្សន្តិ គោតមំ ។
បុព្វេនិវាសំ យោ វេទី
សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ
អភិញ្ញាវោសិតោ មុនិ
ឯតាហិ តីហិ វិជ្ជាហិ
តេវិជ្ជោ ហោតិ ព្រាហ្មណោ
តមហំ វទាមិ តេវិជ្ជំ
នាញ្ញំ លបិតលាបនន្តិ ។

ឯវំ ខោ ព្រាហ្មណ អរិយស្ស វិនយេ តេវិជ្ជោ ហោតីតិ ។ អញ្ញថា ភោ គោតម ព្រាហ្មណានំ តេវិជ្ជោ អញ្ញថា ច បន អរិយស្ស វិនយេ តេវិជ្ជោ ហោតិ ឥមស្ស ច ភោ គោតម អរិយស្ស វិនយេ តេវិជ្ជស្ស ព្រាហ្មណានំ តេវិជ្ជោ កលំ នាគ្ឃតិ សោឡសឹ ។ អភិក្កន្តំ ភោ គោតម ។ បេ ។ ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុ-បេតំ សរណំ គតន្តិ ។

១ ម. អន្តិមទេហីនំ ។

ចាក់ធ្លុះនូវសច្ចៈទាំង ៤ ទ្រទ្រង់នូវសរីរៈមានក្នុងទីបំផុត ពួកទេវតានិងមនុស្សតែងនមស្ការព្រះគោតម នោះ ។ បុគ្គលណាដឹងនូវបុព្វេនិវាស ឃើញនូវសួគ៌និងអបាយមួយទៀត ជាខីណាសវមុនិ ដល់នូវការអស់ទៅនៃជាតិដឹងហើយ បានសម្រេចសម្រាន្តនៅដោយទីបំផុតនៃកិច្ចបានវិជ្ជា ៣ ដោយវិជ្ជា ៣ នុ៎ះ តថាគតហៅបុគ្គលអ្នកបានវិជ្ជា ៣ នោះ ថាជាព្រាហ្មណ៍ មិនមែនហៅបុគ្គលដទៃតាមពាក្យដែលគេធ្លាប់ហៅឡើយ ។

ម្នាលព្រាហ្មណ៍ វិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈយ៉ាងនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន វិជ្ជា ៣ របស់ព្រាហ្មណ៍ទាំងឡាយ ដោយឡែកវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈដោយឡែក បពិត្រព្រះគោតមដ៏ចម្រើន តែថាវិជ្ជា ៣ របស់ព្រាហ្មណ៍ទាំងឡាយ មិនដល់នូវចំណែកទី ១៦។ ដងនៃវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈទេ ។ បពិត្រព្រះគោតមដ៏ចម្រើនភ្លឺច្បាស់ណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់សរណគមន៍ស្មើដោយជីវិតតាំងពីថ្ងៃនេះជាដើមទៅ ។

១៦១



[៦១] អថខោ ជានុស្សោណី ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ ជានុស្សោណី ព្រាហ្មណោ ភគវន្តំ ឯតទវោច យស្សស្សុ ភោ គោតម យញ្ញោ វា សទ្ធំ វា ថាលិបាកោ វា ទេយ្យធម្មំ វា តេវិជ្ជេសុ ព្រាហ្មណេសុ ទានំ ទទេយ្យាតិ ។ យថាកថំ បន ព្រាហ្មណា ព្រាហ្មណា ព្រាហ្មណំ តេវិជ្ជំ បញ្ញាបេន្តីតិ ។ ឥធ ភោ គោតម ព្រាហ្មណោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោតិ ។

[៦១] គ្រានោះឯង ជានុស្សោណិព្រាហ្មណ៍ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ បេ ។ លុះជានុស្សោណិព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន គ្រឿងបូជាក្តី មតកភត្តដែលឲ្យដោយសទ្ធាក្តី អាហារជាសម្រាប់ដែលគប្បីឲ្យដល់បុគ្គលដទៃក្តី ទេយ្យធម៌គឺវត្ថុក្រៅពីនោះក្តី របស់បុគ្គលណា បុគ្គលនោះគួរឲ្យទាន ចំពោះព្រាហ្មណ៍ទាំងឡាយ អ្នកបានវិជ្ជា ៣ ដែរឬទេ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ចុះពួកព្រាហ្មណ៍បញ្ញត្ត ព្រាហ្មណ៍អ្នកមានវិជ្ជា ៣ ដោយប្រការយ៉ាងណា ។ បពិត្រព្រះគោតមដ៏ចម្រើន ព្រាហ្មណ៍ក្នុងលោកនេះជាឧភតោសុជាត (មានជាតិល្អទាំងពីរខាង) គឺខាងមាតានិងខាងបិតា កើតអំពីគភ៌ដ៏បរិសុទ្ធ មិនមានបុគ្គលរង្កៀស មិនមានគេតិះដៀលដោយពោលអំពីជាតិកំណើតបានដរាបអំពីជួរនៃជីតាគម្រប់ ៧ ស្វាធ្យាយទ្រទ្រង់នូវមន្ត ដល់ត្រើយនៃត្រៃវេទព្រមទាំងគម្ពីរនិឃណ្ឌុ និងកេដុភៈ ព្រមទាំងអក្ខរប្បភេទ គឺសិក្ខានិងនិរុត្តិដែលមានគម្ពីរឈ្មោះឥតិហាសៈជាគម្រប់ ៥ ជាអ្នកចេះបទនិងវេយ្យាករណ៍ ជាអ្នកស្ទាត់ជំនាញ ក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណៈ ។

ឯវំ ខោ ភោ គោតម ព្រាហ្មណា ព្រាហ្មណំ តេវិជ្ជំ បញ្ញាបេន្តីតិ ។ អញ្ញថា ខោ ព្រាហ្មណា ព្រាហ្មណា ព្រាហ្មណំ តេវិជ្ជំ បញ្ញាបេន្តិ អញ្ញថា ច បន អរិយស្ស វិនយេ តេវិជ្ជោ ហោតីតិ ។ យថាកថំ បន ភោ គោតម អរិយស្ស វិនយេ តេវិជ្ជោ ហោតិ សាធុ មេ ភវំ គោតមោ តថា ធម្មំ ទេសេតុ យថា អរិយស្ស វិនយេ តេវិជ្ជោ ហោតីតិ ។ តេនហិ ព្រាហ្មណា សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ ជាណុស្សោណិ ព្រាហ្មណោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច ឥធ ព្រាហ្មណា ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតុ-បក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ បេ ។

បពិត្រព្រះគោតមដ៏ចម្រើន ពួកព្រាហ្មណ៍ បញ្ញត្តព្រាហ្មណ៍អ្នកបានវិជ្ជា ៣ យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ ពួកព្រាហ្មណ៍ បញ្ញត្តព្រាហ្មណ៍អ្នកបានវិជ្ជា ៣ ដោយឡែក ឯវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈដោយឡែក ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈតើដូចម្តេច វិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈយ៉ាងណា សូមព្រះគោតមដ៏ចម្រើន មេត្តាប្រោសសម្តែងធម៌ដល់ខ្ញុំព្រះអង្គយ៉ាងនោះ ។ ម្នាលព្រាហ្មណ៍ បើដូច្នោះអ្នកចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ជានុស្សោណិព្រាហ្មណ៍ ទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលព្រាហ្មណ៍ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ក៏ចូលចតុត្ថជ្ឈាន ។ កាលបើចិត្ត តាំងខ្ជាប់ខ្ជួន បរិសុទ្ធស្អាត ឥតមានកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះរឭកឃើញនូវបុព្វេនិវាសច្រើនប្រការ ។ បេ ។

១៦៣



អយមស្ស បឋមា វិជ្ជា អធិគតា ហោតិ អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិ-តត្តស្ស វិហរតោ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតុបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ។ បេ ។ អយមស្ស ទុតិយា វិជ្ជា អធិគតា ហោតិ អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ ។ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតុបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ

នេះជាវិជ្ជាទី ១ ដែលភិក្ខុនោះបានសម្រេចហើយ អវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើង (ជាផល) សមគួរដល់ភិក្ខុអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន ។ កាលបើចិត្តតាំងខ្ជាប់ បរិសុទ្ធស្អាត ឥតមានកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះក៏បង្អោនចិត្តទៅ ដើម្បីសត្តានំ ចុតូបបាតញ្ញាណ ភិក្ខុនោះមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតា ឃើញពួកសត្វ ។ បេ ។ នេះជាវិជ្ជាទី ២ ដែលភិក្ខុនោះបានសម្រេចហើយ អវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើង (ជាផល) សមគួរដល់ភិក្ខុអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន ។ កាលបើចិត្ត តាំងខ្ជាប់ខ្ជួន បរិសុទ្ធស្អាត ឥតមានកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ ភិក្ខុនោះ ក៏បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ

១៦៤



សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ ឥមេ អាសវាតិ យថាភូតំ បជានាតិ ។ បេ ។ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ អយមស្ស តតិយា វិជ្ជា អធិគតា ហោតិ អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោតិ ។

ភិក្ខុនោះដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមពិតថា នេះជាបដិបទានាំឲ្យដល់សេចក្តីរលត់ទុក្ខ ។ ដឹងច្បាស់តាមពិតថា ទាំងអស់នេះជាអាសវៈ ។ បេ ។ ដឹងច្បាស់តាមពិតថា នេះជាបដិបទានាំឲ្យបានដល់សេចក្តីរលត់អាសវៈ ។ កាលភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តក៏រួចស្រឡះ ចាកកាមាសវៈផង ចិត្តក៏រួចស្រឡះ ចាកភវាសវៈផង ចិត្តក៏រួចស្រឡះ ចាកអវិជ្ជាសវៈផង កាលចិត្តរួចស្រឡះហើយ ញាណកើតឡើងថា ចិត្តរួចស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបានប្រព្រឹត្តស្រេចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ នេះជាវិជ្ជាទី ៣ ដែលភិក្ខុនោះបានសម្រេចហើយ អវិជ្ជាបាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតបាត់ទៅ ពន្លឺក៏កើតឡើង (ជាផល) សមគួរដល់ភិក្ខុអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន ។

យោ សីលព្វតសម្បន្នោ
បហិតត្តោ សមាហិតោ
ចិត្តំ យស្ស វសីភូតំ
ឯកគ្គំ សុសមាហិតំ
បុព្វេនិវាសំ យោ វេទិ
សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ
អភិញ្ញាវោសិតោ មុនិ
ឯតាហិ តីហិ វិជ្ជាហិ
តេវិជ្ជោ ហោតិ ព្រាហ្មណោ
តមហំ វទាមិ តេវិជ្ជំ
នាញ្ញំ លបិតលាបនន្តិ ។

ឯវំ ខោ ព្រាហ្មណ អរិយស្ស វិនយេ តេវិជ្ជោ ហោតីតិ ។ អញ្ញថា ភោ គោតម ព្រាហ្មណានំ តេវិជ្ជោ អញ្ញថា ច បន អរិយស្ស វិនយេ តេវិជ្ជោ ហោតិ ឥមស្ស ច ភោ គោតម អរិយស្ស វិនយេ តេវិជ្ជស្ស ព្រាហ្មណានំ តេវិជ្ជោ កលំ នាគ្ឃតិ សោឡសឹ ។ អភិក្កន្តំ ភោ គោតម ។ បេ ។

បុគ្គលណា បរិបូណ៌ដោយសីលនិងវ័ត មានចិត្តបញ្ជូនទៅរក
ព្រះនិព្វាន មានចិត្តតម្កល់មាំ ចិត្តរបស់បុគ្គលណា ស្ទាត់
ប្រសើរឯក ខ្ជាប់ខ្ជួនប្រពៃ បុគ្គលណាដឹងនូវបុព្វេនិវាសផង
ឃើញនូវសួគ៌និងអបាយផង មួយទៀត ដល់នូវការអស់ទៅ
នៃជាតិ បានដឹងច្បាស់ហើយ សម្រេចសម្រាន្តនៅដោយ
ទីបំផុតនៃកិច្ច ជាខីណាសវមុនិ អ្នកបានវិជ្ជា ៣ ដោយវិជ្ជា
៣ នុ៎ះ តថាគតហៅបុគ្គល អ្នកបានវិជ្ជា ៣ នោះ ថាជា
ព្រាហ្មណ៍ មិនហៅបុគ្គលដទៃតាមពាក្យ ដែលគេធ្លាប់ពោល
ឡើយ ។

ម្នាលព្រាហ្មណ៍ វិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈ យ៉ាងនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន វិជ្ជា ៣ របស់ពួកព្រាហ្មណ៍ដោយឡែក ឯវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈដោយឡែក បពិត្រព្រះគោតមដ៏ចម្រើន វិជ្ជា ៣ របស់ពួកព្រាហ្មណ៍ មិនដល់នូវចំណែកទី ១៦ ៗ ដង នៃវិជ្ជា ៣ ក្នុងវិន័យរបស់អរិយៈនេះទេ ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ ។ បេ ។

ឧចាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ ចាណុបេតំ សរណំ គតន្តិ ។

[៦២] អថខោ សង្គារវោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សង្គារវោ ព្រាហ្មណោ ភគវន្តំ ឯតទវោច មយមស្សុ ភោ គោតម ព្រាហ្មណា នាម យញ្ញំ យជាមបិ យជា-បេមបិ តត្រ ភោ គោតម យោ ចេវ យញ្ញំ យជតិ យោ ច យជាបេតិ សព្វេ តេ អនេកសារីរិកំ បុញ្ញប្បដិបទំ បដិបន្នា ហោន្តិ យទិទំ យញ្ញាធិករណំ យោ បនាយំ ភោ គោតម យស្ស វា តស្ស វា កុលា អគារស្មា អនគារិយំ បព្វជិតោ ឯកមត្តានំ ទមេតិ ឯកមត្តានំ សមេតិ ឯកមត្តានំ បរិនិព្វាបេតិ ឯវមស្សាយំ ឯកសារីរិកា បុញ្ញប្បដិបទា ហោតិ

សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់នូវសរណៈ ស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមតទៅ ។

[៦២] គ្រានោះឯង សង្គារវព្រាហ្មណ៍ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យគួររឭកហើយក៏អង្គុយក្នុងទីសមគួរ ។ លុះសង្គារវព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន យើងទាំងឡាយឈ្មោះថាជាព្រាហ្មណ៍ បូជានូវយញ្ញខ្លួនឯងខ្លះ ប្រើគេឲ្យបូជាខ្លះ បពិត្រព្រះគោតមដ៏ចម្រើន ក្នុងដំណើរនោះ ព្រាហ្មណ៍ណា បូជាយញ្ញដោយខ្លួនឯងផង ព្រាហ្មណ៍ណា ប្រើគេឲ្យបូជាផង ព្រាហ្មណ៍ទាំងអស់នោះ ឈ្មោះថាប្រតិបត្តិនូវសេចក្តីប្រតិប័ទជាហេតុឲ្យកើតបុណ្យដែលប្រព្រឹត្តទៅ ក្នុងសរីរៈដ៏ច្រើន ព្រោះហេតុតែការបូជានេះ បពិត្រព្រះគោតមដ៏ចម្រើន ចំណែកខាងបុគ្គលណា ចេញចាកត្រកូលណាក្តី ចេញចាកផ្ទះណាក្តី ហើយបួសក្នុងសំណាក់បុគ្គលមិនមានផ្ទះ ក៏ទូន្មានចំពោះខ្លួនមួយៗ រម្ងាប់ចំពោះខ្លួនមួយៗ រំលត់ទុក្ខចំពោះខ្លួនមួយៗ បុញ្ញប្បដិបទានេះប្រព្រឹត្តទៅក្នុងសរីរៈតែមួយ រមែងមានដល់បុគ្គលនោះយ៉ាងនេះ

១៦៧



យទិទំ បព្វជ្ជាធិករណន្តិ ។ តេនហិ ព្រាហ្មណ តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ ។ តំ កឹ មញ្ញសិ ព្រាហ្មណ ឥធ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឯវមាហ ឯថាយំ មគ្គោ អយំ បដិបទា យថា បដិបន្នោ អហំ អនុត្តរំ ព្រហ្មចរិយោគធំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេមិ ឯថ តុម្ហេបិ តថា បដិបជ្ជថ យថា បដិបន្នា តុម្ហេបិ អនុត្តរំ ព្រហ្មចរិយោគធំ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរិស្សថាតិ ។ ឥតិ អយំ ចេវ សត្ថា ធម្មំ ទេសេតិ បរេ ច តថត្ថាយ បដិបជ្ជន្តិ ។

ព្រោះហេតុតែបញ្ហានេះ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ តថាគតនឹងត្រឡប់សួរដំណើរនោះ ចំពោះអ្នកវិញ អ្នកគាប់ចិត្តយ៉ាងណា គប្បីដោះស្រាយប្រស្នានោះ យ៉ាងនោះចុះ ។ ម្នាលព្រាហ្មណ៍ អ្នកសម្គាល់សេចក្ដីនោះ ដូចម្ដេច ព្រះតថាគត កើតឡើង ក្នុងលោកនេះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ មានដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក មិនមានបុគ្គលដទៃប្រសើរជាង ជាសារថីទូន្មាននូវបុរស ដែលគួរទូន្មានបាន ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវអរិយសច្ចទាំង ៤ លែងវិលមកកាន់ភពថ្មីទៀត ព្រះតថាគតនោះ ពោលយ៉ាងនេះថា នេះជាផ្លូវ នេះជាបដិបទា ក្នុងដំណើរនោះ ដូចតថាគតប្រតិបត្តិ បានធ្វើឲ្យជាក់ច្បាស់ នូវការចុះស៊ប់កាន់ព្រហ្មចរិយៈដ៏ប្រសើរ ដោយប្រាជ្ញាដ៏ឧត្តមខ្លួនឯង ទើបប្រកាសប្រាប់ (សត្វដទៃ) ថា អើអ្នកទាំងឡាយ ចូរមក អ្នកទាំងឡាយ ចូរប្រតិបត្តិធ្វើឲ្យជាក់ច្បាស់នូវការចុះស៊ប់កាន់ព្រហ្មចរិយៈដ៏ប្រសើរ ដោយប្រាជ្ញាខ្លួនឯង សម្រេចសម្រាន្តនៅយ៉ាងណា អ្នកទាំងឡាយ ចូរប្រតិបត្តិយ៉ាងនោះចុះ ។ ព្រះសាស្ដានេះ តែងសម្ដែងធម៌ផង ពួកជនដទៃប្រតិបត្តិតាមបែបនោះផង ដោយប្រការដូច្នេះ ។

តានិ ខោ បន ហោន្តិ អនេកានិបិ សតានិ អនេកានិបិ សហស្សានិ អនេកានិបិ សតសហស្សានិ ។ តំ កឹ មញ្ញសិ ព្រាហ្មណ ឥច្ចាយំ ឯវំ សន្តេ ឯកសារីរិកា វា បុញ្ញប្បដិបទា ហោតិ អនេកសារីរិកា វា យទិទំ បព្វជ្ជាធិករណន្តិ ។ ឥច្ចាយំបិ ភោ គោតម ឯវំ សន្តេ អនេកសារីរិកា បុញ្ញប្បដិបទា ហោតិ យទិទំ បព្វជ្ជាធិករណន្តិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ សង្គារវំ ព្រាហ្មណំ ឯតទវោច ឥមាសំ តេ ព្រាហ្មណ ទ្វិន្នំ បដិបទានំ កតមា បដិបទា ខមតិ អប្បត្ថតរា[១] ច អប្បសមារម្ភតរា ច មហប្ផលតរា ច មហានិសំសតរា ចាតិ ។ ឯវំ វុត្តេ សង្គារវោ ព្រាហ្មណោ អាយស្មន្តំ អានន្ទំ ឯតទវោច សេយ្យថាបិ ភវំ គោតមោ ភវញ្ចានន្ទោ ឯតេ មេ បុជ្ជា ឯតេ មេ បាសំសាតិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ សង្គារវំ ព្រាហ្មណំ ឯតទវោច

១ អប្បដ្ឋតរាតិប្បត្តិ ។

ការប្រមាណនៃសត្វទាំងឡាយនោះ មានរយដ៏ច្រើនផង មានពាន់ដ៏ច្រើនផង មានសែនដ៏ច្រើនផង ម្នាលព្រាហ្មណ៍ អ្នកសម្គាល់សេចក្តីនោះដូចម្តេច កាលបើហេតុមានយ៉ាងនេះ បុញ្ញប្បដិបទានេះឈ្មោះថា ប្រព្រឹត្តទៅក្នុងសរីរៈតែមួយ ឬប្រព្រឹត្តទៅ ក្នុងសរីរៈដ៏ច្រើន ព្រោះហេតុតែបព្វជ្ជាដោយប្រការដូច្នេះ ។ បពិត្រព្រះគោតមដ៏ចម្រើន កាលបើហេតុមានយ៉ាងនេះ បុញ្ញប្បដិបទានេះ ឈ្មោះថាប្រព្រឹត្តទៅក្នុងសរីរៈដ៏ច្រើន ព្រោះហេតុតែបព្វជ្ជានេះដូច្នេះ ។ កាលបើព្រាហ្មណ៍និយាយយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ បាននិយាយនឹងសង្គារវ-ព្រាហ្មណ៍ដូច្នេះថា ម្នាលព្រាហ្មណ៍ បណ្តាបដិបទាទាំង ២ នេះ អ្នកគាប់ចិត្តបដិបទាណា ថា មានសេចក្តីត្រូវការតិចផង មានការរៀបចំតិចផង មានផលច្រើនផង មានអានិសង្សច្រើនផង ។ កាលបើព្រះអានន្ទ និយាយយ៉ាងនេះហើយ សង្គារវព្រាហ្មណ៍ បាននិយាយនឹងព្រះអានន្ទមានអាយុដូច្នេះថា បុគ្គលដូចជាព្រះគោតមដ៏ចម្រើន និងព្រះអានន្ទដ៏ចម្រើនទាំងនេះ ខ្ញុំត្រូវបូជា ខ្ញុំត្រូវសរសើរ ។ ព្រះអានន្ទមានអាយុ បាននិយាយនឹងសង្គារវព្រាហ្មណ៍ជាគម្រប់ ២ ដងដូច្នេះថា

១៦៩



ង ខោ ត្យាហំ ព្រាហ្មណា ឯវំ បុច្ឆាមិ កោ វា តេ បុជ្ជា កោ វា តេ ចាសំសាតិ ។ ឯវញ្ច ខោ ត្យាហំ ព្រាហ្មណា បុច្ឆាមិ ឥមាសំ តេ ព្រាហ្មណា ទ្វិន្នំ បដិបទានំ កតមា បដិបទា ខមតិ អប្បត្ថតរា ច អប្បសមារម្ភតរា ច មហប្ផលតរា ច មហានិសំសតរា ចាតិ ។ ទុតិយម្បិ ខោ សង្គារវោ ព្រាហ្មណោ អាយស្មន្តំ អានន្ទំ ឯតទវោច សេយ្យថាបិ ភវំ គោតមោ ភវញ្ចានន្ទោ ឯតេ មេ បុជ្ជា ឯតេ មេ ចាសំសាតិ ។ តតិយម្បិ ខោ អាយស្មា អានន្ទោ សង្គារវំ ព្រាហ្មណំ ឯតទវោច ង ខោ ត្យាហំ ព្រាហ្មណា បុច្ឆាមិ កោ វា តេ បុជ្ជា កោ វា តេ ចាសំសាតិ ។ ឯវញ្ច ខោ ត្យាហំ ព្រាហ្មណា បុច្ឆាមិ ឥមាសំ តេ ព្រាហ្មណា ទ្វិន្នំ បដិបទានំ កតមា បដិបទា ខមតិ អប្បត្ថតរា ច អប្បសមារម្ភតរា ច មហប្ផលតរា ច មហានិសំសតរា ចាតិ ។

ម្នាលព្រាហ្មណ៍ អាត្មាមិនសួរអ្នកថា ពួកបុគ្គលដូចម្តេច ដែលអ្នកត្រូវបូជា ឬ ពួកបុគ្គលដូចម្តេច ដែលអ្នកត្រូវសរសើរយ៉ាងនេះទេ ។ ម្នាលព្រាហ្មណ៍ អាត្មាសួរអ្នកយ៉ាងនេះថា ម្នាលព្រាហ្មណ៍ បណ្តាបដិបទាទាំងពីរនេះ អ្នកគាប់ចិត្តបដិបទាណា ថា មានសេចក្តីត្រូវការតិចផង មានការរៀបចំតិចផង មានផលច្រើនផង មានអានិសង្សច្រើនផង ដូច្នេះទេតើ ។ សង្គារវព្រាហ្មណ៍ បាននិយាយនឹងព្រះអានន្ទមានអាយុ ជាគម្រប់ ២ ដងដូច្នេះថា បុគ្គលដូចជាព្រះសមណគោតមដ៏ចម្រើន នឹងព្រះអានន្ទដ៏ចម្រើននេះ ខ្ញុំត្រូវបូជា ខ្ញុំត្រូវសរសើរ ។ ព្រះអានន្ទមានអាយុ បាននិយាយនឹងសង្គារវព្រាហ្មណ៍ជាគម្រប់ ៣ ដងដូច្នេះយ៉ាងនេះថា ម្នាលព្រាហ្មណ៍ អាត្មាមិនសួរអ្នកថា ពួកបុគ្គលដូចម្តេច ដែលអ្នកត្រូវបូជា ឬពួកបុគ្គលដូចម្តេច ដែលអ្នកត្រូវសរសើរទេ ។ ម្នាលព្រាហ្មណ៍ អាត្មាសួរអ្នកយ៉ាងនេះថា ម្នាលព្រាហ្មណ៍ បណ្តាបដិបទាទាំងពីរនេះ អ្នកកាន់បដិបទាណា ថា មានសេចក្តីត្រូវការតិចផង មានការរៀបចំតិចផង មានផលច្រើនផង មានអានិសង្សច្រើនផង ដូច្នេះទេតើ ។

តតិយម្បិ ខោ សង្គារវោ ព្រាហ្មណោ អាយស្មន្តំ អានន្ទំ ឯតទវោច សេយ្យថាបិ ភវំ គោតមោ ភវញ្ចា-នន្ទោ ឯតេ មេ បុជ្ជា ឯតេ មេ ចាសំសាតិ ។ អថខោ ភគវតោ ឯតទហោសិ យាវតតិយម្បិ ខោ សង្គារវោ ព្រាហ្មណោ អានន្ទេន សហធម្មិកំ បញ្ហំ បុដ្ឋោ សំសាទេតិ នោ វិស្សជ្ជេតិ យន្នូនាហំ បរិមោ-ចេយ្យន្តិ ។ អថខោ ភគវា សង្គារវំ ព្រាហ្មណំ ឯត-ទវោច កានុជ្ជ ព្រាហ្មណ រាជន្តេបុរេ រាជបរិសាយំ សន្និសិន្នានំ សន្និបតិតានំ អន្តរាកថា ឧទបាទីតិ ។ អយំ ខ្វជ្ជ ភោ គោតម រាជន្តេបុរេ រាជបរិសាយំ សន្និសិន្នានំ សន្និបតិតានំ អន្តរាកថា ឧទបាទិ បុព្វស្សុទំ អប្បតរា ចេវ ភិក្ខូ អហេសុំ ពហុតរា ច ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយំ ទស្សេសុំ ឯតរហិ ខោ ពហុតរា ចេវ ភិក្ខូ អប្បតរា ច ឧត្តរិមនុស្សធម្មា ឥទ្ធិប្បាដិហារិយំ ទស្សេន្តីតិ ។ អយំ ខ្វជ្ជ ភោ គោតម រាជន្តេបុរេ រាជបរិសាយំ សន្និ-សិន្នានំ សន្និបតិតានំ អន្តរាកថា ឧទបាទីតិ ។

សង្គារវព្រាហ្មណ៍ បាននិយាយនឹងព្រះអានន្ទមានអាយុជាគម្រប់ ៣ ដង ដូច្នេះថាបុគ្គលដូចជាព្រះគោតមដ៏ចម្រើន និងព្រះអានន្ទដ៏ចម្រើននេះ ខ្ញុំត្រូវបូ-ជាខ្ញុំ ត្រូវសរសើរ ។ លំដាប់នោះឯង ព្រះមានព្រះភាគ មានសេចក្តីត្រិះរិះដូច្នេះថា សង្គារវព្រាហ្មណ៍ត្រូវអានន្ទសួរប្រស្នាប្រកបដោយហេតុ ដរាប ៣ ដងហើយ បន្ទប់មិនដោះស្រាយ បើដូច្នោះមានតែតថាគតដោះស្រាយ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់នឹងសង្គារវព្រាហ្មណ៍ដូច្នេះថា ម្នាលព្រាហ្មណ៍ ថ្ងៃនេះអន្តរាកថា (ពាក្យពោលក្នុងចន្លោះឬរវាង) ដូចម្តេចកើតឡើង ដល់ពួកជន ដែលអង្គុយប្រជុំគ្នា ក្នុងរាជបរិសទ្យ ក្នុងខាងក្នុងរាជបុរី ។ បពិត្រព្រះគោតមដ៏ច្រើន ថ្ងៃនេះខាងក្នុងរាជបុរី អន្តរាកថានេះឯង កើតឡើងដល់ពួកជន ដែលអង្គុយប្រជុំគ្នា ក្នុងរាជបរិសទ្យថា បានឮថា កាលពីដើម ពួកភិក្ខុមានប្រមាណតិច តែភិក្ខុអ្នកមានឧត្តរិមនុស្សធម៌ សម្តែងឥទ្ធិប្បាដិហារ្យបាន មានច្រើន ឥឡូវនេះ ពួកភិក្ខុមានច្រើនមែន តែភិក្ខុអ្នកមានឧត្តរិមនុស្សធម៌ សម្តែងឥទ្ធិប្បាដិហារ្យបាន មានប្រមាណតិចវិញ ។ បពិត្រព្រះគោតមដ៏ចម្រើន ថ្ងៃនេះខាងក្នុងរាជបុរី អន្តរាកថានេះកើតឡើង ដល់ពួកជន ដែលអង្គុយប្រជុំគ្នា ក្នុងរាជបរិសទ្យ ។

តីណិ ខោ ឥមានិ ព្រាហ្មណ បាដិហារិយានិ ។ កតមានិ តីណិ ។ ឥទ្ធិប្បាដិហារិយំ អាទេសនាបាដិហារិយំ អនុសាសនីបាដិហារិយំ ។ កតមញ្ច ព្រាហ្មណ ឥទ្ធិប្បាដិហារិយំ ។ ឥធ ព្រាហ្មណ ឯកច្ចោ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ បឋវិយាបិ ឧម្មុជ្ជនិមុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆតិ សេយ្យថាបិ បឋវិយា អាកាសេបិ បល្លង្កេន កមតិ សេយ្យថាបិ បក្ខិសកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសតិ បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។ ឥទំ វុច្ចតិ ព្រាហ្មណ ឥទ្ធិប្បាដិហារិយំ ។ កតមញ្ច ព្រាហ្មណ អាទេសនាបាដិហារិយំ ។ ឥធ ព្រាហ្មណ ឯកច្ចោ និមិត្តេន អាទិសតិ ឯវម្បិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ ។

ម្នាលព្រាហ្មណ៍បាដិហារ្យនេះ មាន ៣ ។ បាដិហារ្យ ៣ ដូចម្ដេច ។ គឺឥទ្ធិប្បាដិហារ្យ ១ អាទេសនាបាដិហារ្យ ១ អនុសាសនីបាដិហារ្យ ១ ។ ម្នាលព្រាហ្មណ៍ ឥទ្ធិប្បាដិហារ្យ តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះក្នុងលោកនេះ បានសម្រេចឫទ្ធិច្រើនប្រការ គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាមនុស្សច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាមនុស្សម្នាក់វិញក៏បាន ដើរទៅមិនជាប់ចំពាក់នឹងទីវាលទីខាងក្រៅ ទីខាងក្រៅជញ្ជាំង ទីខាងក្រៅកំពែង ទីខាងក្រៅភ្នំហាក់ដូចជាដើរទៅ ក្នុងអាកាសក៏បាន ធ្វើនូវការងើបឡើង ឬមុជចុះក្នុងផែនដី ហាក់ដូចជាងើបឡើង ឬមុជចុះក្នុងទឹកក៏បាន ដើរលើទឹកមិនបែកធ្លាយ ហាក់ដូចជា ដើរលើផែនដីក៏បាន ទៅឯអាកាសទាំងភ្នែន ហាក់ដូចសត្វស្លាបក៏បាន យកដៃទៅស្ទាបអង្អែលចាប់ពាល់ព្រះចន្ទព្រះអាទិត្យនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ធ្វើអំណាចឲ្យប្រព្រឹត្តទៅដោយកាយដរាបដល់ព្រហ្មលោក ក៏បាន ។ ម្នាលព្រាហ្មណ៍ នេះហៅថា ឥទ្ធិប្បាដិហារ្យ ។ ម្នាលព្រាហ្មណ៍ អាទេសនាបាដិហារ្យ តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ ទាយ (ចិត្ត) តាមនិមិត្តថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នក ដោយប្រការដូច្នេះខ្លះ ចិត្តអ្នកដូច្នេះខ្លះ ។

សោ ពហុញ្ចេបិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថា ។ ឥធ បន ព្រាហ្មណ ឯកច្ចោ ន ហេវ ខោ និមិត្តេន អាទិសតិ អបិច ខោ មនុស្សានំ វា អមនុស្សានំ វា ទេវតានំ វា សទ្ទំ សុត្វា អាទិសតិ ឯវម្បិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ ។ សោ ពហុញ្ចេបិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថា ។ ឥធ បន ព្រាហ្មណ ឯកច្ចោ ន ហេវ ខោ និមិត្តេន អាទិសតិ នបិ មនុស្សានំ វា អមនុស្សានំ វា ទេវតានំ វា សទ្ទំ សុត្វា អាទិសតិ អបិច ខោ វិតក្កយតោ វិចារយតោ វិតក្កវិចារសទ្ទំ សុត្វា អាទិសតិ ឯវម្បិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ ។ សោ ពហុញ្ចេបិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថា ។ ឥធ បន ព្រាហ្មណ ឯកច្ចោ ន ហេវ ខោ និមិត្តេន អាទិសតិ នបិ មនុស្សានំ វា អមនុស្សានំ វា ទេវតានំ វា សទ្ទំ សុត្វា អាទិសតិ នបិ វិតក្កយតោ វិចារយតោ វិតក្កវិចារសទ្ទំ សុត្វា អាទិសតិ

បុគ្គលនោះ ទោះបីទាយច្រើន ហេតុដែលទាយដូច្នោះនោះ ក៏មិនក្លាត់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ មិនបាច់ទាយចិត្ត តាមនិមិត្តទេ គ្រាន់តែឮសំឡេងពួកមនុស្ស ពួកអមនុស្ស និងពួកទេវតា ហើយក៏ទាយបានថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នកដោយ ប្រការដូច្នេះខ្លះ ចិត្តអ្នកដូច្នេះខ្លះ ។ បុគ្គលនោះ ទោះបីទាយច្រើន ហេតុដែលទាយដូច្នោះនោះ ក៏មិនក្លាត់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបាច់ទាយចិត្តតាមនិមិត្តទេ មិនបាច់ឮ សំឡេងពួកមនុស្ស ពួកអមនុស្ស និងពួកទេវតាហើយទាយទេ គ្រាន់ តែឮសូរវិតក្កៈវិចារៈរបស់បុគ្គល ដែលត្រិះរិះពិចារណា ក៏ទាយបានថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នក ដោយប្រការដូច្នេះខ្លះ គំនិតអ្នកដូច្នេះខ្លះ ។ បុគ្គលនោះ ទោះបីទាយច្រើន ហេតុដែលទាយ ដូច្នោះនោះ ក៏មិនក្លាត់ ។ ម្នាលព្រាហ្មណ៍ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនបាច់ទាយចិត្តតាមនិមិត្តទេ ទាំងមិនបាច់ស្តាប់សំឡេង ពួកមនុស្ស ពួកអមនុស្ស ពួកទេវតា ហើយទាយទេ ទាំងមិនបាច់ស្តាប់ សូរវិតក្កៈវិចារៈ របស់មនុស្សដែលត្រិះរិះ ដែលពិចារណាហើយទាយទេ

អបិច ខោ អវិតក្កំ អវិចារំ សមាធឹ សមាបន្នស្ស ចេតសា ចេតោ បរិច្ច បជានាតិ យថា ឥមស្ស ភោតោ មនោសង្ខារា បណិហិតា ឥមស្ស ចិត្តស្ស អនន្តរា អមុន្នាម វិតក្កំ វិតក្កិស្សតីតិ ។ សោ ពហុញ្ចបិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថា ។ ឥទំ វុច្ចតិ ព្រាហ្មណ អាទេសនាបាដិហារិយំ ។ កតមញ្ច ព្រាហ្មណ អនុសាសនីបាដិហារិយំ ។ ឥធ ព្រាហ្មណ ឯកច្ចោ ឯវំ អនុសាសតិ ឯវំ វិតក្កេថ មា ឯវំ វិតក្កយិត្ថ ឯវំ មនសិករោថ មា ឯវំ មនសាកត្ថ ឥទំ បជហថ ឥទំ ឧបសម្បជ្ជ វិហរថាតិ ។ ឥទំ វុច្ចតិ ព្រាហ្មណ អនុសាសនីបាដិហារិយំ ។ ឥមានិ ខោ ព្រាហ្មណ តីណិ បាដិហារិយានិ ។ ឥមេសំ តេ ព្រាហ្មណ តិណ្ណំ បាដិហារិយានំ កតមំ បាដិហារិយំ ខមតិ អភិក្កន្តតរញ្ច បណីតតរញ្ចាតិ ។ តត្រ ភោ គោតម យមិទំ បាដិហារិយំ ឥធេកច្ចោ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតីតិ

ប៉ុន្តែថា កំណត់ដឹងចិត្តដោយចិត្តនៃបុគ្គលដែលចូលសមាធិ មិនមានវិតក្កៈ មិនមានវិចារៈថា មនោសង្ខារទាំងឡាយ របស់បុគ្គលដ៏ចម្រើននេះ តាំងទុកហើយយ៉ាងណា បុគ្គលដ៏ចម្រើន នឹងត្រិះរិះនូវវិតក្កៈ ឈ្មោះឯណោះ អំពីលំដាប់នៃចិត្តនេះ ។ បុគ្គលនោះ ទោះបីទាយច្រើន ហេតុដែលទាយដូច្នោះនោះ ក៏មិនក្លាត់ ។ ម្នាលព្រាហ្មណ៍ នេះហៅថា អាទេសនាបាដិហារ្យ ។ ម្នាលព្រាហ្មណ៍ ចុះអនុសាសនីបាដិហារ្យ តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ បុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយ ត្រូវត្រិះរិះយ៉ាងនេះ កុំត្រិះរិះយ៉ាងនេះឡើយ ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះ កុំធ្វើទុកក្នុងចិត្តយ៉ាងនេះឡើយ ចូរលះបង់ នូវអំពើនេះចេញ ចូរឱបក្រសោបនូវអំពើនេះចុះ ។ ម្នាលព្រាហ្មណ៍ នេះហៅថា អនុសាសនីបាដិហារ្យ ។ ម្នាលព្រាហ្មណ៍ បាដិហារ្យ មាន ៣ ប្រការនេះឯង ។ ម្នាលព្រាហ្មណ៍ បណ្ដាបាដិហារ្យទាំង ៣ នេះ អ្នកគាប់ចិត្ត បាដិហារ្យណាថា ល្អផង ឧត្តមផង ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្ដាបាដិហារ្យទាំងនោះ បាដិហារ្យដែលបុគ្គលពួកខ្លះ ក្នុងលោកនេះ បានសម្រេចឫទ្ធិច្រើនប្រការ ។បេ។ ធ្វើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយដរាបដល់ព្រហ្មលោក

ឥទំ ភោ គោតម បាដិហារិយំ យោ ច នំ ករោតិ សោ ច នំ បដិសំវេទេតិ យោ ច នំ ករោតិ តស្សេវ តំ ហោតិ ។ ឥទំ មេ ភោ គោតម បាដិហារិយំ មាយាសហធម្មរូបំ វិយ ខាយតិ ។ យម្បិទំ ភោ គោតម បាដិហារិយំ ឥធេកច្ចោ និមិត្តេន អាទិសតិ ឯវម្បិ តេ មនោ ឥត្ថម្បិ តេ មនោ ឥតិបិ តេ ចិត្តន្តិ សោ ពហុញ្ចេបិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថា ។ ឥធ បន ភោ គោតម ឯកច្ចោ ន ហេវ ខោ និមិត្តេន អាទិសតិ អបិច ខោ មនុស្សានំ វា អមនុស្សានំ វា ទេវតានំ វា សទ្ទំ សុត្វា អាទិសតិ... នបិ មនុស្សានំ វា អមនុស្សានំ វា ទេវតានំ វា សទ្ទំ សុត្វា អាទិសតិ អបិច ខោ វិតក្កយតោ វិចារយតោ វិតក្កវិចារសទ្ទំ សុត្វា អាទិសតិ... នបិ វិតក្កយតោ វិចារយតោ វិតក្កវិចារសទ្ទំ សុត្វា អាទិសតិ អបិច ខោ អវិតក្កំ អវិចារំ សមាធឹ សមាបន្នស្ស ចេតសា ចេតោ បរិច្ច បជានាតិ

បពិត្រព្រះគោតមដ៏ចម្រើន បាដិហារ្យនេះ បុគ្គលណាធ្វើបាដិហារ្យនោះ បុគ្គលនោះឯង រមែងបានបាដិហារ្យនោះ បុគ្គលណាធ្វើបាដិហារ្យនោះ បាដិហារ្យនោះ តែងមានដល់បុគ្គលនោះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន បាដិហារ្យនេះ ប្រាកដដល់ខ្ញុំព្រះអង្គ បីដូចរូបភាពប្រកបដោយកលមាយា ។ បពិត្រព្រះគោតមដ៏ចម្រើន បាដិហារ្យណា ដែលបុគ្គលពួកខ្លះ ក្នុងលោកនេះ ទាយចិត្តតាមនិមិត្តបានថា មនោរបស់អ្នកយ៉ាងនេះខ្លះ មនោរបស់អ្នកដោយប្រការដូច្នេះខ្លះ ចិត្តរបស់អ្នកដូច្នេះខ្លះ ។ បុគ្គលនោះ ទោះបីទាយច្រើន ហេតុដែលទាយដូច្នោះនោះ ក៏មិនក្លាត់ ។ បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះ មិនបាច់ទាយចិត្តតាមនិមិត្តទេ គ្រាន់តែឮសំឡេងពួកមនុស្ស ពួកអមនុស្សឬពួកទេវតាហើយទាយបាន... មិនបាច់ ឮសំឡេងពួកមនុស្ស ពួកអមនុស្ស ឬ ពួកទេវតាហើយទាយ គ្រាន់តែឮសូរវិតក្កៈ វិចារៈរបស់បុគ្គលកំពុងត្រិះរិះ កំពុងពិចារណាហើយទាយត្រូវ... មិនបាច់ឮសូរវិតក្កៈ វិចារៈរបស់បុគ្គលកំពុងត្រិះរិះ កំពុងពិចារណាហើយទាយទេ គ្រាន់តែកំណត់ដឹងចិត្តដោយចិត្តរបស់អ្នកបានសមាធិ មិនមានវិតក្កៈ មិនមានវិចារៈថា

យថា ឥមស្ស ភោតោ មនោសង្ខារា បណិហិតា ឥមស្ស ចិត្តស្ស អនន្តរា អមុន្នាម វិតក្កំ វិតក្កិស្សតីតិ ។ សោ ពហុញ្ចេបិ អាទិសតិ តថេវ តំ ហោតិ នោ អញ្ញថាតិ ឥទម្បិ ភោ គោតម បាដិហារិយំ យោ ច នំ ករោតិ សោ ច នំ បដិសំវេទេតិ យោ ច នំ ករោតិ តស្ស ចេវ តំ ហោតិ ឥទម្បិ មេ ភោ គោតម បាដិហារិយំ មាយាសហធម្មរូបំ វិយ ខាយតិ ។ យញ្ច ខោ ឥទំ ភោ គោតម បាដិហារិយំ ឥធេកច្ចោ ឯវំ អនុសាសតិ ឯវំ វិតក្កេថ មា ឯវំ វិតក្កយិត្ថ ឯវំ មនសិករោថ មា ឯវំ មនសាកត្ថ ឥទំ បជហថ ឥទំ ឧបសម្បជ្ជ វិហរថាតិ ។ ឥទំ មេ ភោ គោតម បាដិហារិយំ ខមតិ ឥមេសំ តិណ្ណំ បាដិហារិយានំ អភិក្កន្តតរញ្ច បណីតតរញ្ច ។ អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម យាវ សុភាសិតញ្ចិទំ ភោតា គោតមេន

មនោសង្ខារទាំងឡាយ របស់បុគ្គលដ៏ចម្រើននេះ តាំងទុកយ៉ាងណា បុគ្គលដ៏ចម្រើន នឹងត្រិះរិះនូវវិតក្កៈឈ្មោះឯណោះ តាមលំដាប់នៃចិត្តនេះ ។ បុគ្គលនោះទោះបីទាយច្រើន ហេតុដែលទាយដូច្នោះនោះ ក៏មិនភ្លាត់ បពិត្រព្រះគោតមដ៏ចម្រើន បាដិហារ្យនេះ បុគ្គលណាបានធ្វើបាដិហារ្យនោះ បុគ្គលនោះឯងបាននូវបាដិហារ្យនោះ បុគ្គលណាធ្វើបាដិហារ្យនោះ បាដិហារ្យនោះ រមែងមានដល់បុគ្គលនោះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន បាដិហារ្យនេះប្រាកដដល់ខ្ញុំព្រះអង្គ បីដូចរូបភាពប្រកបដោយកលមាយា ។ បពិត្រព្រះគោតមដ៏ចម្រើន បាដិហារ្យណា ដែលបុគ្គលពួកខ្លះ ក្នុងលោកនេះ ប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយ ចូរត្រិះរិះយ៉ាងនេះ កុំត្រិះរិះយ៉ាងនេះឡើយ ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះ កុំធ្វើទុកក្នុងចិត្តយ៉ាងនេះឡើយ ចូរលះបង់អំពើនេះចេញ ចូរប្រកបអំពើនេះវិញ ។ បពិត្រព្រះគោតមដ៏ចម្រើន បណ្តាបាដិហារ្យទាំង ៣ នេះ ខ្ញុំព្រះអង្គគាប់ចិត្តបាដិហារ្យនេះល្អផង ឧត្តមផង ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចំឡែកណាស់ ពាក្យដែលព្រះគោតមដ៏ចម្រើន ទ្រង់សម្តែងហើយនេះ ថាជាសុភាសិត

ឥមេហិ ច មយំ តីហិ ចាដិហារិយេហិ សមន្នាគតំ ភវន្តំ គោតមំ ធារេម ភវញ្ហិ គោតមោ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ភវញ្ហិ គោតមោ អវិតក្កំ អវិចារំ សមាធឹ សមាបន្នស្ស ចេតសា ចេតោ បរិច្ច បជានាតិ យថា ឥមស្ស ភោតោ មនោសង្ខារា បណិហិតា ឥមស្ស ចិត្តស្ស អនន្តរា អមុន្នាម វិតក្កំ វិតក្កិស្សតីតិ ភវញ្ហិ គោតមោ ឯវំ អនុសាសតិ ឯវំ វិតក្កេថ មា ឯវំ វិតក្កយិត្ថ ឯវំ មនសិករោថ មា ឯវំ មនសាកត្ថ ឥទំ បជហថ ឥទំ ឧបសម្បជ្ជ វិហរថាតិ ។ អទ្ធា ខោ ត្យាហំ ព្រាហ្មណ អាសជ្ជ ឧបនីយវាចា ភាសិតា អបិច ត្យាហំ ព្យាករិស្សាមិ អហញ្ហិ ព្រាហ្មណ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោមិ ។ បេ ។ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេមិ

យើងខ្ញុំចាំទុកនូវព្រះគោតមដ៏ចម្រើន ដែលប្រកបដោយបាដិហារ្យទាំង ៣ នេះ ព្រោះព្រះគោតមដ៏ចម្រើន បានសម្រេចឫទ្ធិច្រើនប្រការ ។ បេ ។ ប្រើអំណាច ឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោក ព្រោះព្រះគោតមដ៏ចម្រើន កំណត់ដឹងនូវចិត្តដោយចិត្តរបស់បុគ្គលអ្នកបានសមាធិឥតមានវិតក្កៈ ឥតមានវិចារៈថា មនោសង្ខារទាំងឡាយ ដែលបុគ្គលដ៏ចម្រើននេះតម្កល់ទុក បុគ្គលដ៏ចម្រើននេះ នឹងត្រិះរិះនូវវិតក្កៈឈ្មោះឯណោះក្នុងលំដាប់នៃចិត្តនេះ ដ្បិតព្រះគោតមដ៏ចម្រើន ប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយ ចូរត្រិះរិះយ៉ាងនេះ កុំត្រិះរិះយ៉ាងនេះឡើយ ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះ កុំធ្វើទុកក្នុងចិត្តយ៉ាងនេះឡើយ ចូរលះបង់អំពើនេះចេញ ចូរប្រកបអំពើនេះចុះ ។ ម្នាលព្រាហ្មណ៍ វាចាអែបនែបដែលអ្នកពោលហើយ ប៉ះត្រូវតថាគតដោយពិត មានតែតថាគតនឹងសម្តែងដល់អ្នក ម្នាលព្រាហ្មណ៍ ព្រោះតថាគត បានសម្រេចឫទ្ធិច្រើនប្រការ ។ បេ ។ ប្រើអំណាចឲ្យប្រព្រឹត្តទៅ ដោយកាយដរាបដល់ព្រហ្មលោក

១៧៧



អហញ្ហិ ព្រាហ្មណ អវិតក្កំ អវិចារំ សមាធឹ សមាបន្នស្ស ចេតសា ចេតោ បរិច្ច បជានាមិ យថា ឥមស្ស ភោតោ មនោសង្ខារា បណិហិតា ឥមស្ស ចិត្តស្ស អនន្តរា អមុន្នាម វិតក្កំ វិតក្កិស្សតីតិ អហញ្ហិ ព្រាហ្មណ ឯវំ អនុសាសាមិ ឯវំ វិតក្កេថ មា ឯវំ វិតក្កយិត្ថ ឯវំ មនសិករោថ មា ឯវំ មនសាកត្ថ ឥទំ បជហថ ឥទំ ឧបសម្បជ្ជ វិហរថាតិ ។ អត្ថិ បន ភោ គោតម អញ្ញោ ឯកភិក្ខុបិ យោ ឥមេហិ តីហិ បាដិហារិយេហិ សមន្នាគតោ អញ្ញត្រ ភោតា គោតមេនាតិ ។ ន ខោ ព្រាហ្មណ ឯកំយេវ សតំ ន ទ្វេ សតានិ ន តីណិ សតានិ ន ចត្តារិ សតានិ ន បញ្ចសតានិ អថខោ ភិយ្យោ វ យេ ភិក្ខូ ឥមេហិ តីហិ បាដិហារិយេហិ សមន្នាគតាតិ ។ កហំ បន ភោ គោតម ឯតរហិ តេ ភិក្ខូ វិហរន្តីតិ ។ ឥមស្មឹយេវ ខោ ព្រាហ្មណ ភិក្ខុសង្ឃេតិ ។ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ

ម្នាលព្រាហ្មណ៍ ព្រោះតថាគត កំណត់ដឹងនូវចិត្តដោយចិត្តរបស់បុគ្គល អ្នកបានសមាធិ ឥតមានវិតក្កៈ ឥតមានវិចារៈថា មនោសង្ខារទាំងឡាយ ដែលបុគ្គលដ៏ចម្រើននេះ បានតម្កល់ទុក បុគ្គលដ៏ចម្រើននេះ នឹងត្រិះរិះនូវវិតក្កៈឈ្មោះឯណោះ ក្នុងលំដាប់នៃចិត្តនេះ ម្នាលព្រាហ្មណ៍ ព្រោះតថាគតប្រៀនប្រដៅយ៉ាងនេះថា អ្នកទាំងឡាយ ចូរត្រិះរិះយ៉ាងនេះ កុំត្រិះរិះយ៉ាងនេះឡើយ ចូរធ្វើទុកក្នុងចិត្តយ៉ាងនេះ កុំធ្វើទុកក្នុងចិត្តយ៉ាងនេះឡើយ ចូរលះបង់អំពើនេះចេញ ចូរប្រកបអំពើនេះវិញ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះភិក្ខុអង្គណាមួយដទៃទៀត ដែលប្រកបដោយបាដិហារ្យទាំង ៣ នេះ លើកលែងតែព្រះគោតមដ៏ចម្រើនចេញ មានដែរឬ ។ ម្នាលព្រាហ្មណ៍ មិនមានត្រឹមមួយរយ មិនមានត្រឹម ២ រយ មិនមានត្រឹម ៣ រយ មិនមានត្រឹម ៤ រយ មិនមានត្រឹមតែ ៥ រយទេ ដែលពិតនោះ ពួកភិក្ខុដែលប្រកបដោយបាដិហារ្យទាំង ៣ នេះ មានច្រើនណាស់ ។ បពិត្រព្រះគោតមដ៏ចម្រើន ចុះឥឡូវនេះ ពួកភិក្ខុទាំងនោះនៅក្នុងទីណា ។ ម្នាលព្រាហ្មណ៍ នៅក្នុងពួកភិក្ខុនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភ្លឺច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ដូចជាគេផ្ងាររបស់ដែលផ្កាប់

បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

ព្រាហ្មណវគ្គោ បឋមោ ។

## តស្សុទ្ទានំ

ទ្វេជនា ព្រាហ្មណា ចេវ
បរិព្វាជកេន និព្វុតំ
បលោកវជ្ជោ តិកណ្ណោ
សោណី សង្គារវេន ចាតិ ។

ឬបើកបង្ហាញរបស់ដែលបិទបាំង ឬក៏ប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះដូចគេទ្រោលប្រទីបក្នុងទីងងឹតឲ្យមនុស្សមានចក្ខុមើលឃើញរូបទាំងឡាយបានយ៉ាងណា ធម៌ដែលព្រះគោតមដ៏ចម្រើន ប្រកាសហើយ ដោយអនេកបរិយាយ ក៏យ៉ាងនោះដែរ ខ្ញុំព្រះអង្គនុ៎ះ សូមដល់ព្រះគោតមដ៏ចម្រើនផងព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីរឭក សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសកអ្នកដល់សរណគមន៍ ជាទីពឹងស្មើដោយជីវិតតាំងពីថ្ងៃនេះជាដើមទៅ ។

ចប់ ព្រាហ្មណវគ្គ ទី ១ ។

# ឧទ្ទាននៃព្រាហ្មណវគ្គនោះគឺ

ពោលអំពីជន ២ លើក អំពីព្រាហ្មណ៍ ១ អំពីបរិព្វាជក ១ អំពីសេចក្ដីរលត់ ១ អំពីសត្វលោកដែលជាប់ជំពាក់ដោយអធម្មរាគៈជាដើម ១ អំពីសេចក្ដីប្រាថ្នាដ៏ក្រៃលែង ១ អំពីព្រាហ្មណ៍ឈ្មោះតិកណ្ណៈ ១ អំពីព្រាហ្មណ៍ឈ្មោះជាណុស្សោណិ ១ អំពីព្រាហ្មណ៍ឈ្មោះសង្គារវៈ ១ ។

# មហាវគ្គោ

[៦៣] តីណីមានិ ភិក្ខវេ តិត្ថាយតនានិ យានិ បណ្ឌិតេហិ សមនុយុញ្ជិយមានានិ សមនុគ្គាហិយមានានិ សមនុភាសិយមានានិ បរម្បិ គន្ត្វា អកិរិយាយ សណ្ឋហន្តិ ។ កតមានិ តីណិ ។ សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យំកិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ បុព្វេ កតហេតូតិ ។ សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យំកិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ ឥស្សរនិម្មានហេតូតិ ។ សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យំកិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ អហេតុអប្បច្ចយាតិ ។

# មហាវគ្គ

[៦៣] ម្នាលភិក្ខុទាំងឡាយ លទ្ធិនៃតិត្ថិយមាន ៣ យ៉ាងដែលពួកបណ្ឌិតសាកសួររឿយៗ ដេញដោលរឿយៗ ប្រដៅរឿយៗ ប្រព្រឹត្តទៅតាមនូវបរម្បរាចារ្យ ហើយតាំងនៅក្នុងអកិរិយមតិ ។ លទ្ធិនៃតិត្ថិយ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះទទួលនូវអារម្មណ៍ណាមួយ ជាសុខឬជាទុក្ខឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ (ដែលបុគ្គលបានទទួលហើយ) ព្រោះហេតុតែអំពើដែលគេបានធ្វើហើយក្នុងកាលមុន ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះទទួលនូវអារម្មណ៍ណាមួយ ជាសុខឬជាទុក្ខ ឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ (ដែលបុគ្គលទទួលហើយ) ព្រោះហេតុតែព្រះឥស្វរបានតាក់តែងមក ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍មួយពួក មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះទទួលនូវអារម្មណ៍ណាមួយ ជាសុខឬជាទុក្ខ ឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ (ដែលបុគ្គលបានទទួលហើយ) ព្រោះមិនមានហេតុ មិនមានបច្ច័យ ។

តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឯវំ-វាទិនោ ឯវំទិដ្ឋិនោ យំកិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ បុព្វេ កាតហេតូតិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ សច្ចំ កិរ តុម្ហេ អាយស្មន្តោ ឯវំវាទិនោ ឯវំទិដ្ឋិនោ យំកិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ បុព្វេ កាតហេតូតិ ។ តេ ចេ មេ ឯវំ បុដ្ឋា អាមាតិ បដិជានន្តិ ត្យាហំ ឯវំ វទាមិ តេនហាយស្មន្តោ បាណាតិបាតិនោ ភវិស្សន្តិ បុព្វេ កាតហេតុ អទិន្នា-ទាយិនោ ភវិស្សន្តិ បុព្វេ កាតហេតុ អព្រហ្មចារិនោ ភវិស្សន្តិ បុព្វេ កាតហេតុ មុសាវាទិនោ ភវិស្សន្តិ

ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះ ទទួលនូវអារម្មណ៍ណាមួយ ជាសុខឬជាទុក្ខឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ (ដែលបុគ្គលបានទទួលហើយ) ព្រោះហេតុតែអំពើដែលគេបានធ្វើហើយក្នុងកាលមុន តថាគតបានចូលទៅរកពួកសមណព្រាហ្មណ៍ទាំងនោះ ហើយពោលយ៉ាងនេះថា ម្នាលអ្នកមានអាយុទាំងឡាយ ឮថា អ្នកទាំងឡាយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះទទួលនូវអារម្មណ៍ណាមួយ ជាសុខឬជាទុក្ខ ឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ (ដែលបុគ្គលបានទទួលហើយ) ព្រោះហេតុតែអំពើដែលគេបានធ្វើហើយក្នុងកាលមុនពិតមែនឬ ។ បើសមណព្រាហ្មណ៍ទាំងនោះដែលតថាគតសួរយ៉ាងនេះហើយ ក៏ប្តេជ្ញាថា ព្រះករុណាព្រះអង្គ តថាគតក៏និយាយទៅនឹងពួកសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះវិញថា បើដូច្នោះ អ្នកមានអាយុទាំងឡាយ នឹងប្រព្រឹត្តបាណាតិបាត ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងប្រព្រឹត្តអទិន្នាទាន ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងប្រព្រឹត្តអព្រហ្មចរិយ ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងប្រព្រឹត្តមុសាវាទ ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន

១៨១



បុព្វេ កតហេតុ បិសុណាវាចា ភវិស្សន្តិ បុព្វេ កត-
ហេតុ ផរុសវាចា ភវិស្សន្តិ បុព្វេ កតហេតុ សម្ផប្ប-
លាបិនោ ភវិស្សន្តិ បុព្វេ កតហេតុ អភិជ្ឈាលុនោ
ភវិស្សន្តិ បុព្វេ កតហេតុ ព្យាបន្នចិត្តា ភវិស្សន្តិ បុព្វេ
កតហេតុ មិច្ឆាទិដ្ឋិកា ភវិស្សន្តិ បុព្វេ កតហេតុ ។
បុព្វេ កតំ ខោ បន ភិក្ខវេ សារតោ បច្ចាគច្ឆតំ ន
ហោតិ ឆន្ទោ វា វាយាមោ វា ឥទំ វា ករណីយំ
ឥទំ វា អករណីយន្តិ ។ ឥតិ ករណីយាករណីយេ
ខោ បន សច្ចតោ ថេតតោ អនុបលព្ភិយមានេ
មុដ្ឋស្សតីនំ អនារក្ខានំ វិហរតំ ន ហោតិ បច្ចត្តំ
សហធម្មិកោ សមណវាទោ ។ អយំ ខោ មេ
ភិក្ខវេ តេសុ សមណព្រាហ្មណេសុ ឯវំវាទីសុ
ឯវំទិដ្ឋីសុ បឋមោ សហធម្មិកោ និគ្គហោ ហោតិ ។
តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ

នឹងប្រព្រឹត្តបិសុណាវាចា ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងប្រព្រឹត្តផរុសវាចា ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងប្រព្រឹត្តសម្ផប្បលាបៈ ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងជាអ្នកច្រើនដោយអភិជ្ឈា ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងមានចិត្តព្យាបាទ ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន នឹងជាមិច្ឆាទិដ្ឋិ ព្រោះហេតុតែអំពើដែលខ្លួនបានធ្វើហើយ ក្នុងកាលមុន ។ ម្នាលភិក្ខុទាំង-ឡាយ សេចក្តីប្រាថ្នាឬសេចក្តីព្យាយាមថា កិច្ចនេះគួរធ្វើក្តី កិច្ចនេះមិនគួរធ្វើក្តី មិនសម្រេចដល់ពួកបុគ្គលដែលប្រកាន់នូវអំពើដែលខ្លួនបានធ្វើហើយក្នុងកាលមុនថា មានសារៈទេ ។ កាលបើកិច្ចដែលគួរធ្វើនិងមិនគួរធ្វើ មិនប្រាកដដោយពិត ដោយមាំមួនហើយ សមណវាទដែលប្រកបដោយហេតុចំពោះខ្លួន ក៏មិនសម្រេចដល់ពួកបុគ្គល ដែលភាន់ភាំងសតិនិងមិនមានការរក្សាឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាវាទៈរបស់តថាគតប្រកបដោយហេតុទី ១ ជាធម៌សង្កត់សង្កិនពួកសមណព្រាហ្មណ៍ទាំងនោះ ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណាមានវាទៈយ៉ាងនេះ

ឯវំទិដ្ឋិនោ យំកិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ ឥស្សរនិម្មានហេតូតិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ សច្ចំ កិរ តុម្ហេ អាយស្មន្តោ ឯវំវាទិនោ ឯវំទិដ្ឋិនោ យំកិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ ឥស្សរនិ-ម្មានហេតូតិ ។ តេ ច មេ ឯវំ បុដ្ឋា អាមាតិ បដិជានន្តិ ត្យាហំ ឯវំ វទាមិ តេនហាយស្មន្តោ បាណាតិបាតិនោ ភវិស្សន្តិ ឥស្សរនិម្មានហេតុ ។ បេ ។ មិច្ឆាទិដ្ឋិកា[១] ភវិស្សន្តិ ឥស្សរនិម្មានហេតុ ។ ឥស្សរនិម្មានំ ខោ បន ភិក្ខវេ សារតោ បច្ចាគច្ឆតំ ន ហោតិ ឆន្ទោ វា វាយាមោ វា ឥទំ វា ករណីយំ ឥទំ វា អករណីយន្តិ ។

១ ឱ. មិច្ឆាទិដ្ឋិនោ ។

មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះ រមែងទទួលនូវអារម្មណ៍ណាមួយ ជាសុខឬជាទុក្ខ ឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ (ដែលបុគ្គលបានទទួលហើយ) ព្រោះហេតុតែព្រះឥស្សរ បានតាក់តែងមក តថាគតចូលទៅរកសមណព្រាហ្មណ៍ទាំងនោះហើយ ពោលយ៉ាងនេះថា ម្នាលអ្នកមានអាយុទាំងឡាយ ឮថាអ្នកទាំងឡាយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះ ទទួលនូវអារម្មណ៍ណាមួយ ជាសុខឬជាទុក្ខ ឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ (ដែលបុគ្គលបានទទួលហើយ) ព្រោះហេតុតែព្រះឥស្សរ បានតាក់តែងមកពិតឬ ។ បើតថាគត សួរយ៉ាងនេះហើយ សមណព្រាហ្មណ៍ទាំងនោះក៏ប្តេជ្ញាថា ព្រះករុណាព្រះអង្គ តថាគតក៏ពោលទៅនឹងសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះវិញថា បើដូច្នោះ អ្នកមានអាយុទាំងឡាយ នឹងប្រព្រឹត្តបាណាតិបាត ព្រោះហេតុតែព្រះឥស្សរ បានតាក់តែងមក ។ បេ ។ នឹងមានគំនិតយល់ខុស ព្រោះហេតុតែព្រះឥស្សរ បានតាក់តែងមក ។ សេចក្តីប្រាថ្នាឬសេចក្តីព្យាយាមថា កិច្ចនេះ គួរធ្វើក្តី កិច្ចនេះ មិនគួរធ្វើក្តី មិនសម្រេចដល់ពួកបុគ្គលដែលប្រកាន់នូវសេចក្តីយល់ថា ព្រះឥស្សរ អ្នកតាក់តែងមកថា មានសារៈទេ ។

១៨៣



ឥតិ ករណីយាករណីយេ ខោ បន សច្ចតោ ថេតតោ អនុបលព្ភិយមានេ មុដ្ឋស្សតីនំ អនារក្ខានំ វិហរតំ ន ហោតិ បច្ចត្តំ សហធម្មិកោ សមណវាទោ ។ អយំ ខោ មេ ភិក្ខវេ តេសុ សមណព្រាហ្មណេសុ ឯវំវាទីសុ ឯវំទិដ្ឋីសុ ទុតិយោ សហធម្មិកោ និគ្គហោ ហោតិ ។ តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ យំកិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ អហេតុអប្បច្ចយាតិ ត្យាហំ ឧបសង្កមិត្វា ឯវំ វទាមិ សច្ចំ កិរ តុម្ហេ អាយស្មន្តោ ឯវំវាទិនោ ឯវំទិដ្ឋិនោ យំកិញ្ចាយំ បុរិសបុគ្គលោ បដិសំវេទេតិ សុខំ វា ទុក្ខំ វា អទុក្ខមសុខំ វា សព្វន្តំ អហេតុអប្បច្ចយាតិ ។ តេ ចេ មេ ឯវំ បុដ្ឋា អាមាតិ បដិជានន្តិ

កាលបើកិច្ចគួរធ្វើនិងមិនគួរធ្វើ មិនប្រាកដដោយពិត ដោយមាំមួនទេ សមណវាទដែលប្រកបដោយហេតុចំពោះខ្លួន ក៏មិនសម្រេចដល់បុគ្គលដែលភ្លេចសតិ និងមិនមានការរក្សាឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាវាទៈរបស់តថាគតប្រកបដោយហេតុទី ២ ជាធម៌សង្កត់សង្កិនពួកសមណព្រាហ្មណ៍ទាំងនោះដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះពួកព្រាហ្មណ៍ណាមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះទទួលនូវអារម្មណ៍ណាមួយ ជាសុខឬ ជាទុក្ខ ឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ (ដែលបុគ្គលបានទទួលហើយ) ព្រោះមិនមានហេតុ មិនមានបច្ច័យ តថាគតក៏បានចូលទៅរកពួកសមណ-ព្រាហ្មណ៍ទាំងនោះ ហើយពោលយ៉ាងនេះថា ម្នាលអ្នកមានអាយុទាំង-ឡាយ ឮថា អ្នកទាំងឡាយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បុរសបុគ្គលនេះទទួលនូវអារម្មណ៍ណាមួយ ជាសុខ ឬជាទុក្ខ ឬមិនមែនទុក្ខ មិនមែនសុខ អារម្មណ៍ទាំងអស់នោះ (ដែលបុគ្គលបានទទួលហើយ) ព្រោះមិនមានហេតុ មិនមានបច្ច័យពិតឬ ។ បើតថាគតសួរយ៉ាងនេះហើយ សមណព្រាហ្មណ៍ទាំងនោះ ប្តេជ្ញាព្រមថា ព្រះករុណាព្រះអង្គ

ត្យាហំ ឯវំ វទាមិ តេនហាយស្មន្តោ ចាណាតិ-
បាតិនោ ភវិស្សន្តិ អហេតុអប្បច្ចយា ។ បេ ។
មិច្ឆាទិដ្ឋិកា ភវិស្សន្តិ អហេតុអប្បច្ចយា ។
អហេតុ[១] ខោ បន ភិក្ខវេ សារតោ បច្ចាគច្ឆតំ
ន ហោតិ ឆន្ទោ វា វាយាមោ វា ឥទំ វា ករណីយំ
ឥទំ វា អករណីយន្តិ ។ ឥតិ ករណីយាករណីយេ
ខោ បន សច្ចតោ ថេតតោ អនុបលព្ភិយមានេ
មុដ្ឋស្សតីនំ អនារក្ខានំ វិហរតំ ន ហោតិ បច្ចត្តំ
សហធម្មិកោ សមណវាទោ ។ អយំ ខោ មេ ភិក្ខវេ
តេសុ សមណព្រាហ្មណេសុ ឯវំវាទីសុ ឯវំទិដ្ឋីសុ
តតិយោ សហធម្មិកោ និគ្គហោ ហោតិ ។ ឥមានិ ខោ
ភិក្ខវេ តីណិ តិត្ថាយតនានិ យានិ[២] បណ្ឌិតេហិ
សមនុយុញ្ជិយមានានិ សមនុគ្គាហិយមានានិ សមនុ-
ភាសិយមានានិ បរម្បិ គន្ត្វា អកិរិយាយ សណ្ឋហន្តិ ។

---

១ ឱ. អហេតុ អប្បច្ចយា ។ ម. អហេតុំ អបច្ចយំ ។ ២ ឱ. យានិ តានិ ។

តថាគតពោលទៅនឹងសមណព្រាហ្មណ៍ទាំងនោះ យ៉ាងនេះវិញថា បើដូច្នោះអ្នកមានអាយុទាំងឡាយ នឹងប្រព្រឹត្តបាណាតិបាត ព្រោះមិនមានហេតុ មិនមានបច្ច័យ ។ បេ ។ នឹងមានគំនិតយល់ខុស ព្រោះមិនមានហេតុ មិនមានបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាឬសេចក្តីព្យាយាម ថា កិច្ចនេះ គួរធ្វើក្តី កិច្ចនេះ មិនគួរធ្វើក្តី មិនសម្រេចដល់ពួកបុគ្គលដែលប្រកាន់នូវអំពើ ដែលមិនមានហេតុថាជាសារៈឡើយ ។ កាលបើកិច្ចដែលគួរធ្វើនិងមិនគួរធ្វើ មិនប្រាកដដោយពិត ដោយមាំមួនទេ សមណវាទដែលប្រកបដោយហេតុចំពោះខ្លួន ក៏មិនសម្រេច ដល់ពួកបុគ្គលដែលភ្លេចស្មារតីនិងមិនមានការរក្សាឡើយ ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ជាវាទៈរបស់តថាគតប្រកបដោយហេតុទី ៣ ជាធម៌សង្កត់សង្កិនពួកសមណព្រាហ្មណ៍ទាំងនោះ ដែលមានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ លទ្ធិនៃតិរ្ថិយទាំង ៣ យ៉ាងនេះឯង ហើយ ដែលបណ្ឌិតសាកសួររឿយ ៗ ដេញដោលរឿយ ៗ ប្រដៅរឿយ ៗ ប្រព្រឹត្តតាមបរម្បរាចារ្យ តាំងនៅដោយអកិរិយមតិ ។

១៨៤



អយំ ខោ បន ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គ-ហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិក្កុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ កតមោ ច ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិ-លិដ្ឋោ អនុបវជ្ជោ អប្បដិក្កុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ ឥមា ឆ ធាតុយោតិ ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិក្កុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ ឥមានិ ឆ ផស្សាយតនានីតិ ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិក្កុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ ឥមេ អដ្ឋារស មនោបវិចារាតិ ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិក្កុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ ឥមានិ ចត្តារិ អរិយសច្ចានីតិ ភិក្ខវេ មយា ធម្មោ ទេសិតោ

ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតសម្តែងមកហើយនេះ ពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញសង្កត់សង្កិនមិនបានធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគត បានសម្តែងមកហើយ ពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញសង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបានតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះធាតុ ៦ ពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះផស្សាយតនៈ ៦ ពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញសង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះមនោបវិចារ ១៨ ពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញសង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ។ ម្នាលភិក្ខុទាំង-ឡាយ ធម៌ដែលតថាគត បានសម្តែងហើយថា នេះអរិយសច្ច ៤

អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិក្កុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ ឥមា ឆ ធាតុយោតិ ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិក្កុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ឆយិមា ភិក្ខវេ ធាតុយោ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ វិញ្ញាណធាតុ ។ ឥមា ឆ ធាតុយោតិ ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិក្កុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥមានិ ឆ ផស្សាយតនានីតិ ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិក្កុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ឥតិ ខោ បនេតំ វុត្តំ ។

ពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញសង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះធាតុ ៦ ពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញសង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យនុ៎ះតថាគតបានពោលដូច្នេះឯង ។ ពាក្យដែលតថាគតបានពោលហើយនុ៎ះ ព្រោះអាស្រ័យនូវហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ (ព្រោះអាស្រ័យ) នូវធាតុ ៦ នេះ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ អាកាសធាតុ ១ វិញ្ញាណ-ធាតុ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះធាតុ ៦ ពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យណាដែលតថាគត បានពោលដូច្នេះហើយ ពាក្យនុ៎ះតថាគតបានពោលហើយ ព្រោះអាស្រ័យនូវហេតុនេះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគត បានសម្តែងហើយថា នេះផស្សាយតនៈ ៦ ពួកសមណ-ព្រាហ្មណ៍ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យនោះតថាគតបានពោលហើយដូច្នេះឯង ។

១៨៧



កិញ្ចេតំ បដិច្ច វុត្តំ ។ ឆយិមានិ ភិក្ខវេ ផស្សាយតនានិ ចក្ខុំ ផស្សាយតនំ សោតំ ផស្សាយតនំ ឃានំ ផស្សាយតនំ ជិវ្ហា ផស្សាយតនំ កាយោ ផស្សាយតនំ មនោ ផស្សាយតនំ ។ ឥមានិ ឆ ផស្សាយតនានីតិ ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិកុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ។ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥមេ អដ្ឋារស មនោបវិចារាតិ ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិកុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ចក្ខុនា រូបំ ទិស្វា សោមនស្សដ្ឋានិយំ រូបំ ឧបវិចរតិ ទោមនស្សដ្ឋានិយំ រូបំ ឧបវិចរតិ ឧបេក្ខាហានិយំ រូបំ ឧបវិចរតិ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា...

ពាក្យដែលតថាគតបានពោលហើយនុ៎ះ ព្រោះអាស្រ័យនូវហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ (ព្រោះអាស្រ័យ) នូវផស្សាយតនៈ ៦ នេះគឺ ផស្សាយតនៈគឺចក្ខុ ១ ផស្សាយតនៈគឺសោតៈ ១ ផស្សាយតនៈគឺឃានៈ ១ ផស្សាយតនៈគឺជិវ្ហា ១ ផស្សាយតនៈគឺកាយៈ ១ ផស្សាយតនៈគឺមនោ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគត បានសម្តែងហើយថា នេះ ផស្សាយតនៈ ៦ ពួកសមណព្រាហ្មណ៍សង្កត់សង្កិន មិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យណា ដែលតថាគត បានពោលហើយដូច្នេះ ពាក្យដែលតថាគតបានពោល ហើយនុ៎ះ ព្រោះអាស្រ័យនូវហេតុនេះ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ដែលតថាគតបានសម្តែងហើយថា នេះមនោបវិចារ ១៨ ពួកសមណ-ព្រាហ្មណ៍ សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិន បាន ស្អប់ខ្ពើមមិនបាន ពាក្យនុ៎ះតថាគតបានពោលហើយដូច្នេះឯង ។ ពាក្យដែលតថាគតបានពោលហើយនុ៎ះ ព្រោះអាស្រ័យនូវហេតុអ្វី ។ ព្រោះ ឃើញនូវរូបដោយចក្ខុ ហើយពិចារណានូវរូប ដែលជាទីតាំងនៃសោម-នស្ស ពិចារណានូវរូបដែលជាទីតាំងនៃទោមនស្ស ពិចារណានូវរូបដែល ជាទីតាំងនៃឧបេក្ខា ឮសំឡេងដោយត្រចៀក... ហិតក្លិនដោយច្រមុះ...

ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ សោមនស្សដ្ឋានិយំ ធម្មំ ឧបវិចរតិ ទោមនស្សដ្ឋានិយំ ធម្មំ ឧបវិចរតិ ឧបេក្ខាឋានិយំ ធម្មំ ឧបវិចរតិ ។ ឥមេ អដ្ឋារស មនោបវិចារាតិ ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិក្កុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឥមានិ ចត្តារិ អរិយ-សច្ចានីតិ ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិក្កុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ឥតិ ខោ បនេតំ វុត្តំ ។ កិញ្ចេតំ បដិច្ច វុត្តំ ។ ឆន្នំ ភិក្ខវេ ធាតូនំ ឧបាទាយ គព្ភស្សាវក្កន្តិ ហោតិ ឱក្កន្តិយា សតិ នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡា-យតនប្បច្ចយា ផស្សោ ផស្សប្បច្ចយា វេទនា ។

ជញ្ជក់នូវរសដោយអណ្តាត... ពាល់ត្រូវនូវផោដ្ឋព្វដោយកាយ... ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត ពិចារណានូវធម្មារម្មណ៍ដែលជាទីតាំងនៃសោមនស្ស ពិចារណានូវធម្មារម្មណ៍ ដែលជាទីតាំងនៃទោមនស្ស ពិចារណានូវធម្មារម្មណ៍ដែលជាទីតាំងនៃឧបេក្ខា ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះមនោបវិចារ ១៨ ពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញសង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យណាដែលតថាគតបានពោលហើយដូច្នេះ ពាក្យដែលតថាគតបានពោលហើយនុ៎ះ ព្រោះអាស្រ័យនូវហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្តែងហើយថា នេះអរិយសច្ច ៤ ពួកសមណព្រាហ្មណ៍សង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យនុ៎ះតថាគតបានពោលហើយដូច្នេះឯង ។ ពាក្យដែលតថាគតបានពោលហើយនុ៎ះ ព្រោះអាស្រ័យនូវហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ការចុះកាន់គភ៌ព្រោះអាស្រ័យនូវធាតុ កាលបើចុះកាន់គភ៌មាន នាមរូបក៏មាន កាលបើនាមរូបជាបច្ច័យមាន សឡាយតនៈក៏មាន កាលបើសឡាយតនៈជាបច្ច័យមាន ផស្សៈក៏មាន កាលបើផស្សៈជាបច្ច័យមាន វេទនាក៏មាន ។

វេទិយមានស្ស ខោ បនាហំ ភិក្ខវេ ឥទំ ទុក្ខន្តិ បញ្ញាបេមិ អយំ ទុក្ខសមុទយោតិ បញ្ញាបេមិ អយំ ទុក្ខនិរោធោតិ បញ្ញាបេមិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ បញ្ញាបេមិ ។ កតមញ្ច ភិក្ខវេ ទុក្ខំ អរិយសច្ចំ ។ ជាតិបិ ទុក្ខា ជរាបិ ទុក្ខា[១] មរណម្បិ ទុក្ខំ សោកបរិទេវទុក្ខទោមនស្សុបាយាសាបិ ទុក្ខា អប្បិយេហិ សម្បយោគោ ទុក្ខោ បិយេហិ វិប្បយោគោ ទុក្ខោ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ សង្ខិត្តេន បញ្ចុបាទានក្ខន្ធា ទុក្ខា ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខំ អរិយសច្ចំ ។ កតមញ្ច ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ ។ អវិជ្ជាបច្ចយា សង្ខារា សង្ខារប្បច្ចយា វិញ្ញាណំ វិញ្ញាណប្បច្ចយា នាមរូបំ នាមរូបប្បច្ចយា សឡាយតនំ សឡាយតនប្បច្ចយា ផស្សោ ផស្សប្ប-ច្ចយា វេទនា វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានប្បច្ចយា ភវោ ភវប្បច្ចយា ជាតិ

១ ឱ. ឯត្ថន្តរេ ព្យាធិបិ ទុក្ខា ។ ម. ព្យាធិបិ ទុក្ខោតិ បាឋោ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ កាលបុគ្គលដឹងនូវអារម្មណ៍ (ទាំងនោះ) ទើបតថាគតបញ្ញត្តថា នេះជាទុក្ខ បញ្ញត្តថា នេះជាទុក្ខសមុទ័យ បញ្ញត្តថា នេះជាទុក្ខនិរោធ បញ្ញត្តថា នេះជាទុក្ខនិរោធគាមិនីបដិបទា ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខអរិយសច្ច តើដូចម្តេច ។ គឺជាតិទុក្ខ ជរាទុក្ខ មរណទុក្ខ សោកទុក្ខ បរិទេវទុក្ខ ទុក្ខទុក្ខ ទោមនស្សទុក្ខ ឧបាយាសទុក្ខ អប្បិយេហិ សម្បយោគទុក្ខ បិយេហិ វិប្បយោគទុក្ខ យម្បិច្ឆំ ន លភតិ តម្បិទុក្ខ សង្ខិត្តេន បញ្ចុបាទានក្ខន្ធទុក្ខ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខសមុទយអរិយសច្ច តើដូចម្តេច ។ គឺ សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ វេទនាកើតមានព្រោះផស្សៈជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ

ជាតិប្បច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខសមុទយោ អរិយសច្ចំ ។ កតមញ្ច ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ។ អវិជ្ជាយត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ សង្ខារនិរោធា វិញ្ញាណនិរោធោ វិញ្ញាណនិរោធា នាមរូបនិរោធោ នាមរូបនិរោធា សឡាយតននិរោធោ សឡាយតននិរោធា ផស្សនិរោធោ ផស្សនិរោធា វេទនានិរោធោ វេទនានិរោធា តណ្ហានិរោធោ តណ្ហានិរោធា ឧបាទាននិរោធោ ឧបាទាននិរោធា ភវនិរោធោ ភវនិរោធា ជាតិនិរោធោ ជាតិនិរោធា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា និរុជ្ឈន្តិ ។ ឯវមេតស្ស កេវលស្ស ទុក្ខក្ខន្ធស្ស និរោធោ ហោតិ ។ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធោ អរិយសច្ចំ ។ កតមញ្ច ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។

ជរានិងមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សេចក្តីសោកខ្សឹកខ្សួលទុក្ខ ទោមនស្ស តានតឹងក៏កើតមានព្រម ។ សេចក្តីកើតឡើងនៃកងទុក្ខទាំងអស់នេះ រមែងមានយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខសមុទយអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខនិរោធអរិយសច្ច តើដូចម្តេច ។ សេចក្តីរលត់សង្ខារ ព្រោះវិនាសរលត់ មិនមានសេសសល់នៃអវិជ្ជា សេចក្តីរលត់វិញ្ញាណ ព្រោះរលត់សង្ខារ សេចក្តីរលត់នាមរូប ព្រោះរលត់វិញ្ញាណ សេចក្តីរលត់សឡាយតនៈ ព្រោះរលត់នាមរូប សេចក្តីរលត់ផស្សៈ ព្រោះរលត់សឡាយតនៈ សេចក្តីរលត់វេទនា ព្រោះរលត់ផស្សៈ សេចក្តីរលត់តណ្ហា ព្រោះរលត់វេទនា សេចក្តីរលត់ឧបា-ទាន ព្រោះរលត់តណ្ហា សេចក្តីរលត់ភព ព្រោះរលត់ឧបាទាន សេចក្តីរលត់ជាតិ ព្រោះរលត់ភព សេចក្តីចាស់ ស្លាប់ រលត់ ព្រោះរលត់ជាតិ សេចក្តីសោកខ្សឹកខ្សួល លំបាកកាយ លំបាកចិត្តនិងការចង្អៀតចង្អល់ចិត្តទាំងឡាយ ក៏រលត់ទៅ ។ សេចក្តីរលត់នៃកងទុក្ខទាំងអស់នេះ តែងមានយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខនិរោធអរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច តើដូចម្តេច ។

អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ឥទំ វុច្ចតិ ភិក្ខវេ ទុក្ខនិរោធគាមិនី បដិបទា អរិយសច្ចំ ។ ឥមានិ ចត្តារិ អរិយសច្ចានីតិ ភិក្ខវេ មយា ធម្មោ ទេសិតោ អនិគ្គហិតោ អសង្កិលិដ្ឋោ អនុបវជ្ជោ អប្បដិក្កុដ្ឋោ សមណេហិ ព្រាហ្មណេហិ វិញ្ញូហីតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។

[៦៤] តីណីមានិ ភិក្ខវេ អមាតាបុត្តិកានិ ភយានីតិ អស្សុតវា បុថុជ្ជនោ ភាសតិ ។ កាតមានិ តីណិ ។ ហោតិ សោ ភិក្ខវេ សមយោ យំ មហា-អគ្គិឌាហោ វុដ្ឋាតិ ។ មហាអគ្គិឌាហេ ខោ បន ភិក្ខវេ វុដ្ឋិតេ តេន គាមាបិ ឌយ្ហន្តិ និគមាបិ ឌយ្ហន្តិ នគរាបិ ឌយ្ហន្តិ គាមេសុបិ ឌយ្ហមានេសុ និគមេសុបិ ឌយ្ហមានេសុ នគរេសុបិ ឌយ្ហមានេសុ

មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុក្ខនិរោធគាមិនីបដិបទា-អរិយសច្ច ។ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលតថាគតបានសម្ដែងហើយថា នេះអរិយសច្ច ៤ ពួកសមណព្រាហ្មណ៍ជាអ្នកប្រាជ្ញសង្កត់សង្កិនមិនបាន ធ្វើឲ្យសៅហ្មងមិនបាន តិះដៀលមិនបាន ស្អប់ខ្ពើមមិនបាន ពាក្យណាដែលតថាគតពោលហើយដូច្នេះ ពាក្យនេះតថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុនុ៎ះ ។

[៦៤] ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនមិនចេះដឹង រមែងពោលថា អមាតាបុត្តិកភ័យ (ភ័យដែលមាតាមិនបានឃើញបុត្រ បុត្រមិនបានឃើញមាតា) នេះ មាន ៣ យ៉ាង ។ ភ័យ ៣ យ៉ាងដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សម័យដែលមានកម្ដៅភ្លើងធំតាំងឡើង ។ ម្នាលភិក្ខុទាំងឡាយ កាលបើកម្ដៅភ្លើងធំតាំងឡើងហើយ អ្នកស្រុកក៏ក្ដៅ អ្នកនិគមក៏ក្ដៅ អ្នកនគរក៏ក្ដៅដោយភ្លើងនោះ កាលបើអ្នកស្រុកក្ដៅ អ្នកនិគមក្ដៅ អ្នកនគរក្ដៅ

តត្ថ មាតាបិ បុត្តំ ន បដិលភតិ បុត្តោបិ មាតរំ ន បដិលភតិ ។ ឥទំ ភិក្ខវេ បឋមំ អមាតាបុត្តិកំ ភយន្តិ អស្សុតវា បុថុជ្ជនោ ភាសតិ ។ បុន ចបរំ ភិក្ខវេ ហោតិ សោ សមយោ យំ មហាមេឃោ វុដ្ឋាតិ ។ មហាមេឃេ ខោ បន ភិក្ខវេ វុដ្ឋិតេ មហាឧទកវាហកោ សញ្ជាយតិ មហាឧទកវាហកេ សញ្ជាតេ តេន គាមាបិ វុយ្ហន្តិ និគមាបិ វុយ្ហន្តិ នគរាបិ វុយ្ហន្តិ គាមេ-សុបិ វុយ្ហមានេសុ និគមេសុបិ វុយ្ហមានេសុ នគរេសុបិ វុយ្ហមានេសុ តត្ថ មាតាបិ បុត្តំ ន បដិលភតិ បុត្តោបិ មាតរំ ន បដិលភតិ ។ ឥទំ ភិក្ខវេ ទុតិយំ អមាតាបុត្តិកំ ភយន្តិ អស្សុតវា បុថុជ្ជនោ ភាសតិ ។ បុន ចបរំ ភិក្ខវេ ហោតិ សោ សមយោ យំ ភយំ ហោតិ អដវីសង្កោបោ[១] ចក្កសមារូឡ្ហា ជានបទា បរិយាយន្តិ ។ ភយេ ខោ បន ភិក្ខវេ សតិ អដវីសង្កោបេ ចក្កសមារូឡ្ហេសុ ជាន-បទេសុ បរិយាយន្តេសុ តត្ថ មាតាបិ បុត្តំ ន បដិលភតិ បុត្តោបិ មាតរំ ន បដិលភតិ ។

១ ឱ. អដវីសង្ខេបោ ។

មាតាក៏មិនបានឃើញកូន ទាំងកូនក៏មិនបានឃើញមាតា ក្នុងកាលដែលអគ្គិភ័យកើតឡើងនោះ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹងតែងពោលថា នេះជាអមាតាបុត្តិកភ័យទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សម័យដែលមហាមេឃតាំងឡើង គឺបង្អុរភ្លៀងឲ្យធ្លាក់ចុះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើមហាមេឃ បង្អុរភ្លៀងធ្លាក់ចុះ អន្លង់ទឹកធំរមែងកើតព្រម កាលបើជំនន់ធំកើតព្រមហើយ អ្នកស្រុករមែងរសាត់ទៅ អ្នកនិគមរមែងរសាត់ទៅ អ្នកនគររមែងរសាត់ទៅដោយទឹកនោះ កាលបើអ្នកស្រុករសាត់ទៅ អ្នកនិគមរសាត់ទៅ អ្នកនគររសាត់ទៅ មាតាក៏មិនបានឃើញកូន ទាំងកូនក៏មិនបានឃើញមាតា ក្នុងពេលដែលឧទកភ័យកើតឡើងនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹងរមែងពោលថា នេះជាអមាតាបុត្តិកភ័យទី ២ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សម័យដែលមាន អដវីសង្កោបភ័យ (គឺសេចក្តីកម្រើកចោរក្នុងដងព្រៃ)[១] នោះពួកអ្នកជនបទក៏នាំគ្នាឡើងកាន់ចក្កយានបរទៅ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអដវីសង្កោបភ័យមានហើយ ពួកអ្នកជនបទនាំគ្នាឡើងកាន់ចក្កយានបរទៅ មាតាក៏មិនបានឃើញបុត្រ ទាំងបុត្រក៏មិនបានឃើញមាតា ក្នុងកាលដែលអដវីសង្កោបភ័យ កើតឡើងនោះ ។

១. ពួកចោរដែលនៅក្នុងដងព្រៃ លបចាំប្លន់អ្នកស្រុក ( អដ្ឋកថា )

១៩៣



ឥទំ ភិក្ខវេ តតិយំ អមាតាបុត្តិកំ ភយន្តិ អស្សុតវា បុថុជ្ជនោ ភាសតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ អមាតាបុត្តិកានិ ភយានីតិ អស្សុតវា បុថុជ្ជនោ ភាសតិ ។ តានិ ខោ បនិមានិ ភិក្ខវេ តីណិ សមាតាបុត្តិកានិយេវ ភយានិ អមាតាបុត្តិកានិ ភយានីតិ អស្សុតវា បុថុជ្ជនោ ភាសតិ ។ កតមានិ តីណិ ។ ហោតិ សោ ភិក្ខវេ សមយោ យំ មហាអគ្គិឌាហោ វុដ្ឋាតិ ។ មហាអគ្គិឌាហេ ខោ បន ភិក្ខវេ វុដ្ឋិតេ តេន គាមាបិ ឌយ្ហន្តិ និគមាបិ ឌយ្ហន្តិ នគរាបិ ឌយ្ហន្តិ គាមេសុបិ ឌយ្ហមានេសុ និគមេសុបិ ឌយ្ហមានេសុ នគរេសុបិ ឌយ្ហមានេសុ ហោតិ សោ សមយោ យំ កទាចិ ករហចិ មាតាបិ បុត្តំ បដិលភតិ បុត្តោបិ មាតរំ បដិលភតិ ។ ឥទំ ភិក្ខវេ បឋមំ សមាតាបុត្តិកញ្ញេវ ភយំ អមាតាបុត្តិកំ ភយន្តិ អស្សុតវា បុថុជ្ជនោ ភាសតិ ។ បុន ចបរំ ភិក្ខវេ

ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង តែងពោលថា នេះជា អមាតាបុត្តិកភ័យទី ៣ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិន ចេះដឹង តែងពោលថា អមាតាបុត្តិកភ័យមាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង រមែងពោលនូវសមាតាបុត្តិ- កភ័យ (ភ័យដែលមាតានិងបុត្រនៅឃើញគ្នាបាន) ថាជាអមាតាបុត្តិក- ភ័យ (ភ័យដែលមាតានិងបុត្រមិនបានឃើញគ្នា) នេះ មាន ៣ យ៉ាង ។ ភ័យ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សម័យដែលមាន កម្តៅភ្លើងធំតាំងឡើង ។ ម្នាលភិក្ខុទាំងឡាយ កាលបើកម្តៅភ្លើងធំ តាំងឡើងហើយ អ្នកស្រុកក៏ក្តៅ អ្នកនិគមក៏ក្តៅ អ្នកនគរក៏ក្តៅដោយ ភ្លើងនោះ កាលបើអ្នកស្រុកក្តៅ អ្នកនិគមក្តៅ អ្នកនគរក្តៅ សម័យ នោះ ជួនកាលមាតាបានឃើញបុត្រ បុត្រក៏បានឃើញមាតាខ្លះ ។ ម្នាល ភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង រមែងពោលនូវសមាតាបុត្តិកភ័យ នេះថា ជាអមាតាបុត្តិកភ័យទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត

ហោតិ សោ សមយោ យំ មហាមេឃោ វុដ្ឋាតិ ។ មហាមេឃេ ខោ បន ភិក្ខវេ វុដ្ឋិតេ មហាឧទកវាហកោ សញ្ជាយតិ មហាឧទកវាហកេ សញ្ជាតេ តេន គាមាបិ វុយ្ហន្តិ និគមាបិ វុយ្ហន្តិ នគរាបិ វុយ្ហន្តិ គាមេសុបិ វុយ្ហមានេសុ និគមេសុបិ វុយ្ហមានេសុ នគរេសុបិ វុយ្ហមានេសុ ហោតិ សោ សមយោ យំ កទាចិ ករហចិ មាតាបិ បុត្តំ បដិលភតិ បុត្តោបិ មាតរំ បដិលភតិ ។ ឥទំ ភិក្ខវេ ទុតិយំ សមាតាបុត្តិកញ្ញេវ ភយំ អមាតាបុត្តកំ ភយន្តិ អស្សុតវា បុថុជ្ជនោ ភាសតិ ។ បុន ចបរំ ភិក្ខវេ ហោតិ សោ សមយោ យំ ភយំ ហោតិ អដវីសង្កោបោ ចក្កសមារូឡ្ហា ជានបទា បរិយាយន្តិ ។ ភយេ ខោ បន ភិក្ខវេ សតិ អដវីសង្កោបេ ចក្កសមារូឡ្ហេសុ ជានបទេសុ បរិយាយន្តេសុ ហោតិ សោ សមយោ យំ កទាចិ ករហចិ មាតាបិ បុត្តំ បដិលភតិ

សម័យដែលមានមហាមេឃបង្អុរភ្លៀង ។ ម្នាលភិក្ខុទាំងឡាយ កាលបើ មហាមេឃបង្អុរភ្លៀងហើយ ជំនន់ធំក៏កើតឡើង កាលបើជំនន់ទឹកធំកើត ហើយ ពួកអ្នកស្រុកក៏រសាត់ទៅ អ្នកនិគមក៏រសាត់ទៅ អ្នកនគរក៏រសាត់ ទៅដោយទឹកនោះ កាលបើអ្នកស្រុករសាត់ទៅ អ្នកនិគមរសាត់ទៅ អ្នក នគរក៏រសាត់ទៅ សម័យនោះ ជួនកាលមាតាក៏បានឃើញបុត្រ បុត្រក៏បាន ឃើញមាតាខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង តែងពោលនូវសមាតាបុត្តិកភ័យនេះថា ជាអមាតាបុត្តិកភ័យទី ២ ។ ម្នាល ភិក្ខុទាំងឡាយ មួយទៀត សម័យដែលមាន អដវីសង្កោបភ័យ ពួកអ្នក ជនបទក៏នាំគ្នាឡើងកាន់ចក្កយានបរទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយ វិញទៀត កាលបើអដវីសង្កោបភ័យមានហើយ ពួកអ្នកជនបទក៏នាំគ្នា ឡើងកាន់ចក្កយានបរទៅ សម័យនោះ ជួនកាលមាតាបានឃើញបុត្រ

បុត្តោបិ មាតរំ បដិលភតិ ។ ឥធំ ភិក្ខវេ តតិយំ សមាតាបុត្តិកញ្ញេវ ភយំ អមាតាបុត្តិកំ ភយន្តិ អស្សុតវា បុថុជ្ជនោ ភាសតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ សមាតាបុត្តិកានិយេវ ភយានិ អមាតាបុត្តិកានិ ភយានីតិ អស្សុតវា បុថុជ្ជនោ ភាសតិ ។ តីណីមានិ ភិក្ខវេ អមាតាបុត្តិកានិ ភយានិ ។ កតមានិ តីណិ ។ ជរាភយំ ព្យាធិភយំ មរណភយំ ។ ន ភិក្ខវេ មាតា បុត្តំ ជីរមានំ ឯវំ លភតិ អហំ ជីរាមិ មា មេ បុត្តោ ជីរីតិ បុត្តោ វា បន មាតរំ ជីរមានំ ន ឯវំ លភតិ អហំ ជីរាមិ មា មេ មាតា ជីរីតិ ។ ន ភិក្ខវេ មាតា បុត្តំ ព្យាធិយមានំ ឯវំ លភតិ អហំ ព្យាធិយាមិ មា មេ បុត្តោ ព្យាធិយីតិ បុត្តោ វា បន មាតរិ ព្យាធិយមានំ ន ឯវំ លភតិ អហំ ព្យាធិយាមិ មា មេ មាតា ព្យាធិយីតិ ។ ន ភិក្ខវេ មាតា បុត្តំ មិយ្យមានំ ឯវំ លភតិ អហំ មិយ្យាមិ មា មេ បុត្តោ មិយ្យីតិ

បុត្រក៏បានឃើញមាតាខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង តែងពោលនូវសមាតាបុត្តិកភ័យនេះ ថាជាអមាតាបុត្តិកភ័យទី ៣ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនចេះដឹង រមែងពោលនូវសមាតា-បុត្តិកភ័យ ៣ យ៉ាងនេះឯងថាជាអមាតាបុត្តិកភ័យ ។ ម្នាលភិក្ខុទាំងឡាយ អមាតាបុត្តិកភ័យនេះ មាន ៣ យ៉ាង ។ អមាតាបុត្តិកភ័យ ៣ យ៉ាង តើដូចម្តេច ។ គឺជរាភ័យ ភ័យព្រោះជរា ១ ព្យាធិភ័យ ភ័យព្រោះព្យាធិ ១ មរណភ័យ ភ័យព្រោះមរណៈ ១ ។ ម្នាលភិក្ខុទាំងឡាយ មាតាមិនបានឃើញបុត្រដែលកំពុងជរាយ៉ាងនេះថា អាត្មាអញចាស់ សូមកុំឲ្យបុត្រអាត្មាអញចាស់ឡើយ ចំណែកខាងបុត្រក៏មិនបានឃើញមាតាដែលកំពុងចាស់យ៉ាងនេះថា អាត្មាអញ សូមកុំឲ្យមាតារបស់អញចាស់ឡើយ ។ ម្នាលភិក្ខុទាំងឡាយ មាតាមិនបានឃើញបុត្រ ដែលកំពុងមានព្យាធិយ៉ាងនេះថា អាត្មាអញមានព្យាធិ សូមកុំឲ្យបុត្ររបស់អាត្មាអញមានព្យាធិឡើយ ចំណែកខាងបុត្រមិនបានឃើញមាតា ដែលកំពុងមានព្យាធិយ៉ាងនេះថា អាត្មាអញមានព្យាធិ សូមកុំឲ្យមាតារបស់អាត្មាអញមានព្យាធិឡើយ ។ ម្នាលភិក្ខុទាំងឡាយ មាតាមិនបានឃើញបុត្រដែលស្លាប់យ៉ាងនេះថា អាត្មាអញរមែងស្លាប់ សូមកុំឲ្យបុត្ររបស់អញស្លាប់ឡើយ

បុត្តោ វា បន មាតរំ មិយ្យមានំ ន ឯវំ លភតិ អហំ មិយ្យាមិ មា មេ មាតា មិយ្យីតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ អមាតាបុត្តិកានិ ភយានិ ។ អត្ថិ ភិក្ខវេ មគ្គោ អត្ថិ បដិបទា ឥមេសញ្ច តិណ្ណំ សមាតាបុត្តិកានំ ភយានំ ឥមេសញ្ច តិណ្ណំ អមាតាបុត្តិកានំ ភយានំ បហានាយ សមតិក្កមាយ សំវត្តតិ ។ កតមោ ច ភិក្ខវេ មគ្គោ កតមា បដិបទា ឥមេសញ្ច តិណ្ណំ សមាតាបុត្តិកានំ ភយានំ ឥមេសញ្ច តិណ្ណំ អមាតាបុត្តិកានំ ភយានំ បហានាយ សមតិក្កមាយ សំវត្តតិ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ អយំ ខោ ភិក្ខវេ មគ្គោ អយំ បដិបទា ឥមេសញ្ច តិណ្ណំ សមាតាបុត្តិកានំ ភយានំ ឥមេសញ្ច តិណ្ណំ អមាតាបុត្តិកានំ ភយានំ បហានាយ សមតិក្កមាយ សំវត្តតីតិ ។

ចំណែកខាងបុត្រ ក៏មិនបានឃើញមាតាដែលស្លាប់យ៉ាងនេះថា អាត្មាអញរមែងតែស្លាប់ សូមកុំឲ្យមាតារបស់អាត្មាអញស្លាប់ឡើយ ម្នាលភិក្ខុទាំងឡាយ អមាតាបុត្តិកភ័យមាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ មគ្គនិងបដិបទា រមែងប្រព្រឹត្តទៅ ដើម្បីលះបង់ ដើម្បីកន្លងបង់នូវសមាតាបុត្តិកភ័យទាំង ៣ យ៉ាងនេះផង នូវអមាតាបុត្តិកភ័យទាំង ៣ យ៉ាងនេះផង ។ ម្នាលភិក្ខុទាំងឡាយ មគ្គ តើដូចម្តេច បដិបទា តើដូចម្តេច រមែងប្រព្រឹត្តទៅ ដើម្បីលះបង់ កន្លងបង់នូវសមាតាបុត្តិកភ័យទាំង ៣ យ៉ាងនេះបានផង នូវអមាតាបុត្តិកភ័យទាំង ៣ នេះបានផង ។ មគ្គដែលប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មា-សតិ ១ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា មគ្គ នេះហៅថា បដិបទា ប្រព្រឹត្តទៅដើម្បីលះបង់ ដើម្បីកន្លងបង់នូវសមាតា-បុត្តិកភ័យទាំង ៣ យ៉ាងនេះផង នូវអមាតាបុត្តិកភ័យទាំង ៣ យ៉ាងនេះផង ។

[៦៤] ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន វេនាគបុរំ នាម[១] កោសលានំ ព្រាហ្មណគ្គាមោ តទវសរិ ។ អស្សោសុំ ខោ វេនាគបុរិកា ព្រាហ្មណ-គហបតិកា សមណោ ខលុ ភោ គោតមោ សក្យ-បុត្តោ សក្យកុលា បព្វជិតោ វេនាគបុរំ អនុប្បត្តោ ។ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោ-សានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។

១ ម. វេនាហបុរំ នាម ។

[៦៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់ស្ដេចទៅកាន់ចារិកក្នុងកោសលជនបទមួយអន្លើដោយភិក្ខុសង្ឃជាច្រើនអង្គ ទ្រង់បានចូលទៅដល់ព្រាហ្មណគ្រាម ឈ្មោះវេនាគបុរីនៃកោសលជនបទ ។ ពួកព្រាហ្មណ៍និងគហបតីអ្នកនៅក្នុងវេនាគបុរី បានឮច្បាស់នូវដំណឹងនោះហើយ ទើបប្រកាសសេចក្ដីថា ម្នាលគ្នាយើង ឮថាព្រះសមណគោតមជាសក្យបុត្តចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួសហើយស្ដេចបានមកដល់វេនាគបុរី ។ កិត្តិស័ព្ទសរសើរព្រះគោតមដ៏ចម្រើននោះ ពីរោះឮខ្ចរខ្ចាយសុះសាយយ៉ាងនេះថា ព្រះមានព្រះភាគនោះទ្រង់ព្រះនាមថា អរហំ ថា សម្មាសម្ពុទ្ធោ ថា វិជ្ជាចរណសម្បន្នោ ថា សុគតោ ថា លោកវិទូ ថា អនុត្តរោ ថា បុរិសទម្មសារថិ ថា សត្ថាទេវមនុស្សានំ ថា ពុទ្ធោ ថា ភគវា ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានចំពោះព្រះអង្គ ហើយញុំាងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឲ្យបានត្រាស់ដឹងផង ព្រះអង្គសម្ដែងធម៌ពីរោះបទដើម ពីរោះបទកណ្ដាល និងពីរោះបទខាងចុង ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈដ៏បរិបូណ៌បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានឃើញបានជួបនឹងព្រះអរហន្តទាំងឡាយមានសភាពយ៉ាងហ្នឹង ជាការប្រពៃពេក ។

អថខោ វេជាតបុរិកា ព្រាហ្មណគហបតិកា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ យេន ភគវា តេនញ្ជលិម្បណាមេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ វេជាតបុរិកោ វច្ឆគោត្តោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម យាវញ្ចិទំ ភោតោ គោតមស្ស វិប្បសន្នានិ ឥន្ទ្រិយានិ បរិសុទ្ធោ ឆវិវណ្ណោ បរិយោទាតោ សេយ្យថាបិ ភោ គោតម សារទំ ពទរបណ្ឌុំ[១] បរិសុទ្ធំ ហោតិ បរិយោទាតំ ឯវមេវ ភោតោ គោតមស្ស វិប្បសន្នានិ ឥន្ទ្រិយានិ បរិសុទ្ធោ ឆវិវណ្ណោ បរិយោទាតោ ។ សេយ្យថាបិ ភោ គោតម តាលបក្កំ សម្បតិពន្ធនា បមុត្តំ បរិសុទ្ធំ ហោតិ

១ ឱ. ភទរបណ្ឌុំ ។

លំដាប់នោះឯង ព្រាហ្មណ៍និងគហបតីអ្នកនៅក្នុងវេនាគបុរី ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ពួកខ្លះក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ពួកខ្លះអង្គុយក្នុងទីដ៏សមគួរប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគ ពួកខ្លះញ៉ាំងនាមនិងគោត្រឲ្យឮឡើងអង្គុយក្នុងទីសមគួរ ពួកខ្លះអង្គុយស្ងៀមក្នុងទីសមគួរ ។ ព្រាហ្មណ៍ជាវច្ឆគោត្រអ្នកនៅក្នុងវេនាគបុរីអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន សេចក្តីអស្ចារ្យមិនធ្លាប់កើតក៏កើតមាន បពិត្រព្រះគោតមដ៏ចម្រើន ឥន្ទ្រិយរបស់ព្រះគោតមដ៏ចម្រើន ជ្រះថ្លា ទាំងសម្បុរស្បែក ក៏បរិសុទ្ធផូរផង់ដោយពិត បពិត្រព្រះគោតមដ៏ចម្រើន ប្រៀបដូចជាផ្លែពុទ្រាទុំក្នុងសរទកាល បរិសុទ្ធផូរផង់យ៉ាងណាមិញ ឥន្ទ្រិយរបស់ព្រះគោតមដ៏ចម្រើន ជ្រះថ្លា ទាំងសម្បុរស្បែក ក៏បរិសុទ្ធផូរផង់ យ៉ាងនោះដែរ ។ បពិត្រព្រះគោតមដ៏ចម្រើនមួយទៀត ប្រៀបដូចជាផ្លែត្នោតទុំ បរិសុទ្ធល្អ ជ្រុះចាកទងយ៉ាងណាមិញ

បរិយោទាតំ ឯវមេវ ភោតោ គោតមស្ស វិប្បសន្នានិ ឥន្ទ្រិយានិ បរិសុទ្ធោ ឆវិវណ្ណោ បរិយោទាតោ ។ សេយ្យថាបិ ភោ គោតម នេក្ខំ ជម្ពោនទំ ទក្ខកម្មារបុត្តសុបរិកម្មកតំ[១] កុសលសម្បហដ្ឋំ បណ្ឌុកម្ពលេ និក្ខិត្តំ ភាសតេ ច តបតេ ច វិរោចតិ ច ឯវមេវ ភោតោ គោតមស្ស វិប្បសន្នានិ ឥន្ទ្រិយានិ បរិសុទ្ធោ ឆវិវណ្ណោ បរិយោទាតោ ។ យានិ នូន តានិ ភោ គោតម ឧច្ចាសយនមហាសយនានិ សេយ្យថីទំ អាសន្ទិ បល្លង្កោ គោណកោ ចិត្តិកា បដិកា បដលិកា តូលិកា

១ ម. ឯត្តន្តរេ ឧក្កាមុខេសូតិ បាឋោ អត្ថិ ។

ឥន្ទ្រិយរបស់ព្រះគោតមដ៏ចម្រើន ជ្រះថ្លា ទាំងសម្បុរស្បែក ក៏បរិសុទ្ធផូរផង់ យ៉ាងនោះដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន មួយទៀត ដូចដុំមាសជម្ពូនទៈ ដែលកម្មារបុត្រអ្នកឈ្លាស ធ្វើបរិកម្មល្អ ទាំងរំលាយល្អហើយ តម្កល់ទុកលើសំពត់កម្ពល មានពណ៌លឿងទុំ រមែងភ្លឺផង ច្បាស់ផង រុងរឿងផង យ៉ាងណាមិញ ឥន្ទ្រិយរបស់ព្រះគោតមដ៏ចម្រើន ជ្រះថ្លាទាំងសម្បុរស្បែក ក៏បរិសុទ្ធផូរផង់ យ៉ាងនោះដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន ឧច្ចាសយនៈនិងមហាសយនៈទាំងនោះ មានដោយពិតគឺ អាសន្ទិ (អាសនៈដែលខ្ពស់ហួសប្រមាណ) ១ បល្លង្ក (គ្រែដែលមានជើងវិចិត្រដោយរូបសត្វសាហាវ) ១ គោណកៈ (ព្រំដែលមានរោមវែងជាង ៤ ធ្នាប់) ១ ចិត្តិកា (កម្រាលដែលគេធ្វើដោយរោមសត្វវិចិត្រដោយរតនៈ) ១ បដិកា (កម្រាលដែលមានពណ៌សធ្វើដោយរោមសត្វ) ១ បដលិកា (កម្រាលដែលធ្វើដោយរោមសត្វជាផ្កាចង្កោម) ១ តូលិកា (កម្រាលដែលញាត់ដោយសំឡី) ១

វិកតិកា ឧទ្ទលោមី ឯកន្តលោមី កដ្ឋិស្សំ កោសេយ្យំ កុត្តកំ ហត្ថត្ថរំ អស្សត្ថរំ រថត្ថរំ អជិនប្បវេណិ កាទលិមិគប្បវរប្បច្ចត្ថរណំ សឧត្តរច្ឆទំ ឧភតោលោ-ហិតកុបធានំ ឯវរូបានំ នូន ភវំ គោតមោ ឧច្ចា-សយនមហាសយនានំ និកាមលាភី អកិច្ឆលាភី អកសិរលាភីតិ ។ យានិ ខោ បន តានិ ព្រាហ្មណ ឧច្ចាសយនមហាសយនានិ សេយ្យថីទំ អាសន្ទិ... ឧភតោលោហិតកុបធានំ ទុល្លភានិ តានិ បព្ពជិតានំ

វិកតិកា (កម្រាលដែលធ្វើដោយរោមសត្វវិចិត្រ ដោយរូបសត្វមានសីហៈនិងខ្លាធំជាដើម) ១ ឧទ្ធលោមី (កម្រាលដែលធ្វើដោយរោមសត្វមានជាយទាំងពីរខាង) ១ ឯកន្តលោមី (កម្រាលដែលធ្វើដោយរោមសត្វមានជាយតែម្ខាង) ១ កដ្ឋិស្សៈ (កម្រាលដែលធ្វើដោយអំបោះលាយសូត្រដោតក្រងដោយរតនៈ) ១ កោសេយ្យៈ (កម្រាលដែលធ្វើដោយសូត្រដោតក្រងដោយរតនៈ) ១ កុត្តកៈ (កម្រាលដែលធ្វើដោយរោមសត្វល្មមពួកស្រីរបាំ ១០ នាក់ឈររាំបាន) ១ ហត្ថត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងដំរី) ១ អស្សត្ថរៈ (កម្រាលសម្រាប់ក្រាលលើខ្នងសេះ) ១ រថត្ថរៈ (កម្រាលសម្រាប់ក្រាលលើរថ) ១ អជិនប្បវេណិ (កម្រាលដែលគេធ្វើដោយស្បែកខ្លាឃ្មុំ) ១ កាទលិមិគប្បវរប្បច្ចត្ថរណៈ (កម្រាលដ៏ឧត្តមដែលធ្វើដោយស្បែកសត្វឈ្លូស) ១ សឧត្តរច្ឆទៈ (ទីដេកដែលមានពិតានក្រហម) ១ ឧភតោលោហិតកុបធានៈ (ខ្នើយមានពណ៌ក្រហមទាំងពីរខាង) ១ ព្រះគោតមទ្រង់បានតាមសេចក្តីប្រាថ្នា ទ្រង់បានដោយងាយ ទ្រង់បានដោយមិនលំបាក នូវឧច្ចាសយនៈនិងមហាសយនៈ មានសភាពយ៉ាងនេះដោយពិត ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ឧច្ចាសយនៈនិងមហាសយនៈទាំងនោះគឺ អាសន្ទិ ១... ឧភតោលោហិតកុបធានៈ ១ ពួកបព្វជិតបានដោយលំបាក

លទ្ធានិ ច ន កប្បន្តិ ។ តីណិ ខោ ឥមានិ ព្រាហ្មណ ឧច្ចាសយនមហាសយនានិ យេសាហំ ឯតរហិ និកាមលាភី អកិច្ឆលាភី អកសិរលាភី ។ កតមានិ តីណិ ។ ទិព្វំ ឧច្ចាសយនមហាសយនំ ព្រហ្មំ ឧច្ចាសយនមហាសយនំ អរិយំ ឧច្ចាសយនមហាសយនំ ។ ឥមានិ ខោ ព្រាហ្មណ តីណិ ឧច្ចាសយនមហាសយនានិ យេសាហំ ឯតរហិ និកាមលាភី អកិច្ឆលាភី អកសិរលាភីតិ ។ កតមំ បន តំ ភោ គោតម ទិព្វំ ឧច្ចាសយនមហាសយនំ យស្ស ភវំ គោតមោ ឯតរហិ និកាមលាភី អកិច្ឆលាភី អកសិរលាភីតិ ។ ឥធាហំ ព្រាហ្មណ យំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរាមិ សោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ តមេវ គាមំ វា និគមំ វា បិណ្ឌាយ បវិសាមិ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ វនន្តំយេវ បវិសាមិ

ប្រសិនបើបព្វជិតបានហើយ ក៏មិនគួរប្រើប្រាស់បានទេ ។ ម្នាលព្រាហ្មណ៍ ឥឡូវនេះតថាគតជាអ្នកបានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិនលំបាក នូវឧច្ចាសយនៈ និងមហាសយនៈ ៣ យ៉ាងនេះឯង ។ ឧច្ចាសយនៈនិងមហាសយនៈ ៣ យ៉ាងតើដូចម្តេច ។ គឺឧច្ចាសយនៈនិងមហាសយនៈជាទិព្វ ១ ឧច្ចាសយនៈនិងមហាសយនៈជារបស់ព្រហ្ម ១ ឧច្ចាសយនៈនិងមហាសយនៈជារបស់អរិយៈ ១ ។ ម្នាលព្រាហ្មណ៍ ឥឡូវនេះ តថាគតបានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិនលំបាកនូវឧច្ចាសយនៈនិងមហាសយនៈ ៣ យ៉ាងនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន ឥឡូវព្រះគោតមដ៏ចម្រើន បានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិនលំបាកនូវឧច្ចាសយនៈនិងមហាសយនៈជាទិព្វនោះ តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ ក្នុងទីឯណោះ តថាគតបានចូលទៅអាស្រ័យនូវស្រុកឬនិគមក្នុងបុព្វណ្ហសម័យ តថាគតស្លៀកស្បង់ប្រដាប់បាត្រនិងចីវរចូលទៅកាន់ស្រុកនិងនិគមនោះឯង ដើម្បីបិណ្ឌបាត្រ កាលតថាគតត្រឡប់ពីបិណ្ឌបាត្រក្នុងបច្ឆាភត្ត ក៏ចូលទៅកាន់ព្រៃ

សោ យនេវ តត្ថ ហោន្តិ តិណានិ វា បណ្ណានិ វា តានិ ឯកជ្ឈំ សង្ហរិត្វា និសីទាមិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា សោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរាមិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរាមិ បីតិយា ច វិរាគា ឧបក្ខកោ ច វិហរាមិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេមិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខ-វិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរាមិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោម-នស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខា-សតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរាមិ ។

តថាគតឯង ក៏ប្រមូលយកស្មៅឬស្លឹកឈើទាំងនោះ ដែលមានក្នុងព្រៃនោះឲ្យនៅតែមួយកន្លែងហើយ អង្គុយពែនភ្នែនតម្កល់កាយឲ្យត្រង់តាំងសតិឆ្ពោះទៅកាន់កម្មដ្ឋាន តថាគតនោះស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈនិងវិចារៈមានបីតិនិងសុខដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ សម្រេចសម្រាន្តនៅ ព្រោះរម្ងាប់នូវវិតក្កៈវិចារៈ ក៏ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិ គឺបឋមជ្ឈានក៏សម្រេចសម្រាន្តនៅ ព្រោះនឿយណាយចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង មានសតិនិងសម្បជញ្ញៈផង ទទួលនូវសុខដោយនាមកាយផង ព្រះអរិយៈទាំង-ឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះបានដល់នូវតតិយជ្ឈាននោះ ទើបសម្រេចសម្រាន្តនៅ ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ព្រោះអស់ទៅនៃសោមនស្សនិងទោមនស្សក្នុងកាលមុនផង ចូលកាន់ចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនជាទុក្ខមិនមែនជាសុខមានសតិដ៏បរិសុទ្ធដោយឧបេក្ខា ក៏សម្រេចសម្រាន្តនៅ ។

២០៣



សោ ចេ អហំ ព្រាហ្មណ ឯវម្ភូតោ ចង្កមាមិ ទិព្វោ មេ ឯសោ តស្មឹ សមយេ ចង្កមោ ហោតិ សោ ចេ អហំ ព្រាហ្មណ ឯវម្ភូតោ តិដ្ឋាមិ ទិព្វំ មេ ឯតំ តស្មឹ សមយេ ឋានំ ហោតិ សោ ចេ អហំ ព្រាហ្មណ ឯវម្ភូតោ និសីទាមិ ទិព្វំ មេ ឯតំ តស្មឹ សមយេ អាសនំ ហោតិ សោ ចេ អហំ ព្រាហ្មណ ឯវម្ភូតោ សេយ្យំ កប្បេមិ ទិព្វំ មេ ឯតំ តស្មឹ សមយេ ឧច្ចាសយនមហាសយនំ ហោតិ ។ ឥទំ ខោ តំ ព្រាហ្មណ ទិព្វំ ឧច្ចាសយនមហាសយនំ យស្សាហំ ឯតរហិ និកាមលាភី អកិច្ឆលាភី អកសិរលាភីតិ ។ អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម កោ ចញ្ញោ ឯវរូបស្ស ទិព្វស្ស ឧច្ចាសយនមហាសយនស្ស និកាមលាភី ភវិស្សតិ អកិច្ឆលាភី អកសិរលាភី អញ្ញត្រ ភោតា គោតមេន ។

ម្នាលព្រាហ្មណ៍ បើតថាគតនោះ ចង្រ្កមមានសភាពយ៉ាងនេះ ទីចង្រ្កមជាទិព្វនោះ រមែងមានដល់តថាគតក្នុងសម័យនោះ ម្នាលព្រាហ្មណ៍ បើតថាគតនោះ ឈរមានសភាពយ៉ាងនេះ ទីឈរជាទិព្វនោះ រមែងមានដល់តថាគតក្នុងសម័យនោះ ម្នាលព្រាហ្មណ៍ បើតថាគតនោះ អង្គុយមានសភាពយ៉ាងនេះ ទីអង្គុយជាទិព្វនោះ រមែងមានដល់តថាគតក្នុងសម័យនោះ ម្នាលព្រាហ្មណ៍ បើតថាគតនោះ សម្រេចនូវសំណឹង មានសភាពយ៉ាងនេះ សំណឹងដ៏ខ្ពស់និងទីអង្គុយដ៏ប្រសើរជាទិព្វនោះ រមែងមានដល់តថាគតក្នុងសម័យនោះ ។ ម្នាលព្រាហ្មណ៍ ឥឡូវ តថាគតជាអ្នកបានតាមសេចក្តីប្រាថ្នា ជាអ្នកបានដោយងាយ បានដោយមិនលំបាកនូវសំណឹងដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរ ជាទិព្វនោះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចំឡែកណាស់ មានបុគ្គលណាដទៃ អាចនឹងបានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិនលំបាក នូវទីដេកដ៏ខ្ពស់និងទីអង្គុយដ៏ប្រសើរ ជាទិព្វ មានសភាពយ៉ាងនេះបានឡើយ លើកលែងតែព្រះគោតមដ៏ចម្រើនចេញ ។

កាតមំ បន តំ ភោ គោតម ព្រហ្មំ ឧច្ចា-
សយនមហាសយនំ យស្ស ភវំ គោតមោ ឯតរហិ
និកាមលាភី អកិច្ឆលាភី អកសិរលាភីតិ ។
ឥធាហំ ព្រាហ្មណ យំ គាមំ វា និគមំ វា ឧបនិស្សាយ
វិហរាមិ សោ បុព្វណ្ហសមយំ និវាសេត្វា
បត្តចីវរមាទាយ តមេវ គាមំ វា និគមំ វា បិណ្ឌាយ
បវិសាមិ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ វនន្តំ-
យេវ បចារយាមិ សោ យទេវ តត្ថ ហោន្តិ តិណានិ
វា បណ្ណានិ វា តានិ ឯកជ្ឈំ សង្ឃរិត្វា និសីទាមិ
បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ
សតឹ ឧបដ្ឋបេត្វា សោ មេត្តាសហគតេន ចេតសា
ឯកំ ទិសំ ផរិត្វា វិហរាមិ តថា ទុតិយំ តថា តតិយំ
តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្ត-
តាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា
វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យា-
បជ្ឈេន ផរិត្វា វិហរាមិ ករុណាសហគតេន ចេតសា...

បពិត្រព្រះគោតមដ៏ចម្រើន ឥឡូវ ព្រះគោតមដ៏ចម្រើន ទ្រង់បានតាមសេចក្ដីប្រាថ្នា បានដោយងាយ បានដោយមិនលំបាកនូវទីដេកដ៏ខ្ពស់និងទីអង្គុយដ៏ប្រសើរ ជារបស់ព្រហ្មនោះ តើដូចម្ដេច ។ ម្នាលព្រាហ្មណ៍ ក្នុងទីឯណោះ តថាគតចូលទៅអាស្រ័យស្រុក ឬនិគមណា តថាគតស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ស្រុកនិងនិគមនោះឯង ដើម្បីបិណ្ឌបាត កាលតថាគតនោះត្រឡប់ពីបិណ្ឌបាត ក្នុងបច្ឆាភត្តហើយចូលទៅក្នុងដងព្រៃ តថាគតនោះបានប្រមូលនូវស្មៅ ឬស្លឹកឈើទាំងនោះ ដែលមានក្នុងដងព្រៃនោះ ឲ្យតម្កល់នៅមួយកន្លែង ហើយអង្គុយពែនភ្នែនតម្កល់កាយឲ្យត្រង់ប្រុងសតិឲ្យមានមុខឆ្ពោះទៅកាន់កម្មដ្ឋាន តថាគតនោះ មានចិត្តប្រកបដោយមេត្តាទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ និងទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូចៗ មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ដោយអាការទាំងពួង ក្នុងទីទាំងពួង មានចិត្តប្រកបដោយករុណា...

មុទិតាសហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរាមិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរាមិ ។ សោ ចេ អហំ ព្រាហ្មណ ឯវម្ភូតោ ចង្កមាមិ ព្រហ្មា មេ ឯសោ តស្មឹ សមយេ ចង្កមោ ហោតិ សោ ចេ អហំ ព្រាហ្មណ ឯវម្ភូតោ តិដ្ឋាមិ... និសីទាមិ... សេយ្យំ កប្បេមិ ព្រហ្មំ មេ ឯតំ តស្មឹ សមយេ ឧច្ចា-សយនមហាសយនំ ហោតិ ។ ឥទំ ខោ តំ ព្រាហ្មណ ព្រហ្មំ ឧច្ចាសយនមហាសយនំ យស្សាហំ ឯតរហិ និកាមលាភី អកិច្ឆលាភី អកសិរលាភីតិ ។ អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម

មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ និងទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូចៗ មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ដោយអាការទាំងពួង ក្នុងទីទាំងពួង ។ ម្នាលព្រាហ្មណ៍ បើតថាគតនោះចង្រ្កមយ៉ាងនេះ ទីចង្រ្កមដ៏ប្រសើរ រមែងមានដល់តថាគត ក្នុងសម័យនោះ ម្នាលព្រាហ្មណ៍ បើតថាគតនោះឈរយ៉ាងនេះ... អង្គុយ... សម្រេចនូវសំណឹងសំណឹងដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរជារបស់ព្រហ្មនោះ រមែងមានដល់តថាគតក្នុងសម័យនោះ ។ ម្នាលព្រាហ្មណ៍ តថាគតជាអ្នកបានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិនលំបាក នូវសំណឹងដ៏ខ្ពស់និងអង្គុយទីដ៏ប្រសើរ ជារបស់ព្រហ្មនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកណាស់

កោ ចញ្ញោ ឯវរូបស្ស ព្រហ្មស្ស ឧច្ចាសយនមហា-
សយនស្ស និកាមលាភី ភវិស្សតិ អកិច្ឆលាភី
អកសិរលាភី អញ្ញត្រ ភោតា គោតមេន ។ កតមំ
បន តំ ភោ គោតម អរិយំ ឧច្ចាសយនមហា-
សយនំ យស្ស ភវំ គោតមោ ឯតរហិ និកាម-
លាភី អកិច្ឆលាភី អកសិរលាភីតិ ។ ឥធាហំ
ព្រាហ្មណ យំ គាមំ វា និគមំ វា ឧបនិស្សាយ
វិហរាមិ សោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរ-
មាទាយ តមេវ គាមំ វា និគមំ វា បិណ្ឌាយ បវិសាមិ
សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ វនន្តំយេវ
បចារយាមិ សោ យទេវ តត្ថ ហោន្តិ តិណានិ វា
បណ្ណានិ វា តានិ ឯកជ្ឈំ សង្ឃរិត្វា និសីទាមិ
បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ
សតឹ ឧបដ្ឋបេត្វា សោ ឯវំ បជានាមិ រាគោ មេ
បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ

តើមានបុគ្គលដទៃឯណា នឹងបានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិនលំបាក នូវសំណឹងដ៏ខ្ពស់និងទីអង្គុយដ៏ប្រសើរ ជារបស់ព្រហ្ម មានសភាពយ៉ាងនេះ លើកលែងតែព្រះគោតមដ៏ចម្រើនចេញ ។ បពិត្រព្រះគោតមដ៏ចម្រើន ឥឡូវ ព្រះគោតមដ៏ចម្រើន បានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិនលំបាក នូវសំណឹងដ៏ខ្ពស់និងទីអង្គុយដ៏ប្រសើរ ជារបស់អរិយៈដូចម្តេច ។ ម្នាលព្រាហ្មណ៍ ក្នុងទីឯណោះ តថាគតនោះ ចូលទៅអាស្រ័យនូវស្រុកឬនិគមណា តថាគតនោះ ស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ស្រុកឬនិគមនោះឯង ដើម្បីបិណ្ឌបាត កាលតថាគតនោះ ត្រឡប់ពីបិណ្ឌបាតក្នុងបច្ឆាភត្ត ចូលទៅកាន់ដងព្រៃ តថាគតនោះ ប្រមូលនូវស្មៅឬស្លឹកឈើទាំងនោះ ក្នុងដងព្រៃនោះឲ្យតាំងនៅក្នុងទី ១ ហើយអង្គុយពែនភ្នែន តម្កល់កាយឲ្យត្រង់ប្រុងស្មារតីឆ្ពោះទៅកាន់កម្មដ្ឋាន តថាគតនោះ ដឹងយ៉ាងនេះថា រាគៈតថាគត បានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត

២០៧

## ទុតិយបណ្ណាសកេ មហាវគ្គោ

អាយតឹអនុប្បាទធម្មោ ទោសោ មេ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ មោហោ មេ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ ។ សោ ចេ អហំ ព្រាហ្មណ ឯវម្ភូតោ ចង្កមាមិ អរិយោ មេ ឯសោ តស្មឹ សមយេ ចង្កមោ ហោតិ សោ ចេ អហំ ព្រាហ្មណ ឯវម្ភូតោ តិដ្ឋាមិ... និសីទាមិ... សេយ្យំ កប្បេមិ អរិយំ មេ ឯតំ តស្មឹ សមយេ ឧច្ចាសយនមហាសយនំ ហោតិ ។ ឥទំ ខោ តំ ព្រាហ្មណ អរិយំ ឧច្ចាសយនមហាសយនំ យស្សាហំ ឯតរហិ និកាមលាភី អកិច្ឆលាភី អកសិរលាភីតិ ។ អច្ឆរិយំ ភោ គោតម អព្ភុតំ ភោ គោតម កោ ចញ្ញោ

ជាសភាវៈដល់នូវការសាបសូន្យ មានសភាពមិនកើតឡើងតទៅឡើយ ទោសៈតថាគត បានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការសាបសូន្យ មានសភាពមិនកើតឡើងតទៅ មោហៈតថាគតបានលះបង់ហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការសាបសូន្យ មានសភាពមិនកើតឡើងតទៅឡើយ ។ ម្នាលព្រាហ្មណ៍ បើតថាគតនោះ ចង្រ្កមមានសភាពយ៉ាងនេះ ទីចង្រ្កមជារបស់អរិយៈនុ៎ះ រមែងមានដល់តថាគតក្នុងសម័យនោះ ម្នាលព្រាហ្មណ៍ បើតថាគតនោះឈរ មានសភាពយ៉ាងនេះ... អង្គុយ... សម្រេចនូវសំណឹង សំណឹងដ៏ខ្ពស់និងទីអង្គុយដ៏ប្រសើរ ជារបស់អរិយៈនុ៎ះ រមែងមានដល់តថាគតក្នុងសម័យនោះ ។ ម្នាលព្រាហ្មណ៍ តថាគតជាអ្នកបានតាមសេចក្តីប្រាថ្នា បានដោយងាយ បានដោយមិនលំបាក នូវសំណឹងដ៏ខ្ពស់ និងទីអង្គុយដ៏ប្រសើរជារបស់អរិយៈនេះឯង ។ បពិត្រព្រះគោតមដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះគោតមដ៏ចម្រើន ចម្លែកណាស់ តើមានបុគ្គលដទៃឯណា

ឯវរូបស្ស អរិយស្ស ឧច្ចាសយនមហាសយនស្ស និកាមលាភី ភវិស្សតិ អកិច្ឆលាភី អកសិរលាភី អញ្ញត្រ ភោតា គោតមេន ។ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ។ ឯតេ មយំ ភវន្តំ គោតមំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណំ គតេតិ ។

[៦៦] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ តេន ខោ បន សមយេន សរភោ នាម បរិព្វាជកោ អចិរបក្កន្តោ ហោតិ ឥមស្មា ធម្មវិនយា សោ រាជគហេ បរិសតិ ឯវំ វាចំ ភាសតិ

នឹងបានតាមសេចក្ដីប្រាថ្នា បានដោយងាយ បានដោយមិនលំបាកនូវសំណឹងដ៏ខ្ពស់និងទីអន្តុយដ៏ប្រសើរ ជារបស់អរិយៈ មានសភាពយ៉ាងនេះ លើកលែងតែព្រះគោតមដ៏ចម្រើនចេញ ។ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ដូចជាបុគ្គលផ្ងាររបស់ដែលគេផ្កាប់ ឬបើករបស់ដែលគេបិទបាំង ពុំនោះក៏ដូចគេប្រាប់ផ្លូវ ដល់បុគ្គលអ្នកវង្វេងទិស ពុំនោះសោតដូចគេទ្រោលបំភ្លឺប្រទីបប្រេងក្នុងទីងងឹត ឲ្យបុគ្គលអ្នកមានចក្ខុឃើញនូវរូបទាំងឡាយបាន យ៉ាងណាមិញ ធម៌ដែលព្រះគោតមដ៏ចម្រើនសម្ដែងដោយអនេកបរិយាយក៏យ៉ាងនោះដែរ ។ យើងខ្ញុំព្រះអង្គនេះសូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹង សូមព្រះគោតមដ៏ចម្រើន ទ្រង់ចាំទុកនូវយើងខ្ញុំព្រះអង្គថាជាឧបាសកដល់នូវសរណៈស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមទៅ ។

[៦៦] សម័យមួយ ព្រះមានព្រះភាគគង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង សរភបរិព្វាជក (បួសក្នុងព្រះពុទ្ធសាសនា) ទើបតែនឹង (សឹក) ចាកធម្មវិន័យនេះ បរិព្វាជកនោះ ក៏ពោលពាក្យយ៉ាងនេះ

២០៩



អញ្ញាតោ មយា សមណានំ សក្យបុត្តិយានំ ធម្មោ អញ្ញាយ ច បនាហំ សមណានំ សក្យបុត្តិយានំ ធម្មំ ឯវាហំ តស្មា ធម្មវិនយា អប្បក្កន្តោតិ ។ អថខោ សម្ពហុលា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមា-ទាយ រាជគហំ បិណ្ឌាយ បវិសឹសុ ។ អស្សោសុំ ខោ តេ ភិក្ខូ សរភស្ស បរិព្វាជកស្ស រាជគហេ បរិសតិ ឯវំ វាចំ ភាសមានស្ស អញ្ញាតោ មយា សមណានំ សក្យបុត្តិយានំ ធម្មោ អញ្ញាយ ច បនាហំ សមណានំ សក្យបុត្តិយានំ ធម្មំ ឯវាហំ តស្មា ធម្មវិនយា អប្បក្កន្តោតិ ។ អថខោ តេ ភិក្ខូ រាជគហេ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ភិក្ខូ ភគវន្តំ ឯតទវោចុំ សរភោ នាម ភន្តេ បរិព្វាជកោ អចិរប្បក្កន្តោ ឥមស្មា ធម្មវិនយា សោ រាជគហេ បរិសតិ ឯវំ វាចំ ភាសតិ

ក្នុងបរិសទ្យក្នុងក្រុងរាជគ្រឹះថា ធម៌របស់ពួកសមណសក្យបុត្តិយ៍ អញបានដឹងច្បាស់ហើយ លុះអាត្មាអញ បានដឹងច្បាស់នូវធម៌របស់ពួកសមណសក្យបុត្តិយ៍ហើយ ទើបអាត្មាអញ សឹកចាកធម្មវិន័យនោះ យ៉ាងនេះ ។ លំដាប់នោះឯង ភិក្ខុច្រើនរូប ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ភិក្ខុទាំងនោះ បានស្តាប់នូវវាចាដែលសរភបរិព្វាជក ពោលក្នុងបរិសទ្យក្នុងក្រុងរាជគ្រឹះយ៉ាងនេះថា ធម៌របស់ពួកសមណសក្យបុត្តិយ៍ អញបានដឹងច្បាស់ហើយ លុះអាត្មាអញដឹងច្បាស់ នូវធម៌របស់សមណសក្យបុត្តិយ៍ហើយ ទើបអាត្មាអញសឹកចាកធម្មវិន័យនេះ ។ លំដាប់នោះឯង ភិក្ខុទាំងនោះ ត្រេចទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ កាលត្រឡប់ពីបិណ្ឌបាតក្នុងបច្ឆាភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ បានថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយ ក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយ ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សរភបរិព្វាជក ទើបនឹងសឹកចាកធម្មវិន័យនេះ គាត់ក៏ពោលនូវពាក្យ ក្នុងបរិសទ្យក្នុងក្រុងរាជគ្រឹះ យ៉ាងនេះថា

អញ្ញាតោ មយា សមណានំ សក្យបុត្តិយានំ ធម្មោ អញ្ញាយ ច បនាហំ សមណានំ សក្យបុត្តិយានំ ធម្មំ ឯវាហំ តស្មា ធម្មវិនយា អបក្កន្តោតិ សាធុ ភន្តេ ភគវា យេន សប្បិនិយា តីរំ បរិព្វាជការាមោ យេន សរភោ បរិព្វាជកោ តេនុបសង្កមតុ អនុកម្បំ ឧបាទាយាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន សប្បិ-និយា តីរំ បរិព្វាជការាមោ យេន សរភោ បរិព្វាជកោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា សរភំ បរិព្វាជកំ ឯតទវោច សច្ចំ កិរ ត្វំ សរភ ឯវំ វទេសិ អញ្ញាតោ មយា សមណានំ សក្យបុត្តិយានំ ធម្មោ អញ្ញាយ ច បនាហំ សមណានំ សក្យបុត្តិយានំ ធម្មំ ឯវាហំ តស្មា ធម្មវិនយា អបក្កន្តោតិ ។ ឯវំ វុត្តេ សរភោ បរិព្វាជកោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ភគវា សរភំ បរិព្វាជកំ ឯតទវោច វទេហិ សរភ កិន្តិ

ធម៌របស់ពួកសមណសក្យបុត្តិយ៍ អញបានដឹងច្បាស់ហើយ លុះអាត្មាអញបានដឹងច្បាស់ធម៌របស់ពួកសមណសក្យបុត្តិយ៍ហើយ ទើបអាត្មាអញសឹកចាកធម្មវិន័យនោះយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ចូលទៅជួបនឹងសរភបរិព្វាជក ក្នុងបរិព្វាជការាម ក្បែរឆ្នេរស្ទឹងឈ្មោះសប្បិនី ដោយសេចក្តីអនុគ្រោះ ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ចេញចាកទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅជួបនឹងសរភ-បរិព្វាជក ក្នុងបរិព្វាជការាម ក្បែរឆ្នេរស្ទឹងឈ្មោះសប្បិនី លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគគង់ហើយ បានត្រាស់ទៅនឹងសរភបរិព្វាជកដូច្នេះថា ម្នាលសរភៈ ឮថា អ្នកនិយាយយ៉ាងនេះថា ធម៌របស់ពួកសមណសក្យបុត្តិយ៍អាត្មាអញបានដឹងច្បាស់ហើយ លុះអាត្មាអញបានដឹងច្បាស់ធម៌របស់ពួកសមណសក្យបុត្តិយ៍ហើយ ទើបអាត្មាអញសឹកចាកធម្មវិន័យនោះយ៉ាងនេះពិតមែនឬ ។ កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ សរភ-បរិព្វាជកក៏នៅស្ងៀម ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ទៅនឹងសរភ-បរិព្វាជកអស់វារៈ២ ដងថា ម្នាលសរភៈ អ្នកចូរនិយាយទៅមើលថាដូចម្តេច

តេ អញ្ញាតោ សមណានំ សក្យបុត្តិយានំ ធម្មោ សចេ តេ អបរិប្ចូរំ ករិស្សតិ អហំ បរិបូរេស្សាមិ សចេ បន តេ បរិប្ចូរំ ករិស្សតិ អហំ អនុមោទិស្សាមីតិ ។ ទុតិយម្បិ ខោ សរភោ បរិព្វាជកោ តុណ្ហី អហោសិ ។ តតិយម្បិ ខោ ភគវា សរភំ បរិព្វាជកំ ឯតទវោច ឲយា ខោ សរភ បញ្ញាយតិ សមណានំ សក្យបុត្តិយានំ ធម្មោ វទេហិ សរភ កិន្តិ តេ អញ្ញាតោ សមណានំ សក្យបុត្តិយានំ ធម្មោ សចេ តេ អបរិប្ចូរំ ករិស្សតិ អហំ បរិបូរេស្សាមិ សចេ បន តេ បរិប្ចូរំ ករិស្សតិ អហំ អនុមោទិស្សាមីតិ ។ តតិយម្បិ ខោ សរភោ បរិព្វាជកោ តុណ្ហី អហោសិ ។ អថខោ តេ បរិព្វាជកា សរភំ បរិព្វាជកំ ឯតទវោចុំ យទេវ ខោ ត្វំ អាវុសោ សរភ សមណំ គោតមំ យាចេយ្យាសិ តទេវ តេ សមណោ គោតមោ បវារេតិ វទេហិ អាវុសោ សរភ កិន្តិ តេ អញ្ញាតោ សមណានំ សក្យបុត្តិយានំ ធម្មោ សចេ តេ អបរិប្ចូរំ ករិស្សតិ សមណោ គោតមោ

ធម៌របស់ពួកសមណសក្យបុត្តិយ៍អ្នកបានដឹងហើយ ប្រសិនបើមិនទាន់គ្រប់គ្រាន់ដល់អ្នកទេ តថាគតនឹងបំពេញឲ្យ តែបើគ្រប់គ្រាន់ដល់អ្នកហើយ តថាគតនឹងអនុមោទនា ។ សរភបរិព្វាជកក៏ស្ងៀមអស់វារៈ ២ ដង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ទៅនឹងសរភបរិព្វាជក អស់វារៈ ៣ ដងទៀតថា ម្នាលសរភៈ ធម៌របស់ពួកសមណសក្យបុត្តិយ៍មានតែតថាគតទើបឲ្យប្រាកដបានថា ម្នាលសរភៈ អ្នកចូរនិយាយទៅមើលថា ដូចម្ដេច ធម៌របស់ពួកសមណសក្យបុត្តិយ៍ដែលអ្នកបានដឹងហើយ ប្រសិនបើមិនទាន់គ្រប់គ្រាន់ដល់អ្នកទេ តថាគតនឹងបំពេញឲ្យ តែបើគ្រប់គ្រាន់ដល់អ្នកហើយ តថាគតនឹងអនុមោទនា ។ សរភបរិព្វាជកក៏ស្ងៀម អស់វារៈ ៣ ដង ។ លំដាប់នោះ បរិព្វាជកទាំងនោះបាននិយាយទៅនឹងសរភបរិព្វាជកដូច្នេះថា ម្នាលអាវុសោសរភៈ អ្នកគប្បីសូមនូវវត្ថុណាចំពោះព្រះសមណគោតម ឯព្រះសមណគោតម ទ្រង់បវារណាវត្ថុនោះឯងដល់អ្នក ម្នាលអាវុសោសរភៈ អ្នកចូរនិយាយទៅមើលថា ដូចម្ដេច ធម៌របស់ពួកសមណសក្យបុត្តិយ៍អ្នកបានដឹងហើយ ប្រសិនបើមិនទាន់គ្រប់គ្រាន់ដល់អ្នកទេ ព្រះសមណគោតម

បរិបូរេស្សតិ សចេ បន តេ បរិបូរំ ករិស្សតិ សមណោ គោតមោ អនុមោទិស្សតីតិ ។ ឯវំ វុត្តេ សរភោ បរិព្វាជកោ តុណ្ហីភូតោ មង្កុភូតោ បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិភាណោ និសីទិ ។ អថខោ ភគវា សរភំ បរិព្វាជកំ តុណ្ហីភូតំ មង្កុភូតំ បត្តក្ខន្ធំ អធោមុខំ បជ្ឈាយន្តំ អប្បដិភាណំ វិទិត្វា តេ បរិព្វាជកេ ឯតទវោច យោ ខោ មំ បរិព្វាជកា ឯវំ វទេយ្យ សម្មាសម្ពុទ្ធស្ស តេ បដិជានតោ ឥមេ ធម្មា អនភិសម្ពុទ្ធាតិ តមហំ តត្ថ សាធុកំ សមនុយុញ្ជេយ្យំ សមនុគ្គាហេយ្យំ សមនុភាសេយ្យំ សោ វត មយា សាធុកំ សមនុយុញ្ជិយមានោ សមនុគ្គាហិយមានោ សមនុភាសិយមានោ អដ្ឋានមេតំ អនវកាសោ យំ សោ តិណ្ណំ ឋានានំ នាញ្ញតរំ ឋានំ និគច្ឆេយ្យ អញ្ញេន វា អញ្ញំ បដិចរិស្សតិ ពហិទ្ធា កថំ អបនាមេស្សតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករិស្សតិ តុណ្ហីភូតោ វា មង្កុភូតោ

នឹងបំពេញឲ្យ តែបើគ្រប់គ្រាន់ដល់អ្នកហើយ ព្រះសមណគោតម នឹងទទួលអនុមោទនា ។ កាលបរិព្វាជកទាំងនោះនិយាយ យ៉ាងនេះហើយ សរភបរិព្វាជកក៏នៅស្ងៀម មានមុខសំយុងចុះ មានកឱនចុះ មានមុខជ្រប់ចុះ ស្រពោនមុខ រកនិយាយតបតមកវិញមិនរួចឡើយ ក៏អង្គុយទៅ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបថា សរភបរិព្វាជកនៅស្ងៀម មានមុខសំយុងចុះ មានកឱនចុះ មានមុខជ្រប់ចុះ ស្រពោន មិននិយាយតបហើយ ក៏ទ្រង់ត្រាស់ទៅនឹងបរិព្វាជកទាំងនោះដូច្នេះថា ម្នាលបរិព្វាជកទាំងឡាយ បុគ្គលណា ពោលចំពោះតថាគតយ៉ាងនេះថា ធម៌ទាំងនេះ ដែលព្រះអង្គជាសម្មាសម្ពុទ្ធ គ្រាន់តែប្តេជ្ញា មិនទាន់បានត្រាស់ដឹងទេ តថាគត គប្បីសាកសួរ ដេញដោល ឈ្វេចឈ្វីមែនទែនចំពោះបុគ្គលនោះ ក្នុងពាក្យដែលតថាគត បានសម្តែងហើយនោះ បុគ្គលនោះឯង កាលបើត្រូវតថាគត សាកសួរ ដេញដោល ឈ្វេចឈ្វីមែនទែនក៏ឥតមានហេតុ ឥតមានឱកាស គួរនឹងឲ្យបុគ្គលនោះមិនដល់នូវឋានៈ ៣ ឋានៈណាមួយ គឺបំបិទពាក្យដទៃ ដោយពាក្យដទៃ ឬនាំពាក្យពីខាងក្រៅចេញ ១ បញ្ចេញនូវសេចក្តីក្រោធផង នូវទោសៈផង នូវអាការមិនត្រេកអរផង ១ មានសភាពស្ងៀម មានមុខសំយុងចុះ

២១៣



បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិភាណោ និសីទិស្សតិ សេយ្យថាបិ សរកោ បរិព្វាជកោ ។ យោ ខោ មំ បរិព្វាជកោ ឯវំ វទេយ្យ ខីណាសវស្ស តេ បដិជានតោ ឥមេ អាសវា អបរិក្ខីណាតិ តមហំ តត្ថ សាធុកំ សមនុយុញ្ជេយ្យំ សមនុគ្គាហេយ្យំ សមនុភាសេយ្យំ សោ វត មយា សាធុកំ សមនុយុញ្ជិយមានោ សមនុគ្គាហិយមានោ សមនុភាសិយមានោ អដ្ឋានមេតំ អនវកាសោ យំ សោ តិណ្ណំ ឋានានំ អញ្ញតរំ ឋានំ និគច្ឆេយ្យ អញ្ញេន វា អញ្ញំ បដិចរិស្សតិ ពហិទ្ធា កថំ អបនាមេស្សតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករិស្សតិ តុណ្ហីភូតោ វា មង្កុភូតោ បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិភាណោ និសីទិស្សតិ សេយ្យថាបិ សរកោ បរិព្វាជកោ ។ យោ ខោ មំ បរិព្វាជកោ ឯវំ វទេយ្យ យស្ស ខោ បន តេ អត្ថាយ ធម្មោ ទេសិតោ សោ ន និយ្យាតិ

មានកឱនចុះ មានមុខជ្រប់ចុះ ស្រពោន រកនិយាយតបតមកវិញមិនរួច នឹងអង្គុយនៅ ១ ដូចជាសរភបរិញ្វាជក ។ ម្នាលបរិញ្វាជកទាំងឡាយ បុគ្គលណាគប្បីពោល ចំពោះតថាគត យ៉ាងនេះថា អាសវៈទាំងនេះ ដែលព្រះអង្គជាខីណាសវៈគ្រាន់តែប្តេជ្ញា មិនទាន់បានអស់រលីងទេ តថាគតគប្បីសាកសួរ ដេញដោល ឈ្លេចឈ្លីមែនទែន ចំពោះបុគ្គលនោះក្នុងពាក្យដែលតថាគតសម្តែងហើយនោះ បុគ្គលនោះឯង កាលបើត្រូវតថាគតសាក-សួរ ដេញដោល ឈ្លេចឈ្លីមែនទែនក៏ឥតមានហេតុឥតមានឱកាស គួរនឹងឲ្យបុគ្គលនោះ មិនដល់នូវឋានៈ ៣ ឋានៈណាមួយ គឺបំបិទពាក្យដទៃដោយពាក្យដទៃ ឬនាំពាក្យខាងក្រៅចេញ ១ បញ្ចេញនូវសេចក្តីក្រោធផង នូវទោសៈផង នូវអាការមិនត្រេកអរផង ១ មានសភាពស្ងៀម មានមុខសំយុងចុះ មានកឱនចុះ មានមុខជ្រប់ចុះ ស្រពោន រកនិយាយតបតមកវិញមិនរួច នឹងអង្គុយនៅ ១ ដូចជាសរភបរិញ្វាជក ។ ម្នាលបរិញ្វាជកទាំងឡាយ បុគ្គលណាគប្បីពោលចំពោះតថាគតយ៉ាងនេះថា ធម៌គឺសច្ចៈ ៤ ដែលព្រះអង្គសម្តែងហើយ ដើម្បីប្រយោជន៍ដល់មគ្គនិងផលណា ធម៌នោះមិនប្រព្រឹត្តទៅ

២១៤



តក្ការស្ស សម្មាទុក្ខក្ខយាយាតិ តមហំ តត្ថ សាធុកំ សមនុយុញ្ជេយ្យំ សមនុគ្គាហេយ្យំ សមនុភាសេយ្យំ សោ វត មយា សាធុកំ សមនុយុញ្ជិយមានោ សមនុគ្គាហិយមានោ សមនុភាសិយមានោ អដ្ឋានមេតំ អនវកាសោ យំ សោ តិណ្ណំ ឋានានំ អញ្ញតរំ ឋានំ និគច្ឆេយ្យ អញ្ញេន វា អញ្ញំ បដិចរិស្សតិ ពហិទ្ធា កថំ អបនាមេស្សតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករិស្សតិ តុណ្ហីភូតោ វា មង្កុភូតោ បត្តក្ខន្ធោ អធោមុខោ បជ្ឈាយន្តោ អប្បដិភាណោ និសីទិស្សតិ សេយ្យថាបិ សរភោ បរិព្វាជកោតិ ។ អថខោ ភគវា សប្បិនិយា តីរេ បរិព្វាជការាមេ តិក្ខត្តុំ សីហនាទំ នទិត្វា វេហាសំ បក្កាមិ ។ អថខោ តេ បរិព្វាជកា អចិរបក្កន្តស្ស ភគវតោ សរភំ បរិព្វាជកំ សមន្តតោ វាចាយ សន្និតោទកេន សញ្ជម្ភរឹ អកំសុ សេយ្យថាបិ អាវុសោ សរភ ព្រហារញ្ញេ ជរសិគាលោ សីហនាទំ នទិស្សាមីតិ

ដើម្បីឲ្យអស់ទៅនៃទុក្ខដោយប្រពៃដល់បុគ្គលអ្នកធ្វើ ដើម្បីមគ្គផលនោះទេ តថាគតគប្បីសាកសួរ ដេញដោល ឈ្វេចឈ្វីមែនទែនចំពោះបុគ្គលនោះ ក្នុងធម៌ដែលតថាគតសម្តែងហើយ បុគ្គលនោះឯង កាលបើត្រូវតថាគត សាកសួរ ដេញដោល ឈ្វេចឈ្វីមែនទែន ក៏ឥតមានហេតុឥតមានឱកាស គួរនឹងឲ្យបុគ្គលនោះមិនដល់នូវឋានៈ ៣ ឋានៈ ណាមួយ គឺបំបិទពាក្យ ដទៃដោយពាក្យដទៃឬនាំពាក្យខាងក្រៅចេញ ១ បញ្ចេញនូវសេចក្តីក្រោធ ផង នូវទោសៈផង នូវអាការមិនត្រេកអរផង ១ មានសភាពស្ងៀម មានមុខ សំយុងចុះ មានកឱនចុះ មានមុខជ្រប់ចុះ ស្រពោន រកនិយាយតបតមក វិញមិនរួចនឹងអង្គុយនៅ ១ ដូចជាសរភបរិព្វាជក ។ លំដាប់នោះព្រះមាន ព្រះភាគបន្លឺនូវសីហនាទអស់វារៈ ៣ ដង ក្នុងបរិព្វាជការាម ជិតឆ្នេរស្ទឹង សប្បិនី ហើយហោះទៅកាន់វេហាស៍ ។ កាលដែលព្រះមានព្រះភាគ ទ្រង់និមន្តមិនយូរប៉ុន្មាន បរិព្វាជកទាំងនោះ ក៏និយាយចាក់ដោតទៅ នឹងសរភបរិព្វាជកដោយជន្ទ្រញ គឺសម្តីដោយជុំវិញថា ម្នាលអាវុសោ សរភៈ ប្រៀបដូចជាចចកចាស់ក្នុងព្រៃធំ គិតថា អញនឹងបន្លឺនូវសីហនាទ

សេគាលកំយេវ នទតិ ភេរណ្ឌកំយេវ នទតិ ឯវមេវ ខោ ត្វំ អាវុសោ សរភ អញ្ញត្រេវ សមណេន គោតមេន សីហនាទំ នទិស្សាមីតិ សេគាលកំយេវ នទសិ ភេរណ្ឌកំយេវ នទសិ ។ សេយ្យថាបិ អាវុសោ សរភ អម្ពកមទ្ទរី បុស្សករវិតំ[១] រវិស្សាមីតិ អម្ពកមទ្ទរីរវិតំយេវ រវតិ ឯវមេវ ខោ ត្វំ អាវុសោ សរភ អញ្ញត្រេវ សមណេន គោតមេន បុស្សករវិតំ រវិស្សាមីតិ អម្ពកមទ្ទរីរវិតំយេវ រវសិ ។ សេយ្យថាបិ អាវុសោ សរភ ឧសភោ សុញ្ញាយ គោសាលាយ គម្ភីរំ នទិតព្វំ មញ្ញតិ ឯវមេវ ខោ ត្វំ អាវុសោ សរភ អញ្ញត្រេវ សមណេន គោតមេន គម្ភីរំ នទិតព្វំ មញ្ញសីតិ ។ អថខោ តេ បរិព្វាជកា សរភំ បរិព្វាជកំ សមន្តតោ វាចាយ សន្និតោទកេន សញ្ជម្ភរឹ អកំសុតិ ។

---

១ អម្ពុកបច្ចរី បុស្សុករវិកន្តិ ឥទដ្ឋកថា ។ ម. អម្ពុកសញ្ចរី បុរិសករវិតំ ។

ហើយក៏បន្លឺនូវសំឡេងជាសំឡេងចចកដដែល  បន្លឺនូវសំឡេងក៏នៅជាសំឡេងស្អាដដែលយ៉ាងណាមិញ  ម្នាលអាវុសោសរភៈ  អ្នកវៀរចាកព្រះសមណគោតមចេញគិតថា  អញនឹងបន្លឺនូវសីហនាទហើយ  ក៏បន្លឺដូចជាសំឡេងរបស់ចចកដែលបន្លឺនូវសំឡេង ក៏នៅជាសំឡេងស្អាដដែលយ៉ាងនោះដែរ ។ ម្នាលអាវុសោ សរភៈ ប្រៀបដូចជាមាន់ញីគិតថា អញនឹងរងាវឲ្យដូចជាមាន់ឈ្មោលហើយ  ក៏រងាវជាសំឡេងមាន់ញីដដែលយ៉ាងណាមិញ  ម្នាលអាវុសោសរភៈ  អ្នកវៀរចាកព្រះសមណគោតមចេញគិតថា  អញនឹងរងាវឲ្យដូចជាមាន់ឈ្មោលហើយរងាវជាសំឡេងមាន់ញីដដែល យ៉ាងនោះដែរ ។ ម្នាលអាវុសោសរភៈ ប្រៀបដូចគោបា សម្គាល់នូវសំឡេងដែលខ្លួនគប្បីបន្លឺឡើងដ៏ខ្លាំងក្នុងពោងគោ  ដែលមិនមានគោបាយ៉ាងណាមិញ  ម្នាលអាវុសោសរភៈ  អ្នកវៀរចាកព្រះសមណគោតមចេញហើយ  សម្គាល់នូវសំឡេងដែលខ្លួនគប្បីបន្លឺឡើងខ្លាំង  ក៏យ៉ាងនោះដែរ  ។  លំដាប់នោះ  បរិព្វាជកទាំងនោះ  ពោលពាក្យចាក់ដោតចំពោះសរភបរិព្វាជកដោយជន្លួញគឺពាក្យដោយជុំវិញ  ។

[៦៧] ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន កេសបុត្តំ នាម កាលាមានំ និគមោ តទវសរិ ។ អស្សោសុំ ខោ កេសបុត្តិយា កាលាមា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ កេសបុត្តំ អនុប្បត្តោ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ

[៦៧] *សម័យមួយ ព្រះមានព្រះភាគទ្រង់ស្តេចទៅកាន់ចារិក ក្នុងកោសលជនបទជាមួយនឹងភិក្ខុសង្ឃច្រើន ក៏បានទៅដល់និគមឈ្មោះកេសបុត្ររបស់ពួកក្សត្រិយ៍ឈ្មោះកាលាមៈ ។ ពួកកាលាមក្សត្រិយ៍នៅក្នុងកេសបុត្តនិគម បានឮដំណឹងហើយប្រកាសប្រាប់គ្នាថា ម្នាលគ្នាយើងដ៏ចម្រើន បានឮថា ព្រះសមណគោតមជាសក្យបុត្រចេញពីសក្យត្រកូលបួសហើយ បានមកដល់កេសបុត្តនិគម កិត្តិស័ព្ទសរសើរព្រះគោតមដ៏ចម្រើននោះឯង ពីរោះល្បីខ្ទរខ្ទាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្ត ទ្រង់ត្រាស់ដឹងនូវធម៌ទាំងពួងដោយព្រះអង្គឯង ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ប្រសើរជាងសត្វលោក ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ជាសាស្តាចារ្យនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះមានព្រះភាគអង្គនោះ ទ្រង់ធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយព្រះអង្គឯង នូវលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វព្រមទាំងពួកសមណព្រាហ្មណ៍និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយអាចប្រកាសបាន ព្រះអង្គទ្រង់សម្តែងធម៌ ពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង*

សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្ម-
ចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ
អរហតំ ទស្សនំ ហោតីតិ ។ អថខោ កេសបុ-
ត្តិយា កាលាមា យេន ភគវា តេនុបសង្កមឹសុ
ឧបសង្កមិត្វា អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា
ឯកមន្តំ និសីទឹសុ អប្បេកច្ចេ ភគវតា សទ្ធឹ
សម្មោទឹសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា
ឯកមន្តំ និសីទឹសុ អប្បេកច្ចេ យេន ភគវា
តេនញ្ជលិម្បណាមេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ
នាមគោត្តំ សាវេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ
តុណ្ហីភូតា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា
ខោ កេសបុត្តិយា កាលាមា ភគវន្តំ ឯតទវោចុំ
សន្តិ ភន្តេ ឯកេ សមណព្រាហ្មណា កេសបុត្តំ
អាគច្ឆន្តិ តេ សកំយេវ វាទំ ទីបេន្តិ ជោតេន្តិ បរវាទំ
បន ខុំសេន្តិ វម្ភេន្តិ បរិភវន្តិ ឱបបក្ខឹ ករោន្តិ អបរេបិ
ភន្តេ ឯកេ សមណព្រាហ្មណា កេសបុត្តំ អាគច្ឆន្តិ

ព្រះអង្គប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានឃើញបានជួបនឹងព្រះអរហន្តទាំង-ឡាយ មានសភាពដូច្នោះ ជាការប្រពៃពេកណាស់ ។ លំដាប់នោះ ពួកកាលាមក្សត្រិយ៍នៅក្នុងកេសបុត្តនិគម បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ពួកខ្លះក៏ធ្វើសេចក្ដីរីករាយ ជាមួយព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយនិងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ពួកខ្លះប្រណម្យអញ្ជលីចំពោះព្រះមានព្រះភាគអង្គុយក្នុងទីសមគួរ ពួកខ្លះប្រកាសនាមនិងគោត្តអង្គុយក្នុងទីសមគួរ ពួកខ្លះអង្គុយស្ងៀមក្នុងទីសមគួរ ។ លុះពួកកាលាមក្សត្រក្នុងកេសបុត្តនិគម អង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍មួយពួកមកកាន់កេសបុត្តនិគម សមណ-ព្រាហ្មណ៍ទាំងនោះ សម្ដែងប្រកាសនូវវាទៈ គឺលទ្ធិរបស់ខ្លួនឯង បៀតបៀនមើលងាយបង្អាប់បង្អោនលើកទម្លាក់នូវវាទៈរបស់បុគ្គលដទៃ បពិត្រព្រះអង្គដ៏ចម្រើន មានសមណព្រាហ្មណ៍ដទៃមួយពួកទៀត មកកាន់កេសបុត្តនិគម

តេបិ សកំយេវ វាទំ ទីបេន្តិ ជោតេន្តិ បរវាទំ បន ខុំសេន្តិ វម្ភេន្តិ បរិភវន្តិ ឱបបក្ខឹ ករោន្តិ តេសំ នោ ភន្តេ អម្ហាកំ ហោតេវ កង្ខា ហោតិ វិចិកិច្ឆា កោ សុ នាម ឥមេសំ ភវន្តានំ សមណព្រាហ្មណានំ សច្ចំ អាហ កោ មុសាតិ ។ អលំ ហិ វោ កាលាមា កង្ខិតុំ អលំ វិចិកិច្ឆិតុំ កង្ខានិយេវ បន វោ ឋានេ វិចិកិច្ឆា ឧប្បន្នា ។ ឯថ តុម្ហេ កាលាមា មា អនុស្សវេន មា បរម្បរាយ មា ឥតិកិរាយ មា បិដកសម្បទានេន មា តក្កហេតុ មា នយហេតុ[១] មា អាការបរិវិតក្កេន មា ទិដ្ឋិនិជ្ឈានក្ខន្តិយា មា ភព្វរូបតាយ មា សមណោ នោ គរូតិ យទា តុម្ហេ កាលាមា អត្តនា វ ជានេយ្យាថ ឥមេ ធម្មា អកុសលា ឥមេ ធម្មា សាវជ្ជា ឥមេ ធម្មា វិញ្ញុគរហិតា ឥមេ ធម្មា សមត្តា សមាទិន្នា

---

១ ម. មា តក្កគ្គាហេន មា នយគ្គាហេន ។

សមណព្រាហ្មណ៍ទាំងនោះ ក៏សម្តែងប្រកាសនូវវាទៈរបស់ខ្លួនឯង បៀត-បៀនមើលងាយ បង្អាប់បង្អោន លើកទម្លាក់នូវវាទៈរបស់បុគ្គលដទៃដែរ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំទាំងនោះ មានសេចក្តីងឿងឆ្ងល់សង្ស័យពេកណាស់ ចុះបណ្តាសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនេះ អ្នកណានិយាយពិត អ្នកណានិយាយកុហក ។ ម្នាលកាលាមក្សត្រិយ៍ គួរអ្នកទាំងឡាយ ងឿងឆ្ងល់ដែរ គួរសង្ស័យដែរ ព្រោះការងឿងឆ្ងល់និងការសង្ស័យកើតឡើងដល់អ្នកទាំងឡាយក្នុងទីនេះហើយ ។ ម្នាលកាលាមក្សត្រិយ៍ទាំងឡាយ អ្នកចូរមក អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរូយផ្សែផ្សំ កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យសមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថាមានសភាពគួរ (ជឿ) កុំប្រកាន់ដោយគិតថា សមណៈ (នេះ) ជាគ្រូរបស់យើង ម្នាលកាលាម-ក្សត្រិយ៍ កាលណាបើអ្នកទាំងឡាយ ដឹងដោយខ្លួនឯងថា ធម៌ទាំងនេះជាអកុសល ធម៌ទាំងនេះប្រកបដោយទោស ធម៌ទាំងនេះអ្នកប្រាជ្ញតិះដៀល

អហិតាយ ទុក្ខាយ សំវត្តន្តីតិ អថ តុម្ហេ កាលាមា បជហេយ្យាថ ។ តំ កឹ មញ្ញថ កាលាមា លោភោ បុរិសស្ស អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ ហិតាយ វា អហិតាយ វាតិ ។ អហិតាយ ភន្តេ ។ លុទ្ធោ បនាយំ កាលាមា បុរិសបុគ្គលោ លោភេន អភិភូតោ បរិយាទិន្នចិត្តោ បាណម្បិ ហនតិ អទិន្នម្បិ អាទិយតិ បរទារម្បិ គច្ឆតិ មុសាបិ ភណតិ បរម្បិ តថត្តាយ សមាទបេតិ យំស ហោតិ[១] ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ កាលាមា ទោសោ បុរិសស្ស អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ ហិតាយ វា អហិតាយ វាតិ ។ អហិតាយ ភន្តេ ។ ទុដ្ឋោ បនាយំ កាលាមា បុរិសបុគ្គលោ ទោសេន អភិភូតោ បរិយាទិន្នចិត្តោ បាណម្បិ ហនតិ អទិន្នម្បិ អាទិយតិ

១ ម. យំ តស្ស បហោតិ ។

ធម៌ទាំងនេះ  បុគ្គលបានសមាទានពេញលេញហើយ  រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ម្នាលកាលាមក្សត្រិយ៍ទាំងឡាយក្នុងកាលនោះ  អ្នកទាំងឡាយត្រូវលះបង់ចោលចេញ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់នូវហេតុនោះដូចម្តេច លោភៈកាលកើតឡើង ក៏កើតឡើងក្នុងសន្តានរបស់បុរស ដើម្បីជាប្រយោជន៍ឬ ដើម្បីមិនជាប្រយោជន៍ទេ  ។  បពិត្រព្រះអង្គដ៏ចម្រើន  ដើម្បីមិនជាប្រយោជន៍ទេ  ។  ម្នាលកាលាមក្សត្រិយ៍  ចុះបុរសបុគ្គលនេះជាអ្នកល្មោភ  ត្រូវសេចក្តីលោភគ្របសង្កត់  មានចិត្តត្រូវសេចក្តីលោភរួបរឹត  រមែងសម្លាប់នូវសត្វមានជីវិតខ្លះកាន់យកនូវទ្រព្យដែលបុគ្គលដទៃមិនបានឲ្យខ្លះ  គប់រកនូវភរិយាអ្នកដទៃខ្លះនិយាយកុហកខ្លះ ដឹកនាំបុគ្គលដទៃដើម្បីហេតុនោះខ្លះ ហេតុនេះប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍  ដើម្បីទុក្ខអស់កាលដ៏អង្វែងដល់បុគ្គលនោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ម្នាលកាលាមក្សត្រិយ៍អ្នកសម្គាល់ហេតុនោះ  ដូចម្តេច  ទោសៈកាលកើតឡើង  ក៏កើតឡើងក្នុងសន្តាននៃបុរស ដើម្បីជាប្រយោជន៍ឬ ដើម្បីមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដើម្បីមិនជាប្រយោជន៍ទេ ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះ ជាអ្នកប្រទូស្ត ត្រូវទោសៈគ្របសង្កត់ មានចិត្តត្រូវទោសៈរួបរឹត  រមែងសម្លាប់នូវសត្វមានជីវិតខ្លះ រមែងកាន់យកទ្រព្យរបស់បុគ្គលដទៃ

បរទារម្បិ គច្ឆតិ មុសាបិ ភណតិ បរម្បិ តថត្តាយ សមាទបេតិ យំស ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ កាលាមា មោហោ បុរិសស្ស អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ ហិតាយ វា អហិតាយ វាតិ ។ អហិតាយ ភន្តេ ។ មូឡ្ហោ បនាយំ កាលាមា បុរិសបុគ្គលោ មោហេន អភិភូតោ បរិយាទិន្នចិត្តោ បាណម្បិ ហនតិ អទិន្នម្បិ អាទិយតិ បរទារម្បិ គច្ឆតិ មុសាបិ ភណតិ បរម្បិ តថត្តាយ សមាទបេតិ យំស ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ កាលាមា ឥមេ ធម្មា កុសលា វា អកុសលា វាតិ ។ អកុសលា ភន្តេ ។ សាវជ្ជា វា អនវជ្ជា វាតិ ។ សាវជ្ជា ភន្តេ ។ វិញ្ញុគរហិតា វា វិញ្ញុប្ប-សត្ថា វាតិ ។ វិញ្ញុគរហិតា ភន្តេ ។ សមត្តា សមាទិន្នា

ដែលគេមិនបានឲ្យខ្លះ គប់រកនូវភរិយាអ្នកដទៃខ្លះ និយាយកុហកខ្លះ ដឹកនាំបុគ្គលដទៃដើម្បីហេតុនោះខ្លះ ហេតុនេះប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលជាអង្វែងដល់បុគ្គលនោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្ដេច មោហៈកាលកើតឡើង ក៏កើតឡើងក្នុងសន្ដាននៃបុរស ដើម្បីជាប្រយោជន៍ ឬ ដើម្បីមិនជាប្រយោជន៍ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ដើម្បីមិនជាប្រយោជន៍ទេ ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះ ជាអ្នកវង្វេងត្រូវមោហៈគ្របសង្កត់ មានចិត្តត្រូវមោហៈរួបរឹត រមែងសម្លាប់សត្វមានជីវិតខ្លះ កាន់យកទ្រព្យរបស់បុគ្គលដទៃដែលគេមិនបានឲ្យខ្លះ គប់រកនូវភរិយាអ្នកដទៃខ្លះ និយាយកុហកខ្លះ បបួលបុគ្គលដទៃដើម្បីហេតុនោះខ្លះ ហេតុនេះប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខអស់កាលជាអង្វែងដល់បុគ្គលនោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងហ្នឹងហើយ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្ដេច ធម៌នេះជាកុសល ឬជាអកុសល ។ ជាអកុសលព្រះអង្គ ។ ជាធម៌ប្រកបដោយទោស ឬ មិនប្រកបដោយទោសទេ ។ ជាធម៌ប្រកបដោយទោសព្រះអង្គ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬ អ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀលព្រះអង្គ ។ ធម៌ទាំងនេះ ដែលបុគ្គលសមាទានពេញលេញហើយ

អហិតាយ ទុក្ខាយ សំវត្តន្តិ នោ វា កថំ វា ឯត្ថ ហោតីតិ ។ សមត្តា ភន្តេ សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តិ ឯវំ នោ ឯត្ថ ហោតីតិ ។ ឥតិ ខោ កាលាមា យន្តំ អវោចុម្ហ ឯថ តុម្ហេ កាលាមា មា អនុស្សវេន មា បរម្បរាយ មា ឥតិកិរាយ មា បិដកសម្បទានេន មា តក្កហេតុ មា នយហេតុ មា អាការបរិវិតក្កេន មា ទិដ្ឋិនិជ្ឈានក្ខន្តិយា មា ភព្វរូបតាយ មា សមណោ នោ គរូតិ យទា តុម្ហេ កាលាមា អត្តនា វ ជានេយ្យាថ ឥមេ ធម្មា អកុសលា ឥមេ ធម្មា សាវជ្ជា ឥមេ ធម្មា វិញ្ញុគរហិតា ឥមេ ធម្មា សមត្តា សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តីតិ អថ តុម្ហេ កាលាមា បជហេយ្យាថាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឯថ តុម្ហេ កាលាមា

រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខឬ មិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនុ៎ះដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះដែលបុគ្គលសមាទានបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ យើងខ្ញុំក៏យល់ក្នុងដំណើរនុ៎ះដូច្នោះដែរ ។ ម្នាលកាលាមក្សត្រិយ៍ តថាគតបានសម្តែងនូវហេតុនោះដូច្នេះហើយថា ម្នាលកាលាក្សត្រិយ៍ អ្នកចូរមក អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរួយផ្សេងៗ កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យថា សមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថាមានសភាពគួរ (ជឿ) កុំប្រកាន់ដោយគិតថា សមណៈ (នេះ) ជាគ្រូរបស់យើង ម្នាលកាលាមក្សត្រិយ៍ កាលណាបើអ្នកដឹងដោយខ្លួនឯងថា ធម៌ទាំងនេះជាអកុសល ធម៌ទាំងនេះប្រកបដោយទោស ធម៌ទាំងនេះដែលអ្នកប្រាជ្ញតិះដៀល ធម៌ទាំងនេះដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ម្នាលកាលាមក្សត្រិយ៍ទាំងឡាយ ក្នុងកាលនោះអ្នកត្រូវលះបង់ចោលចេញ ពាក្យណាដែលតថាគតសម្តែងហើយ ពាក្យនោះតថាគតពោលហើយ ព្រោះអាស្រ័យនូវហេតុនេះដោយប្រការដូច្នេះ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកចូរមក

មា អនុស្សវេន មា បរម្បរាយ មា ឥតិកិរាយ មា បិដកសម្បទានេន មា តក្កហេតុ មា នយហេតុ មា អាការបរិវិតក្កេន មា ទិដ្ឋិនិជ្ឈានក្ខន្តិយា មា ភព្វរូបតាយ មា សមណោ នោ គរូតិ យទា តុម្ហេ កាលាមា អត្តនា វ ជានេយ្យាថ ឥមេ ធម្មា កុសលា ឥមេ ធម្មា អនវជ្ជា ឥមេ ធម្មា វិញ្ញុប្បសត្ថា ឥមេ ធម្មា សមត្តា សមាទិន្នា ហិតាយ សុខាយ សំវត្តន្តីតិ អថ តុម្ហេ កាលាមា ឧបសម្បជ្ជ វិហរេយ្យាថ ។ តំ កឹ មញ្ញថ កាលាមា អលោភោ បុរិសស្ស អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ ហិតាយ វា អហិតាយ វាតិ ។ ហិតាយ ភន្តេ ។ អលុទ្ធោ បនាយំ កាលាមា បុរិសបុគ្គលោ លោភេន អនភិ-ភូតោ អបរិយាទិន្នចិត្តោ នេវ បាណំ ហនតិ ន អទិន្នំ អាទិយតិ ន បរទារំ គច្ឆតិ ន មុសា ភណតិ

អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរួយផ្សេផ្សំ កុំប្រកាន់ដោយគ្រាន់តែត្រិះរិះនូវអាការ កុំប្រកាន់ដោយសេចក្ដីពេញចិត្តតាមការពិនិត្យថាសមនឹងសេចក្ដីយល់ឃើញ កុំប្រកាន់ដោយយល់ថា មានសភាពគួរ (ជឿ) កុំប្រកាន់ដោយគិតថា សមណៈ (នេះ) ជាគ្រូរបស់យើង ម្នាលកាលាមក្សត្រិយ៍ កាលណាបើអ្នកដឹង ដោយខ្លួនឯងថា ធម៌ទាំងនេះជាកុសល ធម៌ទាំងនេះមិនមានទោស ធម៌ទាំងនេះដែលអ្នកប្រាជ្ញសរសើរ ធម៌ទាំងនេះ ដែលបុគ្គលសមាទានពេញលេញហើយ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ម្នាលកាលាមក្សត្រិយ៍ ក្នុងកាលនោះ អ្នកទាំងឡាយចូរដល់នូវធម៌ទាំងនោះហើយនៅ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្ដេច អលោភៈកាលកើតឡើង ក៏កើតក្នុងសន្ដានរបស់បុរស ដើម្បីជាប្រយោជន៍ ឬមិនជាប្រយោជន៍ទេ ។ ដើម្បីជាប្រយោជន៍ព្រះអង្គ ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះ ជាអ្នកមិនល្មោភ មិនត្រូវសេចក្ដីលោភគ្របសង្កត់មានចិត្ត មិនត្រូវសេចក្ដីលោភរួបរឹត មិនសម្លាប់សត្វ មិនកាន់យកនូវទ្រព្យ ដែលគេមិនបានឲ្យ មិនគប់រកភរិយាអ្នកដទៃ មិននិយាយកុហក

បរម្បិ តថត្តាយ សមាទបេតិ យំស ហោតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ កាលាមា អទោសោ បុរិសស្ស អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ ហិតាយ វា អហិតាយ វាតិ ។ ហិតាយ ភន្តេ ។ អទុដ្ឋោ បនាយំ កាលាមា បុរិសបុគ្គលោ ទោសេន អនភិភូតោ អបរិយាទិន្នចិត្តោ នេវ បាណំ ហនតិ ន អទិន្នំ អាទិយតិ ន បរទារំ គច្ឆតិ ន មុសា ភណតិ បរម្បិ តថត្តាយ សមាទបេតិ យំស ហោតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ កាលាមា អមោហោ បុរិសស្ស អជ្ឈត្តំ ឧប្បជ្ជមានោ ឧប្បជ្ជតិ ហិតាយ វា អហិតាយ វាតិ ។ ហិតាយ ភន្តេ ។ អមូឡ្ហោ បនាយំ កាលាមា បុរិសបុគ្គលោ មោហេន អនភិភូតោ អបរិយា-ទិន្នចិត្តោ នេវ បាណំ ហនតិ ន អទិន្នំ អាទិយតិ ន បរទារំ គច្ឆតិ ន មុសា ភណតិ

ទាំងមិនបានដឹកនាំអ្នកដទៃដើម្បីហេតុនោះ តើហេតុនេះ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ដើម្បីសេចក្តីសុខ អស់កាលជាអង្វែងដល់បុគ្គលនោះដែរឬ ។ យ៉ាងហ្នឹងហើយព្រះអង្គ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្តេច អទោសៈកាលកើតឡើង ក៏កើតឡើងក្នុងសន្តានរបស់បុរសដើម្បីជាប្រយោជន៍ ឬដើម្បីមិនជាប្រយោជន៍ទេ ។ ដើម្បីជាប្រយោជន៍ព្រះអង្គ ។ ម្នាលកាលាមក្សត្រិយ៍ ចុះបុរសបុគ្គលនេះជាអ្នកមិនប្រទូស្តមិនត្រូវទោសៈគ្របសង្កត់ មានចិត្តមិនត្រូវទោសៈរួបរឹត មិនសម្លាប់សត្វមិនកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ មិនគប់រកភរិយាអ្នកដទៃ មិននិយាយកុហក ទាំងមិនបានដឹកនាំបុគ្គលដទៃ ដើម្បីហេតុនោះ តើហេតុនេះ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែងដល់បុគ្គលនោះដែរឬ ។ យ៉ាងហ្នឹងហើយព្រះអង្គ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្តេច អមោហៈកាលកើតឡើង ក៏កើតឡើងក្នុងសន្តានរបស់បុរស ដើម្បីជាប្រយោជន៍ ឬដើម្បីមិនជាប្រយោជន៍ទេ ។ ដើម្បីជាប្រយោជន៍ព្រះអង្គ ។ ម្នាលកាលាម-ក្សត្រិយ៍ ចុះបុរសបុគ្គលនេះ ជាអ្នកមិនវង្វេង មិនត្រូវមោហៈគ្របសង្កត់ មានចិត្តមិនត្រូវមោហៈរួបរឹត មិនសម្លាប់សត្វ មិនកាន់យកនូវទ្រព្យដែលគេមិនបានឲ្យ មិនគប់រកភរិយាអ្នកដទៃ មិននិយាយកុហក

បរម្បិ តទត្ថាយ សមាទបេតិ យំស ហោតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ កាលាមា ឥមេ ធម្មា កុសលា វា អកុសលា វាតិ ។ កុសលា ភន្តេ ។ សាវជ្ជា វា អនវជ្ជា វាតិ ។ អនវជ្ជា ភន្តេ ។ វិញ្ញុគរហិតា វា វិញ្ញុប្បសត្ថា វាតិ ។ វិញ្ញុប្បសត្ថា ភន្តេ ។ សមត្តា សមាទិន្នា ហិតាយ សុខាយ សំវត្តន្តិ នោ វា កថំ វា ឯត្ថ ហោតីតិ ។ សមត្តា ភន្តេ សមាទិន្នា ហិតាយ សុខាយ សំវត្តន្តិ ឯវំ នោ ឯត្ថ ហោតីតិ ។ ឥតិ ខោ កាលាមា យន្តំ អវោចុម្ហ ឯថ តុម្ហេ កាលាមា មា អនុស្សវេន មា បរម្បរាយ មា ឥតិកិរាយ មា បិដក-សម្បទានេន មា តក្កហេតុ មា នយហេតុ មា អាការបរិវិតក្កេន មា ទិដ្ឋិនិជ្ឈានក្ខន្តិយា

ទាំងមិនដឹកនាំបុគ្គលដទៃដើម្បីហេតុនោះ តើហេតុនេះប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលអង្វែងដល់បុគ្គលនោះដែរឬ ។ យ៉ាងហ្នឹងហើយព្រះអង្គ ។ ម្នាលកាលាមក្សត្រិយ៍ អ្នកសម្គាល់ហេតុនោះដូចម្តេច ធម៌នេះជាកុសល ឬអកុសល ។ ជាកុសលព្រះអង្គ ។ ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ មិនប្រកបដោយទោសទេ ព្រះអង្គ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬ អ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញសរសើរព្រះអង្គ ។ ធម៌ដែលបុគ្គលសមាទានពេញលេញហើយ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ឬមិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនុ៎ះ ដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ដែលបុគ្គលសមាទានពេញលេញហើយ ប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ យើងខ្ញុំក៏យល់ក្នុងដំណើរនុ៎ះដូច្នោះដែរ ។ ម្នាលកាលាមក្សត្រិយ៍ តថាគតបានសម្តែងនូវហេតុនោះ ដូច្នេះហើយថា ម្នាលកាលាមក្សត្រិយ៍ អ្នកចូរមក អ្នកកុំប្រកាន់ដោយគ្រាន់តែឮតាមគ្នា អ្នកកុំប្រកាន់តាមពាក្យបរម្បរា អ្នកកុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរូយផ្សៃផ្សំ កុំប្រកាន់ដោយត្រិះរិះ តាមអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យថា សមនឹងសេចក្តីយល់ឃើញ

មា ភព្ពរូបតាយ មា សមណោ នោ គរូតិ យទា តុម្ហេ កាលាមា អត្តនា វ ជានេយ្យាថ ឥមេ ធម្មា កុសលា ឥមេ ធម្មា អនវជ្ជា ឥមេ ធម្មា វិញ្ញុប្បសត្ថា ឥមេ ធម្មា សមត្តា សមាទិន្នា ហិតាយ សុខាយ សំវត្តន្តីតិ អថ តុម្ហេ កាលាមា ឧបសម្បជ្ជ វិហរេយ្យាថាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ស ខោ សោ កាលាមា អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អសម្មូឡ្ហោ សម្បជានោ បតិស្សតោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ មេត្តាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ករុណាសហគតេន ចេតសា... មុទិតាសហគតេន ចេតសា... ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ

កុំប្រកាន់ដោយយល់ថា មានសភាពគួរ (ជឿ) កុំប្រកាន់ដោយគិតថា សមណៈ (នេះ) ជាគ្រូរបស់យើង ម្នាលកាលាមក្សត្រិយ៍ កាលណាបើដឹងដោយខ្លួនឯងថា ធម៌នេះជាកុសល ធម៌នេះមិនប្រកបដោយទោស ធម៌នេះដែលអ្នកប្រាជ្ញសរសើរ ធម៌នេះដែលបុគ្គលសមាទានពេញលេញហើយរមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ម្នាលកាលាម-ក្សត្រិយ៍ ក្នុងកាលនោះ អ្នកទាំងឡាយ ចូរដល់នូវធម៌ទាំងនោះហើយនៅ ហេតុនោះ តថាគតបានពោលហើយដោយប្រការដូច្នេះ ពាក្យនុ៎ះតថាគតបានពោលហើយ ព្រោះអាស្រ័យនូវហេតុនេះ ។ ម្នាលកាលាមក្សត្រិយ៍ អរិយសាវ័កនោះឯង មិនមានអភិជ្ឈា មិនមានព្យាបាទ មិនវង្វេង មានសម្បជញ្ញៈ មានសតិយ៉ាងនេះឯង មានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ ទិសទី ៤ ក៏ដូចគ្នា ផ្សាយទៅទិសខាងលើ ទិសខាងក្រោម ទិសទទឹងគឺទិសតូចៗ មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យា-បាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ដោយអាការទាំងពួង ក្នុងទីទាំងពួង មានចិត្តប្រកបដោយករុណា... មានចិត្តប្រកបដោយមុទិតា... មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ ទិសទី ២ ទិសទី ៣ និងទិសទី ៤

ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ឈេន ផរិត្វា វិហរតិ ។ ស ខោ សោ កាលាមា អរិយសាវកោ ឯវំ អវេរចិត្តោ ឯវំ អព្យាបជ្ឈចិត្តោ ឯវំ អសំកិលិដ្ឋចិត្តោ ឯវំ វិសុទ្ធចិត្តោ តស្ស ទិដ្ឋេវ ធម្មេ ចត្តារោ អស្សាសា អធិគតា ហោន្តិ សចេ ខោ បន អត្ថិ បរោ លោកោ អត្ថិ សុកដទុក្កដានំ កម្មានំ ផលវិបាកោ ឋានមេតំ[១] យេនាហំ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ អយមស្ស បឋមោ អស្សាសោ អធិគតោ ហោតិ ។ សចេ ខោ បន នត្ថិ បរោ លោកោ នត្ថិ សុកដទុក្កដានំ កម្មានំ ផលវិបាកោ ឥធាហំ ទិដ្ឋេវ ធម្មេ អវេរំ អព្យាបជ្ឈំ អនីឃំ សុខឹ អត្តានំ បរិហរាមីតិ អយមស្ស ទុតិយោ អស្សាសោ អធិគតោ ហោតិ ។ សចេ ខោ បន ករោតោ ករីយតិ បាបំ

១ ឱ. ឋានមហំ ។ ម. អថាហំ ។

ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោមទិសទទឹងគឺទិសតូចៗ មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវសភាវៈធំ មិនមានប្រមាណ មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងអស់ ដោយអាការទាំងពួង ក្នុងទីទាំងពួង ។ ម្នាលកាលាមក្សត្រិយ៍ អរិយ-សាវ័កនោះឯង មិនមានចិត្តចងពៀរយ៉ាងនេះ មិនមានចិត្តព្យាបាទយ៉ាងនេះ មិនមានចិត្តសៅហ្មងយ៉ាងនេះ មានចិត្តស្អាតយ៉ាងនេះហើយ ជាអ្នកបាននូវអានិសង្ស ៤ យ៉ាង ក្នុងបច្ចុប្បន្ន បើបរលោកមាន ផលនិងវិបាកនៃអំពើទាំងឡាយ ដែលបុគ្គលធ្វើល្អនិងអាក្រក់ក៏មាន លុះអាត្មាអញទម្លាយរាងកាយ ស្លាប់ទៅនឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ដោយហេតុណា ហេតុនោះជាឋានៈ នេះជាអានិសង្សទី ១ ដែលអរិយសាវ័កនោះបានហើយ ។ បើបរលោកមិនមាន ផលនិងវិបាកនៃអំពើដែលបុគ្គលធ្វើល្អនិងធ្វើអាក្រក់ ក៏មិនមាន អាត្មាអញរក្សានូវខ្លួនឲ្យជាបុគ្គលមិនមានពៀរ មិនមានព្យាបាទ មិនមានទុក្ខ មានតែសេចក្តីសុខក្នុងបច្ចុប្បន្ននេះឯង នេះជាអានិសង្សទី ២ ដែលអរិយសាវ័កនោះបានហើយ ។ បើអំពើអាក្រក់ដែលបុគ្គលធ្វើហើយ ឈ្មោះថាបានធ្វើហើយ

២២៧



ន ខោ បនាហំ កស្សចិ បាបំ ចេតេមិ អករោន្តំ ខោ បន មំ បាបកម្មំ កុតោ ទុក្ខំ ផុសិស្សតីតិ[១] អយមស្ស តតិយោ អស្សាសោ អធិគតោ ហោតិ ។ សចេ ខោ បន ករោតោ ន ករិយតិ បាបំ ឥធាហំ ឧភយេនេវ វិសុទ្ធំ អត្តានំ សមនុបស្សាមីតិ អយមស្ស ចតុត្ថោ អស្សាសោ អធិគតោ ហោតិ ។ ស ខោ សោ កាលាមា អរិយសាវកោ ឯវំ អវេរចិត្តោ ឯវំ អព្យាបជ្ឈចិត្តោ ឯវំ អសំកិលិដ្ឋចិត្តោ ឯវំ វិសុទ្ធចិត្តោ តស្ស ទិដ្ឋេវ ធម្មេ ឥមេ ចត្តារោ អស្សាសា អធិគតា ហោន្តីតិ ។ ឯវមេតំ ភគវា ឯវមេតំ សុគត ស ខោ សោ ភន្តេ អរិយសាវកោ ឯវំ អវេរចិត្តោ ឯវំ អព្យាបជ្ឈចិត្តោ ឯវំ អសំកិលិដ្ឋចិត្តោ ឯវំ វិសុទ្ធចិត្តោ តស្ស ទិដ្ឋេវ ធម្មេ ចត្តារោ អស្សាសា អធិគតា ហោន្តិ

---

១ ឱ. ម. ផុស្សតតិ ។

អញមិនដែលគិតនូវអំពើអាក្រក់របស់បុគ្គលណាមួយ សេចក្តីទុក្ខនឹងពាល់ត្រូវនូវអាត្មាអញ ដែលមិនបានធ្វើនូវអំពើអាក្រក់អំពីទីណាបាន នេះជាអានិសង្សទី ៣ ដែលអរិយសាវ័កនោះបានហើយ ។ បើអំពើអាក្រក់ដែលបុគ្គលធ្វើហើយឈ្មោះថាមិនបានធ្វើ អាត្មាអញនឹងពិចារណាឃើញច្បាស់នូវខ្លួនដ៏បរិសុទ្ធ ដោយហេតុទាំងពីរ ក្នុងលោកនេះ នេះជាអានិសង្សទី ៤ ដែលអរិយសាវ័កនោះបានហើយ ។ ម្នាលកាលាមក្សត្រិយ៍ អរិយសាវ័កនោះឯង មិនមានចិត្តប្រកបដោយពៀរយ៉ាងនេះ មិនមានចិត្តព្យាបាទយ៉ាងនេះ មិនមានចិត្តសៅហ្មងយ៉ាងនេះ មានចិត្តបរិសុទ្ធយ៉ាងនេះ នេះជាអានិសង្ស ៤ យ៉ាង ដែលអរិយសាវ័កនោះបានក្នុងបច្ចុប្បន្ន ។ បពិត្រព្រះមានព្រះភាគ ហេតុនុ៎ះយ៉ាងនេះឯង បពិត្រព្រះសុគត ហេតុនុ៎ះយ៉ាងនេះឯង បពិត្រព្រះអង្គដ៏ចម្រើន អរិយសាវ័កនោះឯង មិនមានចិត្តប្រកបដោយពៀរយ៉ាងនេះ មិនមានចិត្តព្យាបាទយ៉ាងនេះ មិនមានចិត្តសៅហ្មងយ៉ាងនេះ មានចិត្តបរិសុទ្ធយ៉ាងនេះ ទើបអរិយសាវ័កនោះ បាននូវអានិសង្ស ៤ យ៉ាង ក្នុងបច្ចុប្បន្ន

សចេ ខោ បន អត្ថិ បរោ លោកោ អត្ថិ សុកដ-ទុក្កដានំ កម្មានំ ផលវិបាកោ ឋានមេតំ យេនាហំ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ អយមស្ស បឋមោ អស្សាសោ អធិគតោ ហោតិ ។ សចេ ខោ បន នត្ថិ បរោ លោកោ នត្ថិ សុកដទុក្កដានំ កម្មានំ ផលវិបាកោ ឥធាហំ ទិដ្ឋេវ ធម្មេ អវេរំ អព្យាបជ្ឈំ អនីឃំ សុខឹ អត្តានំ បរិហ-រាមីតិ អយមស្ស ទុតិយោ អស្សាសោ អធិគតោ ហោតិ ។ សចេ ខោ បន ករោតោ ករិយតិ បាបំ ន ខោ បនាហំ កស្សចិ បាបំ ចេតេមិ អករោន្តំ ខោ បន មំ បាបកម្មំ កុតោ ទុក្ខំ ផុសិស្សតីតិ អយមស្ស តតិយោ អស្សាសោ អធិគតោ ហោតិ ។ សចេ ខោ បន ករោតោ ន ករិយតិ បាបំ ឥធាហំ ឧភយេនេវ វិសុទ្ធំ អត្តានំ សមនុ-បស្សាមីតិ អយមស្ស ចតុត្ថោ អស្សាសោ អធិគតោ ហោតិ ។ ស ខោ សោ ភន្តេ អរិយសាវកោ

បើបរលោកមានផល និងវិបាកនៃអំពើដែលបុគ្គលធ្វើល្អនិងធ្វើអាក្រក់ក៏មាន លុះអាត្មាអញទម្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក ដោយហេតុណា ហេតុនោះជាឋានៈ នេះជាអានិសង្សទី ១ ដែលអរិយសាវ័កនោះបានហើយ ។ បើបរលោកមិនមាន ផលនិងវិបាកនៃអំពើដែលបុគ្គលធ្វើល្អនិងអាក្រក់ក៏មិនមាន អាត្មាអញនឹងរក្សាខ្លួនឲ្យជាបុគ្គលមិនមានពៀរ មិនមានព្យាបាទ មិនមានទុក្ខ មានតែសេចក្តីសុខក្នុងបច្ចុប្បន្ននេះឯង នេះជាអានិសង្សទី ២ ដែលអរិយសាវ័កនោះបានហើយ ។ បើអំពើអាក្រក់ដែលបុគ្គលធ្វើហើយ ឈ្មោះថាបានធ្វើ អាត្មាអញមិនដែលគិតនូវអំពើអាក្រក់របស់បុគ្គលណាមួយឡើយ សេចក្តីទុក្ខនឹងពាល់ត្រូវនូវអាត្មាអញដែលមិនធ្វើអំពើអាក្រក់អំពីទីណាបាន នេះជាអានិ-សង្សទី ៣ ដែលអរិយសាវ័កនោះបានហើយ ។ បើអំពើអាក្រក់ដែលបុគ្គលធ្វើហើយ ឈ្មោះថាមិនបានធ្វើ អាត្មាអញនឹងពិចារណាឃើញច្បាស់នូវខ្លួនដ៏បរិសុទ្ធដោយហេតុទាំង ២ ក្នុងលោកនេះ នេះជាអានិសង្សទី ៤ ដែលអរិយសាវ័កនោះបានហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន អរិយសាវ័កនោះឯង

ឯវំ អវេរចិត្តោ ឯវំ អព្យាបជ្ឈចិត្តោ ឯវំ អសំកិលិដ្ឋចិត្តោ ឯវំ វិសុទ្ធចិត្តោ តស្ស ទិដ្ឋេវ ធម្មេ ឥមេ ចត្តារោ អស្សាសា អធិគតា ហោន្តិ ។ អភិក្កន្តំ ភន្តេ ។ បេ ។ ឯតេ មយំ ភន្តេ ភគវន្តំ សរណំ គច្ឆាម ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកេ នោ ភន្តេ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតេ សរណំ គតេតិ ។

[៦៨] ឯកំ សមយំ អាយស្មា នន្ទកោ សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុបាសាទេ ។ អថខោ សាឡ្ហោ ច មិគារនត្តា រោហណោ ច បេខុណិយនត្តា[១] យេនាយស្មា នន្ទកោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ នន្ទកំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នំ ខោ សាឡ្ហំ មិគារនត្តារំ អាយស្មា នន្ទកោ ឯតទវោច

១ ម. សាណោ ច សេខុនិយនត្តា ។

មិនមានចិត្តប្រកបដោយពៀរយ៉ាងនេះ មិនមានចិត្តព្យាបាទយ៉ាងនេះ មិនមានចិត្តសៅហ្មងយ៉ាងនេះ មានចិត្តបរិសុទ្ធយ៉ាងនេះ នេះជាអានិសង្ស ៤ យ៉ាងដែលអរិយសាវ័កនោះបានក្នុងបច្ចុប្បន្ន ។ បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គទាំងនេះ សូមដល់នូវព្រះមានព្រះភាគផង នូវព្រះធម៌ផង នូវព្រះសង្ឃផង ជាជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ចាំទុកនូវយើងខ្ញុំព្រះអង្គថាជាឧបាសកដល់នូវសរណៈស្មើដោយជីវិត តាំងអំពីថ្ងៃនេះជាដើមតទៅ ។

[៦៨] សម័យមួយ ព្រះនន្ទកៈ មានអាយុ គង់ក្នុងប្រាសាទរបស់មិគារមាតា ក្នុងវត្តបុព្វារាម ទៀបក្រុងសាវត្ថី ។ គ្រានោះសាឡ្ហៈ ជាចៅរបស់មិគារសេដ្ឋីនិងរោហនៈជាចៅរបស់បេខុណិយសេដ្ឋី នាំគ្នាចូលទៅរកព្រះនន្ទកៈមានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះនន្ទកៈមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះសាឡ្ហៈជាចៅរបស់មិគារ-សេដ្ឋី អង្គុយនៅក្នុងទីសមគួរ ព្រះនន្ទកៈមានអាយុបានពោលដូច្នេះថា

ឯថ តុម្ហេ សាឡ្ហា មា អនុស្សវេន មា បរម្បរាយ មា ឥតិកិរាយ មា បិដកសម្បទានេន មា តក្កហេតុ មា នយហេតុ[១] មា អាការបរិវិតក្កេន មា ទិដ្ឋិនិជ្ឈានក្ខន្តិយា មា ភព្វរូបតាយ មា សមណោ នោ គរូតិ យទា តុម្ហេ សាឡ្ហា អត្តនា វ ជានេយ្យាថ ឥមេ ធម្មា អកុសលា ឥមេ ធម្មា សាវជ្ជា ឥមេ ធម្មា វិញ្ញុគរហិតា ឥមេ ធម្មា សមត្តា សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តីតិ អថ តុម្ហេ សាឡ្ហា បជហេយ្យាថ ។ តំ កឹ មញ្ញថ សាឡ្ហា អត្ថិ លោភោតិ ។ ឯវំ ភន្តេ ។ អភិជ្ឈាតិ ខោ អហំ សាឡ្ហា ឯតមត្ថំ វទាមិ ។

---

១ ម. មា តក្កគ្គាហេន មា នយគ្គាហេន ។

ម្នាលសាឡ្ហៈនិងពោហនៈ អ្នកទាំងឡាយចូលមក អ្នកទាំងឡាយ កុំប្រ-កាន់ដោយការឮតៗ គ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយឮថាដូច្នេះ កុំប្រកាន់ដោយការអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរួយផ្សេងៗ កុំប្រកាន់ដោយត្រិះរិះ តាមអាការ កុំប្រកាន់ដោយសេចក្ដីពេញចិត្តតាមការពិនិត្យថា សមនឹងសេចក្ដីយល់ឃើញ កុំប្រកាន់ដោយយល់ថាមានសភាពគួរជឿ កុំប្រកាន់ដោយគិតថាសមណៈ (នេះ) ជាគ្រូរបស់យើងឡើយ ម្នាលសាឡ្ហៈនិងពោហនៈ កាលណាអ្នកទាំងឡាយ ដឹងដោយខ្លួនឯងថា ធម៌ទាំងអម្បាលនេះ ជាអកុសល ធម៌ទាំងអម្បាលនេះ ប្រកបដោយទោស ធម៌ទាំងអម្បាលនេះ ដែលអ្នកប្រាជ្ញតិះដៀល ធម៌ទាំងអម្បាលនេះ ដែលបុគ្គលបានសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្ដីទុក្ខ ម្នាលសាឡ្ហៈនិងពោហនៈ កាលណោះអ្នកទាំងឡាយត្រូវលះចោលចេញ ។ ម្នាលសាឡ្ហៈនិងពោហនៈ អ្នកសម្គាល់សេចក្ដីនោះដូចម្ដេច លោភៈមានដែរឬ ។ សាឡ្ហៈនិងពោហនៈឆ្លើយថា មានដែរលោកម្ចាស់ ។ ម្នាលសាឡ្ហៈនិងពោហនៈ អាត្មាពោលសេចក្ដីនុ៎ះថា លោភៈជាអភិជ្ឈា ។

លុទ្ធោ ខោ អយំ សាឡ្ហា អភិជ្ឈាលុ បាណម្បិ ហនតិ អទិន្នម្បិ អាទិយតិ បរទារម្បិ គច្ឆតិ មុសាបិ ភណតិ បរម្បិ តថត្តាយ សមាទបេតិ យំសហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ សាឡ្ហា អត្ថិ ទោសោតិ ។ ឯវំ ភន្តេ ។ ព្យាបា-ទោតិ ខោ អហំ សាឡ្ហា ឯតមត្ថំ វទាមិ ។ ទុដ្ឋោ ខោ អយំ សាឡ្ហា ព្យាបន្នចិត្តោ បាណម្បិ ហនតិ អទិន្នម្បិ អាទិយតិ បរទារម្បិ គច្ឆតិ មុសាបិ ភណតិ បរម្បិ តថត្តាយ សមាទបេតិ យំសហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ សាឡ្ហា អត្ថិ មោហោតិ ។ ឯវំ ភន្តេ ។ អវិជ្ជាតិ ខោ អហំ សាឡ្ហា ឯតមត្ថំ វទាមិ ។ មូឡ្ហោ ខោ អយំ សាឡ្ហា អវិជ្ជាគតោ បាណម្បិ ហនតិ អទិន្នម្បិ

ម្នាលសាឡ្ហៈនិងរោហនៈ បុគ្គលអ្នកល្មោភច្រើន ដោយអភិជ្ឈានេះ រមែង សម្លាប់សត្វខ្លះ កាន់យករបស់ដែលគេមិនបានឲ្យខ្លះ ប្រព្រឹត្តខុសក្នុងភរិយារបស់អ្នកដទៃខ្លះ ពោលពាក្យកុហកខ្លះ ដឹកនាំអ្នកដទៃដើម្បីអំពើដូច្នោះខ្លះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ និងសេចក្តីទុក្ខអស់កាលជាយូរអង្វែងដល់បុគ្គលនោះមែនឬ ។ មែនលោកម្ចាស់ ។ ម្នាលសាឡ្ហៈនិងរោហនៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ទោសៈមានដែរឬ ។ មានដែរលោកម្ចាស់ ។ ម្នាលសាឡ្ហៈនិងរោហនៈ អាត្មាពោលសេចក្តីនុ៎ះថា ទោសៈជាព្យាបាទ ។ ម្នាលសាឡ្ហៈនឹងរោហនៈ បុគ្គលអ្នកប្រទូស្ត មានចិត្តប្រកបដោយព្យាបាទនេះ តែងសម្លាប់សត្វខ្លះ កាន់យករបស់ដែលគេមិនបានឲ្យខ្លះ គប់រកនូវភរិយារបស់អ្នកដទៃខ្លះ ពោលពាក្យកុហកខ្លះ ដឹកនាំអ្នកដទៃដើម្បីអំពើដូច្នោះខ្លះ ដែលជាហេតុឲ្យប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍និងសេចក្តីទុក្ខអស់កាលជាយូរអង្វែង ដល់បុគ្គលនេះមែនឬ ។ មែនលោកម្ចាស់ ។ ម្នាលសាឡ្ហៈនិងរោហនៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច មោហៈមានដែរឬទេ ។ មានដែរលោកម្ចាស់ ។ ម្នាលសាឡ្ហៈនិងរោហនៈ អាត្មាពោលសេចក្តីនុ៎ះថា មោហៈជាអវិជ្ជា ។ ម្នាលសាឡ្ហៈនិងរោហនៈ បុគ្គលអ្នកវង្វេង ប្រកបដោយអវិជ្ជានេះ រមែងសម្លាប់សត្វខ្លះ កាន់យករបស់ដែលគេមិនបានឲ្យខ្លះ គប់រកនូវភរិយារបស់អ្នកដទៃខ្លះ

អាទិយតិ បរទារម្បិ គច្ឆតិ មុសាបិ ភណតិ បរម្បិ តថត្តាយ សមាទបេតិ យំស ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ សាឡ្ហា ឥមេ ធម្មា កុសលា វា អកុសលា វាតិ ។ អកុសលា ភន្តេ ។ សាវជ្ជា វា អនវជ្ជា វាតិ ។ សាវជ្ជា ភន្តេ ។ វិញ្ញុគរហិតា វា វិញ្ញុប្ប-សត្ថា វាតិ ។ វិញ្ញុគរហិតា ភន្តេ ។ សមត្តា សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តិ នោ វា កថំ វា ឯត្ថ ហោតីតិ ។ សមត្តា ភន្តេ សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តិ ឯវំ នោ ឯត្ថ ហោតីតិ ។ ឥតិ ខោ សាឡ្ហា យន្តំ អវោចុម្ហ ឯថ តុម្ហេ សាឡ្ហា មា អនុស្សវេន មា បរម្បរាយ មា ឥតិកិរាយ

ពោលពាក្យកុហកខ្លះ ដឹកនាំអ្នកដទៃដើម្បីអំពើដូច្នោះខ្លះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីអំពើមិនជាប្រយោជន៍ និងសេចក្តីទុក្ខអស់កាលជាយូរអង្វែងដល់បុគ្គលនោះមែនឬ ។ មែនលោកម្ចាស់ ។ ម្នាលសាឡ្ហៈនិងរោហនៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ធម៌ទាំងអម្បាលនេះ ជាកុសលឬជាអកុសល ។ ជាអកុសលលោកម្ចាស់ ។ ប្រកបដោយទោសឬមិនប្រកបដោយទោស ។ ប្រកបដោយទោសលោកម្ចាស់ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬ ជាធម៌ដែលអ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល លោកម្ចាស់ ។ ជាធម៌ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ឬ មិនមែនទេ ឬ មួយក្នុងដំណើរនុ៎ះ មានប្រការដូចម្តេចទៅវិញ ។ បពិត្រព្រះករុណាដ៏ចម្រើន អកុសលធម៌ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ និងសេចក្តីទុក្ខមែន យើងខ្ញុំយល់យ៉ាងនេះដែរ ក្នុងដំណើរនុ៎ះ ។ ព្រះនន្ទកៈពោលថា ម្នាលសាឡ្ហៈនិងរោហនៈ យើងបានពោលនូវពាក្យណាដូច្នេះយ៉ាងនេះថា ម្នាលសាឡ្ហៈនិងរោហនៈ អ្នកទាំងឡាយ ចូរមក អ្នកទាំងឡាយ កុំប្រកាន់ដោយការឮតៗ គ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ

មា បិដកសម្បទានេន មា តក្កហេតុ មា នយហេតុ មា អាការបរិវិតក្កេន មា ទិដ្ឋិនិជ្ឈា-នក្ខន្តិយា មា ភព្វរូបតាយ មា សមណោ នោ គរូតិ យទា តុម្ហេ សាឡ្ហា អត្តនាវ ជានេយ្យាថ ឥមេ ធម្មា អកុសលា ឥមេ ធម្មា សាវជ្ជា ឥមេ ធម្មា វិញ្ញុគរហិតា ឥមេ ធម្មា សមត្តា សមាទិន្នា អហិតាយ ទុក្ខាយ សំវត្តន្តីតិ អថ តុម្ហេ សាឡ្ហា បជហេយ្យាថាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ឯថ តុម្ហេ សាឡ្ហា មា អនុស្សវេន មា បរម្បរាយ មា ឥតិកិរាយ មា បិដកសម្ប-ទានេន មា តក្កហេតុ មា នយហេតុ មា អាការបរិវិតក្កេន មា ទិដ្ឋិនិជ្ឈានក្ខន្តិយា

កុំប្រកាន់ដោយការអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរូយផ្សេផ្សំ កុំប្រកាន់ដោយត្រិះរិះតាមអាការៈ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យថា សមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថា មានសភាពគួរជឿ កុំប្រកាន់ដោយគិតថាសមណៈ (នេះ) ជាគ្រូរបស់យើងដូច្នេះឡើយ ម្នាលសាឡ្ហៈនិងពោហនៈ កាលណាអ្នកទាំងឡាយដឹងដោយខ្លួនឯងថា ធម៌ទាំងអម្បាលនេះ ជាអកុសល ធម៌ទាំងអម្បាលនេះ ប្រកបដោយទោស ធម៌ទាំងអម្បាលនេះ ដែលអ្នកប្រាជ្ញតិះដៀល ធម៌ទាំងអម្បាលនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយតែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍និងសេចក្តីទុក្ខ ម្នាលសាឡ្ហៈ និងពោហនៈ កាលណោះ អ្នកទាំងឡាយត្រូវលះចោលចេញ ពាក្យណាដែលយើងពោលហើយដូច្នេះ ពាក្យនុ៎ះ យើងបានពោលហើយ ព្រោះអាស្រ័យហេតុនេះ ។ ម្នាលសាឡ្ហៈនិងពោហនៈ អ្នកទាំងឡាយចូរមក អ្នកទាំងឡាយកុំប្រកាន់ដោយការឮតៗ គ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយការអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរូយផ្សេផ្សំ កុំប្រកាន់ដោយត្រិះរិះតាមអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យថា សមនឹងសេចក្តីយល់

មា ភព្វរូបតាយ មា សមណោ នោ គរូតិ យទា តុម្ហេ សាឡ្ហា អត្តនា វ ជានេយ្យាថ ឥមេ ធម្មា កុសលា ឥមេ ធម្មា អនវជ្ជា ឥមេ ធម្មា វិញ្ញុប្បសត្ថា ឥមេ ធម្មា សមត្តា សមាទិន្នា ហិតាយ សុខាយ សំវត្តន្តីតិ អថ តុម្ហេ សាឡ្ហា ឧបសម្បជ្ជ វិហរេយ្យាថ ។ តំ កឹ មញ្ញថ សាឡ្ហា អត្ថិ អលោភោតិ ។ ឯវំ ភន្តេ ។ អនភិជ្ឈាតិ ខោ អហំ សាឡ្ហា ឯតមត្ថំ វទាមិ ។ អលុទ្ធោ ខោ អយំ សាឡ្ហា អនភិជ្ឈាលុ នេវ បាណំ ហនតិ ន អទិន្នំ អាទិយតិ ន បរទារំ គច្ឆតិ ន មុសា ភណាតិ បរម្បិ តថត្តាយ សមាទបេតិ យំស ហោតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ សាឡ្ហា អត្ថិ អទោសោតិ ។

ឃើញ កុំប្រកាន់ដោយយល់ថា មានសភាពគួរជឿ កុំប្រកាន់ដោយគិតថាសមណៈ (នេះ) ជាគ្រូរបស់យើងឡើយ ម្នាលសាឡ្ហៈនិងពោហនៈ កាលណា អ្នកទាំងឡាយដឹងដោយខ្លួនឯងថា ធម៌ទាំងអម្បាលនេះ ជាកុសល ធម៌ទាំងអម្បាលនេះ មិនប្រកបដោយទោស ធម៌ទាំងអម្បាលនេះ ដែលអ្នកប្រាជ្ញសរសើរ ធម៌ទាំងអម្បាលនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍និងសេចក្តីសុខ ម្នាលសាឡ្ហៈនិងពោហនៈ កាលណោះ អ្នកទាំងឡាយ គួរចូលទៅសម្រេចសម្រាន្តនៅចុះ ។ ម្នាលសាឡ្ហៈនិងពោហនៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អលោភៈមានដែរឬ ។ មានដែរលោកម្ចាស់ ។ ម្នាលសាឡ្ហៈនិងពោហនៈ អាត្មាពោលសេចក្តីនុ៎ះថា អលោភៈជាអនភិជ្ឈា (សេចក្តីមិនលោភ) ម្នាលសាឡ្ហៈនិងពោហនៈ បុគ្គលអ្នកមិនល្មោភ មិនមានអភិជ្ឈានេះ រមែងមិនសម្លាប់សត្វ មិនកាន់យកនូវវត្ថុដែលគេមិនបានឲ្យ មិនគប់រកនូវភរិយារបស់អ្នកដទៃ មិនពោលពាក្យកុហក ដឹកនាំអ្នកដទៃដើម្បីអំពើដូច្នោះ ដែលជាហេតុប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍និងសេចក្តីសុខ អស់កាលជាយូរអង្វែងដល់បុគ្គលនោះមែនឬ ។ មែនហើយលោកម្ចាស់ ។ ម្នាលសាឡ្ហៈនិងពោហនៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អទោសៈមានដែរឬ ។

ឯវំ ភន្តេ ។ អព្យាបាទោតិ ខោ អហំ សាឡ្ហា ឯតមត្ថំ វទាមិ ។ អទុដ្ឋោ ខោ អយំ សាឡ្ហា អព្យាបន្នចិត្តោ នេវ បាណំ ហនតិ ន អទិន្នំ អាទិយតិ ន បរទារំ គច្ឆតិ ន មុសា ភណតិ បរម្បិ តថត្តាយ សមាទបេតិ យំស ហោតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ សាឡ្ហា អត្ថិ អមោហោតិ ។ ឯវំ ភន្តេ ។ វិជ្ជាតិ ខោ អហំ សាឡ្ហា ឯតមត្ថំ វទាមិ ។ អមូឡ្ហោ ខោ អយំ សាឡ្ហា វិជ្ជាគតោ នេវ បាណំ ហនតិ ន អទិន្នំ អាទិយតិ ន បរទារំ គច្ឆតិ ន មុសា ភណតិ បរម្បិ តថត្តាយ សមា-ទបេតិ យំស ហោតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឯវំ ភន្តេ ។ តំ កឹ មញ្ញថ សាឡ្ហា ឥមេ ធម្មា កុសលា វា អកុសលា វាតិ ។ កុសលា ភន្តេ ។

មានដែរលោកម្ចាស់ ។ ម្នាលសាឡ្ហៈនិងរោហនៈ អាត្មាពោលសេចក្តីនុ៎ះថា អទោសៈ ជាអព្យាបាទ (សេចក្តីមិនប្រទូស្ត) ។ ម្នាលសាឡ្ហៈនិងរោហនៈ បុគ្គលអ្នកមិនប្រទូស្ត មានចិត្តមិនព្យាបាទនេះ រមែងមិនសម្លាប់សត្វ មិនកាន់យកនូវវត្ថុដែលគេមិនបានឲ្យ មិនគប់រកនូវភរិយារបស់អ្នកដទៃ មិនពោលពាក្យកុហកដឹកនាំអ្នកដទៃដើម្បីអំពើដូច្នោះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍និងសេចក្តីសុខអស់កាលជាយូរអង្វែងដល់បុគ្គលនោះមែនឬ ។ មែនហើយលោកម្ចាស់ ។ ម្នាលសាឡ្ហៈនិងរោហនៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច អមោហៈមានដែរឬ ។ មានដែរលោកម្ចាស់ ។ ម្នាលសាឡ្ហៈនិងរោហនៈ អាត្មាពោលសេចក្តីនោះថា អមោហៈជាវិជ្ជា ។ ម្នាលសាឡ្ហៈនិងរោហនៈ បុគ្គលអ្នកមិនវង្វេងប្រកបដោយវិជ្ជានេះ រមែងមិនសម្លាប់សត្វ មិនកាន់យកនូវវត្ថុដែលគេមិនបានឲ្យ មិនគប់រកនូវភរិយារបស់អ្នកដទៃ មិនពោលពាក្យកុហកដឹកនាំអ្នកដទៃដើម្បីអំពើដូច្នោះ ដែលជាហេតុឲ្យប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍និងសេចក្តីសុខ អស់កាលជាយូរអង្វែង ដល់បុគ្គលនោះមែនឬ ។ មែនហើយលោកម្ចាស់ ។ ម្នាលសាឡ្ហហៈនិងរោហនៈ អ្នកសម្គាល់សេចក្តីនោះដូចម្តេច ធម៌ទាំងអម្បាលនេះ ជាកុសលឬជាអកុសល ។ ជាកុសលលោកម្ចាស់ ។

សាវជ្ជា វា អនវជ្ជា វាតិ ។ អនវជ្ជា ភន្តេ ។ វិញ្ញុ-
គរហិតា វា វិញ្ញុប្បសត្ថា វាតិ ។ វិញ្ញុប្បសត្ថា ភន្តេ ។
សមត្តា សមាទិន្នា ហិតាយ សុខាយ សំវត្តន្តិ នោ
វា កថំ វា ឯត្ថ ហោតីតិ ។ សមត្តា ភន្តេ
សមាទិន្នា ហិតាយ សុខាយ សំវត្តន្តិ ឯវំ នោ
ឯត្ថ ហោតីតិ ។ ឥតិ ខោ សាឡ្ហា យន្តំ អវោចុម្ហ
ឯថ តុម្ហេ សាឡ្ហា មា អនុស្សវេន មា បរម្បរាយ មា
ឥតិកិរាយ មា បិដកសម្បទានេន មា តក្កហេតុ
មា នយហេតុ មា អាការបរិវិតក្កេន មា ទិដ្ឋិនិជ្ឈាន-
ក្ខន្តិយា មា ភព្វរូបតាយ មា សមណោ នោ គរូតិ

ប្រកបដោយទោស ឬមិនប្រកបដោយទោស ។ មិនប្រកបដោយទោសទេ លោកម្ចាស់ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬជាធម៌ដែលអ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញសរសើរ លោកម្ចាស់ ។ ជាធម៌ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ និងសេចក្តីសុខ ឬមិនមែនទេ ឬមួយក្នុងដំណើរនុ៎ះ មានប្រការដូចម្តេចទៅវិញ ។ បពិត្រព្រះករុណាដ៏ចម្រើន ធម៌ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍និងសេចក្តីសុខ យើងខ្ញុំក៏យល់យ៉ាងនេះដែរ ក្នុងដំណើរនុ៎ះ ។ ព្រះនន្ទកៈពោលថា ម្នាលសាឡ្ហៈនិងរោហនៈ យើងបានពោលនូវពាក្យណាដូច្នេះថា ម្នាលសាឡ្ហៈនិងរោហនៈ អ្នកទាំងឡាយចូលមក អ្នកទាំងឡាយ កុំប្រកាន់ដោយការឮតៗ គ្នា កុំប្រកាន់តាមពាក្យបរម្បរា កុំប្រកាន់ដោយបានឮថាដូច្នេះ កុំប្រកាន់ដោយការអាងក្បួនតម្រា កុំប្រកាន់តាមហេតុដែលត្រិះរិះ កុំប្រកាន់ដោយកាត់ដំរូយផ្សែផ្សំ កុំប្រកាន់ដោយត្រិះរិះតាមអាការ កុំប្រកាន់ដោយសេចក្តីពេញចិត្តតាមការពិនិត្យថា សមនឹងសេចក្តីយល់ឃើញ កុំប្រកាន់ដោយយល់ថា មានសភាពគួរជឿ កុំប្រកាន់ដោយគិតថា សមណៈ (នេះ) ជាគ្រូរបស់យើងដូច្នេះឡើយ

២៣៧

ទុតិយបណ្ណាសកេ មហាវគ្គោ

យទា តុម្ហេ សាឡ្ហា អត្តនាវ ជានេយ្យាថ ឥមេ ធម្មា កុសលា ឥមេ ធម្មា អនវជ្ជា ឥមេ ធម្មា វិញ្ញុប្បសត្ថា ឥមេ ធម្មា សមត្តា សមាទិន្នា ហិតាយ សុខាយ សំវត្តន្តីតិ អថ តុម្ហេ សាឡ្ហា ឧបសម្បជ្ជ វិហរេយ្យាថាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។ ស ខោ សោ សាឡ្ហា អរិយសាវកោ ឯវំ វិគតាភិជ្ឈោ វិគតព្យាបាទោ អសម្មូឡ្ហោ សម្បជានោ បតិស្សតោ មេត្តាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ... ករុណាសហគតេន ចេតសា ។ បេ ។ មុទិតាសហគតេន ចេតសា ។ បេ ។ ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា

ម្នាលសាឡ្ហៈនិងរោហនៈ កាលណាអ្នកទាំងឡាយ ដឹងដោយខ្លួនឯងថា ធម៌ទាំងអម្បាលនេះ ជាកុសល ធម៌ទាំងអម្បាលនេះ ប្រកបដោយទោស ធម៌ទាំងអម្បាលនេះ ជាធម៌ដែលអ្នកប្រាជ្ញសរសើរ ធម៌ទាំងអម្បាលនេះ ដែលបុគ្គលសមាទានឲ្យពេញលេញហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ និងសេចក្ដីសុខ ម្នាលសាឡ្ហៈនិងរោហនៈ កាលណោះ អ្នកទាំងឡាយ គួរចូលទៅសម្រេចសម្រាន្តនៅចុះ ពាក្យណាដែលអាត្មាបានពោលហើយដូច្នេះ ពាក្យនុ៎ះ អាត្មាបានពោលទុកហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលសាឡ្ហៈនិងរោហនៈ អរិយសាវកនោះ ប្រាសចាកអភិជ្ឈា ប្រាសចាកព្យាបាទ ជាអ្នកមិនវង្វេង មានសម្បជញ្ញៈ មានសតិតម្កល់ខ្ជាប់យ៉ាងនេះហើយ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ទោះទិសទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា ផ្សាយទៅកាន់ទិសខាងលើ ខាងក្រោមនិងទិសទទឹង ផ្សាយទៅកាន់លោកទាំងអស់ ដោយប្រការទាំងពួងក្នុងទីទាំងពួង... មានចិត្តប្រកបដោយករុណា ។ បេ ។ មានចិត្តប្រកបដោយមុទិតា ។ បេ ។ មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១

វិហរតិ តថា ទុតិយំ តថា តតិយំ តថា ចតុត្ថំ ឥតិ ឧទ្ធមធោ តិរិយំ សព្វធិ សព្វត្តតាយ សព្វាវន្តំ លោកំ ឧបេក្ខាសហគតេន ចេតសា វិបុលេន មហគ្គតេន អប្បមាណេន អវេរេន អព្យាបជ្ជេន ផរិត្វា វិហរតិ ។ សោ ឯវំ បជានាតិ អត្ថិ ឥទំ អត្ថិ ហីនំ អត្ថិ បណីតំ អត្ថិ ឥមស្ស សញ្ញា-គតស្ស ឧត្តរឹ និស្សរណន្តិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ សោ ឯវំ បជានាតិ អហុ បុព្វេ លោភោ តទហុ អកុសលំ សោ ឯតរហិ នត្ថិ ឥច្ចេតំ កុសលំ អហុ បុព្វេ ទោសោ...

ទោះទិសទី ២ ទី ៣ ទី ៤ ក៏ដូចគ្នា មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តធំទូលាយ ដល់នូវសភាពជាធំ រកប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ផ្សាយទៅកាន់លោកទាំងអស់ ដោយប្រការទាំងពួង ក្នុងទីទាំងពួង ។ ព្រះអរិយសាវ័កនោះ ដឹងច្បាស់យ៉ាងនេះថា ទុក្ខសច្ច ក៏មាន សមុទយសច្ច ក៏មាន មគ្គសច្ច ក៏មាន និរោធសច្ចជាគ្រឿងរលាស់ចេញដ៏ក្រៃលែងនូវសញ្ញាក៏មាន ។ កាលព្រះអរិយសាវ័កនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តរមែងរួចចាកកាមាសវៈផង ចិត្តរមែងរួចចាកភវាសវៈផង ចិត្តរមែងរួចចាកអវិជ្ជាសវៈផង កាលបើចិត្តរួចស្រឡះហើយ សេចក្តីដឹងច្បាស់ក៏កើតឡើងថា ចិត្តរួចផុតស្រឡះហើយ ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ព្រះអរិយសាវ័កនោះដឹងច្បាស់យ៉ាងនេះថា លោភៈកើតមានដល់អាត្មាអញក្នុងកាលមុន ធម្មជាតនោះជាអកុសល ឥឡូវនេះ លោភៈនោះមិនមានឡើយ ធម្មជាតនោះឈ្មោះថាជាកុសល ទោសៈកើតមានដល់អាត្មាអញ ក្នុងកាលមុន...

អហុ បុព្វេ មោហោ តទហុ អកុសលំ សោ ឯតរហិ នត្ថិ ឥច្ចេតំ កុសលន្តិ ។ ឥតិ សោ ទិដ្ឋេវ ធម្មេ និច្ឆាតោ និព្វុតោ សីតិភូតោ សុខប្បដិសំវេទី ព្រហ្មភូតេន អត្តនា វិហរតីតិ ។

[៦៩] តីណិមានិ ភិក្ខវេ កថាវត្ថូនិ ។ កតមានិ តីណិ ។ អតីតំ វា ភិក្ខវេ អទ្ធានំ អារព្ភ កថំ កថេយ្យ ឯវំ អហោសិ អតីតមទ្ធានន្តិ អនាគតំ វា ភិក្ខវេ អទ្ធានំ អារព្ភ កថំ កថេយ្យ ឯវំ ភវិស្សតិ អនាគតមទ្ធានន្តិ ឯតរហិ វា ភិក្ខវេ បច្ចុប្បន្នំ អទ្ធានំ អារព្ភ កថំ កថេយ្យ ឯវំ ហោតិ ឯតរហិ បច្ចុប្បន្នន្តិ ។ កថាសម្បយោគេន ភិក្ខវេ បុគ្គលោ វេទិតព្វោ យទិ វា កច្ឆោ យទិ វា អកច្ឆោតិ ។ សចាយំ ភិក្ខវេ

មោហៈកើតមានដល់អាត្មាអញ ក្នុងកាលមុន ធម្មជាតនោះ ជាអកុសល ឥឡូវនេះ មោហៈនោះមិនមានឡើយ ធម្មជាតនោះឈ្មោះថាជាកុសល ដូច្នេះ ។ ព្រះអរិយសាវ័កនោះអស់សេចក្តីស្រេកឃ្លាន ជាអ្នករលត់កិលេស មានសេចក្តីត្រជាក់ជាប្រក្រតី ទទួលនូវសេចក្តីសុខ មានខ្លួនដ៏ប្រសើរ នៅក្នុងបច្ចុប្បន្ន ។

[៦៩] ម្នាលភិក្ខុទាំងឡាយ កថាវត្ថុនេះ មាន ៣ យ៉ាង ។ កថាវត្ថុ ៣ យ៉ាងដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺបុគ្គលពោលពាក្យប្រារព្ធហេតុជាអតីតកាលថា ហេតុជាអតីតកាល មានមកហើយយ៉ាងនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពោលពាក្យប្រារព្ធហេតុជាអនាគតកាលថា ហេតុជាអនាគតកាលនឹងមានយ៉ាងនេះ ១ ម្នាលភិក្ខុទាំងឡាយ បុគ្គលពោលពាក្យប្រារព្ធហេតុជាបច្ចុប្បន្នកាល ក្នុងកាលឥឡូវនេះថា ហេតុជាបច្ចុប្បន្នកាល ក្នុងកាលឥឡូវនេះយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតគប្បីដឹង ស្គាល់បុគ្គលដោយការចូបប្រទះដោយពាក្យសម្តីថា នេះជាបុគ្គលដែលគួរសាកច្ឆាឬមិនគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ បើ

បុគ្គលោ បញ្ហំ បុដ្ឋោ សមានោ ឯកំសព្យាករណីយំ បញ្ហំ ន ឯកំសេន ព្យាករោតិ វិភជ្ជព្យាករណីយំ បញ្ហំ ន វិភជ្ជព្យាករោតិ បដិបុច្ឆាព្យាករណីយំ បញ្ហំ ន បដិបុច្ឆាព្យាករោតិ ឋបនីយំ បញ្ហំ ន ឋបេតិ ឯវំ សន្តាយំ ភិក្ខវេ បុគ្គលោ អកច្ឆោ ហោតិ ។ សចេ បនាយំ ភិក្ខវេ បុគ្គលោ បញ្ហំ បុដ្ឋោ សមានោ ឯកំសព្យាករណីយំ បញ្ហំ ឯកំសេន ព្យាករោតិ វិភជ្ជព្យាករណីយំ បញ្ហំ វិភជ្ជព្យាករោតិ បដិបុច្ឆាព្យាករណីយំ បញ្ហំ បដិបុច្ឆាព្យាករោតិ ឋបនីយំ បញ្ហំ ឋបេតិ ឯវំ សន្តាយំ ភិក្ខវេ បុគ្គលោ កច្ឆោ ហោតិ ។ កថាសម្បយោគេន ភិក្ខវេ បុគ្គលោ វេទិតព្វោ យទិ វា កច្ឆោ យទិ វា អកច្ឆោតិ ។ សចាយំ ភិក្ខវេ បុគ្គលោ បញ្ហំ បុដ្ឋោ សមានោ ឋានដ្ឋានេ ន សណ្ឋាតិ បរិកប្បេ ន សណ្ឋាតិ អញ្ញវាទេ ន សណ្ឋាតិ

បុគ្គលនេះកាលដែលត្រូវគេសួរប្រស្នាហើយ មិនព្យាករប្រស្នាដែលគេសួរ ព្យាករតែមួយចំណែក (តែម្តង) មិនព្យាករដោយការចែករលែក នូវប្រស្នាដែលគួរព្យាករដោយការចែករលែក មិនព្យាករដោយការសួរតបទៅវិញនូវប្រស្នាដែលគួរព្យាករ ដោយការសួរតបទៅវិញ មិនបញ្ឈប់នូវប្រស្នាដែលគួរបញ្ឈប់ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ បុគ្គលនេះឈ្មោះថាជាបុគ្គល មិនគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលនេះ កាលដែលត្រូវគេសួរប្រស្នា ក៏ព្យាករប្រស្នាដែលគួរព្យាករដោយចំណែកមួយ តែមួយចំណែក (ប៉ុណ្ណោះ) ព្យាករដោយការចែករលែក នូវប្រស្នាដែលគួរព្យាករ ដោយការចែករលែក ព្យាករដោយការសួរតបទៅវិញ នូវប្រស្នាដែលគួរព្យាករ ដោយការសួរតបទៅវិញ បញ្ឈប់នូវប្រស្នាដែលគួរបញ្ឈប់ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ បុគ្គលនេះឈ្មោះថាជាបុគ្គលគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតគប្បីដឹង ស្គាល់បុគ្គល ដោយការចួបប្រទះដោយពាក្យសម្តីថា នេះជាបុគ្គលដែលគួរសាកច្ឆា ឬមិនគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលនេះដែលត្រូវគេសួរប្រស្នាហើយ មិនតាំងនៅក្នុងឋានៈ (ហេតុដែលកើតមាន) និងអដ្ឋានៈ (ហេតុដែលមិនកើតមាន) មិនតាំងនៅក្នុងបរិកប្បៈ (ការកំណត់សួរនិងឆ្លើយ) មិនតាំងនៅក្នុងវាទៈដែលខ្លួនចេះ

២៤១



បដិបទាយ ន សណ្ឋាតិ ឯវំ សន្តាយំ ភិក្ខវេ បុគ្គលោ អកច្ឆោ ហោតិ ។ សចេ បនាយំ ភិក្ខវេ បុគ្គលោ បញ្ហំ បុដ្ឋោ សមានោ ឋានដ្ឋានេ សណ្ឋាតិ បរិកប្បេ សណ្ឋាតិ អញ្ញវាទេ សណ្ឋាតិ បដិបទាយ សណ្ឋាតិ ឯវំ សន្តាយំ ភិក្ខវេ បុគ្គលោ កច្ឆោ ហោតិ ។ កថាសម្បយោគេន ភិក្ខវេ បុគ្គលោ វេទិតព្វោ យទិ វា កច្ឆោ យទិ វា អកច្ឆោតិ ។ សចាយំ ភិក្ខវេ បុគ្គលោ បញ្ហំ បុដ្ឋោ សមានោ អញ្ញេនាញ្ញំ បដិចរតិ ពហិទ្ធា កថំ អបនាមេតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ឯវំ សន្តាយំ ភិក្ខវេ បុគ្គលោ អកច្ឆោ ហោតិ ។ សចេ បនាយំ ភិក្ខវេ បុគ្គលោ បញ្ហំ បុដ្ឋោ សមានោ នាញ្ញេនាញ្ញំ បដិចរតិ ន ពហិទ្ធា កថំ អបនាមេតិ ន កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ឯវំ សន្តាយំ ភិក្ខវេ

មិនតាំងនៅ ក្នុងបដិបទា ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ បុគ្គលនេះឈ្មោះថា ជាបុគ្គល មិនគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលនេះ កាលដែលត្រូវគេសួរប្រស្នាហើយ ក៏តាំងនៅក្នុងឋានៈនិងអដ្ឋានៈ តាំងនៅក្នុងបរិកប្បៈ តាំងនៅក្នុងវាទៈ ដែលខ្លួនចេះដឹង តាំងនៅក្នុងបដិបទា ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ បុគ្គលនេះឈ្មោះថា ជាបុគ្គល គួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតគប្បីដឹងស្គាល់បុគ្គល ដោយការចូបប្រទះ ដោយពាក្យសម្តីថា នេះជាបុគ្គលគួរសាកច្ឆាឬ មិនគួរសាកច្ឆាដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលនេះ កាលដែលត្រូវគេសួរប្រស្នាហើយ ក៏ពោលពាក្យបន្ទ្វៃបន្ទប់ ផ្តេសផ្តាស នាំយកសម្តីខាងក្រៅមកដំណាល ធ្វើសេចក្តីក្រោធខឹងនិងសេចក្តីតូចចិត្តឲ្យប្រាកដឡើង ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ បុគ្គលនេះឈ្មោះថា ជាបុគ្គលមិនគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលនេះ កាលដែលត្រូវគេសួរប្រស្នាហើយ មិនពោលពាក្យបន្ទ្វៃបន្ទប់ ផ្តេសផ្តាស មិននាំយកសម្តីខាងក្រៅមកដំណាល មិនធ្វើសេចក្តីក្រោធខឹង និងសេចក្តីតូចចិត្ត ឲ្យប្រាកដឡើង ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ

បុគ្គលោ កច្ឆោ ហោតិ ។ កថាសម្បយោគេន ភិក្ខវេ បុគ្គលោ វេទិតព្វោ យទិ វា កច្ឆោ យទិ វា អកច្ឆោតិ ។ សចាយំ ភិក្ខវេ បុគ្គលោ បញ្ហំ បុដ្ឋោ សមានោ អភិហរតិ អភិមទ្ទតិ អនុបជគ្ឃតិ ខលិតំ គណ្ហាតិ ឯវំ សន្តាយំ ភិក្ខវេ បុគ្គលោ អកច្ឆោ ហោតិ ។ សចេ បនាយំ ភិក្ខវេ បុគ្គលោ បញ្ហំ បុដ្ឋោ សមានោ ន អភិហរតិ ន អភិមទ្ទតិ ន អនុបជគ្ឃតិ ន ខលិតំ គណ្ហាតិ ឯវំ សន្តាយំ ភិក្ខវេ បុគ្គលោ កច្ឆោ ហោតិ ។ កថាសម្ប-យោគេន ភិក្ខវេ បុគ្គលោ វេទិតព្វោ យទិ វា សឧបនិសោ យទិ វា អនុបនិសោតិ ។ អនោហិត-ស្សោតោ ភិក្ខវេ អនុបនិសោ ហោតិ ឱហិតស្សោតោ សឧបនិសោ ហោតិ ។ សោ សឧបនិសោ សមានោ អភិជានាតិ ឯកំ ធម្មំ បរិជានាតិ ឯកំ ធម្មំ បជហាតិ ឯកំ ធម្មំ សច្ឆិករោតិ ឯកំ ធម្មំ ។ សោ អភិជានន្តោ ឯកំ ធម្មំ បរិជានន្តោ

បុគ្គលនេះ ឈ្មោះថាជាបុគ្គល គួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតគប្បីដឹង ស្គាល់បុគ្គល ដោយការចួបប្រទះ ដោយពាក្យសម្តីថា នេះជាបុគ្គលដែលគួរសាកច្ឆា ឬមិនគួរសាកច្ឆា ដូច្នេះ ។ ម្នាលភិក្ខុទាំង-ឡាយ ប្រសិនបើបុគ្គលនេះ កាលដែលត្រូវគេសួរប្រស្នាហើយ និយាយប៉ប៉ាច់ប៉ប៉ោច និយាយសង្កត់សង្កិន និយាយសើចលេង ប្រុងចាប់ថ្នាក់ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ បុគ្គលនេះឈ្មោះថាជាបុគ្គលមិនគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលនេះ កាលដែលត្រូវគេសួរប្រស្នាហើយ មិននិយាយប៉ប៉ាច់ប៉ប៉ោច មិននិយាយសង្កត់សង្កិន មិននិយាយសើចលេង មិនប្រុងចាប់ថ្នាក់ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ បុគ្គលនេះឈ្មោះថាជាបុគ្គលគួរសាកច្ឆា ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតគប្បីដឹងស្គាល់បុគ្គល ដោយការចួបប្រទះ ដោយពាក្យសម្តីថា នេះជាបុគ្គលមានឧបនិស្ស័យ ឬ មិនមានឧបនិស្ស័យ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលមិនផ្ទៀងត្រចៀកស្តាប់ ជាបុគ្គលមិនមានឧបនិស្ស័យ បុគ្គលដែលផ្ទៀងត្រចៀកស្តាប់ ជាបុគ្គលមានឧបនិស្ស័យ ។ បុគ្គលដែលមានឧបនិស្ស័យនោះ រមែងដឹងច្បាស់នូវធម៌មួយ រមែងកំណត់ដឹងនូវធម៌មួយ រមែងលះបង់នូវធម៌មួយ រមែងធ្វើឲ្យជាក់ច្បាស់នូវធម៌មួយ ។ កាលបុគ្គលនោះដឹងច្បាស់នូវធម៌មួយ កំណត់ដឹងនូវធម៌មួយ

២៤៣



ឯកំ ធម្មំ បជហន្តោ ឯកំ ធម្មំ សច្ឆិករោន្តោ ឯកំ ធម្មំ សម្មា វិមុត្តឹ ផុសតិ ។ ឯតទត្ថា ភិក្ខវេ កថា ឯតទត្ថា មន្តនា ឯតទត្ថា ឧបនិសា ឯតទត្ថំ សោតាវធានំ យទិទំ អនុបាទា ចិត្តស្ស វិមោក្ខោតិ ។

យេ វិរុទ្ធា សល្លបន្តិ
វិនិវិដ្ឋា សមុស្សិតា
អនរិយគុណមាសជ្ជ
អញ្ញោញ្ញវិវរេសិនោ[១]
ទុព្ភាសិតំ វិក្ខលិតំ
សម្បមោហំ បរាជយំ
អញ្ញមញ្ញាភិនន្ទន្តិ
តនរិយោ កថនា ចរេ ។
សចេ ចស្ស កថាកាមោ
កាលមញ្ញាយ បណ្ឌិតោ
ធម្មដ្ឋប្បដិសំយុត្តា
យា អរិយចរិតា កថា
តំ កថំ កថយេ ធីរោ

១ ឱ. អញ្ញមញ្ញំ វិវរេសិនោ ។

លះបង់នូវធម៌មួយ ធ្វើឲ្យជាក់ច្បាស់នូវធម៌មួយ រមែងពាល់ត្រូវនូវវិមុត្តិដោយប្រពៃបាន ។ ម្នាលភិក្ខុទាំងឡាយ ការនិយាយ ការប្រឹក្សាគ្នា ឧបនិស្ស័យនិងការផ្ទៀងត្រចៀកស្តាប់ សុទ្ធតែមានការរួបផុតនៃចិត្ត ព្រោះមិនប្រកាន់មាំ នុ៎ះជាប្រយោជន៍ ។

ជនទាំងឡាយណា និយាយ (ទាំងកំហឹង) ជាអ្នកប្រកាន់ខ្ជាប់ ជាអ្នកលើកតម្កើងខ្លួន ពោលទាក់ទង ដល់អនរិយគុណ ជាអ្នកស្វែងរកកំហុសគ្នា ទៅវិញទៅមក តែងត្រេកអរចំពោះពាក្យទុព្ភាសិត សេចក្តីភ្ញាំងភ្ញាត់ ភាន់ច្រឡំនិងការផ្ចាញ់សម្តីនៃគ្នានិងគ្នា ឯអរិយជនមិនប្រព្រឹត្តការនិយាយដូច្នោះឡើយ ។ បើអរិយជនប្រាថ្នានឹងនិយាយ ក៏ជាអ្នកឈ្លាស ស្គាល់ កាលនិយាយតែពាក្យសម្តីដែលប្រកបដោយធម៌ ជាសម្តីដែលអរិយជនធ្លាប់ប្រព្រឹត្តមកហើយ ជាអ្នកមានប្រាជ្ញា

អវិរុទ្ធោ អនុស្សិតោ
អនុត្តិណ្ណេន(១) មនសា
អបឡាសោ អសាហសោ
អនុសុយ្យមានោ សោ
សម្មទញ្ញាយ ភាសតិ
សុភាសិតំ អនុមោទេយ្យ
ទុព្ភដ្ឋេ នាប្បសាទយេ
ឧបារម្ភំ ន សិក្ខេយ្យ
ខលិតញ្ច ន គាហយេ
នាភិហារេ នាភិមទ្ទេ
ន វាចំ បយុត្តំ ភណេ ។
អញ្ញានត្ថំ បសាទត្ថំ
សតំ វេ ហោតិ មន្តនា
ឯវំ ខោ អរិយា មន្តេន្តិ
ឯសា អរិយានមន្តនា
ឯតទញ្ញាយ មេធាវី
ន សមុស្សេយ្យ មន្តយេតិ ។

១ ឱ. អនុបាទិន្នេន ។ ម. អនុន្នតេន ។

មិនក្រោធ មិនលើកខ្លួន មានចិត្តឥតមានមានះគ្រប សង្កត់ ជាអ្នកមិនលើកកម្ពស់ ជាអ្នកមិនរួសរាន់ លោកជាអ្នកមិនមានឫស្យានិងសេចក្តីប្រកាន់ខ្លួន ដឹង ពិតហើយទើបនិយាយ សម្តីដែលគេនិយាយត្រូវ ក៏ អនុមោទនា កាលបើគេនិយាយខុស ក៏មិនដេញដោល មិនប្រុងប្រណាំងប្រជែង មិនអាងហេតុចាប់ខុសគេ មិននិយាយប៉ប៉ាច់ប៉ប៉ោច មិននិយាយសង្កត់សង្កិន គេ មិននិយាយបាតដៃជាខ្នងដៃ ។ ការប្រឹក្សាគ្នា របស់សប្បុរសទាំងឡាយ តែងប្រព្រឹត្តទៅ ដើម្បីដឹង ច្បាស់ ដើម្បីសេចក្តីជ្រះថ្លា អរិយជនទាំងឡាយ តែងប្រឹក្សាគ្នាយ៉ាងនេះ នេះជាការប្រឹក្សានៃអរិយជន ទាំងឡាយ បុគ្គលអ្នកមានបញ្ញា កាលបើដឹងសេចក្តី នុ៎ះច្បាស់ហើយ មិនគួរនិយាយប្រឹក្សាលើកតម្កើង តែខ្លួនឯងឡើយ ។

[៧០] សចេ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ តយោមេ អាវុសោ ធម្មា ។ កតមេ តយោ ។ រាគោ ទោសោ មោហោ ។ ឥមេ ខោ អាវុសោ តយោ ធម្មា ។ ឥមេសំ អាវុសោ តិណ្ណំ ធម្មានំ កោ វិសេសោ កោ អធិប្បាយសោ កឹ នានាករណន្តិ ។ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ កិន្តិ ព្យាករេយ្យាថាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា ។ សាធុ វត ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

[៧០] ម្នាលភិក្ខុទាំងឡាយ បើបរិព្វាជកជាអន្យតិរ្ថិយ គប្បីសួរ (អ្នកទាំងឡាយ) យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ធម៌ទាំងឡាយអម្បាលនេះ មាន ៣ យ៉ាង ។ ធម៌ទាំង ៣ យ៉ាងតើដូចម្តេច ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ ។ ម្នាលអាវុសោទាំងឡាយ ធម៌មាន ៣ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំង ៣ យ៉ាងនេះ ប្លែកគ្នាដូចម្តេច មានអធិប្បាយដូចម្តេច មានសេចក្តីផ្សេងគ្នាដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកាលត្រូវគេសួរយ៉ាងនេះហើយ គប្បីព្យាករដូចម្តេច ដល់ពួកបរិព្វាជកជាអន្យតិរ្ថិយទាំងអម្បាលនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ របស់យើងខ្ញុំព្រះអង្គ មានព្រះមានព្រះភាគជាទីតាំង មានព្រះមានព្រះភាគជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹង ។ បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គ សូមព្រះរាជទានឱកាស សូមព្រះមានព្រះភាគ បំភ្លឺសេចក្តីនៃភាសិតនុ៎ះឲ្យទានភិក្ខុទាំងឡាយ បានស្តាប់ព្រះមានព្រះភាគហើយនឹងចងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងអម្បាលនោះ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ភគវា ឯតទវោច សចេ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ តយោមេ អាវុសោ ធម្មា ។ កតមេ តយោ ។ រាគោ ទោសោ មោហោ ។ ឥមេ ខោ អាវុសោ តយោ ធម្មា ។ ឥមេសំ អាវុសោ តិណ្ណំ ធម្មានំ កោ វិសេសោ កោ អធិប្បាយសោ កឹ នានាករណន្តិ ។ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ រាគោ ខោ អាវុសោ អប្បសាវជ្ជោ ទន្ធវិរាគី ទោសោ មហាសាវជ្ជោ ខិប្បវិរាគី មោហោ មហាសាវជ្ជោ ទន្ធវិរាគីតិ ។ កោ បនាវុសោ ហេតុ កោ បច្ចយោ យេន អនុប្បន្នោ វា រាគោ ឧប្បជ្ជតិ ឧប្បន្នោ វា រាគោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតីតិ ។ សុភនិមិត្តន្តិស្ស វចនីយំ ។ តស្ស សុភនិមិត្តំ អយោនិសោ មនសិករោតោ អនុប្បន្នោ ចេវ រាគោ ឧប្បជ្ជតិ ឧប្បន្នោ ច រាគោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជកជាអន្យតិរ្ថិយ គប្បីសួរយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ធម៌ទាំងអម្បាលនេះ មាន ៣ យ៉ាង ។ ធម៌ ៣ យ៉ាង តើដូចម្តេច ។ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ ។ ម្នាលអាវុសោទាំងឡាយ ធម៌មាន ៣ យ៉ាងនេះឯង ។ ម្នាលអាវុសោទាំងឡាយ ធម៌ទាំង ៣ យ៉ាងនេះ ប្លែកគ្នាដូចម្តេច មានអធិប្បាយដូចម្តេច មានសេចក្តីផ្សេងគ្នាដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលអ្នកទាំងឡាយ ត្រូវគេសួរយ៉ាងនេះហើយ គប្បីដោះស្រាយដល់ពួកបរិព្វាជក ជាអន្យតិរ្ថិយអម្បាលនោះយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ រាគៈមានទោសតិច ប៉ុន្តែក្រសាបរលាប ទោសៈមានទោសច្រើន ប៉ុន្តែឆាប់សាបរលាប មោហៈមានទោសច្រើនផង ក្រសាបរលាបផង ។ ម្នាលអាវុសោទាំងឡាយ ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យរាគៈដែលមិនទាន់កើត ឲ្យកើតឡើងក្តី រាគៈដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនច្រើនឡើងក្តី ។ គួរដោះស្រាយថា សុភនិមិត្ត (អារម្មណ៍ដែលល្អ) ។ កាលបុគ្គលនោះ ធ្វើទុកក្នុងចិត្តនូវសុភនិមិត្ត ដោយមិនជាឧបាយនៃបញ្ញា រាគៈដែលមិនទាន់កើតឡើងក៏កើតឡើងផង រាគៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនច្រើនឡើងផង ។

អយំ ខោ អាវុសោ ហេតុ អយំ បច្ចយោ យេន អនុប្បន្នោ វា រាគោ ឧប្បជ្ជតិ ឧប្បន្នោ វា រាគោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតីតិ ។ កោ បនាវុសោ ហេតុ កោ បច្ចយោ យេន អនុប្បន្នោ វា ទោសោ ឧប្បជ្ជតិ ឧប្បន្នោ វា ទោសោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតីតិ ។ បដិឃនិមិត្តន្តិស្ស វចនីយំ ។ តស្ស បដិឃនិមិត្តំ អយោនិសោ មនសិករោតោ អនុប្បន្នោចេវ ទោសោ ឧប្បជ្ជតិ ឧប្បន្នោ ច ទោសោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។ អយំ ខោ អាវុសោ ហេតុ អយំ បច្ចយោ យេន អនុប្បន្នោ វា ទោសោ ឧប្បជ្ជតិ ឧប្បន្នោ វា ទោសោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតីតិ ។ កោ បនាវុសោ ហេតុ កោ បច្ចយោ យេន អនុប្បន្នោ វា មោហោ ឧប្បជ្ជតិ ឧប្បន្នោ វា មោហោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតីតិ ។ អយោនិសោ មនសិការោតិស្ស វចនីយំ ។ តស្ស អយោនិសោ មនសិករោតោ

ម្នាលអាវុសោទាំងឡាយ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យរាគៈដែលមិនទាន់កើតឡើងឲ្យកើតឡើងផង រាគៈដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនច្រើនឡើងផង ។ ម្នាលអាវុសោទាំងឡាយ ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យទោសៈដែលមិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ទោសៈដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនច្រើនឡើងក្តី ។ គួរដោះស្រាយថា បដិឃនិមិត្ត (អារម្មណ៍ដែលទាស់ចិត្ត) ។ កាលបុគ្គលនោះ ធ្វើទុកក្នុងចិត្តនូវបដិឃនិមិត្ត ដោយមិនជាឧបាយនៃបញ្ញា ទោសៈដែលមិនទាន់កើតឡើង ក៏កើតឡើងផង ទោសៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនច្រើនឡើងផង ម្នាលអាវុសោទាំងឡាយ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យទោសៈដែលមិនទាន់កើតឡើងឲ្យកើតឡើងផង ទោសៈដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនឡើងផង ។ ម្នាលអាវុសោទាំងឡាយ ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមោហៈដែលមិនទាន់កើតឡើង ឲ្យកើតឡើងក្តី មោហៈដែលកើតឡើងហើយ ឲ្យរឹងរឹតតែចម្រើនច្រើនឡើងក្តី ។ គួរដោះស្រាយថា អយោនិសោមនសិការៈ (ការមិនធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា) ។ កាលបុគ្គលនោះមិនធ្វើទុកក្នុងចិត្ត ដោយជាឧបាយនៃបញ្ញា

អនុប្បន្នោ ចេវ មោហោ ឧប្បជ្ជតិ ឧប្បន្នោ ច មោហោ ភិយ្យោភាវាយ វេបុល្លាយ សំវត្តតិ ។ អយំ ខោ អាវុសោ ហេតុ អយំ បច្ចយោ យេន អនុប្បន្នោ វា មោហោ ឧប្បជ្ជតិ ឧប្បន្នោ វា មោហោ ភិយ្យោ-ភាវាយ វេបុល្លាយ សំវត្តតីតិ ។ កោ បនាវុសោ ហេតុ កោ បច្ចយោ យេន អនុប្បន្នោ វា រាគោ នុប្បជ្ជតិ ឧប្បន្នោ វា រាគោ បហីយតីតិ ។ អសុ-ភនិមិត្តន្តិស្ស វចនីយំ ។ តស្ស អសុភនិមិត្តំ យោនិសោ មនសិករោតោ អនុប្បន្នោ ចេវ រាគោ នុប្បជ្ជតិ ឧប្បន្នោ ច រាគោ បហីយតិ ។ អយំ ខោ អាវុសោ ហេតុ អយំ បច្ចយោ យេន អនុប្បន្នោ វា រាគោ នុប្បជ្ជតិ ឧប្បន្នោ វា រាគោ បហីយតីតិ ។ កោ បនាវុសោ ហេតុ កោ បច្ចយោ យេន អនុប្បន្នោ វា ទោសោ នុប្បជ្ជតិ ឧប្បន្នោ វា ទោសោ បហីយតីតិ ។ មេត្តា ចេតោវិមុត្តីតិស្ស វចនីយំ ។ តស្ស មេត្តំ ចេតោវិមុត្តឹ យោនិសោ មនសិករោតោ

មោហៈដែលមិនទាន់កើតឡើង ក៏កើតឡើងផង មោហៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនច្រើនឡើងផង ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុ នេះជាបច្ច័យដែលនាំឲ្យមោហៈដែលមិនទាន់កើតឡើង ឲ្យកើតឡើងផង មោហៈដែលកើតឡើងហើយ ក៏រឹងរឹតតែចម្រើនឡើងផង ។ ម្នាលអាវុសោទាំងឡាយ ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យរាគៈដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបានក្តី រាគៈដែលកើតឡើងហើយ ក៏លះបង់ចេញបានក្តី ។ គួរដោះស្រាយថា អសុភនិមិត្ត (អារម្មណ៍ដែលមិនល្អ) ។ កាលបុគ្គលនោះធ្វើទុកក្នុងចិត្តនូវអសុភនិមិត្តដោយឧបាយនៃបញ្ញា រាគៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង រាគៈដែលកើតឡើងហើយ ក៏លះបង់ចេញបានផង ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យរាគៈដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងបានផង រាគៈដែលកើតឡើងហើយ ក៏លះបង់ចេញបានផង ។ ម្នាលអាវុសោទាំង-ឡាយ ចុះអ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យទោសៈដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងក្តី ទោសៈដែលកើតឡើងហើយ ក៏លះបង់ចេញបានក្តី ។ គួរដោះស្រាយថា មេត្តាចេតោវិមុត្តិ (គ្រឿងរួចផុតនៃចិត្តដោយអំណាចមេត្តា) ។ កាលបុគ្គលនោះធ្វើទុកក្នុងចិត្តនូវមេត្តាចេតោវិមុត្តិ

ទុតិយបណ្ណាសកេ មហាវគ្គោ

អនុប្បន្នោ ចេវ ទោសោ នុប្បជ្ជតិ ឧប្បន្នោ ច ទោសោ បហីយតិ ។ អយំ ខោ អាវុសោ ហេតុ អយំ បច្ចយោ យេន អនុប្បន្នោ វា ទោសោ នុប្បជ្ជតិ ឧប្បន្នោ វា ទោសោ បហីយតីតិ ។ កោ បនាវុសោ ហេតុ កោ បច្ចយោ យេន អនុប្បន្នោ វា មោហោ នុប្បជ្ជតិ ឧប្បន្នោ វា មោហោ បហីយតីតិ ។ យោនិសោ មនសិការោតិស្ស វចនីយំ ។ តស្ស យោនិសោ មនសិករោតោ អនុប្បន្នោ ចេវ មោហោ នុប្បជ្ជតិ ឧប្បន្នោ ច មោហោ បហីយតិ ។ អយំ ខោ អាវុសោ ហេតុ អយំ បច្ចយោ យេន អនុប្បន្នោ វា មោហោ នុប្បជ្ជតិ ឧប្បន្នោ វា មោហោ បហីយតីតិ ។

ដោយឧបាយនៃបញ្ញា ទោសៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ទោសៈដែលកើតឡើងហើយ ក៏លះបង់ចេញបានផង ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យទោសៈដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងផង ទោសៈដែលកើតឡើងហើយ ក៏លះបង់ចេញបានផង ។ ម្នាលអាវុសោទាំងឡាយ អ្វីជាហេតុ អ្វីជាបច្ច័យ ដែលនាំឲ្យមោហៈដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងក្តី មោហៈដែលកើតឡើងហើយ ក៏លះបង់ចេញបានក្តី ។ គួរដោះស្រាយថា យោនិសោ-មនសិការៈ (ការធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា) ។ កាលបុគ្គលនោះធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា មោហៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង មោហៈដែលកើតឡើងហើយ ក៏លះបង់ចេញបានផង ។ ម្នាលអាវុសោទាំងឡាយ នេះជាហេតុ នេះជាបច្ច័យ ដែលនាំឲ្យមោហៈដែលមិនទាន់កើតឡើង មិនឲ្យកើតឡើងផង មោហៈដែលកើតឡើងហើយក៏លះបង់ចេញបានផង ។

[៧១] តីណីមានិ ភិក្ខវេ អកុសលមូលានិ ។ កតមានិ តីណិ ។ លោភោ អកុសលមូលំ ទោសោ អកុសលមូលំ មោហោ អកុសលមូលំ ។ យទបិ ភិក្ខវេ លោភោ តទបិ អកុសលំ[១] យទបិ លុទ្ធោ អភិសង្ខរោតិ កាយេន វាចាយ មនសា តទបិ អកុសលំ យទបិ លុទ្ធោ លោភេន អភិ-ភូតោ បរិយាទិន្នចិត្តោ បរស្ស អសតា ទុក្ខំ ឧបទហតិ វធេន វា ពន្ធនេន វា ជានិយា វា គរហាយ វា បព្វាជនាយ វា ពលវម្ហិ ពលត្ថោ ឥតិបិ តទបិ អកុសលំ ។ ឥតិស្សមេ លោភជា លោភនិទានា លោភសមុទយា លោភប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ ។ យទបិ ភិក្ខវេ ទោសោ តទបិ អកុសលំ យទបិ ទុដ្ឋោ អភិសង្ខរោតិ កាយេន វាចាយ មនសា តទបិ អកុសលំ យទបិ ទុដ្ឋោ ទោសេន អភិភូតោ បរិយាទិន្នចិត្តោ បរស្ស អសតា ទុក្ខំ ឧបទហតិ វធេន វា ពន្ធនេន វា

១ ម. អកុសលមូលំ ។

[៧១] ម្នាលភិក្ខុទាំងឡាយ អកុសលមូល (ឫសគល់នៃអកុសល) នេះ មាន ៣ យ៉ាង ។ អកុសលមូល ៣ យ៉ាងតើដូចម្តេច ។ គឺ លោភៈជាអកុសលមូល ១ ទោសៈជាអកុសលមូល ១ មោហៈជាអកុសលមូល ១ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាជាតួលោភៈ សភាវៈនោះជាអកុសល បុគ្គលអ្នកល្មោភតែងសន្សំនូវកម្មណា ដោយកាយ វាចា ចិត្ត កម្មនោះក៏ជាអកុសលដែរ បុគ្គលអ្នកល្មោភត្រូវលោភៈគ្របសង្កត់ មានចិត្តត្រូវលោភៈរួបរឹត តែងរករឿងបង្កទុក្ខដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុនោះ ហៅថា ជាអកុសល ។ អកុសលធម៌ទាំងឡាយ ដ៏លាមកជាច្រើនកើតអំពីលោភៈ មានលោភៈជាដើមហេតុ មានលោភៈជាប្រភព មានលោភៈជាបច្ច័យ ទាំងអម្បាលនេះ រមែងប្រជុំកើតព្រមដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណាជាតួទោសៈ សភាវៈនោះក៏ជាអកុសល បុគ្គលអ្នកប្រទូស្តតែងសន្សំនូវកម្មណា ដោយកាយ វាចា ចិត្ត កម្មនោះក៏ជាអកុសលដែរ បុគ្គលអ្នកប្រទូស្ត ត្រូវទោសៈគ្របសង្កត់ មានចិត្តត្រូវទោសៈរួបរឹត តែងរករឿងបង្កទុក្ខដែលមិនពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ

២៤១

ទុតិយបណ្ណាសកេ មហាវគ្គោ

ជានិយា វា គរហាយ វា បព្វាជនាយ វា ពលវម្ហិ ពលត្ថោ ឥតិបិ តជបិ អកុសលំ ។ ឥតិស្សមេ ជោ-សជា ជោសនិទានា ជោសសមុទយា ជោសប្បច្ចយា អនេកេ ចាបកា អកុសលា ជម្មា សម្ភវន្តិ ។ យជបិ ភិក្ខវេ មោហោ តជបិ អកុសលំ យជបិ មូឡ្ហោ អភិសង្ខរោតិ កាយេន វាចាយ មនសា តជបិ អកុសលំ យជបិ មូឡ្ហោ មោហេន អភិ-ភូតោ បរិយាទិន្នចិត្តោ បរស្ស អសតា ទុក្ខំ ឧបទ-ហាតិ វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា បព្វាជនាយ វា ពលវម្ហិ ពលត្ថោ ឥតិបិ តជបិ អកុសលំ ។ ឥតិស្សមេ មោហជា មោហ-និទានា មោហសមុទយា មោហប្បច្ចយា អនេកេ ចាបកា អកុសលា ជម្មា សម្ភវន្តិ ។ ឯវរូបោ ចាយំ ភិក្ខវេ បុគ្គលោ វុច្ចតិ អកាលវាទីតិបិ

ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុនោះហៅថា ជាអកុសល ។ អកុសលធម៌ទាំងឡាយ ដ៏លាមកជាច្រើន ដែលកើតអំពីទោសៈ មានទោសៈជាដើមហេតុ មានទោសៈជាប្រភព (ជាដែនកើត)មានទោសៈជាបច្ច័យ ទាំងអម្បាលនេះ រមែងប្រជុំកើតព្រម ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ សភាវៈណា ជាតួមោហៈ សភាវៈនោះ ជាអកុសល បុគ្គលអ្នកវង្វេង តែងសន្សំនូវកម្មណា ដោយកាយ វាចា ចិត្ត កម្មនោះហៅថាជាអកុសល បុគ្គលអ្នកវង្វេង ត្រូវមោហៈគ្របសង្កត់ មានចិត្តត្រូវមោហៈរួបរឹត តែងរករឿងបង្កទុក្ខ ដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ចេញខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុនោះហៅថា ជាអកុសល ។ អកុសលធម៌ទាំងឡាយ ដ៏លាមកជាច្រើន ដែលកើតអំពីមោហៈ មានមោហៈជាដើមហេតុ មានមោហៈជាប្រភព មានមោហៈជាបច្ច័យ ទាំងអម្បាលនេះ រមែងប្រជុំកើតព្រមដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពដូច្នេះនេះហៅថា អកាលវាទី (និយាយក្នុងកាលមិនគួរ) ខ្លះ

អភូតភាណីតិបិ អនត្ថភាណីតិបិ អធម្មភាណីតិបិ អវិនយភាណី-
តិបិ ។ កស្មា ចាយំ ភិក្ខវេ ឯវរូបោ បុគ្គលោ វុច្ចតិ
អកាលភាណីតិបិ អភូតភាណីតិបិ អនត្ថភាណីតិបិ អធម្ម-
ភាណីតិបិ អវិនយភាណីតិបិ ។ តថា ហាយំ ភិក្ខវេ
បុគ្គលោ បរស្ស អសតា ទុក្ខំ ឧបទហតិ វធេន
វា ពន្ធនេន វា ជានិយា វា គរហាយ វា បព្វា-
ជនាយ វា ពលវម្ហិ ពលត្ថោ ឥតិបិ ភូតេន
ខោ បន វុច្ចមានោ អវជានាតិ នោ បដិជានាតិ
អភូតេន វុច្ចមានោ ន អាតប្បំ ករោតិ តស្ស
និព្វេឋនាយ[១] ឥតិបេតំ អតច្ឆំ ឥតិបេតំ អភូតន្តិ
តស្មា ឯវរូបោ បុគ្គលោ វុច្ចតិ អកាលភាណីតិបិ
អភូតភាណីតិបិ អនត្ថភាណីតិបិ អធម្មភាណីតិបិ អវិនយ-
ភាណីតិបិ ។ ឯវរូបោ ភិក្ខវេ បុគ្គលោ លោភជេហិ
បាបកេហិ អកុសលេហិ ធម្មេហិ អភិភូតោ
បរិយាទិន្នចិត្តោ ទិដ្ឋេវ ធម្មេ ទុក្ខំ វិហរតិ សវិឃាតំ
សឧបាយាសំ សបរិឡាហំ កាយស្ស ភេទា
បរម្មរណា ទុគ្គតិ បាដិកង្ខា ។ ទោសជេហិ ។ បេ ។

---
១ អដ្ឋកថាយំ និព្វេធនាយាតិ ទិស្សតិ ។

អភូតវាទី (និយាយពាក្យមិនពិត) ខ្លះ អនត្ថវាទី (និយាយពាក្យដែលមិនមានប្រយោជន៍) ខ្លះ អធម្មវាទី (និយាយមិនត្រូវតាមធម៌) ខ្លះ អវិនយវាទី (និយាយមិនត្រូវតាមវិន័យ) ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុដូចម្ដេច បានជាបុគ្គលមានសភាពយ៉ាងនេះ ហៅថា អកាលវាទីខ្លះ អភូតវាទីខ្លះ អនត្ថវាទីខ្លះ អធម្មវាទីខ្លះ អវិនយវាទីខ្លះ ។ ម្នាលភិក្ខុទាំងឡាយពិតណាស់ ព្រោះថាបុគ្គលនេះ តែងបង្កទុក្ខដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះ-ដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ តែកាលបើអ្នកដទៃហ៊ាននិយាយដោយសេចក្ដីពិត ក៏បដិសេធ មិនព្រមទទួលដឹង កាលបើ គេនិយាយដោយសេចក្ដីមិនពិត ក៏មិនធ្វើព្យាយាម ដើម្បីដឹងនូវសេចក្ដីមិនពិតនោះថា ពាក្យនោះមិនមែនទេដូច្នេះក្ដី ពាក្យនុ៎ះមិនពិតទេដូច្នេះក្ដី ព្រោះហេតុនោះ បុគ្គលមានសភាពយ៉ាងនេះហៅថា អកាលវាទីខ្លះ អភូតវាទីខ្លះ អនត្ថវាទីខ្លះ អធម្មវាទីខ្លះ អវិនយវាទីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះត្រូវអកុសលធម៌ទាំងឡាយ ដ៏លាមកកើតអំពីលោភៈគ្របសង្កត់ មានចិត្តត្រូវអកុសលធម៌រួបរឹត តែងនៅជាទុក្ខ ប្រកបដោយសេចក្ដីចង្អៀតចង្អល់សេចក្ដីតានតឹង និងសេចក្ដីក្ដៅក្រហាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ មានទុគ្គតិជាទីប្រាកដ ។ កើតអំពីទោសៈ ។ បេ ។

មោហជេហិ បាបកេហិ អកុសលេហិ ធម្មេហិ អភិ-
ភូតោ បរិយាទិន្នចិត្តោ ទិដ្ឋេវ ធម្មេ ទុក្ខំ វិហរតិ
សវិឃាតំ សឧបាយាសំ សបរិឡាហំ កាយស្ស ភេទា
បរម្មរណា ទុគ្គតិ បាដិកង្ខា ។ សេយ្យថាបិ ភិក្ខវេ
សាលោ វា ធវោ វា ផន្ទនោ វា តីហិ មាលុវា-
លតាហិ ឧទ្ធសេតោ[១] បរិយោនទ្ធោ អនយំ
អាបជ្ជតិ ព្យសនំ អាបជ្ជតិ អនយព្យសនំ អាបជ្ជតិ
ឯវមេវ ខោ ភិក្ខវេ ឯវរូបោ បុគ្គលោ លោភជេហិ
បាបកេហិ អកុសលេហិ ធម្មេហិ អភិភូតោ បរិ-
យាទិន្នចិត្តោ ទិដ្ឋេវ ធម្មេ ទុក្ខំ វិហរតិ សវិឃាតំ
សឧបាយាសំ សបរិឡាហំ កាយស្ស ភេទា
បរម្មរណា ទុគ្គតិ បាដិកង្ខា ។ ទោសជេហិ ។ បេ ។
មោហជេហិ បាបកេហិ អកុសលេហិ ធម្មេហិ
អភិភូតោ បរិយាទិន្នចិត្តោ ទិដ្ឋេវ ធម្មេ
ទុក្ខំ វិហរតិ សវិឃាតំ សឧបាយាសំ សបរិឡាហំ
កាយស្ស ភេទា បរម្មរណា ទុគ្គតិ បាដិកង្ខា ។
ឥមានិ ខោ ភិក្ខវេ តីណិ អកុសលមូលានិ ។

១ ម. ឧទ្ធំសោ ។

ត្រូវអកុសលធម៌ទាំងឡាយដ៏លាមក កើតអំពីមោហៈ គ្របសង្កត់ មានចិត្តត្រូវអកុសលធម៌របរឹត តែងនៅជាទុក្ខ ប្រកបដោយសេចក្តីចង្អៀតចង្អល់ សេចក្តីតានតឹង និងសេចក្តីក្តៅក្រហាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ មានទុគ្គតិជាទីប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ ដូចដើមសាលព្រឹក្ស ដើមធ្នឹកឬដើមពន្រ្ល ត្រូវវល្លិ៍ជ្រៃ ៣ ដើម របរឹតពីខាងលើព័ទ្ធព័ន្ធដោយជុំវិញ រមែងដល់នូវសេចក្តីមិនចម្រើន ដល់នូវសេចក្តីវិនាស ដល់នូវខូចខាត និងសេចក្តីហិនហោចយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ត្រូវអកុសលធម៌ទាំងឡាយ ដ៏លាមក តែងកើតអំពីលោភៈ គ្របសង្កត់ មានចិត្តត្រូវអកុសលធម៌របរឹត តែងនៅជាទុក្ខប្រកបដោយសេចក្តីចង្អៀតចង្អល់ សេចក្តីតានតឹង និងសេចក្តីក្តៅក្រហាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយស្លាប់ទៅ មានទុគ្គតិជាទីប្រាកដ ។ កើតអំពីទោសៈ ។ បេ ។ ត្រូវអកុសលធម៌ទាំងឡាយដ៏លាមកតែងកើតអំពីមោហៈគ្របសង្កត់ មានចិត្តត្រូវអកុសលធម៌របរឹត តែងនៅជាទុក្ខ ប្រកបដោយសេចក្តីចង្អៀតចង្អល់ សេចក្តីតានតឹង និងសេចក្តីក្តៅក្រហាយ ក្នុងបច្ចុប្បន្ន លុះបែកធ្លាយរាងកាយ ស្លាប់ទៅ មានទុគ្គតិជាទីប្រាកដក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ អកុសលមូលមាន ៣ យ៉ាងនេះឯង ។

តីណីមានិ ភិក្ខវេ កុសលមូលានិ ។ កាតមានិ តីណិ ។ អលោភោ កុសលមូលំ អទោសោ កុសលមូលំ អមោហោ កុសលមូលំ ។ យទបិ ភិក្ខវេ អលោភោ តទបិ កុសលំ យទបិ អលុទ្ធោ អភិ-សង្ខរោតិ កាយេន វាចាយ មនសា តទបិ កុសលំ យទបិ អលុទ្ធោ លោភេន អនភិភូតោ អបរិយាទិន្នចិត្តោ ន បរស្ស អសតា ទុក្ខំ ឧបទ-ហាតិ វធេន វា ពន្ធនេន វា ជានិយា វា គរហាយ វា បព្វាជនាយ វា ពលវម្ហិ ពលត្ថោ ឥតិបិ តទបិ កុសលំ ។ ឥតិស្សមេ អលោភជា អលោភនិទានា អលោភសមុទយា អលោភប្បច្ចយា អនេកេ កុសលា ធម្មា សម្ភវន្តិ ។ យទបិ ភិក្ខវេ អទោសោ តទបិ កុសលំ យទបិ អទុដ្ឋោ អភិសង្ខរោតិ កាយេន វាចាយ មនសា តទបិ កុសលំ យទបិ អទុដ្ឋោ ទោសេន អនភិភូតោ អបរិយាទិន្នចិត្តោ

ម្នាលភិក្ខុទាំងឡាយ កុសលមូល (ឫសគល់នៃកុសល) នេះ មាន ៣ យ៉ាង ។ កុសលមូល ៣ យ៉ាងតើដូចម្តេច ។ គឺអលោភៈ ជាកុសលមូល ១ អទោសៈ ជាកុសលមូល ១ អមោហៈ ជាកុសលមូល ១ ។ ម្នាលភិក្ខុទាំង-ឡាយ ធម្មជាតណាជាអលោភៈ ធម្មជាតនោះជាកុសល បុគ្គលអ្នកមិនល្មោភតែងសន្សំនូវកម្មណា ដោយកាយ វាចា ចិត្ត កម្មនោះក៏ជាកុសល បុគ្គលអ្នកមិនល្មោភ ត្រូវលោភៈមិនគ្របសង្កត់ មានចិត្តត្រូវលោភៈមិនរួប-រឹត មិនរករឿងបង្កទុក្ខ ដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុនោះហៅថា ជាកុសល ។ កុសលធម៌ទាំង-ឡាយ ច្រើនប្រការ ដែលកើតអំពីអលោភៈ មានអលោភៈជាដើមហេតុ មានអលោភៈជាប្រភព មានអលោភៈជាបច្ច័យ ទាំងអម្បាលនេះ រមែងកើតព្រមដល់បុគ្គលនោះដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតណា ជាអទោសៈ ធម្មជាតនោះជាកុសល បុគ្គលអ្នកមិនប្រទូស្ត តែងសន្សំនូវកម្មណាដោយកាយ វាចា ចិត្ត កម្មនោះក៏ជាកុសល បុគ្គលអ្នកមិនប្រទូស្ត ត្រូវទោសៈ មិនគ្របសង្កត់ មានចិត្តត្រូវទោសៈ មិនរួបរឹត

ន បរស្ស អសតា ទុក្ខំ ឧបទហតិ វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា បព្វាជនាយ វា ពលវម្ហិ ពលត្ថោ ឥតិបិ តទបិ កុសលំ ។ ឥតិស្សមេ អទោសជា អទោសនិទានា អទោសសមុទយា អទោសប្បច្ចយា អនេកេ កុសលា ធម្មា សម្ភវន្តិ ។ យទបិ ភិក្ខវេ អមោហោ តទបិ កុសលំ យទបិ អមូឡ្ហោ អភិសង្ខរោតិ កាយេន វាចាយ មនសា តទបិ កុសលំ យទបិ អមូឡ្ហោ មោហេន អន-ភិភូតោ អបរិយាទិន្នចិត្តោ ន បរស្ស អសតា ទុក្ខំ ឧបទហតិ វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា បព្វាជនាយ វា ពលវម្ហិ ពលត្ថោ ឥតិបិ តទបិ កុសលំ ។ ឥតិស្សមេ អមោហជា អមោហនិទានា អមោហសមុទយា អមោហប្បច្ចយា អនេកេ កុសលា ធម្មា សម្ភវន្តិ ។

មិនរករឿងបង្កទុក្ខ ដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុនោះក៏ជាកុសល ។ កុសលធម៌ទាំងឡាយជាច្រើន ដែលកើតអំពីអទោសៈ មានអទោសៈជាដើមហេតុ មានអទោសៈជាប្រភព មានអទោសៈជាបច្ច័យ ទាំងអម្បាលនេះ រមែងកើតព្រមដល់បុគ្គលនោះដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ធម្មជាតណាជាអមោហៈ ធម្មជាតនោះជាកុសល បុគ្គលអ្នកមិនវង្វេង តែងសន្សំនូវកម្មណា ដោយកាយ វាចា ចិត្ត កម្មនោះក៏ជាកុសល បុគ្គលអ្នកមិនវង្វេង ត្រូវមោហៈមិនគ្របសង្កត់ មានចិត្តត្រូវមោហៈមិនរួបរឹត មិនបានរករឿងបង្កទុក្ខ ដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ ដោយហេតុណា ហេតុនោះ ក៏ជាកុសល ។ កុសលធម៌ទាំងឡាយ ច្រើនកើតអំពីអមោហៈ មានអមោហៈជាដើមហេតុ មានអមោហៈជាប្រភព មានអមោហៈជាបច្ច័យ ទាំងអម្បាលនេះ រមែងកើតព្រមដល់បុគ្គលនោះដោយប្រការដូច្នេះ ។

ឯវរូបោ ចាយំ ភិក្ខវេ បុគ្គលោ វុច្ចតិ កាលវាទីតិបិ ភូតវាទីតិបិ អត្ថវាទីតិបិ ធម្មវាទីតិបិ វិនយវាទីតិបិ ។ កស្មា ចាយំ ភិក្ខវេ ឯវរូបោ បុគ្គលោ វុច្ចតិ កាលវាទីតិបិ ភូតវាទីតិបិ អត្ថវាទីតិបិ ធម្មវាទីតិបិ វិនយវាទីតិបិ ។ តថា ហាយំ ភិក្ខវេ បុគ្គលោ ន បរស្ស អសតា ទុក្ខំ ឧបទហតិ វធេន វា ពន្ធេន វា ជានិយា វា គរហាយ វា បព្វាជនាយ វា ពលវម្ហិ ពលត្ថោ ឥតិបិ ភូតេន ខោ បន វុច្ចមានោ បដិជានាតិ នោ អវជានាតិ អភូតេន វុច្ចមានោ អាតប្បំ ករោតិ តស្ស និព្វេឋនាយ ឥតិបេតំ អតច្ឆំ ឥតិបេតំ អភូតន្តិ[១] តស្មា ឯវរូបោ បុគ្គលោ វុច្ចតិ កាលវាទីតិបិ ភូតវាទីតិបិ អត្ថវាទីតិបិ ធម្មវាទីតិបិ វិនយវាទីតិបិ ។ ឯវរូបស្ស ភិក្ខវេ បុគ្គលស្ស លោភជា បាបកា អកុសលា ធម្មា បហីនា

១ ឱ. ម. តច្ឆំ ឥតិបេតំ ភូតន្តិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ហៅថា កាលវាទី (និយាយក្នុងកាលដែលគួរ) ខ្លះ ភូតវាទី (និយាយពាក្យពិត) ខ្លះ អត្ថវាទី (និយាយពាក្យដែលជាប្រយោជន៍) ខ្លះ ធម្មវាទី (និយាយត្រូវតាមធម៌) ខ្លះ វិនយវាទី (និយាយត្រូវតាមវិន័យ) ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុដូចម្តេច បុគ្គលដែលមានសភាពដូច្នេះ ហៅថា កាលវាទី ខ្លះ ភូត-វាទី ខ្លះ អត្ថវាទី ខ្លះ ធម្មវាទី ខ្លះ វិនយវាទី ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពិតណាស់ ព្រោះថា បុគ្គលនេះមិនបង្កទុក្ខ ដែលមិនមានពិតដល់អ្នកដទៃ ដោយការសម្លាប់ខ្លះ ដោយការចាប់ចងខ្លះ ដោយការបំផ្លាញខ្លះ ដោយការតិះដៀលខ្លះ ដោយការបំបរបង់ខ្លះ ដោយអាងកម្លាំងថា អាត្មាអញជាអ្នកមានកម្លាំងខ្លះ តែកាលបើអ្នកដទៃ និយាយដោយសេចក្តីពិត ក៏ទទួលរ៉ាប់រងមិនបដិសេធ កាលបើគេនិយាយ ដោយសេចក្តីមិនពិត ក៏ធ្វើសេចក្តីព្យាយាម ដើម្បីដឹងនូវសេចក្តីមិនពិតនោះថា ពាក្យនុ៎ះមិនមែនទេដូច្នេះក្តី ពាក្យនោះមិនពិតទេដូច្នេះក្តី ព្រោះហេតុនោះ បុគ្គលមានសភាពយ៉ាងនេះ ហៅថា កាលវាទីខ្លះ ភូតវាទីខ្លះ អត្ថវាទីខ្លះ ធម្មវាទីខ្លះ វិនយវាទីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតអំពីលោភៈ ដែលបុគ្គលមានសភាពយ៉ាងនេះ លះបង់បានហើយ

ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំ កតា អាយតឹអនុប្បាទធម្មា ទិដ្ឋេវ ធម្មេ សុខំ វិហរតិ អវិឃាតំ អនុបាយាសំ អបរិឡាហំ ទិដ្ឋេវ ធម្មេ បរិនិព្វាយតិ ។ ទោសជា ។ បេ ។ មោហជា បាបកា អកុសលា ធម្មា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំ កតា អាយតឹអនុប្បាទធម្មា ទិដ្ឋេវ ធម្មេ សុខំ វិហរតិ អវិឃាតំ អនុបាយាសំ អបរិឡាហំ ទិដ្ឋេវ ធម្មេ បរិនិព្វាយតិ ។ សេយ្យថាបិ ភិក្ខវេ សាលោ វា ធវោ វា ផន្ទនោ វា តីហិ មាលុវាលតាហិ ឧទ្ធសេតោ បរិយោនទ្ធោ ។ អថ បុរិសោ អាគច្ឆេយ្យ កុទ្ទាលបិដកំ អាទាយ សោ តំ មាលុវាលតំ មូលេ ឆិន្ទេយ្យ មូលេ ឆេត្វា បលិខណេយ្យ បលិខណិត្វា មូលានិ ឧទ្ធរេយ្យ អន្តមសោ ឧសីរនាឡមត្តានិបិ សោ តំ មាលុវាលតំ ខណ្ឌាខណ្ឌិកំ ឆិន្ទេយ្យ

គាស់រំលើងឫសគល់អស់ហើយ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើមិនឲ្យមានបែបភាព មានកិរិយាមិនកើតតទៅទៀតជាធម្មតា (បុគ្គលមានសភាពយ៉ាងនេះ) តែងនៅជាសុខ ឥតមានសេចក្តីចង្អៀតចង្អល់ ឥតមានសេចក្តីតានតឹង ឥតមានសេចក្តីក្តៅក្រហាយ ក្នុងបច្ចុប្បន្ន រមែងបរិនិព្វានក្នុងបច្ចុប្បន្ន ។ ដែលកើតអំពីទោសៈ ។ បេ ។ អកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតអំពីមោហៈ បុគ្គលនោះលះបានហើយ គាស់រំលើងឫសគល់អស់ហើយ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើមិនឲ្យមានបែបភាព មានកិរិយាមិនកើតតទៅទៀតជាធម្មតា បុគ្គលមានសភាពយ៉ាងនេះ តែងនៅជាសុខ ឥតមានសេចក្តីចង្អៀតចង្អល់ ឥតមានសេចក្តីតានតឹង ឥតមានសេចក្តីក្តៅក្រហាយ ក្នុងបច្ចុប្បន្ន រមែងបរិនិព្វាន ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ដូចដើមសាលព្រឹក្ស ដើមថ្នឹក ឬដើមពង្រ ត្រូវវល្លិ៍ជ្រៃ ៣ ដើម រួបរឹតព័ទ្ធព័ន្ធដោយជុំវិញ ។ កាលណោះមានបុរសកាន់ចប និងកញ្ជើ ដើរមក បុរសនោះក៏កាប់ពួរជ្រៃ ត្រង់គល់ លុះកាប់គល់រួចហើយជីកគាស់ លុះជីកគាស់ហើយ ក៏កើចយកឫសទាំងឡាយ ដោយហោចទៅ សូម្បីប៉ុនលំពង់ស្បូវភ្លាំង (ក៏មិនឲ្យសល់) បុរសនោះក៏កាត់ពួរជ្រៃនោះ ឲ្យជាកំណាត់តូចកំណាត់ធំ

ខណ្ឌាខណ្ឌិកំ ឆេត្វា ផាលេយ្យ ផាលេត្វា សកលិកំ ករេយ្យ សកលិកំ ករិត្វា វាតាតបេ វិសោសេយ្យ វាតាតបេ វិសោសេត្វា អគ្គិនា ឌហេយ្យ អគ្គិនា ឌហិត្វា មសឹ ករេយ្យ មសឹ ករិត្វា មហាវាតេ វា ឱផុនេយ្យ នទិយា វា សីឃស្សោតាយ បវាហេយ្យ ឯវមស្ស តា ភិក្ខវេ មាលុវាលតា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំ កតា អាយតឹអនុប្បាទធម្មា ឯវមេវ ខោ ភិក្ខវេ ឯវរូបស្ស បុគ្គលស្ស លោភជា បាបកា អកុសលា ធម្មា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំ កតា អាយតឹអនុប្បាទធម្មា ទិដ្ឋេវ ធម្មេ សុខំ វិហរតិ អវិឃាតំ អនុបាយាសំ អបរិឡាហំ ទិដ្ឋេវ ធម្មេ បរិនិព្វាយតិ ។ ទោសជា ។ បេ ។ មោហជា បាបកា អកុសលា ធម្មា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា

លុះកាត់ឲ្យជាកំណាត់តូច កំណាត់ធំរួចហើយ ក៏ពុះ លុះពុះរួចហើយ ក៏ធ្វើឲ្យជាចម្រៀកៗ លុះធ្វើឲ្យជាចម្រៀកៗ រួចហើយ ក៏ហាលខ្យល់និងកម្ដៅថ្ងៃឲ្យស្ងួត លុះហាលខ្យល់និងកម្ដៅថ្ងៃរួចហើយ ក៏ដុតដោយភ្លើង លុះដុតដោយភ្លើងរួចហើយ ក៏ធ្វើឲ្យជាធ្យូង លុះធ្វើឲ្យជាធ្យូងរួចហើយ ក៏បាចសាចទៅតាមខ្យល់ដ៏ខ្លាំង ឬបណ្ដែតទៅតាមខ្សែទឹកស្ទឹង ដែលហូរខ្លាំង ម្នាលភិក្ខុទាំងឡាយ ពូជជ្រៃទាំងអម្បាលនោះ ដែលបុគ្គលនោះ គាស់រំលើងឫសគល់អស់ហើយ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើមិនឲ្យមានបែបភាព មានកិរិយាមិនកើតតទៅទៀតជាធម្មតាយ៉ាងនេះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ទាំងឡាយ ដ៏លាមក ដែលកើតអំពីលោភៈ ដែលបុគ្គលមានសភាពយ៉ាងនេះ លះបានហើយ បានគាស់រំលើងឫសគល់អស់ហើយ ធ្វើឲ្យដូចជាដើមត្នោតកំបុតក ធ្វើមិនឲ្យមានបែបភាព មានកិរិយាមិនកើតតទៅទៀតជាធម្មតា បុគ្គលមានសភាពយ៉ាងនេះ តែងនៅជាសុខ មិនមានសេចក្ដីចង្អៀតចង្អល់ មិនមានសេចក្ដីតានតឹង មិនមានសេចក្ដីក្ដៅក្រហាយ ក្នុងបច្ចុប្បន្ន រមែងបរិនិព្វាន ក្នុងបច្ចុប្បន្ន ។ កើតអំពីទោសៈ ។ បេ ។ អកុសលធម៌ទាំងឡាយដ៏លាមក ដែលកើតអំពីមោហៈ បុគ្គលនោះ លះបានហើយ គាស់រំលើងឫសគល់អស់ហើយ ធ្វើឲ្យដូចជាដើមត្នោតកំបុតក

អនភាវំ កាតា អាយតឹអនុប្បាទធម្មា ទិដ្ឋេវ ធម្មេ សុខំ វិហរតិ អវិឃាតំ អនុបាយាសំ អបរិឡាហំ ទិដ្ឋេវ ធម្មេ បរិនិព្វាយតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ កុសលមូលានីតិ ។

[៧២] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុប្បាសាទេ ។ អថខោ វិសាខា មិគារមាតា តទហុបោសថេ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វិសាខំ មិគារមាតរំ ភគវា ឯតទវោច ហន្ទ កុតោ នុ ត្វំ វិសាខេ អាគច្ឆសិ ទិវា ទិវស្សាតិ ។ ឧបោសថាហំ ភន្តេ អជ្ជ ឧបវសាមីតិ ។ តយោ មេ វិសាខេ ឧបោសថា ។ កតមេ តយោ ។ គោបាលកុបោសថោ និគណ្ឋុបោសថោ អរិយុបោសថោ ។

ធ្វើមិនឲ្យមានបែបភាព មានកិរិយាមិនកើតតទៅទៀតជាធម្មតា បុគ្គលមានសភាពយ៉ាងនេះ តែងនៅជាសុខ មិនមានសេចក្ដីចង្អៀតចង្អល់ មិនមានសេចក្ដីតានតឹង មិនមានសេចក្ដីក្ដៅក្រហាយ ក្នុងបច្ចុប្បន្ន រមែងបរិនិព្វាន ក្នុងបច្ចុប្បន្ន ក៏យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កុសលមូលមាន ៣ យ៉ាងនេះឯង ។

[៧២] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទរបស់មិគារមាតា ក្នុងវត្តបុព្វារាម ទៀបក្រុងសាវត្ថី ។ គ្រានោះ ថ្ងៃនោះជាថ្ងៃឧបោសថសីល នាងវិសាខាមិគារមាតា ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលនាងវិសាខា ចុះនាងមកពីណាទាំងថ្ងៃម៉្ងៃះ ។ នាងវិសាខាក្រាបបង្គំទូលថា ថ្ងៃនេះខ្ញុំម្ចាស់រក្សាឧ-បោសថៈ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលនាងវិសាខា ឧបោ-សថៈនេះ មាន ៣ យ៉ាង ។ ឧបោសថៈ ៣ យ៉ាងតើដូចម្ដេច ។ គឺគោបាលកុ-បោសថៈ (ឧបោសថៈរបស់គង្វាលគោ) ១ និគណ្ឋុបោសថៈ (ឧបោសថៈរបស់និគ្រណ្ឋ) ១ អរិយុបោសថៈ (ឧបោសថៈរបស់ព្រះអរិយៈ) ១ ។

កថញ្ច វិសាខេ គោបាលកុបោសថោ ហោតិ ។ សេយ្យថាបិ វិសាខេ គោបាលកោ សាយណ្ហសមយេ សាមិកានំ គាវោ និយ្យាតេត្វា ឥតិ បដិសញ្ចិក្ខតិ អជ្ជ ខោ គាវោ អមុស្មិញ្ច អមុស្មិញ្ច បទេសេ ចរឹសុ អមុស្មិញ្ច អមុស្មិញ្ច បទេសេ បានីយានិ បិវឹសុ[១] ស្វេទានិ គាវោ អមុស្មិញ្ច អមុស្មិញ្ច បទេសេ ចរិស្សន្តិ អមុស្មិញ្ច អមុស្មិញ្ច បទេសេ បានីយានិ បិវិស្សន្តីតិ ។ ឯវមេវ ខោ វិសាខេ ឥធេកច្ចោ ឧបោសថិកោ ឥតិ បដិសញ្ចិក្ខតិ អហំ ខ្វជ្ជ ឥទញ្ចិទញ្ច ខាទនីយំ ខាទឹ ឥទញ្ចិទញ្ច ភោជនីយំ ភុញ្ជឹ ស្វេទានាហំ ឥទញ្ចិទញ្ច ខាទនីយំ ខាទិស្សាមិ ឥទញ្ចិទញ្ច ភោជនីយំ ភុញ្ជិស្សាមីតិ សោ តេន លោភេន អភិជ្ឈាសហគតេន ចេតសា ទិវសំ អតិនាមេតិ ។ ឯវំ ខោ វិសាខេ គោបាលកុបោសថោ ហោតិ ។ ឯវំ ឧបវុត្ថោ ខោ វិសាខេ គោបាលកុបោសថោ ន មហប្ផលោ ហោតិ

---

១ ឱ. អបំសុ ។

ម្នាលនាងវិសាខា ចុះគោបាលកុបោសថៈតើដូចម្តេច ។ ម្នាលនាងវិសាខា ដូចគង្វាលគោ ប្រគល់គោទាំងឡាយ ដល់អ្នកម្ចាស់គោ ក្នុងវេលាល្ងាចរួចហើយ គិតរំពឹងដូច្នេះថា ថ្ងៃនេះ គោទាំងឡាយ ត្រាច់រកស៊ីក្នុងទីឯណោះៗ ផឹកទឹកក្នុងទីឯណោះៗ ស្អែកនេះ គោទាំងឡាយ នឹងត្រាច់ទៅរកស៊ីក្នុងទីឯណោះៗ នឹងផឹកទឹកក្នុងទីឯណោះៗ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នករក្សាឧបោសថសីលហើយ គិតជញ្ជឹងដូច្នេះថា ក្នុងថ្ងៃនេះ អាត្មាអញបានទំពាស៊ី នូវខាទនីយៈនេះផងៗ អាត្មាអញបានបរិភោគ នូវភោជនីយៈនេះផងៗ ស្អែកនេះ អាត្មាអញនឹងទំពាស៊ី នូវខាទនីយៈនេះផងៗ នឹងបរិភោគនូវភោជនីយៈនេះផង ៗ បុគ្គលនោះ មានចិត្តប្រកបដោយអភិជ្ឈា តែងញុំាងថ្ងៃឲ្យប្រព្រឹត្តកន្លងទៅដោយលោភៈនោះ ក៏យ៉ាងនោះឯង ។ ម្នាលនាងវិសាខា យ៉ាងនេះឯងឈ្មោះថា គោបាលកុបោសថៈ ។ ម្នាលនាងវិសាខា គោបាលកុបោសថៈ ដែលបុគ្គលរក្សាយ៉ាងនេះ ជាឧបោសថៈ មិនមានផលច្រើន

ន មហានិសំសោ ន មហាជុតិកោ ន មហាវិប្ផារោ ។ កថញ្ច វិសាខេ និគណ្ឋុបោសថោ ហោតិ ។ អត្ថិ វិសាខេ និគណ្ឋា នាម សមណជាតិកា តេ សាវកំ ឯវំ សមាទបេន្តិ ឯហិ ត្វំ អម្ភោ បុរិស យេ បុរត្ថិមាយ ទិសាយ បាណា បរំយោជនសតំ តេសុ ទណ្ឌំ និក្ខិបាហិ យេ បច្ឆិមាយ ទិសាយ បាណា បរំយោជនសតំ តេសុ ទណ្ឌំ និក្ខិបាហិ យេ ឧត្តរាយ ទិសាយ បាណា បរំយោជនសតំ តេសុ ទណ្ឌំ និក្ខិបាហិ យេ ទក្ខិណាយ ទិសាយ បាណា បរំយោជនសតំ តេសុ ទណ្ឌំ និក្ខិបាហីតិ ។ ឥតិ ឯកច្ចានំ បាណានំ អនុទ្ទយាយ អនុកម្បាយ សមាទបេន្តិ ឯកច្ចានំ បាណានំ នានុទ្ទយាយ នានុកម្បាយ សមាទបេន្តិ ។ តេ តទហុបោសថេ សាវកំ ឯវំ សមាទបេន្តិ ឯហិ ត្វំ អម្ភោ បុរិស សព្វចេលានិ[១] និក្ខិបិត្វា ឯវំ វទេហិ

---

១ ម. សព្វវេភានិ ។

មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយផលច្រើនទេ ។ ម្នាលនាងវិសាខា ចុះនិគណ្ឋុបោសថៈ តើដូចម្តេច ។ ម្នាលនាងវិសាខា មានពួកសមណៈហៅថា និគណ្ឋៈ សមណៈអម្បាលនោះ តែងដឹកនាំសាវ័កយ៉ាងនេះថា នែ បុរសដ៏ចម្រើន អ្នកចូរមកអាយ សត្វទាំងឡាយណា មាននៅក្នុងទិសខាងកើតខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញា (សម្ងាប់) សត្វអម្បាលនោះចុះ សត្វទាំងឡាយណា មាននៅក្នុងទិសខាងលិចខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញា ក្នុងសត្វអម្បាលនោះចុះ សត្វទាំងឡាយណា មាននៅក្នុងទិសខាងជើងខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញា ក្នុងសត្វអម្បាលនោះចុះ សត្វទាំងឡាយណា មាននៅក្នុងទិសខាងត្បូងខាងនាយពី ១០០ យោជន៍ទៅ អ្នកចូរដាក់អាជ្ញា ក្នុងសត្វអម្បាលនោះចុះ ។ ពួកនិគ្រណ្ឋតែងដឹកនាំសាវ័កឲ្យអាណិត អនុគ្រោះចំពោះពួកសត្វខ្លះ តែងដឹកនាំសាវ័ក មិនឲ្យអាណិត មិនឲ្យអនុគ្រោះចំពោះពួកសត្វខ្លះ ។ ក្នុងថ្ងៃឧបោសថនោះ គេតែងដឹកនាំសាវ័កយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកចូរមកអាយ អ្នកចូរស្រាតសំពត់ឲ្យអស់ ហើយពោលយ៉ាងនេះថា

ជាហំ ក្វចិនិ កស្សចិ កិញ្ចនំ តស្មឹ ន ច មម ក្វចិនិ កិស្មិញ្ចិ កិញ្ចនត្ថីតិ ជានន្តិ ខោ បនស្ស មាតាបិតរោ អយំ អម្ហាកំ បុត្តោតិ សោបិ ជានាតិ ឥមេ មយ្ហំ មាតាបិតរោតិ ជានាតិ ខោ បនស្ស បុត្តទារោ អយំ មយ្ហំ ភត្តាតិ សោបិ ជានាតិ អយំ មយ្ហំ បុត្តទារោតិ ជានន្តិ ខោ បនស្ស ទាសកម្មករបោរិសា អយំ អម្ហាកំ អយ្យោតិ សោបិ ជានាតិ ឥមេ មយ្ហំ ទាសកម្មករបោរិសាតិ ។ ឥតិ យស្មឹ សមយេ សច្ចេ[១] សមាទបេតព្វា មុសាវាទេ តស្មឹ សមយេ សមាទបេតិ ។ ឥទមស្ស មុសាវាទស្មឹ វទាមិ ។ សោ តស្សា រត្តិយា អច្ចយេន តេ ភោគេ អទិន្នំយេវ បរិភុញ្ជតិ ។ ឥទមស្ស អទិន្នាទានស្មឹ វទាមិ ។ ឯវំ ខោ វិសាខេ និគណ្ឋុបោសថោ ហោតិ ។ ឯវំ ឧបវុត្ថោ ខោ វិសាខេ និគណ្ឋុបោសថោ ន មហប្ផលោ ហោតិ ន មហានិសំសោ ន មហាជុតិកោ ន មហា-វិប្ផារោ ។ កថញ្ច វិសាខេ អរិយុបោសថោ ហោតិ ។

១ ឱ. សព្វេ ។

អាត្មាអញមិនទាក់ទាមនឹងនរណាៗ ក្នុងទីណាៗ នឹងមានកង្វល់ក្នុងរបស់អ្វីៗ ក្នុងទីណាៗ ក៏មិនមានដល់អាត្មាអញឡើយ តែមាតាបិតារបស់គេក៏ដឹងថា នេះបុត្ររបស់អញ ទាំងខ្លួនគេក៏ដឹងថា នេះមាតាបិតារបស់អញ បុត្រភរិយារបស់គេក៏ដឹងថា នេះជាស្វាមីរបស់អញ ទាំងខ្លួនគេក៏ដឹងថា នេះជាបុត្រភរិយារបស់អញ ពួកបុរសជាទាសកម្មកររបស់គេក៏ដឹងថា នេះជាម្ចាស់របស់អញ ទាំងខ្លួនគេក៏ដឹងថា នេះជាពួកបុរសដែលជាទាស-កម្មកររបស់អញ (សាវ័កទាំងនោះ) ត្រូវគេដឹកនាំក្នុងសច្ចៈដូច្នេះ ក្នុងសម័យណា (អ្នកដឹកនាំ) ឈ្មោះថា ដឹកនាំក្នុងមុសាវាទ ក្នុងសម័យនោះ ។ តថាគតពោលថា ពាក្យដឹកនាំនេះជាពាក្យមុសាវាទរបស់គេ ។ លុះកន្លងរាត្រីនោះហើយ គេបរិភោគភោគទាំងអម្បាលនោះ ដែលម្ចាស់គេមិនបានឲ្យ ។ តថាគតពោលថា ការបរិភោគៈនេះជាអទិន្នាទានរបស់គេ ។ ម្នាលនាងវិសាខា យ៉ាងនេះឯង ឈ្មោះថា និគណ្ឋុបោសថៈ ។ ម្នាលនាងវិសាខា និគណ្ឋុបោសថៈដែលគេរក្សាយ៉ាងនេះ ជាឧបោសថៈមិនមានផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយផលច្រើនទេ ។ ម្នាលនាងវិសាខា ចុះអរិយុបោសថៈតើដូចម្តេច ។

២៦៣

ទុតិយបណ្ណាសកេ មហាវគ្គោ

ឧបក្កិលិដ្ឋស្ស វិសាខេ ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោ-ទបនា ហោតិ ។ ឥធ វិសាខេ អរិយសាវកោ តថាគតំ អនុស្សរតិ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ តស្ស តថាគតំ អនុស្សរតោ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ សេយ្យថាបិ វិសាខេ ឧបក្កិលិដ្ឋស្ស សីសស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិ-លិដ្ឋស្ស សីសស្ស ឧបក្កមេន បរិយោទបនា ហោតិ ។

ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម តើដូចម្ដេច ។ ម្នាលនាងវិសាខា អរិយសាវ័ក ក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះតថាគតថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថី អ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ កាលអរិយសាវ័កនោះ កំពុងរឭកនូវព្រះតថាគត ចិត្តរមែងជ្រះថ្លា សេចក្ដីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងនោះ អរិយសាវ័កនោះ ក៏លះបង់ចេញបាន ម្នាលនាងវិសាខា ដូចការជម្រះក្បាលដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្ដីព្យាយាម ។ ម្នាលនាងវិសាខា ចុះការជម្រះក្បាល ដែលមិនស្អាតឲ្យស្អាតបាន ដោយសេចក្ដីព្យាយាម តើដូចម្ដេច ។

កក្កញ្ច បដិច្ច មត្តិកញ្ច បដិច្ច ឧទកញ្ច បដិច្ច បុរិសស្ស ច តជ្ជំ វាយាមំ បដិច្ច ឯវំ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស សីសស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឯវមេវ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិ-លិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឥធ វិសាខេ អរិយសាវកោ តថាគតំ អនុស្សរតិ ឥតិបិ សោ ភគវា ។ បេ ។ ពុទ្ធោ ភគវាតិ ។ តស្ស តថាគតំ អនុស្សរតោ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្ប-ជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ អយំ វុច្ចតិ វិសាខេ អរិយសាវកោ ព្រហ្មុបោសថំ ឧបវសតិ ព្រហ្មុនា សទ្ធឹ សំវសតិ ព្រហ្មញ្ចស្ស អារព្ភ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ ។

ម្នាលនាងវិសាខា ការអាស្រ័យកាក (កន្ទួតព្រៃ) ផង អាស្រ័យដីផង អាស្រ័យទឹកផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរដល់កិច្ចនោះ របស់បុរសផង ទើបធ្វើក្បាលដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាមយ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមក៏យ៉ាងនោះដែរ ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់ ដោយសេចក្តីព្យាយាមតើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវ័ក ក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះតថាគតថា ព្រះមានព្រះភាគអង្គនោះ ។ បេ ។ ព្រះអង្គត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត ។ កាលអរិយសាវ័កនោះ កំពុងរឭករឿយៗ នូវព្រះតថាគត ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណា របស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវ័កនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវ័កនេះ ហៅថា រក្សាព្រហ្មុបោសថៈ (ឧបោសថៈរបស់ព្រហ្ម) នៅរួមនឹងព្រហ្ម ចិត្តរបស់គេប្រារព្ធចំពោះព្រហ្ម រមែងជ្រះថ្លា សេចក្តីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណា របស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវ័កនោះ ក៏លះបង់ចេញបាន ។

ឯវំ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឧបក្កិលិដ្ឋស្ស វិសាខេ ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឥធ វិសាខេ អរិយសាវកោ ធម្មំ អនុស្សរតិ ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ តស្ស ធម្មំ អនុស្សរតោ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ ។ សេយ្យថាបិ វិសាខេ ឧបក្កិលិដ្ឋស្ស កាយស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិលិដ្ឋស្ស កាយស្ស ឧបក្កមេន បរិយោទបនា ហោតិ ។

ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរ-ផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវ័ក ក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះធម៌ថា ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ប្រពៃហើយ ជាធម៌ដែលបុគ្គលប្រតិបត្តិគប្បីឃើញចំពោះខ្លួន ជាធម៌ឲ្យផលមិនរង់ចាំកាល ជាធម៌គួរហៅអ្នកដទៃឲ្យចូលមកមើលបាន ជាធម៌គួរបង្អោនចូលមកក្នុងខ្លួន ជាធម៌ដែលវិញ្ញូជន គប្បីដឹងចំពោះខ្លួន ។ កាលអរិយសាវ័កនោះ កំពុងរឭកនូវព្រះធម៌ ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំង-ឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវ័កនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ដូចការជម្រះកាយដែលមិនស្អាតរមែងឲ្យស្អាតបាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការជម្រះកាយដែលមិនស្អាតរមែងឲ្យស្អាតបានដោយសេចក្តីព្យាយាម តើដូចម្តេច ។

២៦៦



សោត្តិញ្ច បដិច្ច ចុណ្ណញ្ច បដិច្ច ឧទកញ្ច បដិច្ច បុរិសស្ស ច តជ្ជំ វាយាមំ បដិច្ច ឯវំ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស កាយស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឯវមេវ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឥធ វិសាខេ អរិយសាវកោ ធម្មំ អនុស្សរតិ ស្វាក្ខាតោ ភគវតា ធម្មោ ។ បេ ។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ ។ តស្ស ធម្មំ អនុស្សរតោ ចិត្តំ បសីទតិ ចាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ អយំ វុច្ចតិ វិសាខេ អរិយសាវកោ ធម្មុបោសថំ ឧបវសតិ ធម្មេន សទ្ធឹ សំវសតិ ធម្មញ្ចស្ស អារព្ភ ចិត្តំ បសីទតិ ចាមុជ្ជំ ឧប្បជ្ជតិ

ម្នាលនាងវិសាខា ការអាស្រ័យដុំលំអិតសម្រាប់ជម្រះកាយផង អាស្រ័យលំអិតសម្រាប់ផ្ងូតផង អាស្រ័យទឹកផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរ ដល់កិច្ចនោះរបស់បុរសផង ទើបធ្វើការជម្រះកាយ ដែលមិនស្អាតឲ្យស្អាតបាន ដោយសេចក្តីព្យាយាម យ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនោះដែរ ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវ័ក ក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះធម៌ថា ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ទុកប្រពៃហើយ ។ បេ ។ ជាធម៌ដែលវិញ្ញូជនទាំងឡាយគប្បីដឹងចំពោះខ្លួន ។ កាលអរិយសាវ័កនោះ កំពុងរឭកនូវព្រះធម៌ ចិត្តរមែងជ្រះថ្លា សេចក្តីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំង-ឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវ័កនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវ័កនេះ ហៅថា រក្សាធម្មុបោសថៈ នៅរួមដោយធម៌ ចិត្តរបស់អរិយសាវ័កនោះប្រារព្ធចំពោះព្រះធម៌ រមែងជ្រះថ្លា សេចក្តីរីករាយ ក៏រមែងកើតឡើង

យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ ។ ឯវំ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឧបក្កិលិដ្ឋស្ស វិសាខេ ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឥធ វិសាខេ អរិយសាវកោ សង្ឃំ អនុស្សរតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិបន្នោ ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិសយុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវកសង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ តស្ស សង្ឃំ អនុស្សរតោ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ ។

ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវ័កនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាមយ៉ាងនេះ ។ ម្នាលនាងវិសាខា ការធ្វើចិត្ត ដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម តើដូចម្ដេច ។ ម្នាលនាងវិសាខា អរិយសាវ័ក ក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវព្រះសង្ឃថាពួកសាវ័កនៃព្រះមានព្រះភាគ ប្រតិបត្តិប្រពៃហើយ ពួកសាវ័កនៃព្រះមានព្រះភាគ ប្រតិបត្តិត្រង់ហើយ ពួកសាវ័កនៃព្រះមានព្រះភាគ ប្រតិបត្តិសមគួរហើយ គឺប្រតិបត្តិគួរដល់សីល សមាធិ បញ្ញា ពួកសាវកណាបើរាប់ជាគូនៃបុរសបាន ៤ គូ បើរាប់រៀងជាបុរសបុគ្គល មាន ៨ ពួក សាវ័កនៃព្រះមានព្រះភាគនុ៎ះ គួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលនាំមកអំពីចម្ងាយហើយបូជា គួរទទួលនូវអាគន្តុកទាន គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ កាលអរិយសាវ័កនោះ កំពុងរឭករឿយៗ នូវព្រះសង្ឃ ចិត្តរមែងជ្រះថ្លា សេចក្ដីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះអរិយសាវ័កនោះ ក៏លះបង់បាន ។

សេយ្យថាបិ វិសាខេ ឧបក្កិលិដ្ឋស្ស វត្ថស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិ-លិដ្ឋស្ស វត្ថស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឩសញ្ច[១] បដិច្ច ខារញ្ច បដិច្ច គោមយញ្ច បដិច្ច ឧទកញ្ច បដិច្ច បុរិសស្ស ច តជ្ជំ វាយាមំ បដិច្ច ឯវំ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស វត្ថស្ស ឧបក្ក-មេន បរិយោទបនា ហោតិ ។ ឯវមេវ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឥធ វិសាខេ អរិយសាវកោ សង្ឃំ អនុស្សរតិ សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ... អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។ តស្ស សង្ឃំ អនុស្សរតោ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ ។ អយំ វុច្ចតិ វិសាខេ អរិយសាវកោ

---

១ ម. ឧស្មញ្ច ។

ម្នាលនាងវិសាខា ដូចការធ្វើសំពត់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើសំពត់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា ព្រោះអាស្រ័យចំហាយផង អាស្រ័យទឹកក្បុងផង អាស្រ័យអាចម៍គោផង អាស្រ័យទឹកផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរ ដល់កិច្ចនោះរបស់បុរសផង ទើបធ្វើសំពត់ដែលមិនស្អាតឲ្យស្អាតបានដោយសេចក្តីព្យាយាម យ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមក៏យ៉ាងនោះឯង ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្ត ដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវ័ក ក្នុងធម្មវិន័យនេះ រមែងរឮករឿយៗ នូវព្រះសង្ឃថា ពួកសាវកនៃព្រះមានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ... ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ កាលព្រះអរិយសាវ័កនោះ កំពុងរឮករឿយៗ នូវព្រះសង្ឃ ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវ័កនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវ័កនេះ ហៅថា ។

២៦៩



សង្ឃុបោសថំ ឧបវសតិ សង្ឃេន សទ្ធឹ សំវសតិ សង្ឃញ្ចស្ស អារព្ភ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ ។ ឯវំ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឧបក្កិលិដ្ឋស្ស វិសាខេ ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឥធ វិសាខេ អរិយសាវកោ អត្តនោ សីលានិ អនុស្សរតិ អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញុប្បសត្ថានិ អបរាមដ្ឋានិ សមាធិសំ-វត្តនិកានិ ។ តស្ស សីលំ អនុស្សរតោ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ ។ សេយ្យថាបិ វិសាខេ ឧបក្កិលិដ្ឋស្ស អាទាសស្ស ឧបក្កមេន បរិយោ-ទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិលិដ្ឋស្ស អាទាសស្ស ឧបក្កមេន បរិយោទបនា ហោតិ ។

រក្សាសង្ឃុបោសថៈ នៅរួមជាមួយនឹងព្រះសង្ឃ ចិត្តរបស់អរិយសាវ័កនោះ ប្រារព្ធចំពោះព្រះសង្ឃ រមែងជ្រះថ្លា សេចក្តីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវ័កនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង រមែងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម យ៉ាងនេះឯង ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវ័កក្នុងធម្មវិន័យនេះ រឭករឿយៗ នូវសីលរបស់ខ្លួន ជាសីលមិនដាច់ មិនធ្លុះធ្លាយ មិនពព្រុស មិនពពាល ជាសីលអ្នកជា ជាសីលដែលវិញ្ញូជនសរសើរហើយ ជាសីលមិនប៉ះពាល់ ដោយតណ្ហានិងទិដ្ឋិ ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ កាលអរិយសាវ័កនោះ កំពុងរលឹករឿយៗ នូវសីល ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយ រមែងកើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវ័កនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ដូចការដុសខាត់កញ្ចក់ដែលមិនស្អាត ឲ្យស្អាតបាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការដុសខាត់កញ្ចក់ដែលមិនស្អាតឲ្យស្អាតបាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។

តេលញ្ច បដិច្ច ឆារិកញ្ច បដិច្ច វាលណ្ឌុកញ្ច បដិច្ច បុរិសស្ស ច តជ្ជំ វាយាមំ បដិច្ច ឯវំ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស អាទាសស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឯវមេវ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឥធ វិសាខេ អរិយសាវកោ អត្តនោ សីលានិ អនុស្សរតិ អខណ្ឌានិ អច្ឆិទ្ទានិ... សមាធិសំវត្តនិកានិ ។ តស្ស សីលំ អនុស្សរតោ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ ។ អយំ វុច្ចតិ វិសាខេ អរិយសាវកោ សីលុបោសថំ ឧបវសតិ សីលេន សទ្ធឹ សំវសតិ សីលញ្ចស្ស អារព្ភ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ ។ ឯវំ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។

ម្នាលនាងវិសាខា ព្រោះអាស្រ័យប្រេងផង អាស្រ័យផេះផង អាស្រ័យប្រាសផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរដល់កិច្ចនោះរបស់បុរសផង ទើបដុសខាត់កញ្ចក់ ដែលមិនស្អាតឲ្យស្អាតបាន ដោយសេចក្តីព្យាយាម យ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមក៏យ៉ាងនោះឯង ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា អរិយសាវ័ក ក្នុងធម្មវិន័យនេះ រឭករឿយៗ នូវសីលរបស់ខ្លួន ដែលជាសីលមិនដាច់ មិនធ្លុះធ្លាយ... ជាសីលប្រព្រឹត្តទៅដើម្បីសមាធិ ។ កាលអរិយសាវ័កនោះ កំពុងរឭករឿយៗ នូវសីល ចិត្តក៏រមែងជ្រះថ្លា សេចក្តីរីករាយ ក៏កើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវ័កនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវ័កនោះ ហៅថា រក្សាសីលុ-បោសថៈ នៅរួមដោយសីល មួយទៀត ចិត្តរបស់អរិយសាវ័កនោះ ប្រារព្ធចំពោះសីល ក៏ជ្រះថ្លា សេចក្តីរីករាយ ក៏រមែងកើតឡើង ឧបក្កិ-លេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយ-សាវ័កនោះ ក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា ការធ្វើចិត្ត ដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម យ៉ាងនេះឯង ។

ឧបក្កិលិដ្ឋស្ស វិសាខេ ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឥធ វិសាខេ អរិយសាវកោ ទេវតា អនុស្សរតិ សន្តិ ទេវា ចាតុម្មហារាជិកា សន្តិ ទេវា តាវត្តឹសា សន្តិ ទេវា យាមា សន្តិ ទេវា តុសិតា សន្តិ ទេវា និម្មានរតិនោ សន្តិ ទេវា បរនិម្មិតវសវត្តិនោ សន្តិ ទេវា ព្រហ្មកាយិកា សន្តិ ទេវា តទុត្តរិ យថារូបាយ សទ្ធាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថុបបន្នា មយ្ហំបិ តថារូបា សទ្ធា សំវិជ្ជតិ យថារូបេន សីលេន សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថុបបន្នា មយ្ហំបិ តថារូបំ សីលំ សំវិជ្ជតិ យថារូបេន សុតេន សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថុបបន្នា មយ្ហំបិ តថារូបំ សុតំ សំវិជ្ជតិ យថារូបេន ចាគេន សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថុបបន្នា មយ្ហំបិ តថារូបោ ចាគោ

ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្ដីព្យាយាម តើដូចម្ដេច ។ ម្នាលនាងវិសាខា អរិយសាវ័ក ក្នុងធម្មវិន័យនេះ រឭករឿយៗ នូវទេវតាទាំងឡាយថា ពួកទេវតាជាន់ចាតុម្មហារាជិកៈក៏មាន ពួកទេវតាជាន់តាវត្តិង្សក៏មាន ពួកទេវតាជាន់យាមៈក៏មាន ពួកទេវតាជាន់តុសិតក៏មាន ពួកទេវតាជាន់និម្មានរតីក៏មាន ពួកទេវតាជាន់បរនិម្មិតវសវត្តីក៏មាន ពួកទេវតាដែលរាប់បញ្ចូល ក្នុងពួកព្រហ្មក៏មាន ពួកទេវតាជាន់ខ្ពស់ឡើងទៅទៀតក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ សទ្ធាមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសីល មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើត ក្នុងភពនោះ សីលមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសុតៈ មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើត ក្នុងភពនោះ សុតៈមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយចាគៈ មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើត ក្នុងភពនោះ ចាគៈមានសភាពដូច្នោះ

សំវិជ្ជតិ យថារូបាយ បញ្ញាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថុបបន្នា មយ្ហំបិ តថារូបា បញ្ញា សំវិជ្ជតីតិ ។ តស្ស អត្តនោ ច តាសញ្ច ទេវតានំ សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរតោ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ ។ សេយ្យថាបិ វិសាខេ ឧបក្កិលិដ្ឋស្ស ជាតរូបស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិលិដ្ឋស្ស ជាតរូបស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឧក្កញ្ច បដិច្ច លោណញ្ច បដិច្ច គេរុញ្ច បដិច្ច នាឡិសណ្ឌាសញ្ច បដិច្ច បុរិសស្ស ច តជ្ជំ វាយាមំ បដិច្ច ឯវំ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស ជាតរូបស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ឯវមេវ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ កថញ្ច វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។

របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយបញ្ញា មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ បញ្ញាមានសភាពដូច្នោះរបស់អាត្មាអញក៏មាន ។ កាលអរិយ-សាវ័កនោះរឭករឿយៗ នូវសទ្ធា សីលៈ សុតៈ ចាគៈបញ្ញារបស់ខ្លួននិងរបស់ទេវតាទាំងអម្បាលនោះ ចិត្តក៏ជ្រះថ្លា សេចក្តីរីករាយ ក៏កើតឡើង ឧបក្កិ-លេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវ័កនោះ ក៏លះបង់បេញបាន ។ ម្នាលនាងវិសាខា ដូចការដុសខាត់មាសដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ។ ម្នាលនាងវិសាខា ចុះការដុសខាត់មាសដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។ ម្នាលនាងវិសាខា ព្រោះអាស្រ័យបាវមាសផង អាស្រ័យដីប្រែផង អាស្រ័យរង្គផង អាស្រ័យស្នប់និងដង្កាប់ផង អាស្រ័យសេចក្តីព្យាយាមដ៏សមគួរដល់កិច្ចនោះរបស់បុរសផង ទើបដុសខាត់មាស ដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម យ៉ាងនេះ យ៉ាងណាមិញ ។ ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម ក៏ដូច្នោះ យ៉ាងនោះឯង ។ ម្នាលនាងវិសាខា ចុះការធ្វើចិត្តដែលសៅហ្មង ឲ្យផូរផង់បាន ដោយសេចក្តីព្យាយាម តើដូចម្តេច ។

៩ឰ វិសាខេ អរិយសាវកោ ទេវតា អនុស្សរតិ សន្តិ ទេវា ចាតុម្មហារាជិកា សន្តិ ទេវា តាវត្តឹសា ។ បេ ។ សន្តិ ទេវា ព្រហ្មកាយិកា សន្តិ ទេវា តទុត្តរិ យថារូបាយ សទ្ធាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថុបបន្នា មយ្ហំបិ តថារូបា សទ្ធា សំវិជ្ជតិ យថារូបេន សីលេន... សុតេន... ចាគេន... បញ្ញាយ សមន្នាគតា តា ទេវតា ឥតោ ចុតា តត្ថុបបន្នា មយ្ហំបិ តថារូបា បញ្ញា សំវិជ្ជតីតិ ។ តស្ស អត្តនោ ច តាសញ្ច ទេវតានំ សទ្ធញ្ច សីលញ្ច សុតញ្ច ចាគញ្ច បញ្ញញ្ច អនុស្សរតោ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ ។ អយំ វុច្ចតិ វិសាខេ អរិយសាវកោ ទេវតូបោ-សថំ ឧបវសតិ ទេវតាហិ សទ្ធឹ សំវសតិ ទេវតា ចស្ស អារព្ភ ចិត្តំ បសីទតិ បាមុជ្ជំ ឧប្បជ្ជតិ យេ ចិត្តស្ស ឧបក្កិលេសា តេ បហីយន្តិ ។

ម្នាលនាងវិសាខា អរិយសាវ័ក ក្នុងធម្មវិន័យនេះ តែងរឭករឿយៗ នូវទេវតាថា ពួកទេវតាជាន់ចាតុម្មហារាជិកៈក៏មាន ពួកទេវតាជាន់តាវត្តិង្សក៏មាន ។ បេ ។ ពួកទេវតាដែលរាប់បញ្ចូលក្នុងពួកព្រហ្មក៏មាន ពួកទេវតាជាន់ខ្ពស់ឡើងទៅទៀតក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសទ្ធា មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើត ក្នុងភពនោះ សទ្ធាមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ទេវតាទាំងអម្បាលនោះ ប្រកបដោយសុតៈ... ដោយចាគៈ... ដោយបញ្ញា... មានសភាពយ៉ាងណា ច្យុតចាកអត្តភាពនេះហើយ ទើបបានទៅកើតក្នុងភពនោះ បញ្ញាមានសភាពដូច្នោះ របស់អាត្មាអញក៏មាន ។ កាលអរិយសាវ័កនោះ រឭករឿយៗ នូវសទ្ធា សីលៈ សុតៈ ចាគៈ បញ្ញា របស់ខ្លួននិងរបស់ទេវតាទាំងនោះ ចិត្តក៏ជ្រះថ្លា សេចក្ដីរីករាយ ក៏កើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិ-លេសទាំងឡាយនោះ អរិយសាវ័កនោះក៏លះបង់ចេញបាន ។ ម្នាលនាងវិសាខា អរិយសាវ័កនេះ ហៅថា ទេវតូបោសថៈ នៅរួមជាមួយនឹងពួកទេវតា មួយទៀត ចិត្តរបស់អរិយសាវ័កនោះ ប្រារព្ធទេវតា ក៏ជ្រះថ្លា សេចក្ដីរីករាយ ក៏កើតឡើង ឧបក្កិលេសទាំងឡាយណារបស់ចិត្ត ឧបក្កិលេសទាំងឡាយនោះ អរិយសាវ័កនោះ ក៏លះបង់ចេញបាន ។

ឯវំ ខោ វិសាខេ ឧបក្កិលិដ្ឋស្ស ចិត្តស្ស ឧបក្កមេន បរិយោទបនា ហោតិ ។ ស ខោ សោ វិសាខេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យាវជីវំ អរហន្តោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតា និហិតទណ្ឌា និហិតសត្ថា លជ្ជី ទយាបន្នា សព្វបា-ណភូតហិតានុកម្បី វិហរន្តិ អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរាមិ ឥមិនាបិ អង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។ យាវជីវំ អរហន្តោ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតា ទិន្នាទាយី ទិន្នប្បាដិកង្ខី អត្ថេនេន សុចិភូតេន អត្តនា វិហរន្តិ អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ទិន្នាទាយី ទិន្នប្បាដិកង្ខី

ម្នាលនាងវិសាខា ការធ្វើចិត្តដែលសៅហ្មងឲ្យផូរផង់បាន ដោយសេចក្តីព្យាយាមយ៉ាងនេះឯង ។ ម្នាលនាងវិសាខា អរិយសាវ័កនោះ តែងពិចារណាឃើញដូច្នេះថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប ប្រកបដោយសេចក្តីអាណិត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះសព្វសត្វដែលមានជីវិត ដរាបដល់អស់ជីវិត ឯអាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប ប្រកបដោយសេចក្តីអាណិត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ចំពោះសព្វសត្វដែលមានជីវិត អស់យប់នេះនិងថ្ងៃនេះដែរ អាត្មាអញឈ្មោះថាធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថៈឈ្មោះថាអាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាយកតែរបស់ដែលគេឲ្យ មានខ្លួនមិនលួច ស្អាតរហូតអស់ ១ ជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែរបស់ដែលគេឲ្យ ប្រាថ្នាយកតែរបស់ដែលគេឲ្យ

អត្ថេនេន សុចិភូតេន អត្តនា វិហរាមិ ឥមិនាបិ អង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។ យាវជីវំ អរហន្តោ អព្រហ្មចរិយំ បហាយ ព្រហ្មចារី អារាចារី វិរតា មេថុនា គាមធម្មា អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ អព្រហ្មចរិយំ បហាយ ព្រហ្មចារី អារាចារី វិរតោ មេថុនា គាមធម្មា ឥមិនាបិ អង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។ យាវជីវំ អរហន្តោ មុសាវាទំ បហាយ មុសាវាទា បដិវិរតា សច្ចវាទី សច្ចសន្ធា ថេតា បច្ចយិកា អវិសំវាទកា លោកស្ស អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស ឥមិនាបិ អង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ

មានខ្លួនមិនលួច ស្អាតនៅអស់យប់នេះនិងថ្ងៃនេះដែរ អាត្មាអញឈ្មោះថាធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថៈឈ្មោះថាអាត្មាអញបានរក្សាផងដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់អព្រហ្មចរិយៈ ជាព្រហ្មចារីបុគ្គល ជាអ្នកប្រព្រឹត្តឆ្ងាយចាក (អព្រហ្មចរិយៈ) វៀរចាកមេថុន ដែលជាធម៌របស់អ្នកស្រុក អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់អព្រហ្មចរិយៈ ជាព្រហ្មចារីបុគ្គល ជាអ្នកប្រព្រឹត្តឆ្ងាយចាក (អព្រហ្មចរិយៈ) វៀរចាកមេថុនដែលជាធម៌របស់អ្នកស្រុក អស់យប់នេះនិងថ្ងៃនេះដែរ អាត្មាអញឈ្មោះថាធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថៈ ឈ្មោះថាអាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់នូវមុសាវាទ វៀរចាកមុសាវាទ និយាយតែពាក្យពិត តភ្ជាប់តែពាក្យពិត មានពាក្យខ្ជាប់ខ្ជួន មានពាក្យគួរជឿ មិនពោលបង្កាច់សត្វលោក រហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់នូវមុសាវាទ វៀរចាកមុសាវាទ និយាយតែពាក្យពិត តភ្ជាប់តែពាក្យពិត មានពាក្យខ្ជាប់ខ្ជួន មានពាក្យគួរជឿ មិនពោលបង្កាច់សត្វលោក អស់យប់នេះនិងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថៈឈ្មោះថាអាត្មាអញ

ឧបវុត្ថោ ភវិស្សតិ ។ យាវជីវំ អរហន្តោ សុរាមេរយ-
មជ្ជប្បមាទដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមាទដ្ឋានា
បដិវិរតា អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សុរា-
មេរយមជ្ជប្បមាទដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមា-
ទដ្ឋានា បដិវិរតោ[១] ឥមិនាបិ អង្គេន អរហតំ អនុ-
ករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។
យាវជីវំ អរហន្តោ ឯកភត្តិកា រត្តូបរតា វិរតា
វិកាលភោជនា អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ
ឯកភត្តិកោ រត្តូបរតោ វិរតោ វិកាលភោជនា
ឥមិនាបិ អង្គេន អរហតំ អនុករោមិ ឧបោ-
សថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។ យាវជីវំ
អរហន្តោ នច្ចគីតវាទិតវិសូកទស្សនា[២]មាលាគន្ធវិ-
លេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតា អហម្បជ្ជ

---

១ ឱ. ម. ឯត្តន្តរេ វិហរាមីតិ បាឋោ ទិស្សតិ ។ ២ ទស្សនា ឥតិបិ ។

រក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ លះបង់ការក្រេបផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ រហូតអស់មួយជីវិត ឯអាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់ការក្រេបផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ វៀរចាកការក្រេបផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ អស់យប់នេះនិងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថៈឈ្មោះថាអាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ បរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគខុសកាល រហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏បរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគខុសកាល អស់យប់នេះនិងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថៈឈ្មោះថាអាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំងឡាយ វៀរចាកការមើលនូវរបាំ និងការស្តាប់នូវចម្រៀងនិងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់ ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាបផ្សេង ៗ អាត្មាអញក្នុងថ្ងៃនេះ

២៧៧



ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ នច្ចគីតវាទិតវិសូកទស្សន-មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ ឥមិនាបិ អង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតិ ។ យាវជីវំ អរហន្តោ ឧច្ចាសយន-មហាសយនំ បហាយ ឧច្ចាសយនមហាសយនា បដិវិរតា នីចសេយ្យំ កប្បេន្តិ មញ្ចកេ វា តិណសន្ថារកេ វា អហម្បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧច្ចាសយនមហាស-យនំ បហាយ ឧច្ចាសយនមហាសយនា បដិវិរតោ នីច-សេយ្យំ កប្បេមិ មញ្ចកេ វា តិណសន្ថារកេ វា ឥមិ-នាបិ អង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឯវំ ខោ វិសាខេ អរិយុបោ-សថោ ហោតិ ឯវំ ឧបវុត្ថោ ខោ វិសាខេ អរិយុបោ-សថោ មហប្ផលោ ហោតិ មហានិសំសោ មហា-ជុតិកោ មហាវិប្ផារោ ។ កីវមហប្ផលោ ហោតិ កីវមហានិសំសោ កីវមហាជុតិកោ កីវមហាវិប្ផារោ

ក៏វៀរចាកការមើលរបាំ និងការស្តាប់ចម្រៀងនិងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់ ស្អិតស្អាងរាងកាយ ដោយផ្កាកម្រងនិងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ អស់យប់នេះនិងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថ: ឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ព្រះអរហន្តទាំង-ឡាយ លះបង់ទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ វៀរស្រឡះចាកទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ សម្រេចទីដេកដ៏ទាប លើគ្រែតូច លើកម្រាលស្មៅក្តី រហូតអស់មួយជីវិត អាត្មាអញក្នុងថ្ងៃនេះ ក៏លះបង់ទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ វៀរស្រឡះចាកទីដេកទីអង្គុយដ៏ខ្ពស់និងទីដេកទីអង្គុយដ៏ប្រសើរ សម្រេចទីដេកដ៏ទាប លើគ្រែតូច លើកម្រាលស្មៅក្តី អស់យប់នេះនិងថ្ងៃនេះដែរ អាត្មាអញឈ្មោះថា ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថ:ឈ្មោះថា អាត្មាអញបានរក្សាផង ដោយអង្គនេះឯង ។ ម្នាលនាងវិសាខា យ៉ាងនេះឈ្មោះថា អរិយុបោសថ: ម្នាលនាងវិសាខា អរិយុបោសថ:ដែលបុគ្គលរក្សាយ៉ាងនេះតែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន ផ្សាយផលទៅច្រើន ។ មានផលច្រើនយ៉ាងណា មានអានិសង្សច្រើនយ៉ាងណា មានសេចក្តីរុងរឿងច្រើនយ៉ាងណា ផ្សាយផលទៅច្រើនយ៉ាងណា ។

សេយ្យថាបិ វិសាខេ យោ ឥមេសំ សោឡសន្នំ មហាជនបទានំ បហូតសត្តរតនានំ ឥស្សរិយាធិបច្ចំ រជ្ជំ ការេយ្យ សេយ្យថីទំ អង្គានំ មគធានំ កាសីនំ កោសលានំ វជ្ជីនំ មល្លានំ ចេតីនំ វំសានំ កុរូនំ បញ្ចាលានំ មច្ឆានំ សុរសេនានំ អស្សកានំ អវន្តីនំ គន្ធារានំ កម្ពោជានំ អដ្ឋង្គសមន្នាគតស្ស ឧបោសថស្ស ឯតំ កលំ នាគ្ឃតិ សោឡសឹ ។ តំ កិស្ស ហេតុ ។ កបណំ វិសាខេ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យានិ វិសាខេ មានុសកានិ បញ្ញាសវស្សានិ ចាតុម្មហារាជិកានំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹស-រត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វានិ បញ្ចវស្សសតានិ ចាតុម្មហារាជិកានំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ វិសាខេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា

ម្នាលនាងវិសាខា ប្រៀបដូចបុគ្គលណាមួយ គប្បីគ្រងរាជសម្បត្តិ ជាឥស្សរិយាធិបតី នៃមហាជនបទទាំង ១៦ នេះ ដែលមានរតនៈ ៧ ប្រការដ៏ច្រើន មហាជនបទទាំង ១៦ គឺអង្គៈ មគធៈ កាសី កោសលៈ វជ្ជី មល្លៈ ចេតីវង្សៈ កុរុ បញ្ចាលៈ មច្ឆៈ សុរសេនៈ អស្សកៈ អវន្តី គន្ធារៈ កម្ពោជៈ រាជ-សម្បត្តិរបស់បុគ្គលនុ៎ះមានតម្លៃមិនស្មើចំណិតទី ១៦ៗ លើក នៃឧបោសថៈប្រកបដោយអង្គ ៨ ឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលនាងវិសាខា រាជសម្បត្តិជារបស់មនុស្សប្រៀបធៀបនឹងសេចក្តីសុខទិព្វ (ឃើញ) ស្តើងស្គួចណាស់ ។ ម្នាលនាងវិសាខា ៥០ ឆ្នាំរបស់មនុស្ស ជាមួយយប់មួយថ្ងៃរបស់ពួកទេវតាជាន់ចាតុម្មហារាជិកៈ រាប់តាមរាត្រីនោះ ៣០ រាត្រីជាមួយខែ រាប់តាមខែនោះ ១២ ខែ ជាមួយឆ្នាំ រាប់តាមឆ្នាំនោះ ៥០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់ចាតុម្មហារាជិកៈ ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដត្រង់ពាក្យថាស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះរក្សាឧបោសថៈ ប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាងកាយស្លាប់ទៅ

ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បនេតំ វិសាខេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យំ វិសាខេ មានុសកំ វស្សសតំ តាវតឹសានំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វំ វស្សសហស្សំ តាវតឹសានំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ វិសាខេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា តាវតឹសានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បនេតំ វិសាខេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យានិ វិសាខេ មានុសកានិ ទ្វេ វស្សសតានិ យាមានំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ

ទៅកើតរួមជាមួយនឹងពួកទេវតាជាន់ចាតុម្មហារាជិកៈ ។ ម្នាលនាងវិសាខា ដែលថា រាជសម្បត្តិជារបស់មនុស្សប្រៀបធៀបនឹងសេចក្តីសុខទិព្វ (ឃើញ) ស្តើងស្តួច នេះតថាគតពោលសំដៅយកត្រង់ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ១០០ ឆ្នាំរបស់មនុស្ស ជាមួយយប់មួយថ្ងៃរបស់ទេវតាជាន់តាវត្តិង្ស រាប់តាមរាត្រីនោះ ៣០ រាត្រីជា ១ ខែ រាប់តាមខែនោះ ១២ ខែជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ១០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់តាវត្តិង្ស ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សាឧបោសថៈ ប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាយកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។ ម្នាលនាងវិសាខា ដែលថារាជសម្បត្តិជារបស់មនុស្សប្រៀបធៀបនឹងសេចក្តីសុខទិព្វ (ឃើញ) ស្តើងស្តួច នេះតថាគតពោលសំដៅយកត្រង់ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ២០០ ឆ្នាំរបស់មនុស្សជាមួយយប់មួយថ្ងៃរបស់ពួកទេវតាជាន់យាមៈ រាប់តាមរាត្រីនោះ ៣០ រាត្រីជា ១ ខែ រាប់តាមខែនោះ ១២ ខែជា ១ ឆ្នាំ

តេន សំវច្ឆរេន ទិព្វានិ ទ្វេ វស្សសហស្សានិ យាមានំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ វិសាខេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា យាមានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បនេតំ វិសាខេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យានិ វិសាខេ មានុសកានិ ចត្តារិ វស្សសតានិ តុសិតានំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វានិ ចត្តារិ វស្សសហស្សានិ តុសិតានំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ វិសាខេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា តុសិតានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បនេតំ វិសាខេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។

រាប់តាមឆ្នាំនោះ ២០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់យាមៈ ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថាស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សានូវឧបោសថៈប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាយកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់យាមៈ ។ ម្នាលនាងវិសាខា ដែលថា រាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀប នឹងសេចក្តីសុខទិព្វ (ឃើញ) ស្តើងស្តួច នេះតថាគតពោលសំដៅយក ត្រង់ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ៤០០ ឆ្នាំរបស់មនុស្ស ជាមួយយប់មួយថ្ងៃ របស់ពួកទេវតាជាន់តុសិត រាប់តាមរាត្រីនោះ ៣០ រាត្រីជា ១ ខែ រាប់តាមខែនោះ ១២ ខែជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ៤០០០ ឆ្នាំទិព្វជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់តុសិត ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថាស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សានូវឧបោសថៈ ប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាយកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់តុសិត ។ ម្នាលនាងវិសាខា ដែលថា រាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ (ឃើញ) ស្តើងស្តួច នេះតថាគតពោលសំដៅយកត្រង់ហេតុនុ៎ះឯង ។

២៨១



យានិ វិសាខេ មានុសកានិ អដ្ឋវស្សសតានិ និម្មានរតីនំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វានិ អដ្ឋវស្សសហស្សានិ និម្មានរតីនំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ វិសាខេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា និម្មានរតីនំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បនេតំ វិសាខេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យានិ វិសាខេ មានុសកានិ សោឡសវស្សសតានិ បរនិម្មិតវសវត្តីនំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វានិ សោឡសវស្សសហស្សានិ បរនិម្មិតវសវត្តីនំ ទេវានំ អាយុប្បមាណំ ។

ម្នាលនាងវិសាខា ៨០០ ឆ្នាំរបស់មនុស្សជាមួយយប់មួយថ្ងៃ របស់ពួកទេវតាជាន់និម្មានរតី រាប់តាមរាត្រីនោះ ៣០ រាត្រីជា ១ ខែ រាប់តាមខែនោះ ១២ ខែ ជា ១ ឆ្នាំរាប់តាមឆ្នាំនោះ ៨០០០ ឆ្នាំទិព្វជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់និម្មានរតី ។ ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថាស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ រក្សានូវឧបោសថៈប្រកបដោយអង្គ ៨ ហើយ លុះដល់រំលាងកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់និម្មានរតី ។ ម្នាលនាងវិសាខា ដែលថា រាជសម្បត្តិជារបស់មនុស្សប្រៀបធៀបនឹងសេចក្តីសុខ (ឃើញ) ស្តើងស្តួចនេះ តថាគតពោលសំដៅយកត្រង់ហេតុនុ៎ះឯង ។ ម្នាលនាងវិសាខា ១.៦០០ ឆ្នាំរបស់មនុស្សជាមួយយប់មួយថ្ងៃរបស់ពួកទេវតាជាន់បរនិម្មិតវសវត្តី រាប់តាមរាត្រីនោះ ៣០ រាត្រីជា ១ ខែ រាប់តាមខែនោះ ១២ ខែជា ១ ឆ្នាំ រាប់តាមឆ្នាំនោះ ១៦០០០ ឆ្នាំទិព្វ ជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់បរនិម្មិតវសវត្តី ។

ឋានំ ខោ បនេតំ វិសាខេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា បរនិម្មិតវសវត្តីនំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បនេតំ វិសាខេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយាតិ ។

បាណំ ន ហញ្ញេ ន ចាទិន្នមាទិយេ
មុសា ន ភាសេ ន ច មជ្ជបោ សិយា
អព្រហ្មចារា វិរមេយ្យ មេថុនា
រត្តឹ ន ភុញ្ជេយ្យ វិកាលភោជនំ
មាលំ ន ធារេ ន ច គន្ធមាចរេ
មញ្ចេ ឆមាយំ វ សយេថ សន្ថតេ
ឯតញ្ហិ អដ្ឋង្គិកមាហុបោសថំ
ពុទ្ធេន ទុក្ខន្តគុនា បកាសិតំ ។

ម្នាលនាងវិសាខា ហេតុនុ៎ះ រមែងមានប្រាកដ ត្រង់ពាក្យថា ស្ត្រីឬបុរស ពួកខ្លះ ក្នុងលោកនេះ រក្សានូវឧបោសថៈប្រកបដោយអង្គ ៨ ហើយ លុះ ដល់រំលាយកាយស្លាប់ទៅ ទៅកើតរួមជាមួយនឹងពួកទេវតាជាន់បរនិម្មិត-វសវត្តី ។ ម្នាលនាងវិសាខា ដែលថា រាជសម្បត្តិជារបស់មនុស្ស ប្រៀបធៀបនឹងសេចក្តីសុខទិព្វ (ឃើញ) ស្តើងស្តួច នេះតថាគត ពោល សំដៅយកត្រង់ហេតុនុ៎ះឯង ។

បុរសឬស្ត្រីមិនគប្បីសម្លាប់សត្វ ១ មិនគប្បីលួចយក ទ្រព្យដែលម្ចាស់គេមិនបានឲ្យ ១ មិនគប្បីនិយាយ កុហក ១មិនគប្បីក្រេបផឹកនូវទឹកស្រវឹង ១ គប្បីវៀរ ចាកមេថុន ដែលមិនមែនជាសេចក្តីប្រព្រឹត្តដ៏ប្រសើរ ១ មិនគប្បីបរិភោគភោជនក្នុងវេលារាត្រី និងភោជនក្នុង វេលាខុសកាល ១ មិនគប្បីទ្រទ្រង់កម្រងផ្កា មិនគប្បី ប្រើប្រាស់គ្រឿងក្រអូប ១ គប្បីដេកលើគ្រែ (ដែល ត្រូវប្រមាណ) ឬកម្រាល ដែលក្រាលផ្ទាល់នឹង ផែនដី ១ (បណ្ឌិតទាំងឡាយពោលសរសើរ) ឧបោសថៈប្រកបដោយអង្គ ៨ នុ៎ះ ដែលព្រះពុទ្ធទ្រង់ ដល់នូវទីបំផុតនៃទុក្ខ ទ្រង់ប្រកាសទុកហើយ ។

២៨៣



ចន្ទោ ច សូរោ ច ឧភោ សុទស្សនា
ឱភាសយន្តា អនុយន្តិ យាវតា
តមោនុទា តេ បន អន្តលិក្ខគា
នភេ បភាសន្តិ ទិសា វិរោចនា
ឯតម្ហិ យំ វិជ្ជតិ អន្តរេ ធនំ
មុត្តា មណិ វេឡុរិយញ្ច ភទ្ទកំ
សិង្គីសុវណ្ណំ អថវាបិ កាញ្ចនំ
យំ ជាតរូបំ ហដកន្តិ វុច្ចតិ
អដ្ឋង្គុបេតស្ស ឧបោសថស្ស
កលម្បិ តេ នានុភវន្តិ សោឡសឹ
ចន្ទប្បភា តារគណា ច សព្វេ
តស្មា ហិ នារី ច នរោ ច សីលវា
អដ្ឋង្គុបេតំ ឧបវស្សុបោសថំ
បុញ្ញានិ កត្វាន សុខុទ្រយានិ
អនិន្ទិតា សគ្គមុបេន្តិ ឋានន្តិ ។

មហាវគ្គោ ទុតិយោ ។

ព្រះចន្ទ្រនិងព្រះអាទិត្យ ទាំងពីរមានរស្មីដ៏រុងរឿង ភ្លឺផ្ទុះផ្សាយចេញទៅ អស់ទីមានកំណត់ត្រឹមណា មួយទៀត ព្រះចន្ទ្រនិងព្រះអាទិត្យ មាននាទីកម្ចាត់បង់នូវងងឹត មានដំណើរទៅក្នុងអាកាស ចាំងពន្លឺសព្វទិស តែងបំភ្លឺក្នុងផ្ទៃមេឃ ទ្រព្យណាមួយ ដែលមាននៅក្នុងចន្លោះនុ៎ះគឺកែវមុក្តា កែវមណី កែវពៃទូរ្យដ៏ល្អមួយវិញទៀត ដែលហៅថា មាសសិង្គី មាសកាញ្ចនៈមាសជាតរូបនិងមាសហដកៈ ទ្រព្យទាំងអម្បាលនោះ (មានតម្លៃ) មិនដល់នូវចំណិតទី ១៦ ។ លើក នៃឧបោសថៈប្រកបដោយអង្គ ៨ ឡើយ ដូចពួកផ្កាយទាំងអស់ (ភ្លឺ) មិនដល់ពន្លឺព្រះចន្ទ្រឡើយ ព្រោះហេតុនោះស្ត្រីបុរសដែលជាអ្នកមានសីល បានរក្សាឧបោសថៈប្រកបដោយអង្គ ៨ ធ្វើបុណ្យទាំងឡាយដែលមានសុខជាកម្រៃជាអ្នកមិនត្រូវគេតិះដៀល តែងទៅកើតក្នុងស្ថានសួគ៌ ។

ចប់ មហាវគ្គទី ២ ។

សុត្តន្តបិដកេ អង្គុត្តរនិកាយស្ស តិកនិបាតោ

# តស្សុទ្ទានំ

តិត្ថភយញ្ច វេនោតោ

សរភោ កេសបុត្តិយោ

សាឡ្ហោ ចាបិ កថាវត្ថុ

តិត្ថិយា មូលុចោសថោតិ ។

សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត

# ឧទ្ទាននៃមហាវគ្គនោះគឺ

*និយាយអំពីតិត្ថាយតនៈ ១ អំពីអមាតាបុត្តិកភ័យ ១ អំពីអ្នកស្រុកវេនាគបុរៈ ១ អំពីសរភបរិព្វាជក ១ អំពីអ្នកនិគមកេសបុត្ត ១ អំពីសាឡ្ហៈចៅរបស់មិគារសេដ្ឋី ១ អំពីកថាវត្ថុ ១ អំពីតិរ្ថិយទាំងឡាយ ១ អំពីអកុសលមូលនិងកុសលមូល ១ អំពីឧបោសថៈ ១ ។*

# អានន្ទវគ្គោ

[៧៣] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថ ខោ ឆន្នោ បរិព្វាជកោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឆន្នោ បរិព្វាជកោ អាយស្មន្តំ អានន្ទំ ឯតទវោច តុម្ហេបិ អាវុសោ អានន្ទ រាគស្ស បហានំ បញ្ញាបេថ ទោសស្ស បហានំ បញ្ញាបេថ មោហស្ស បហានំ បញ្ញាបេថាតិ ។ មយំ ខោ អាវុសោ រាគស្ស បហានំ បញ្ញាបេម ទោសស្ស បហានំ បញ្ញាបេម មោហស្ស បហានំ បញ្ញាបេមាតិ ។ កឹ បន តុម្ហេ អាវុសោ រាគេ អាទីនវំ ទិស្វា រាគស្ស បហានំ បញ្ញាបេថ កឹ ទោសេ អាទីនវំ ទិស្វា ទោសស្ស បហានំ បញ្ញាបេថ កឹ មោហេ អាទីនវំ ទិស្វា មោហស្ស បហានំ បញ្ញាបេថាតិ ។ រត្តោ ខោ អាវុសោ

# អានន្ទវគ្គ

[៧៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេត-ពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ឆន្នបរិព្វាជក ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ពោល រាក់ទាក់ជាមួយនឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ និងពាក្យគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឆន្នបរិព្វាជក អង្គុយក្នុងទីសមគួរហើយ ក៏និយាយនឹងព្រះអានន្ទមានអាយុដូច្នេះថា នែ អាវុសោអានន្ទ លោកបញ្ញត្តការលះបង់រាគៈ បញ្ញត្តការលះបង់ទោសៈ បញ្ញត្តការលះបង់មោហៈ ។ ម្នាលអាវុសោ យើងសោត ក៏បញ្ញត្ត ការលះបង់រាគៈ បញ្ញត្តការលះបង់ទោសៈ បញ្ញត្តការលះបង់មោហៈ ដែរ ។ ម្នាលអាវុសោ តែថាលោកឃើញទោស ក្នុងរាគៈដូចម្ដេច បានជាបញ្ញត្តការលះបង់រាគៈ ឃើញទោស ក្នុងទោសៈដូចម្ដេច បានជា បញ្ញត្តការលះបង់ទោសៈ ឃើញទោស ក្នុងមោហៈដូចម្ដេច បានជា បញ្ញត្តការលះបង់មោហៈ ។ ម្នាលអាវុសោ បុគ្គលអ្នកត្រេកត្រអាល

រាគេន អភិភូតោ បរិយាទិន្នចិត្តោ អត្តព្យាពាធាយបិ ចេតេតិ បរព្យាពាធាយបិ ចេតេតិ ឧភយព្យាពាធាយបិ ចេតេតិ ចេតសិកំបិ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ រាគេ បហីនេ នេវ អត្តព្យាពាធាយ ចេតេតិ ន បរព្យាពាធាយ ចេតេតិ ន ឧភយព្យាពាធាយ ចេតេតិ ន ចេតសិកំ ទុក្ខំ ទោមនស្សំ បដិសំវេទេតិ ។ រត្តោ ខោ អាវុសោ រាគេន អភិភូតោ បរិយាទិន្នចិត្តោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ រាគេ បហីនេ នេវ កាយេន ទុច្ចរិតំ ចរតិ ន វាចាយ ទុច្ចរិតំ ចរតិ ន មនសា ទុច្ចរិតំ ចរតិ ។ រត្តោ ខោ អាវុសា រាគេន អភិភូតោ បរិយាទិន្នចិត្តោ អត្តត្ថំបិ យថាភូតំ នប្បជានាតិ បរត្ថំបិ យថាភូតំ នប្បជានាតិ ឧភយត្ថំបិ យថាភូតំ នប្បជានាតិ រាគេ បហីនេ អត្តត្ថំបិ យថាភូតំ បជានាតិ បរត្ថំបិ យថាភូតំ បជានាតិ ឧភយត្ថំបិ យថាភូតំ បជានាតិ ។ រាគោ ខោ អាវុសោ អន្ធករណោ

ត្រូវរាគៈគ្របសង្កត់ មានចិត្តត្រូវរាគៈរួបរឹត រមែងគិតដើម្បីបៀតបៀនខ្លួនឯងខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនទាំងពីរខាងខ្លះ រមែងទទួលទុក្ខ ទោមនស្ស ប្រព្រឹត្តទៅក្នុងចិត្តខ្លះ កាលលះបង់រាគៈ បានហើយ បុគ្គលរមែងមិនគិតដើម្បីបៀតបៀនខ្លួនឯង មិនគិតដើម្បីបៀតបៀនអ្នកដទៃ មិនគិតដើម្បីបៀតបៀនទាំងពីរខាង មិនទទួលទុក្ខទោមនស្សប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលអាវុសោ បុគ្គលអ្នកត្រេកត្រអាលត្រូវរាគៈគ្របសង្កត់ មានចិត្តត្រូវរាគៈរួបរឹតរមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត កាលបើលះរាគៈបានហើយ បុគ្គលរមែងមិនប្រព្រឹត្តទុច្ចរិតដោយកាយ មិនប្រព្រឹត្តទុច្ចរិតដោយវាចា មិនប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ ម្នាលអាវុសោ បុគ្គលអ្នកត្រេកត្រអាលត្រូវរាគៈគ្របសង្កត់ មានចិត្តត្រូវរាគៈរួបរឹត រមែងមិនដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនតាមពិតខ្លះ មិនដឹងច្បាស់នូវប្រយោជន៍របស់បុគ្គលដទៃតាមពិតខ្លះ មិនដឹងច្បាស់នូវប្រយោជន៍ទាំងពីរខាងតាមពិតខ្លះ កាលបើលះបង់រាគៈបានហើយ បុគ្គលរមែងដឹងច្បាស់នូវប្រយោជន៍របស់ខ្លួនតាមពិតផង ដឹងច្បាស់នូវប្រយោជន៍បុគ្គលដទៃតាមពិតផង ដឹងច្បាស់នូវប្រយោជន៍ទាំងពីរខាងតាមពិតផង ។ ម្នាលអាវុសោ រាគៈជាគ្រឿងធ្វើឲ្យងងឹត

២៨៧

ទុតិយបណ្ណាសកេ អានន្ទវគ្គោ

អចក្ខុករណោ អញ្ញាណករណោ បញ្ញានិរោធិកោ វិឃាតបក្ខិកោ អនិព្វានសំវត្តនិកោ ។ ទុដ្ឋោ ខោ អាវុសោ ។ បេ ។ មូឡ្ហោ ខោ អាវុសោ មោហេន អភិភូតោ បរិយាទិន្នចិត្តោ អត្តព្យាពាធាយបិ ចេតេតិ បរព្យាពាធាយបិ ចេតេតិ ឧភយព្យាពាធាយបិ ចេតេតិ ចេតសិកំបិ ទុក្ខំ ទោមនស្សំ បដិសំ-វេទេតិ មោហេ បហីនេ នេវ អត្តព្យាពាធាយ ចេតេតិ ន បរព្យាពាធាយ ចេតេតិ ន ឧភយព្យា-ពាធាយ ចេតេតិ ន ចេតសិកំ ទុក្ខំ ទោម-នស្សំ បដិសំវេទេតិ ។ មូឡ្ហោ ខោ អាវុសោ មោហេន អភិភូតោ បរិយាទិន្នចិត្តោ កាយេន ទុច្ចរិតំ ចរតិ វាចាយ ទុច្ចរិតំ ចរតិ មនសា ទុច្ចរិតំ ចរតិ មោហេ បហីនេ នេវ កាយេន ទុច្ចរិតំ ចរតិ ន វាចាយ ទុច្ចរិតំ ចរតិ ន មនសា ទុច្ចរិតំ ចរតិ ។ មូឡ្ហោ ខោ អាវុសោ មោហេន អភិភូតោ បរិយាទិន្នចិត្តោ អត្តត្ថំបិ យថាភូតំ នប្បជានាតិ បរត្ថំបិ យថាភូតំ នប្បជានាតិ

ធ្វើឲ្យដូចជាគ្មានចក្ខុ ធ្វើឲ្យគ្មានញាណ ឲ្យរលត់បញ្ញា ជាប៉ែកខាងសេចក្តីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ ។ ម្នាលអាវុសោ បុគ្គលអ្នកប្រទូស្ត ។ បេ ។ ម្នាលអាវុសោ បុគ្គលអ្នកវង្វេង ត្រូវសេចក្តីវង្វេងគ្របសង្កត់ មានចិត្តត្រូវសេចក្តីវង្វេងរួបរឹត រមែងគិតដើម្បីបៀតបៀនខ្លួនខ្លះ គិតដើម្បីបៀតបៀនអ្នកដទៃខ្លះ គិតដើម្បីបៀតបៀនទាំងពីរខាងខ្លះ តែងទទួលទុក្ខទោមនស្សប្រព្រឹត្តទៅក្នុងចិត្តខ្លះ កាលបើលះមោហៈបានហើយ បុគ្គលរមែងមិនគិតដើម្បីបៀតបៀនខ្លួន មិនគិតដើម្បីបៀតបៀនអ្នកដទៃ មិនគិតដើម្បីបៀតបៀនទាំងពីរខាង មិនទទួលទុក្ខទោមនស្សប្រព្រឹត្តទៅក្នុងចិត្ត ។ ម្នាលអាវុសោ បុគ្គលអ្នកវង្វេង ត្រូវមោហៈគ្របសង្កត់ មានចិត្តត្រូវមោហៈរួបរឹត រមែងប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត កាលបើលះបង់មោហៈបានហើយ បុគ្គលរមែងមិនប្រព្រឹត្តទុច្ចរិតដោយកាយ មិនប្រព្រឹត្តទុច្ចរិតដោយវាចា មិនប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ ម្នាលអាវុសោ បុគ្គលអ្នកវង្វេង ត្រូវមោហៈគ្របសង្កត់ មានចិត្តត្រូវមោហៈរួបរឹត រមែងមិនដឹងច្បាស់នូវប្រយោជន៍ខ្លួនតាមពិតខ្លះ មិនដឹងច្បាស់នូវប្រយោជន៍អ្នកដទៃតាមពិតខ្លះ មិនដឹងច្បាស់នូវប្រយោជន៍ទាំងពីរខាង តាមពិតខ្លះ

ឧភយត្ថំបិ យថាភូតំ នប្បជានាតិ មោហេ បហីនេ អត្តត្ថំបិ យថាភូតំ បជានាតិ បរត្ថំបិ យថាភូតំ បជានាតិ ឧភយត្ថំបិ យថាភូតំ បជានាតិ ។ មោហោ ខោ អាវុសោ អន្ធករណោ អចក្ខុករណោ អញ្ញាណករណោ បញ្ញានិរោធិកោ វិឃាតបក្ខិកោ អនិព្វានសំវត្តនិកោ ។ ឥទំ ខោ មយំ អាវុសោ រាគេ អាទីនវំ ទិស្វា រាគស្ស បហានំ បញ្ញាបេម ឥទំ ទោសេ អាទីនវំ ទិស្វា ទោសស្ស បហានំ បញ្ញាបេម ឥទំ មោហេ អាទីនវំ ទិស្វា មោហស្ស បហានំ បញ្ញាបេមាតិ ។ អត្ថិ បនាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស រាគស្ស ទោសស្ស មោហស្ស បហានាយាតិ ។ អត្ថាវុសោ មគ្គោ អត្ថិ បដិបទា ឯតស្ស រាគស្ស ទោសស្ស មោហស្ស បហានាយាតិ ។ កតមោ បនាវុសោ មគ្គោ កតមា បដិបទា ឯតស្ស រាគស្ស ទោសស្ស មោហស្ស បហានាយាតិ ។ អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា

កាលបើលះមោហៈបានហើយ បុគ្គលរមែងដឹងច្បាស់នូវប្រយោជន៍ខ្លួនតាមពិតផង ដឹងច្បាស់នូវប្រយោជន៍អ្នកដទៃតាមពិតផង ដឹងច្បាស់នូវប្រយោជន៍ទាំងពីរខាងតាមពិតផង ។ ម្នាលអាវុសោ មោហៈជាគ្រឿងធ្វើឲ្យងងឹត ធ្វើឲ្យដូចជាគ្មានចក្ខុ ធ្វើឲ្យគ្មានញាណ ឲ្យរលត់បញ្ញា ជាប៉ែកខាងសេចក្ដីចង្អៀតចង្អល់ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វានទេ ។ ម្នាលអាវុសោ យើងឃើញទោស ក្នុងរាគៈនេះឯងហើយ ទើបបញ្ញត្តនូវការលះបង់រាគៈ ឃើញទោស ក្នុងទោសៈនេះហើយ ទើបបញ្ញត្តនូវការលះទោសៈ ឃើញទោស ក្នុងមោហៈនេះហើយ ទើបបញ្ញត្តនូវការលះមោហៈ ។ ម្នាលអាវុសោ ចុះផ្លូវប្រតិបត្តិដើម្បីលះរាគៈទោសៈមោហៈ នុ៎ះមានដែរឬទេ ។ ម្នាលអាវុសោ ផ្លូវប្រតិបត្តិដើម្បីលះរាគៈទោសៈ មោហៈ នុ៎ះមាន ។ ម្នាលអាវុសោ ចុះផ្លូវប្រតិបត្តិដើម្បីលះរាគៈទោសៈមោហៈ នុ៎ះ តើដូចម្ដេច ។ ផ្លូវប្រកបដោយអង្គ ៨ ដ៏ប្រសើរនេះឯង គឺ សេចក្ដីឃើញត្រូវ ១ សេចក្ដីត្រិះរិះត្រូវ ១ វាចាត្រូវ ១

សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ
សម្មាសមាធិ ។ អយំ ខោ អាវុសោ មគ្គោ អយំ
បដិបទា ឯតស្ស រាគស្ស ទោសស្ស មោហស្ស បហានា-
យាតិ ។ ភទ្ទកោ អាវុសោ មគ្គោ ភទ្ទិកា បដិបទា
ឯតស្ស រាគស្ស ទោសស្ស មោហស្ស បហានាយ ។
អលញ្ច បនាវុសោ អានន្ទ អប្បមាទាយាតិ ។

[៧៤] ឯកំ សមយំ អាយស្មា អានន្ទោ
កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ អថខោ
អញ្ញតរោ អាជីវកសាវកោ គហបតិ យេនាយស្មា
អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ
អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ
ខោ សោ អាជីវកសាវកោ គហបតិ អាយស្មន្តំ
អានន្ទំ ឯតទវោច កេសន្នោ ភន្តេ អានន្ទ
ធម្មោ ស្វាក្ខាតោ កេ លោកេ សុប្បដិបន្នា កេ
លោកេ សុគតាតិ ។ តេនហិ គហបតិ តញ្ញេ-
វេត្ថ[១] បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ

១ ឱ. ត្វំយេវ ឯត្ថ ។

ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ការព្យាយាមត្រូវ ១ ការរលឹកត្រូវ ១ ការតម្កល់ចិត្តមាំត្រូវ ១ ។ ម្នាលអាវុសោ នេះឯងជាផ្លូវប្រតិបត្តិដើម្បីលះរាគៈទោសៈមោហៈនុ៎ះ ។ ម្នាលអាវុសោ ផ្លូវប្រតិបត្តិ ដើម្បីលះរាគៈទោសៈមោហៈនុ៎ះ ជាផ្លូវប្រសើរល្អហើយ ។ ម្នាលអាវុសោអានន្ទ ហេតុនោះ គួរតែកុំធ្វេសប្រហែសឡើយ ។

[៧២] សម័យមួយ ព្រះអានន្ទមានអាយុ គង់នៅក្នុងឃោសិតារាមជិតក្រុងកោសម្ពី ។ គ្រានោះ គហបតី ជាសាវ័ករបស់អាជីវកម្នាក់ ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលនៅដល់ហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះគហបតី ជាសាវ័កអាជីវកនោះ អង្គុយក្នុងទីសមគួរហើយ សួរព្រះអានន្ទមានអាយុដូច្នេះថា បពិត្រអានន្ទដ៏ចម្រើន (យើងទាំងពីរនាក់) អ្នកណាសម្តែងធម៌ត្រូវ ពួកអ្នកណាឈ្មោះថា ប្រតិបត្តិត្រូវក្នុងលោក ពួកអ្នកណាឈ្មោះថា ដើរត្រូវក្នុងលោក ។ ម្នាលគហបតី បើដូច្នោះ អាត្មានឹងត្រឡប់សួរទៅអ្នកក្នុងហេតុនុ៎ះវិញ បើហេតុនោះគួរដល់អ្នកយ៉ាងណា

តថា នំ ព្យាករេយ្យាសិ ។ តំ កឹ មញ្ញសិ គហបតិ យេ រាគស្ស បហានាយ ធម្មំ ទេសេន្តិ ទោសស្ស បហានាយ ធម្មំ ទេសេន្តិ មោហស្ស បហានាយ ធម្មំ ទេសេន្តិ តេសំ ធម្មោ ស្វាក្ខាតោ នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ យេ ភន្តេ រាគស្ស បហានាយ ធម្មំ ទេសេន្តិ ទោសស្ស បហានាយ ធម្មំ ទេសេន្តិ មោហស្ស បហានាយ ធម្មំ ទេសេន្តិ តេសំ ធម្មោ ស្វាក្ខាតោ ឯវំ មេ ឯត្ថ ហោតីតិ ។ តំ កឹ មញ្ញសិ គហបតិ យេ រាគស្ស បហានាយ បដិបន្នា ទោសស្ស បហានាយ បដិបន្នា មោហស្ស បហានាយ បដិបន្នា តេ លោកេ សុប្បដិបន្នា នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ យេ ភន្តេ រាគស្ស បហានាយ បដិបន្នា ទោសស្ស បហានាយ បដិបន្នា មោហស្ស បហានាយ បដិបន្នា តេ លោកេ សុប្បដិបន្នា ឯវំ មេ ឯត្ថ ហោតីតិ ។ តំ កឹ មញ្ញសិ គហបតិ យេសំ រាគោ បហីនោ ឧច្ឆិន្នមូលោ

ត្រូវអ្នកដោះស្រាយហេតុនោះ យ៉ាងនោះចុះ ។ ម្នាលគហបតី អ្នកសម្គាល់ហេតុនោះដូចម្តេច ពួកបុគ្គលណា សម្តែងធម៌ដើម្បីលះរាគៈ សម្តែងធម៌ដើម្បីលះទោសៈ សម្តែងធម៌ដើម្បីលះមោហៈ អ្នកទាំងនោះ ឈ្មោះថាសម្តែងធម៌ត្រូវឬទេ ឬថាអ្នកមានសេចក្តីយល់ដូចម្តេច ក្នុងដំណើរនុ៎ះ ។ បពិត្រអានន្ទដ៏ចម្រើន ពួកបុគ្គលណាសម្តែងធម៌ដើម្បីលះរាគៈ សម្តែងធម៌ដើម្បីលះទោសៈ សម្តែងធម៌ដើម្បីលះមោហៈ បុគ្គលទាំងនោះឈ្មោះថាសម្តែងធម៌ត្រូវហើយ ខ្ញុំមានសេចក្តីយល់ ក្នុងដំណើរនុ៎ះយ៉ាងនេះដែរ ។ ម្នាលគហបតី អ្នកសម្គាល់ហេតុនោះដូចម្តេច ពួកបុគ្គលណាប្រតិបត្តិដើម្បីលះរាគៈ ប្រតិបត្តិដើម្បីលះទោសៈ ប្រតិបត្តិដើម្បីលះមោហៈ ពួកបុគ្គលនោះឈ្មោះថា ប្រតិបត្តិត្រូវ ក្នុងលោកឬទេ ឬថាអ្នកមានសេចក្តីយល់ក្នុងដំណើរនុ៎ះដូចម្តេច ។ បពិត្រអានន្ទដ៏ចម្រើន ពួកបុគ្គលណាប្រតិបត្តិដើម្បីលះរាគៈ ប្រតិបត្តិដើម្បីលះទោសៈ ប្រតិបត្តិដើម្បីលះមោហៈ ពួកបុគ្គលនោះឈ្មោះថា ប្រតិបត្តិត្រូវក្នុងលោក ខ្ញុំមានសេចក្តីយល់យ៉ាងនេះ ក្នុងដំណើរនុ៎ះ ។ ម្នាលគហបតី អ្នកសម្គាល់ហេតុនោះដូចម្តេច ពួកបុគ្គលណា បានលះរាគៈហើយ បានរំលើងឫសគល់ចោលហើយ

២៩១

ទុតិយបណ្ណាសកេ  អានន្ទវគ្គោ

តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ យេសំ ទោសោ បហីនោ ។ បេ ។ យេសំ មោហោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ តេ លោកេ សុគតា នោ វា កថំ វា តេ ឯត្ថ ហោតីតិ ។ យេសំ ភន្តេ រាគោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ យេសំ ទោសោ បហីនោ ។ បេ ។ យេសំ មោហោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹ-អនុប្បាទធម្មោ តេ លោកេ សុគតា ឯវំ មេ ឯត្ថ ហោតីតិ ។ ឥតិ ខោ គហបតិ តយាវេតំ ព្យាកតំ យេ ភន្តេ រាគស្ស បហានាយ ធម្មំ ទេសេន្តិ ទោសស្ស បហានាយ ធម្មំ ទេសេន្តិ

ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស មិនឲ្យកើតឡើងតទៅទៀតជាធម្មតា ពួកបុគ្គលណាលះទោសៈហើយ ។ បេ ។ ពួកបុគ្គលណាលះមោហៈហើយ បានរំលើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស មិនឲ្យកើតឡើងតទៅទៀតជាធម្មតា ពួកបុគ្គលនោះឈ្មោះថា ដើរត្រូវហើយក្នុងលោកឬទេ ឬក៏អ្នកមានសេចក្តីយល់ដូចម្តេច ក្នុងដំណើរនុ៎ះ ។ បពិត្រលោកដ៏ចម្រើន ពួកបុគ្គលណាលះរាគៈហើយ បានរំលើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស មិនឲ្យកើតឡើងតទៅទៀតជាធម្មតា ពួកបុគ្គលណាលះទោសៈហើយ ។ បេ ។ ពួកបុគ្គលណាលះមោហៈហើយ បានរំលើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស មិនឲ្យកើតឡើងតទៅទៀត ជាធម្មតា ពួកបុគ្គលនោះឈ្មោះថា ដើរត្រូវ ក្នុងលោកហើយខ្ញុំមានសេចក្តីយល់យ៉ាងនេះ ក្នុងដំណើរនុ៎ះ ។ ម្នាលគហបតី អ្នកបានដោះស្រាយហើយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ពួកបុគ្គលណា សម្តែងធម៌ដើម្បីលះរាគៈ សម្តែងធម៌ដើម្បីលះទោសៈ

មោហស្ស បហានាយ ធម្មំ ទេសេន្តិ តេសំ ធម្មោ ស្វាក្ខាតោតិ ។ តយាវេតំ ព្យាកតំ យេ ភន្តេ រាគស្ស បហានាយ បដិបន្នា ទោសស្ស បហានាយ បដិបន្នា មោហស្ស បហានាយ បដិបន្នា តេ លោកេ សុប្ប-ដិបន្នាតិ ។ តយាវេតំ ព្យាកតំ យេសំ ភន្តេ រាគោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ យេសំ ទោសោ បហីនោ ។ បេ ។ យេសំ មោហោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទ-ធម្មោ តេ លោកេ សុគតាតិ ។ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ ន ចេវ នាម សធម្មុក្កំសនា[១] ភវិស្សតិ ន ច បរធម្មាបសាទនា អាយតនេវ ធម្មទេសនា អត្ថោ ច វុត្តោ អត្តា ច អនុបនីតោ តុម្ហេ ភន្តេ អានន្ទ រាគស្ស បហានាយ ធម្មំ ទេសេថ ទោសស្ស បហានាយ ធម្មំ ទេសេថ មោហស្ស បហានាយ ធម្មំ ទេសេថ តុម្ហាកំ ធម្មោ ស្វាក្ខាតោ

១ ម. សទ្ធម្មុដ្ឋាបនា ។

សម្តែងធម៌ដើម្បីលះមោហៈ បុគ្គលនោះឈ្មោះថាសម្តែងត្រូវហើយ ។ អ្នកបានដោះស្រាយហើយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ពួកបុគ្គលណាបានប្រតិបត្តិដើម្បីលះរាគៈ ប្រតិបត្តិដើម្បីលះទោសៈ ប្រតិបត្តិដើម្បីលះមោហៈ បុគ្គលទាំងនោះឈ្មោះថា ប្រតិបត្តិត្រូវក្នុងលោក ។ អ្នកបានដោះស្រាយហើយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ពួកបុគ្គលណា បានលះរាគៈហើយ បានរំលើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបានដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀតជាធម្មតា ពួកបុគ្គលណាបានលះទោសៈហើយ ។ បេ ។ ពួកបុគ្គលណាបានលះមោហៈហើយ បានរំលើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបានដូចជាត្នោតកំបុតក ធ្វើឲ្យវិនាសមិនឲ្យកើតតទៅទៀតជាធម្មតា ពួកបុគ្គលនោះឈ្មោះថាដើរត្រូវក្នុងលោក ។ បពិត្រលោកដ៏ចម្រើន អស្ចារ្យណាស់ បពិត្រលោកដ៏ចម្រើន ចំឡែកណាស់ឈ្មោះថា មិនមានការលើកតម្កើងតែធម៌ខ្លួនផង មិនមានការបន្តុះបង្អាប់ធម៌បុគ្គលដទៃផង សម្តែងធម៌ត្រង់តាមតែហេតុ និយាយចំពោះតែសេចក្តី ទាំងមិនទាញមករកតែប៉ែកខាងខ្លួនផង ។ បពិត្រអានន្ទដ៏ចម្រើន លោក(ហ្នឹងហើយ) សម្តែងធម៌ដើម្បីលះរាគៈ សម្តែងធម៌ដើម្បីលះទោសៈ សម្តែងធម៌ដើម្បីលះមោហៈ លោកសម្តែងធម៌ត្រូវហើយ

តុម្ហេ ភន្តេ អានន្ទ រាគស្ស បហានាយ បដិបន្នា ទោសស្ស បហានាយ បដិបន្នា មោហស្ស បហានាយ បដិបន្នា តុម្ហេ លោកេ សុប្បដិបន្នា តុម្ហាកំ ភន្តេ អានន្ទ រាគោ បហីនោ ឧច្ឆិន្នមូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹអនុប្បាទធម្មោ តុម្ហាកំ ទោសោ បហីនោ ។ បេ ។ តុម្ហាកំ មោហោ បហីនោ ឧច្ឆិន្ន-មូលោ តាលាវត្ថុកតោ អនភាវំ កតោ អាយតឹ-អនុប្បាទធម្មោ តុម្ហេ លោកេ សុគតា ។ អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ អយ្យេន អានន្ទេន អនេកបរិយាយេន ធម្មោ បកាសិតោ ។ ឯសាហំ ភន្តេ អានន្ទ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ អយ្យោ អានន្ទោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

បពិត្រអានន្ទដ៏ចម្រើន លោកប្រតិបត្តិដើម្បីលះរាគៈ ប្រតិបត្តិដើម្បីលះទោសៈ ប្រតិបត្តិដើម្បីលះមោហៈ ប្រតិបត្តិត្រូវហើយ ក្នុងលោក បពិត្រអានន្ទដ៏ចម្រើន លោកបានលះរាគៈហើយ បានរំលើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀតជាធម្មតា លោកបានលះទោសៈហើយ ។ បេ ។ លោកបានលះមោហៈហើយ បានរំលើងឫសគល់ចោលហើយ ធ្វើមិនឲ្យដុះទៀតបាន ដូចជាត្នោតកំបុតក ធ្វើឲ្យវិនាស ធ្វើមិនឲ្យកើតតទៅទៀតជាធម្មតា លោកឈ្មោះថា ដើរត្រូវក្នុងលោក ។ បពិត្រលោកដ៏ចម្រើន ពីរោះណាស់ បពិត្រលោកដ៏ចម្រើន ពីរោះណាស់ បពិត្រលោកដ៏ចម្រើន ដូចគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់មនុស្សអ្នកវង្វេង ពុំនោះសោត ដូចគេទ្រោលប្រទីបប្រេងក្នុងទីងងឹត ដោយគិតថា មនុស្សអ្នកមានភ្នែក រមែងមើលឃើញរូបទាំងឡាយ យ៉ាងណាមិញ ធម៌ដែលលោកម្ចាស់អានន្ទ បានសម្តែងហើយដោយអនេកបរិយាយយ៉ាងនេះ ក៏យ៉ាងនោះដែរ ។ បពិត្រអានន្ទដ៏ចម្រើន ខ្ញុំនោះដល់នូវព្រះមានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីរលឹក សូមលោកម្ចាស់អានន្ទ ចាំទុកនូវខ្ញុំព្រះករុណា ជាឧបាសក អ្នកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមពីថ្ងៃនេះតទៅ ។

[៧៤] ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន ភគវា គិលានា វុដ្ឋិតោ ហោតិ អចិរវុដ្ឋិតោ គេលញ្ញា ។ អថខោ មហានាមោ សក្កោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច ទីឃរត្តាហំ ភន្តេ ភគវតា ឯវំ ធម្មំ ទេសិតំ អាជានាមិ សមាហិតស្ស ញាណំ នោ អសមាហិតស្សាតិ ។ សមាធិ នុ ខោ ភន្តេ បុព្វេ បច្ឆា ញាណំ ឧទាហុ ញាណំ បុព្វេ បច្ឆា សមាធីតិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ ភគវា ខោ គិលានា វុដ្ឋិតោ អចិរវុដ្ឋិតោ គេលញ្ញា អយញ្ច មហានាមោ សក្កោ ភគវន្តំ អតិគម្ភីរំ បញ្ហំ បុច្ឆតិ យន្នូនាហំ មហានាមំ សក្កំ ឯកមន្តំ អបនេត្វា ធម្មំ ទេសេយ្យន្តិ ។ អថខោ អាយស្មា អានន្ទោ

[៧៥] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ ។ សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់ស្បើយអំពីជំងឺ ទើបតែនឹងស្បើយអំពីជំងឺ មិនទាន់យូរប៉ុន្មាន ។ គ្រានោះ មហានាមសក្កៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅ ដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយគង់ក្នុងទីសមគួរ ។ លុះមហានាមសក្កៈ គង់ក្នុងទីសមគួរហើយ ក៏ក្រាបថ្វាយបង្គំទូលព្រះមាន ព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹងច្បាស់នូវធម៌ ដែលព្រះមានព្រះភាគទ្រង់សម្តែងអស់កាលជាយូរហើយ យ៉ាងនេះថា ញាណមានដល់បុគ្គលដែលមានចិត្តតម្កល់ខ្ជាប់ មិនមានដល់បុគ្គលដែល មានចិត្តមិនតម្កល់ខ្ជាប់ទេ ។ បពិត្រព្រះអង្គដ៏ចម្រើន សមាធិកើតមុន ញាណកើតក្រោយ ឬក៏ញាណកើតមុន សមាធិកើតក្រោយ ។ លំដាប់ នោះ ព្រះអានន្ទមានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមានព្រះ ភាគទ្រង់ស្បើយអំពីជំងឺ ទើបតែនឹងស្បើយអំពីជំងឺ មិនទាន់យូរ ប៉ុន្មានស្រាប់តែមហានាមសក្កៈនេះ សួរប្រស្នាដ៏ជ្រៅក្រៃពេក ចំពោះព្រះ ដ៏មានព្រះភាគ បើដូច្នោះ គួរតែអាត្មាអញ នាំមហានាមសក្កៈ ទៅក្នុង ទីសមគួរហើយ សម្តែងធម៌ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ

មហាជាមំ សក្កំ ពាហាយំ គហេត្វា ឯកមន្តំ អបនេត្វា មហានាមំ សក្កំ ឯតទវោច សេក្ខម្បិ ខោ មហានាម សីលំ វុត្តំ ភគវតា អសេក្ខម្បិ សីលំ វុត្តំ ភគវតា សេក្ខោបិ សមាធិ វុត្តោ ភគវតា អសេក្ខោបិ សមាធិ វុត្តោ ភគវតា សេក្ខាបិ បញ្ញា វុត្តា ភគវតា អសេក្ខាបិ បញ្ញា វុត្តា ភគវតា ។ កាតមញ្ច មហានាម សេក្ខំ សីលំ ។ ឥធ មហានាម ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ ឥទំ វុច្ចតិ មហានាម សេក្ខំ សីលំ ។ កាតមោ ច មហានាម សេក្ខោ សមាធិ ។ ឥធ មហានាម ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ មហានាម សេក្ខោ សមាធិ ។ កាតមា ច មហានាម សេក្ខា បញ្ញា ។ ឥធ មហានាម ភិក្ខុ

ក៏ចាប់ព្រះពាហានៃមហានាមសក្កៈ នាំទៅក្នុងទីសមគួរហើយ និយាយនឹងមហានាមសក្កៈដូច្នេះថា បពិត្រព្រះមហានាម សេក្ខសីល ក៏ព្រះមានព្រះភាគទ្រង់សម្តែងហើយ អសេក្ខសីល ក៏ព្រះមានព្រះភាគទ្រង់សម្តែងហើយ សេក្ខសមាធិ ក៏ព្រះមានព្រះភាគទ្រង់សម្តែងហើយ អសេក្ខ-សមាធិ ក៏ព្រះមានព្រះភាគទ្រង់សម្តែងហើយ សេក្ខប្បញ្ញា ក៏ព្រះមានព្រះភាគទ្រង់សម្តែងហើយ អសេក្ខប្បញ្ញា ក៏ព្រះមានព្រះភាគទ្រង់សម្តែងហើយដែរ ។ បពិត្រមហានាម ចុះសេក្ខសីល តើដូចម្តេច ។ បពិត្រមហានាម ភិក្ខុក្នុងសាសនានេះជាអ្នកមានសីល ។ បេ ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ បពិត្រមហានាម នេះហៅថា សេក្ខសីល ។ បពិត្រមហានាម ចុះសេក្ខសមាធិ តើដូចម្តេច ។ បពិត្រមហានាម ភិក្ខុក្នុងសាសនានេះស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បានដល់ចតុត្ថជ្ឈានសម្រេចសម្រាន្តនៅ ។ បពិត្រមហានាម នេះហៅថា សេក្ខសមាធិ ។ បពិត្រមហា-នាម ចុះសេក្ខប្បញ្ញា តើដូចម្តេច ។ បពិត្រមហានាម ភិក្ខុក្នុងសាសនានេះ

ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ ទុក្ខ-និរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ អយំ វុច្ចតិ មហានាម សេក្ខោ បញ្ញោ ។ ស ខោ សោ មហានាម អរិយសាវកោ ឯវំ សីលសម្បន្នោ ឯវំ សមាធិសម្បន្នោ ឯវំ បញ្ញាសម្បន្នោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឯវំ ខោ មហានាម សេក្ខម្បិ សីលំ វុត្តំ ភគវតា អសេក្ខម្បិ សីលំ វុត្តំ ភគវតា សេក្ខោបិ សមាធិ វុត្តោ ភគវតា អសេក្ខោបិ សមាធិ វុត្តោ ភគវតា សេក្ខាបិ បញ្ញា វុត្តា ភគវតា អសេក្ខាបិ បញ្ញា វុត្តា ភគវតាតិ ។

[៧៦] ឯកំ សមយំ អាយស្មា អានន្ទោ វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ អភយោ ច លិច្ឆវិ បណ្ឌិតកុមារកោ ច លិច្ឆវិ យេនាយស្មា អានន្ទោ តេនុបសង្កមឹសុ

ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមពិតថា នេះជាបដិបទាដំណើរទៅកាន់ទីរំលត់ទុក្ខ ។ បពិត្រមហានាម នេះហៅថា សេក្ខបញ្ញា ។ បពិត្រមហានាម អរិយសាវ័កនោះ អ្នកបរិបូណ៌ដោយសីលយ៉ាងនេះ បរិបូណ៌ដោយសមាធិយ៉ាងនេះ បរិបូណ៌ដោយបញ្ញាយ៉ាងនេះ រមែងធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ បពិត្រមហានាម សេក្ខសីល ក៏ព្រះមានព្រះភាគ ទ្រង់សម្តែងហើយ អសេក្ខសីល ក៏ព្រះមានព្រះភាគទ្រង់សម្តែងហើយ សេក្ខសមាធិ ក៏ព្រះមានព្រះភាគទ្រង់សម្តែងហើយ អសេក្ខសមាធិ ក៏ព្រះមានព្រះភាគទ្រង់សម្តែងហើយ សេក្ខបញ្ញា ក៏ព្រះមានព្រះភាគ ទ្រង់សម្តែងហើយ អសេក្ខបញ្ញា ក៏ព្រះមានព្រះភាគទ្រង់សម្តែងហើយ យ៉ាងនេះឯង ។

[៧៦] សម័យមួយ ព្រះអានន្ទមានអាយុ គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ។ គ្រានោះ ស្តេចលិច្ឆវិនាមអភ័យ និងស្តេចលិច្ឆវិនាមបណ្ឌិតកុមារកៈ ចូលទៅរកព្រះអានន្ទមានអាយុ

ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អភយោ លិច្ឆវិ អាយស្មន្តំ អានន្ទំ ឯតទវោច និគណ្ឋោ ភន្តេ នាដបុត្តោ សព្វញ្ញូ សព្វទស្សាវី អបរិសេសំ ញាណទស្សនំ បដិជានាតិ ចរតោ ច មេ តិដ្ឋតោ ច សុត្តស្ស ច ជាគរស្ស ច សតតំ សមិតំ ញាណទស្សនំ បច្ចុបដ្ឋិតន្តិ ។ សោ បុរាណានំ កម្មានំ តបសា ព្យន្តីភាវំ បញ្ញាបេតិ នវានំ កម្មានំ អករណា សេតុឃាតំ ឥតិ កម្មក្ខយា ទុក្ខក្ខយោ ទុក្ខក្ខយា វេទនាក្ខយោ វេទនាក្ខយា សព្វំ ទុក្ខំ និជ្ជិណ្ណំ ភវិស្សតិ ឯវមេតិស្សា សន្ទិដ្ឋិកាយ និជ្ជរាយ វិសុទ្ធិយា[១] សមតិក្កមោ ហោតិ ។ ឥធ ភន្តេ ភគវា កិមាហាតិ ។ តិស្សោ ខោ ឥមា អភយ និជ្ជរា វិសុទ្ធិយោ

១ ឥទំ អដ្ឋកថាយំ និជ្ជរាវិសុទ្ធិយាតិ ទិស្សតិ ។

លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះអានន្ទមានអាយុ ហើយគង់ក្នុងទីសមគួរ ។ លុះស្តេចលិច្ឆវិនាមអភ័យអង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះអានន្ទមានអាយុដូច្នេះថា បពិត្រអានន្ទដ៏ចម្រើន និគណ្ឋនាដបុត្រជាសព្វញ្ញូឃើញសព្វ តែងប្តេជ្ញានូវញាណទស្សនៈ (សព្វញ្ញុតញ្ញាណ) មិនមានសេសសល់ថា អាត្មាអញទោះដើរក្តី ឈរក្តី ដេកលក់ក្តី ភ្ញាក់ឡើងក្តី ញាណទស្សនៈតាំងឡើងឥតចន្លោះរាល់ពេល ។ និគណ្ឋនាដបុត្រនោះ តែងបញ្ញត្តនូវកិច្ច ធ្វើឲ្យអស់ទៅ នៃកម្មចាស់ទាំងឡាយដោយតបធម៌ បញ្ញត្តនូវការសម្លាប់បច្ច័យ ព្រោះមិនធ្វើកម្មថ្មីទាំងឡាយ ការអស់ទុក្ខ ព្រោះអស់កម្ម ការអស់វេទនា ព្រោះអស់ទុក្ខ ទុក្ខទាំងពួងនឹងសាបរលាបទៅ ព្រោះអស់វេទនា ដោយប្រការដូច្នេះឯង ការកន្លងនូវ (វដ្តទុក្ខ) ដោយវិសុទ្ធិដែលត្រូវឃើញចំពោះខ្លួនជាគ្រឿងធ្វើឲ្យកិលេសសាបរលាបនុ៎ះយ៉ាងនេះ ។ បពិត្រអានន្ទដ៏ចម្រើន ចុះព្រះមានព្រះភាគទ្រង់សម្តែងដូចម្តេច ក្នុងសាសនានេះ ។ ម្នាលអភ័យ និជ្ជរវិសុទ្ធិ (វិសុទ្ធិជាគ្រឿងធ្វើកិលេសឲ្យសាបរលាប) ទាំង ៣ នេះ

តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្មទក្ខាតា សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយ ។ កតមា តិស្សោ ។ ឥធ អភយ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ សោ នវញ្ច កម្មំ ន ករោតិ បុរាណញ្ច កម្មំ ផុស្ស ផុស្ស ព្យន្តីករោតិ សន្ទិដ្ឋិកា និជ្ជរា អកាលិកា ឯហិបស្សិកា ឱបនយិកា បច្ចត្តំ វេទិតព្វា វិញ្ញូហីតិ ។ ស ខោ សោ អភយ ភិក្ខុ ឯវំ សីលសម្បន្នោ វិវិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយ ដោយប្រពៃ ដើម្បីសេចក្តីស្អាតនៃសត្វទាំងឡាយ ដើម្បីកន្លងនូវសោកនិងខ្សឹកខ្សួលទាំងឡាយ ដើម្បីរលត់ទៅនៃទុក្ខនិងទោមនស្សទាំងឡាយ ដើម្បីត្រាស់ដឹងនូវមគ្គដែលប្រកបដោយវិបស្សនា ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ និជ្ជរាវិសុទ្ធិទាំង ៣ តើដូចម្តេច ។ ម្នាលអភ័យ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ភិក្ខុនោះមិនធ្វើកម្មថ្មីផង[១] បានពាល់ត្រូវរឿយៗ នូវកម្មចាស់[២]ហើយ ធ្វើឲ្យអស់ទៅផង ព្រោះវិសុទ្ធិ ជាធម្មជាតិដែលបុគ្គលគប្បីឃើញ ដោយខ្លួនឯង ជាគ្រឿងធ្វើកិលេសឲ្យសាបរលោប ឲ្យនូវផលមិនរង់ចាំកាល គួរដើម្បីបង្ហាញឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួនបាន ជាធម្មជាតិដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងច្បាស់ចំពោះខ្លួន ។ ម្នាលអភ័យ ភិក្ខុនោះ បរិបូណ៌ដោយសីលយ៉ាងនេះ ក៏ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បានដល់ចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅ ។

---

១-២ អដ្ឋកថាថា មិនសន្សំ មិនកសាងកម្មថ្មីទេ ឯផលកម្មចាស់នោះនៅខ្សោយតែលោកធ្វើឲ្យអស់ផលកម្មនោះ មិនឲ្យមានសល់តទៅទៀត ។

សោ នវញ្ច កម្មំ ន ករោតិ បុរាណញ្ច កម្មំ ផុស្ស ផុស្ស ព្យន្តីករោតិ សន្ទិដ្ឋិកា និជ្ជរា អកាលិកា ឯហិបស្សិកា ឱបនយិកា បច្ចត្តំ វេទិតព្វា វិញ្ញូហីតិ ។ ស ខោ សោ អភយ ភិក្ខុ ឯវំ សីលសម្បន្នោ ឯវំ សមាធិសម្បន្នោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ សោ នវញ្ច កម្មំ ន ករោតិ បុរាណញ្ច កម្មំ ផុស្ស ផុស្ស ព្យន្តីករោតិ សន្ទិដ្ឋិកា និជ្ជរា អកាលិកា ឯហិបស្សិកា ឱបនយិកា បច្ចត្តំ វេទិតព្វា វិញ្ញូហីតិ ។ ឥមា ខោ អភយ តិស្សោ និជ្ជរា វិសុទ្ធិយោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្មទក្ខាតា

ភិក្ខុនោះមិនធ្វើកម្មថ្មីផង ពាល់ត្រូវរឿយៗ នូវកម្មចាស់ហើយ ធ្វើឲ្យអស់ទៅផង ព្រោះវិសុទ្ធិ ជាធម្មជាតិដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ជាគ្រឿងធ្វើកិលេសឲ្យសាបរលាប ឲ្យនូវផលមិនរង់ចាំកាល គួរដើម្បីបង្ហាញឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួនបាន ជាធម្មជាតិដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងច្បាស់ចំពោះខ្លួន ។ ម្នាលអភ័យ ភិក្ខុនោះ បរិបូណ៌ដោយសីលយ៉ាងនេះ បរិបូណ៌ដោយសមាធិយ៉ាងនេះរមែងធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯងក្នុងបច្ចុប្បន្ន ។ ភិក្ខុនោះ មិនធ្វើកម្មថ្មីផង ពាល់ត្រូវរឿយៗ នូវកម្មចាស់ហើយ ធ្វើឲ្យអស់ទៅផង ព្រោះវិសុទ្ធិ ជាធម្មជាតិ ដែលបុគ្គលគប្បីឃើញដោយខ្លួនឯង ជាគ្រឿងធ្វើកិលេសឲ្យសាបរលាប ឲ្យនូវផលមិនរង់ចាំកាល គួរដើម្បីបង្ហាញឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួនបាន ជាធម្មជាតិដែលអ្នកប្រាជ្ញទាំងឡាយ គប្បីដឹងច្បាស់ចំពោះខ្លួន ។ ម្នាលអភ័យ នេះឯងនិជ្ជរាវិសុទ្ធិទាំង ៣ ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសម្តែងហើយដោយប្រពៃ

សត្តានំ វិសុទ្ធិយា សោកបរិទេវានំ សមតិក្កមាយ ទុក្ខទោមនស្សានំ អត្ថង្គមាយ ញាយស្ស អធិគមាយ និព្វានស្ស សច្ឆិកិរិយាយាតិ ។ ឯវំ វុត្តេ បណ្ឌិតកុមារកោ លិច្ឆវិ អភយំ លិច្ឆវឹ ឯតទវោច កិម្បន ត្វំ សម្ម អភយ អាយស្មតោ អានន្ទស្ស សុភាសិតំ សុភាសិតតោ នាព្ភនុមោទសីតិ ។ ក្យាហំ សម្ម អាយស្មតោ អានន្ទស្ស សុភាសិតំ សុភាសិតតោ នាព្ភនុមោទិស្សាមិ ។ មុទ្ធាបិ តស្ស វិបតេយ្យ យោ អាយស្មតោ អានន្ទស្ស សុភាសិតំ សុភាសិតតោ នាព្ភនុមោទេយ្យាតិ ។

[៧៧] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ

ដើម្បីសេចក្តីស្អាតរបស់សត្វទាំងឡាយ ដើម្បីកន្លងនូវសោកនិងខ្សឹកខ្សួល ទាំងឡាយ ដើម្បីរលត់ទុក្ខនិងទោមនស្សទាំងឡាយ ដើម្បីត្រាស់ដឹងនូវមគ្គ ប្រកបដោយវិបស្សនា ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ កាលបើព្រះ អានន្ទមានអាយុ សម្តែងយ៉ាងនេះហើយ ស្តេចលិច្ឆវិនាមបណ្ឌិតកុមារកៈ ក៏និយាយនឹងស្តេចលិច្ឆវិនាមអភ័យដូច្នេះថា នែអភ័យជាសំឡាញ់ ចុះ ហេតុអ្វី បានជាអ្នកមិនអនុមោទនាសុភាសិត របស់ព្រះអានន្ទមានអាយុ ដោយសុភាសិត ។ នែសំឡាញ់ ថ្វីក៏ខ្ញុំមិនអនុមោទនាសុភាសិតរបស់ព្រះ អានន្ទមានអាយុ ដោយសុភាសិត ។ អ្នកណាមិនអនុមោទនានូវសុភាសិត របស់ព្រះអានន្ទមានអាយុ ដោយសុភាសិតទេ ក្បាលរបស់អ្នកនោះ មុខជាធ្លាក់ចុះមិនខាន ។

[៧៧] គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះ ភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ

អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច យំ អានន្ទ អនុកម្បេយ្យាថ យេ ច សោតព្វំ មញ្ញេយ្យុំ មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា តេ វោ អានន្ទ តីសុ ឋានេសុ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ។ កតមេសុ តីសុ ។ ពុទ្ធេ អវេច្ចប្បសាទេ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេ-តព្វា ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ធម្មេ អវេច្ចប្បសាទេ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា ស្វាក្ខាតោ ភគវតា ធម្មោ សន្ទិដ្ឋិកោ អកាលិកោ ឯហិបស្សិកោ ឱបនយិកោ

ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលអានន្ទ អ្នកទាំងឡាយគប្បីអនុគ្រោះអ្នកណា ឬថា ពួកជនណាដែលជាមិត្រក្តី អាមាត្យក្តី ញាតិក្តី សាលោហិតក្តី គប្បីសម្គាល់នូវពាក្យដែលត្រូវស្តាប់ ម្នាលអានន្ទ ជនទាំងនោះ អ្នកទាំងឡាយ គួរណែនាំ គួរឲ្យនៅ គួរឲ្យតាំងនៅក្នុងឋានៈ ៣ យ៉ាង ។ ឋានៈ ៣ យ៉ាងនេះ តើដូចម្តេច ។ គឺគួរណែនាំ គួរឲ្យនៅ គួរឲ្យតាំងនៅ ក្នុងសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធថា ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ជាសារថីទូន្មាននូវបុរស ជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ខ្ជាក់ចោលនូវត្រៃភព លែងវិលត្រឡប់មកកើតទៀត ១ គួរណែនាំ គួរឲ្យនៅ គួរឲ្យតាំងនៅ ក្នុងសេចក្តីជ្រះថ្លា មិនកម្រើក ក្នុងព្រះធម៌ថា ធម៌ព្រះមានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ ជាធម៌ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ឲ្យនូវផលមិនរង់ចាំកាល គួរនឹងហៅបុគ្គលដទៃឲ្យចូលមកមើលបាន គួរបង្អោនចូលមកទុកក្នុងខ្លួន

បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ សង្ឃេ អវេច្ចប្ប-
សាទេ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វា
សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ឧជុប្បដិ-
បន្នោ ភគវតោ សាវកសង្ឃោ ញាយប្បដិ-
បន្នោ ភគវតោ សាវកសង្ឃោ សាមីចិប្បដិបន្នោ
ភគវតោ សាវកសង្ឃោ យទិទំ ចត្តារិ បុរិស-
យុគានិ អដ្ឋបុរិសបុគ្គលា ឯស ភគវតោ សាវក-
សង្ឃោ អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ
អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។
សិយា អានន្ទ ចតុន្នំ មហាភូតានំ អញ្ញថត្តំ
បឋវិធាតុយា អាបោធាតុយា តេជោធាតុយា វាយោ-
ធាតុយា ន ត្វេវ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតស្ស
អរិយសាវកស្ស សិយា អញ្ញថត្តំ ។ តត្រិទំ អញ្ញថត្តំ ។
សោ វតានន្ទ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតោ
អរិយសាវកោ និរយំ វា តិរច្ឆានយោនឹ វា
បេត្តិវិសយំ វា ឧបបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។

អ្នកប្រាជ្ញទាំងឡាយ គប្បីដឹងច្បាស់ចំពោះខ្លួន ១ គួរណែនាំ គួរឲ្យនៅ គួរឲ្យតាំងនៅក្នុងសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះសង្ឃថា ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ ប្រតិបត្តិដោយប្រពៃ ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ ប្រតិបត្តិដោយត្រង់ ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ ប្រតិបត្តិដើម្បីត្រាស់ដឹងនូវព្រះនិព្វាន ព្រះសង្ឃជាសាវ័កនៃព្រះមានព្រះភាគ ប្រតិបត្តិគួរដល់សាមីចិកម្ម ព្រះសង្ឃជាសាវ័កនៃព្រះដ៏មានព្រះភាគនុ៎ះ រាប់ជាគូនៃបុរសមាន ៤ គូ បើរាប់រៀងជាបុរសបុគ្គលមាន ៨ ពួកលោកគួរទទួលនូវរបស់ដែលគេរៀប ទទួលភ្ញៀវ គួរទទួលនូវរបស់ដែលគេនាំមកបូជា គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តរបស់សត្វលោកដ៏ប្រសើរបំផុត ។ ម្នាលអានន្ទ សេចក្តីប្រែប្រួលមានចំពោះតែមហាភូតរូប ៤ គឺបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ឯសេចក្តីប្រែប្រួលរបស់អរិយសាវ័ក ដែលប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធ មិនមានសោះឡើយ ។ នេះជាសេចក្តីប្រែប្រួលក្នុងហេតុនោះ ។ ម្នាលអានន្ទ ពាក្យថា អរិយសាវកនោះ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះពុទ្ធហើយ មុខជានឹងទៅកើតក្នុងនរកក្តី កំណើតតិរច្ឆានក្តី ប្រេតវិស័យក្តី ដូច្នេះនុ៎ះ មិនមែនជាឋានៈទេ ។

សិយា អានន្ទ ចតុន្នំ មហាភូតានំ អញ្ញថត្តំ បឋវីធាតុយា អាបោធាតុយា តេជោធាតុយា វាយោធាតុយា ន ត្វេវ ធម្មេ ។ បេ ។ ន ត្វេវ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតស្ស អរិយ-សាវកស្ស សិយា អញ្ញថត្តំ ។ តត្រិទំ អញ្ញថត្តំ ។ សោ វតានន្ទ សង្ឃេ អវេច្ចប្បសាទេន សមន្នាគតោ អរិយសាវកោ និរយំ វា តិរច្ឆានយោនឹ វា បេត្តិ-វិសយំ វា ឧបបជ្ជិស្សតីតិ នេតំ ឋានំ វិជ្ជតិ ។ យំ អានន្ទ អនុកម្បេយ្យាថ យេ ច សោតព្វំ មញ្ញេយ្យុំ មិត្តា វា អមច្ចា វា ញាតី វា សាលោហិតា វា តេ វោ អានន្ទ ឥមេសុ តីសុ ឋានេសុ សមាទបេតព្វា និវេសេតព្វា បតិដ្ឋាបេតព្វាតិ ។

[៧៨] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ

ម្នាលអានន្ទ សេចក្តីប្រែប្រួល មានចំពោះតែមហាភូតរូប ៤ គឺបឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ឯសេចក្តីប្រែប្រួល ។ បេ ។ ក្នុងព្រះធម៌ មិនគប្បីមានឡើយ សេចក្តីប្រែប្រួលមិនមានដល់ អរិយសាវ័កដែលប្រកប ដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះសង្ឃសោះទេ ។ នេះជាសេចក្តី ប្រែប្រួលក្នុងហេតុនោះ ។ ម្នាលអានន្ទ ពាក្យថា អរិយសាវ័កដែលប្រកប ដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះសង្ឃនោះ មុខជានឹងទៅកើត ក្នុងនរកក្តី កំណើតតិរច្ឆានក្តី ប្រេតវិស័យក្តី ដូច្នេះនុ៎ះ មិនមែនជាឋានៈ ទេ ។ ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីអនុគ្រោះអ្នកណា ឬថា អ្នក ណាជាមិត្រក្តី អាមាត្យក្តី ញាតិក្តី សាលោហិតក្តី គប្បីសម្គាល់នូវ ពាក្យដែលត្រូវស្តាប់ ម្នាលអានន្ទ ជនទាំងនោះ អ្នកទាំងឡាយ គួរ ណែនាំ គួរឲ្យនៅ គួរឲ្យតាំងនៅ ក្នុងឋានៈ ៣ យ៉ាងនេះ ។

[៧៨] គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះ ភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុអង្គុយក្នុងទីសមគួរហើយ

អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ភវោ ភវោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ភវោ ហោតីតិ ។ កាមធាតុវេបក្កញ្ច អានន្ទ កម្មំ នាភវិស្ស អបិ នុ ខោ កាមភវោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ ឥតិ ខោ អានន្ទ កម្មំ ខេត្តំ វិញ្ញាណំ ពីជំ តណ្ហា សិនេហោ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ ហីនាយ ធាតុយា វិញ្ញាណំ បតិដ្ឋិតំ ឯវំ អាយតឹបុនព្ភវាភិនិព្វត្តិ ហោតិ ។ រូបធាតុវេបក្កញ្ច អានន្ទ កម្មំ នាភវិស្ស អបិ នុ ខោ រូបភវោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ ឥតិ ខោ អានន្ទ កម្មំ ខេត្តំ វិញ្ញាណំ ពីជំ តណ្ហា សិនេហោ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ មជ្ឈិមាយ ធាតុយា វិញ្ញាណំ បតិដ្ឋិតំ ឯវំ អាយតឹបុនព្ភវាភិនិព្វត្តិ ហោតិ ។

ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់សម្តែងថា ភព ភព ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា ភព តើដោយហេតុដូចម្តេច ។ ម្នាលអានន្ទ បើកម្មដែលឲ្យផល (សម្រេច) ក្នុងកាមធាតុមិនមានហើយ កាមភពគប្បីមានប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុថា កម្មជាស្រែ វិញ្ញាណជាពូជ តណ្ហាជាទឹក វិញ្ញាណរបស់ពួកសត្វដែលមានអវិជ្ជាជាទំនប់ មានតណ្ហាជាគ្រឿងព័ន្ធព័ទ្ធ តម្កល់នៅស៊ប់ហើយក្នុងធាតុដ៏ថោកទាបគឺកាមធាតុ ការកើតចំពោះក្នុងភពថ្មីតទៅទៀត រមែងមានយ៉ាងនេះ ។ ម្នាលអានន្ទ បើកម្មដែលឲ្យផលក្នុងរូបធាតុមិនមានហើយ រូបភពគប្បីមានប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុថា កម្មជាស្រែ វិញ្ញាណជាពូជ តណ្ហាជាទឹក អភិសង្ខារវិញ្ញាណរបស់ពួកសត្វដែលមានអវិជ្ជាជាទំនប់ មានតណ្ហាជាគ្រឿងព័ន្ធព័ទ្ធ រមែងតម្កល់នៅស៊ប់ ក្នុងធាតុជាន់កណ្តាល គឺរូបធាតុ ការកើតចំពោះក្នុងភពថ្មីតទៅទៀត រមែងមានយ៉ាងនេះ ។

អរូបធាតុវេបក្កញ្ច អានន្ទ កម្មំ នាភវិស្ស អបិ នុ ខោ អរូបភវោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ ឥតិ ខោ អានន្ទ កម្មំ ខេត្តំ វិញ្ញាណំ ពីជំ តណ្ហា សិនេហោ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ បណីតាយ ធាតុយា វិញ្ញាណំ បតិដ្ឋិតំ ឯវំ អាយតឹបុនព្ភវាភិនិព្វត្តិ ហោតិ ។ ឯវំ ខោ អានន្ទ ភវោ ហោតីតិ ។

[៧៩] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ

ទុតិយបណ្ណាសក អានន្ទវគ្គ

ម្នាលអានន្ទ បើកម្មដែលឲ្យផលក្នុងអរូបធាតុ មិនមានហើយ អរូបភព គប្បីមានប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុថា កម្ម ជាស្រែ វិញ្ញាណ ជាពូជ តណ្ហា ជាទឹក ទើបអភិសង្ខារវិញ្ញាណរបស់ពួកសត្វ ដែលមានអវិជ្ជា ជាទំនប់ មានតណ្ហា ជាគ្រឿងព័ន្ធព័ទ្ធ រមែងតម្កល់នៅ ក្នុងជាតុជាន់ខ្ពស់គឺអរូប-ជាតុ ការកើតចំពោះក្នុងភពថ្មីតទៅទៀត រមែងមានយ៉ាងនេះ ។ ម្នាលអានន្ទ ភពរមែងមាន យ៉ាងនេះឯង ។

[៧៩] គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុអង្គុយក្នុងទីសមគួរហើយ

អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ភវោ ភវោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ ភវោ ហោតីតិ ។ កាមធាតុវេបក្កញ្ច អានន្ទ កម្មំ នាភវិស្ស អបិ នុ ខោ កាមភវោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ ឥតិ ខោ អានន្ទ កម្មំ ខេត្តំ វិញ្ញាណំ ពីជំ តណ្ហា សិនេហោ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ ហីនាយ ធាតុយា ចេតនា បតិដ្ឋិតា បត្ថនា[១] បតិដ្ឋិតា ឯវំ អាយតឹ-បុនព្ភវាភិនិព្វត្តិ ហោតិ ។ រូបធាតុវេបក្កញ្ច អានន្ទ កម្មំ នាភវិស្ស អបិ នុ ខោ រូបភវោ បញ្ញា-យេថាតិ ។ នោ ហេតំ ភន្តេ ។ ឥតិ ខោ អានន្ទ កម្មំ ខេត្តំ វិញ្ញាណំ ពីជំ តណ្ហា សិនេហោ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ មជ្ឈិមាយ ធាតុយា ចេតនា បតិដ្ឋិតា បត្ថនា បតិដ្ឋិតា ឯវំ អាយតឹបុនព្ភវាភិនិព្វត្តិ ហោតិ ។

---

១ បដ្ឋនាតិបិ ឯវំ សព្វត្ថ ។

ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ភព ភព ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ដែលហៅថា ភព តើដោយហេតុដូចម្តេច ។ ម្នាលអានន្ទ បើកម្មដែលឲ្យផលក្នុងកាមធាតុ មិនមានហើយ កាមភព គប្បីមានប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុថា កម្ម ជាស្រែ វិញ្ញាណ ជាពូជ តណ្ហាជាទឹក ចេតនានិងសេចក្តីប្រាថ្នារបស់ពួកសត្វដែលមានអវិជ្ជា ជាទំនប់ មានតណ្ហា ជាគ្រឿងព័ន្ធព័ទ្ធ រមែងតម្កល់នៅស៊ប់ក្នុងធាតុដ៏ថោកទាបគឺកាមធាតុ ការកើតចំពោះ ក្នុងភពថ្មីតទៅទៀត រមែងមាន យ៉ាងនេះ ។ ម្នាលអានន្ទ បើកម្មដែលឲ្យផល ក្នុងរូបធាតុ មិនមានហើយ រូបភព គប្បីមានប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះមិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុថា កម្ម ជាស្រែ វិញ្ញាណ ជាពូជ តណ្ហាជាទឹក ចេតនានិងសេចក្តីប្រាថ្នារបស់ពួកសត្វ ដែលមានអវិជ្ជា ជាទំនប់មានតណ្ហាជាគ្រឿងព័ន្ធព័ទ្ធ រមែងតម្កល់នៅស៊ប់ក្នុងធាតុជាន់កណ្តាលគឺរូបធាតុ ការកើតចំពោះ ក្នុងភពថ្មីទៅទៀត រមែងមានយ៉ាងនេះ ។

អរូបធាតុវេបក្កញ្ច អានន្ទ កម្មំ នាភវិស្ស អបិ នុ ខោ អរូបភវោ បញ្ញាយេថាតិ ។ នោ ហេតំ ភន្តេ ។ ឥតិ ខោ អានន្ទ កម្មំ ខេត្តំ វិញ្ញាណំ ពីជំ តណ្ហា សិនេហោ អវិជ្ជានីវរណានំ សត្តានំ តណ្ហាសញ្ញោជនានំ បណីតាយ ធាតុយា ចេតនា បតិដ្ឋិតា បត្ថនា បតិដ្ឋិតា ឯវំ អាយតឹបុនព្ភវាភិនិព្វត្តិ ហោតិ ។ ឯវំ ខោ អានន្ទ ភវោ ហោតីតិ ។

[៨០] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិ-វាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អានន្ទំ ភគវា ឯតទវោច សព្វំ នុ ខោ អានន្ទ សីលព្វតំ ជីវិតំ ព្រហ្មចរិយំ ឧបដ្ឋានសារំ សផលន្តិ ។ ន ខ្វេត្ត ភន្តេ ឯកំ-សេនាតិ ។ តេនហានន្ទ វិភជស្សូតិ ។ យញ្ហិស្ស ភន្តេ សីលព្វតំ ជីវិតំ ព្រហ្មចរិយំ ឧបដ្ឋាន-សារំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ

ម្នាលអានន្ទ បើកម្មដែលឲ្យផល ក្នុងអរូបធាតុ មិនមានហើយ អរូបភព គប្បីមានប្រាកដដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនុ៎ះ មិនមានទេ ។ ម្នាលអានន្ទ ព្រោះហេតុថា កម្ម ជាស្រែ វិញ្ញាណ ជាពូជ តណ្ហា ជាទឹក ចេតនានិងសេចក្តីប្រាថ្នារបស់ពួកសត្វ ដែលមានអវិជ្ជា ជាទំនប់ មានតណ្ហា ជាគ្រឿងព័ន្ធព័ទ្ធ រមែងតម្កល់នៅស៊ប់ ក្នុងធាតុជាន់ខ្ពស់គឺអរូបធាតុ ការកើតបំពោះក្នុងភពថ្មីតទៅទៀត រមែងមានយ៉ាងនេះ ។ ម្នាលអានន្ទ ភព រមែងមាន យ៉ាងនេះឯង ។

[៨០] គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់សួរដូច្នេះថា ម្នាលអានន្ទ សីលនិងវ័តជីវិត[១] ព្រហ្មចារ្យនិងការបម្រើ ដោយយល់ថា មានខ្លឹម ទាំងអស់ សុទ្ធតែមានផលឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងសេចក្តីនុ៎ះមិនគួរព្យាករដោយចំណែកតែម្យ៉ាងទេ ។ ម្នាលអានន្ទ បើដូច្នោះចូរអ្នកចែកសេចក្តីទៅមើល ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលសេពនូវសីលវ័ត ជីវិត ព្រហ្មចារ្យនិងការបម្រើ ដោយយល់ថា មានខ្លឹមណា អកុសលធម៌ទាំងឡាយ ចម្រើនឡើង

១ ព្យាយាមប្រកបដោយអំពើដែលគេធ្វើបានដោយកម្រ ( អដ្ឋកថា ) ។

កុសលា ធម្មា បរិហាយន្តិ ឯវរូបំ សីលព្វតំ ជីវិតំ ព្រហ្មចរិយំ ឧបដ្ឋានសារំ អផលំ ។ យញ្ច ខ្វស្ស ភន្តេ សីលព្វតំ ជីវិតំ ព្រហ្មចរិយំ ឧបដ្ឋានសារំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបំ សីលព្វតំ ជីវិតំ ព្រហ្មចរិយំ ឧបដ្ឋានសារំ សផលន្តិ ។ ឥទមវោច អាយស្មា អានន្ទោ សមនុញ្ញោ សត្ថា អហោសិ ។ អថខោ អាយស្មា អានន្ទោ សមនុញ្ញោ មេ សត្ថាតិ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា អចិរបក្កន្តេ អាយស្មន្តេ អានន្ទេ ភិក្ខូ អាមន្តេសិ សេក្ខោ ភិក្ខវេ អានន្ទោ ន ច បនស្ស សុលភរូបោ សមសមោ បញ្ញាយាតិ ។

កុសលធម៌ទាំងឡាយ វិនាសទៅ សីលវ័តជីវិត ព្រហ្មចារ្យ និងការបម្រើ ដោយយល់ថា មានខ្លឹម មានសភាពយ៉ាងនេះ ឈ្មោះថា ឥតផលទេ ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលសេពនូវសីលវ័ត ជីវិត ព្រហ្មចារ្យ និងការបម្រើ ដោយយល់ថា មានខ្លឹមណា អកុសលធម៌ទាំងឡាយ វិនាសទៅ កុសលធម៌ទាំងឡាយ ចម្រើនឡើង សីលវ័ត ជីវិត ព្រហ្មចារ្យនិងការបម្រើ ដោយយល់ថា មានខ្លឹម មានសភាពយ៉ាងនេះ ទើបឈ្មោះថា មានផល ។ លុះព្រះអានន្ទមានអាយុ ក្រាបទូលពាក្យនេះហើយ ព្រះសាស្តាក៏ទ្រង់គាប់ព្រះទ័យ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ដឹងថា ព្រះសាស្តារបស់អាត្មាអញ គាប់ព្រះទ័យហើយ ក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណរួចហើយចេញទៅ ។ កាលដែលព្រះអានន្ទមានអាយុ ចេញទៅមិនយូរប៉ុន្មាន ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អានន្ទជាសេក្ខបុគ្គល ប៉ុន្តែបុគ្គលដែលត្រឹមស្មើដោយបញ្ញារបស់អានន្ទនុ៎ះ មិនងាយនឹងរកបានទេ។

៣០៩



[៨១] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច តីណិមានិ ភន្តេ គន្ធជាតានិ យេសំ អនុវាតំយេវ គន្ធោ គច្ឆតិ នោ បដិវាតំ ។ កតមានិ តីណិ ។ មូលគន្ធោ សារគន្ធោ បុប្ផគន្ធោ ។ ឥមានិ ខោ ភន្តេ តីណិ គន្ធជាតានិ យេសំ អនុវាតំយេវ គន្ធោ គច្ឆតិ នោ បដិវាតំ ។ អត្ថិ នុខោ ភន្តេ កិញ្ចិ គន្ធជាតំ យស្ស អនុវាតម្បិ គន្ធោ គច្ឆតិ បដិវាតម្បិ គន្ធោ គច្ឆតិ អនុវាតប្បដិវាតម្បិ គន្ធោ គច្ឆតីតិ ។ អត្ថានន្ទ គន្ធជាតំ យស្ស អនុវាតម្បិ គន្ធោ គច្ឆតិ បដិវាតម្បិ គន្ធោ គច្ឆតិ អនុវាតប្បដិវាតម្បិ គន្ធោ គច្ឆតីតិ ។ កតមំ បន តំ ភន្តេ គន្ធជាតំ យស្ស អនុវាតម្បិ គន្ធោ គច្ឆតិ បដិវាតម្បិ គន្ធោ គច្ឆតិ អនុវាតប្បដិវាតម្បិ គន្ធោ គច្ឆតីតិ ។ ឥធានន្ទ យស្មឹ

ទុតិយបណ្ណាសក  អានន្ទវគ្គ

[៨១] គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្លិននៃគន្ធជាត ដែលផ្សាយទៅកាន់ទីបណ្តោយខ្យល់បាន ទៅច្រាសខ្យល់មិនបាន នេះ មាន ៣ យ៉ាង ។ គន្ធជាត ៣ យ៉ាង តើដូចម្តេច ។ គឺក្លិនឫស ១ ក្លិនខ្លឹម ១ ក្លិនផ្កា ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្លិនគន្ធជាតទាំង ៣ នេះឯង ផ្សាយទៅបានតែទីបណ្តោយខ្យល់ ទៅច្រាសខ្យល់មិនបានទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្រែងមានក្លិនគន្ធជាតអ្វី ដែលផ្សាយទៅបណ្តោយខ្យល់ក៏បាន ផ្សាយទៅច្រាសខ្យល់ក៏បាន ផ្សាយទៅទាំងបណ្តោយខ្យល់និងច្រាសខ្យល់ក៏បាន មានដែរឬទេ ។ ម្នាលអានន្ទ ក្លិនគន្ធជាត ដែលផ្សាយទៅបណ្តោយខ្យល់ក៏បាន ទៅច្រាសខ្យល់ក៏បាន ទៅបណ្តោយខ្យល់និងច្រាសខ្យល់ក៏បាន មានដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះគន្ធជាត ដែលផ្សាយទៅបណ្តោយខ្យល់ក៏បាន ច្រាសខ្យល់ក៏បាន ទាំងបណ្តោយខ្យល់និងច្រាសខ្យល់ក៏បាន តើដូចម្តេច ។ ម្នាលអានន្ទ ក្នុងលោកនេះ

គាមេ វា និគមេ វា ឥត្ថី វា បុរិសោ វា ពុទ្ធំ សរណំ គតោ ហោតិ ធម្មំ សរណំ គតោ ហោតិ សង្ឃំ សរណំ គតោ ហោតិ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ សីលវា ហោតិ កល្យាណធម្មោ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគោ បយតបាណិ វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ តស្ស ទិសាសុ សមណព្រាហ្មណា វណ្ណំ ភាសន្តិ អសុកស្មឹ នាម គាមេ វា និគមេ វា ឥត្ថី វា បុរិសោ វា ពុទ្ធំ សរណំ គតោ ធម្មំ សរណំ គតោ សង្ឃំ សរណំ គតោ បាណាតិបាតា បដិវិរតោ អទិន្នាទានា បដិ-វិរតោ កាមេសុ មិច្ឆាចារា បដិវិរតោ មុសាវាទា បដិវិរតោ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ សីលវា

ស្ត្រីក្តី បុរសក្តី ក្នុងស្រុកឬនិគមណា បានដល់ព្រះពុទ្ធជាទីរលឹក បានដល់ព្រះធម៌ជាទីរលឹក បានដល់ព្រះសង្ឃជាទីរលឹក វៀរចាកការសម្លាប់សត្វ វៀរចាកការលួចលាក់យកវត្ថុ ដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាម វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ជាអ្នកមានសីល មានធម៌ល្អ មានចិត្តប្រាសចាកសេចក្តីកំណាញ់ជាមន្ទិល នៅគ្រប់គ្រងផ្ទះ ជាអ្នកមានទានបរិច្ចាគហើយ មានដៃលាងស្អាតហើយ ជាអ្នកត្រេកអរក្នុងការលះ ជាអ្នកគួរគេសូមបាន ត្រេកអរក្នុងការឲ្យនិងការចែករលែក សមណ-ព្រាហ្មណ៍ក្នុងទិសទាំងឡាយ រមែងសរសើរបុគ្គលនោះថា ស្ត្រីក្តី បុរសក្តី ក្នុងស្រុកឬនិគមឈ្មោះឯណោះ ដល់ព្រះពុទ្ធជាទីរលឹក ដល់ព្រះធម៌ជាទីរលឹក ដល់ព្រះសង្ឃជាទីរលឹក វៀរចាកការសម្លាប់សត្វ វៀរចាកការលួចយកវត្ថុ ដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុស ក្នុងកាមទាំងឡាយ វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ ជាអ្នកមានសីល

កល្យាណធម្មោ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគោ បយតបាណិ វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោតិ ។ ទេវតាបិស្ស[១] វណ្ណំ ភាសន្តិ អសុកស្មឹ ធាម គាមេ វា និគមេ វា ឥត្ថី វា បុរិសោ វា ពុទ្ធំ សរណំ គតោ ។ បេ ។ យាចយោគោ ទានសំវិភាគរតោតិ ។ ឥទំ ខោ តំ អានន្ទ គន្ធជាតំ យស្ស អនុវាតម្បិ គន្ធោ គច្ឆតិ បដិវាតម្បិ គន្ធោ គច្ឆតិ អនុវាតប្បដិវាតម្បិ គន្ធោ គច្ឆតីតិ ។

ន បុប្ផគន្ធោ បដិវាតមេតិ
ន ចន្ទនំ តគរមល្លិកា វា
សតញ្ច គន្ធោ បដិវាតមេតិ
សព្វា ទិសា សប្បុរិសោ បវាយតីតិ ។

---

១ ឱ. ម. ឯត្ថន្តរេ អមនុស្សាបីតិ បាឋោ ទិស្សតិ ។

មានធម៌ល្អ មានចិត្តប្រាសចាកសេចក្ដីកំណាញ់ជាមន្ទិល នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគហើយ មានដៃលាងស្អាតហើយ ជាអ្នកត្រេកអរក្នុងការលះ គួរគេសូមបាន ត្រេកអរក្នុងការចែករំលែកទាន ។ សូម្បីពួកទេវតា ក៏តែងសរសើរបុគ្គលនោះថា ស្ត្រីក្តី បុរសក្តី ក្នុងស្រុកឬនិគមឈ្មោះឯណោះ ជាអ្នកដល់ព្រះពុទ្ធជាទីរលឹក ។ បេ ។ គួរគេសូមបាន ត្រេកអរក្នុងការចែករំលែកទាន ។ ម្នាលអានន្ទ ក្លិននៃគន្ធជាតនេះឯង ទើបផ្សាយទៅបណ្ដោយខ្យល់ក៏បាន ប្រាសខ្យល់ក៏បាន ទាំងបណ្ដោយខ្យល់ ទាំងប្រាសខ្យល់ក៏បាន ។

ក្លិនផ្កាផ្សាយទៅប្រាសខ្យល់ មិនបានទេ ទោះ ( ក្លិន )
ខ្លឹមចន្ទន៍ ក្រឹស្នានិងម្លិះលា ក៏ផ្សាយទៅប្រាសខ្យល់
មិនបានដែរ មានតែក្លិនរបស់សប្បុរសទាំងឡាយ
ទើបផ្សាយទៅប្រាសខ្យល់បាន សប្បុរស រមែងផ្សព្វ
ផ្សាយទៅកាន់ទិសទាំងពួង ។

[៨២] អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ ភគវតោ អានន្ទ សិខិស្ស អភិភូ នាម សាវកោ ព្រហ្មលោកេ ឋិតោ សហស្សីលោកធាតុំ សរេន វិញ្ញាបេសីតិ ។ ភគវា បន ភន្តេ អរហំ សម្មាសម្ពុទ្ធោ កីវតកំ បហោតិ សរេន វិញ្ញាបេតុន្តិ ។ សាវកោ សោ អានន្ទ អប្បមេយ្យា តថាគតាតិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ ភគវតោ អានន្ទ សិខិស្ស អភិភូ នាម សាវកោ ព្រហ្មលោកេ ឋិតោ សហស្សីលោកធាតុំ សរេន វិញ្ញាបេសីតិ ភគវា បន ភន្តេ អរហំ សម្មាសម្ពុទ្ធោ កីវតកំ បហោតិ សរេន វិញ្ញាបេតុន្តិ ។

[៨២] គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រនៃព្រះមានព្រះភាគ បានទទួលចំពោះព្រះភក្ត្រ នៃព្រះដ៏មានព្រះភាគយ៉ាងនេះថា ម្នាលអានន្ទ ភិក្ខុឈ្មោះ អភិភូ ជាសាវ័ករបស់ព្រះពុទ្ធសិខី ស្ថិតនៅឯព្រហ្មលោក បានញុំាងលោកធាតុទាំង ១០០០ ឲ្យដឹងច្បាស់ដោយសំឡេងបាន ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះមានព្រះភាគជាអរហន្តសម្មាសម្ពុទ្ធ អាចញុំាងលោកធាតុ មានប្រមាណត្រឹមណាឲ្យដឹងច្បាស់ដោយសំឡេងបាន ។ ម្នាលអានន្ទ អភិភូនោះជាសាវ័ក ឯព្រះតថាគតទាំងឡាយ មានអានុភាពប្រមាណមិនបានទេ ។ ព្រះអានន្ទមានអាយុក្រាបបង្គំទូលសួរព្រះមានព្រះភាគជាគម្រប់ ២ ដងដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រព្រះមានព្រះភាគ បានទទួលចំពោះព្រះភក្ត្រព្រះមានព្រះភាគយ៉ាងនេះថា ម្នាលអានន្ទ ភិក្ខុឈ្មោះអភិភូជាសាវ័ករបស់ព្រះពុទ្ធសិខី ស្ថិតនៅឯព្រហ្មលោក ញុំាងលោកធាតុ ១០០០ ឲ្យដឹងច្បាស់ដោយសំឡេងបាន បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ អាចញុំាងលោកធាតុមានប្រមាណត្រឹមណា ឲ្យដឹងច្បាស់ដោយសំឡេងបាន ។

សាវកោ សោ អានន្ទ អប្បមេយ្យោ តថាគតោតិ ។ តតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សម្មុខា មេតំ ភន្តេ ភគវតោ សុតំ សម្មុខា បដិគ្គហិតំ ភគវតោ អានន្ទ សិខិស្ស អភិភូ នាម សាវកោ ព្រហ្មលោកេ ឋិតោ សហស្សីលោកធាតុំ សរេន វិញ្ញាបេសីតិ ភគវា បន ភន្តេ អរហំ សម្មាសម្ពុទ្ធោ កីវតកំ បហោតិ សរេន វិញ្ញាបេតុន្តិ ។ សុតា តេ អានន្ទ សហស្សី ចូឡនិកា លោកធាតូតិ ។ ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ យំ ភគវា ភាសេយ្យ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ[១] ។ តេនហានន្ទ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បច្ចស្សោសិ ។

---

១ ឱ. ម. ធារេយ្យន្តីតិ ។

ម្នាលអានន្ទ អភិភូនោះជាសាវ័ក ឯព្រះតថាគតទាំងឡាយ មានអានុភាពប្រមាណមិនបានទេ ។ ព្រះអានន្ទមានអាយុ ក្រាបបង្គំទូលសួរ ព្រះដ៏មានព្រះភាគជាគម្រប់ ៣ ដងដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រព្រះមានព្រះភាគ បានទទួលចំពោះព្រះភក្ត្រព្រះមានព្រះភាគយ៉ាងនេះថា ម្នាលអានន្ទ ភិក្ខុឈ្មោះអភិភូ ជាសាវ័ករបស់ព្រះពុទ្ធសិខី ស្ថិតនៅឯព្រហ្មលោកញុំាងលោកធាតុ ១០០០ ឲ្យដឹងច្បាស់ដោយសំឡេងបាន បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ អាចញុំាងលោកធាតុ មានប្រមាណត្រឹមណា ឲ្យដឹងច្បាស់ដោយសំឡេងបាន ។ ម្នាលអានន្ទ លោកធាតុតូច ១០០០ អ្នកបានស្តាប់ហើយ ។ បពិត្រព្រះមានព្រះភាគ ជាកាលគួរនឹងសម្តែងរឿងនុ៎ះហើយ បពិត្រព្រះសុគត ជាកាលគួរនឹងសម្តែងរឿងនុ៎ះហើយ ព្រោះថាព្រះមានព្រះភាគ សម្តែងធម៌ណា ភិក្ខុទាំងឡាយ បានស្តាប់ព្រះមានព្រះភាគហើយ នឹងចាំទុកនូវធម៌នោះ ។ ម្នាលអានន្ទ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ព្រះអានន្ទដ៏មានអាយុ បានទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

ភគវា ឯតទវោច យាវតានន្ទ ចន្ទិមសុរិយា បរិហរន្តិ ទិសា ភន្តិ វិរោចនា តាវ សហស្សធា[១] លោកោ តស្មឹ សហស្សំ ចន្ទានំ សហស្សំ សុរិយានំ សហស្សំ សិនេរុបព្វតរាជានំ សហស្សំ ជម្ពុទីបានំ សហស្សំ អបរគោយានានំ សហស្សំ ឧត្តរកុរូនំ សហស្សំ បុព្វវិទេហានំ ចត្តារិ មហាសមុទ្ទសហស្សានិ ចត្តារិ មហារាជសហស្សានិ សហស្សំ ចាតុម្មហារាជិកានំ សហស្សំ តាវតឹសានំ សហស្សំ យាមានំ សហស្សំ តុសិតានំ សហស្សំ និម្មានរតីនំ សហស្សំ បរនិម្មិតវសវត្តីនំ សហស្សំ ព្រហ្មលោកានំ ។ អយំ វុច្ចតានន្ទ សហស្សី ចូឡនិកា លោកធាតុ ។ យាវតានន្ទ សហស្សី ចូឡនិកា លោកធាតុ តាវ សហស្សធា លោកោ អយំ វុច្ចតានន្ទ ទ្វិសហស្សី មជ្ឈិមិកា លោកធាតុ ។

១ ម. សហស្សធាតុ ។

ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលអានន្ទ ព្រះចន្ទ្រនិងព្រះអាទិត្យដ៏រុងរឿងគោចរទៅបំភ្លឺទិសទាំងឡាយ បានត្រឹមណា ត្រឹមណោះជាលោកមួយ (ត្រូវកំណត់យកលោកនោះ) ១០០០ ក្នុងលោកដែលកំណត់ ១០០០ ដងនោះមានព្រះចន្ទ្រ ១០០០ ព្រះអាទិត្យ ១០០០ ស្តេចភ្នំសិនេរុ ១០០០ ជម្ពូទ្វីប ១០០០ អបរគោយានទ្វីប ១០០០ ឧត្តរកុរុទ្វីប ១០០០ បុព្វវិទេហទ្វីប ១០០០ មហាសមុទ្រ ៤០០០ មហារាជ (លោកបាល) ៤០០០ ស្ថានចាតុម្មហារាជិកៈ ១០០០ ស្ថានតាវត្តិង្ស ១០០០ ស្ថានយាមៈ ១០០០ ស្ថានតុសិត ១០០០ ស្ថាននិម្មានរតី ១០០០ ស្ថានបរនិម្មិតវសវត្តី ១០០០ ព្រហ្មលោក ១០០០ ។ ម្នាលអានន្ទ នេះហៅថា សហស្សីចូឡនិកាលោកធាតុ[១] (លោកធាតុតូច) ។ ម្នាលអានន្ទ សហស្សីចូឡនិកាលោកធាតុកំណត់ត្រឹមណា ត្រឹមណោះទុកជាលោកមួយ (លោកនោះកំណត់) ១០០០ ដង ម្នាលអានន្ទ នេះហៅថា ទ្វិសហស្សីមជ្ឈិមិកាលោកធាតុ[២] ។

---

១ អដ្ឋកថាន័យ សេចក្តីថា ភពផែនដីដែលកំណត់ដោយព្រះអាទិត្យ ១ ព្រះចន្ទ្រ ១ អាចផ្សាយរស្មីភ្លឺបានត្រឹមណា ទីត្រឹមណោះ ទុកជាលោកធាតុ ១ ឬចក្រវាឡ ១ ។

២ កំណត់យកលោកធាតុឬចក្រវាឡមួយៗ នោះមួយពាន់ដងហៅថា មួយសហស្សីចូឡនិកាលោកធាតុ ។ កំណត់យកសហស្សីចូឡនិកាលោកធាតុនោះ មួយពាន់ដងហៅថា មួយ ទ្វិសហស្សីមជ្ឈិមិកាលោកធាតុ ។ លោកធាតុទី ២ នេះហួសវិស័យសាវ័កហើយ ជាវិស័យរបស់ព្រះពុទ្ធប៉ុណ្ណោះ ។ ដែលហៅថា ជាតិក្ខេត្តរបស់ព្រះពុទ្ធនោះសំដៅយកលោកធាតុទី២នេះឯងគឺ ក្នុងថ្ងៃដែលព្រះពោធិសត្វច្យុតចាកទេវលោកមកចាប់បដិសន្ធិក្នុងបច្ឆិមភពក្តី ថ្ងៃប្រសូតិក្តី ថ្ងៃចេញមហាភិនិស្រ្កមន៍ក្តី ថ្ងៃត្រាស់ដឹងក្តី ថ្ងៃសម្តែងធម្មចក្កប្បវត្តនសូត្រក្តី ថ្ងៃដាក់អាយុសង្ខារក្តី ថ្ងៃបរិនិព្វានក្តី លោកធាតុទាំងប៉ុណ្ណោះ កម្រើកញាប់ញ័រ ។

យាវតានន្ទ ទ្វិសហស្សី មជ្ឈិមិកា លោកធាតុ តាវ សហស្សធា លោកោ អយំ វុច្ចតានន្ទ តិសហស្សី មហាសហស្សី លោកធាតុ ។ អាកង្ខមានោ អានន្ទ តថាគតោ តិសហស្សឹ មហាសហស្សឹ លោកធាតុំ សរេន វិញ្ញាបេយ្យ យាវតា វា បន អាកង្ខេយ្យាតិ ។ យថាកថំ បន ភន្តេ ភគវា តិសហស្សឹ មហា-សហស្សឹ លោកធាតុំ សរេន វិញ្ញាបេយ្យ យាវតា វា បន អាកង្ខេយ្យាតិ ។ ឥធានន្ទ តថាគតោ តិសហស្សឹ មហាសហស្សឹ លោកធាតុំ ឱភាសេន ផរេយ្យ យទា តេ សត្តា តំ អាលោកំ សញ្ជានេយ្យុំ អថ តថាគតោ ឃោសំ ករេយ្យ សទ្ទមនុស្សាវេយ្យ

ម្នាលអានន្ទ ទិសហស្សីមជ្ឈិមិកាលោកធាតុត្រឹមណា ត្រឹមណោះជាលោកមួយ (លោកនោះកំណត់) ១០០០ដង ម្នាលអានន្ទ នេះហៅថា តិសហស្សីមហាសហស្សីលោកធាតុ[១] ។ ម្នាលអានន្ទ កាលបើ តថាគតប្រាថ្នាគប្បីញ៉ាំងតិសហស្សីមហាសហស្សីលោកធាតុ ឲ្យដឹងច្បាស់ដោយសំឡេងបាន ឬថាគប្បីប្រាថ្នាដល់ត្រឹមណាក៏បាន[២] ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះដ៏មានព្រះភាគ គប្បីញ៉ាំងតិសហស្សីមហាសហស្សីលោកធាតុ ឲ្យដឹងច្បាស់ដោយសំឡេងបាន ឬថាគប្បីប្រាថ្នាដល់ត្រឹមណាក៏បាន តើដូចម្តេច ។ ម្នាលអានន្ទ ក្នុងលោកនេះ តថាគតផ្សាយរស្មីទៅកាន់តិសហស្សីមហាសហស្សីលោកធាតុ កាលណាពួកសត្វទាំងនោះ ស្គាល់ច្បាស់នូវពន្លឺនោះបាន ក្នុងកាលនោះ តថាគតគប្បីធ្វើនូវសំឡេងឲ្យគឹកកងញ៉ាំងសំឡេងឲ្យលាន់ឮ

---

១ កណត់យកទិសហស្សីមជ្ឈិមិកាលោកធាតុនោះមួយពាន់ដងហៅថា មួយ តិសហស្សីមហាសហស្សីលោកធាតុ ។ បើព្រះសម្ពុទ្ធប្រាថ្នាផ្សាយព្រះសុរីរោភាសកម្ចាត់បង់ងងឹតក្នុងទីមានប្រមាណប៉ុណ្ណោះ ព្រះអង្គអាចផ្សាយបានឥតមានទើស ។ ទីប៉ុណ្ណោះហើយដែលហៅថាអាណាខេត្ត គឺអំណាចអាដានាដិយបរិត្ត ឥសិគិលិបរិត្ត ធជគ្គបរិត្ត ពោជ្ឈង្គបរិត្ត ខន្ធបរិត្ត មោរបរិត្ត មេត្តបរិត្ត និងរតនបរិត្ត ដែលព្រះសម្ពុទ្ធទ្រង់សម្តែងហើយ អាចផ្សាយដល់ទីប្រមាណប៉ុណ្ណោះ ។ ២ សំដៅយកវិសយក្ខេត្តៗ របស់ព្រះពុទ្ធនេះប្រមាណមិនបានឥតមានទើសទាល់ឡើយ។ចំនួនចក្រវាឡនោះច្រើនហួសនឹងគណនាបានឧបមាដូចជាបុគ្គលវិសេសណាមួយចង់ដឹងចំនួនចក្រវាឡហើយយកគ្រាប់ស្ពៃដែលពេញពីផែនដីដល់ព្រហ្មលោកក្នុង ១ សែនកោដិចក្រវាឡទៅរកចក្រវាឡក្នុងទិសខាងកើតឃើញចក្រវាឡ ១ ហើយដាក់គ្រាប់ស្ពៃ ១ គ្រាប់ ឃើញចក្រវាឡប៉ុន្មានក៏ដាក់គ្រាប់ស្ពៃប៉ុណ្ណោះយ៉ាងនេះគ្រាប់ស្ពៃទាំងឡាយអស់នោះមិនគ្រាន់អស់មុនឯចក្រវាឡនៅតែមានច្រើនទៅទៀត ។ ចំណែកចក្រវាឡក្នុងទិសឯទៀតក៏មានន័យដូចគ្នាដែរ ។

ឯវំ ខោ អានន្ទ តថាគតោ តិសហស្សី មហាសហស្សី លោកធាតុំ សរេន វិញ្ញាបេយ្យ យាវតា វា បន អាកង្ខេយ្យាតិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ ឯតទវោច លាភា វត មេ សុលទ្ធំ វត មេ យស្ស មេ សត្ថា ឯវំ មហិទ្ធិកោ ឯវំ មហានុភាវោតិ ។ ឯវំ វុត្តេ អាយស្មា ឧទាយិ អាយស្មន្តំ អានន្ទំ ឯតទវោច កឹ តុយ្ហេត្ថ អាវុសោ អានន្ទ យទិ តេ សត្ថា ឯវំ មហិទ្ធិកោ ឯវំ មហានុភាវោតិ ។ ឯវំ វុត្តេ ភគវា អាយស្មន្តំ ឧទាយឹ ឯតទវោច មាហេវំ ឧទាយិ សចេវំ ឧទាយិ អានន្ទោ អវីតរាគោ កាលំ ករេយ្យ តេន ចិត្តប្បសាទេន សត្តក្ខត្តុំ ទេវេសុ ទេវរជ្ជំ ការេយ្យ សត្តក្ខត្តុំ ឥមស្មឹយេវ ជម្ពុទីបេ មហារជ្ជំ ការេយ្យ អបិច ឧទាយិ អានន្ទោ ទិដ្ឋេវ ធម្មេ បរិនិព្វាយិស្សតីតិ ។

អានន្ទវគ្គោ តតិយោ ។

ម្នាលអានន្ទ តថាគត គប្បីញ៉ាំងតិសហស្សី មហាសហស្សីលោកធាតុ ឲ្យដឹងច្បាស់ដោយសំឡេងបាន ឬថាគប្បីប្រាថ្នាដល់ណាក៏បាន យ៉ាងនេះឯង ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ បានក្រាបទូលយ៉ាងនេះថា ឱ ជាលាភរបស់ខ្ញុំព្រះអង្គហើយ ខ្ញុំព្រះអង្គឈ្មោះថា បានល្អហើយ ព្រោះថា ព្រះសាស្តារបស់ខ្ញុំព្រះអង្គមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ។ កាលបើព្រះអានន្ទដ៏មានអាយុ និយាយយ៉ាងនេះហើយ ព្រះឧទាយិមានអាយុ ក៏និយាយតបនឹងព្រះអានន្ទមានអាយុដូច្នេះថា ម្នាលអាវុសោអានន្ទ ប្រសិនបើព្រះសាស្តារបស់អ្នក មានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ តើអ្នកនឹងបានអ្វីក្នុងដំណើរនុ៎ះ ។ កាលបើព្រះឧទាយិមានអាយុនិយាយយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះឧទាយិដ៏មានអាយុដូច្នេះថា ម្នាលឧទាយិ អ្នកកុំនិយាយយ៉ាងនេះឡើយ ម្នាលឧទាយិ បើអានន្ទ មិនទាន់ប្រាសចាករាគៈយ៉ាងនេះ ហើយគប្បីធ្វើមរណកាលដោយចិត្តជ្រះថ្លានោះ អានន្ទគប្បីសោយទេវរជ្ជសម្បត្តិ ក្នុងទេវលោក ៧ ដង សោយមហារជ្ជសម្បត្តិ ក្នុងជម្ពូទ្វីបនេះ ៧ ដង ម្នាលឧទាយិ តែថាអានន្ទនឹងបរិនិព្វាន ក្នុងអត្តភាពជាបច្ចុប្បន្ននេះ ។

ចប់ អានន្ទវគ្គ ទី ៣ ។

# តស្សុទ្ទានំ

ឆន្នោ   អាជីវកោ   សក្កោ

និគណ្ឋា   សមាទបកោ

ឆវាបិ   ច   តថា   ភវោ

សីលព្វតា   គន្ធា   ច   ចូឡនីតិ   ។

ទុតិយបណ្ណាសក អានន្ទវគ្គ

# ឧទ្ទាននៃអានន្ទវគ្គនោះ គឺ

*រឿងឆន្នបរិព្វាជក ១ សូត្រ អាជីវកសាវ័ក ១ សូត្រ មហានាមសក្កៈ ១ សូត្រ និគ្គណ្ឋនាដបុត្រ ១ សូត្រ ការដឹកនាំឲ្យល្អ ១ សូត្រ កម្មថ្មី ១ សូត្រ រឿងភពមានដូចគ្នានោះ ១ សូត្រ សីលវ័ត ១ សូត្រ ក្លិន ១ សូត្រ ចូឡនិកាលោកធាតុ ១ សូត្រ ។*

# សមណវគ្គោ

[៨៣] តីណីមានិ ភិក្ខវេ សមណស្ស សមណករណីយានិ ។ កតមានិ តីណិ ។ អធិសីលសិក្ខាសមាទានំ អធិចិត្តសិក្ខាសមាទានំ អធិប្បញ្ញាសិក្ខាសមាទានំ ។ ឥមានិ ខោ ភិក្ខវេ តីណិ សមណស្ស សមណករណីយានិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ តិព្វោ នោ ឆន្ទោ ភវិស្សតិ អធិសីលសិក្ខាសមាទានេ តិព្វោ នោ ឆន្ទោ ភវិស្សតិ អធិចិត្តសិក្ខាសមាទានេ តិព្វោ នោ ឆន្ទោ ភវិស្សតិ អធិប្បញ្ញាសិក្ខាសមាទានេតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[៨៤] សេយ្យថាបិ ភិក្ខវេ គទ្រភោ គោគណំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធោ ហោតិ អហម្បិ អម្ភា[១] អហម្បិ អម្ភាតិ[២] ។ តស្ស ន តាទិសោ វណ្ណោ ហោតិ សេយ្យថាបិ គុន្នំ ន តាទិសោ សរោ ហោតិ សេយ្យថាបិ គុន្នំ ន តាទិសំ បទំ ហោតិ សេយ្យថាបិ គុន្នំ ។

១-២ ម. ទម្មោ ។

# សមណវគ្គ

[៨៣] ម្នាលភិក្ខុទាំងឡាយ សមណកិច្ចរបស់សមណៈនេះ មាន ៣ យ៉ាង ។ កិច្ច ៣ យ៉ាង តើដូចម្តេច ។ គឺការសមាទាននូវអធិសីលសិក្ខា ១ ការសមាទាននូវអធិចិត្តសិក្ខា ១ ការសមាទាននូវអធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាសមណកិច្ចរបស់សមណៈ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិសីលសិក្ខា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិចិត្តសិក្ខា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិប្បញ្ញាសិក្ខា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះចុះ ។

[៨៤] ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចលា ជាប់តាមហ្វូងគោអំពីក្រោយៗ ថា អញជាគោដែរ អញជាគោដែរ ។ តែសម្បុរលានោះ មិនមែនដូចជាសម្បុររបស់ពួកគោទេ សម្រែកបែបលានោះក៏មិនដូចពួកគោទេ ស្នាមជើងបែបលានោះ ក៏មិនដូចពួកគោទេ ។

សោ គោគណំយេវ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធោ ហោតិ អហម្បិ អម្ហា អហម្បិ អម្ហាតិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ ភិក្ខុ ភិក្ខុសង្ឃំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធោ ហោតិ អហម្បិ ភិក្ខុ អហម្បិ ភិក្ខូតិ ។ តស្ស ន តាទិសោ ឆន្ទោ ហោតិ អធិសីលសិក្ខាសមាទានេ សេយ្យថាបិ អញ្ញេសំ ភិក្ខូនំ ន តាទិសោ ឆន្ទោ ហោតិ អធិចិត្តសិក្ខាសមាទានេ សេយ្យថាបិ អញ្ញេសំ ភិក្ខូនំ ន តាទិសោ ឆន្ទោ ហោតិ អធិប្បញ្ញា-សិក្ខាសមាទានេ សេយ្យថាបិ អញ្ញេសំ ភិក្ខូនំ ។ សោ ភិក្ខុសង្ឃំយេវ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធោ ហោតិ អហម្បិ ភិក្ខុ អហម្បិ ភិក្ខូតិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ តិព្វោ នោ ឆន្ទោ ភវិស្សតិ អធិសីលសិក្ខាសមាទានេ តិព្វោ នោ ឆន្ទោ ភវិស្សតិ អធិចិត្តសិក្ខាសមាទានេ តិព្វោ នោ ឆន្ទោ ភវិស្សតិ អធិប្បញ្ញាសិក្ខាសមាទានេតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

លានោះជាប់តាមហ្វូងគោអំពីក្រោយៗ ថា អញជាគោដែរ អញជាគោដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាប់តាមភិក្ខុសង្ឃអំពីក្រោយៗ ថា អាត្មាអញ ជាភិក្ខុដែរ អាត្មាអញ ជាភិក្ខុដែរ ។ តែសេចក្តីប៉ុនប៉ងបែបនោះរបស់ភិក្ខុនោះ មិនមានក្នុងការសមាទាននូវអធិសីលសិក្ខា ដូចជាពួកភិក្ខុដទៃទេ សេចក្តីប៉ុនប៉ងបែបនោះ មិនមានក្នុងការសមាទាននូវអធិចិត្តសិក្ខា ដូចជាពួកភិក្ខុដទៃទេ សេចក្តីប៉ុនប៉ងបែបនោះ មិនមានក្នុងការសមាទាននូវអធិប្បញ្ញាសិក្ខា ដូចជាពួកភិក្ខុដទៃទេ ។ ភិក្ខុនោះ គ្រាន់តែជាប់តាមភិក្ខុសង្ឃ អំពីក្រោយៗ ថា អាត្មាអញជាភិក្ខុដែរ អាត្មាអញជាភិក្ខុដែរប៉ុណ្ណោះ ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយគប្បីសិក្សាយ៉ាងនេះថា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិសីលសិក្ខា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិចិត្តសិក្ខា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិប្បញ្ញាសិក្ខា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសិក្សា យ៉ាងនេះចុះ ។

[៨៥] តីណីមានិ ភិក្ខវេ កស្សកស្ស គហបតិស្ស បុព្វ ករណីយានិ ។ កតមានិ តីណិ ។ ឥធ ភិក្ខវេ កស្សកោ គហបតិ បដិកច្ចេវ ខេត្តំ សុកដ្ឋំ ករោតិ សុមតិកតំ បដិកច្ចេវ ខេត្តំ សុកដ្ឋំ ករិត្វា សុមតិកតំ កាលេន ពីជានិ បតិដ្ឋាបេតិ កាលេន ពីជានិ បតិដ្ឋាបេត្វា សមយេន ឧទកំ អភិនេតិបិ អបនេតិបិ ។ ឥមានិ ខោ ភិក្ខវេ តីណិ កស្សកស្ស គហបតិស្ស បុព្វ ករណីយានិ ។ ឯវមេវ ខោ ភិក្ខវេ តីណីមានិ ភិក្ខុស្ស បុព្វ ករណីយានិ ។ កតមានិ តីណិ ។ អធិសីលសិក្ខាសមាទានំ អធិចិត្តសិក្ខាសមាទានំ អធិប្បញ្ញាសិក្ខាសមាទានំ ។ ឥមានិ ខោ ភិក្ខវេ តីណិ ភិក្ខុស្ស បុព្វ ករណីយានិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ តិព្វោ នោ ឆន្ទោ ភវិស្សតិ អធិសីលសិក្ខាសមាទានេ តិព្វោ នោ ឆន្ទោ ភវិស្សតិ អធិចិត្តសិក្ខាសមាទានេ តិព្វោ នោ ឆន្ទោ ភវិស្សតិ អធិប្បញ្ញាសិក្ខាសមាទានេតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[៨៩] ម្នាលភិក្ខុទាំងឡាយ កិច្ចដែលត្រូវធ្វើមុន របស់គហបតីអ្នកភ្ជួរនេះ មាន ៣ យ៉ាង ។ កិច្ច ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គហបតីអ្នកភ្ជួរ ក្នុងលោកនេះ មុនដំបូងត្រូវភ្ជួររាស់ស្រែឲ្យល្អលុះភ្ជួររាស់ស្រែឲ្យល្អដំបូងហើយ ក៏សាបព្រោះពូជតាមកាលដ៏គួរ លុះសាបព្រោះពូជ ក្នុងកាលដ៏គួរហើយ ក៏បញ្ចូលទឹកខ្លះ បញ្ចេញទឹកខ្លះតាមសម័យដ៏គួរ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាកិច្ចដែលត្រូវធ្វើមុនរបស់គហបតីអ្នកភ្ជួរ ៣ យ៉ាង ។ ម្នាលភិក្ខុទាំងឡាយ បុព្វកិច្ចរបស់ភិក្ខុនេះ ក៏មាន ៣ យ៉ាងដូច្នោះដែរ ។ កិច្ច ៣ យ៉ាងតើដូចម្តេច ។ គឺការសមាទាននូវអធិសីលសិក្ខា ១ ការសមាទាននូវអធិចិត្តសិក្ខា ១ ការសមាទាននូវអធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាបុព្វ-កិច្ច ៣ យ៉ាងរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះថា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិសីលសិក្ខា យើងនឹងមានសេចក្តីប៉ុន-ប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិចិត្តសិក្ខា យើងនឹងមានសេចក្តីប៉ុនប៉ងឲ្យណាស់ ក្នុងការសមាទាននូវអធិប្បញ្ញាសិក្ខា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសិក្សា យ៉ាងនេះចុះ ។

[៨៦] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ អញ្ញតរោ វជ្ជិបុត្តកោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ វជ្ជិបុត្តកោ ភិក្ខុ ភគវន្តំ ឯតទវោច សាធិកមិទំ ភន្តេ ទិយឌ្ឍសិក្ខាបទសតំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ នាហំ ភន្តេ ឯត្ថ សក្កោមិ សិក្ខិតុន្តិ ។ សក្ខសិ[១]បន ត្វំ ភិក្ខុ តីសុ សិក្ខាសុ សិក្ខិតុំ អធិសីលសិក្ខាយ អធិចិត្តសិក្ខាយ អធិប្បញ្ញាសិក្ខាយាតិ ។ សក្កោមហំ ភន្តេ តីសុ សិក្ខាសុ សិក្ខិតុំ អធិសីលសិក្ខាយ អធិចិត្តសិក្ខាយ អធិប្បញ្ញាសិក្ខាយាតិ ។ តស្មាតិហ ត្វំ ភិក្ខុ តីសុ សិក្ខាសុ សិក្ខស្សុ អធិសីលសិក្ខាយ អធិចិត្តសិក្ខាយ អធិប្បញ្ញាសិក្ខាយ យតោ ខោ ត្វំ ភិក្ខុ អធិសីលម្បិ សិក្ខិស្សសិ អធិចិត្តម្បិ សិក្ខិស្សសិ អធិប្បញ្ញម្បិ សិក្ខិស្សសិ

---

១ ម. សិក្ខិស្សសិ ។

[៨៦] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ។ គ្រានោះ វជ្ជិបុត្តកភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះវជ្ជិបុត្តកភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សិក្ខាបទ ១៥០ ដែលសម្រេចហើយនេះ មកកាន់ឧទ្ទេស រាល់កន្លះខែ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាចនឹងសិក្សា ក្នុងសិក្ខាបទទាំងនុ៎ះបានទេ ។ ម្នាលភិក្ខុ ចុះអ្នកអាចសិក្សាក្នុងសិក្ខា ៣ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ បានឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអាចនឹងសិក្សា ក្នុងសិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុ បើដូច្នោះក្នុងសាសនានេះ អ្នកចូរសិក្សា ក្នុងសិក្ខា ៣ គឺ អធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ចុះ ម្នាលភិក្ខុ កាលណាបើអ្នកនឹងសិក្សានូវអធិសីលផង សិក្សានូវអធិចិត្តផង សិក្សានូវអធិប្បញ្ញាផង

តស្ស[១] តុយ្ហំ[២] អធិសីលម្បិ សិក្ខតោ អធិចិត្តម្បិ សិក្ខតោ អធិប្បញ្ញម្បិ សិក្ខតោ រាគោ បហីយិស្សតិ ទោសោ បហីយិស្សតិ មោហោ បហីយិស្សតិ សោ ត្វំ រាគស្ស បហានា ទោសស្ស បហានា មោហស្ស បហានា យំ អកុសលំ តំ ន ករិស្សសិ យំ ធាបំ តំ ន សេវិស្សសីតិ ។ អថខោ សោ ភិក្ខុ អបរេន សមយេន អធិសីលម្បិ សិក្ខិ អធិចិត្តម្បិ សិក្ខិ អធិប្បញ្ញម្បិ សិក្ខិ ។ តស្ស អធិសីលម្បិ សិក្ខតោ អធិចិត្តម្បិ សិក្ខតោ អធិប្បញ្ញម្បិ សិក្ខតោ រាគោ បហីយិ ទោសោ បហីយិ មោហោ បហីយិ សោ រាគស្ស បហានា ទោសស្ស បហានា មោហស្ស បហានា យំ អកុសលំ តំ នាកាសិ យំ ធាបំ តំ ន សេវីតិ ។

[៨៧] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ

១ ឱ. តស្មា ។ ២ ឱ. ម. តុយ្ហំ ភិក្ខុ ។

កាលបើអ្នកកំពុងសិក្សានូវអធិសីលផង សិក្សានូវអធិចិត្តផង សិក្សានូវអធិប្បញ្ញាផង អ្នកគង់នឹងបានលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ (មិនខាន) ព្រោះតែការលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ អ្នកនោះនឹងមិនធ្វើអំពើដែលជាអកុសល ទាំងមិនសេពនូវអំពើដែលលាមក ។ លុះសម័យតមក ភិក្ខុនោះ ក៏សិក្សាអធិសីលផង សិក្សាអធិចិត្តផង សិក្សាអធិប្បញ្ញាផង ។ កាលភិក្ខុនោះ កំពុងសិក្សាអធិសីលផង សិក្សាអធិចិត្តផង សិក្សាអធិប្បញ្ញាផង ភិក្ខុនោះក៏បានលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ ព្រោះតែការលះបង់រាគៈ លះបង់ទោសៈ លះបង់មោហៈ ភិក្ខុនោះ មិនបានធ្វើអំពើដែលជាអកុសល ទាំងមិនបានសេពនូវអំពើដែលលាមកឡើយ ។

[៨៧] គ្រានោះ ភិក្ខុមួយរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ

ភគវន្តំ ឯតទវោច សេក្ខោ សេក្ខោតិ ភន្តេ វុច្ចតិ កិត្តាវតា នុ ខោ ភន្តេ សេក្ខោ ហោតីតិ ។ សិក្ខតីតិ ខោ ភិក្ខុ តស្មា សេក្ខោតិ វុច្ចតិ ។ កិញ្ច សិក្ខតិ ។ អធិសីលម្បិ សិក្ខតិ អធិចិត្តម្បិ សិក្ខតិ អធិប្បញ្ញម្បិ សិក្ខតីតិ ខោ ភិក្ខុ តស្មា សេក្ខោតិ វុច្ចតីតិ ។

សេក្ខស្ស  សិក្ខមានស្ស
ឧជុមគ្គានុសារិនោ
ខយស្មឹ  បឋមំ  ញាណំ
តតោ  អញ្ញា  អនន្តរា
តតោ  អញ្ញាវិមុត្តស្ស
ញាណំ  វេ  ហោតិ  តាទិនោ
អកុប្បា  មេ  វិមុត្តីតិ
ភវសញ្ញោជនក្ខយេតិ  ។

ក៏ក្រាបបង្គំទូលសួរ ព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់សម្តែងថា ភិក្ខុជាសេក្ខៈសេក្ខៈដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាសេក្ខៈ តើដោយហេតុដូចម្តេច ។ ម្នាលភិក្ខុ ព្រោះតែភិក្ខុនៅសិក្សា ហេតុនោះបានជា តថាគតហៅថា សេក្ខៈ ។ នៅសិក្សាអ្វី ។ ម្នាលភិក្ខុ នៅសិក្សាអធិសីលផង នៅសិក្សាអធិចិត្តផង នៅសិក្សាអធិប្បញ្ញាផង ហេតុនោះបានជា តថាគតហៅថា សេក្ខៈ ។

មគ្គញ្ញាណជាបឋម ក្នុងការអស់ទៅនៃកិលេស រមែងកើតឡើងដល់សេក្ខបុគ្គល នៅកំពុងសិក្សាជាអ្នកប្រតិបត្តិនូវផ្លូវដ៏ត្រង់ អរហត្តផល តែងកើតឡើង ជាលំដាប់អំពីមគ្គញ្ញាណទី ៤ នោះ តពីនោះទៅ បច្ចវេក្ខណញ្ញាណក្នុងការអស់ទៅនៃសំយោជនៈក្នុងភព រមែងមានដល់បុគ្គលដែលមានចិត្ត រួចស្រឡះហើយ ដោយអរហត្តផលវិមុត្តិជាតាទិបុគ្គល (អ្នកមិនញាប់ញ័រដោយលោកធម៌) ថា ការរួចស្រឡះរបស់អាត្មាអញ មិនបានកម្រើកឡើយ ។

[៨៨] សាធិកមិទំ ភិក្ខវេ ទិយឌ្ឍសិក្ខាបទសតំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ យត្ថ អត្តកាមា កុលបុត្តា សិក្ខន្តិ ។ តិស្សោ ឥមា ភិក្ខវេ សិក្ខា យត្ថេតំ សព្វំ សមោធានំ គច្ឆតិ ។ កតមា តិស្សោ ។ អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ ឥមា ខោ ភិក្ខវេ តិស្សោ សិក្ខា យត្ថេតំ សព្វំ សមោធានំ គច្ឆតិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលេសុ បរិបូរការី ហោតិ សមាធិស្មឹ មត្តសោការី បញ្ញាយ មត្តសោការី សោ យានិ តានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ តានិ អាបជ្ជតិបិ វុដ្ឋាតិបិ ។ តំ កិស្ស ហេតុ ។ ន ហិ មេត្ថ ភិក្ខវេ អភព្វតា វុត្តា ។ យានិ ច ខោ តានិ សិក្ខាបទានិ អាទិព្រហ្មចរិយកានិ ព្រហ្មចរិយសារុប្បានិ

[៨៨] ម្នាលភិក្ខុទាំងឡាយ សិក្ខាបទ ១៥០ ដែលម្រេចហើយនេះ តែងមកកាន់ឧទ្ទេស រាល់កន្លះខែ ដែលជាទីសិក្សារបស់ពួកកុលបុត្រអ្នកប្រាថ្នានូវប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ សិក្ខានេះ មាន ៣ ដែលជាទីប្រជុំចុះរបស់សិក្ខាបទ ១៥០ ទាំងអស់នុ៎ះ ។ សិក្ខា ៣ តើដូចម្តេច ។ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយនេះឯងសិក្ខា ៣ ដែលជាទីប្រជុំចុះរបស់សិក្ខាបទទាំងអស់នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីលទាំងឡាយធ្វើល្មមប្រមាណក្នុងសមាធិ ធ្វើល្មមប្រមាណក្នុងបញ្ញា ភិក្ខុនោះនៅត្រូវសិក្ខាបទតូច និងតូចបន្ទាប់[១] ទាំងនោះខ្លះ នៅចេញចាក(អាបត្តិ)ខ្លះ ។ ហេតុនោះនឹងទៅជាអ្វី ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែមិនឲ្យឈ្មោះថាជា អភព្វក្នុងការត្រូវអាបត្តិហើយចេញចាកអាបត្តិនុ៎ះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យទី ៤

១ បានដល់សិក្ខាបទដ៏សេសទាំងឡាយលើកលែងតែបារាជិក៤ចេញហៅថាតូចនិងតូចបន្ទាប់ គឺសង្ឃាទិសេសជាសិក្ខាបទតូច ថុល្លច្ច័យតូចបន្ទាប់ ថុល្លច្ច័យតូច បាចិត្តិយតូចបន្ទាប់ បាចិត្តិយតូច បាដិទេសនីយ ទុក្កដ ទុព្ភាសិត ឈ្មោះថា តូចបន្ទាប់ៗ ។ (អដ្ឋកថា) ។

តត្ថ ធុវសីលោ ច ហោតិ ឋិតសីលោ ច សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ សោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នោ ហោតិ អវិនិបាតធម្មោ និយតោ សម្ពោធិបរាយនោ ។ ឥធ បន ភិក្ខវេ ភិក្ខុ សីលេសុ បរិបូរការី ហោតិ សមាធិស្មឹ មត្តសោការី បញ្ញាយ មត្តសោការី សោ យានិ តានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ តានិ អាបជ្ជតិបិ វុដ្ឋាតិបិ ។ តំ កិស្ស ហេតុ ។ ន ហិ មេត្ថ ភិក្ខវេ អភព្វតា វុត្តា ។ យានិ ចិ ខោ តានិ សិក្ខាបទានិ អាទិព្រហ្មចរិយកានិ ព្រហ្មចរិយសារុប្បានិ តត្ថ ធុវសីលោ ច ហោតិ ឋិតសីលោ ច សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ សោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី ហោតិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករោតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ សីលេសុ បរិបូរការី ហោតិ សមាធិស្មឹ បរិបូរការី

ភិក្ខុនោះជាអ្នកមានសីលដាច់មិនដាច់ផង មានសីលតាំងនៅផង សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះ នៅតែបានសោតៈព្រោះការអស់សំយោជនៈ ៣ មានសភាពជាអ្នកមិនបានធ្លាក់ចុះក្នុងអបាយ ជាអ្នកទៀងមានការត្រាស់ដឹងប្រព្រឹត្តទៅក្នុងខាងមុខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើល្មមប្រមាណក្នុងសមាធិ ធ្វើល្មមប្រមាណក្នុងបញ្ញា ភិក្ខុនោះនៅតែត្រូវសិក្ខាបទតូច និងតូចដោយលំដាប់ខ្លះ ចេញចាកខ្លះ ។ ហេតុនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែមិនឲ្យឈ្មោះថាជាអភព្វ ក្នុងការត្រូវ និងការចេញនុ៎ះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យ ឲ្យតែភិក្ខុនោះ មានសីលខ្ជាប់ខ្ជួនផង មានសីលស្ថិតស្ថេរផង សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះនៅតែបានជាសកទាគាមី ព្រោះអស់សញ្ញោជនៈ ៣ ព្រោះតែស្រាលស្តើងរាគៈ ទោសៈ មោហៈ មកកាន់លោកនេះ ម្តងទៀតក៏ធ្វើនូវទីបំផុតទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ

បញ្ញាយ មត្តសោការី សោ យានិ តានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ តានិ អាបជ្ជតិបិ វុដ្ឋាតិបិ ។ តំ កិស្ស ហេតុ ។ ន ហិ មេត្ថ ភិក្ខវេ អភព្វតា វុត្តា ។ យានិ ច ខោ តានិ សិក្ខាបទានិ អាទិព្រហ្មចរិយកានិ ព្រហ្មចរិយសារុប្បានិ តត្ថ ធុវសីលោ ច ហោតិ ឋិតសីលោ ច សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថបរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ ឥធ បន ភិក្ខវេ ភិក្ខុ សីលេសុ បរិបូរការី ហោតិ សមាធិស្មឹ បរិបូរការី បញ្ញាយ បរិបូរការី សោ យានិ តានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ តានិ អាបជ្ជតិបិ វុដ្ឋាតិបិ ។ តំ កិស្ស ហេតុ ។ ន ហិ មេត្ថ ភិក្ខវេ អភព្វតា វុត្តា ។ យានិ ច ខោ តានិ សិក្ខាបទានិ អាទិព្រហ្មចរិយកានិ

ធ្វើល្មមប្រមាណក្នុងបញ្ញា ភិក្ខុនោះ នៅតែត្រូវសិក្ខាបទតូច និងតូចបន្ទាប់នោះខ្លះ ចេញចាកខ្លះ ។ ហេតុនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែមិនឲ្យឈ្មោះថា ជាអភព្វ ព្រោះការត្រូវ និងការចេញចាកនុ៎ះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យ ភិក្ខុនោះមានសីលខ្ជាប់ខ្ជួនផង មានសីលស្ថិតស្ថេរផង សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះជាឱបបាតិកៈ ព្រោះអស់សំយោជនៈជាចំណែកខាងក្រោម ៥ បរិនិព្វាន ក្នុងស្ថានសុទ្ធាវាសនោះ ទៀងតែមិនត្រឡប់មកពីលោកនោះវិញ ។ ម្នាលភិក្ខុទាំងឡាយមួយទៀត ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ធ្វើឲ្យបរិបូណ៌ក្នុងបញ្ញា ភិក្ខុនោះនៅតែត្រូវសិក្ខាបទតូច និងតូចបន្ទាប់នោះខ្លះ ចេញចាកខ្លះ ។ ហេតុនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែមិនទាន់ឲ្យឈ្មោះថា ជាអភព្វ ព្រោះការត្រូវនិងការចេញចាកនុ៎ះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ

ព្រហ្មចរិយសារុប្បានិ តត្ថ ធុវសីលោ ច ហោតិ ឋិតសីលោ ច សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ សោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥតិ ខោ ភិក្ខវេ បទេសំ បទេសការី អារាធេតិ បរិបូរំ បរិបូរការី អវញ្ឈានិត្វេវាហំ ភិក្ខវេ សិក្ខាបទានិ វទាមីតិ ។

[៨៩] សាធិកមិទំ ភិក្ខវេ ទិយឌ្ឍសិក្ខាបទសតំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ យត្ថ អត្តកាមា កុលបុត្តា សិក្ខន្តិ ។ តិស្សោ ឥមា ភិក្ខវេ សិក្ខា យត្ថេតំ សព្វំ សមោធានំ គច្ឆតិ ។ កតមា តិស្សោ ។ អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ ឥមា ខោ ភិក្ខវេ តិស្សោ សិក្ខា

សមគួរដល់មគ្គព្រហ្មចារ្យ ភិក្ខុនោះមានសីលខ្ជាប់ខ្ជួនផង មានសីលស្ថិតស្ថេរផង សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះ នៅតែធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ មិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលជាអ្នកធ្វើបានដោយអន្ទើ រមែងសម្រេចមគ្គផលដោយអន្ទើ[១] បុគ្គលជាអ្នកធ្វើឲ្យបរិបូណ៌ រមែងសម្រេចមគ្គផលបរិបូណ៌[២] ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែសម្តែងថា សិក្ខាបទទាំងឡាយ មិនមែនឥតអំពើឡើយ ។

[៨៩] ម្នាលភិក្ខុទាំងឡាយ សិក្ខាបទ ១៥០ ដែលសម្រេចហើយនេះតែងមកកាន់ឧទ្ទេស រាល់កន្លះខែ ដែលជាទីសិក្សារបស់ពួកកុលបុត្រអ្នកប្រាថ្នានូវប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ សិក្ខានេះ មាន ៣ ដែលជាទីប្រជុំចុះរបស់សិក្ខាបទទាំងអស់នុ៎ះ ។ សិក្ខា ៣ តើអ្វីខ្លះ ។ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងសិក្ខា ៣

---

១ បានដល់សោតាបន្នបុគ្គល សកទាគាមិបុគ្គល និងអនាគាមិបុគ្គល ។ ២. បានដល់ព្រះអរហន្ត ។ អដ្ឋកថា ។

យត្ថេតំ សព្វំ សមោធានំ គច្ឆតិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលេសុ បរិបូរការី ហោតិ សមាធិស្មឹ មត្តសោការី បញ្ញាយ មត្តសោការី សោ យានិ តានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ តានិ អាបជ្ជតិបិ វុដ្ឋាតិបិ ។ តំ កិស្ស ហេតុ ។ ន ហិ មេត្ថ ភិក្ខវេ អភព្វតា វុត្តា ។ យានិ ច ខោ តានិ សិក្ខាបទានិ អាទិព្រហ្មចរិយកានិ ព្រហ្មចរិយសារុប្បានិ តត្ថ ធុវសីលោ ច ហោតិ ឋិតសីលោ ច សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ សោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សត្តក្ខត្តុបរមោ ហោតិ សត្តក្ខត្តុបរមំ ទេវេ ច មនុស្សេ ច សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករោតិ ។ សោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា កោលង្កោលោ ហោតិ ទ្វេ វា តីណិ វា កុលានិ សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករោតិ ។

ដែលជាទីប្រជុំចុះនៃសិក្ខាបទទាំងអស់នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើល្មមប្រមាណក្នុងសមាធិ ធ្វើល្មមប្រមាណក្នុងបញ្ញា ភិក្ខុនោះនៅតែត្រូវសិក្ខាបទតូចនិងតូចបន្ទាប់នោះខ្វះ បេញចាកខ្វះ ។ ហេតុនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ឲ្យឈ្មោះថា ជាអកព្វក្នុងហេតុនុ៎ះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យ ឲ្យតែភិក្ខុនោះមាន សីលទៀងទាត់ស្ថិតស្ថេរ សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះគង់បានជាសត្តក្ខត្តុបរមៈ ព្រោះការអស់រលីងនៃសញ្ញោជនៈ ៣ ត្រេចរង្គាត់អន្ទោលទៅក្នុងទេវលោក និងមនុស្សលោកយ៉ាងច្រើនត្រឹម ៧ ជាតិ ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ ភិក្ខុនោះជាកោលង្កោលៈ ព្រោះអស់សញ្ញោជនៈ ៣ត្រេចរង្គាត់ អន្ទោលទៅកាន់ត្រកូល ២ ឬ[១] ៣ ក៏ធ្វើនូវទីបំផុតទុក្ខបាន។

---

១ កំណត់យកតាំងអំពី ២ ជាតិទៅដល់ ៦ ជាតិ ។ អដ្ឋកថា ។

ទុតិយបណ្ណាសកេ  សមណវគ្គោ

សោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា ឯកពីជី ហោតិ ឯកំយេវ មានុសកំ ភវំ និព្វត្តេត្វា ទុក្ខស្សន្តំ ករោតិ ។ សោ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគ-ទោសមោហានំ តនុត្តា សកទាគាមី ហោតិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករោតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ សីលេសុ បរិបូរការី ហោតិ សមាធិស្មឹ បរិបូរការី បញ្ញាយ មត្តសោការី សោ យានិ តានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ តានិ អាបជ្ជតិបិ វុដ្ឋាតិបិ ។ តំ កិស្ស ហេតុ ។ ន ហិ មេត្ថ ភិក្ខវេ អភព្វតា វុត្តា ។ យានិ ច ខោ តានិ សិក្ខាបទានិ អាទិព្រហ្មចរិយកានិ ព្រហ្មចរិយសារុប្បានិ តត្ថ ធុវសីលោ ច ហោតិ ឋិតសីលោ ច សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី ។

ភិក្ខុនោះជាឯកពីជី ព្រោះអស់សញ្ញោជនៈ ៣ កើតក្នុងភពជារបស់មនុស្ស តែម្តងប៉ុណ្ណោះ ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ ភិក្ខុនោះជាសកទាគាមី ព្រោះអស់សំយោជនៈ ៣ ព្រោះស្រាលស្តើងរាគៈ ទោសៈ មោហៈ មកកាន់លោកនេះ តែម្តងទៀត ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ធ្វើល្មមប្រមាណក្នុងបញ្ញា ភិក្ខុនោះ នៅត្រូវសិក្ខាបទតូច និងតូចបន្ទាប់ខ្លះ ចេញចាកខ្លះ ។ ហេតុនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ឲ្យឈ្មោះថា ជាអភព្វក្នុងហេតុនុ៎ះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យ ភិក្ខុនោះមានសីលទៀងទាត់ ស្ថិតស្ថេរ សមាទាន សិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះ ជាឧទ្ធំសោតអកនិដ្ឋគាមី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។

សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា សសង្ខារបរិនិព្វាយី ហោតិ ។ សោ បញ្ចន្នំ ឱរម្ភា-តិយានំ សញ្ញោជនានំ បរិក្ខយា អសង្ខារបរិនិព្វាយី ហោតិ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឧបហច្ចបរិនិព្វាយី ហោតិ ។ សោ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ សីលេសុ បរិបូរការី ហោតិ សមាធិស្មឹ បរិបូរការី បញ្ញាយ បរិបូរការី សោ យានិ តានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ តានិ អាបជ្ជតិបិ វុដ្ឋាតិបិ ។ តំ កិស្ស ហេតុ ។ ន ហិ មេត្ថ ភិក្ខវេ អភព្វតា វុត្តា ។ យានិ ច ខោ តានិ សិក្ខាបទានិ អាទិព្រហ្មចរិយកានិ ព្រហ្មចរិយ-សារុប្បានិ តត្ថ ធុវសីលោ ច ហោតិ ឋិតសីលោ ច សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ សោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។

ភិក្ខុនោះជាសសង្ខារបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ភិក្ខុនោះ ជាអសង្ខារបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ភិក្ខុនោះ ជាឧបហច្ចបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ភិក្ខុនោះ ជាអន្តរាបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ធ្វើឲ្យបរិបូណ៌ក្នុងបញ្ញា ភិក្ខុនោះ នៅត្រូវសិក្ខាបទតូច និងតូចបន្ទាប់ទាំងនោះខ្លះ ចេញចាកខ្លះ ។ ហេតុនោះតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ឲ្យឈ្មោះថា ជាអភព្វក្នុងហេតុនុ៎ះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ សមគួរដល់មគ្គព្រហ្មចារ្យ ឲ្យតែភិក្ខុនោះមានសីលខ្ជាប់ខ្ជួន មានសីលស្ថិតស្ថេរ សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះ គង់បានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញា ដ៏ក្រៃលែងខ្លួនឯងក្នុងបច្ចុប្បន្ន ។

ឥតិ ខោ ភិក្ខវេ បទេសំ បទេសការី អារាធេតិ បរិបូរំ បរិបូរការី អវញ្ឈានិត្វេវាហំ ភិក្ខវេ សិក្ខា-បទានិ វទាមីតិ ។

[៩០] សាធិកមិទំ ភិក្ខវេ ទិយឌ្ឍសិក្ខា-បទសតំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ យត្ថ អត្តកាមា កុលបុត្តា សិក្ខន្តិ ។ តិស្សោ ឥមា ភិក្ខវេ សិក្ខា យត្ថេតំ សព្វំ សមោធានំ គច្ឆតិ ។ កតមា តិស្សោ ។ អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ ឥមា ខោ ភិក្ខវេ តិស្សោ សិក្ខា យត្ថេតំ សព្វំ សមោធានំ គច្ឆតិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលេសុ បរិបូរការី ហោតិ សមាធិស្មឹ បរិបូរការី បញ្ញាយ បរិបូរការី សោ យានិ តានិ ខុទ្ទានុខុទ្ទកានិ សិក្ខាបទានិ តានិ អាបជ្ជតិបិ វុដ្ឋាតិបិ ។ តំ កិស្ស ហេតុ ។ ន ហិ មេត្ថ ភិក្ខវេ អភព្វតា វុត្តា ។ យានិ ច ខោ តានិ សិក្ខាបទានិ អាទិព្រហ្មចរិយកានិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកធ្វើបានដោយអន្ទើ រមែងញ៉ាំងមគ្គផល ដោយអន្ទើ ឲ្យសម្រេច បុគ្គលអ្នកធ្វើឲ្យបរិបូណ៌ រមែងញ៉ាំងមគ្គផល ឲ្យសម្រេចបានបរិបូណ៌ ដោយប្រការដូច្នេះឯង ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែសម្តែងថា សិក្ខាបទទាំងឡាយ មិនមែនឥតអំពើទេ ។

[៩០] ម្នាលភិក្ខុទាំងឡាយ សិក្ខាបទ ១៥០ ដែលសម្រេចហើយនេះ មកកាន់ឧទ្ទេស រាល់កន្លះខែ ដែលជាទីសិក្សារបស់កុលបុត្រអ្នកប្រាថ្នាប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ សិក្ខានេះ មាន ៣ ដែលជាទីប្រជុំរបស់សិក្ខាបទទាំងអស់នុ៎ះ ។ សិក្ខា ៣ តើដូចម្តេចខ្លះ ។ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងសិក្ខា ៣ ដែលជាទីប្រជុំនៃសិក្ខាបទទាំងអស់នុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ធ្វើឲ្យបរិបូណ៌ក្នុងសីល ធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ធ្វើឲ្យបរិបូណ៌ក្នុងបញ្ញា ភិក្ខុនោះនៅតែត្រូវសិក្ខាបទតូច និងតូចបន្ទាប់ទាំងនោះខ្លះ ចេញចាកខ្លះ ។ ហេតុនោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនទាន់ឲ្យឈ្មោះថាជាអភព្វក្នុងហេតុនុ៎ះទេ ។ ពួកសិក្ខាបទណា ជាខាងដើមនៃមគ្គព្រហ្មចារ្យ

ព្រហ្មចរិយសារុប្បានិ តត្ថ ធុវសីលោ ច ហោតិ ឋិតសីលោ ច សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ សោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ តំ វា បន អនភិសម្ភវំ អប្បដិវិជ្ឈំ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អន្តរាបរិនិព្វាយី ហោតិ ។ តំ វា បន អនភិសម្ភវំ អប្បដិវិជ្ឈំ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឧបហច្ចបរិនិព្វាយី ហោតិ ។ តំ វា បន អនភិសម្ភវំ អប្បដិវិជ្ឈំ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា អសង្ខារបរិនិព្វាយី ហោតិ ។ តំ វា បន អនភិសម្ភវំ អប្បដិវិជ្ឈំ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា សសង្ខារបរិនិព្វាយី ហោតិ ។ តំ វា បន អនភិសម្ភវំ អប្បដិវិជ្ឈំ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឧទ្ធំសោតោ ហោតិ អកនិដ្ឋគាមី ។

សមគួរដល់មគ្គព្រហ្មចារ្យ ឲ្យតែភិក្ខុមានសីលខ្ជាប់ខ្ជួន មានសីលស្ថិតស្ថេរ សមាទានសិក្សាក្នុងសិក្ខាបទទាំងនោះ ។ ភិក្ខុនោះ គង់ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯង ក្នុងបច្ចុប្បន្ន ។ ទោះបីមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវអរហត្តផលនោះទេ គង់បានសម្រេចភាពជាអន្តរាបរិនិព្វាយី ព្រោះអស់សញ្ញោជនៈជាចំណែកខាងក្រោម ៥ ។ បើទុកជាមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវអន្តរាបរិនិព្វាយីនោះទេ គង់បានសម្រេចភាពជាឧបហច្ចបរិនិព្វាយី ព្រោះអស់សញ្ញោជនៈជាចំណែកខាងក្រោម ៥ ។ ឬថា បើមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះ នូវឧបហច្ចបរិនិព្វាយីនោះទេ គង់បានសម្រេចភាពជាអសង្ខារបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ពុំនោះសោត បើមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវអសង្ខារបរិនិព្វាយីនោះទេ គង់បានសម្រេច ភាពជាសសង្ខារបរិនិព្វាយី ព្រោះអស់សញ្ញោជនៈ ជាចំណែកខាងក្រោម ៥ ។ ទោះបីមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវសសង្ខារបរិនិព្វាយីនោះទេ គង់បានសម្រេចភាពជាឧទ្ធំសោតអកនិដ្ឋគាមី ព្រោះអស់សញ្ញោជនៈជាចំណែកខាងក្រោម ៥ ។

៣៣៣



តំ វា បន អនភិសម្ភវំ អប្បដិវិជ្ឈំ តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមី ហោតិ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករោតិ ។ តំ វា បន អនភិសម្ភវំ អប្បដិវិជ្ឈំ តិណ្ណំ សញ្ញោជនានំ បរិក្ខយា ឯកពីជី ហោតិ ឯកំយេវ មានុសកំ ភវំ និព្វត្តេត្វា ទុក្ខស្សន្តំ ករោតិ ។ តំ វា បន អនភិសម្ភវំ អប្បដិវិជ្ឈំ តិណ្ណំ សញ្ញោជនានំ បរិក្ខយា កោលង្កោលោ ហោតិ ទ្វេ វា តីណិ វា កុលានិ សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករោតិ ។ តំ វា បន អនភិសម្ភវំ អប្បដិវិជ្ឈំ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សត្តក្ខត្តុបរមោ ហោតិ សត្តក្ខត្តុបរមំ ទេវេ ច មានុសេ ច សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករោតិ ។ ឥតិ ខោ ភិក្ខវេ បរិបូរំ បរិបូរការី អារាធេតិ បទេសំ បទេសការី អវញ្ឈានិត្វេវាហំ ភិក្ខវេ សិក្ខាបទានិ វទាមីតិ ។

កាលបើមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវឧទ្ធំសោតអកនិដ្ឋគាមីនោះទេ គង់តែបានសម្រេចភាពជាសកទាគាមី ព្រោះអស់សញ្ញោជនៈ ៣ ព្រោះស្រាលស្តើងរាគៈ ទោសៈ មោហៈ មកកាន់លោកនេះត្រឹមតែម្តង ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ កាលបើមិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវសកទាគាមិផលនោះទេ ដោយហោចទៅគង់បានសម្រេចភាពជាឯកពីជីសោត ព្រោះអស់សញ្ញោជនៈ ៣ កើតក្នុងភពជារបស់មនុស្សតែម្តងប៉ុណ្ណោះ ក៏ធ្វើនូវទីបំផុតនៃទុក្ខបាន ។ ឬក៏មិនទាន់សម្រេច មិនទាន់ចាក់ធ្លុះនូវឯកពីជីនោះទេ គង់បានសម្រេចភាពជាកោលង្កោលៈ ព្រោះអស់សញ្ញោជនៈ ៣ ត្រេចរង្គាត់ អន្ទោលទៅកាន់ត្រកូល ២ ឬ ៣ ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ ពុំនោះសោត កាលបើមិនទាន់សម្រេចមិនទាន់ចាក់ធ្លុះនូវកោលង្កោលៈនោះទេ គង់បានសម្រេចភាពជាសត្តក្ខត្តុបរមៈព្រោះអស់សញ្ញោជនៈ ៣ ត្រេចរង្គាត់ អន្ទោលទៅក្នុងទេវលោក និងមនុស្សលោកយ៉ាងច្រើនត្រឹម ៧ ជាតិ ក៏ធ្វើនូវទីបំផុតទុក្ខបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអ្នកធ្វើឲ្យបរិបូណ៌ រមែងសម្រេចមគ្គផលបរិបូណ៌ បុគ្គលអ្នកធ្វើបានដោយអន្ទើ រមែងសម្រេចមគ្គផលដោយអន្ទើ ដោយប្រការដូច្នេះឯង ម្នាលភិក្ខុទាំងឡាយ តថាគតនៅតែសម្តែងថា សិក្ខាបទទាំងឡាយ មិនមែនឥតអំពើទេ ។

[៩១] តិស្សោ ឥមា ភិក្ខវេ សិក្ខា ។ កតមា តិស្សោ ។ អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា ។ កតមា ច ភិក្ខវេ អធិសីលសិក្ខា ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ អយំ វុច្ចតិ ភិក្ខវេ អធិសីលសិក្ខា ។ កតមា ច ភិក្ខវេ អធិចិត្តសិក្ខា ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ អធិចិត្តសិក្ខា ។ កតមា ច ភិក្ខវេ អធិប្បញ្ញាសិក្ខា ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ អយំ វុច្ចតិ ភិក្ខវេ អធិប្បញ្ញាសិក្ខា ។ ឥមា ខោ ភិក្ខវេ តិស្សោ សិក្ខាតិ ។

[៩១] ម្នាលភិក្ខុទាំងឡាយ សិក្ខានេះ មាន ៣ ។ សិក្ខា ៣ តើដូចម្ដេច ។ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ អធិសីលសិក្ខា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សាក្នុងសិក្ខា-បទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិសីលសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ អធិចិត្តសិក្ខា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ។ បេ ។ បានដល់ចតុត្ថជ្ឈានសម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិចិត្តសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ អធិប្បញ្ញាសិក្ខា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិប្បញ្ញាសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ នេះឯងសិក្ខា ៣ ។

[៩២] តិស្សោ ឥមា ភិក្ខវេ សិក្ខា ។ កតមា តិស្សោ ។ អធិសីលសិក្ខា អធិចិត្តសិក្ខា អធិ-ប្បញ្ញាសិក្ខា ។ កតមា ច ភិក្ខវេ អធិសីលសិក្ខា ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ។ អយំ វុច្ចតិ ភិក្ខវេ អធិ-សីលសិក្ខា ។ កតមា ច ភិក្ខវេ អធិចិត្តសិក្ខា ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ អធិចិត្តសិក្ខា ។ កតមា ច ភិក្ខវេ អធិប្បញ្ញាសិក្ខា ។ ឥធ ភិក្ខវេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ អធិប្បញ្ញាសិក្ខា ។ ឥមា ខោ ភិក្ខវេ តិស្សោ សិក្ខាតិ ។

អធិសីលំ អធិចិត្តំ
អធិប្បញ្ញញ្ច វីរិយវា
ថាមវា ធីតិមា ឈាយី
សតោ គុត្តិន្ទ្រិយោ ចរេ

[៩២] ម្នាលភិក្ខុទាំងឡាយ សិក្ខានេះ មាន ៣ ។ សិក្ខា ៣ តើដូចម្ដេច ។ គឺអធិសីលសិក្ខា ១ អធិចិត្តសិក្ខា ១ អធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ អធិសីលសិក្ខា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិសីលសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ អធិចិត្តសិក្ខា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ បានដល់ចតុត្ថជ្ឈានសម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិចិត្តសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ អធិប្បញ្ញាសិក្ខា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់ នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាខ្លួនឯងដ៏ក្រៃលែង ក្នុងបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អធិប្បញ្ញាសិក្ខា ។ ម្នាលភិក្ខុទាំងឡាយ នេះឯងសិក្ខា ៣ ។

បុគ្គលមានព្យាយាម មានកម្លាំង មានប្រាជ្ញា ជាគ្រឿង
ទ្រទ្រង់ មានឈាន មានស្មារតី មានឥន្ទ្រិយគ្រប់គ្រង
គួរប្រព្រឹត្តនូវអធិសីលផង អធិចិត្តផង អធិប្បញ្ញាផង

យថា បុរេ តថា បច្ឆា
យថា បច្ឆា តថា បុរេ
យថា អធោ តថា ឧទ្ធំ
យថា ឧទ្ធំ តថា អធោ
យថា ទិវា តថា រត្តឹ
យថា រត្តឹ តថា ទិវា
អភិភុយ្យ ទិសា សព្វា
អប្បមាណសមាធិនា ។
តមាហុ សេក្ខំ បដិបទំ
អថោ សំសុទ្ធចារិនំ
តមាហុ លោកេ សម្ពុទ្ធំ
ធីរំ(១) បដិបទន្តគុំ ។
វិញ្ញាណស្ស និរោធេន
តណ្ហាក្ខយវិមុត្តិនោ
បជ្ជោតស្សេវ និព្វានំ
វិមោក្ខោ ហោតិ ចេតសោតិ ។

---

១ ឥទដ្ឋកថាយំ ថិរន្តិ ទិស្សតិ ។

បុគ្គល (សិក្សាក្នុងសិក្ខា ៣) ក្នុងកាលមុន យ៉ាងណា ក្នុងកាលក្រោយក៏យ៉ាងនោះ ក្រោយយ៉ាងណា មុនក៏យ៉ាងនោះ (ឃើញ) កាយខាងក្រោម (ដោយអំណាចនៃអសុភ) យ៉ាងណា ឃើញកាយខាងលើក៏យ៉ាងនោះ កាយខាងលើ យ៉ាងណា ខាងក្រោមក៏យ៉ាងនោះ (សិក្សាក្នុងសិក្ខា ៣) ក្នុងវេលាថ្ងៃយ៉ាងណា ក្នុងវេលាយប់ ក៏យ៉ាងនោះ ក្នុងវេលាយប់យ៉ាងណា ក្នុងវេលាថ្ងៃក៏យ៉ាងនោះដែរ គប្បីគ្របសង្កត់ (នូវអារម្មណ៍ទាំងឡាយ) គ្រប់ទិសដោយអប្បមាណសមាធិគឺសមាធិប្រកបដោយអរហត្តមគ្គ ។ ពួកព្រះអរិយៈតែងសរសើរ បុគ្គលជាសេក្ខៈអ្នកប្រតិបត្តិ ថាជាអ្នកមានសេចក្តីប្រព្រឹត្តដ៏បរិសុទ្ធ សរសើរបុគ្គលអ្នកត្រាស់ដឹងអរិយសច្ច ៤ ក្នុងលោកនេះ ថាជាអ្នកមានប្រាជ្ញា ដល់នូវទីបំផុតនៃសេចក្តីប្រតិបត្តិ ។ ការរួចស្រឡះនៃចិត្តរបស់បុគ្គលដែលមានសេចក្តីរួចស្រឡះ ព្រោះអស់តណ្ហា ដោយសេចក្តីរលត់វិញ្ញាណ ដូចជាការរលត់ទៅនៃប្រទីបជាគ្រឿងបំភ្លឺ ។

[៩៣] ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន បង្កធា នាម កោសលានំ និគមោ តទវសរិ ។ តត្រ សុទំ ភគវា បង្កធាយំ វិហរតិ បង្កធា នាម កោសលានំ និគមោ ។ តេន ខោ បន សមយេន កស្សបគោត្តោ នាម ភិក្ខុ បង្កធាយំ អាវាសិកោ ហោតិ ។ តត្រ សុទំ ភគវា សិក្ខាបទប្បដិសំយុត្តាយ ធម្មិយា កថាយ ភិក្ខូ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ ។ អថខោ កស្សប-គោត្តស្ស ភិក្ខុនោ ភគវតា សិក្ខាបទប្បដិសំយុត្តាយ ធម្មិយា កថាយ ភិក្ខូ សន្ទស្សេន្តេ សមាទបេន្តេ សមុត្តេជេន្តេ សម្បហំសេន្តេ អហុទេវ អក្ខន្តិ អហុ អប្បច្ចយោ អធិសល្លេខតេវាយំ សមណោតិ ។ អថខោ ភគវា បង្កធាយំ យថាភិរន្តំ វិហរិត្វា យេន រាជគហំ តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន រាជគហំ តទវសរិ ។

[៩៣] សម័យមួយ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិក ក្នុងដែនកោសល ជាមួយនឹងភិក្ខុសង្ឃច្រើនរូប បានដល់និគមឈ្មោះបង្កជា របស់ដែនកោសល ។ បានឮថា សម័យនោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងបង្កជានិគម របស់ដែនកោសល ។ សម័យនោះ ភិក្ខុឈ្មោះកស្សបគោត្រ ជាចៅអាវាសក្នុងបង្កជានិគម ។ បានឮថា ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាដ៏ប្រកបដោយសិក្ខាបទ ។ គ្រាកាលដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុ ឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទហើយ ភិក្ខុកស្សបគោត្រ មានសេចក្តីមិនអត់ទ្រាំ មិនត្រេកអរថា សមណៈនេះដូចជាជុសខាត់ជ្រុលពេក ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងបង្កជានិគមតាមសមគួរដល់ពុទ្ធអធ្យាស្រ័យហើយ ក៏ទ្រង់ត្រេចចារិកទៅកាន់ក្រុងរាជគ្រឹះ កាលទ្រង់ត្រេចចារិកដោយលំដាប់ ក៏បានដល់ក្រុងរាជគ្រឹះនោះ ។

តត្រ សុទំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អថខោ កស្សបគោត្តស្ស ភិក្ខុនោ អចិរបក្កន្តស្ស ភគវតោ អហុទេវ កុក្កុច្ចំ អហុ វិប្បដិសារោ អលាភា វត មេ ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ យស្ស មេ ភគវតា សិក្ខាបទប្បដិសំយុត្តាយ ធម្មិយា កថាយ ភិក្ខូ សន្ទស្សេន្តេ សមាទបេន្តេ សមុត្តេជេន្តេ សម្បហំសេន្តេ អហុទេវ អក្ខន្តិ អហុ អប្បច្ចយោ អធិសល្លេខតេវាយំ សមណោតិ យន្នូនាហំ យេន ភគវា តេនុបសង្កមេយ្យំ ឧបសង្កមិត្វា ភគវតោ សន្តិកេ អច្ចយំ អច្ចយតោ ទេសេយ្យន្តិ ។ អថខោ កស្សបគោត្តោ ភិក្ខុ សេនាសនំ សំសាមេត្វា បត្តចីវរមាទាយ យេន រាជគហំ តេន បក្កាមិ អនុ-បុព្វេន យេន រាជគហំ គិជ្ឈកូដោ បព្វតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ

បានឮថា ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ កាលដែលព្រះមានព្រះភាគ ទ្រង់ស្ដេចចេញទៅ មិនយូរប៉ុន្មាន ភិក្ខុកស្សបគោត្រ មានសេចក្ដីក្ដៅក្រហាយ ស្ដាយក្រោយថា មិនជាលាភរបស់អាត្មាអញ អាត្មាអញឈ្មោះថាឥតលាភ អាត្មាអញឈ្មោះថាបានទាស់ហើយ អាត្មាអញមិនមែនបានស្រួលទេ ព្រោះថា កាលដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុ ឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាដ៏ប្រកបដោយសិក្ខាបទហើយ អាត្មាអញមានសេចក្ដីមិនអត់ទ្រាំ មិនត្រេកអរថា សមណៈនេះ ដូចជាជុសខាត់ជ្រុលពេក បើដូច្នោះគួរតែអាត្មាអញចូលទៅគាល់ ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ត្រូវសម្ដែងទោសតាមទោស ក្នុងសំណាក់ព្រះមានព្រះភាគ ។ លំដាប់នោះ ភិក្ខុកស្សបគោត្រ រៀបទុកដាក់សេនាសនៈហើយ ក៏ប្រដាប់បាត្រនិងចីវររួចចេញទៅកាន់ក្រុងរាជគ្រឹះ បានចូលទៅគាល់ព្រះមានព្រះភាគឯភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះនោះ ដោយលំដាប់ លុះចូលទៅហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុកស្សបគោត្រ អង្គុយក្នុងទីសមគួរហើយ

៣៣៩



កស្សបគោត្តោ ភិក្ខុ ភគវន្តំ ឯតទវោច ឯកមិទំ ភន្តេ សមយំ ភគវា បង្កធាយំ វិហរតិ បង្កធា នាម កោសលានំ និគមោ ។ តត្រ សុទំ ភគវា សិក្ខាបទប្បដិសំយុត្តាយ ធម្មិយា កថាយ ភិក្ខូ សន្ទស្សេតិ សមាទបេតិ សមុត្តេជេតិ សម្បហំសេតិ[១] តស្ស មយ្ហំ ភន្តេ ភគវតា សិក្ខាបទប្បដិសំ-យុត្តាយ ធម្មិយា កថាយ ភិក្ខូ សន្ទស្សេន្តេ សមាទបេន្តេ សមុត្តេជេន្តេ សម្បហំសេន្តេ អហុទេវ អក្ខន្តិ អហុ អប្បច្ចយោ អធិសល្លេខតេវាយំ សមណោតិ អថខោ ភគវា បង្កធាយំ យថាភិរន្តំ វិហរិត្វា យេន រាជគហំ តេន ចារិកំ បក្កាមិ តស្ស មយ្ហំ ភន្តេ អចិរប្បក្កន្តស្ស ភគវតោ អហុទេវ កុក្កុច្ចំ អហុ វិប្បដិសារោ អលាភា វត មេ

១ ឱ. ម. សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។

ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងបង្កធានិគម របស់ដែនកោសល ។ ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុ ឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទ ខ្ញុំព្រះអង្គ អ្នកមានសេចក្តីមិនអត់ទ្រាំ មិនត្រេកអរថា សមណៈនេះ ដូចជាជុសខាត់ជ្រុលពេក គ្រានោះ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងបង្កធានិគម តាមសមគួរ ដល់ពុទ្ធ-អធ្យាស្រ័យហើយ ទ្រង់ត្រេចចារិកមកកាន់ក្រុងរាជគ្រឹះ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះមានព្រះភាគ ទ្រង់ស្តេចចេញមក មិនយូរប៉ុន្មាន ខ្ញុំព្រះអង្គកើតសេចក្តីក្តៅក្រហាយស្តាយក្រោយថា មិនជាលាភ

ន វត មេ លាភា ទុល្លទ្ធំ វត មេ ន វត មេ សុលទ្ធំ យស្ស មេ ភគវតា សិក្ខាបទប្បដិសំយុត្តាយ ធម្មិយា កថាយ ភិក្ខូ សន្ទស្សេន្តេ សមាទបេន្តេ សមុត្តេជេន្តេ សម្បហំសេន្តេ អហុទេវ អក្ខន្តិ អហុ អប្បច្ចយោ អជិសល្លេខតេវាយំ សមណោតិ យន្នូណាហំ យេន ភគវា តេនុបសង្កមេយ្យំ ឧបសង្កមិត្វា ភគវតោ សន្តិកេ អច្ចយំ អច្ចយតោ ទេសេយ្យន្តិ អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យស្ស មេ ភគវតា សិក្ខាបទប្បដិសំយុត្តាយ ធម្មិយា កថាយ ភិក្ខូ សន្ទស្សេន្តេ សមាទបេន្តេ សមុត្តេជេន្តេ សម្បហំសេន្តេ អហុទេវ អក្ខន្តិ អហុ អប្បច្ចយោ អជិសល្លេខតេវាយំ សមណោតិ តស្ស មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។ តគ្ឃ តំ កស្សប អច្ចយោ អច្ចគមា យថាពាលំ

របស់អាត្មាអញហើយ អាត្មាអញឈ្មោះថាឥតលាភ អាត្មាអញបានទាស់ហើយ អាត្មាអញមិនមែនបានល្អទេ ព្រោះថា ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុ ឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទហើយ អាត្មាអញមានសេចក្តីមិនអត់ទ្រាំ មិនត្រេកអរថា សមណៈនេះដូចជាដុសខាត់ជ្រុលពេក បើដូច្នោះគួរអាត្មាអញ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយត្រូវសម្តែងទោសតាមទោស ក្នុងសំណាក់ព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន ទោសបានប្រព្រឹត្តកន្លងហើយនូវខ្ញុំព្រះអង្គ ជាមនុស្សពាលយ៉ាងណា វង្វេងយ៉ាងណា មិនឈ្លាសវៃយ៉ាងណា ព្រោះថា ព្រះមានព្រះភាគ ទ្រង់ពន្យល់ពួកភិក្ខុឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទហើយ ខ្ញុំព្រះអង្គមានសេចក្តីមិនអត់ទ្រាំ មិនត្រេកអរថា សមណៈនេះ ដូចជាដុសខាត់ជ្រុលពេក បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់ទទួលអត់ទោសតាមទោស ដល់ខ្ញុំព្រះអង្គនោះ ដើម្បីសេចក្តីសង្រួមតទៅ ។ អើកស្សបៈ ទោសប្រព្រឹត្តកន្លងហើយនូវអ្នក ដែលជាមនុស្សពាលយ៉ាងណា

យថាមូឡ្ហំ យថាអកុសលំ យស្ស តេ មយា សិក្ខាបទប្បដិសំយុត្តាយ ធម្មិយា កថាយ ភិក្ខូ សន្ទស្សេន្តេ សមាទបេន្តេ សមុត្តេជេន្តេ សម្បហំសេន្តេ អហុទេវ អក្ខន្តិ អហុ អប្បច្ចយោ អធិសល្លេខតេ-វាយំ សមណោតិ យតោ ច ខោ ត្វំ កស្សប អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោសិ តន្តេ មយំ បដិគ្គណ្ហាម វុឌ្ឍិ ហេសា កស្សប អរិយស្ស វិនយេ យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតិ ។ ថេរោ ចេបិ កស្សប ភិក្ខុ ហោតិ ន សិក្ខាកាមោ សិក្ខាសមាទានស្ស ន វណ្ណវាទី យេ ចញ្ញេ ភិក្ខូ ន សិក្ខាកាមា តេ ច សិក្ខាយ ន សមាទបេតិ យេ ចញ្ញេ ភិក្ខូ សិក្ខាកាមា តេសញ្ច ន វណ្ណំ ភណតិ ភូតំ តច្ឆំ កាលេន ឯវរូបស្សាហំ កស្សប ថេរស្ស ភិក្ខុនោ ន វណ្ណំ ភណាមិ ។ តំ កិស្ស ហេតុ ។

វង្វេងយ៉ាងណា មិនឈ្លាសវៃយ៉ាងណា អ្នកមិនមានសេចក្តីអត់ទ្រាំ មិនមានសេចក្តីត្រេកអរនឹងតថាគត កាលដែលពន្យល់ពួកភិក្ខុ ឲ្យឃើញច្បាស់ ឲ្យកាន់តាម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ដ៏ប្រកបដោយសិក្ខាបទថា សមណៈនេះ ដូចជាដុសខាត់ជ្រុលពេក ម្នាលកស្សបៈ កាលបើអ្នកឃើញទោសតាមទោស ហើយត្រឡប់ធ្វើសមគួរតាមធម៌ តថាគតទទួលអត់ទោសនោះដល់អ្នក ម្នាលកស្សបៈ បុគ្គលណាឃើញទោសតាមទោស ហើយត្រឡប់ធ្វើសមគួរតាមធម៌ ដល់នូវសេចក្តីសង្រួមតទៅ នេះជាសេចក្តីចម្រើនក្នុងវិន័យ របស់អរិយៈ ។ ម្នាលកស្សបៈ បើទុកជាភិក្ខុជាថេរៈ មិនចូលចិត្តនឹងការសិក្សា មិនសរសើរគុណនៃកិរិយាសមាទាននូវការសិក្សា មិនបបួលពួកភិក្ខុដទៃ ដែលមិនចូលចិត្តនឹងការសិក្សានោះ ឲ្យសិក្សា មិនសរសើរគុណពួកភិក្ខុដទៃ ដែលចូលចិត្តនឹងការសិក្សានោះ ឲ្យពិតមែនតាមកាល ម្នាលកស្សបៈ តថាគតមិនសរសើរភិក្ខុជាថេរៈមានសភាពដូច្នេះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។

៣៤២



សត្ថា ហិស្ស វណ្ណំ ភណតីតិ អញ្ញេ នំ ភិក្ខូ ភជេយ្យុំ យេ នំ ភជេយ្យុំ ត្យស្ស ទិដ្ឋានុគតឹ អាបជ្ជេយ្យុំ យស្ស ទិដ្ឋានុគតឹ អាបជ្ជេយ្យុំ តេសន្តំ អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយាតិ តស្មាហំ កស្សប ឯវរូបស្ស ថេរស្ស ភិក្ខុនោ ន វណ្ណំ ភណាមិ ។ មជ្ឈិមោ ចេបិ កស្សប ភិក្ខុ ហោតិ ។ បេ ។ នវោ ចេបិ កស្សប ភិក្ខុ ហោតិ ន សិក្ខាកាមោ សិក្ខាសមាទានស្ស ន វណ្ណវាទី យេ ចញ្ញេ ភិក្ខូ ន សិក្ខាកាមា តេ ច សិក្ខាយ ន សមាទបេតិ យេ ចញ្ញេ ភិក្ខូ សិក្ខាកាមា តេសញ្ច ន វណ្ណំ ភណតិ ភូតំ តច្ឆំ កាលេន ឯវរូបស្សាហំ កស្សប នវស្ស ភិក្ខុនោ ន វណ្ណំ ភណាមិ ។ តំ កិស្ស ហេតុ ។ សត្ថា ហិស្ស វណ្ណំ ភណតីតិ អញ្ញេ នំ ភិក្ខូ ភជេយ្យុំ

ព្រោះក្រែងពួកភិក្ខុដទៃសេពគប់ ភិក្ខុជាថេរៈនោះ ដោយចូលចិត្តថា ព្រះជាគ្រូទ្រង់សរសើរភិក្ខុជាថេរៈនោះ ពួកភិក្ខុជាអ្នកសេពគប់នឹងភិក្ខុជាថេរៈនោះ រមែងប្រព្រឹត្តតាមទិដ្ឋិរបស់ភិក្ខុជាថេរៈនោះ អំពើនោះ ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលដ៏វែង ដល់ពួកភិក្ខុដែលប្រព្រឹត្តតាមទិដ្ឋិនោះ ម្នាលកស្សបៈ ព្រោះហេតុនោះហើយ បានជាតថាគតមិនសរសើរ ភិក្ខុជាថេរៈ មានសភាពដូច្នេះ ។ ម្នាលកស្សបៈ បើទុកជាភិក្ខុជាកណ្តាល ។ បេ ។ ម្នាលកស្សបៈ បើទុកជាភិក្ខុខ្ចី តែមិនចូលចិត្តនឹងការសិក្សា មិនសរសើរគុណ នៃកិរិយាសមាទានទូវការសិក្សា មិនបបួលពួកភិក្ខុដទៃ ដែលមិនចូលចិត្តនឹងការសិក្សានោះ ឲ្យសិក្សា មិនសរសើរគុណរបស់ពួកភិក្ខុដទៃ ដែលចូលចិត្តនឹងការសិក្សាឲ្យទៀងពិតតាមកាលគួរ ម្នាលកស្សបៈ តថាគតមិនសរសើរភិក្ខុខ្ចីបែបនោះទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថាពួកភិក្ខុដទៃសេពគប់ពួកភិក្ខុខ្ចីនោះដោយគិតថា ព្រះជាគ្រូទ្រង់សរសើរគុណភិក្ខុនោះ

៣៤៣

## ទុតិយបណ្ណាសកេ សមណវគ្គោ

យេ នំ ភជេយ្យុំ ត្យស្ស ទិដ្ឋានុគតឹ អាបជ្ជេយ្យុំ យស្ស ទិដ្ឋានុគតឹ អាបជ្ជេយ្យុំ តេសន្តំ អស្ស ទីឃរត្តំ អហិតាយ ទុក្ខាយាតិ តស្មាហំ កស្សប ឯវរូបស្ស នវស្ស ភិក្ខុនោ ន វណ្ណំ ភណាមិ ។ ថេរោ ចេបិ កស្សប ភិក្ខុ ហោតិ សិក្ខាកាមោ សិក្ខាសមាទានស្ស វណ្ណវាទី យេ ចញ្ញេ ភិក្ខូ ន សិក្ខាកាមា តេ ច សិក្ខាយ សមាទបេតិ យេ ចញ្ញេ ភិក្ខូ សិក្ខាកាមា តេសញ្ច វណ្ណំ ភណតិ ភូតំ តច្ឆំ កាលេន ឯវរូបស្សាហំ កស្សប ថេរស្ស ភិក្ខុនោ វណ្ណំ ភណាមិ ។ តំ កិស្ស ហេតុ ។ សត្ថា ហិស្ស វណ្ណំ ភណតីតិ អញ្ញេ នំ ភិក្ខូ ភជេយ្យុំ យេ នំ ភជេយ្យុំ ត្យស្ស ទិដ្ឋានុគតឹ អាបជ្ជេយ្យុំ យស្ស ទិដ្ឋានុគតឹ អាបជ្ជេយ្យុំ តេសន្តំ អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ តស្មាហំ កស្សប ឯវរូបស្ស ថេរស្ស ភិក្ខុនោ វណ្ណំ ភណាមិ ។

ពួកភិក្ខុអ្នកសេពគប់ភិក្ខុខ្ទីនោះ ប្រព្រឹត្តទៅតាមទិដ្ឋិភិក្ខុនោះ អំពើនោះប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលដ៏វែងដល់ពួកភិក្ខុដែលប្រព្រឹត្តតាមទិដ្ឋិនោះ ម្នាលកស្សបៈ ព្រោះហេតុនោះបានជាតថាគតមិនសរសើរគុណរបស់ភិក្ខុខ្ទីមានសភាពដូច្នេះទេ ។ ម្នាលកស្សបៈ បើភិក្ខុជាថេរៈ អ្នកមានប្រាថ្នានូវការសិក្សា សរសើរគុណនៃកិរិយាសមាទាននូវការសិក្សា តែងបបួលពួកភិក្ខុដទៃ ដែលមិនប្រាថ្នានូវការសិក្សានោះឲ្យសិក្សា សរសើរគុណរបស់ពួកភិក្ខុដទៃ ដែលប្រាថ្នានូវការសិក្សា ពិតមែនតាមកាល ម្នាលកស្សបៈ តថាគតសរសើរគុណភិក្ខុជាថេរៈមានសភាពដូច្នេះ ។ ហេតុនោះ តើដូចម្តេច ។ ព្រោះពួកភិក្ខុដទៃ សេពគប់នូវភិក្ខុជាថេរៈនោះដោយគិតថា ព្រះជាគ្រូទ្រង់សរសើរគុណភិក្ខុនោះ ពួកភិក្ខុនោះតែងប្រព្រឹត្តតាមទិដ្ឋិរបស់ភិក្ខុជាថេរៈដែលខ្លួនសេពគប់នោះ អំពើរបស់ពួកភិក្ខុដែលប្រព្រឹត្តតាមទិដ្ឋិរបស់ភិក្ខុជាថេរៈនោះ រមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលដ៏វែង ម្នាលកស្សបៈ ព្រោះហេតុនោះ តថាគតសរសើរគុណរបស់ភិក្ខុជាថេរៈមានសភាពដូច្នេះ ។

មជ្ឈិមោ ចេបិ កស្សប ភិក្ខុ ហោតិ ។ បេ ។ នវោ ចេបិ កស្សប ភិក្ខុ ហោតិ សិក្ខាកាមោ សិក្ខាសមាទានស្ស វណ្ណវាទី យេ ចញ្ញេ ភិក្ខូ ន សិក្ខាកាមា តេ ច សិក្ខាយ សមាទបេតិ យេ ចញ្ញេ ភិក្ខូ សិក្ខាកាមា តេសញ្ច វណ្ណំ ភណតិ ភូតំ តច្ឆំ កាលេន ឯវរូបស្សាហំ កស្សប នវស្ស ភិក្ខុនោ វណ្ណំ ភណាមិ ។ តំ កិស្ស ហេតុ ។ សត្ថា ហិស្ស វណ្ណំ ភណតីតិ អញ្ញេ នំ ភិក្ខូ ភជេយ្យុំ យេ នំ ភជេយ្យុំ ត្យស្ស ទិដ្ឋានុគតឹ អាបជ្ជេយ្យុំ យស្ស ទិដ្ឋានុគតឹ អាបជ្ជេយ្យុំ តេសន្តំ អស្ស ទីឃរត្តំ ហិតាយ សុខាយាតិ តស្មាហំ កស្សប ឯវរូបស្ស នវស្ស ភិក្ខុនោ វណ្ណំ ភណាមីតិ ។

សមណវគ្គោ ចតុត្ថោ ។

ម្នាលកស្សបៈ បើភិក្ខុជាកណ្តាល ។ បេ ។ ម្នាលកស្សបៈ បើភិក្ខុខ្ចី ជាអ្នកមានប្រាថ្នានូវការសិក្សា ជាអ្នកសរសើរគុណនៃកិរិយាសមាទាននូវការសិក្សា បបួលពួកភិក្ខុដទៃ ដែលមិនមានប្រាថ្នានូវការសិក្សានោះឲ្យសិក្សាផង សរសើរគុណរបស់ភិក្ខុដទៃ ដែលប្រាថ្នាការសិក្សាពិតមែន តាមកាលដ៏គួរផង ម្នាលកស្សបៈ តថាគតសរសើរគុណរបស់ភិក្ខុខ្ចីមានសភាពដូច្នេះ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះពួកភិក្ខុដទៃ សេពគប់នឹងភិក្ខុខ្ចីនោះដោយគិតថា ព្រះជាគ្រូទ្រង់សរសើរគុណរបស់ភិក្ខុនោះ ពួកភិក្ខុនោះ រមែងប្រព្រឹត្តតាមទិដ្ឋិរបស់ភិក្ខុដែលខ្លួនសេពគប់នោះ អំពើរបស់ពួកភិក្ខុដែលប្រព្រឹត្តតាមទិដ្ឋិរបស់ពួកភិក្ខុខ្ចីនោះរមែងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលដ៏វែង ម្នាលកស្សបៈ ព្រោះហេតុនោះ ទើបតថាគត សរសើរគុណរបស់ភិក្ខុខ្ចីមានសភាពដូច្នេះ ។

ចប់ សមណវគ្គ ទី ៤ ។

# តស្សុទ្ទានំ

សមណោ  គទ្រភោ  ខេត្តោ
វជ្ជិបុត្តោ  ច  សេខិណា
តយោ  ច  សេខិណោ  វុត្តា
ទ្វេ  សិក្ខា  បង្កធេន  ជាតិ  ។

ទុតិយបណ្ណាសក សមណវគ្គ

# ឧទ្ទាននៃសមណវគ្គនោះគឺ

*សមណកិច្ច ១ សូត្រ សត្វលា ១ សូត្រ ស្រែ ១ សូត្រ វជ្ជិបុត្តកៈ ១ សូត្រ សេក្ខបុគ្គល ១ សូត្រ ភិក្ខុបំពេញសិក្សា ៣ សូត្រ សិក្ខា ២ សូត្រ រឿងបង្កធានិគម ១ សូត្រ ។*

# លោណផលវគ្គោ

[៩៤] តីណិមានិ ភិក្ខវេ កស្សកស្ស គហបតិស្ស អច្ចាយិកានិ ករណីយានិ ។ កតមានិ តីណិ ។ ឥធ ភិក្ខវេ កស្សកោ គហបតិ សីឃសីឃំ ខេត្តំ សុកដ្ឋំ ករោតិ សុមតិកតំ[១] សីឃសីឃំ ខេត្តំ សុកដ្ឋំ ករិត្វា សុមតិកតំ សីឃសីឃំ ពីជានិ បតិដ្ឋាបេតិ សីឃសីឃំ ពីជានិ បតិដ្ឋាបេត្វា សីឃសីឃំ ឧទកំ អភិនេតិបិ អបនេតិបិ ។ ឥមានិ ខោ ភិក្ខវេ តីណិ កស្សកស្ស គហបតិស្ស អច្ចាយិកានិ ករណីយានិ ។ តស្ស ខោ តំ ភិក្ខវេ កស្សកស្ស គហបតិស្ស នត្ថិ សា ឥទ្ធិ វា អានុភាវោ វា អជ្ជេវ មេ ធញ្ញានិ ជាយន្តុ ស្វេវ គព្ភិនិយោ ហោន្តុ ឧត្តរស្វេ បចន្តូតិ អថខោ ភិក្ខវេ ហោតិ សោ សមយោ

១ ម. សុមជ្ជកតំ ។

# លោណផលវគ្គ

[៩៦] ម្នាលភិក្ខុទាំងឡាយករណីយកិច្ច ប្រព្រឹត្តទៅយ៉ាងរួសរាន់ របស់កស្សកគហបតី (គហបតីអ្នកភ្ជួររាស់) នេះ មាន ៣ យ៉ាង ។ ករណីយកិច្ច ៣ យ៉ាង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ កស្សកគហបតី ក្នុងលោកនេះ ភ្ជួររាស់ស្រែឲ្យរាប ឲ្យល្អិតល្អយ៉ាងប្រញាប់ ១ លុះភ្ជួររាស់ស្រែ រាបល្អិតល្អ យ៉ាងប្រញាប់ហើយ ក៏ព្រោះពូជយ៉ាងប្រញាប់ ១ លុះព្រោះពូជ យ៉ាងប្រញាប់ហើយ ក៏បញ្ចូលទឹកខ្លះ បញ្ចេញទឹកខ្លះយ៉ាងប្រញាប់ ១ ។ ម្នាលភិក្ខុទាំងឡាយ ករណីយកិច្ចយ៉ាងរួសរាន់ របស់កស្សកគហបតី មាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ កស្សកគហបតីនោះ មិនមានឫទ្ធិ មិនមានអានុភាព (បង្គាប់បញ្ជា) ស្រូវនោះថា សូមឲ្យស្រូវទាំងឡាយ របស់អាត្មាអញលូតលាស់ក្នុងថ្ងៃនេះ មានបង្កើមក្នុងថ្ងៃស្អែក ទុំក្នុងថ្ងៃខានស្អែកដូច្នេះបានឡើយ ម្នាលភិក្ខុទាំងឡាយ លុះតែដល់វេលា ទើបស្រូវទាំងនោះ

យំ តស្ស កាស្សកាស្ស គហបតិស្ស តានិ ធញ្ញានិ ឧតុបរិណាមីនិ ជាយន្តិបិ គព្ភិនីបិ ហោន្តិ បចន្តិបិ ។ ឯវមេវ ខោ ភិក្ខវេ តីណិមានិ ភិក្ខុស្ស អច្ចាយិកានិ ករណីយានិ ។ កតមានិ តីណិ ។ អធិសីលសិក្ខាសមាទានំ អធិចិត្តសិក្ខាសមាទានំ អធិប្បញ្ញាសិក្ខាសមាទានំ ។ ឥមានិ ខោ ភិក្ខវេ តីណិ ភិក្ខុស្ស អច្ចាយិកានិ ករណីយានិ ។ តស្ស ខោ តំ ភិក្ខវេ ភិក្ខុនោ នត្ថិ សា ឥទ្ធិ វា អានុភាវោ វា អជ្ជេវ មេ អនុបាទាយ អាសវេហិ ចិត្តំ វិមុច្ចតុ ស្វេ វា ឧត្តរស្វេ វាតិ អថខោ ភិក្ខវេ ហោតិ សោ សមយោ យំ តស្ស ភិក្ខុនោ អធិសីលម្បិ សិក្ខតោ អធិចិត្តម្បិ សិក្ខតោ អធិប្បញ្ញម្បិ សិក្ខតោ អនុបា-ទាយ អាសវេហិ ចិត្តំ វិមុច្ចតិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ តិព្វោ នោ[១] ឆន្ទោ ភវិស្សតិ អធិសីលសិក្ខាសមាទានេ តិព្វោ នោ ឆន្ទោ ភវិស្សតិ

---

១ ម. នោតិ នត្ថិ ។

របស់កស្សកគហបតីនោះផ្លាស់រដូវហើយ ក៏លូតលាស់មានបង្អើមទុំបាន ។ ម្នាលភិក្ខុទាំងឡាយ ករណីយកិច្ច ប្រព្រឹត្តទៅយ៉ាងរួសរាន់ របស់ភិក្ខុនេះ ក៏មាន ៣ យ៉ាង យ៉ាងនោះដែរ ។ ករណីយកិច្ច ៣ យ៉ាង តើដូចម្តេច ។ គឺ សមាទាននូវអធិសីលសិក្ខា ១ សមាទាននូវអធិចិត្តសិក្ខា ១ សមាទាននូវអធិប្បញ្ញាសិក្ខា ១ ។ ម្នាលភិក្ខុទាំងឡាយ ករណីយកិច្ច ប្រព្រឹត្តទៅយ៉ាងរួសរាន់ របស់ភិក្ខុ មាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុនោះមិនមានឫទ្ធិ មិនមានអានុភាព (បង្គាប់បញ្ជា) ចិត្តនោះថា សូមឲ្យចិត្តរបស់អាត្មាអញ ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ក្នុងថ្ងៃនេះឬថ្ងៃស្អែកឬក៏ថ្ងៃខានស្អែក ដូច្នេះបានឡើយ ម្នាលភិក្ខុទាំងឡាយ លុះតែដល់វេលាហើយ ទើបចិត្តរបស់ភិក្ខុនោះ ដែលសិក្សានូវអធិសីលផង សិក្សានូវអធិចិត្តផង សិក្សានូវអធិប្បញ្ញាផង ផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំបាន ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះថា ពួកយើងនឹងជាបុគ្គលមានឆន្ទៈយ៉ាងក្លៀវក្លា ក្នុងការសមាទាននូវអធិសីលសិក្ខា

អធិចិត្តសិក្ខាសមាទានេ តិព្វោ នោ ឆន្ទោ ភវិស្សតិ អធិប្បញ្ញាសិក្ខាសមាទានេតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[៩៤] តីណីមានិ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វា-ជកា បរិវេកានិ បញ្ញាបេន្តិ ។ កតមានិ តីណិ ។ ចីវរប្បវិវេកំ បិណ្ឌបាតប្បវិវេកំ សេនាសនប្បវិវេកំ[១] ។ តត្រិទំ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ចីវរប្បវិវេ-កស្មឹ បញ្ញាបេន្តិ សាណានិបិ ធារេន្តិ មសាណានិបិ ធារេន្តិ ឆវទុស្សានិបិ ធារេន្តិ បំសុកូលានិបិ ធារេន្តិ តិរីដកានិបិ ធារេន្តិ អជិនានិបិ ធារេន្តិ អជិនក្ខិបម្បិ ធារេន្តិ កុសចីរម្បិ ធារេន្តិ វាកចីរម្បិ ធារេន្តិ ផលកចីរម្បិ ធារេន្តិ កេសកម្ពលម្បិ ធារេន្តិ

---

១ ឱ. សេនាសនបវិវេកន្តិ ។

ពួកយើងនឹងជាបុគ្គលមានឆន្ទៈយ៉ាងក្លៀវក្លា ក្នុងការសមាទាននូវអធិចិត្ត-សិក្ខា ពួកយើងនឹងជាបុគ្គលមានឆន្ទៈយ៉ាងក្លៀវក្លា ក្នុងការសមាទាននូវអធិប្បញ្ញាសិក្ខាដូច្នេះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះចុះ ។

[៩៥] ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជក ជាអន្យតិរ្ថិយ រមែងបញ្ញត្តនូវសេចក្តីស្ងប់ស្ងាត់ ៣ យ៉ាងនេះ ។ សេចក្តីស្ងប់ស្ងាត់ ៣ យ៉ាង តើដូចម្តេច ។ គឺសេចក្តីស្ងប់ស្ងាត់ចាកកិលេស ដែលកើតឡើង ព្រោះអាស្រ័យចីវរ ១ សេចក្តីស្ងប់ស្ងាត់ចាកកិលេស ដែលកើតឡើង ព្រោះអាស្រ័យបិណ្ឌបាត ១ សេចក្តីស្ងប់ស្ងាត់ចាកកិលេស ដែលកើតឡើង ព្រោះអាស្រ័យសេនាសនៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ តែងបញ្ញត្តនូវហេតុនេះ ក្នុងសេចក្តីស្ងប់ស្ងាត់ ចាកកិលេសដែលកើតឡើង ព្រោះអាស្រ័យចីវរនោះ គឺទ្រទ្រង់សំពត់សម្បកធ្មៃខ្លះ ទ្រទ្រង់សំពត់ដែលត្បាញលាយគ្នាខ្លះ ទ្រទ្រង់សំពត់ដែលបកចេញអំពីសាកសពខ្លះ ទ្រទ្រង់សំពត់បំសុកូលខ្លះ ទ្រទ្រង់សំពត់ដែលធ្វើដោយសម្បកឈើខ្លះ ទ្រទ្រង់ស្បែកខ្លាឃ្មុំខ្លះ ទ្រទ្រង់ស្បែកខ្លាទាំងក្រចកខ្លះ ទ្រទ្រង់សំពត់ដែលក្រងដោយស្បូវខ្លះ ទ្រទ្រង់សំពត់ដែលក្រងដោយសម្បកក្រចៅខ្លះ ទ្រទ្រង់សំពត់ដែលក្រងដោយចម្រៀកក្តារខ្លះ ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ

វាលកម្ពលម្បិ ធារេន្តិ ឧលូកបក្ខម្បិ ធារេន្តិ ។ ឥធំ ខោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ចីវរប្បវិវេកស្មឹ បញ្ញាបេន្តិ ។ តត្រិធំ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា បិណ្ឌបាតប្បវិវេកស្មឹ បញ្ញាបេន្តិ សាកភក្ខាបិ ហោន្តិ សាមាកភក្ខាបិ ហោន្តិ និវារភក្ខាបិ ហោន្តិ ទទ្ទុលភក្ខាបិ ហោន្តិ ហដភក្ខាបិ ហោន្តិ កណភក្ខាបិ ហោន្តិ អាចាមភក្ខាបិ ហោន្តិ បិញ្ញាកភក្ខាបិ ហោន្តិ តិណភក្ខាបិ ហោន្តិ គោមយភក្ខាបិ ហោន្តិ វនមូលផលាហារា យាបេន្តិ បវត្តផលភោជី ។ ឥធំ ខោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា បិណ្ឌបាតប្បវិវេកស្មឹ បញ្ញាបេន្តិ ។ តត្រិធំ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា សេនាសនប្បវិវេកស្មឹ បញ្ញាបេន្តិ អរញ្ញំ រុក្ខមូលំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ភុសាគារំ ។

ទ្រទ្រង់សំពត់កម្ពលដែលត្បាញដោយរោមកន្ទុយសេះខ្លះ ទ្រទ្រង់សំពត់ដែលក្រងដោយស្លាបមៀមខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យ-តិរ្ថិយ តែងបញ្ញត្តនូវហេតុនេះឯង ក្នុងសេចក្តីស្ងប់ស្ងាត់ចាកកិលេសដែលកើតឡើងព្រោះអាស្រ័យចីវរ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជា-អន្យតិរ្ថិយ តែងបញ្ញត្តនូវហេតុនេះឯង ក្នុងសេចក្តីស្ងប់ស្ងាត់ចាកកិលេសដែលកើតឡើងព្រោះអាស្រ័យបិណ្ឌបាតនោះ គឺជាអ្នកមានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្កួយជាអាហារខ្លះ មានកម្ទេច (ចំណៀរ) ស្បែកជាអាហារខ្លះ មានស្វែឬសារាយជាអាហារខ្លះ មានកន្ទក់ជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមឈើនិងផ្លែឈើព្រៃជាអាហារខ្លះ បរិភោគតែផ្លែឈើដែលជ្រុះស្រាប់ចម្អែតអាត្មា ។ ម្នាលភិក្ខុទាំង-ឡាយ បរិព្វាជកជាអន្យតិរ្ថិយ តែងបញ្ញត្តនូវហេតុនេះឯងក្នុងសេចក្តីស្ងប់ស្ងាត់ចាកកិលេសដែលកើតឡើង ព្រោះអាស្រ័យបិណ្ឌបាត ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជកជាអន្យតិរ្ថិយ តែងបញ្ញត្តនូវហេតុនេះក្នុងសេចក្តីស្ងប់ស្ងាត់ចាកកិលេស ដែលកើតឡើង ព្រោះអាស្រ័យសេនាសនៈនោះ គឺ ព្រៃម្ងប់ឈើ ព្រៃស្មសាន ព្រៃធំ ទីវាល គំនរចំបើង រោងទីលាន ។

ឥទំ ខោ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា សេនាសនប្បវិវេកស្មឹ បញ្ញាបេន្តិ ។ ឥមានិ ខោ ភិក្ខវេ តីណិ អញ្ញតិត្ថិយា បរិព្វាជកា បវិវេកានិ បញ្ញាបេន្តិ ។ តីណិ ខោ បនិមានិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ ភិក្ខុនោ បវិវេកានិ ។ កតមានិ តីណិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ច ហោតិ ទុស្សីល្យញ្ចស្ស បហីនំ ហោតិ តេន ច វិវិត្តោ ហោតិ សម្មាទិដ្ឋិកោ ច ហោតិ មិច្ឆាទិដ្ឋិ ចស្ស បហីនា ហោតិ តាយ ច វិវិត្តោ ហោតិ ខីណាសវោ ច ហោតិ អាសវា ចស្ស បហីនា ហោន្តិ តេហិ ច វិវិត្តោ ហោតិ ។ យតោ ខោ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ទុស្សីល្យញ្ចស្ស បហីនំ ហោតិ តេន ច វិវិត្តោ ហោតិ សម្មាទិដ្ឋិកោ ច ហោតិ មិច្ឆាទិដ្ឋិ ចស្ស បហីនា ហោតិ តាយ ច វិវិត្តោ ហោតិ ខីណាសវោ ច ហោតិ អាសវា ចស្ស បហីនា ហោន្តិ តេហិ ច វិវិត្តោ ហោតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អគ្គប្បត្តោ សារប្បត្តោ សុទ្ធោ សារេ បតិដ្ឋិតោ ។

ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជក ជាអន្យតិរ្ថិយ តែងបញ្ញត្តនូវហេតុនេះឯង ក្នុងសេចក្តីស្ងប់ស្ងាត់ចាកកិលេស ដែលកើតឡើង ព្រោះអាស្រ័យសេនាសនៈ ។ ម្នាលភិក្ខុទាំងឡាយ ពួកបរិព្វាជក ជាអន្យតិរ្ថិយ តែងបញ្ញត្តនូវសេចក្តីស្ងប់ស្ងាត់មាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំង-ឡាយ ចំណែកសេចក្តីស្ងប់ស្ងាត់របស់ភិក្ខុ ក្នុងធម្មវិន័យនេះ ក៏មាន ៣ យ៉ាងនេះដែរ ។ សេចក្តីស្ងប់ស្ងាត់ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល លះបង់ការទ្រុស្តសីល ស្ងប់ស្ងាត់ចាកការទ្រុស្តសីល ១ ជាអ្នកឃើញត្រូវ លះបង់ការឃើញខុស ស្ងប់ស្ងាត់ចាកការឃើញខុសនោះ ១ ជាខីណាស្រព លះបង់អាសវៈ ស្ងប់ស្ងាត់ចាកអាសវៈនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុជាអ្នកមានសីល លះបង់ការទ្រុស្តសីល ស្ងប់ស្ងាត់ចាកការទ្រុស្តសីលនោះ ជាអ្នកឃើញត្រូវ លះបង់ការឃើញខុស ស្ងប់ស្ងាត់ចាកការឃើញខុសនោះ ជាខីណាស្រព លះបង់អាសវៈ ស្ងប់ស្ងាត់ចាកអាសវៈហើយ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះជាអ្នកដល់នូវការប្រសើរបំផុត ដល់នូវខ្លឹមសារ បរិសុទ្ធ តាំងនៅស៊ប់ ក្នុងធម៌មានខ្លឹម ។

៣៤១



សេយ្យថាបិ ភិក្ខវេ កស្សកស្ស គហប-
តិកស្ស សម្បន្នំ សាលិក្ខេត្តំ ។ តមេនំ
កស្សកោ គហបតិ សីឃសីឃំ វេចាបេយ្យ
សីឃសីឃំ វេចាបេត្វា សីឃសីឃំ សង្ឃរាបេយ្យ
សីឃសីឃំ សង្ឃរាបេត្វា សីឃសីឃំ ឧព្វហាបេយ្យ
សីឃសីឃំ ឧព្វហាបេត្វា សីឃសីឃំ បុញ្ជ
ការាបេយ្យ សីឃសីឃំ បុញ្ជ ការាបេត្វា សីឃសីឃំ
មទ្ទាបេយ្យ សីឃសីឃំ មទ្ទាបេត្វា សីឃសីឃំ
បលាលានិ ឧទ្ធរាបេយ្យ សីឃសីឃំ បលាលានិ
ឧទ្ធរាបេត្វា សីឃសីឃំ ភុសិកំ ឧទ្ធរាបេយ្យ
សីឃសីឃំ ភុសិកំ ឧទ្ធរាបេត្វា សីឃសីឃំ
ឱផុណាបេយ្យ សីឃសីឃំ ឱផុណាបេត្វា សីឃសីឃំ
អតិហរាបេយ្យ សីឃសីឃំ អតិហរាបេត្វា សីឃសីឃំ
កោដ្ដាបេយ្យ សីឃសីឃំ កោដ្ដាបេត្វា សីឃសីឃំ
ផុសានិ ឧទ្ធរាបេយ្យ ឯវមស្សុ តស្ស ភិក្ខវេ
កស្សកស្ស គហបតិស្ស តានិ ធញ្ញានិ អគ្គប្បត្តានិ
សារប្បត្តានិ សុទ្ធានិ សារេ បតិដ្ឋិតានិ ។

ម្នាលភិក្ខុទាំងឡាយ ដូចជាស្រែស្រូវសាលីដ៏បរិបូណ៌របស់កស្សកគហ-បតី ។ កស្សកគហបតី ត្រូវព្រោះស្រូវនោះយ៉ាងប្រញាប់ លុះព្រោះរួចយ៉ាងប្រញាប់ហើយ ត្រូវច្រូតយ៉ាងប្រញាប់ លុះច្រូតយ៉ាងប្រញាប់ហើយ ត្រូវជញ្ជូនដាក់លានយ៉ាងប្រញាប់ លុះជញ្ជូនដាក់លានយ៉ាងប្រញាប់ហើយ ត្រូវគរជាគំនរយ៉ាងប្រញាប់ លុះគរជាគំនរយ៉ាងប្រញាប់ហើយ ត្រូវបែនឬបញ្ជាន់យ៉ាងប្រញាប់ លុះបែន ឬ បញ្ជាន់យ៉ាងប្រញាប់ហើយ ត្រូវជជុះចំបើងយ៉ាងប្រញាប់ លុះជជុះចំបើងយ៉ាងប្រញាប់ហើយ ត្រូវរាស់កំទេច ឬ កំញ៉មយ៉ាងប្រញាប់ លុះរាស់កំទេច ឬ កំញ៉មយ៉ាងប្រញាប់ហើយ ត្រូវរោយយ៉ាងប្រញាប់ លុះរោយយ៉ាងប្រញាប់ហើយ ត្រូវជញ្ជូនដាក់ជង្រុក យ៉ាងប្រញាប់ លុះជញ្ជូនដាក់ជង្រុកយ៉ាងប្រញាប់ហើយ ត្រូវបុកយ៉ាងប្រញាប់ លុះបុកយ៉ាងប្រញាប់ហើយ ត្រូវអុំយកអង្កាមចេញយ៉ាងប្រញាប់ ម្នាលភិក្ខុទាំងឡាយ កាលបើយ៉ាងនេះ ស្រូវរបស់កស្សកគហបតីនោះ រមែងដល់នូវការប្រសើរបំផុតដល់នូវខ្លឹមសារ ដ៏បរិសុទ្ធ តាំងនៅស៊ប់ក្នុងខ្លឹមសារ យ៉ាងណាមិញ ។

ឯវមេវ ខោ ភិក្ខវេ ភិក្ខុ សីលវា ច ហោតិ ទុស្សីលញ្ចស្ស បហីនំ ហោតិ តេន ច រិត្តោ ហោតិ សម្មាទិដ្ឋិកោ ច ហោតិ មិច្ឆាទិដ្ឋិ ចស្ស បហីនា ហោតិ តាយ ច រិត្តោ ហោតិ ខីណាសវោ ច ហោតិ អាសវា ចស្ស បហីនា ហោន្តិ តេហិ ច រិត្តោ ហោតិ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ អគ្គប្បត្តោ សារប្បត្តោ សុទ្ធោ សារេ បតិដ្ឋិតោតិ ។

[៩៦] សេយ្យថាបិ ភិក្ខវេ សរទសមយេ វិទ្ធេ វិគតវលាហកេ ទេវេ អាទិច្ចោ នភំ អព្ភុស្សក្កមានោ សព្វំ អាកាសគតំ តមំ[១] អភិវិហច្ច ភាសតេ ច តបតេ ច វិរោចតិ ច ឯវមេវ ខោ ភិក្ខវេ យតោ អរិយសាវកស្ស វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ សហទស្សនុប្បាទា ភិក្ខវេ អរិយសាវកស្ស តីណិ សញ្ញោជនានិ បហីយន្តិ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាសោ អថាបរំ ទ្វីហិ ធម្មេហិ និយ្យាតិ[២]

---

១ ម. តមគតំ ។ ២ ម. បហិយ្យតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសីល លះបង់នូវការទ្រុស្តសីល ស្ងប់ស្ងាត់ចាកការទ្រុស្តសីលនោះផង ជាអ្នកឃើញត្រូវ លះបង់នូវការឃើញខុស ស្ងប់ស្ងាត់ចាកការឃើញខុសនោះផង ជាខីណាស្រព លះបង់អាសវៈ ស្ងប់ស្ងាត់ចាកអាសវៈនោះផង ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ភិក្ខុនេះជាអ្នកដល់នូវការប្រសើរបំផុត ដល់នូវខ្លឹមសារ បរិសុទ្ធតាំងនៅស៊ប់ ក្នុងធម៌មានខ្លឹមសារ ក៏យ៉ាងនោះដែរ ។

[៩៦] ម្នាលភិក្ខុទាំងឡាយ ដូចជាព្រះអាទិត្យស្វាងស្រឡះចាកពពក ឰដ៏អាកាស ដែលមានវលាហកៈប្រាសទៅឆ្ងាយ ក្នុងសរទសម័យ ហើយក៏កម្ចាត់បង់នូវងងឹត ដែលនៅឯអាកាសទាំងអស់ រមែងភ្លឺត្រចះត្រចែង យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលណា ធម្មចក្ខុដែលប្រាសចាកធូលី ប្រាសចាកមន្ទិល បានកើតឡើងដល់អរិយសាវ័កហើយ ម្នាលភិក្ខុទាំងឡាយ ទើបអរិយសាវ័ក លះបង់នូវសញ្ញោជនៈ ៣ ប្រការ គឺសក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាសៈ ១ ជាមួយនឹងការកើតឡើងនៃទស្សនៈ លុះកាលជាខាងក្រោយមកទៀត ក៏ចេញចាកធម៌ ២ យ៉ាង

អភិជ្ឈាយ ច ព្យាបាទេន ច ។ សោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ តស្មិំ ចេ ភិក្ខវេ សមយេ អរិយសាវកោ កាលំ ករេយ្យ នត្ថិ តំ សញ្ញោជនំ យេន សញ្ញោជនេន សំយុត្តោ អរិយសាវកោ បុនយិមំ លោកំ អាគច្ឆេយ្យាតិ ។

[៩៧] តិស្សោ ឥមា ភិក្ខវេ បរិសា ។ កតមា តិស្សោ ។ អគ្គវតី បរិសា វគ្គា បរិសា សមគ្គា បរិសា ។ កតមា ច ភិក្ខវេ អគ្គវតី បរិសា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ថេរា ភិក្ខូ ន ពាហុល្លិកា ហោន្តិ ន សាថលិកា

គឺអភិជ្ឈា ១ ព្យាបាទ ១ ។ អរិយសាវ័កនោះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារ មានបីតិនិងសុខៈកើតអំពីសេចក្ដីស្ងាត់ សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ បើអរិយសាវ័ក ធ្វើកាលកិរិយា ក្នុងសម័យនោះ អរិយសាវ័កនោះ រមែងមិនប្រកបដោយសញ្ញោជនៈ ដែលនាំឲ្យមកកាន់លោកនេះទៀតឡើយ ។

[៩៧] ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ មាន ៣ ពួក ។ បរិសទ្យ ៣ ពួក តើដូចម្ដេច ។ គឺអគ្គវតីបរិសទ្យ (បរិសទ្យមានគុណប្រសើរបំផុត) ១ វគ្គបរិសទ្យ (បរិសទ្យជាពួក) ១ សមគ្គបរិសទ្យ (បរិសទ្យមានសេចក្ដីព្រមព្រៀងគ្នា) ១ ។ ម្នាលភិក្ខុទាំងឡាយ អគ្គវតីបរិសទ្យ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ មានពួកភិក្ខុជាថេរៈ ក្នុងបរិសទ្យណា មិនល្មោភ (ក្នុងបច្ច័យ) មិនបន្ធូរបន្ថយ (ក្នុងត្រៃសិក្ខា)

ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា វីរិយំ អារភន្តិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ តេសំ បច្ឆិមា ជនតា ទិដ្ឋានុគតឹ អាបជ្ជតិ សាបិ ហោតិ ន ពាហុល្លិកា ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ។ អយំ វុច្ចតិ ភិក្ខវេ អគ្គវតី បរិសា ។ កតមា ច ភិក្ខវេ វគ្គា បរិសា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ។ អយំ វុច្ចតិ ភិក្ខវេ វគ្គា បរិសា ។ កតមា ច ភិក្ខវេ សមគ្គា បរិសា ។ ឥធ ភិក្ខវេ យស្សំ បរិសាយំ ភិក្ខូ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា

ដាក់ចុះនូវធុរៈក្នុងទីទាបគឺនីវរណៈទាំង ៥ មានការស្ទុះទៅក្នុងសេចក្ដីស្ងប់ស្ងាត់ជាប្រធាន ប្រារព្ធព្យាយាមដើម្បីដល់នូវធម៌ ដែលមិនទាន់ដល់ ដើម្បីបាននូវធម៌ដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ ពួកជនជាខាងក្រោយ រមែងដល់នូវទិដ្ឋានុគតិនៃភិក្ខុជាថេរៈទាំងនោះ ឯពួកបរិសទ្យនោះក៏មិនបានល្មោភក្នុងបច្ច័យ មិនបានបន្ធូរបន្ថយក្នុងត្រៃសិក្ខា ដាក់ចុះនូវធុរៈក្នុងទីទាប មានការស្ទុះទៅក្នុងសេចក្ដីស្ងប់ជាប្រធាន ប្រារព្ធព្យាយាមដើម្បីដល់នូវធម៌ដែលមិនទាន់ដល់ ដើម្បីបាននូវធម៌ដែលមិនទាន់បាន ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលមិនទាន់ធ្វើឲ្យជាក់ច្បាស់ដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា អគ្គវតីបរិសទ្យ ។ ម្នាលភិក្ខុទាំងឡាយ វគ្គបរិសទ្យ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ពួកភិក្ខុក្នុងបរិសទ្យណា ជាអ្នកបង្កហេតុបង្កជម្លោះ ទាស់ទែងគ្នា ចាក់ដោតគ្នាទៅវិញទៅមក ដោយលំពែងគឺមាត់ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា វគ្គបរិសទ្យ ។ ម្នាលភិក្ខុទាំងឡាយ សមគ្គបរិសទ្យ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ពួកភិក្ខុក្នុងបរិសទ្យណា ព្រមព្រៀងគ្នារីករាយរកគ្នា មិនវិវាទគ្នា មានសភាពដូចជាទឹកដោះ លាយដោយទឹក

អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរន្តិ ។ អយំ វុច្ចតិ ភិក្ខវេ សមគ្គា បរិសា ។ យស្មឹ ភិក្ខវេ សមយេ ភិក្ខូ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរន្តិ ពហុំ ភិក្ខវេ ភិក្ខូ តស្មឹ សមយេ បុញ្ញំ បសវន្តិ ព្រហ្មំ ភិក្ខវេ វិហារំ តស្មឹ សមយេ ភិក្ខូ វិហរន្តិ យទិទំ មុទិតាយ ចេតោវិ-មុត្តិយា បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទិយតិ សុខិនោ ចិត្តំ សមាធិយតិ ។ សេយ្យថាបិ ភិក្ខវេ ឧបរិបព្វតេ ថុល្លផុសិតកេ ទេវេ វស្សន្តេ តំ ឧទកំ យថានិន្នំ វត្តមានំ បព្វតកន្ទរបទរសាខា បរិបូរេតិ បព្វតកន្ទរបទរសាខា បរិបូរា កុសោព្ភេ បរិបូរេន្តិ កុសោព្ភា បរិបូរា មហាសោព្ភេ បរិបូរេន្តិ មហាសោព្ភា បរិបូរា កុន្នទិយោ បរិបូរេន្តិ កុន្នទិយោ បរិបូរា មហានទិយោ បរិបូរេន្តិ មហានទិយោ បរិបូរា សមុទ្ទំ បរិបូរេន្តិ ឯវមេវ ខោ ភិក្ខវេ យស្មឹ សមយេ

មើលគ្នាទៅវិញទៅមក ដោយចក្ខុជាទីស្រឡាញ់ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងហៅថា សមគ្គបរិសទ្យ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងវេលាណា ពួកភិក្ខុមានសេចក្ដីព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានសភាពដូចទឹកដោះ លាយដោយទឹក មើលគ្នាទៅវិញទៅមក ដោយចក្ខុជាទីស្រឡាញ់ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ រមែងបានបុណ្យដ៏ច្រើន ក្នុងវេលានោះ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ រមែងនៅដោយព្រហ្មវិហារធម៌ក្នុងវេលានោះ កាលបើភិក្ខុ មានចិត្តរីករាយ ដោយមុទិតាចេតោវិមុត្តិហើយ បីតិក៏កើតឡើង កាលបើភិក្ខុមានចិត្តប្រកបដោយបីតិ កាយក៏ស្ងប់រម្ងាប់ លុះភិក្ខុមានកាយស្ងប់រម្ងាប់ហើយ ក៏ទទួលនូវសេចក្ដីសុខ កាលបើភិក្ខុបានទទួលនូវសុខហើយ ទើបចិត្តតាំងមាំក្នុងអារម្មណ៍បាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាភ្លៀងដែលមានគ្រាប់ដ៏ធំៗ បង្អុរចុះមកលើភ្នំ ទឹកភ្លៀងនោះ រមែងហូរទៅកាន់ទំនាប បំពេញជ្រោះភ្នំអូរនិងប្រឡាយ លុះជ្រោះភ្នំអូរនិងប្រឡាយពេញហើយ ក៏បំពេញបឹងតូចៗ លុះបឹងតូចៗ ពេញហើយ ក៏បំពេញបឹងធំៗ លុះបឹងធំៗ ពេញហើយ ក៏បំពេញស្ទឹងតូចៗ លុះស្ទឹងតូចៗ ពេញហើយ ក៏បំពេញស្ទឹងធំៗ លុះស្ទឹងធំៗ ពេញហើយ ក៏បំពេញសមុទ្រ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ក្នុងវេលាណា

ភិក្ខូ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរន្តិ ពហុំ ភិក្ខវេ ភិក្ខូ តស្មឹ សមយេ បុញ្ញំ បសវន្តិ ព្រហ្មំ ភិក្ខវេ វិហារំ តស្មឹ សមយេ ភិក្ខូ វិហរន្តិ យទិទំ មុទិតាយ ចេតោវិមុត្តិយា បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ វេទិយតិ សុខិនោ ចិត្តំ សមាធិយតិ ។ ឥមា ខោ ភិក្ខវេ តិស្សោ បរិសាតិ ។

[៩៨] តីហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខ្យំ គច្ឆតិ ។ កាត-មេហិ តីហិ ។ ឥធ ភិក្ខវេ រញ្ញោ ភទ្រោ អស្សា-ជានីយោ វណ្ណសម្បន្នោ ច ហោតិ ពលសម្បន្នោ ច ជវសម្បន្នោ ច ។ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខ្យំ គច្ឆតិ ។

ពួកភិក្ខុមានសេចក្តីព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា មានសភាពដូចជាទឹកដោះ លាយដោយទឹក មើលគ្នាទៅវិញទៅមក ដោយចក្ខុជាទីស្រឡាញ់ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុ រមែងបាននូវបុណ្យដ៏ច្រើនក្នុងវេលានោះ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុរមែងនៅដោយព្រហ្មវិហារធម៌ក្នុងវេលានោះ កាលបើភិក្ខុមានចិត្តរីករាយ ដោយមុទិតាចេតោវិមុត្តិហើយ បីតិ ក៏កើតឡើង កាលបើភិក្ខុមានចិត្តប្រកបដោយបីតិហើយ កាយក៏ស្ងប់រម្ងាប់ លុះភិក្ខុមានកាយស្ងប់រម្ងាប់ហើយ ក៏ទទួលនូវសុខ កាលបើភិក្ខុបានទទួលសុខហើយ ចិត្តក៏តាំងមាំបាន ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ បរិសទ្យមាន ៣ ពួកនេះឯង ។

[៩៨] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អ របស់ព្រះរាជាដែលប្រកបដោយអង្គ ៣ ជាសេះគួរដល់ព្រះរាជា ជាសេះព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ប្រកបដោយអង្គ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អ របស់ព្រះរាជាក្នុងលោកនេះ ជាសេះបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយសន្ទុះ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អ របស់ព្រះរាជាដែលប្រកបដោយអង្គ ៣ នេះឯង ជាសេះគួរដល់ព្រះរាជា ជាសេះព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។

៣៩៧



ឯវមេវ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នា-
គតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ
ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ
លោកស្ស ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ
ភិក្ខុ វណ្ណសម្បន្នោ ច ហោតិ ពលសម្បន្នោ ច
ជវសម្បន្នោ ច ។ កថញ្ច ភិក្ខវេ ភិក្ខុ វណ្ណ-
សម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា
ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោ-
ចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី
សមាទាយ សិក្ខតិ សិក្ខាបទេសុ ឯវំ ខោ ភិក្ខវេ
ភិក្ខុ វណ្ណសម្បន្នោ ហោតិ ។ កថញ្ច ភិក្ខវេ
ភិក្ខុ ពលសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៣ យ៉ាង ជាអ្នកគួរទទួលនូវរបស់ដែលគេនាំមកបូជា គួរទទួលនូវរបស់ដែលគេបម្រុងទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ក៏យ៉ាងនោះដែរ ។ ប្រកបដោយធម៌ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយសន្ទុះ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុដែលបរិបូណ៌ដោយសម្បុរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីលសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញនូវភ័យ ក្នុងទោសសូម្បីយ៉ាងតូច សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសម្បុរ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនា

អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហ-បរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ឯវំ ខោ ភិក្ខវេ ភិក្ខុ ពលសម្បន្នោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ជវសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខ-និរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធ-គាមិនី បដិបទាតិ យថាភូតំ បជានាតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ជវសម្បន្នោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុ-នេយ្យោ ហោតិ ចាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

នេះ ជាអ្នកប្រារព្ធព្យាយាម ដើម្បីលះពួកធម៌ជាអកុសល ដើម្បីញ៉ាំងពួកធម៌ជាកុសលឲ្យបរិបូណ៌ ជាអ្នកមានកម្លាំង មានសេចក្តីសង្វាតយ៉ាងមាំ មិនដាក់ចុះ នូវធុរៈក្នុងកុសលធម៌ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសន្ទុះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាទីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់ទីរលត់ទុក្ខ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសន្ទុះយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ទើបជាអ្នកគួរទទួលនូវរបស់ដែលគេនាំមកបូជា គួរទទួលនូវរបស់ ដែលគេបម្រុងទទួលភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុត របស់សត្វលោក ។

[៩៩] តីហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្ទោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខ្យំ គច្ឆតិ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ រញ្ញោ ភទ្ទោ អស្សាជានីយោ វណ្ណសម្បន្នោ ច ហោតិ ពលសម្បន្នោ ច ជវសម្បន្នោ ច ។ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតោ រញ្ញោ ភទ្ទោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខ្យំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ ភិក្ខុ វណ្ណសម្បន្នោ ច ហោតិ ពលសម្បន្នោ ច ជវសម្បន្នោ ច ។ កថញ្ច ភិក្ខវេ ភិក្ខុ វណ្ណសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ

[៩៩] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អ របស់ព្រះរាជា ដែលប្រកបដោយអង្គ ៣ ជាសេះគួរដល់ព្រះរាជា ជាសេះព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គនៃព្រះរាជា ។ ប្រកបដោយអង្គ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អរបស់ព្រះរាជាក្នុងលោកនេះ ជាសេះបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយសន្ទុះ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អរបស់ព្រះរាជាដែលប្រកបដោយអង្គ ៣ យ៉ាងនេះឯង ទើបជាសេះគួរដល់ព្រះរាជា ជាសេះព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គនៃព្រះរាជា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៣ យ៉ាងជាអ្នកគួរទទួលនូវរបស់ដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ក៏យ៉ាងនោះដែរ ។ ប្រកបដោយធម៌ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយសន្ទុះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសម្បុរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។បេ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ

ឯវំ ខោ ភិក្ខវេ ភិក្ខុ វណ្ណសម្បន្នោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ពលសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អារទ្ធវីរិយោ វិហរតិ ។ បេ ។ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ ឯវំ ខោ ភិក្ខវេ ភិក្ខុ ពលសម្បន្នោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ជវសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថបរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ឯវំ ខោ ភិក្ខវេ ភិក្ខុ ជវសម្បន្នោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[១០០] តីហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខ្យំ គច្ឆតិ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ រញ្ញោ ភទ្រោ អស្សាជានីយោ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយសម្បុរយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំង តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រារព្ធព្យាយាម ។ បេ ។ មិនដាក់ធុរៈ ក្នុងកុសលធម៌ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបរិបូណ៌ដោយកម្លាំងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូណ៌ដោយសន្ទុះ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានជាឧបបាតិកៈ (ក្នុងសុទ្ធាវាស) ព្រោះអស់សញ្ញោជនៈ ៥ ជាចំណែកខាងក្រោម ហើយ បរិនិព្វានក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់ចាកលោកនោះវិញឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយសន្ទុះយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ទើបជាអ្នកគួរទទួលនូវរបស់ដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ។

[១០០] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អ របស់ព្រះរាជាដែលប្រកបដោយអង្គ ៣ ជាសេះគួរដល់ព្រះរាជា ជាសេះព្រះរាជទ្រព្យដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ប្រកបដោយអង្គ ៣ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អ របស់ព្រះរាជាក្នុងលោកនេះ

វណ្ណសម្បន្នោ ច ហោតិ ពលសម្បន្នោ ច ជវសម្បន្នោ ច ។ ឥមេហិ ខោ ភិក្ខវេ តីហង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានីយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ ភិក្ខុ វណ្ណសម្បន្នោ ច ហោតិ ពលសម្បន្នោ ច ជវសម្បន្នោ ច ។ កថញ្ច ភិក្ខវេ ភិក្ខុ វណ្ណសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ឯវំ ខោ ភិក្ខវេ ភិក្ខុ វណ្ណសម្បន្នោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ពលសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អារទ្ធវីរិយោ វិហរតិ ។ បេ ។ អនិក្ខិត្តធុរោ

ជាសេះបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយសន្ទុះ ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អ របស់ព្រះរាជា ដែលប្រកបដោយអង្គ ៣ នេះឯង ទើបជាសេះគួរដល់ព្រះរាជា ជាសេះព្រះរាជទ្រព្យ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៣ យ៉ាង ជាអ្នកគួរទទួលនូវរបស់ដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វ-លោកក៏យ៉ាងនោះដែរ ។ ប្រកបដោយធម៌ ៣ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបរិបូណ៌ដោយសម្បុរ ១ បរិបូណ៌ដោយកម្លាំង ១ បរិបូណ៌ដោយសន្ទុះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូណ៌ដោយសម្បុរ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបរិបូណ៌ដោយសម្បុរ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូណ៌ដោយកម្លាំង តើដូចម្តេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រារព្ធព្យាយាម ។បេ។ មិនដាក់ធុរៈ

កុសលេសុ ធម្មេសុ ឯវំ ខោ ភិក្ខវេ ភិក្ខុ ពល-សម្បន្នោ ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ ជវ-សម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឯវំ ខោ ភិក្ខវេ ភិក្ខុ ជវសម្បន្នោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[១០១] ឥធាបិ ភិក្ខវេ ចោត្តកោ ទុព្វណ្ណោ ច ហោតិ ទុក្ខសម្ផស្សោ ច អប្បគ្ឃោ ច មជ្ឈិមោបិ ភិក្ខវេ ចោត្តកោ ទុព្វណ្ណោ ច ហោតិ ទុក្ខសម្ផស្សោ ច អប្បគ្ឃោ ច ជិណ្ណោបិ ភិក្ខវេ ចោត្តកោ ទុព្វណ្ណោ ច ហោតិ ទុក្ខសម្ផស្សោ ច

ក្នុងកុសលធម៌ទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបរិបូណ៌ដោយកម្លាំងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូណ៌ដោយសន្ទុះតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ខ្លួនឯងក្នុងបច្ចុប្បន្ន សម្រេចសម្រាន្តនៅ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលបរិបូណ៌ដោយសន្ទុះយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលប្រកបដោយធម៌ ៣ យ៉ាងនេះឯង ជាអ្នកគួរទទួលនូវរបស់ដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើរបំផុតរបស់សត្វលោក ។

[១០១] ម្នាលភិក្ខុទាំងឡាយ សំពត់ដែលត្បាញដោយសម្បកឈើ ទោះបីថ្មី មានពណ៌អាក្រក់ មានសម្ផស្សអាក្រក់ ទាំងមានតម្លៃក៏តិច ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើ ទោះបីជំនំ មានពណ៌អាក្រក់ មានសម្ផស្សអាក្រក់ ទាំងមានតម្លៃក៏តិច ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើ ទោះបីចាស់ មានពណ៌អាក្រក់ មានសម្ផស្សអាក្រក់

អប្បគ្ឃោ ច ។ ជិណ្ណម្បិ ភិក្ខវេ ចោឡកំ ឧក្ខ-លិបរិមជ្ជនំ[១] វា ករោន្តិ សង្ការកូដេ វា នំ ឆឌ្ឌេន្តិ ។ ឯវមេវ ខោ ភិក្ខវេ នវោ ចេបិ ភិក្ខុ ហោតិ ទុស្សីលោ បាបធម្មោ ឥទមស្ស ទុព្វណ្ណតាយ វទាមិ សេយ្យថាបិ សោ ភិក្ខវេ ចោឡកោ ទុព្វណ្ណោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ យេ ខោ បនស្ស សេវន្តិ ភជន្តិ បយិរុបាសន្តិ ទិដ្ឋា-នុគតឹ អាបជ្ជន្តិ តេសន្តំ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ ឥទមស្ស ទុក្ខសម្ផស្សតាយ វទាមិ សេយ្យ-ថាបិ សោ ភិក្ខវេ ចោឡកោ ទុក្ខសម្ផស្សោ តថូប-មាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ យេសំ ខោ បន បដិគ្គណ្ហាតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយ-ភេសជ្ជបរិក្ខារំ តេសន្តំ ន មហប្ផលំ ហោតិ ន មហានិសំសំ ឥទមស្ស អប្បគ្ឃតាយ វទាមិ

---

១ ម. ឧក្ខលិ បរិមជ្ជនំ ។

ទាំងមានតម្លៃក៏តិច ។ ម្នាលភិក្ខុទាំងឡាយ ពួកជនរមែងធ្វើនូវសំពត់សម្បកឈើដ៏ចាស់នោះ ឲ្យជាសំពត់សម្រាប់ជូតឆ្នាំង ឬចោលលើគំនរសម្រាម ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុខ្ចីវស្សា ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ក៏យ៉ាងនោះដែរ បានជាតថាគតពោលយ៉ាងនេះ ព្រោះភិក្ខុនោះ មានសម្បុរគឺគុណអាក្រក់ ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើនោះ មានពណ៌អាក្រក់យ៉ាងណា តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បើពួកជនណា សេពគប់ចូលទៅអង្គុយជិត ក៏ដល់នូវទិដ្ឋានុគតិ គឺយកបុគ្គលនោះជាបែបយ៉ាង ការសេពគប់ជាដើមនោះ របស់ជនទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលជាយូរអង្វែង បានជា តថាគតពោលយ៉ាងនេះ ព្រោះភិក្ខុនោះមានសម្ផស្សអាក្រក់ ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើមានសម្ផស្សអាក្រក់យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បើបុគ្គលនោះទទួលចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ចយភេសជ្ជបរិក្ខាររបស់ពួកជនណា ការទទួលនោះ មិនមានផលច្រើន មិនមានអានិសង្សច្រើន ដល់ពួកជននោះឡើយ បានជា តថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះមានតម្លៃតិច

សេយ្យថាបិ សោ ភិក្ខវេ បោត្ថកោ អប្បគ្ឃោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ មជ្ឈិមោ ចេបិ ភិក្ខវេ ភិក្ខុ ហោតិ ។ បេ ។ ថេរោ ចេបិ ភិក្ខវេ ភិក្ខុ ហោតិ ទុស្សីលោ បាបធម្មោ ឥទមស្ស ទុព្វណ្ណតាយ វទាមិ សេយ្យថាបិ សោ ភិក្ខវេ បោត្ថកោ ទុព្វណ្ណោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ យេ ខោ បនស្ស សេវន្តិ ភជន្តិ បយិរុបាសន្តិ ទិដ្ឋានុគតឹ អាបជ្ជន្តិ តេសន្តំ ហោតិ ទីឃរត្តំ អហិតាយ ទុក្ខាយ ឥទមស្ស ទុក្ខ-សម្ផស្សតាយ វទាមិ សេយ្យថាបិ សោ ភិក្ខវេ បោត្ថកោ ទុក្ខសម្ផស្សោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ យេសំ ខោ បន បដិគ្គ-ណ្ហាតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារំ តេសន្តំ ន មហប្ផលំ ហោតិ ន មហានិសំសំ

ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើនោះ មានតម្លៃតិចយ៉ាងណា តថាគតពោលនូវបុគ្គលនោះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុជាកណ្តាល ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ទោះបីភិក្ខុជាថេរៈ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក (ក៏យ៉ាងនោះដែរ) បានជាតថាគត ពោលយ៉ាងនេះ ព្រោះភិក្ខុនោះមានសម្បុរគឺគុណអាក្រក់ ម្នាលភិក្ខុទាំង-ឡាយ សំពត់សម្បកឈើនោះ មានពណ៌អាក្រក់យ៉ាងណា ម្នាលភិក្ខុទាំង-ឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បើពួកជនណា សេពគប់ចូលទៅអង្គុយជិត ដល់នូវទិដ្ឋានុគតិ គឺយកបុគ្គលនោះជាបែប យ៉ាងការសេពគប់ជាដើមនោះ របស់បុគ្គលទាំងនោះ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខអស់កាលជាយូរអង្វែង បានជា តថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះមានសម្ផស្សអាក្រក់ ម្នាលភិក្ខុ ទាំងឡាយ សំពត់សម្បកឈើនោះ មានសម្ផស្សអាក្រក់ យ៉ាងណាមិញ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បើបុគ្គលនោះ ទទួល ចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខាររបស់ពួក ជនណា ការទទួលនោះ មិនមានផលច្រើន មិនមានអានិសង្សច្រើន

ឥធមស្ស អប្បត្តាយ វទាមិ សេយ្យថាបិ សោ ភិក្ខវេ ចោត្តកោ អប្បត្តោ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឯវរូបោ ចាយំ ភិក្ខវេ ថេរោ ភិក្ខុ សង្ឃមជ្ឈេ ភណាតិ តមេនំ ភិក្ខូ ឯវមាហំសុ កឹ នុ ខោ តុយ្ហំ ពាលស្ស អព្យត្តស្ស ភណិតេន ត្វំបិ នាម ភណិតព្វំ មញ្ញសីតិ ។ សោ កុបិតោ អនត្តមនោ តថារូបឹ វាចំ និច្ឆារេតិ យថារូបាយ វាចាយ សង្ឃោ[1] ឧក្ខិបតិ សង្ការកូដេវ នំ ចោត្តកំ ។ នវម្បិ ភិក្ខវេ កាសិកំ វត្ថំ វណ្ណវន្តញ្ចេវ ហោតិ សុខសម្ផស្សញ្ច មហគ្ឃញ្ច មជ្ឈិមម្បិ ភិក្ខវេ កាសិកំ វត្ថំ វណ្ណវន្តញ្ចេវ ហោតិ សុខសម្ផស្សញ្ច មហគ្ឃញ្ច ជិណ្ណម្បិ ភិក្ខវេ កាសិកំ វត្ថំ វណ្ណវន្តញ្ចេវ ហោតិ សុខសម្ផស្សញ្ច មហគ្ឃញ្ច ។ ជិណ្ណម្បិ ភិក្ខវេ កាសិកំ វត្ថំ រតនបលិវេឋនំ វា ករោន្តិ គន្ធករណ្ឌកេ វា នំ និក្ខិបន្តិ ។

១ ឱ. សង្ឃោ តំ ។

ដល់ពួកជននោះឡើយ បានជាតថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះ មានតម្លៃតិច ម្នាលភិក្ខុទាំងឡាយ សំពត់សម្បកឈើនោះ មានតម្លៃតិច យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាង នោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុជាថេរៈនេះ មានសភាពយ៉ាងនេះ ពោលក្នុងកណ្តាលជំនុំសង្ឃ ពួកភិក្ខុបាននិយាយទៅនឹងភិក្ខុជាថេរៈនោះ យ៉ាងនេះថា ប្រយោជន៍អ្វី ដោយពាក្យដែលលោកជាភិក្ខុល្ងង់មិនឈ្លាស និយាយហើយ ទាំងខ្លួនលោកក៏ចេះបានត្រឹមតែពាក្យដែលខ្លួនត្រូវនិយាយ (ប៉ុណ្ណោះទេ) ។ ភិក្ខុជាថេរៈនោះ ក៏ក្រោធខឹង អាក់អន់ចិត្ត សង្ឃបោះបង់ ខ្លួនចោលដោយវាចាយ៉ាងណា ក៏បញ្ចេញវាចាយ៉ាងនោះ ដូចគេចោល សំពត់សម្បកឈើនោះលើគំនរសម្រាម ។ ម្នាលភិក្ខុទាំងឡាយ សំពត់ កាសិក ទោះថ្មីមានពណ៌ល្អ មានសម្ផស្សក៏ស្រួល ទាំងមានតម្លៃក៏ច្រើន ម្នាលភិក្ខុទាំងឡាយ សំពត់កាសិក ទោះជំនំ មានពណ៌ល្អមានសម្ផស្សក៏ ស្រួល ទាំងមានតម្លៃក៏ច្រើន ម្នាលភិក្ខុទាំងឡាយ សំពត់កាសិក ទោះចាស់ មានពណ៌ល្អ មានសម្ផស្សក៏ស្រួល ទាំងមានតម្លៃក៏ច្រើន ។ ម្នាលភិក្ខុ ទាំងឡាយ សំពត់កាសិក បើទុកជាចាស់ ក៏ពួកជនរមែងធ្វើនូវសំពត់នោះ ឲ្យជាសំពត់សម្រាប់រុំកែវ ឬដាក់ចុះក្នុងខ្លួចសម្រាប់ដាក់គ្រឿងក្រអូបដែរ ។

ឯវមេវ ខោ ភិក្ខវេ ឥធេ ចេបិ ភិក្ខុ ហោតិ សីលវា កល្យាណធម្មោ ឥធមស្ស សុវណ្ណតាយ វទាមិ សេយ្យថាបិ តំ ភិក្ខវេ កាសិកំ វត្ថំ វណ្ណវន្តំ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ យេ ខោ បនស្ស សេវន្តិ ភជន្តិ បយិរុបាសន្តិ ទិដ្ឋានុគតឹ អាបជ្ជន្តិ តេសន្តំ ហោតិ ទីឃរត្តំ ហិតាយ សុខាយ ឥទមស្ស សុខសម្ផស្សតាយ វទាមិ សេយ្យថាបិ តំ ភិក្ខវេ កាសិកំ វត្ថំ សុខសម្ផស្សំ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ យេសំ ខោ បន បដិគ្គណ្ហាតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយ-ភេសជ្ជបរិក្ខារំ តេសន្តំ មហប្ផលំ ហោតិ មហា-និសំសំ ឥទមស្ស មហគ្ឃតាយ វទាមិ សេយ្យថាបិ តំ ភិក្ខវេ កាសិកំ វត្ថំ មហគ្ឃំ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ មជ្ឈិមោ ចេបិ ភិក្ខវេ ភិក្ខុ ហោតិ ។ បេ ។ ថេរោ ចេបិ ភិក្ខវេ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុខ្ចីវស្សា បើជាអ្នកមានសីល មានធម៌ដ៏ល្អ ក៏យ៉ាងនោះដែរ បានជាតថាគតពោលយ៉ាងនេះ ព្រោះភិក្ខុនោះ មានសម្បុរគឺគុណដ៏ល្អ ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានពណ៌ល្អយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ បើជនពួកណា សេពគប់ចូលទៅអង្គុយជិត ដល់នូវទិដ្ឋានុគតិ គឺយកបុគ្គលនោះជាបែបយ៉ាង ការសេពគប់ជាដើមនោះ របស់បុគ្គលនោះ រមែងប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលជាយូរអង្វែង បានជាតថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះមានសម្ផស្សស្រួល ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានសម្ផស្សស្រួលយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះក៏យ៉ាងនោះដែរ ។ ប្រសិនបើបុគ្គលនោះ ទទួលចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខាររបស់ជនពួកណា ការទទួលនោះ រមែងមានផលច្រើន មានអានិសង្សច្រើនដល់ពួកជនទាំងនោះ បានជាតថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះមានតម្លៃច្រើន ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានតម្លៃច្រើនយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ទោះភិក្ខុជាកណ្តាល ។បេ។ ម្នាលភិក្ខុទាំងឡាយ ទោះភិក្ខុជាថេរៈ

៣៦៧



ភិក្ខុ ហោតិ សីលវា កល្យាណធម្មោ ឥទមស្ស សុវណ្ណតាយ វទាមិ សេយ្យថាបិ តំ ភិក្ខវេ កាសិកំ វត្ថំ វណ្ណវន្តំ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ យេ ខោ បនស្ស សេវន្តិ ភជន្តិ បយិរុបាសន្តិ ទិដ្ឋានុគតឹ អាបជ្ជន្តិ តេសន្តំ ហោតិ ទីឃរត្តំ ហិតាយ សុខាយ ឥទមស្ស សុខសម្ផស្សតាយ វទាមិ សេយ្យថាបិ តំ ភិក្ខវេ កាសិកំ វត្ថំ សុខសម្ផស្សំ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ យេសំ ខោ បន បដិគ្គណ្ហាតិ ចីវរបិណ្ឌបាតសេនាសន-គិលានប្បច្ចយភេសជ្ជបរិក្ខារំ តេសន្តំ មហប្ផលំ ហោតិ មហានិសំសំ ឥទមស្ស មហគ្ឃតាយ វទាមិ សេយ្យថាបិ តំ ភិក្ខវេ កាសិកំ វត្ថំ មហគ្ឃំ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ។ ឯវរូបោ ចាយំ ភិក្ខវេ ថេរោ ភិក្ខុ សង្ឃមជ្ឈេ ភណតិ

ជាអ្នកមានសីល មានកល្យាណធម៌ (ក៏យ៉ាងនោះដែរ) បានជាតថាគត ពោលយ៉ាងនេះ ព្រោះភិក្ខុនោះមានសម្បុរគឺគុណដ៏ល្អ ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានពណ៌ល្អយ៉ាងណាមិញ តថាគតពោលនូវបុគ្គល នេះ ក៏យ៉ាងនោះដែរ ។ បើជនពួកណា សេពគប់ចូលទៅអង្គុយជិត ដល់នូវទិដ្ឋានុគតិ គឺយកបុគ្គលនោះជាបែបយ៉ាង ការសេពគប់ជាដើមនោះ របស់បុគ្គលនោះ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាយូរអង្វែង បានជា តថាគតពោលយ៉ាងនេះ ព្រោះបុគ្គលនោះ មានសម្ផស្សស្រួល ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានសម្ផស្ស ស្រួលយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ ប្រសិនបើបុគ្គលនោះទទួលចីវរ បិណ្ឌបាត សេនាសនៈ និងគិលានប្បច្ច័យភេសជ្ជបរិក្ខាររបស់ពួកជនណា ការទទួលនោះ រមែង មានផលច្រើន មានអានិសង្សច្រើន ដល់ពួកជននោះ បានជាតថាគត ពោលយ៉ាងនេះ ព្រោះបុគ្គលនោះមានតម្លៃច្រើន ម្នាលភិក្ខុទាំងឡាយ សំពត់កាសិកនោះ មានតម្លៃច្រើន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវបុគ្គលនេះ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បើ ភិក្ខុជាថេរៈនេះ មានសភាពយ៉ាងនេះ ពោលក្នុងកណ្តាលជំនុំសង្ឃ

តមេនំ ភិក្ខូ ឯវមាហំសុ អប្បសន្នា អាយស្មន្តោ ហោថ ថេរោ ភិក្ខុ ធម្មញ្ច វិនយញ្ច ភណាតីតិ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ កាសិកវត្ថុបមា ភវិស្សាម ន ចោឡកូបមាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[១០២] យោ ខោ ភិក្ខវេ ឯវំ វទេយ្យ យថា យថាយំ បុរិសោ កម្មំ ករោតិ តថា តថា តំ បដិសំវេទិយតីតិ ឯវំ សន្តំ ភិក្ខវេ ព្រហ្មចរិយ-វាសោ ន ហោតិ ឱកាសោ ន បញ្ញាយតិ សម្មាទុក្ខស្ស អន្តកិរិយាយ ។ យោ ច ខោ ភិក្ខវេ ឯវំ វទេយ្យ យថា យថា វេទនីយំ អយំ បុរិសោ កម្មំ ករោតិ តថា តថាស្ស វិបាកំ បដិសំវេទិយតីតិ ឯវំ សន្តំ ភិក្ខវេ ព្រហ្ម-ចរិយវាសោ ហោតិ ឱកាសោ បញ្ញាយតិ សម្មា-ទុក្ខស្ស អន្តកិរិយាយ ។ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស អប្បមត្តកម្បិ បាបកម្មំ កតំ តមេនំ

ពួកភិក្ខុបាននិយាយគ្នាចំពោះព្រះថេរៈនោះយ៉ាងនេះថា សូមលោកដ៏មានអាយុទាំងឡាយ កុំមាត់ខ្លាំង ភិក្ខុជាថេរៈ កំពុងសម្តែងធម៌និងវិន័យ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះថា ពួកយើងឧបមាដូចជាកាសិកពស្ត្រ មិនមែនឧបមាដូចជាសំពត់សម្បកឈើទេ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះឯង ។

[១០២] ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណា និយាយយ៉ាងនេះថា បុរសនេះធ្វើអំពើយ៉ាងណាៗ រមែងទទួលនូវផលនៃអំពើយ៉ាងនោះៗ ម្នាលភិក្ខុទាំងឡាយ កាលបើហេតុយ៉ាងនេះ មានហើយ ការនៅប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនមានឱកាស ដើម្បីធ្វើឲ្យផុតទុក្ខដោយប្រពៃក៏មិនប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណា និយាយយ៉ាងនេះថា បុរសនេះធ្វើអំពើដែលគួរទទួលផលយ៉ាងណាៗ រមែងទទួលនូវផល នៃអំពើនោះយ៉ាងនោះៗ ម្នាលភិក្ខុទាំងឡាយ កាលបើហេតុយ៉ាងនេះមាន ការនៅប្រព្រឹត្តព្រហ្មចរិយៈក៏មាន ឱកាសដើម្បីធ្វើឲ្យផុតទុក្ខដោយប្រពៃក៏ប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះបានធ្វើបាប-កម្ម សូម្បីត្រឹមតែបន្តិចបន្តួចហើយ (បាបកម្មនោះ) រមែងនាំបុគ្គលនោះ

និរយំ ឧបនេតិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស តាទិសំយេវ អប្បមត្តកំ បាបកម្មំ កតំ ទិដ្ឋធម្មវេទនីយំ ហោតិ នាណុបិ ខាយតិ[១] ពហុ-នេវ ។ កថំរូបស្ស ភិក្ខវេ បុគ្គលស្ស អប្បមត្តកម្បិ បាបកម្មំ កតំ តមេនំ និរយំ ឧបនេតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អភាវិតកាយោ ហោតិ អភាវិត-សីលោ អភាវិតចិត្តោ អភាវិតប្បញ្ញោ បរិត្តោ អប្បាតុមោ អប្បទុក្ខវិហារី ឯវរូបស្ស ភិក្ខវេ បុគ្គលស្ស អប្ប-មត្តកម្បិ បាបកម្មំ កតំ តមេនំ និរយំ ឧបនេតិ ។ កថំរូបស្ស ភិក្ខវេ បុគ្គលស្ស តាទិសំយេវ អប្បមត្តកំ បាបកម្មំ កតំ ទិដ្ឋធម្មវេទនីយំ ហោតិ នាណុបិ ខាយតិ ពហុនេវ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ភាវិតកាយោ ហោតិ ភាវិតសីលោ

---

១ ម. ខាយតិ កឹ ។

ទៅកាន់នរក ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បាបកម្មត្រឹមតែបន្តិច ប្រហែលគ្នានឹងបាបកម្មមុននោះដែរ ដែលបុគ្គលពួកខ្លះ ក្នុងលោកនេះ ធ្វើហើយ ជាកម្មត្រូវទទួលផលក្នុងបច្ចុប្បន្ន ឯកម្មតិចតួចស្តួចស្តើងមិនប្រាកដគឺថាមិនបានឲ្យផលក្នុងអត្តភាពជាគម្រប់ពីរទេ (លុះណា) តែកម្មច្រើន ទើបប្រាកដគឺថាឲ្យផល ក្នុងអត្តភាពជាគម្រប់ពីរបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបណា ដែលបានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិចហើយ (បាបកម្មនោះ) នាំបុគ្គលនោះចូលទៅកាន់នរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនសមាធិចិត្ត មិនបានចម្រើនវិបស្សនាបញ្ញា មានគុណដ៏ស្តួចស្តើង មានគុណក្នុងខ្លួនដ៏តិច មានការនៅជាទុក្ខ ព្រោះផលតិច ម្នាលភិក្ខុទាំង-ឡាយ បុគ្គលបែបយ៉ាងនេះ ដែលបានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិចហើយ (បាបកម្មនោះ) នាំបុគ្គលនោះចូលទៅកាន់នរកបាន ។ ម្នាលភិក្ខុទាំង-ឡាយ បុគ្គលបែបណា ដែលបានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិច ប្រហែលគ្នានឹងបាបកម្មមុននោះដែរ ហើយទទួលផលក្នុងបច្ចុប្បន្ន ឯកម្មតិចតួចស្តួច-ស្តើង មិនប្រាកដ គឺថាមិនបានឲ្យផល ក្នុងអត្តភាពជាគម្រប់ពីរ (លុះណា) តែកម្មច្រើន ទើបប្រាកដគឺថាឲ្យផលបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបានចម្រើនកាយ បានចម្រើនសីល

ភាវិតចិត្តោ ភាវិតប្បញ្ញោ អបរិត្តោ មហត្តា អប្បមាណវិហារី ឯវរូបស្ស ភិក្ខវេ បុគ្គលស្ស តាទិសំយេវ អប្បមត្តកំ បាបកម្មំ កតំ ទិដ្ឋធម្មវេទនីយំ ហោតិ នាណុបិ ខាយតិ ពហុទេវ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ លោណផលំ បរិត្តេ ឧទកមល្លកេ បក្ខិបេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិនុ តំ បរិត្តំ ឧទកមល្លកេ ឧទកំ អមុនា លោណផលេន លោណំ អស្ស អបេយ្យន្តិ ។ ឯវំ ភន្តេ ។ តំ កិស្ស ហេតុ ។ អទុំ[១] ហិ ភន្តេ បរិត្តំ ឧទកមល្លកេ ឧទកំ តំ អមុនា លោណផលេន លោណំ អស្ស អបេយ្យន្តិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ លោណផលំ គង្គាយ នទិយា បក្ខិបេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិនុ សា គង្គា នទី អមុនា លោណផលេន លោណំ អស្ស អបេយ្យន្តិ ។ នោ ហេតំ ភន្តេ ។

១ ម. អនុញ្ញិ ។

បានចម្រើនសមាធិចិត្ត បានចម្រើនវិបស្សនាបញ្ញា មានគុណដ៏ច្រើន មានគុណក្នុងខ្លួនច្រើន មានការនៅដោយមិនមានរាគាទិក្កិលេស ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបយ៉ាងនេះ ដែលបានធ្វើបាបកម្មត្រឹមតែបន្តិច ប្រហែលគ្នានឹងបាបកម្មមុននោះហើយ ត្រូវទទួលផលក្នុងបច្ចុប្បន្ន ឯកម្មតិចតួចស្តួចស្តើង មិនប្រាកដ គឺថាមិនឲ្យផល ក្នុងអត្តភាពជាគម្រប់ពីរ (លុះណា) តែកម្មច្រើន ទើបប្រាកដគឺថាឲ្យផលបាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសបង់ដុំអំបិលមួយគ្រាប់ក្នុងផ្តិលទឹកយ៉ាងតូច ។ ម្នាលភិក្ខុទាំងឡាយ ចុះអ្នកទាំងឡាយ សម្គាល់នូវហេតុនោះដូចម្តេច ទឹកក្នុងផ្តិលយ៉ាងតូចនោះគួរជាទឹកប្រៃសព្វ ដោយអំបិលមួយគ្រាប់ ប៉ុណ្ណោះដែរឬ ។ យ៉ាងហ្នឹងហើយ ព្រះអង្គ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះទឹកក្នុងផ្តិលនោះមានប្រមាណតិច ទឹកនោះជាទឹកប្រៃសព្វដោយអំបិលមួយគ្រាប់ ប៉ុណ្ណោះបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសបង់អំបិលមួយគ្រាប់ក្នុងទន្លេគង្គា ។ ម្នាលភិក្ខុទាំងឡាយ តើអ្នកទាំងឡាយ សម្គាល់នូវហេតុនោះដូចម្តេច ទន្លេគង្គានោះគួរប្រៃសព្វដោយអំបិលមួយគ្រាប់ ប៉ុណ្ណោះដែរឬ ។ មិនមែនដូច្នោះទេ ព្រះអង្គ ។

តំ កិស្ស ហេតុ ។ អសុ ហិ ភន្តេ គង្គាយ នទិយា មហាឧទកក្ខន្ធោ សោ អមុនា លោណផលេន លោណោ អស្ស អបេយ្យោតិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចស្ស បុគ្គលស្ស អប្បមត្តកម្បិ បាបកម្មំ កតំ តមេនំ និរយំ ឧបនេតិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស តាទិសំយេវ អប្បមត្តកំ បាបកម្មំ កតំ ទិដ្ឋធម្មវេទនីយំ ហោតិ នាណុបិ ខាយតិ ពហុទេវ ។ កថំរូបស្ស ភិក្ខវេ បុគ្គលស្ស អប្បមត្តកម្បិ បាបកម្មំ កតំ តមេនំ និរយំ ឧបនេតិ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អភាវិតកាយោ ហោតិ អភាវិតសីលោ អភាវិតចិត្តោ អភាវិតប្បញ្ញោ បរិត្តោ អប្បាតុមោ អប្បទុក្ខវិហារី ឯវរូបស្ស ភិក្ខវេ បុគ្គលស្ស អប្បមត្តកម្បិ បាបកម្មំ កតំ តមេនំ និរយំ ឧបនេតិ ។

ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះក្នុងទន្លេគង្គាឯណោះ មានគំនរទឹកច្រើន គំនរទឹកយ៉ាងធំនោះមិនគួរប្រៃសព្វ ដោយអំបិលមួយគ្រាប់ប៉ុណ្ណោះបាន យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិចបន្តួចហើយ (បាបកម្មនោះ) នាំបុគ្គលនោះចូលទៅកាន់នរក ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើបាប-កម្មត្រឹមតែបន្តិចបន្តួច ប្រហែលគ្នានឹងបាបកម្មមុននោះដែរ ហើយត្រូវទទួលផលក្នុងបច្ចុប្បន្ន ឯកម្មមានប្រមាណតិច មិនប្រាកដ (លុះណា) តែកម្មច្រើនទើបប្រាកដ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបណាដែលបានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិចបន្តួចហើយ (បាបកម្មនោះ) នាំបុគ្គលនោះចូលទៅកាន់នរក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានចម្រើនកាយ មិនបានចម្រើនសីល មិនបានចម្រើនសមាធិចិត្ត មិនបានចម្រើនវិបស្សនាបញ្ញា មានគុណស្តួចស្តើង មានគុណក្នុងខ្លួនតិច មានការនៅជាទុក្ខ ព្រោះផលតិច ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបនេះឯង ដែលបានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិចបន្តួចហើយ (បាបកម្មនោះ) នាំបុគ្គលនោះចូលទៅកាន់នរក ។

កថំរូបស្ស ភិក្ខវេ បុគ្គលស្ស តាទិសំយេវ អប្បមត្តកំ ចាបកម្មំ កតំ ទិដ្ឋធម្មវេទនីយំ ហោតិ នាណុបិ ខាយតិ ពហុទេវ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ភាវិតកាយោ ហោតិ ភាវិតសីលោ ភាវិតចិត្តោ ភាវិតបញ្ញោ អបរិត្តោ មហត្តា អប្បមាណវិហារី ឯវរូបស្ស ភិក្ខវេ បុគ្គលស្ស តាទិសំយេវ អប្បមត្តកំ ចាបកម្មំ កតំ ទិដ្ឋធម្មវេទនីយំ ហោតិ នាណុបិ ខាយតិ ពហុទេវ ។ ឥធ ភិក្ខវេ ឯកច្ចោ អឌ្ឍកហាបណេនបិ ពន្ធនំ និគច្ឆតិ កហាបណេនបិ ពន្ធនំ និគច្ឆតិ កហាបណសតេនបិ ពន្ធនំ និគច្ឆតិ ។ ឥធ បន ភិក្ខវេ ឯកច្ចោ អឌ្ឍកហាបណេនបិ ន ពន្ធនំ និគច្ឆតិ កហាបណេនបិ ន ពន្ធនំ និគច្ឆតិ កហាបណសតេនបិ ន ពន្ធនំ និគច្ឆតិ ។ កថំរូបោ ភិក្ខវេ អឌ្ឍកហាបណេនបិ ពន្ធនំ និគច្ឆតិ កហាបណេនបិ ពន្ធនំ និគច្ឆតិ កហាបណសតេនបិ ពន្ធនំ និគច្ឆតិ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបណា ដែលបានធ្វើបាបកម្ម ត្រឹមតែបន្តិចបន្តួច ប្រហែលគ្នានឹងបាបកម្មមុននោះដែរ ហើយត្រូវទទួលផលក្នុងបច្ចុប្បន្ន ឯកម្មតិចតួច រមែងមិនប្រាកដ (លុះណា) តែកម្មច្រើនទើបប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកបានចម្រើនកាយ បានចម្រើនសីល បានចម្រើនសមាធិចិត្ត បានចម្រើនវិបស្សនាបញ្ញា មានគុណច្រើន មានគុណក្នុងខ្លួនច្រើន មានការនៅដោយមិនមានរាគាទិក្កិលេសទេ ម្នាលភិក្ខុទាំងឡាយ បុគ្គលបែបយ៉ាងនេះឯងបានធ្វើបាបកម្មត្រឹមតែបន្តិចបន្តួច ប្រហែលគ្នានឹងបាបកម្មមុននោះដែរ ហើយត្រូវទទួលផលក្នុងបច្ចុប្បន្ន ឯកម្មតិចតួច រមែងមិនប្រាកដ (លុះណា) តែកម្មច្រើន ទើបប្រាកដគឺឲ្យផលបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាប់ចំណង ព្រោះកន្លះកហាបណៈខ្លះ ជាប់ចំណងព្រោះមួយកហាបណៈខ្លះ ជាប់ចំណងព្រោះកហាបណៈ ១០០ ខ្លះ ។ ម្នាលភិក្ខុទាំងឡាយមួយវិញទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ មិនជាប់ចំណង ព្រោះកន្លះកហាបណៈខ្លះ មិនជាប់ចំណងព្រោះកហាបណៈមួយខ្លះ មិនជាប់ចំណងព្រោះកហាបណៈ ១០០ ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងណា រមែងជាប់ចំណង ព្រោះកន្លះកហាបណៈខ្លះ ជាប់ចំណងព្រោះកហាបណៈមួយខ្លះ ជាប់ចំណងព្រោះកហាបណៈ ១០០ ខ្លះ ។

ឥធ ភិក្ខវេ ឯកច្ចោ ទឡិទ្ទោ ហោតិ អប្បស្សកោ អប្បភោគោ ឯវរូបោ ភិក្ខវេ អឌ្ឍកហាបណេនបិ ពន្ធនំ និគច្ឆតិ កហាបណេនបិ ពន្ធនំ និគច្ឆតិ កហាបណសតេនបិ ពន្ធនំ និគច្ឆតិ ។ កថំរូបោ ភិក្ខវេ អឌ្ឍកហាបណេនបិ ន ពន្ធនំ និគច្ឆតិ កហាបណេនបិ ន ពន្ធនំ និគច្ឆតិ កហាបណសតេនបិ ន ពន្ធនំ និគច្ឆតិ ។ ឥធ ភិក្ខវេ ឯកច្ចោ អឌ្ឍោ ហោតិ មហទ្ធនោ មហាភោគោ ឯវរូបោ ភិក្ខវេ អឌ្ឍកហាបណេនបិ ន ពន្ធនំ និគច្ឆតិ កហាបណេនបិ ន ពន្ធនំ និគច្ឆតិ កហាបណសតេនបិ ន ពន្ធនំ និគច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចស្ស បុគ្គលស្ស អប្បមត្តកម្បិ ចាបកម្មំ កតំ តមេនំ និរយំ ឧបនេតិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស តាទិសំយេវ អប្បមត្តកំ ចាបកម្មំ កតំ ទិដ្ឋធម្មវេទនីយំ ហោតិ ជាណុបិ ខាយតិ ពហុទេវ ។ បេ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកក្រីក្រឥតទីពំនាក់ មានគ្រឿងប្រើប្រាស់តិច ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ រមែងជាប់ចំណង ព្រោះកន្ទះកហាបណៈខ្លះ ជាប់ចំណង ព្រោះកហាបណៈមួយខ្លះ ជាប់ចំណងព្រោះកហាបណៈ ១០០ ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងណា មិនជាប់ចំណង ព្រោះកន្ទះកហាបណៈខ្លះ មិនជាប់ចំណងព្រោះកហាបណៈមួយខ្លះ មិនជាប់ចំណង ព្រោះកហាបណៈ ១០០ ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ រមែងមិនជាប់ចំណងព្រោះកន្ទះកហាបណៈខ្លះ មិនជាប់ចំណង ព្រោះកហាបណៈមួយខ្លះ មិនជាប់ចំណង ព្រោះកហាបណៈ ១០០ ខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ បានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិចបន្តួចហើយ (បាបកម្មនោះ) រមែងនាំបុគ្គលនោះចូលទៅកាន់នរក ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើបាបកម្ម ត្រឹមតែបន្តិចបន្តួច ប្រហែលនឹងបាបកម្មមុននោះដែរ ហើយគួរទទួលផលក្នុងបច្ចុប្បន្ន ឯកម្មតិចតួច មិនប្រាកដទេ (លុះណា) តែកម្មច្រើនទើបប្រាកដបាន ។ បេ ។

សេយ្យថាបិ ភិក្ខវេ ឱវត្តិកោ វា ឧវត្តឃាតកោ វា អប្បេកច្ចោ ឧវត្តំ អជិន្នំ អាជិយមានំ បហោតិ ហន្តុំ វា ពន្ធិតុំ វា ឈាបេតុំ វា យថាបច្ចយំ វា កាតុំ អប្បេកច្ចោ ឧវត្តំ អជិន្នំ អាជិយមានំ ឩប្បហោតិ ហន្តុំ វា ពន្ធិតុំ វា ឈាបេតុំ វា យថាបច្ចយំ វា កាតុំ ។ កាចំរូចោ ភិក្ខវេ ឱវត្តិកោ វា ឧវត្តឃាតកោ វា ឧវត្តំ អជិន្នំ អាជិយមានំ បហោតិ ហន្តុំ វា ពន្ធិតុំ វា ឈាបេតុំ វា យថា-បច្ចយំ វា កាតុំ ។ ឥឩ ភិក្ខវេ ឯកច្ចោ ឩលិទ្ទោ ហោតិ អប្បស្សកោ អប្បភោគោ ឯវរូចោ ភិក្ខវេ ឱវត្តិកោ វា ឧវត្តឃាតកោ វា ឧវត្តំ អជិន្នំ អាជិយមានំ បហោតិ ហន្តុំ វា ពន្ធិតុំ វា ឈាបេតុំ វា យថាបច្ចយំ វា កាតុំ ។ កាចំរូចោ ភិក្ខវេ ឱវត្តិកោ វា ឧវត្តឃាតកោ វា ឧវត្តំ អជិន្នំ អាជិយមានំ ឩប្បហោតិ ហន្តុំ វា ពន្ធិតុំ វា ឈាបេតុំ វា យថាបច្ចយំ វា កាតុំ ។

ម្នាលភិក្ខុទាំងឡាយ ដូចជាជនពួកខ្លះ ជាអ្នកម្ចាស់ចៀម ឬ ជាអ្នកសម្លាប់ចៀម ល្មមដើម្បីសម្លាប់ក្តី ចងក្តី ដុតក្តី ធ្វើកិច្ចគួរតាមការក្តី នូវជនអ្នកយកចៀម ដែលខ្លួនមិនបានឲ្យ ជនពួកខ្លះ មិនល្មមដើម្បីសម្លាប់ក្តី ចងក្តី ដុតក្តី ធ្វើកិច្ចគួរតាមការក្តី នូវជនអ្នកយកចៀម ដែលខ្លួនមិនបានឲ្យ ។ ម្នាលភិក្ខុទាំងឡាយ ជនមានសភាពយ៉ាងណាដែលជាម្ចាស់ចៀមឬជាអ្នកសម្លាប់ចៀម ល្មមដើម្បីសម្លាប់ក្តី ចងក្តី ដុតក្តី ធ្វើកិច្ចគួរតាមការក្តី នូវជនអ្នកយកចៀម ដែលខ្លួនមិនបានឲ្យ ។ ម្នាលភិក្ខុទាំងឡាយ ជនពួកខ្លះក្នុងលោកនេះ ជាអ្នកក្រីក្រឥតទីពឹងពំនាក់ មានគ្រឿងប្រើប្រាស់តិច ម្នាលភិក្ខុទាំងឡាយ ជនមានសភាពយ៉ាងនេះ ដែលម្ចាស់ចៀមឬអ្នកសម្លាប់ចៀម ល្មមដើម្បីសម្លាប់ក្តី ចងក្តី ដុតក្តី ធ្វើកិច្ចគួរតាមការក្តី នូវជនអ្នកយកចៀមដែលខ្លួនមិនបានឲ្យ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងណាដែលជាម្ចាស់ចៀម ឬជាអ្នកសម្លាប់ចៀម មិនល្មមដើម្បីសម្លាប់ក្តី ចងក្តី ដុតក្តី ធ្វើកិច្ចគួរតាមការក្តី នូវជនអ្នកយកចៀម ដែលខ្លួនមិនបានឲ្យ ។

ឥធ ភិក្ខវេ ឯកច្ចោ អឌ្ឍោ ហោតិ មហទ្ធនោ មហាភោគោ រាជា វា រាជមហាមត្តោ វា ឯវរូបោ ភិក្ខវេ ឱរព្ភិកោ វា ឧរព្ភឃាតកោ វា ឧរព្ភំ អទិន្នំ អាទិយមានំ នប្បហោតិ ហន្តុំ វា ពន្ធិតុំ វា ឈាបេតុំ វា យថាបច្ចយំ វា កាតុំ ។ អញ្ញទត្ថុ បញ្ជលិកោ វ នំ យាចតិ ទេហិ មេ មារិស ឧរព្ភំ វា ឧរព្ភធនំ វាតិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចស្ស បុគ្គលស្ស អប្បមត្តកំបិ បាបកម្មំ កតំ តមេនំ និរយំ ឧបនេតិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស តាទិសំយេវ អប្បមត្តកំ បាបកម្មំ កតំ ទិដ្ឋធម្មវេទនីយំ ហោតិ នាណុបិ ខាយតិ ពហុទេវ ។ បេ ។ យោ ខោ ភិក្ខវេ ឯវំ វទេយ្យ យថា យថាយំ បុរិសោ កម្មំ ករោតិ តថា តថា តំ បដិសំវេទិយតីតិ ឯវំ សន្តំ ភិក្ខវេ ព្រហ្មចរិយវាសោ ន ហោតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ទោះស្ដេចក្ដី អាមាត្យធំរបស់ស្ដេចក្ដី ជាអ្នកស្ដុកស្ដម្ភមានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសភាពយ៉ាងនេះ ដែលជាម្ចាស់ចៀម ឬជាអ្នកសម្លាប់ចៀម មិនល្មមដើម្បីសម្លាប់ក្ដី ចងក្ដី ដុតក្ដី ធ្វើកិច្ចគួរតាមការក្ដីនូវជនអ្នកយកចៀម ដែលខ្លួនមិនបានឲ្យដោយពិត អ្នកដែលគេលួចចៀមរមែងសំពះអង្វរអ្នកលួចចៀមនោះថា បពិត្រលោកអ្នកនិរទុក្ខ សូមលោកឲ្យចៀម ឬ តម្លៃចៀមមកខ្ញុំ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើបាបកម្ម សូម្បីត្រឹមតែបន្តិចបន្តួចហើយ (បាបកម្មនោះ) នាំបុគ្គលនោះចូលទៅកាន់នរក ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ បានធ្វើបាបកម្ម ត្រឹមតែបន្តិចបន្តួច ប្រហែលគ្នានឹងបាបកម្មមុននោះដែរហើយ គួរទទួលផលក្នុងបច្ចុប្បន្ន ឯបាបកម្មតិចតួច មិនប្រាកដ (លុះណា) បាបកម្មច្រើន ទើបប្រាកដបាន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បើបុគ្គលណា និយាយយ៉ាងនេះថា បុរសនេះធ្វើកម្ម យ៉ាងណាៗ រមែងទទួលផលកម្មនោះ យ៉ាងនោះៗ ម្នាលភិក្ខុទាំងឡាយ កាលបើហេតុ យ៉ាងនេះ មានការប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនមាន

ឱកាសោ ន បញ្ញាយតិ សម្មាទុក្ខស្ស អន្តកិរិ-
យាយ ។ យោ ច ខោ ភិក្ខវេ ឯវំ វទេយ្យ
យថា យថា វេទនីយំ អយំ បុរិសោ កម្មំ ករោតិ
តថា តថាស្ស វិបាកំ បដិសំវេទិយតីតិ ឯវំ សន្តំ
ភិក្ខវេ ព្រហ្មចរិយវាសោ ហោតិ ឱកាសោ បញ្ញាយតិ
សម្មាទុក្ខស្ស អន្តកិរិយាយាតិ ។

[១០៣] សន្តិ ភិក្ខវេ ជាតរូបស្ស ឱឡារិកា
ឧបក្កិលេសា បំសុវាលិកា សក្ខរកឋលា[១] តមេនំ
បំសុធោវកោ វា បំសុធោវកន្តេវាសី វា ទោណិយំ
អាកិរិត្វា ធោវតិ សន្ធោវតិ និទ្ធោវតិ តស្មឹ បហីនេ
តស្មឹ ព្យន្តីកតេ[២] សន្តិ ជាតរូបស្ស មជ្ឈិមស-
ហគតា ឧបក្កិលេសា សុខុមសក្ខរា ថុលវាលិកា
តមេនំ បំសុធោវកោ វា បំសុធោវកន្តេវាសី វា
ធោវតិ សន្ធោវតិ និទ្ធោវតិ តស្មឹ បហីនេ តស្មឹ
ព្យន្តីកតេ សន្តិ ជាតរូបស្ស សុខុមសហគតា
ឧបក្កិលេសា សុខុមវាលិកា កាឡជល្លិកា
តមេនំ បំសុធោវកោ វា បំសុធោវកន្តេវាសី វា

១ ម. សក្ខរាកឋលា ថូលា ។ ២ ម. ព្យន្តីករោន្តេ ។

ឱកាសដើម្បីធ្វើឲ្យផុតទុក្ខដោយប្រពៃក៏មិនប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បើបុគ្គលណា និយាយយ៉ាងនេះថា បុរសនេះធ្វើកម្ម ដែលខ្លួនត្រូវដឹងបាន យ៉ាងណាៗ ក៏រមែងទទួលយកនូវផល របស់កម្មនោះ យ៉ាងនោះៗ ឯង ម្នាលភិក្ខុទាំងឡាយ កាលបើហេតុយ៉ាងនេះមាន ការប្រព្រឹត្តព្រហ្មចរិយៈក៏មាន ឱកាសដើម្បីធ្វើឲ្យផុតទុក្ខ ដោយប្រពៃក៏ប្រាកដ ។

[១០៣] ម្នាលភិក្ខុទាំងឡាយ ខ្សាច់លាយដោយអាចម៍ដី គ្រឿងលាយដោយក្រួស ជាឧបក្កិលេសយ៉ាងគ្រោតគ្រាត របស់មាស ក៏មាន មេជាងអ្នកលាងអាចម៍ដីក្តី កូនជាងអ្នកលាងអាចម៍ដីក្តី ពោយរាយមាសនោះចុះក្នុងស្នូកហើយ លាងជម្រះដេញកម្ចាត់ចេញ (នូវមន្ទិល) ត្រាតែធ្វើមាសនោះឲ្យអស់មន្ទិល ឲ្យបាត់មន្ទិលចេញបាន ក្រួសយ៉ាងល្អិតៗ ខ្សាច់យ៉ាងធំៗ ជាឧបក្កិលេស (មន្ទិល) យ៉ាងកណ្តាលរបស់មាស មេជាងអ្នកលាងអាចម៍ដីក្តី កូនជាងអ្នកលាងអាចម៍ដីក្តី រមែងលាងជម្រះដេញកម្ចាត់ចេញនូវមន្ទិលនោះត្រាតែធ្វើមាសនោះឲ្យអស់មន្ទិល ឲ្យបាត់មន្ទិលចេញបាន ដីខ្សាច់យ៉ាងល្អិត ជារបស់មានពណ៌ខ្មៅ ជាឧបក្កិលេសយ៉ាងល្អិតរបស់មាសក៏មាន មេជាងអ្នកលាងអាចម៍ដីក្តី កូនជាងអ្នកលាងអាចម៍ដីក្តី

ធោវតិ សន្ធោវតិ និទ្ធោវតិ តស្មឹ បហីនេ តស្មឹ ព្យន្តីកតេ អថាបរំ សុវណ្ណសិកតាវសិស្សន្តិ[១] ។ តមេនំ សុវណ្ណការោ វា សុវណ្ណការន្តេវាសី វា ជាតរូបំ[២] មូសាយំ បក្ខិបិត្វា ធមតិ សន្ធមតិ និទ្ធមតិ ។ តំ ហោតិ ជាតរូបំ អធន្តំ អសន្ធន្តំ អនិទ្ធន្តំ អនិហិតំ អនិន្នីតកសាវំ[៣] ន ចេវ មុទុំ ហោតិ ន ច កម្មនីយំ ន ច បភស្សរំ បភង្គុ ច ន ច សម្មា ឧបេតិ កម្មាយ ។ ហោតិ សោ ភិក្ខវេ សមយោ យំ សោ សុវណ្ណការោ វា សុវណ្ណការន្តេវាសី វា តំ ជាតរូបំ ធមតិ សន្ធមតិ និទ្ធមតិ តំ ហោតិ ជាតរូបំ ធន្តំ សន្ធន្តំ និទ្ធន្តំ និហិតំ និន្នីតកសាវំ មុទុំ ច ហោតិ កម្មនីយញ្ច បភស្សរញ្ច ន ច បភង្គុ សម្មា ឧបេតិ កម្មាយ យស្សា យស្សា ច បិឡន្ធនវិកតិយា អាកង្ខតិ យទិ បដ្ដិកាយ[៤] យទិ កុណ្ឌលាយ

---

១ ម. សុវណ្ណជាតរូបការសិស្សន្តិ ។ ២ ឱ. ម. តំ ជាតរូបំ ។ ៣ ឱ. ធន្តំ សន្ធន្តំ អនិទ្ធន្តំ អនិហិតំ អនិន្នីតកសាវន្តិ ទិស្សន្តិ ។ ម. ធន្តំ សន្ធន្តំ និទ្ធន្តំ អនិទ្ធន្តកសាវន្តិ ទិស្សន្តិ ។ ៤ បដ្ដកាយាតិបិ ។

លាងជម្រះដេញកម្ចាត់ចេញ នូវមន្ទិលនោះ ត្រាតែធ្វើមាសនោះឲ្យអស់មន្ទិល ឲ្យបាត់មន្ទិលចេញបាន តអំពីនោះ នឹងសល់នៅតែមាសសុទ្ធ ជាងមាសក្តី កូនជាងមាសក្តី ដាក់មាសនោះចុះក្នុងបាវហើយ ទើបសប់រំលាយដេញសាច់ ។ មាសនោះដែលមិនបានសប់រំលាយដេញសាច់ មិនបានកម្ចាត់មន្ទិលចេញ មិនបាននាំមន្ទិលចេញហើយ មិនទៅជាមាសទន់ផង មិនទៅជាមាសគួរដល់ការងារផង មិនទៅជាមាសមានពន្លឺផ្លេកផង ទៅជាមាសស្រួយ មិនគួរដល់ការងារដោយប្រពៃផង ។ ម្នាលភិក្ខុទាំងឡាយ សម័យគួរនោះ គឺសម័យដែលជាងមាសឬកូនជាងមាស សប់រំលាយដេញសាច់ មាសនោះដែលបានសប់រំលាយដេញសាច់ កម្ចាត់មន្ទិលចេញ នាំមន្ទិលចេញហើយ រមែងទៅជាមាសទន់ផង គួរដល់ការងារផង មានពន្លឺភ្លឺផ្លេកផង មិនទៅជាមាសស្រួយផង គួរដល់ការងារដោយប្រពៃផង ជាងប្រាថ្នាគ្រឿងប្រដាប់ប្លែកៗ ឯណាៗ ទោះជាដំបារមាសក្តី កុណ្ឌលក្តី

យថិ គីវេយ្យកេ យថិ សុវណ្ណមាលាយ តញ្ចស្ស អត្ថំ អនុភោតិ ។ ឯវមេវ ខោ ភិក្ខវេ សន្តិ អធិ-ចិត្តមនុយុត្តស្ស ភិក្ខុនោ ឱឡារិកា ឧបក្កិលេសា កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ។ តមេនំ សចេតសោ ភិក្ខុ ឧព្ភជាតិកោ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ តស្មឹ បហីនេ តស្មឹ ព្យន្តីកតេ ។ សន្តិ អធិចិត្តមនុយុត្តស្ស ភិក្ខុនោ មជ្ឈិមសហគតា ឧបក្កិលេសា កាមវិតក្កោ ព្យាបាទវិតក្កោ វិហឹសាវិតក្កោ ។ តមេនំ សចេតសោ ភិក្ខុ ឧព្ភជាតិកោ បជហតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ តស្មឹ បហីនេ តស្មឹ ព្យន្តីកតេ ។ សន្តិ អធិចិត្តមនុយុត្តស្ស ភិក្ខុនោ សុខុម-សហគតា ឧបក្កិលេសា ញាតិវិតក្កោ ជនបទ-វិតក្កោ អនវញ្ញត្តិប្បដិសំយុត្តោ វិតក្កោ ។

ជាគ្រឿងប្រដាប់កក្តី កម្រង់មាសក្តី រមែងសម្រេចតាមត្រូវការនោះបានទាំងអស់ ។ ម្នាលភិក្ខុទាំងឡាយ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាឧបក្កិលេស យ៉ាងគ្រោតគ្រាតរបស់ភិក្ខុដែលប្រកបរឿយៗ នូវអធិចិត្ត ក៏មានយ៉ាងនោះដែរ ។ ភិក្ខុអ្នកបរិបូណ៌ដោយសមាធិចិត្ត ប្រកបដោយជាតិជាអ្នកប្រាជ្ញ រមែងលះបង់ បន្ទោបង់ធ្វើឲ្យវិនាសនូវឧបក្កិលេសនោះចេញ ឲ្យតាំងនៅមិនបាន ត្រាតែធ្វើចិត្តនោះឲ្យអស់មន្ទិល ឲ្យបាត់មន្ទិលចេញ ។ កាមវិតក្កៈ ព្យាបាទវិតក្កៈ វិហឹសាវិតក្កៈ ជាឧបក្កិលេសយ៉ាងកណ្តាល របស់ភិក្ខុអ្នកប្រកបនូវអធិចិត្ត ។ ភិក្ខុអ្នកបរិបូណ៌ដោយសមាធិចិត្ត ប្រកបដោយជាតិជាអ្នកប្រាជ្ញ រមែងលះបង់ បន្ទោបង់ ធ្វើឲ្យវិនាសនូវឧបក្កិលេសនោះចេញ ឲ្យតាំងនៅមិនបាន ត្រាតែធ្វើចិត្តនោះ ឲ្យអស់មន្ទិល ឲ្យបាត់មន្ទិលចេញ ។ ញាតិវិតក្កៈ (សេចក្តីត្រិះរិះ[១]អំពីញាតិ) ជនបទវិតក្កៈ (សេចក្តីត្រិះរិះ[២]អំពីជនបទ) អនវញ្ញត្តិប្បដិសំយុត្តវិតក្កៈ (សេចក្តីត្រិះរិះ[៣] ប្រកបដោយការមិនចង់ឲ្យគេមើលងាយ) ជាឧបក្កិលេសយ៉ាងល្អិតរបស់ភិក្ខុអ្នកប្រកបនូវអធិចិត្ត ។

១ សេចក្តីត្រិះរិះចំពោះពួកញាតិថា ពួកញាតិរបស់អាត្មាអញមានបុណ្យច្រើន ។

២ សេចក្តីត្រិះរិះចំពោះជនបទថា ជនបទឯណោះក្សេមក្សាន្តបរិបូណ៌ដោយភិក្ខាហារ ។

៣ សេចក្តីត្រិះរិះកើតឡើងថា ពួកជនដទៃមិនគួរមើលងាយអាត្មាអញឡើយ ។ អដ្ឋកថា ។

តមេនំ សចេតសោ ភិក្ខុ ទព្វជាតិកោ បជហាតិ វិនោទេតិ ព្យន្តីករោតិ អនភាវំ គមេតិ តស្មឹ បហីនេ តស្មឹ ព្យន្តីកតេ អថាបរំ ធម្មវិតក្កាវសិស្សន្តិ ។ សោ ហោតិ សមាធិ ន ចេវ សន្តោ នប្បណីតោ នប្បដិប្បស្សទ្ធលទ្ធោ ន ឯកោទិភាវាធិគតោ សសង្ខារនិគ្គយ្ហវារិតវតោ ។ ហោតិ សោ ភិក្ខវេ សមយោ យន្តំ ចិត្តំ អជ្ឈត្តំយេវ សន្តិដ្ឋតិ សន្និ-សីទតិ ឯកោទិភាវោ ហោតិ សមាធិយតិ ។ សោ ហោតិ សមាធិ សន្តោ បណីតោ បដិប្បស្សទ្ធលទ្ធោ ឯកោទិភាវាធិគតោ ន សសង្ខារនិគ្គយ្ហវារិតវតោ យស្ស យស្ស ច អភិញ្ញាសច្ឆិករណីយស្ស ធម្មស្ស ចិត្តំ អភិនិន្នាមេតិ អភិញ្ញាសច្ឆិកិរិយាយ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។

ភិក្ខុអ្នកបរិបូណ៌ដោយសមាធិចិត្ត ប្រកបដោយជាតិជាអ្នកប្រាជ្ញ រមែងលះបង់ បន្ទោបង់ ធ្វើឲ្យវិនាសនូវឧបក្កិលេសនោះចេញ ឲ្យតាំងនៅមិនបាន ត្រាតែធ្វើចិត្តនោះឲ្យអស់មន្ទិល ឲ្យបាត់មន្ទិលចេញ ។ លំដាប់តពីនោះ នឹងនៅសល់តែធម្មវិតក្កៈ (សេចក្តីត្រិះរិះនូវធម៌)[១] ប៉ុណ្ណោះ ។ សមាធិនោះ មិនបានរម្ងាប់ មិនបានខ្ពង់ខ្ពស់ មិនបាននូវការស្ងប់កិលេស មិនបានដល់នូវភាពជាចិត្តប្រសើរឯក មិនបានសង្កត់សង្កិនរារាំង (កិលេសដោយព្យាយាម) ប្រកបដោយសង្ខារ ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះ ចិត្តក៏ស្ងប់ស្ងៀមនៅក្នុងសន្តាន មានសភាពជាចិត្តប្រសើរឯក ហើយតាំងនៅមាំ ។ សមាធិនោះក៏បានរម្ងាប់ខ្ពង់ខ្ពស់ ស្ងប់កិលេស ដល់នូវភាពជាចិត្តប្រសើរឯក សង្កត់សង្កិនរារាំង (កិលេសដោយព្យាយាម) មិនប្រកបដោយសង្ខារ មួយទៀត បុគ្គលបង្អោនចិត្តទៅដើម្បីធម៌ដែលត្រូវធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាណា ៗ កាលបើហេតុមាន រមែងគួរដល់នូវភាពគួរជាបន្ទាល់ ក្នុងធម៌នោះ ៗ ព្រោះធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញា ។

---

១ សំដៅយកវិបស្សនូបក្កិលេសទាំង ១០ ។ អដ្ឋកថា ។

សោ សចេ អាកង្ខតិ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភវេយ្យំ ឯកោបិ ហុត្វា ពហុធា អស្សំ ពហុធាបិ ហុត្វា ឯកោ អស្សំ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆេយ្យំ សេយ្យថាបិ អាកាសេ បឋវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ ករេយ្យំ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆេយ្យំ សេយ្យថាបិ បឋវិយំ អាកា-សេបិ បល្លង្កេន កមេយ្យំ សេយ្យថាបិ បក្ខិសកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំ មហិទ្ធិកេ ឯវំ មហា-នុភាវេ បាណិនា បរិមសេយ្យំ បរិមជ្ជេយ្យំ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។ សោ សចេ អាកង្ខតិ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណេយ្យំ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ចាតិ តត្រ តត្រេវ សក្ខិ-ភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។

បុគ្គលនោះ បើប្រាថ្នាថា សូមឲ្យអាត្មាអញ ទទួលនូវការតាក់តែង ឫទ្ធិច្រើនប្រការ គឺអាត្មាអញតែម្នាក់ឯង ធ្វើឲ្យទៅជាមនុស្សច្រើននាក់ គ្នាច្រើននាក់ឲ្យទៅជាម្នាក់ ធ្វើនូវទីកំបាំងឲ្យទៅជាទីវាល ធ្វើនូវវាលឲ្យទៅជាទីកំបាំង ដើរទម្លុះទៅក្រៅជញ្ជាំង ក្រៅកំពែង ក្រៅភ្នំបាន មិនមានទើសទាល់ដូចជាដើរទៅក្នុងទីវាល ធ្វើនូវការមុជចុះនិងងើបឡើង ក្នុងផែនដីដូចជាមុជងើបក្នុងទឹក ដើរទៅលើទឹក មិនបែកធ្លាយទឹក ដូចជាដើរទៅលើផែនដី អណ្តែតទៅឯអាកាសទាំងភ្នែនបាន ដូចជាសត្វស្លាប ចាប់ស្ទាល អង្អែល ព្រះចន្ទ្រនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះដោយដៃ ញុំាងអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោក កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ ក្នុងការតាក់តែងឫទ្ធិនោះៗ ។ បើបុគ្គលនោះប្រាថ្នាថា សូមឲ្យអាត្មាអញមានសោតធាតុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងសោតធាតុរបស់មនុស្សធម្មតាហើយ ឮនូវសំឡេងទាំងពីរគឺសំឡេងទិព្វ ១ សំឡេងរបស់មនុស្ស ១ ដែលមាននៅក្នុងទីឆ្ងាយនិងទីជិត កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ ក្នុងការឮនូវសំឡេងនោះ ៗ ។

សោ សចេ អាកង្ខតិ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានេយ្យំ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានេយ្យំ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានេយ្យំ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានេយ្យំ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានេយ្យំ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានេយ្យំ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានេយ្យំ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជា-នេយ្យំ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានេយ្យំ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានេយ្យំ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានេយ្យំ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានេយ្យំ

បើបុគ្គលនោះប្រាថ្នាថា សូមឲ្យអាត្មាអញ កំណត់ដឹងច្បាស់ នូវចិត្តសត្វទាំងឡាយដទៃ បុគ្គលទាំងឡាយដទៃ ដោយចិត្ត (របស់ខ្លួន) បាន ចិត្តប្រកបដោយរាគៈក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈហើយក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈហើយ ចិត្តដែលប្រកបដោយទោសៈក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈហើយក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈហើយ ចិត្តដែលប្រកបដោយមោហៈក្តី អាត្មាក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈហើយក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈហើយ ចិត្តដែលរួញថយក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តរួញថយ ចិត្តដែលរាយមាយក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈ (ចិត្តដល់នូវភាពជាធំ) ក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តជាមហគ្គតៈ ចិត្តដែលជាអមហគ្គតៈ (ចិត្តមិនបានដល់នូវភាពជាធំ) ក្តី អាត្មាអញដឹងច្បាស់ថា ចិត្តជាអមហគ្គតៈ ចិត្តដែលមានចិត្តដទៃក្រៃលែងជាង (កាមាវចរៈ) ក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តមានចិត្តដទៃក្រៃលែងជាង

អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានេយ្យំ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានេយ្យំ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានេយ្យំ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានេយ្យំ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។ សោ សចេ អាកង្ខតិ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យំ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសម្បិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្តកប្បេ អនេកេបិ វិវដ្តកប្បេ អនេកេបិ សំវដ្តវិវដ្តកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ

ចិត្តដែលមិនមានចិត្តដទៃក្រៃលែងជាង (រូបាវចរៈនិងអរូបាវចរៈ) ក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃក្រៃលែងជាង ចិត្តដែលតាំងមាំក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តតាំងមាំ ចិត្តដែលមិនបានតាំងមាំក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តមិនបានតាំងមាំ ចិត្តដែលរួចស្រឡះហើយក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះហើយ ចិត្តដែលមិនរួចស្រឡះក្តី អាត្មាអញក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ កាលបើហេតុមាន រមែងដល់នូវភាពជាបន្ទាល់ក្នុងការដឹងនោះៗ ។ បើបុគ្គលនោះប្រាថ្នាថា សូមឲ្យអាត្មាអញឃើញនូវបុព្វេនិវាសជាច្រើនប្រការ គឺរឭកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១ ពាន់ជាតិខ្លះ ១ សែនជាតិខ្លះ សំវដ្ត-កប្ប (កប្បវិនាស) ខ្លះ វិវដ្តកប្ប (កប្បដែលចម្រើន) ខ្លះ សំវដ្តវិវដ្តកប្ប (កប្បវិនាសនិងកប្បចម្រើន) ខ្លះ ថា អាត្មាអញ បានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះអាត្មាអញច្យុតចាកភពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលអាត្មាអញបានកើតក្នុងភពនេះ មានឈ្មោះយ៉ាងនេះ

៣៨៣



ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំ សុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធុបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ ចាបុណាតិ សតិ សតិ អាយតនេ ។ សោ សចេ អាកង្ខតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សេយ្យំ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មុបគេ សត្តេ បជានេយ្យំ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា

មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះអាត្មាអញបានច្យុតចាកភពនោះហើយ ក៏បានមកកើតក្នុងភពនេះ សូមឲ្យអាត្មាអញរឭកឃើញនូវបុព្វេនិវាសជាច្រើនប្រការ ព្រមទាំងអាការគឺ សម្បុរនិងអាហារជាដើម ព្រមទាំងឧទ្ទេសគឺឈ្មោះ និងគោត្រកូល ដោយប្រការដូច្នេះឯង កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ក្នុងការរឭកឃើញនោះៗ ។ បើបុគ្គលនោះប្រាថ្នាថា សូមឲ្យអាត្មាអញមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធស្អាត កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា បានឃើញនូវសត្វទាំងឡាយដែលច្យុត ដែលកើតឡើង ថោកទាបនិងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎សត្វពួកនេះ ប្រកបដោយកាយ-ទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវព្រះអរិយៈទាំងឡាយ ជាមិច្ឆាទិដ្ឋិ កាន់យកនូវអំពើជាមិច្ឆាទិដ្ឋិ សត្វពួកនោះ លុះទម្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក អើហ្ន៎ ចំណែកឯសត្វពួកនេះ ប្រកបដោយកាយសុចរិត

វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សេយ្យំ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។ សោ សចេ អាកង្ខតិ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេតិ ។

ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀល នូវព្រះអរិយៈទាំងឡាយ ជាសម្មាទិដ្ឋិ កាន់យកនូវអំពើជាសម្មាទិដ្ឋិ សត្វពួកនោះ លុះទម្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកាន់លោក គឺសុគតិសួគ៌ សូមឲ្យអាត្មាអញ មានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា ឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើតជាសត្វថោកថយ និងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនដោយប្រការដូច្នេះ កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ ក្នុងការដឹងនិងការឃើញនោះៗ ។ បើបុគ្គលនោះប្រាថ្នាថា សូមឲ្យអាត្មាអញ បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រេចសម្រាន្តនៅ កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ ក្នុងការសម្រេចនោះៗ ។

[១០៤] អធិចិត្តមនុយុត្តេន ភិក្ខវេ ភិក្ខុនា តីណិ និមិត្តានិ កាលេន កាលំ មនសិកាតព្វានិ កាលេន កាលំ សមាធិនិមិត្តំ មនសិកាតព្វំ កាលេន កាលំ បគ្គាហនិមិត្តំ មនសិកាតព្វំ កាលេន កាលំ ឧបេក្ខានិមិត្តំ មនសិកាតព្វំ ។ សចេ ភិក្ខវេ អធិចិត្តមនុយុត្តោ ភិក្ខុ ឯកន្តំ សមាធិនិមិត្តំយេវ មនសិករេយ្យ ឋានន្តំ ចិត្តំ កោសជ្ជាយ សំវត្តេយ្យ ។ សចេ ភិក្ខវេ អធិចិត្ត-មនុយុត្តោ ភិក្ខុ ឯកន្តំ បគ្គាហនិមិត្តំយេវ មនសិករេយ្យ ឋានន្តំ ចិត្តំ ឧទ្ធច្ចាយ សំវត្តេយ្យ ។ សចេ ភិក្ខវេ អធិចិត្តមនុយុត្តោ ភិក្ខុ ឯកន្តំ ឧបេក្ខានិមិត្តំយេវ មនសិករេយ្យ ឋានន្តំ ចិត្តំ ន សម្មា សមាធិយេយ្យ អាសវានំ ខយាយ ។ យតោ ខោ ភិក្ខវេ អធិចិត្តមនុយុត្តោ ភិក្ខុ កាលេន កាលំ សមាធិនិមិត្តំ មនសិករោតិ កាលេន កាលំ បគ្គាហនិមិត្តំ មនសិករោតិ

[១០៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបនូវអធិចិត្តហើយ ត្រូវធ្វើទុកក្នុងចិត្តនូវនិមិត្ត ៣ យ៉ាង ក្នុងកាលដ៏គួរ គឺត្រូវធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្ត ក្នុងកាលដ៏គួរ ១ ត្រូវធ្វើទុកក្នុងចិត្តនូវបគ្គាហនិមិត្ត[១] ក្នុងកាលដ៏គួរ ១ ត្រូវធ្វើទុកក្នុងចិត្ត នូវឧបេក្ខានិមិត្ត ក្នុងកាលដ៏គួរ ១ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្តតែមួយចំណែក ហេតុនោះ គប្បីនាំចិត្តអោយប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវបគ្គាហនិមិត្តតែមួយចំណែក ហេតុនោះ គប្បីនាំចិត្តឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីរាយមាយ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្តតែមួយចំណែក ហេតុនោះ គប្បីនាំចិត្តមិនឲ្យតាំងមាំដោយប្រពៃ ដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុអ្នកប្រកបនូវអធិចិត្ត រមែងធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្ត ក្នុងកាលដ៏គួរ ធ្វើទុកក្នុងចិត្តនូវបគ្គាហនិមិត្ត ក្នុងកាលដ៏គួរ

---

១ នេះជាឈ្មោះនៃសេចក្តីព្យាយាម ។ អដ្ឋកថា ។

កាលេន កាលំ ឧបេក្ខានិមិត្តំ មនសិករោតិ តំ ហោតិ ចិត្តំ មុទុញ្ច កម្មនីយញ្ច បភស្សរញ្ច ន ច បភង្គុ សម្មា សមាធិយតិ អាសវានំ ខយាយ ។ សេយ្យថាបិ ភិក្ខវេ សុវណ្ណការោ វា សុវណ្ណការន្តេវាសី វា ឧក្កំ ពន្ធតិ ឧក្កំ ពន្ធិត្វា ឧក្កាមុខំ អាលិម្បេតិ ឧក្កាមុខំ អាលិម្បេត្វា សណ្ឌាសេន ជាតរូបំ គហេត្វា ឧក្កាមុខេ បក្ខិបិត្វា កាលេន កាលំ អភិធមតិ កាលេន កាលំ ឧទកេន បរិប្ផោសេតិ កាលេន កាលំ អជ្ឈុបេក្ខតិ ។ សចេ ភិក្ខវេ សុវណ្ណការោ វា សុវណ្ណការន្តេវាសី វា តំ ជាតរូបំ ឯកន្តំ អភិធមេយ្យ ឋានន្តំ ជាតរូបំ ឌហេយ្យ ។ សចេ ភិក្ខវេ សុវណ្ណការោ វា សុវណ្ណការន្តេវាសី វា តំ ជាតរូបំ ឯកន្តំ ឧទកេន បរិប្ផោសេយ្យ ឋានន្តំ ជាតរូបំ និព្វាបេយ្យ ។ សចេ ភិក្ខវេ សុវណ្ណការោ វា សុវណ្ណការន្តេវាសី វា តំ ជាតរូបំ ឯកន្តំ អជ្ឈុបេក្ខេយ្យ ឋានន្តំ ជាតរូបំ ន សម្មា បរិបាកំ គច្ឆេយ្យ ។

ធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្ត ក្នុងកាលដ៏គួរ ទើបចិត្តនោះក៏ទន់ គួរដល់ភាវនាកម្ម ជាចិត្តភ្លឺផ្លេក មិនរឹង តាំងមាំដោយប្រពៃ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយបាន ។ ម្នាលភិក្ខុទាំងឡាយ ដូចជាជាងមាសក្តី កូនសិស្សជាងមាសក្តី ចាត់ចែងបាវ លុះចាត់ចែងបាវរួចហើយ ក៏ដុតមាត់បាវ កាលដុតមាត់បាវ ក៏យកដង្កៀបចាប់មាសដាក់ក្នុងមាត់បាវ ហើយសប់ក្នុងកាលដ៏គួរ បំព្រំទឹកក្នុងកាលដ៏គួរ សំឡឹងមើលក្នុងកាលដ៏គួរ ។ ម្នាលភិក្ខុទាំងឡាយ បើជាងមាសក្តី កូនសិស្សជាងមាសក្តី គប្បីសប់តែមាសនោះមួយចំណែក នោះជាហេតុធ្វើឲ្យមាសឆេះរលួយទៅ ។ ម្នាលភិក្ខុទាំង-ឡាយ បើជាងមាសក្តី កូនសិស្សជាងមាសក្តី បំព្រំតែមាសនោះដោយទឹកមួយចំណែក នោះជាហេតុធ្វើមាសឲ្យត្រជាក់ ។ ម្នាលភិក្ខុទាំង-ឡាយ បើជាងមាសក្តី កូនសិស្សជាងមាសក្តី សំឡឹងមើលតែមាសនោះមួយចំណែក នោះជាហេតុធ្វើ មិនឲ្យមាសឆ្អិនសព្វសាច់បាន ។

យតោ ខោ ភិក្ខវេ សុវណ្ណការោ វា សុវណ្ណការន្តេវាសី វា តំ ជាតរូបំ កាលេន កាលំ អភិធមតិ កាលេន កាលំ ឧទកេន បរិប្ផោសេតិ កាលេន កាលំ អជ្ឈុបេក្ខតិ តំ ហោតិ ជាតរូបំ មុទុញ្ច កម្មនីយញ្ច បភស្សរញ្ច ន ច បភង្គុ សម្មា ឧបេតិ កម្មាយ យស្សា យស្សា ច បិឡន្ធនវិកតិយា អាកង្ខតិ យទិ បដ្ដិកាយ យទិ កុណ្ឌលាយ យទិ គីវេយ្យកេ យទិ សុវណ្ណមាលាយ តញ្ចស្ស អត្ថំ អនុភោតិ ។ ឯវមេវ ខោ ភិក្ខវេ អធិចិត្តម-នុយុត្តេន ភិក្ខុនា តីណិ និមិត្តានិ កាលេន កាលំ មនសិកាតព្វានិ កាលេន កាលំ សមាធិនិមិត្តំ មនសិកាតព្វំ កាលេន កាលំ បគ្គាហនិមិត្តំ មនសិកាតព្វំ កាលេន កាលំ ឧបេក្ខានិមិត្តំ មនសិកាតព្វំ ។ សចេ ភិក្ខវេ អធិចិត្តមនុយុត្តោ ភិក្ខុ ឯកន្តំ សមាធិនិមិត្តំយេវ មនសិករេយ្យ ឋានន្តំ ចិត្តំ កោសជ្ជាយ សំវត្តេយ្យ ។

ម្នាលភិក្ខុទាំងឡាយ កាលណា ជាងមាសក្តី កូនសិស្សជាងមាសក្តី សប់មាសនោះ ក្នុងកាលដ៏គួរ បំព្រំដោយទឹក ក្នុងកាលដ៏គួរ សំឡឹងមើល ក្នុងកាលដ៏គួរហើយ ទើបមាសនោះ ទៅជាមាសទន់ គួរដល់ការងារ ជាមាសមានសម្បុរភ្លឺផ្លេក មិនស្រួយ គួរបង្អោនទៅ ដើម្បីការងារដោយប្រពៃផង បើគេប្រាថ្នាគ្រឿងប្រដាប់ប្លែកៗ ណាៗ ទោះជាដំបារមាសក្តី កណ្ឋលក្តី គ្រឿងប្រដាប់ក្តី កម្រងមាសក្តី រមែងសម្រេចប្រយោជន៍នោះៗបាន (យ៉ាងណាមិញ) ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្តត្រូវធ្វើទុកក្នុងចិត្តនូវនិមិត្ត ៣ យ៉ាង ក្នុងកាលដ៏គួរ គឺត្រូវធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្ត ក្នុងកាលដ៏គួរ ១ ត្រូវធ្វើទុកក្នុងចិត្តនូវបគ្គាហនិមិត្ត ក្នុងកាលដ៏គួរ ១ ត្រូវធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្ត ក្នុងកាលដ៏គួរ ១ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបនូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្ត តែមួយចំណែកហេតុនោះ គប្បីនាំចិត្តឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស ។

សចេ ភិក្ខវេ អធិចិត្តមនុយុត្តោ ភិក្ខុ ឯកន្តំ បគ្គាហនិមិត្តំយេវ មនសិករេយ្យ ឋានន្តំ ចិត្តំ ឧទ្ធច្ចាយ សំវត្តេយ្យ ។ សចេ ភិក្ខវេ អធិចិត្តមនុយុត្តោ ភិក្ខុ ឯកន្តំ ឧបេក្ខានិមិត្តំយេវ មនសិករេយ្យ ឋានន្តំ ចិត្តំ ន សម្មា សមាធិយេយ្យ អាសវានំ ខយាយ ។ យតោ ខោ ភិក្ខវេ អធិចិត្តមនុយុត្តោ ភិក្ខុ កាលេន កាលំ សមាធិនិមិត្តំ មនសិករោតិ កាលេន កាលំ បគ្គាហនិមិត្តំ មនសិករោតិ កាលេន កាលំ ឧបេក្ខានិមិត្តំ មនសិករោតិ តំ ហោតិ ចិត្តំ មុទុញ្ច កម្មនីយញ្ច បភស្សរញ្ច ន ច បភង្គុ សម្មា សមាធិយតិ អាសវានំ ខយាយ យស្ស យស្ស ច អភិញ្ញាសច្ឆិករណីយស្ស ធម្មស្ស ចិត្តំ អភិនិន្នាមេតិ អភិញ្ញាសច្ឆិកិរិយាយ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេ ។

ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្ត នូវបគ្គាហនិមិត្ត តែមួយចំណែក ហេតុនោះ គប្បីនាំចិត្តឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីរាយមាយ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត គប្បីធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្ត តែមួយចំណែក ហេតុនោះ គប្បីនាំចិត្តមិនឲ្យតាំងមាំដោយប្រពៃ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ លុះណាតែភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត ធ្វើទុកក្នុងចិត្តនូវសមាធិនិមិត្ត ក្នុងកាលដ៏គួរ ធ្វើទុកក្នុងចិត្តនូវបគ្គាហនិមិត្ត ក្នុងកាលដ៏គួរ ធ្វើទុកក្នុងចិត្តនូវឧបេក្ខានិមិត្ត ក្នុងកាលដ៏គួរ ទើបចិត្តនោះរមែងទៅជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តភ្លឺផ្លេក មិនរឹង តាំងមាំដោយប្រពៃ ដើម្បីអស់ទៅនៃអាសវៈទាំងឡាយ បុគ្គលបង្អោនទៅនូវចិត្ត ដើម្បីធម៌ដែលត្រូវធ្វើអោយជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តមណាៗ កាលបើហេតុមាន រមែងដល់នូវភាពគួរជាបន្ទាល់ក្នុងធម៌នោះ ៗ ដើម្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ។

៣៨៩



សោ សចេ អាកង្ខតិ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភវេយ្យំ ។ បេ ។ អាសវានំ ខយា... សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ តត្រ តត្រេវ សក្ខិភព្វតំ បាបុណាតិ សតិ សតិ អាយតនេតិ ។

លោណផលវគ្គោ បញ្ចមោ ។

## តស្សុទ្ទានំ

អច្ចាយិកំ វិវេកញ្ច
សរទា បរិសា តិស្សោ
តយោ អាជានីយា វេ
លោណកោ សង្ឃសមុគ្គតាតិ ។

ទុតិយោ បណ្ណាសកោ សមត្តោ ។

បើបុគ្គលនោះប្រាថ្នាថា សូមឲ្យអាត្មាអញបានចំពោះ នូវការតាក់តែង ឫទ្ធិ ជាច្រើនប្រការ ។ បេ ។ សូមឲ្យអាត្មាអញអស់អាសវៈ... ធ្វើឲ្យជាក់ច្បាស់សម្រេចសម្រាន្តនៅ កាលបើហេតុមាន (បុគ្គលនោះ) រមែងដល់នូវភាពគួរជាបន្ទាល់ ក្នុងគុណនោះ ៗ មិនខាន ។

ចប់ លោណផលវគ្គ ទី ៥ ។

# ឧទ្ទាននៃលោណផលវគ្គនោះគឺ

និយាយពីកិច្ចដែលត្រូវធ្វើយ៉ាងរួសរាន់ ១ ការស្ងប់ស្ងាត់ ១ ធម្មចក្ខុកើតឡើងដូចព្រះអាទិត្យក្នុងសរទសម័យ ១ បរិសទ្យ ៣ ពួក ១ ភិក្ខុប្រកបដោយធម៌ ៣ ដូចសេះអាជានេយ្យ មាន ៣ លើក ១ បាបកម្មដូចជាអំបិល ១ គុណសម្បត្តិដ៏ខ្ពង់-ខ្ពស់របស់ភិក្ខុសង្ឃ ១ ។

ចប់ បណ្ណាសកទី ២ ។

# សម្ពោធិវគ្គោ

[១០៤] បុព្វេ មេ ភិក្ខវេ សម្ពោធា អនភិ-
សម្ពុទ្ធស្ស ពោធិសត្តស្សេវ សតោ ឯតទហោសិ
កោ នុ ខោ លោកេ អស្សាទោ កោ អាទីនវោ
កឹ និស្សរណន្តិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទ-
ហោសិ យំ ខោ លោកេ បដិច្ច ឧប្បជ្ជតិ សុខំ
សោមនស្សំ អយំ លោកេ អស្សាទោ យំ លោកោ
អនិច្ចោ ទុក្ខោ វិបរិណាមធម្មោ អយំ លោកេ
អាទីនវោ យោ លោកេ ឆន្ទរាគប្បដិវិនយោ
ឆន្ទរាគប្បហានំ ឥទំ លោកេ និស្សរណន្តិ ។
យាវកីវញ្ចាហំ ភិក្ខវេ ឯវំ លោកស្ស អស្សាទញ្ច
អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរ-
ណញ្ច និស្សរណតោ យថាភូតំ នាព្ភញ្ញាសឹ

# សម្ពោធិវគ្គ

[១០៥] ម្នាលភិក្ខុទាំងឡាយ កាលមុននឹងត្រាស់ដឹង តថាគត នៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ មានសេចក្ដីត្រិះរិះដូច្នេះថា អានិសង្សដូចម្ដេច ទោសដូចម្ដេច ការរលាស់ខ្លួនចេញដូចម្ដេច ក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្ដីត្រិះរិះដូច្នេះថា សភាវៈណាកើតឡើងព្រោះអាស្រ័យសេចក្ដីសុខ សោមនស្ស ក្នុងលោក សភាវៈនេះឈ្មោះថាជាអានិសង្សក្នុងលោក សភាវៈណាមិនទៀងជាទុក្ខ មានសេចក្ដីប្រែប្រួលទៅ ជាធម្មតា សភាវៈនេះឈ្មោះថាជាទោសក្នុងលោក សភាវៈណាជាគ្រឿងបន្ទោបង់នូវឆន្ទរាគ ជាគ្រឿងលះបង់នូវឆន្ទរាគក្នុងលោក សភាវៈនេះឈ្មោះថា ជាការរលាស់ខ្លួនចេញ ក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ តថាគតនៅមិនទាន់ត្រាស់ដឹង តាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោក ថាជាការរលាស់ខ្លួនចេញផង យ៉ាងនេះ ត្រឹមណា

នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។ យតោ ច ខោហំ ភិក្ខវេ ឯវំ លោកស្ស អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ អព្ភញ្ញាសឹ អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ[១] អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

[១០៦] លោកស្សាហំ ភិក្ខវេ អស្សាទបរិយេសនំ អាចរឹ យោ លោកេ អស្សាទោ តទជ្ឈគមំ យាវតកោ លោកេ អស្សាទោ បញ្ញាយ មេ សោ សុទិដ្ឋោ ។ លោកស្សាហំ ភិក្ខវេ អាទីនវបរិយេសនំ អាចរឹ

១ ឱ. ម. អកុប្បា មេ ចេតោវិមុត្តិ ។

ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិនប្តេជ្ញាថា ជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេសត្រឹមណោះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែតថាគតបានត្រាស់ដឹងតាមពិតនូវអានិសង្សថាជាអានិសង្សផងនូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថាជាការរលាស់ខ្លួនចេញផង យ៉ាងនេះ ក្នុងកាលណា ម្នាលភិក្ខុទាំងឡាយ ទើបតថាគតប្តេជ្ញាថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស ក្នុងកាលណោះ ។ ទាំងការដឹងនិងការឃើញ ក៏កើតឡើងដល់តថាគតថា ការរួចស្រឡះរបស់តថាគតមិនកម្រើកទេ ជាតិនេះជាទីបំផុត ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ។

[១០៦] ម្នាលភិក្ខុទាំងឡាយ តថាគតត្រាច់ ស្វែងរកអានិសង្សរបស់លោក សភាវៈណាជាអានិសង្ស ក្នុងលោក តថាគតក៏បានជួបប្រទះនូវសភាវៈនោះ អានិសង្សទាំងអម្បាលមាណ ក្នុងលោក អានិសង្សនោះ តថាគតឃើញច្បាស់ហើយដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតត្រាច់ ស្វែងរកទោសរបស់លោក

យោ លោកេ អាទីនវោ តទជ្ឈគមំ យាវតកោ លោកេ អាទីនវោ បញ្ញាយ មេ សោ សុទិដ្ឋោ ។ លោកស្សាហំ ភិក្ខវេ និស្សរណបរិយេសនំ អាចរឹ យំ លោកេ និស្សរណំ តទជ្ឈគមំ យាវតកំ លោកេ និស្សរណំ បញ្ញាយ មេ តំ សុទិដ្ឋំ ។ យាវកីវញ្ចាហំ ភិក្ខវេ លោកស្ស អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ ជាព្ភញ្ញាសឹ នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវ-មនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។ យតោ ច ខោហំ ភិក្ខវេ លោកស្ស អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ អព្ភញ្ញាសឹ

សភាវៈឯណាជាទោសក្នុងលោក តថាគតក៏បានចូលប្រទះនូវសភាវៈនោះ ទោសទាំងអម្បាលមាណ ក្នុងលោក ទោសនោះ តថាគតឃើញច្បាស់ ហើយដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគតត្រាច់ ស្វែងរក នូវការរលាស់ខ្លួន ចេញចាកលោក ធម្មជាតណាជាការរលាស់ខ្លួន ចេញក្នុងលោក តថាគតក៏បានចូលប្រទះធម្មជាតនោះ ការរលាស់ខ្លួន ចេញទាំងអម្បាលមាណ ក្នុងលោក ការរលាស់ខ្លួនចេញនោះ តថាគត ក៏បានឃើញច្បាស់ហើយដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ តថាគត មិនទាន់ត្រាស់ដឹងតាមពិត នូវអានិសង្សថាជាអានិសង្សផង នូវទោស ថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថា ជាការរលាស់ ខ្លួនចេញផង ដរាបណា ម្នាលភិក្ខុទាំងឡាយ តថាគតក៏មិន ទាន់ប្តេជ្ញាថាជាអ្នកត្រាស់ដឹង នូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំង សមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ដរាប នោះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែតថាគត បានត្រាស់ដឹងតាមពិត នូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ ខ្លួនចេញចាកលោកថា ជាការរលាស់ខ្លួនចេញផង ក្នុងកាលណា

អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ វិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

[១០៧] នោ ចេតំ ភិក្ខវេ លោកេ អស្សាទោ អភវិស្ស នយិទំ សត្តា លោកេ សារជ្జេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ លោកេ អស្សាទោ តស្មា សត្តា លោកេ សារជ្ជន្តិ ។ នោ ចេតំ ភិក្ខវេ លោកេ អាទីនវោ អភវិស្ស

ម្នាលភិក្ខុទាំងឡាយ ទើបតថាគតប្ដេជ្ញាថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មា-សម្ពោធិញ្ញាណ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ក្នុងកាលនោះ ។ ទាំងការដឹងនិងការឃើញ ក៏កើតឡើងដល់តថាគតថា ការរួចស្រឡះរបស់តថាគត មិនកម្រើកទេ ជាតិនេះជាទីបំផុត ឥឡូវនេះ ភពថ្មីទៀត មិនមានឡើយ ។

[១០៧] ម្នាលភិក្ខុទាំងឡាយ បើអានិសង្សនុ៎ះ មិនមានក្នុងលោក ពួកសត្វក៏មិនគប្បីត្រេកត្រអាលនឹងអានិសង្សនេះក្នុងលោកដែរ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែអានិសង្សមាននៅក្នុងលោក ពួកសត្វទើបត្រេកត្រអាលក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បើទោសក្នុងលោកមិនមានទេ

ឆយិជំ សត្តា លោកេ ធិព្វិន្ទេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ លោកេ អាធីនវោ តស្មា សត្តា លោកេ ធិព្វិន្ទន្តិ ។ នោ ចេតំ ភិក្ខវេ លោកេ ធិស្សរណំ អភវិស្ស ឆយិជំ សត្តា លោកម្ហា ធិស្សរេយ្យុំ យស្មា ច ខោ ភិក្ខវេ អត្ថិ លោកេ ធិស្សរណំ តស្មា សត្តា លោកម្ហា ធិស្សរន្តិ ។ យាវកីវញ្ច ភិក្ខវេ សត្តា លោកស្ស អស្សាទញ្ច អស្សាទតោ អាធីនវញ្ច អាធីនវតោ ធិស្សរណញ្ច ធិស្សរណតោ យថាភូតំ ឆាព្ភញ្ញាសុំ ធេវ តាវ ភិក្ខវេ សត្តា សទេវកា លោកា សមារកា សព្រហ្មកា សស្សមណ-ព្រាហ្មណិយា បជាយ សទេវមនុស្សាយ ធិស្សដា វិសំយុត្តា វិប្បមុត្តា វិមរិយាទីកតេន ចេតសា វិហរឹសុ ។ យតោ ច ខោ ភិក្ខវេ សត្តា លោកស្ស អស្សាទញ្ច អស្សាទតោ អាធីនវញ្ច អាធីនវតោ ធិស្សរណញ្ច ធិស្សរណតោ យថាភូតំ អព្ភញ្ញាសុំ

ពួកសត្វក៏មិនគប្បីនឿយណាយនឹងទោសនេះក្នុងលោកដែរ ម្នាលភិក្ខុទាំង-ឡាយ ព្រោះហេតុតែទោសមាននៅក្នុងលោក ទើបពួកសត្វនឿយណាយក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បើការរលាស់ខ្លួនចេញនុ៎ះ មិនមានក្នុងលោកទេ ពួកសត្វក៏មិនគប្បីរលាស់ខ្លួននេះ ចេញចាកលោកបានដែរ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែការរលាស់ខ្លួនចេញមាននៅក្នុងលោក ទើបពួកសត្វរលាស់ខ្លួនចេញចាកលោកបាន ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមិនទាន់ដឹងច្បាស់ តាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថា ជាការរលាស់ខ្លួនចេញផង ដរាបណា ម្នាលភិក្ខុទាំងឡាយ សត្វមិនទាន់ប្រាសចេញ មិនទាន់គេចចេញ មិនទាន់រួចផុតស្រឡះចាកលោកព្រមទាំងទេវ-លោក មារលោក ព្រហ្មលោក ចាកពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេស មានចិត្តមិនទាន់ប្រាសចាកព្រំដែនដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែពួកសត្វដឹងច្បាស់តាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថា ជាការរលាស់ខ្លួនចេញផង ក្នុងកាលណា

អថ ភិក្ខវេ សត្តា សទេវកា លោកា សមារកា សព្រហ្មកា សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ និស្សដា វិសំយុត្តា វិប្បមុត្តា វិមរិយាទីកតេន ចេតសា វិហរន្តីតិ ។

[១០៨] យេ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា លោកស្ស អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ នប្បជានន្តិ ន មេ តេ ភិក្ខវេ សមណា វា ព្រាហ្មណា វា សមណេសុ វា សមណ-សម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា ន ច បន តេ អាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្ម-ញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តិ ។ យេ ច ខោ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា លោកស្ស អស្សាទញ្ច អស្សាទតោ អាទីនវញ្ច អាទីនវតោ និស្សរណញ្ច និស្សរណតោ យថាភូតំ បជានន្តិ តេ ខោ មេ ភិក្ខវេ សមណា វា ព្រាហ្មណា វា

ម្នាលភិក្ខុទាំងឡាយ ពួកសត្វទើបប្រាសចេញ គេចចេញ រួចផុតស្រឡះ ចាកលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ចាកពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសមានចិត្តប្រាសចាកព្រំដែនក្នុងកាលនោះ ។

[១០៨] ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ មិនដឹងច្បាស់តាមពិតនូវអានិសង្សថា ជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថា ជាការរលាស់ខ្លួនចេញផង ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ទាំងនោះ តថាគតមិនសន្មតថាជាសមណៈក្នុងពួកសមណៈ មិនសន្មតថាជាព្រាហ្មណ៍ក្នុងពួកព្រាហ្មណ៍ទេ ដ្បិតថា អ្នកមានអាយុទាំងនោះ មិនទាន់ធ្វើឲ្យជាក់ច្បាស់នូវប្រយោជន៍ ជារបស់សមណៈផង នូវប្រយោជន៍ ជារបស់ព្រាហ្មណ៍ផង ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ។ ម្នាលភិក្ខុទាំងឡាយ លុះតែពួកសមណៈ ឬ ព្រាហ្មណ៍ណាមួយដឹងច្បាស់ តាមពិតនូវអានិសង្សថាជាអានិសង្សផង នូវទោសថាជាទោសផង នូវការរលាស់ខ្លួនចេញចាកលោកថាជាការរលាស់ខ្លួនចេញផង ម្នាលភិក្ខុទាំងឡាយ ពួកសមណៈ ឬ ព្រាហ្មណ៍ទាំងនោះ តថាគត សន្មតថា

សមណេសុ វា សមណសម្មតា ព្រាហ្មណេសុ វា ព្រាហ្មណសម្មតា តេ ច បនាយស្មន្តោ សាមញ្ញត្ថញ្ច ព្រហ្មញ្ញត្ថញ្ច ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរន្តីតិ ។

[១០៩] រុណ្ណមិទំ ភិក្ខវេ អរិយស្ស វិនយេ យទិទំ គីតំ ឧម្មត្តកមិទំ ភិក្ខវេ អរិយស្ស វិនយេ យទិទំ នច្ចំ កោមារិកមិទំ ភិក្ខវេ អរិយស្ស វិនយេ យទិទំ អតិវេលំ ទន្តវិទំសកហសិតំ ។ តស្មាតិហ ភិក្ខវេ សេតុឃាតោ គីតេ សេតុឃាតោ នច្ចេ អលំ វោ ធម្មប្បមោទិតានំ សតំ សិតំ សិតមត្តាយាតិ ។

[១១០] តិណ្ណំ ភិក្ខវេ បដិសេវនាយ នត្ថិ តិត្តិ ។ កតមេសំ តិណ្ណំ ។ សុប្បស្ស ភិក្ខវេ បដិសេវនាយ នត្ថិ តិត្តិ សុរាមេរយបានស្ស ភិក្ខវេ បដិសេវនាយ នត្ថិ តិត្តិ មេថុនធម្មសមាបត្តិយា ភិក្ខវេ បដិសេវនាយ នត្ថិ តិត្តិ ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ បដិសេវនាយ នត្ថិ តិត្តីតិ ។

ជាសមណៈ ក្នុងពួកសមណៈ សន្មតថាជាព្រាហ្មណ៍ ក្នុងពួកព្រាហ្មណ៍ ដ្បិតថា អ្នកមានអាយុទាំងនោះ ធ្វើឲ្យជាក់ច្បាស់នូវប្រយោជន៍ ជារបស់សមណៈផង នូវប្រយោជន៍ ជារបស់ព្រាហ្មណ៍ផង ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ ។

[១០៩] ម្នាលភិក្ខុទាំងឡាយ ការច្រៀងទុកដូចជាការយំ ក្នុងអរិយវិន័យ ម្នាលភិក្ខុទាំងឡាយ ការរាំទុកដូចជាការឆ្កួត ក្នុងអរិយវិន័យ ម្នាលភិក្ខុទាំងឡាយ ការសើចក្អាកក្អាយ បញ្ចេញធ្មេញឲ្យកន្លងហួសវេលា ទុកដូចជាល្បែងក្មេង ក្នុងអរិយវិន័យ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរបំបាក់ស្ពានក្នុងការច្រៀង ចូរបំបាក់ស្ពានក្នុងការរាំចេញ កាលអ្នកទាំងឡាយ មានសេចក្តីរីករាយ ក្នុងហេតុ (ណាមួយ) គ្រាន់តែសម្តែងអាការញញឹមប៉ុណ្ណោះល្មមហើយ ។

[១១០] ម្នាលភិក្ខុទាំងឡាយ ការសេពចំពោះធម៌ ៣ យ៉ាងមិនចេះឆ្អែតឆ្អន់ទេ ។ ៣ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺសេពនូវការដេកលក់មិនចេះឆ្អែត ១ ម្នាលភិក្ខុទាំងឡាយ ការសេពគ្រឿងផឹក គឺសុរានិងមេរ័យ មិនចេះឆ្អែត ១ ម្នាលភិក្ខុទាំងឡាយ ការសេពចំពោះការប្រកបដោយមេថុនធម្ម មិនចេះឆ្អែត ១ ។ ម្នាលភិក្ខុទាំងឡាយ ការសេពចំពោះធម៌ ៣ យ៉ាងនេះ មិនចេះឆ្អែតឡើយ ។

៣៩៧



[១១១] អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថបិណ្ឌិកំ គហបតឹ ភគវា ឯតទវោច ចិត្តេ គហបតិ អរក្ខិតេ កាយកម្មម្បិ អរក្ខិតំ ហោតិ វចីកម្មម្បិ អរក្ខិតំ ហោតិ មនោកម្មម្បិ អរក្ខិតំ ហោតិ ។ តស្ស អរក្ខិតកាយកម្មស្ស អរក្ខិតវចីកម្មស្ស អរក្ខិតមនោកម្មស្ស កាយកម្មម្បិ អវស្សុតំ ហោតិ វចីកម្មម្បិ អវស្សុតំ ហោតិ មនោកម្មម្បិ អវស្សុតំ ហោតិ ។ តស្ស អវស្សុតកាយកម្មស្ស អវស្សុតវចីកម្មស្ស អវស្សុតមនោកម្មស្ស កាយកម្មម្បិ បូតិកំ ហោតិ វចីកម្មម្បិ បូតិកំ ហោតិ មនោកម្មម្បិ បូតិកំ ហោតិ ។ តស្ស បូតិកាយកម្មស្ស បូតិវចីកម្មស្ស បូតិមនោកម្មស្ស ន ភទ្ទកំ មរណំ ហោតិ ន ភទ្ទិកា កាលកិរិយា ។ សេយ្យថាបិ គហបតិ កូដាគារេ ទុច្ឆន្នេ

[១១១] គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី កាលបើចិត្តដែលបុគ្គលមិនបានរក្សាហើយ កាយកម្មក៏ឈ្មោះថា មិនបានរក្សាផង វចីកម្មក៏ឈ្មោះថា មិនបានរក្សាផង មនោកម្មក៏ឈ្មោះថា មិនបានរក្សាផងដែរ ។ កាលបុគ្គលនោះមិនរក្សាកាយកម្ម មិនរក្សាវចីកម្ម មិនរក្សាមនោកម្ម កាយកម្មឈ្មោះថាជោក វចីកម្មក៏ឈ្មោះថាជោក មនោកម្មក៏ឈ្មោះថាជោក (ដោយរាគាទិក្កិលេស) ។ កាលបុគ្គលនោះ មានកាយកម្មជោក មានវចីកម្មជោក មានមនោកម្មជោកដោយរាគាទិក្កិលេសហើយ កាយកម្មក៏ឈ្មោះថា ស្អុយផង វចីកម្មក៏ឈ្មោះថា ស្អុយផង មនោកម្មក៏ឈ្មោះថា ស្អុយផងដែរ ។ កាលបុគ្គលនោះមានកាយកម្មស្អុយ មានវចីកម្មស្អុយ មានមនោកម្មស្អុយហើយ មរណៈ (បុគ្គលនោះ) មិនល្អទេ កាលកិរិយាក៏មិនល្អទេ ។ ម្នាលគហបតី ដូចជាផ្ទះមានកំពូល ដែលបុគ្គលប្រក់មិនជិត

ក្វចម្បិ អរក្ខិតំ ហោតិ គោចាណសិយោបិ អរក្ខិតា ហោន្តិ ភិត្តិបិ អរក្ខិតា ហោតិ ក្វចម្បិ អវស្សុតំ ហោតិ គោចាណសិយោបិ អវស្សុតា ហោន្តិ ភិត្តិបិ អវស្សុតា ហោតិ ក្វចម្បិ បូតិកំ ហោតិ គោចាណសិយោបិ បូតិកា ហោន្តិ ភិត្តិបិ បូតិកា ហោតិ ឯវមេវ ខោ គហបតិ ចិត្តេ អរក្ខិតេ ។ បេ ។ ន ភទ្ទកំ មរណំ ហោតិ ន ភទ្ទិកា កាលកិរិយា ។ ចិត្តេ គហបតិ រក្ខិតេ កាយកម្មម្បិ រក្ខិតំ ហោតិ វចីកម្មម្បិ រក្ខិតំ ហោតិ មនោកម្មម្បិ រក្ខិតំ ហោតិ តស្ស រក្ខិតកាយកម្មស្ស រក្ខិតវចីកម្មស្ស រក្ខិតមនោកម្មស្ស កាយកម្មម្បិ អនវស្សុតំ ហោតិ វចីកម្មម្បិ អនវស្សុតំ ហោតិ មនោកម្មម្បិ អនវស្សុតំ ហោតិ ។ តស្ស អនវស្សុតកាយកម្មស្ស អនវស្សុតវចីកម្មស្ស អនវស្សុតមនោកម្មស្ស កាយកម្មម្បិ អបូតិកំ ហោតិ វចីកម្មម្បិ អបូតិកំ ហោតិ មនោកម្មម្បិ អបូតិកំ ហោតិ ។ តស្ស អបូតិកាយកម្មស្ស អបូតិវចីកម្មស្ស អបូតិមនោកម្មស្ស

កំពូលក៏រក្សាទុកមិនបាន បង្គង់ក៏រក្សាទុកមិនបាន ជញ្ជាំងក៏រក្សាទុកមិន បាន កំពូលក៏ទទឹកជោក បង្គង់ក៏ទទឹកជោក ជញ្ជាំងក៏ទទឹកជោក កំពូលក៏ ពុក បង្គង់ក៏ពុក ជញ្ជាំងក៏ពុក យ៉ាងណា ម្នាលគហបតី កាលបើចិត្តដែល បុគ្គលមិនរក្សាហើយ ។ បេ ។ មរណៈក៏មិនល្អទេ កាលកិរិយាក៏មិនល្អទេ យ៉ាងនោះដែរ ។ ម្នាលគហបតី កាលបើចិត្តដែលបុគ្គលរក្សាហើយ កាយកម្មក៏ឈ្មោះថា បានរក្សា វចីកម្មក៏ឈ្មោះថា បានរក្សា មនោកម្មក៏ ឈ្មោះថា បានរក្សាដែរ កាលបុគ្គលនោះ រក្សាកាយកម្ម រក្សាវចីកម្ម រក្សាមនោកម្ម កាយកម្មក៏ឈ្មោះថា មិនជោក វចីកម្មក៏ឈ្មោះថា មិនជោក មនោកម្មក៏ឈ្មោះថា មិនជោក ដោយរាគាទិក្កិលេស ។ កាលបុគ្គល នោះ មានកាយកម្មមិនជោក មានវចីកម្មមិនជោក មានមនោកម្មមិន ជោក ដោយរាគាទិក្កិលេសហើយ កាយកម្ម (របស់បុគ្គលនោះ) ក៏មិន ស្អុយ វចីកម្មក៏មិនស្អុយ មនោកម្មក៏មិនស្អុយដែរ ។ កាលបុគ្គលនោះ មានកាយកម្មមិនស្អុយ មានវចីកម្មមិនស្អុយ មានមនោកម្មមិនស្អុយ

ភទ្ទកំ មរណំ ហោតិ ភទ្ទិកា កាលកិរិយា ។ សេយ្យថាបិ គហបតិ កូដាគារេ សុច្ឆន្នេ កូដម្បិ រក្ខិតំ ហោតិ គោបានសិយោបិ រក្ខិតា ហោន្តិ ភិត្តិបិ រក្ខិតា ហោតិ កូដម្បិ អនវស្សុតំ ហោតិ គោបានសិយោបិ អនវស្សុតា ហោន្តិ ភិត្តិបិ អនវស្សុតា ហោតិ កូដម្បិ អបតិតំ ហោតិ គោបានសិយោបិ អបតិតា ហោន្តិ ភិត្តិបិ អបតិតា ហោតិ ឯវមេវ ខោ គហបតិ ចិត្តេ រក្ខិតេ ។ បេ ។ ភទ្ទកំ មរណំ ហោតិ ភទ្ទិកា កាលកិរិយាតិ ។

[១១២] អថខោ អនាថបិណ្ឌិកោ គហបតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អនាថ-បិណ្ឌិកំ គហបតឹ ភគវា ឯតទវោច ចិត្តេ គហបតិ ព្យាបន្នេ កាយកម្មម្បិ ព្យាបន្នំ ហោតិ វចីកម្មម្បិ ព្យាបន្នំ ហោតិ មនោកម្មម្បិ ព្យាបន្នំ ហោតិ ។ តស្ស ព្យាបន្នកាយកម្មស្ស ព្យាបន្នវចីកម្មស្ស ព្យាបន្នមនោ-កម្មស្ស ន ភទ្ទកំ មរណំ ហោតិ ន ភទ្ទិកា កាលកិរិយា ។ សេយ្យថាបិ គហបតិ កូដាគារេ

មរណៈ(របស់បុគ្គលនោះ)ក៏ល្អ កាលកិរិយាក៏ល្អ ។ ម្នាលគហបតី ដូចជាផ្ទះមានកំពូល ដែលបុគ្គលប្រក់ជិតល្អហើយ កំពូលក៏រក្សាទុកបាន បង្កង់ក៏រក្សាទុកបាន ជញ្ជាំងក៏រក្សាទុកបាន កំពូលក៏មិនទទឹកជោក បង្កង់ក៏មិនទទឹកជោក ជញ្ជាំងក៏មិនទទឹកជោក កំពូលក៏មិនពុក បង្កង់ក៏មិនពុក ជញ្ជាំងក៏មិនពុក យ៉ាងណា ម្នាលគហបតី កាលបើចិត្តដែលបុគ្គលរក្សាហើយ ។ បេ ។ មរណៈក៏ល្អ កាលកិរិយាក៏ល្អ យ៉ាងនោះដែរ ។

[១១២] គ្រានោះអនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី កាលបើចិត្តព្យាបាទហើយ កាយកម្មក៏ព្យាបាទតាមដែរ វចីកម្មក៏ព្យាបាទតាមដែរ មនោកម្មក៏ព្យាបាទតាមដែរ ។ កាលបុគ្គលនោះ មានកាយកម្មប្រកបដោយព្យាបាទ មានវចីកម្មប្រកបដោយព្យាបាទ មានមនោកម្មប្រកបដោយព្យាបាទហើយ មរណៈ (របស់បុគ្គលនោះ) ក៏មិនល្អទេ កាលកិរិយាក៏មិនល្អទេ ។ ម្នាលគហបតី ដូចជាផ្ទះមានកំពូល

ទុច្ឆន្នេ កូដម្បិ ព្យាបន្នំ ហោតិ គោបាណសិយោបិ ព្យាបន្នា ហោន្តិ ភិត្តិបិ ព្យាបន្នា ហោតិ ឯវមេវ ខោ គហបតិ ចិត្តេ ព្យាបន្នេ ។ បេ ។ ន ភទ្ទកំ មរណំ ហោតិ ន ភទ្ទិកា កាលកិរិយា ។ ចិត្តេ គហបតិ អព្យាបន្នេ កាយកម្មម្បិ អព្យាបន្នំ ហោតិ វចីកម្មម្បិ អព្យាបន្នំ ហោតិ មនោកម្មម្បិ អព្យាបន្នំ ហោតិ ។ តស្ស អព្យាបន្នកាយកម្មស្ស អព្យាបន្នវចីកម្មស្ស អព្យាបន្នមនោកម្មស្ស ភទ្ទកំ មរណំ ហោតិ ភទ្ទិកា កាលកិរិយា ។ សេយ្យថាបិ គហបតិ កូដាគារេ សុច្ឆន្នេ កូដម្បិ អព្យាបន្នំ ហោតិ គោបាណសិយោបិ អព្យាបន្នា ហោន្តិ ភិត្តិបិ អព្យាបន្នា ហោតិ ឯវមេវ ខោ គហបតិ ចិត្តេ អព្យាបន្នេ ។ បេ ។ ភទ្ទកំ មរណំ ហោតិ ភទ្ទិកា កាលកិរិយាតិ ។

[១១៣] តីណីមានិ ភិក្ខវេ និទានានិ កម្មានំ សមុទយាយ ។ កតមានិ តីណិ ។ លោភោ និទានំ

ដែលបុគ្គលប្រក់មិនជិត កំពូលក៏ខូចផង បង្កង់ក៏ខូចផង ជញ្ជាំងក៏ខូចផង ម្នាលគហបតី កាលបើចិត្តព្យាបាទហើយ ។ បេ ។ មរណៈក៏មិនល្អ កាលកិរិយាក៏មិនល្អ ដូច្នោះដែរ ។ ម្នាលគហបតី កាលបើចិត្ត មិនព្យាបាទ ហើយកាយកម្មក៏មិនព្យាបាទតាម វចីកម្មក៏មិនព្យាបាទតាម មនោកម្មក៏មិនព្យាបាទតាម ។ កាលបុគ្គលនោះ មានកាយកម្ម មិនប្រកបដោយព្យាបាទ មានវចីកម្ម មិនប្រកបដោយព្យាបាទ មានមនោកម្ម មិនប្រកបដោយព្យាបាទហើយ មរណៈក៏ល្អ កាលកិរិយាក៏ល្អ ។ ម្នាលគហបតី ដូចជាផ្ទះមានកំពូល ដែលបុគ្គលប្រក់ជិត កំពូលក៏មិនខូចផង បង្កង់ក៏មិនខូចផង ជញ្ជាំងក៏មិនខូចផង ម្នាលគហបតី កាលបើចិត្តមិនព្យាបាទហើយ ។ បេ ។ មរណៈក៏ល្អ កាលកិរិយាក៏ល្អ ដូច្នោះដែរ ។

[១១៣] ម្នាលភិក្ខុទាំងឡាយ ហេតុនោះមាន ៣ យ៉ាង នៃការកើតឡើងនៃកម្ម ។ ហេតុ ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺលោភៈ ជាហេតុ

## ៤០១



កម្មានំ សមុទយាយ ទោសោ និទានំ កម្មានំ សមុទយាយ មោហោ និទានំ កម្មានំ សមុទយាយ ។ យំ ភិក្ខវេ លោភប្បកតំ កម្មំ លោភជំ លោភនិទានំ លោភសមុទយំ តំ កម្មំ អកុសលំ តំ កម្មំ សាវជ្ជំ តំ កម្មំ ទុក្ខវិបាកំ តំ កម្មំ កម្មសមុទយាយ សំវត្តតិ ន តំ កម្មំ កម្មនិរោធាយ សំវត្តតិ ។ យំ ភិក្ខវេ ទោសប្បកតំ កម្មំ ទោសជំ ទោសនិទានំ ទោសសមុទយំ តំ កម្មំ អកុសលំ តំ កម្មំ សាវជ្ជំ តំ កម្មំ ទុក្ខវិបាកំ តំ កម្មំ កម្មសមុទយាយ សំវត្តតិ ន តំ កម្មំ កម្មនិរោធាយ សំវត្តតិ ។ យំ ភិក្ខវេ មោហប្បកតំ កម្មំ មោហជំ មោហនិទានំ មោហសមុទយំ តំ កម្មំ អកុសលំ តំ កម្មំ សាវជ្ជំ តំ កម្មំ ទុក្ខវិបាកំ តំ កម្មំ កម្មសមុទយាយ សំវត្តតិ ន តំ កម្មំ កម្មនិរោធាយ សំវត្តតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ និទានានិ កម្មានំ សមុទយាយ ។ តីណីមានិ ភិក្ខវេ និទានានិ កម្មានំ សមុទយាយ ។ កតមានិ តីណិ ។

នៃការកើតឡើងនៃកម្ម ១ ទោសៈជាហេតុនៃការកើតឡើងនៃកម្ម ១ មោហៈជាហេតុនៃការកើតឡើងនៃកម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ កម្មណា សម្រេចមកអំពីលោភៈ កើតមកអំពីលោភៈ មានលោភៈជាហេតុ មានលោភៈជាដែនកើត កម្មនោះជាអកុសល កម្មនោះប្រកបដោយទោស កម្មនោះមានទុក្ខជាវិបាក កម្មនោះប្រព្រឹត្តទៅដើម្បីកើតឡើងនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីទោសៈ កើតមកអំពីទោសៈ មានទោសៈជាហេតុ មានទោសៈជាដែនកើត កម្មនោះជាអកុសល កម្មនោះប្រកបដោយទោស កម្មនោះមានទុក្ខជាវិបាក កម្មនោះប្រព្រឹត្តទៅដើម្បីកើតឡើងនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីមោហៈ កើតមកអំពីមោហៈ មានមោហៈជាហេតុ មានមោហៈជាដែនកើត កម្មនោះជាអកុសល កម្មនោះប្រកបដោយទោស កម្មនោះមានទុក្ខជាវិបាក កម្មនោះប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃកម្ម កម្មនោះ មិនប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះឯង ដើម្បីកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះ ដើម្បីកើតឡើងនៃកម្ម ។ ហេតុ ៣ យ៉ាងដូចម្តេចខ្លះ ។

អលោភោ និទានំ កម្មានំ សមុទយាយ អទោសោ និទានំ កម្មានំ សមុទយាយ អមោហោ និទានំ កម្មានំ សមុទយាយ ។ យំ ភិក្ខវេ អលោភប្បកតំ កម្មំ អលោភជំ អលោភនិទានំ អលោភសមុទយំ តំ កម្មំ កុសលំ តំ កម្មំ អនវជ្ជំ តំ កម្មំ សុខវិបាកំ តំ កម្មំ កម្មនិរោធាយ សំវត្តតិ ន តំ កម្មំ កម្មសមុទយាយ សំវត្តតិ ។ យំ ភិក្ខវេ អទោសប្បកតំ កម្មំ អទោសជំ អទោសនិទានំ អទោសសមុទយំ តំ កម្មំ កុសលំ តំ កម្មំ អនវជ្ជំ តំ កម្មំ សុខវិបាកំ តំ កម្មំ កម្មនិរោធាយ សំវត្តតិ ន តំ កម្មំ កម្មសមុទយាយ សំវត្តតិ ។ យំ ភិក្ខវេ អមោហប្បកតំ កម្មំ អមោហជំ អមោហនិទានំ អមោហសមុទយំ តំ កម្មំ កុសលំ តំ កម្មំ អនវជ្ជំ តំ កម្មំ សុខវិបាកំ តំ កម្មំ កម្មនិរោធាយ សំវត្តតិ ន តំ កម្មំ កម្មសមុទយាយ សំវត្តតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ និទានានិ កម្មានំ សមុទយាយាតិ ។

គឺអលោភៈជាហេតុ នៃការកើតឡើងនៃកម្ម ១ អទោសៈជាហេតុ នៃការកើតឡើងនៃកម្ម ១ អមោហៈជាហេតុ នៃការកើតឡើងនៃកម្ម ១ ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីអលោភៈ កើតមកអំពីអលោភៈ មានអលោភៈជាហេតុ មានអលោភៈជាដែនកើត កម្មនោះ ជាកុសល កម្មនោះឥតទោស កម្មនោះមានសុខជាវិបាក កម្មនោះប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីអទោសៈ កើតមកអំពីអទោសៈ មានអទោសៈជាហេតុ មានអទោសៈជាដែនកើត កម្មនោះ ជាកុសល កម្មនោះឥតទោស កម្មនោះមានសុខជាវិបាក កម្មនោះប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅដើម្បីកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ កម្មណាសម្រេចមកអំពីអមោហៈ កើតមកអំពីអមោហៈ មានអមោហៈជាហេតុ មានអមោហៈជាដែនកើត កម្មនោះជាកុសល កម្មនោះឥតទោស កម្មនោះមានសុខជាវិបាក កម្មនោះប្រព្រឹត្តទៅ ដើម្បីរលត់ទៅនៃកម្ម កម្មនោះមិនប្រព្រឹត្តទៅ ដើម្បីកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះឯង ដើម្បីកើតឡើងនៃកម្ម ។

តតិយបណ្ណាសកេ   សម្ពោធិវគ្គោ

[១១៤] តីណិមានិ ភិក្ខវេ និទានានិ កម្មានំ សមុទយាយ ។ កតមានិ តីណិ ។ អតីតេ ភិក្ខវេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ឆន្ទោ ជាយតិ អនាគតេ ភិក្ខវេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ឆន្ទោ ជាយតិ បច្ចុប្បន្នេ ភិក្ខវេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ឆន្ទោ ជាយតិ ។ កថញ្ច ភិក្ខវេ អតីតេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ឆន្ទោ ជាយតិ ។ អតីតេ ភិក្ខវេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ចេតសា អនុវិតក្កេតិ អនុវិចារេតិ ។ តស្ស អតីតេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ចេតសា អនុវិតក្កយតោ អនុវិចារយតោ ឆន្ទោ ជាយតិ ឆន្ទជាតោ តេហិ ធម្មេហិ សំយុត្តោ ហោតិ ។ ឯតាហំ ភិក្ខវេ សញ្ញោជនំ វទាមិ យោ ចេតសោ សារាគោ ។ ឯវំ ខោ ភិក្ខវេ អតីតេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ឆន្ទោ ជាយតិ ។ កថញ្ច ភិក្ខវេ អនាគតេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ឆន្ទោ ជាយតិ ។

[១១៤] ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះ ដើម្បីកើតឡើងនៃកម្ម ។ ៣ យ៉ាងតើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃឆន្ទរាគជាអតីត ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃឆន្ទរាគជាអនាគត ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃឆន្ទរាគជាបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តកើតឡើងព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃឆន្ទរាគជាអតីត ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃឆន្ទរាគជាអតីត ។ កាលបុគ្គលនោះ មានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ប្រារព្ធនូវធម៌ ជាទីតាំងនៃឆន្ទរាគជាអតីត សេចក្តីគាប់ចិត្តក៏កើតឡើង បុគ្គលនោះ លុះមានសេចក្តីគាប់ចិត្តកើតឡើងហើយ តែងប្រកបដោយធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចិត្ត ដែលប្រកបដោយរាគៈ ថា ជាសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃឆន្ទរាគជាអតីត ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃឆន្ទរាគជាអនាគតដូចម្តេច ។

អនាគតេ ភិក្ខវេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ចេតសា អនុវិតក្កេតិ អនុវិចារេតិ ។ តស្ស អនាគតេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ចេតសា អនុវិតក្ក-យតោ អនុវិចារយតោ ឆន្ទោ ជាយតិ ឆន្ទជាតោ តេហិ ធម្មេហិ សំយុត្តោ ហោតិ ។ ឯតាហំ ភិក្ខវេ សញ្ញោជនំ វទាមិ យោ ចេតសោ សារាគោ ។ ឯវំ ខោ ភិក្ខវេ អនាគតេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ឆន្ទោ ជាយតិ ។ កថញ្ច ភិក្ខវេ បច្ចុប្បន្នេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ឆន្ទោ ជាយតិ ។ បច្ចុប្បន្នេ ភិក្ខវេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ចេតសា អនុវិតក្កេតិ អនុវិចារេតិ ។ តស្ស បច្ចុប្បន្នេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ចេតសា អនុវិតក្ក-យតោ អនុវិចារយតោ ឆន្ទោ ជាយតិ ឆន្ទជាតោ តេហិ ធម្មេហិ សំយុត្តោ ហោតិ ។ ឯតាហំ ភិក្ខវេ សញ្ញោជនំ វទាមិ យោ ចេតសោ សារាគោ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលមានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃឆន្ទរាគ ជាអនាគត ។ កាលបុគ្គលនោះ មានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃឆន្ទរាគជាអនាគត សេចក្តីគាប់ចិត្តក៏កើតឡើង បុគ្គលនោះ លុះមានសេចក្តីគាប់ចិត្តកើតឡើងហើយ តែងប្រកបដោយធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវចិត្តដែលប្រកបដោយរាគៈថា ជាសញ្ញោជនៈ ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃឆន្ទរាគ ជាអនាគត ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ជាទីតាំងនៃឆន្ទរាគ ជាបច្ចុប្បន្ន ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាលបុគ្គល មានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃឆន្ទរាគ ជាបច្ចុប្បន្ន ។ កាលបុគ្គលនោះ មានចិត្តត្រិះរិះរឿយៗ ពិចារណារឿយៗ ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃឆន្ទរាគជាបច្ចុប្បន្ន សេចក្តីគាប់ចិត្តក៏កើតឡើង បុគ្គលនោះ លុះមានសេចក្តីគាប់ចិត្តកើតឡើងហើយ តែងប្រកបដោយធម៌ទាំងនោះ ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតពោលនូវចិត្ត ដែលប្រកបដោយរាគៈថា ជាសញ្ញោជនៈ ។

ឯវំ ខោ ភិក្ខវេ បច្ចុប្បន្នេ ឆន្ទរាគដ្ឋានិយេ ធម្មេ អារព្ភ ឆន្ទោ ជាយតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ និទានានិ កម្មានំ សមុទយាយ ។ តីណីមានិ ភិក្ខវេ និទានានិ កម្មានំ សមុទយាយ ។ កតមានិ តីណិ ។ អតីតេ ភិក្ខវេ ឆន្ទរាគដ្ឋានិយេ ធម្មេ អារព្ភ ឆន្ទោ ន ជាយតិ អនាគតេ ភិក្ខវេ ឆន្ទរាគដ្ឋានិយេ ធម្មេ អារព្ភ ឆន្ទោ ន ជាយតិ បច្ចុប្បន្នេ ភិក្ខវេ ឆន្ទរាគដ្ឋានិយេ ធម្មេ អារព្ភ ឆន្ទោ ន ជាយតិ ។ កថញ្ច ភិក្ខវេ អតីតេ ឆន្ទរាគដ្ឋានិយេ ធម្មេ អារព្ភ ឆន្ទោ ន ជាយតិ ។ អតីតានំ ភិក្ខវេ ឆន្ទរាគដ្ឋានិយានំ ធម្មានំ អាយតឹ វិបាកំ បជានាតិ អាយតឹ វិបាកំ វិទិត្វា តទភិនិវជ្ជេតិ តទភិនិវជ្ជេត្វា ចេតសា អភិវិរាជេត្វា[១] បញ្ញាយ អតិវិជ្ឈ បស្សតិ ។ ឯវំ ខោ ភិក្ខវេ អតីតេ ឆន្ទរាគដ្ឋានិយេ ធម្មេ អារព្ភ ឆន្ទោ ន ជាយតិ ។ កថញ្ច ភិក្ខវេ អនាគតេ ឆន្ទរាគដ្ឋានិយេ ធម្មេ អារព្ភ ឆន្ទោ ន ជាយតិ ។

១ ម. អភិនិវិជ្ឈិត្វា ។

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្ដីគាប់ចិត្តកើតឡើង ព្រោះប្រារព្ធនូវធម៌ ជាទីតាំងនៃឆន្ទរាគជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ទាំងនេះជាហេតុ ៣ យ៉ាង នៃការកើតឡើងនៃកម្ម ។ ម្នាលភិក្ខុទាំងឡាយ ហេតុ ៣ យ៉ាងនេះ ដើម្បីកើតឡើងនៃកម្ម ។ ៣ យ៉ាង ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាអតីត ១ ម្នាលភិក្ខុទាំងឡាយ សេចក្ដីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគ ជាអនាគត ១ ម្នាលភិក្ខុទាំងឡាយ សេចក្ដីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាបច្ចុប្បន្ន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្ដីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាអតីត ដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដឹងច្បាស់នូវវិបាកនៃធម៌ទាំងឡាយ ជាទីតាំងនៃឆន្ទរាគជាអតីតតទៅ លុះដឹងនូវវិបាកតទៅហើយ ក៏លះបង់វិបាកនោះ លុះលះបង់វិបាកនោះហើយ ទើបមានចិត្តនឿយណាយ ហើយចាក់ធ្លុះឃើញច្បាស់ ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្ដីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាអតីត ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្ដីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាអនាគត ដូចម្ដេច ។

អនាគតានំ ភិក្ខវេ ឆន្ទរាគដ្ឋានីយានំ ធម្មានំ អាយតឹ វិបាកំ បជានាតិ អាយតឹ វិបាកំ វិទិត្វា តទភិនិវជ្ជេតិ តទភិនិវជ្ជេត្វា ចេតសា អភិវិរាជេត្វា បញ្ញាយ អតិវិជ្ឈ បស្សតិ ។ ឯវំ ខោ ភិក្ខវេ អនាគតេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ឆន្ទោ ន ជាយតិ ។ កថញ្ច ភិក្ខវេ បច្ចុប្បន្នេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ឆន្ទោ ន ជាយតិ ។ បច្ចុប្បន្នានំ ភិក្ខវេ ឆន្ទរាគដ្ឋានីយានំ ធម្មានំ អាយតឹ វិបាកំ បជានាតិ អាយតឹ វិបាកំ វិទិត្វា តទភិនិវជ្ជេតិ តទភិនិវជ្ជេត្វា ចេតសា អភិវិរាជេត្វា បញ្ញាយ អតិវិជ្ឈ បស្សតិ ។ ឯវំ ខោ ភិក្ខវេ បច្ចុប្បន្នេ ឆន្ទរាគដ្ឋានីយេ ធម្មេ អារព្ភ ឆន្ទោ ន ជាយតិ ។ ឥមានិ ខោ ភិក្ខវេ តីណិ និទានានិ កម្មានំ សមុទយាយាតិ ។

សម្ពោធិវគ្គោ បឋមោ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលដឹងច្បាស់នូវវិបាកនៃធម៌ទាំងឡាយ ជាទីតាំងនៃឆន្ទរាគ ជាអនាគតតទៅ លុះដឹងច្បាស់នូវវិបាកតទៅហើយ ក៏លះបង់នូវវិបាកនោះ លុះលះបង់វិបាកនោះហើយ ទើបមានចិត្តនឿយណាយ ហើយចាក់ធ្លុះឃើញច្បាស់ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថាសេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាអនាគត ។ ម្នាលភិក្ខុទាំងឡាយ ចុះសេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាបច្ចុប្បន្ន ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដឹងច្បាស់នូវវិបាកនៃធម៌ទាំងឡាយ ជាទីតាំងនៃឆន្ទរាគជាបច្ចុប្បន្នតទៅ លុះដឹងច្បាស់នូវវិបាកតទៅហើយ ក៏លះបង់នូវវិបាកនោះ លុះលះបង់វិបាកនោះហើយ ទើបមានចិត្តនឿយណាយ ហើយចាក់ធ្លុះ ឃើញច្បាស់ដោយបញ្ញា ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា សេចក្តីគាប់ចិត្តមិនកើតឡើង ព្រោះប្រារព្ធធម៌ ជាទីតាំងនៃឆន្ទរាគជាបច្ចុប្បន្ន ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៣ យ៉ាងនេះឯង ដើម្បីកើតឡើងនៃកម្ម ។

ចប់ សម្ពោធិវគ្គទី ១ ។

៤០៧

តតិយបណ្ណាសកេ សម្ពោធិវគ្គោ

# តស្សុទ្ទានំ

បុព្វេ មនុស្សេ អស្សាទោ
សមណោ រោណបញ្ចមំ
អតិត្តា ទ្វេ ច កញ្ជានិ
និទានា អបរេ ទុវេតិ ។

តតិយបណ្ណាសក សម្មោធិវគ្គ

# ឧទ្ទាននៃសម្មោធិវគ្គនោះគឺ

និយាយអំពីកាលមុនត្រាស់ដឹង ១ អំពីអានិសង្ស ជាដើមក្នុងមនុស្ស ១ អំពីសមណព្រាហ្មណ៍ ១ អំពីសេចក្តីយំស្រែកមួយទៀតជាគម្រប់ប្រាំ ១ អំពីការសេពមិនចេះឆ្អែត ១ អំពីផ្ទះមានកំពូលមានពីរលើក ១ អំពីហេតុដទៃទៀត មានពីរលើក ១ ។

# អាបាយិកវគ្គោ

[១១៥] តយោមេ ភិក្ខវេ អាបាយិកា នេរយិកា ឥទមប្បហាយ ។ កតមេ តយោ ។ យោ ច អព្រហ្មចារី ព្រហ្មចារិប្បដិញ្ញោ យោ ច សុទ្ធព្រហ្មចារឹ សុទ្ធំ ព្រហ្មចរិយំ ចរន្តំ អមូលកេន អព្រហ្មចរិយេន អនុទ្ធំសេតិ យោចាយំ ឯវំវាទី ឯវំទិដ្ឋិ នត្ថិ កាមេសុ ទោសោតិ សោ កាមេសុ បាតព្យតំ អាបជ្ជតិ ។ ឥមេ ខោ ភិក្ខវេ តយោ អាបាយិកា នេរយិកា ឥទមប្បហាយាតិ ។

[១១៦] តិណ្ណំ ភិក្ខវេ បាតុភាវោ ទុល្លភោ លោកស្មឹ ។ កតមេសំ តិណ្ណំ ។ តថាគតស្ស ភិក្ខវេ អរហតោ សម្មាសម្ពុទ្ធស្ស បាតុភាវោ ទុល្លភោ លោកស្មឹ តថាគតប្បវេទិតស្ស ធម្មវិនយស្ស ទេសេតា បុគ្គលោ ទុល្លភោ លោកស្មឹ កតញ្ញូ កតវេទី បុគ្គលោ ទុល្លភោ លោកស្មឹ ។ ឥមេសំ ខោ ភិក្ខវេ តិណ្ណំ បាតុភាវោ ទុល្លភោ លោកស្មិន្តិ ។

# អាបាយិកវគ្គ

[១១៥] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ តែងទៅកាន់អបាយ ទៅកាន់នរក ព្រោះមិនលះបង់អំពើអាក្រក់នេះ ។ បុគ្គល ៣ ពួកដូចម្តេចខ្លះ ។ គឺបុគ្គលណា មិនមែនជាព្រហ្មចារ្យ តែប្តេជ្ញាថាខ្លួនជាព្រហ្មចារ្យ ១ បុគ្គលណា ចោទបុគ្គលជាព្រហ្មចារ្យ បរិសុទ្ធ ជាអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ដ៏បរិសុទ្ធ ដោយអព្រហ្មចរិយធម៌មិនមានមូល ១ បុគ្គលណា មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា ទោសក្នុងកាមទាំងឡាយមិនមាន បុគ្គលនោះ ក៏ដល់នូវសេចក្តីស្រេកឃ្លានក្នុងកាមទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៣ ពួកនេះ តែងទៅកាន់អបាយ ទៅកាន់នរក ព្រោះមិនលះបង់អំពើអាក្រក់នេះ ។

[១១៦] ម្នាលភិក្ខុទាំងឡាយ សេចក្តីកើតប្រាកដនៃបុគ្គល ៣ ពួករកបានដោយក្រក្នុងលោក ។ បុគ្គល ៣ ពួកដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ សេចក្តីកើតប្រាកដនៃព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ រកបានដោយក្រក្នុងលោក ១ បុគ្គលអ្នកសម្តែងធម្មវិន័យ ដែលព្រះតថាគតសម្តែងហើយ រកបានដោយក្រក្នុងលោក ១ បុគ្គលជាកតញ្ញូកតវេទីរកបានដោយក្រក្នុងលោក ១ ។ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គល ៣ ពួកនេះ រកបានដោយក្រក្នុងលោក ។

តតិយបណ្ណាសកេ អាបាយិកវគ្គោ

[១១៧] តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ សុប្បមេយ្យោ ទុប្បមេយ្យោ អប្បមេយ្យោ ។ កតមោ ច ភិក្ខវេ បុគ្គលោ សុប្បមេយ្យោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ ឧទ្ធតោ ហោតិ ឧន្នឡោ ចបលោ មុខរោ វិកិណ្ណវាចោ មុដ្ឋស្សតិ អសម្បជានោ អសមាហិតោ វិព្ភន្តចិត្តោ ចាកតិន្ទ្រិយោ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ សុប្បមេយ្យោ ។ កតមោ ច ភិក្ខវេ បុគ្គលោ ទុប្បមេយ្យោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អនុទ្ធតោ ហោតិ អនុន្នឡោ អចបលោ អមុខរោ អវិកិណ្ណវាចោ ឧបដ្ឋិតស្សតិ សម្បជានោ សមាហិតោ ឯកគ្គចិត្តោ សំវុតិន្ទ្រិយោ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ ទុប្បមេយ្យោ ។ កតមោ ច ភិក្ខវេ បុគ្គលោ អប្បមេយ្យោ ។ ឥធ ភិក្ខវេ ភិក្ខុ អរហំ ហោតិ ខីណាសវោ ។ អយំ វុច្ចតិ ភិក្ខវេ បុគ្គលោ អប្បមេយ្យោ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១១៧] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួកដូចម្តេចខ្លះ ។ គឺសុប្បមេយ្យបុគ្គល (បុគ្គលដែលគេប្រមាណដោយងាយ) ១ ទុប្បមេយ្យបុគ្គល (បុគ្គលដែលគេប្រមាណដោយក្រ) ១ អប្បមេយ្យបុគ្គល (បុគ្គលដែលគេប្រមាណមិនបាន) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសុប្បមេយ្យបុគ្គល ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកលើកកម្ពស់ ឆ្មើងឆ្មៃ រពើតរពើង មាត់រឹង និយាយប៉ប៉ាច់ប៉ប៉ោច ភ្លេចស្មារតី មិនដឹងខ្លួន មានចិត្តមិននឹងធឹង មានចិត្តប្រែប្រួល មានឥន្ទ្រិយបើកចំហ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សុប្បមេយ្យបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ចុះទុប្បមេយ្យបុគ្គល ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកមិនលើកកម្ពស់ មិនឆ្មើងឆ្មៃ មិនរពើតរពើង មិនមានមាត់រឹង មិននិយាយប៉ប៉ាច់ប៉ប៉ោច តម្កល់ស្មារតី ដឹងខ្លួន មានចិត្តនឹងធឹង មានចិត្តមានអារម្មណ៍តែមួយ សង្រួមឥន្ទ្រិយល្អ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទុប្បមេយ្យបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ ចុះអប្បមេយ្យបុគ្គល ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គឺបានដល់ភិក្ខុ ជាអរហំខីណាស្រព ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អប្បមេយ្យបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះឯង រមែងមាននៅក្នុងលោក ។

[១១៨] តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចា-យតនំ ឧបសម្បជ្ជ វិហរតិ ។ សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្វហុលវិហារី អបរិហីនោ កាលំ កុរុមានោ អាកាសានញ្ចាយតនូបគានំ ទេវានំ សហ-ព្យតំ ឧបបជ្ជតិ ។ អាកាសានញ្ចាយតនូបគានំ ភិក្ខវេ ទេវានំ វីសតិ កប្បសហស្សានិ អាយុប្បមាណំ ។ តត្ថ បុថុជ្ជនោ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា និរយម្បិ គច្ឆតិ តិរច្ឆានយោនិម្បិ គច្ឆតិ បិត្តិវិសយម្បិ គច្ឆតិ ។ ភគវតោ បន សាវកោ តត្ថ យាវតាយុកំ ឋត្វា

[១១៨] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ ពួកដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ព្រោះកន្លងបង់នូវរូបសញ្ញា ដោយប្រការទាំងពួង ព្រោះរលត់នូវបដិឃសញ្ញា ព្រោះមិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ ។ បុគ្គលនោះ ត្រេកអរនឹងឈាននោះ ប្រាថ្នានូវឈាននោះដល់នូវសេចក្តីត្រេកអរនឹងឈាននោះ ស្ថិតនៅក្នុងឈាននោះ សម្រាកក្នុងឈាននោះ សម្រេចសម្រាន្តនៅដោយច្រើនក្នុងឈាននោះ មិនសាបសូន្យ (ចាកឈាននោះ) កាលធ្វើមរណកាល ក៏ទៅកើតជាមួយនឹងពួកទេវតាដែលកើតក្នុងជាន់អាកាសានញ្ចាយតនៈ ។ ម្នាលភិក្ខុទាំងឡាយ ប្រមាណអាយុរបស់ពួកទេវតា ដែលកើតក្នុងជាន់អាកាសានញ្ចាយតនៈ កំណត់ពីរហ្មឺនកប្ប (២០០០០កប្ប) ។ បុថុជ្ជន ដែលឋិតនៅក្នុងភពនោះ ដរាបដល់អស់អាយុ គឺកំណត់អស់អាយុទាំងអស់ ដែលជាប្រមាណអាយុ នៃទេវតាទាំងនោះ ហើយក៏ទៅកើតក្នុងនរកខ្លះ ទៅកើតក្នុងកំណើតតិរច្ឆានខ្លះ ទៅកើតក្នុងបិត្តិវិស័យខ្លះ ។ ចំណែកខាងសាវ័ករបស់ព្រះមានព្រះភាគ ដែលឋិតនៅក្នុងភពនោះដរាបដល់អស់អាយុ គឺថាកំណត់អស់អាយុ

យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា តស្មិំយេវ ភវេ បរិនិព្ពាយតិ ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ ឥទំ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេន យទិទំ គតិយា ឧបបត្តិយា សតិ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្វហុលវិហារី អបរិហីនោ កាលំ កុរុមានោ វិញ្ញាណញ្ចាយតនុបគានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ វិញ្ញាណញ្ចាយតនុបគានំ ភិក្ខវេ ទេវានំ ចត្តាឡីស កប្បសហស្សានិ អាយុប្បមាណំ ។ តត្ថ បុថុជ្ជនោ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា និរយម្បិ គច្ឆតិ

ទាំងអស់ ដែលជាប្រមាណអាយុរបស់ពួកទេវតាទាំងនោះ ហើយក៏បរិនិព្វានក្នុងភពនោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្ដីប្លែក នេះជាសេចក្ដីអធិប្បាយ នេះជាអំពើផ្សេងៗ គ្នា នៃអរិយសាវ័ក អ្នកចេះដឹង និងបុថុជ្ជនអ្នកមិនចេះដឹង កាលបើនៅមានគតិភព និងឧបបត្តិភពនៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត បុគ្គលពួកមួយ ក្នុងលោកនេះ កន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុតដូច្នេះ បុគ្គលនោះ ត្រេកអរនឹងឈាននោះ ប្រាថ្នានូវឈាននោះ ដល់នូវសេចក្ដីត្រេកអរដោយឈាននោះ ឋិតនៅក្នុងឈាននោះ សម្រាកនៅក្នុងឈាននោះ សម្រេចសម្រាន្តនៅដោយច្រើនក្នុងឈាននោះ មិនសាបសូន្យ (ចាកឈាននោះ) កាលធ្វើមរណកាលទៅ ក៏ទៅកើតជាមួយនឹងទេវតា ដែលកើតក្នុងជាន់វិញ្ញាណញ្ចាយតនៈ ។ ម្នាលភិក្ខុទាំងឡាយ ប្រមាណអាយុនៃពួកទេវតា ដែលកើតក្នុងជាន់ វិញ្ញាណញ្ចាយតនៈ កំណត់បួនហ្មឺនកប្ប (៤០០០០កប្ប) ។ បុថុជ្ជជន ដែលឋិតនៅក្នុងភពនោះ ដរាបដល់អស់អាយុ គឺថាកំណត់អស់អាយុទាំងអស់ ដែលជាប្រមាណអាយុ នៃពួកទេវតាទាំងនោះហើយ ទៅកើតក្នុងនរកខ្លះ

តិរច្ឆានយោនិម្បិ គច្ឆតិ បិត្តិវិសយម្បិ គច្ឆតិ ។ ភគវតោ បន សាវកោ តត្ថ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា តស្មឹយេវ ភវេ បរិនិព្វាយតិ ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ ឥទំ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេន យទិទំ គតិយា ឧបបត្តិយា សតិ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ តទស្សាទេតិ តំ និកាមេតិ តេន ច វិត្តឹ អាបជ្ជតិ តត្ថ ឋិតោ តទធិមុត្តោ តព្ពហុលវិហារី អបរិហីនោ កាលំ កុរុមានោ អាកិញ្ចញ្ញាយតនុបគានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ អាកិញ្ចញ្ញាយតនុបគានំ ភិក្ខវេ ទេវានំ សដ្ឋី កប្បសហស្សានិ អាយុប្បមាណំ ។

ទៅកើតក្នុងកំណើតតិរច្ឆានខ្លះ ទៅកើតក្នុងបិត្តិវិស័យខ្លះ ។ ចំណែកសាវ័ករបស់ព្រះមានព្រះភាគ ឋិតនៅក្នុងភពនោះ ដរាបដល់អស់អាយុ គឺកំណត់អស់អាយុទាំងអស់ ដែលជាប្រមាណអាយុនៃពួកទេវតាទាំងនោះ ហើយក៏បរិនិព្វានក្នុងភពនោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្តីប្លែក នេះជាសេចក្តីអធិប្បាយ នេះជាអំពើផ្សេងៗ គ្នា នៃអរិយសាវ័ក អ្នកចេះដឹង និងបុថុជ្ជនអ្នកមិនចេះដឹង កាលបើគតិភព និងឧបបត្តិភពមាននៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពួកមួយ ក្នុងលោកនេះ កន្លងបង់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា អ្វីតិចតួចមិនមាន ដូច្នេះ ។ បុគ្គលនោះ ត្រេកអរនឹងឈាននោះ ប្រាថ្នាឈាននោះ ដល់នូវសេចក្តីត្រេកអរដោយឈាននោះ ឋិតនៅក្នុងឈាននោះ សម្រាកនៅក្នុងឈាននោះ សម្រេចសម្រាន្តនៅដោយច្រើនក្នុងឈាននោះ មិនសាបសូន្យ (ចាកឈាននោះ) កាលធ្វើមរណកាលទៅ រមែងទៅកើតជាមួយនឹងពួកទេវតា ដែលកើតក្នុងជាន់អាកិញ្ចញ្ញាយតនៈ ។ ម្នាលភិក្ខុទាំងឡាយ ប្រមាណអាយុនៃពួកទេវតា ដែលកើតក្នុងជាន់អាកិញ្ចញ្ញាយតនៈ កំណត់ប្រាំមួយហ្មឺនកប្ប (៦០០០០ កប្ប) ។

តត្ថ បុថុជ្ជនោ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា និរយម្បិ គច្ឆតិ តិរច្ឆានយោនិម្បិ គច្ឆតិ បិត្តិវិសយម្បិ គច្ឆតិ ។ ភគវតោ បន សាវកោ តត្ថ យាវតាយុកំ ឋត្វា យាវតកំ តេសំ ទេវានំ អាយុប្បមាណំ តំ សព្វំ ខេបេត្វា តស្មឹយេវ ភវេ បរិនិព្វាយតិ ។ អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ ឥទំ នានា-ករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេន យទិទំ គតិយា ឧបបត្តិយា សតិ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[១១៩] តិស្សោ ឥមា ភិក្ខវេ វិបត្តិយោ ។ កតមា តិស្សោ ។ សីលវិបត្តិ ចិត្តវិបត្តិ ទិដ្ឋិវិបត្តិ ។ កតមា ច ភិក្ខវេ សីលវិបត្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុ មិច្ឆាចារី ហោតិ មុសាវាទី ហោតិ បិសុណាវាចោ ហោតិ ផរុសាវាចោ ហោតិ

បុថុជ្ជនឋិតនៅក្នុងភពនោះ ដរាបដល់អស់អាយុ គឺថាកំណត់អស់អាយុទាំងអស់ ដែលជាប្រមាណអាយុ នៃពួកទេវតាទាំងនោះ ហើយក៏ទៅកើតក្នុងនរកខ្លះ ទៅកើតក្នុងកំណើតតិរច្ឆានខ្លះ ទៅកើតក្នុងបិត្តិវិស័យខ្លះ ។ ចំណែកខាងសាវ័ករបស់ព្រះមានព្រះភាគវិញ ឋិតនៅក្នុងភពនោះ ដរាបដល់អស់អាយុ គឺថាកំណត់អស់អាយុទាំងអស់ ដែលជាប្រមាណអាយុនៃពួកទេវតាទាំងនោះ ហើយក៏បរិនិព្វានក្នុងភពនោះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាសេចក្ដីប្លែក នេះជាសេចក្ដីអធិប្បាយ នេះជាអំពើផ្សេងៗនៃអរិយសាវ័ក អ្នកចេះដឹង និងបុថុជ្ជនអ្នកមិនចេះដឹង កាលបើគតិភពនិងឧបបត្តិភព មាននៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៣ ពួកនេះ រមែងមាននៅក្នុងលោក ។

[១១៩] ម្នាលភិក្ខុទាំងឡាយ វិបត្តិទាំងឡាយនេះ មាន ៣ យ៉ាង ។ វិបត្តិ ៣ យ៉ាងដូចម្ដេចខ្លះ ។ គឺសីលវិបត្តិ ១ ចិត្តវិបត្តិ ១ ទិដ្ឋិវិបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសីលវិបត្តិ ដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់

សម្ផប្បលាបី ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សីលវិបត្តិ ។ កតមា ច ភិក្ខវេ ចិត្តវិបត្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ចិត្តវិបត្តិ ។ កតមា ច ភិក្ខវេ ទិដ្ឋិវិបត្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ មិច្ឆាទិដ្ឋិកោ ហោតិ វិបរី-តទស្សនោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ អយំ វុច្ចតិ ភិក្ខវេ ទិដ្ឋិវិបត្តិ ។ សីលវិបត្តិហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ចិត្តវិបត្តិហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ទិដ្ឋិវិបត្តិហេតុ វា ភិក្ខវេ សត្តា

ពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ចុះចិត្តវិបត្តិ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ច្រើនដោយអភិជ្ឈា មានចិត្តព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិវិបត្តិ ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់វិបរិតថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាធំមិនមានផល ការបូជាតូចមិនមានផល ផលវិបាកនៃកម្មដែលបុគ្គលធ្វើល្អនិងអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមាន បិតាមិនមាន ពួកសត្វជាឱបបាតិកៈមិនមាន ពួកសមណព្រាហ្មណ៍ជាអ្នកព្រមព្រៀងគ្នាប្រតិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះនិងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយប្រកាសក្នុងលោកក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែចិត្តវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិវិបត្តិ បានជាសត្វទាំងឡាយ

កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ ឥមា ខោ ភិក្ខវេ តិស្សោ វិបត្តិយោ ។ តិស្សោ ឥមា ភិក្ខវេ សម្បទា ។ កតមា តិស្សោ ។ សីលសម្បទា ចិត្តសម្បទា ទិដ្ឋិសម្បទា ។ កតមា ច ភិក្ខវេ សីលសម្បទា ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សីលសម្បទា ។ កតមា ច ភិក្ខវេ ចិត្តសម្បទា ។ ឥធ ភិក្ខវេ ឯកច្ចោ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ចិត្តសម្បទា ។ កតមា ច ភិក្ខវេ ទិដ្ឋិសម្បទា ។ ឥធ ភិក្ខវេ ឯកច្ចោ សម្មាទិដ្ឋិកោ ហោតិ អវិបរីតទស្សនោ

លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិមាន ៣ យ៉ាងប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ សម្បទានេះ មាន ៣ យ៉ាង ។ សម្បទា ៣ យ៉ាងដូចម្តេចខ្លះ ។ គឺសីលសម្បទា ១ ចិត្តសម្បទា ១ ទិដ្ឋិសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសីលសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកបិសុណាវាចា វៀរចាកផរុសវាចា វៀរចាកសម្ផប្បលាបៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះចិត្តសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ មិនច្រើនដោយអភិជ្ឈា មានចិត្តមិនព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសម្មាទិដ្ឋិ មានសេចក្តីយល់មិនវិបរិតថា

អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកដទុក្កដានំ កម្មានំ ផលវិចាកោ អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបចាតិកា អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ អយំ វុច្ចតិ ភិក្ខវេ ទិដ្ឋិ-សម្បទា ។ សីលសម្បទាហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ចិត្តសម្បទាហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ទិដ្ឋិសម្បទាហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ ឥមា ខោ ភិក្ខវេ តិស្សោ សម្បទាតិ ។

ទានដែលបុគ្គលឲ្យហើយមានផល ការបូជាធំមានផល ការបូជាតូចមានផល ផលវិបាកនៃកម្មដែលសត្វធ្វើល្អនិងអាក្រក់មាន លោកនេះក៏មាន លោកខាងមុខក៏មាន មាតាមាន បិតាមាន ពួកសត្វជាឱបបាតិកៈមាន ពួកសមណព្រាហ្មណ៍ ជាអ្នកព្រមព្រៀងគ្នាប្រតិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះនិងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯងហើយប្រកាសក្នុងលោកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោកគឺសុគតិនិងស្ថានសួគ៌ក៏មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែចិត្តសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅកើតក្នុងលោកគឺសុគតិនិងស្ថានសួគ៌ក៏មាន ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺសុគតិនិងស្ថានសួគ៌ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ សម្បទាមាន ៣ យ៉ាងប៉ុណ្ណោះ ។

[១២០] តិស្សោ ឥមា ភិក្ខវេ វិបត្តិយោ ។ កាតមា តិស្សោ ។ សីលវិបត្តិ ចិត្តវិបត្តិ ទិដ្ឋិវិបត្តិ ។ កាតមា ច ភិក្ខវេ សីលវិបត្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតី ហោតិ ។ បេ ។ សម្ផប្បលាបី ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សីលវិបត្តិ ។ កាតមា ច ភិក្ខវេ ចិត្តវិបត្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ អភិជ្ឈាលុ ហោតិ ព្យាបន្នចិត្តោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ចិត្តវិបត្តិ ។ កាតមា ច ភិក្ខវេ ទិដ្ឋិវិបត្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ មិច្ឆាទិដ្ឋិកោ ហោតិ វិបរីតទស្សនោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ ។ បេ ។ យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ អយំ វុច្ចតិ ភិក្ខវេ ទិដ្ឋិវិបត្តិ ។ សីលវិបត្តិហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ

[១២០] ម្នាលភិក្ខុទាំងឡាយ វិបត្តិនេះ មាន ៣ យ៉ាង ។ វិបត្តិ ៣ យ៉ាងដូចម្តេចខ្លះ ។ គឺសីលវិបត្តិ ១ ចិត្តវិបត្តិ ១ ទិដ្ឋិវិបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសីលវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ បេ ។ ពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ចុះចិត្តវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ច្រើនដោយអភិជ្ឈា មានចិត្តប្រកបដោយព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាមិច្ឆាទិដ្ឋិ មានសេចក្តីយល់វិបរិតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ។ បេ ។ ពួកសមណព្រាហ្មណ៍ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសក្នុងលោកក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិវិបត្តិ ។ ម្នាលភិក្ខុទាំង-ឡាយ ព្រោះហេតុតែសីលវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន

ចិត្តវិបត្តិហេតុ វា... ទិដ្ឋិវិបត្តិហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ សេយ្យថាបិ ភិក្ខវេ អបណ្ណកោ មណិ ឧទ្ធំខិត្តោ យេន យេនេវ បតិដ្ឋាតិ សុប្បតិដ្ឋិ-តំយេវ បតិដ្ឋាតិ ឯវមេវ ខោ ភិក្ខវេ សីលវិបត្តិ-ហេតុ វា សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ចិត្តវិបត្តិហេតុ វា... ទិដ្ឋិវិបត្តិហេតុ វា សត្តា កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជន្តិ ។ ឥមា ខោ ភិក្ខវេ តិស្សោ វិបត្តិយោ ។ តិស្សោ ឥមា ភិក្ខវេ សម្បទា ។ កតមា តិស្សោ ។ សីល-សម្បទា ចិត្តសម្បទា ទិដ្ឋិសម្បទា ។ កតមា ច ភិក្ខវេ សីលសម្បទា ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សម្ផប្បលាបា បដិវិរតោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ សីលសម្បទា ។ កតមា ច ភិក្ខវេ ចិត្តសម្បទា ។

ព្រោះហេតុតែចិត្តវិបត្តិ... ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចកូនបាសកា មានជ្រុង ៦ ដែលបុគ្គលបោះទៅហើយ (ធ្លាក់ចុះមក) តាំងនៅដោយជ្រុងណាៗ រមែងឋិតនៅនឹង (ដោយជ្រុងនោះៗ) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរកក៏មាន ព្រោះហេតុតែចិត្តវិបត្តិ ក៏មាន... ព្រោះហេតុតែទិដ្ឋិវិបត្តិ បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏មាន យ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិមាន ៣ យ៉ាងប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ សម្បទានេះ មាន ៣ យ៉ាង ។ សម្បទា ៣ យ៉ាងដូចម្ដេចខ្លះ ។ គឺសីលសម្បទា ១ ចិត្តសម្បទា ១ ទិដ្ឋិសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះសីលសម្បទា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ វៀរចាកបាណាតិបាត ។ បេ ។ វៀរចាកសម្ផប្បលាបៈ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះចិត្តសម្បទា តើដូចម្ដេច ។

៤១៩

តតិយបណ្ណាសកេ អាបាយិកវគ្គោ

ឥធ ភិក្ខវេ ឯកច្ចោ អនភិជ្ឈាលុ ហោតិ អព្យាបន្នចិត្តោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ ចិត្ត-សម្បទា ។ កតមា ច ភិក្ខវេ ទិដ្ឋិសម្បទា ។ ឥធ ភិក្ខវេ ឯកច្ចោ សម្មាទិដ្ឋិកោ ហោតិ អវិបរីតទស្សនោ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ ។ បេ ។ យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ អយំ វុច្ចតិ ភិក្ខវេ ទិដ្ឋិសម្បទា ។ សីលសម្បទាហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ចិត្តសម្បទាហេតុ វា... ទិដ្ឋិ-សម្បទាហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ សេយ្យថាបិ ភិក្ខវេ អបណ្ណកោ មណិ ឧទ្ធំ ខិត្តោ យេន យេនេវ បតិដ្ឋាតិ សុប្បតិដ្ឋិតំយេវ បតិដ្ឋាតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ មិនច្រើនដោយអភិជ្ឈា មានចិត្តមិនព្យាបាទ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចិត្តសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសម្មាទិដ្ឋិ មានសេចក្តីយល់មិនវិបរិតថា ទានដែលបុគ្គលឲ្យ មានផល ការបូជាធំ មានផល ។ បេ ។ ពួកសមណ-ព្រាហ្មណ៍ ដែលធ្វើឲ្យជាក់ច្បាស់ នូវលោកនេះនិងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសក្នុងលោក ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោកគឺសុគតិនិងស្ថានសួគ៌ក៏មាន ព្រោះហេតុតែចិត្តសម្បទា... ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិ-សម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោកគឺសុគតិនិងស្ថានសួគ៌ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចកូនបាសកា មានជ្រុង ៦ ដែលបុគ្គលបោះទៅលើ (ធ្លាក់ចុះមក) តាំងនៅដោយជ្រុងណា ៗ រមែងឋិតនៅនឹង (ដោយជ្រុងនោះ ៗ)

ឯវមេវ ខោ ភិក្ខវេ សីលសម្បទាហេតុ វា សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ចិត្តសម្បទាហេតុ វា... ទិដ្ឋិសម្បទាហេតុ វា ភិក្ខវេ សត្តា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជន្តិ ។ ឥមា ខោ ភិក្ខវេ តិស្សោ សម្បទាតិ ។

[១២១] តិស្សោ ឥមា ភិក្ខវេ វិបត្តិយោ ។ កតមា តិស្សោ ។ កម្មន្តវិបត្តិ អាជីវវិបត្តិ ទិដ្ឋិវិបត្តិ ។ កតមា ច ភិក្ខវេ កម្មន្តវិបត្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតី ហោតិ ។ បេ ។ សម្ផប្បលាបី ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ កម្មន្តវិបត្តិ ។ កតមា ច ភិក្ខវេ អាជីវវិបត្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ មិច្ឆាអាជីវោ ហោតិ មិច្ឆាអាជីវេន ជីវិតំ កប្បេតិ ។ អយំ វុច្ចតិ ភិក្ខវេ អាជីវវិបត្តិ ។ កតមា ច ភិក្ខវេ ទិដ្ឋិវិបត្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ មិច្ឆាទិដ្ឋិកោ ហោតិ វិបរីតទស្សនោ នត្ថិ ទិន្នំ នត្ថិ

ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែសីលសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោកគឺសុគតិនិងស្ថានសួគ៌ក៏មាន ព្រោះហេតុតែចិត្តសម្បទា... ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែទិដ្ឋិសម្បទា បានជាសត្វទាំងឡាយ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈ ទៅកើតក្នុងលោក គឺសុគតិនិងស្ថានសួគ៌ ក៏មាន ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សម្បទាមាន ៣ យ៉ាងប៉ុណ្ណេះ ។

[១២១] ម្នាលភិក្ខុទាំងឡាយ វិបត្តិនេះ មាន ៣ យ៉ាង ។ វិបត្តិ ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺកម្មន្តវិបត្តិ ១ អាជីវវិបត្តិ ១ ទិដ្ឋិវិបត្តិ ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះកម្មន្តវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ។ បេ ។ ជាអ្នកពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មន្តវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ចុះអាជីវ-វិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកចិញ្ចឹមជីវិតខុស សម្រេចការរស់នៅ ដោយការចិញ្ចឹមជីវិតខុស ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាជីវវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិវិបត្តិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាមិច្ឆា-ទិដ្ឋិ មានសេចក្តីយល់វិបរិតថា ទានដែលបុគ្គលឲ្យហើយ មិនមានផល

៤២១



យិដ្ឋំ ។ បេ ។ យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ អយំ វុច្ចតិ ភិក្ខវេ ទិដ្ឋិវិបត្តិ ។ ឥមា ខោ ភិក្ខវេ តិស្សោ វិបត្តិយោ ។ តិស្សោ ឥមា ភិក្ខវេ សម្បទា ។ កតមា តិស្សោ ។ កម្មន្តសម្បទា អាជីវសម្បទា ទិដ្ឋិសម្បទា ។ កតមា ច ភិក្ខវេ កម្មន្តសម្បទា ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សម្ផប្បលាបា បដិវិរតោ ហោតិ ។ អយំ វុច្ចតិ ភិក្ខវេ កម្មន្តសម្បទា ។ កតមា ច ភិក្ខវេ អាជីវសម្បទា ។ ឥធ ភិក្ខវេ ឯកច្ចោ សម្មា-អាជីវោ ហោតិ សម្មាអាជីវេន ជីវិតំ កប្បេតិ ។ អយំ វុច្ចតិ ភិក្ខវេ អាជីវសម្បទា ។ កតមា ច ភិក្ខវេ ទិដ្ឋិសម្បទា ។ ឥធ ភិក្ខវេ ឯកច្ចោ សម្មាទិដ្ឋិកោ ហោតិ អវិបរីតទស្សនោ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ ។ បេ ។

ការបូជាធំ មិនមានផល ។ បេ ។ ពួកសមណព្រាហ្មណ៍ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសក្នុងលោកក៏មិនមាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិវិបត្តិ ។ ម្នាលភិក្ខុទាំងឡាយ វិបត្តិមាន ៣ យ៉ាងប៉ុណ្ណេះ ។ ម្នាលភិក្ខុទាំងឡាយ សម្បទានេះ មាន ៣ យ៉ាង ។ សម្បទា ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺកម្មន្តសម្បទា ១ អាជីវសម្បទា ១ ទិដ្ឋិសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ កម្មន្តសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ ។ បេ ។ ជាអ្នកវៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កម្មន្តសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះអាជីវសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយបុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកចិញ្ចឹមជីវិតត្រូវ សម្រេចការរស់នៅ ដោយការចិញ្ចឹមជីវិតត្រូវ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាជីវសម្បទា ។ ម្នាលភិក្ខុទាំងឡាយ ចុះទិដ្ឋិសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសម្មាទិដ្ឋិ មានសេចក្តីយល់មិនវិបរិតថា ទានដែលបុគ្គលឲ្យហើយ មានផល ការបូជាធំ មានផល ។ បេ ។

យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ អយំ វុច្ចតិ ភិក្ខវេ និជ្ជិសម្បទា ។ ឥមា ខោ ភិក្ខវេ តិស្សោ សម្បទាតិ ។

[១២២] តីណីមានិ ភិក្ខវេ សោចេយ្យានិ ។ កតមានិ តីណិ ។ កាយសោចេយ្យំ វចីសោចេយ្យំ មនោសោចេយ្យំ ។ កតមញ្ច ភិក្ខវេ កាយសោចេយ្យំ ។ ឥធ ភិក្ខវេ ឯកច្ចោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ ។ ឥទំ វុច្ចតិ ភិក្ខវេ កាយសោចេយ្យំ ។ កតមញ្ច ភិក្ខវេ វចីសោចេយ្យំ ។ ឥធ ភិក្ខវេ ឯកច្ចោ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ ។ ឥទំ វុច្ចតិ ភិក្ខវេ វចីសោចេយ្យំ ។ កតមញ្ច ភិក្ខវេ មនោសោចេយ្យំ ។

ពួកសមណព្រាហ្មណ៍ ដែលធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ហើយប្រកាសក្នុងលោកនេះក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ទិដ្ឋិសម្បទា ។ ម្នាលភិក្ខុទាំងឡាយ សម្បទាមាន ៣ យ៉ាងប៉ុណ្ណេះ ។

[១២២] ម្នាលភិក្ខុទាំងឡាយ ការស្អាតនេះ មាន ៣ យ៉ាង ។ ការស្អាត ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺស្អាតកាយ ១ ស្អាតវាចា ១ ស្អាតចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតកាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តខុសក្នុងកាម ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតកាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតវាចា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ វៀរចាកការពោលពាក្យកុហក វៀរចាកការពោលពាក្យញុះញង់ វៀរចាកការពោលពាក្យអាក្រក់ វៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតចិត្ត តើដូចម្តេច ។

ឥធ ភិក្ខវេ ឯកច្ចោ អនភិជ្ឈាលុ ហោតិ អព្យា-
បន្នចិត្តោ ហោតិ សម្មាទិដ្ឋិកោ ហោតិ ។ ឥទំ
វុច្ចតិ ភិក្ខវេ មនោសោចេយ្យំ ។ ឥមានិ ខោ ភិក្ខវេ
តីណិ សោចេយ្យានីតិ ។

[១២៣] តីណីមានិ ភិក្ខវេ សោចេយ្យានិ ។ កត-
មានិ តីណិ ។ កាយសោចេយ្យំ វចីសោចេយ្យំ
មនោសោចេយ្យំ ។ កតមញ្ច ភិក្ខវេ កាយ-
សោចេយ្យំ ។ ឥធ ភិក្ខវេ ភិក្ខុ បាណាតិបាតា
បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ
អព្រហ្មចរិយា បដិវិរតោ ហោតិ ។ ឥទំ វុច្ចតិ
ភិក្ខវេ កាយសោចេយ្យំ ។ កតមញ្ច ភិក្ខវេ
វចីសោចេយ្យំ ។ ឥធ ភិក្ខវេ ភិក្ខុ មុសាវាទា
បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ
ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ
សម្ផប្បលាបា បដិវិរតោ ហោតិ ។ ឥទំ វុច្ចតិ
ភិក្ខវេ វចីសោចេយ្យំ ។ កតមញ្ច ភិក្ខវេ មនោ-
សោចេយ្យំ ។ ឥធ ភិក្ខវេ ភិក្ខុ សន្តំ វា អជ្ឈត្តំ
កាមច្ឆន្ទំ អត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាអ្នកមិនច្រើនដោយអភិជ្ឈា មិនមានចិត្តព្យាបាទ ជាសម្មាទិដ្ឋិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាការស្អាតចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ការស្អាតមាន ៣ យ៉ាងប៉ុណ្ណេះ ។

[១២៣] ម្នាលភិក្ខុទាំងឡាយ ការស្អាតនេះ មាន ៣ យ៉ាង ។ ការស្អាតមាន ៣ យ៉ាងដូចម្តេចខ្លះ ។ គឺការស្អាតកាយ ១ ស្អាតវាចា ១ ស្អាតចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតកាយតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ វៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកកិរិយាប្រព្រឹត្តមិនប្រសើរ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា ការស្អាតកាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតវាចា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកវៀរចាកការពោលពាក្យកុហក វៀរចាកការពោលពាក្យញុះញង់ វៀរចាកការពោលពាក្យអាក្រក់ វៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះការស្អាតចិត្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទោះកាមច្ឆន្ទៈមាននៅក្នុងខ្លួនក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមាននៅក្នុងខ្លួនអាត្មាអញ

អសន្តំ វា អជ្ឈត្តំ កាមច្ឆន្ទំ នត្ថិ មេ អជ្ឈត្តំ កាមច្ឆន្ទោតិ បជានាតិ ។ យថា ច អនុប្បន្នស្ស កាមច្ឆន្ទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស កាមច្ឆន្ទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស កាមច្ឆន្ទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ ព្យាបាទំ អត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ អសន្តំ វា អជ្ឈត្តំ ព្យាបាទំ នត្ថិ មេ អជ្ឈត្តំ ព្យាបាទោតិ បជានាតិ ។ យថា ច អនុ-ប្បន្នស្ស ព្យាបាទស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ព្យាបាទស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ព្យាបាទស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ អត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ថីនមិទ្ធំ នត្ថិ មេ អជ្ឈត្តំ ថីនមិទ្ធន្តិ បជានាតិ ។

ទោះកាមច្ឆន្ទៈមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា កាមច្ឆន្ទៈមិនមាននៅក្នុងខ្លួនអាត្មាអញ ។ មួយទៀត កិរិយាកើតឡើងនៃកាមច្ឆន្ទៈ ដែលមិនទាន់កើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវកាមច្ឆន្ទៈដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតទៅទៀតនៃកាមច្ឆន្ទៈ ដែលលះបង់បានហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះព្យាបាទមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមាននៅក្នុងខ្លួនអាត្មាអញ ទោះព្យាបាទមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ព្យាបាទមិនមាននៅក្នុងខ្លួនអាត្មាអញ ។ មួយទៀត កិរិយាកើតឡើងនៃព្យាបាទ ដែលមិនទាន់កើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់ព្យាបាទដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀត នៃព្យាបាទដែលលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះថីនមិទ្ធៈ មាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ថីនមិទ្ធៈ មាននៅក្នុងខ្លួនអាត្មាអញ ទោះថីនមិទ្ធៈមិនមាននៅក្នុងខ្លួនក៏ដឹងច្បាស់ថា ថីនមិទ្ធៈមិនមាននៅក្នុងខ្លួនអាត្មាអញ ។

យថា ច អនុប្បន្នស្ស ថីនមិទ្ធស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ថីនមិទ្ធស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហី-នស្ស ថីនមិទ្ធស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ អត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ បជានាតិ អសន្តំ វា អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចំ នត្ថិ មេ អជ្ឈត្តំ ឧទ្ធច្ចកុក្កុច្ចន្តិ បជានាតិ ។ យថា ច អនុប្បន្នស្ស ឧទ្ធច្ចកុក្កុច្ចស្ស ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នស្ស ឧទ្ធច្ចកុក្កុច្ចស្ស បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនស្ស ឧទ្ធច្ចកុក្កុច្ចស្ស អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ សន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ អត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ អសន្តំ វា អជ្ឈត្តំ វិចិកិច្ឆំ នត្ថិ មេ អជ្ឈត្តំ វិចិកិច្ឆាតិ បជានាតិ ។

មួយទៀត កិរិយាកើតឡើងនៃថីនមិទ្ធៈ ដែលមិនទាន់កើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវថីនមិទ្ធៈ ដែលកើតឡើងហើយដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃថីនមិទ្ធៈ ដែលលះបង់ហើយដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមាននៅក្នុងខ្លួនអាត្មាអញ ទោះឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា ឧទ្ធច្ចកុក្កុច្ចៈមិនមាននៅក្នុងខ្លួនអាត្មាអញ ។ មួយទៀត កិរិយាកើតឡើងនៃឧទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើតឡើងដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់នូវឧទ្ធច្ចកុក្កុច្ចៈ ដែលកើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃឧទ្ធច្ចកុក្កុច្ចៈ ដែលលះបង់ហើយដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ទោះវិចិកិច្ឆា មាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមាននៅក្នុងខ្លួនអាត្មាអញ ទោះវិចិកិច្ឆាមិនមាននៅក្នុងខ្លួន ក៏ដឹងច្បាស់ថា វិចិកិច្ឆាមិនមាននៅក្នុងខ្លួនអាត្មាអញ ។

យថា ច អនុប្បន្នាយ វិចិកិច្ឆាយ ឧប្បាទោ ហោតិ តញ្ច បជានាតិ យថា ច ឧប្បន្នាយ វិចិកិច្ឆាយ បហានំ ហោតិ តញ្ច បជានាតិ យថា ច បហីនាយ វិចិកិច្ឆាយ អាយតឹ អនុប្បាទោ ហោតិ តញ្ច បជានាតិ ។ ឥទំ វុច្ចតិ ភិក្ខវេ មនោសោចេយ្យំ ។ ឥមានិ ខោ ភិក្ខវេ តីណិ សោចេយ្យានីតិ ។

កាយសុចឹ វាចាសុចឹ
ចេតោសុចិមនាសវំ
សុចឹ សោចេយ្យសម្បន្នំ
អាហុ និន្ហាតបាបកន្តិ ។

[១២៤] តីណីមានិ ភិក្ខវេ មោនេយ្យានិ ។ កតមានិ តីណិ ។ កាយមោនេយ្យំ វចីមោនេយ្យំ

មួយទៀត កិរិយាកើតឡើងនៃវិចិកិច្ឆា ដែលមិនទាន់កើតឡើង ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ការលះបង់វិចិកិច្ឆាដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃវិចិកិច្ឆា ដែលកើតឡើងហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង កិរិយាមិនកើតតទៅទៀតនៃវិចិកិច្ឆា ដែលលះបង់ហើយ ដោយហេតុណា ក៏ដឹងច្បាស់នូវហេតុនោះផង ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ការស្អាតចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ការស្អាតមាន ៣ យ៉ាងប៉ុណ្ណេះ ។

អ្នកប្រាជ្ញទាំងឡាយ ពោលចំពោះបុគ្គល អ្នកស្អាតកាយ ស្អាតវាចា ស្អាតចិត្ត មិនមានអាសវៈ ជាអ្នកស្អាត បរិបូណ៌ដោយការស្អាត ថាជាបុគ្គលមានបាបលាងជ្រះហើយ ។

[១២៤] ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកប្រាជ្ញនេះ មាន ៣ យ៉ាង ។ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺភាពជាអ្នកប្រាជ្ញផ្លូវកាយ ១ ភាពជាអ្នកប្រាជ្ញផ្លូវវាចា ១

មនោមោនេយ្យំ ។ កតមញ្ច ភិក្ខវេ កាយមោនេយ្យំ ។ ឥធ ភិក្ខវេ ភិក្ខុ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ អព្រហ្មចរិយា បដិវិរតោ ហោតិ ។ឥទំ វុច្ចតិ ភិក្ខវេ កាយមោនេយ្យំ ។ កតមញ្ច ភិក្ខវេ វចីមោនេយ្យំ ។ ឥធ ភិក្ខវេ ភិក្ខុ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ ។ ឥទំ វុច្ចតិ ភិក្ខវេ វចីមោនេយ្យំ ។ កតមញ្ច ភិក្ខវេ មនោមោនេយ្យំ ។ ឥធ ភិក្ខវេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥទំ វុច្ចតិ ភិក្ខវេ មនោមោនេយ្យំ ។ ឥមានិ ខោ ភិក្ខវេ តីណិ មោនេយ្យានីតិ ។

ភាពជាអ្នកប្រាជ្ញផ្លូវចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភាពជាអ្នកប្រាជ្ញផ្លូវកាយ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ វៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តមិនប្រសើរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាពជាអ្នកប្រាជ្ញផ្លូវកាយ ។ ម្នាលភិក្ខុទាំងឡាយ ចុះភាពជាអ្នកប្រាជ្ញផ្លូវវាចា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ វៀរចាកការពោលពាក្យកុហក វៀរចាកការពោលពាក្យញុះញង់ វៀរចាកការពោលពាក្យអាក្រក់ វៀរចាកការពោលពាក្យឥតប្រយោជន៍ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាពជាអ្នកប្រាជ្ញផ្លូវវាចា ។ ម្នាលភិក្ខុទាំងឡាយ ចុះភាពជាអ្នកប្រាជ្ញផ្លូវចិត្ត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះបានធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិនិងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននេះ សម្រេចសម្រាន្តនៅ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភាពជាអ្នកប្រាជ្ញផ្លូវចិត្ត ។ ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកប្រាជ្ញមាន ៣ យ៉ាងប៉ុណ្ណោះ ។

កាយមុនឹ វាចាមុនឹ

ចេតោមុនិមនាសវំ

មុនឹ មោនេយ្យសម្បន្នំ

អាហុ សព្វប្បហាយិនន្តិ ។

អាបាយិកវគ្គោ ទុតិយោ ។

តស្សុទ្ទានំ

អាចាយិកោ ទុល្លភោ ច

អប្បមេយ្យំ អនេញ្ជកំ

អយំ អបណ្ណកម្មន្តោ

ទ្វេ ច សោចេយ្យមោនេយ្យាតិ ។

អ្នកប្រាជ្ញទាំងឡាយ ពោលចំពោះបុគ្គល ដែលជាអ្នកប្រាជ្ញផ្លូវកាយ ផ្លូវវាចា ផ្លូវចិត្ត មិនមានអាសវៈ ជាអ្នកប្រាជ្ញ បរិបូណ៌ដោយភាពជាអ្នកប្រាជ្ញ ថាជាអ្នកមានបាបលះបង់អស់ហើយ ។

ចប់ អាបាយិកវគ្គទី ២ ។

## ឧទ្ទាននៃអាបាយិកវគ្គនោះគឺ

ពោលអំពីបុគ្គលទៅកាន់អបាយ ១ អំពីបុគ្គលរកបានដោយក្រ ១ អំពីអប្បមេយ្យបុគ្គលជាដើម ១ អំពីបុគ្គលបានអរូបជ្ឈាន មិនញាប់ញ័រ ១ អំពីវិបត្តិមានសេចក្តីប្រៀបដោយបាសកា មានជ្រុងប្រាំមួយ ១ អំពីកម្មន្តវិបត្តិជាដើម ១ អំពីការស្អាតមានពីរលើក ១ អំពីភាពជាអ្នកប្រាជ្ញ ១ ។

# កុសិនារវគ្គោ

[១២៨] ឯកំ សមយំ ភគវា កុសិនារាយំ វិហរតិ ពលិហរណេ វនសណ្ឌេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច ឥធ ភិក្ខវេ ភិក្ខុ អញ្ញតរំ គាមំ វា និគមំ វា ឧបនិស្សាយ វិហរតិ ។ តមេនំ គហបតិ វា គហបតិបុត្តោ វា ឧបសង្កមិត្វា ស្វាតនាយ ភត្តេន និមន្តេតិ អាកង្ខមានោ ភិក្ខវេ ភិក្ខុ អធិវាសេតិ ។ សោ តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន តស្ស គហបតិស្ស វា គហបតិបុត្តស្ស វា និវេសនំ តេនុបសង្កមតិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទតិ ។ តមេនំ សោ គហបតិ វា គហបតិបុត្តោ វា បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេតិ សម្បវារេតិ ។ តស្ស ឯវំ ហោតិ សាធុ

# កុសិនារវគ្គ

[១២៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃឈ្មោះពលិហរណៈ[១] ជិតក្រុងកុសិនារា ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះចូលទៅនៅអាស្រ័យនឹងស្រុកឬនិគមណាមួយ ។ ឯគហបតីឬគហបតិបុត្រចូលទៅរកភិក្ខុនោះនិមន្តដោយភត្ត ដើម្បីឆាន់ក្នុងថ្ងៃស្អែក ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុដែលចង់ឆាន់ ក៏ទទួលនិមន្តន៍ ។ លុះកន្លងរាត្រីនោះទៅ ភិក្ខុនោះស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាព្រឹក រួចចូលទៅកាន់លំនៅគហបតីឬគហបតិបុត្រនោះ លុះចូលទៅដល់ហើយ អង្គុយលើអាសនៈដែលគេក្រាលបម្រុងទុក ។ គហបតីឬគហបតិបុត្រនោះ ក៏និមន្តភិក្ខុនោះឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រពៃណាស់ហ្ន៎

១ ព្រៃជាកន្លែងដែលមហាជននាំគ្រឿងបូជា ទៅបូជាពួកភូតបិសាច ។ អដ្ឋកថា ។

វត មាយំ គហបតិ វា គហបតិបុត្តោ វា បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេតិ សម្បវារេតីតិ ។ ឯវម្បិស្ស ហោតិ អហោ វត មាយំ គហបតិ វា គហបតិបុត្តោ វា អាយតឹបិ ឯវរូបេន បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេយ្យ សម្បវារេយ្យាតិ ។ សោ តំ បិណ្ឌបាតំ គធិតោ មុច្ឆិតោ អជ្ឈោបន្នោ អនាទីនវទស្សាវី អនិស្សរណប្បញ្ញោ បរិភុញ្ជតិ ។ សោ តត្ថ កាម-វិតក្កម្បិ វិតក្កេតិ ព្យាបាទវិតក្កម្បិ វិតក្កេតិ វិហឹសា-វិតក្កម្បិ វិតក្កេតិ ។ ឯវរូបស្សាហំ ភិក្ខវេ ភិក្ខុនោ ទិន្នំ ន មហប្ផលំ វទាមិ ។ តំ កិស្ស ហេតុ ។ បមត្តោ ហិ ភិក្ខវេ ភិក្ខុ វិហរតិ ។ ឥធ បន ភិក្ខវេ ភិក្ខុ អញ្ញតរំ គាមំ វា និគមំ វា ឧប-និស្សាយ វិហរតិ ។ តមេនំ គហបតិ វា គហបតិ-បុត្តោ វា ឧបសង្កមិត្វា ស្វាតនាយ ភត្តេន និមន្តេតិ

គហបតីឬគហបតិបុត្រនេះ និមន្តអញឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទ-នីយភោជនីយាហារ ដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ។ ភិក្ខុនោះ ក៏គិតយ៉ាងនេះទៀតថា ធ្វើម្តេចហ្ន៎ នឹងបានគហបតីឬគហបតិបុត្រនេះ និមន្តអញឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់មានទំនងយ៉ាងនេះ ដោយដៃខ្លួនឯង តទៅទៀតអេះ ។ ភិក្ខុនោះ មានចិត្តផ្តេកផ្តួល ជ្រុលជ្រប់ល្មោភ ជាអ្នកមិនឃើញទោស មិនមានបញ្ញាជាគ្រឿងរលាស់ខ្លួនចេញ បរិភោគនូវបិណ្ឌបាតនោះ ។ ភិក្ខុនោះ រមែងត្រិះរិះនូវកាមវិតក្កៈផង ត្រិះរិះនូវព្យាបាទវិតក្កៈផង ត្រិះរិះនូវវិហឹសាវិតក្កៈផងក្នុងបិណ្ឌបាតនោះ ។ ម្នាលភិក្ខុទាំងឡាយ ទានដែលទាយកឲ្យហើយដល់ភិក្ខុមានសភាពយ៉ាងនេះ តថាគតមិនហៅថាជាទានមានផលច្រើនទេ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុមានសេចក្តីប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ចូលទៅនៅអាស្រ័យនឹងស្រុកឬនិគមណាមួយ ។ ឯគហបតីឬគហបតិបុត្រចូលទៅរកភិក្ខុនោះ និមន្តដោយភត្ត ដើម្បីឆាន់ក្នុងថ្ងៃស្អែក

៤៣១



អាកង្ខមានោ ភិក្ខវេ ភិក្ខុ អធិវាសេតិ ។ សោ តស្សា រត្តិយា អច្ចយេន បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន តស្ស គហបតិស្ស វា គហបតិបុត្តស្ស វា និវេសនំ តេនុបសង្កមតិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទតិ ។ តមេនំ សោ គហបតិ វា គហបតិបុត្តោ វា បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេតិ សម្បវារេតិ ។ តស្ស ន ឯវំ ហោតិ សាធុ វត មាយំ គហបតិ វា គហបតិបុត្តោ វា បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេតិ សម្បវារេតីតិ ។ ឯវម្បិស្ស ន ហោតិ អហោ វត មាយំ គហបតិ វា គហបតិបុត្តោ វា អាយតឹបិ ឯវរូបេន បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេយ្យ សម្បវារេយ្យាតិ ។ សោ តំ បិណ្ឌបាតំ អគធិតោ អមុច្ឆិតោ អនជ្ឈោបន្នោ អាទីនវទស្សាវី និស្សរណប្បញ្ញោ បរិភុញ្ជតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលចង់ឆាន់ក៏ទទួលនិមន្តន៍ ។ លុះកន្លងរាត្រីនោះទៅ ភិក្ខុនោះស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាព្រឹក រួចចូលទៅកាន់លំនៅ នៃគហបតី ឬគហបតិបុត្រនោះ លុះចូលទៅដល់ហើយ អង្គុយលើអាសនៈ ដែលគេក្រាលបម្រុងទុក ។ គហបតី ឬ គហបតិបុត្រនោះ ក៏និមន្តភិក្ខុនោះ ឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ។ ភិក្ខុនោះ មិនមានសេចក្ដីត្រិះរិះយ៉ាងនេះថា ប្រពៃណាស់ហ្ន៎ គហបតីឬគហបតិបុត្រនេះ និមន្តអញឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ដោយដៃខ្លួនឯង ។ ទាំងមិនមានសេចក្ដីត្រិះរិះ យ៉ាងនេះថា ធ្វើម្ដេចហ្ន៎ នឹងបានគហបតីឬគហបតិបុត្រនេះ និមន្តអញឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារ ដ៏ផ្ចិតផ្ចង់មានទំនងដូច្នេះ ដោយដៃខ្លួនឯងតទៅទៀតឡើយ ។ ភិក្ខុនោះ មិនផ្ដេកផ្ដួល មិនជ្រុលជ្រប់ មិនល្មោភ ជាអ្នកឃើញទោស មានប្រាជ្ញាជាគ្រឿងរលាស់ខ្លួនចេញ បរិភោគនូវបិណ្ឌបាត្រនោះ ។

សោ តត្ថ នេក្ខម្មវិតក្កម្បិ វិតក្កេតិ អព្យាបាទវិតក្កម្បិ វិតក្កេតិ អវិហឹសាវិតក្កម្បិ វិតក្កេតិ ។ ឯវរូបស្សាហំ ភិក្ខវេ ភិក្ខុនោ និដ្ឋំ មហាប្ផលំ វទាមិ ។ តំ កិស្ស ហេតុ ។ អប្បមត្តោ ហិ ភិក្ខវេ ភិក្ខុ វិហរតីតិ ។

[១២៦] យស្មិំ ភិក្ខវេ ទិសាយំ ភិក្ខូ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ មនសិកាតុំបិ មេ ឯសា ភិក្ខវេ ទិសា ន ផាសុ ហោតិ បគេវ គន្តុំ និដ្ឋំ ឯត្ថ គច្ឆាមិ អទ្ធា តេ អាយស្មន្តោ តយោ ធម្មេ បជហឹសុ តយោ ធម្មេ ពហុលីមកំសុ ។ កតមេ តយោ ធម្មេ បជហឹសុ ។ នេក្ខម្មវិតក្កំ អព្យាបាទវិតក្កំ អវិហឹសាវិតក្កំ ។ ឥមេ តយោ ធម្មេ បជហឹសុ ។ កតមេ តយោ ធម្មេ ពហុលីមកំសុ ។

ភិក្ខុនោះ រមែងត្រិះរិះនូវនេក្ខម្មវិតក្កៈផង ត្រិះរិះនូវអព្យាបាទវិតក្កៈផង ត្រិះរិះនូវអវិហឹសាវិតក្កៈផង ក្នុងបិណ្ឌបាតនោះ ។ ម្នាលភិក្ខុទាំងឡាយ ទានដែលទាយកឲ្យហើយ ដល់ភិក្ខុមានសភាពយ៉ាងនេះ ទើបតថាគតហៅថា ជាទានមានផលច្រើន ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុមិនមានសេចក្តីប្រមាទ ។

[១២៦] ម្នាលភិក្ខុទាំងឡាយ ក្នុងទិសណា ភិក្ខុទាំងឡាយ បង្កហេតុ បង្កជម្លោះ ទាស់ទែងគ្នា ចាក់ដោតគ្នា ទៅវិញទៅមក ដោយលំពែងគឺមាត់ ម្នាលភិក្ខុទាំងឡាយ ទិសនោះមិនជាទីសប្បាយដល់តថាគត ដើម្បីធ្វើទុកក្នុងចិត្ត មិនបាច់និយាយ ដល់ការដើរទៅឡើយ តថាគតចូលចិត្តក្នុងការណ៍នោះថា អ្នកមានអាយុទាំងឡាយនោះ បានលះបង់នូវធម៌ ៣ យ៉ាង បានធ្វើរឿយៗ នូវធម៌ ៣ យ៉ាងដោយពិតប្រាកដ ។ ចុះភិក្ខុទាំងនោះលះបង់នូវធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺនេក្ខម្មវិតក្កៈ ១ អព្យាបាទវិតក្កៈ ១ អវិហឹសាវិតក្កៈ ១ ។ ភិក្ខុទាំងនោះ លះបង់ធម៌ ៣ យ៉ាងនេះឯង ។ ចុះភិក្ខុទាំងនោះ បានធ្វើរឿយ ៗ នូវធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។

៤៣៣



កាមវិតក្កំ ព្យាបាទវិតក្កំ វិហឹសាវិតក្កំ ។ ឥមេ តយោ ធម្មេ ពហុលីមកំសុ ។ យស្សំ ភិក្ខវេ ទិសាយំ ភិក្ខូ ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ មនសិកាតុំបិ មេ ឯសា ភិក្ខវេ ទិសា ន ផាសុ ហោតិ បគេវ គន្តុំ និដ្ឋំ ឯត្ថ គច្ឆាមិ អទ្ធា តេ អាយស្មន្តោ ឥមេ តយោ ធម្មេ បជហឹសុ ឥមេ តយោ ធម្មេ ពហុលីមកំសុ ។ យស្សំ ភិក្ខវេ ទិសាយំ ភិក្ខូ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរន្តិ គន្តុំបិ មេ ឯសា ភិក្ខវេ ទិសា ផាសុ ហោតិ បគេវ មនសិកាតុំ និដ្ឋំ ឯត្ថ គច្ឆាមិ អទ្ធា តេ អាយស្មន្តោ[១] តយោ ធម្មេ បជហឹសុ តយោ ធម្មេ ពហុលីមកំសុ ។ កតមេ តយោ ធម្មេ បជហឹសុ ។

---

១ ឱ. ឯត្ថន្តរេ ឥមេតិ ទិស្សតិ ។

គឺកាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ ។ ភិក្ខុទាំងនោះ បានធ្វើរឿយៗ នូវធម៌ ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងទិសណា ភិក្ខុទាំងឡាយ បង្កហេតុ បង្កជម្លោះ ទាស់ទែងគ្នា ចាក់ដោតគ្នាទៅវិញទៅមកដោយលំពែងគឺមាត់ ម្នាលភិក្ខុទាំងឡាយ ទិសនេះមិនជាទីសប្បាយដល់តថាគតដើម្បីធ្វើទុកក្នុងចិត្តទេ មិនចាំបាច់និយាយ ដល់ការដើរទៅឡើយ តថាគតចូលចិត្តក្នុងការណ៍នោះថា អ្នកមានអាយុទាំងនោះ បានលះបង់នូវធម៌ ៣ យ៉ាងនេះឯង បានធ្វើឲ្យរឿយៗ នូវធម៌ ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងទិសណា ភិក្ខុទាំងឡាយ ព្រមព្រៀងគ្នា រីករាយនឹងគ្នា មិនទាស់ទែងគ្នា ដូចទឹកដោះស្រស់លាយដោយទឹក មើលគ្នាត្រង់ដោយចក្ខុជាទីស្រឡាញ់ ម្នាលភិក្ខុទាំងឡាយ ទិសនុ៎ះ ជាទីសប្បាយដល់តថាគតដើម្បីដើរទៅ មិនបាច់និយាយ ដល់ការធ្វើទុកក្នុងចិត្តឡើយ តថាគតចូលចិត្ត ក្នុងការណ៍នោះថា អ្នកមានអាយុទាំងនោះ បានលះបង់នូវធម៌ ៣ យ៉ាង បានធ្វើឲ្យរឿយៗ នូវធម៌ ៣ យ៉ាង ដោយពិតប្រាកដ ។ អ្នកមានអាយុទាំងនោះ បានលះបង់ធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។

កាមវិតក្កំ ព្យាបាទវិតក្កំ វិហឹសាវិតក្កំ ។ ឥមេ តយោ ធម្មេ បជហឹសុ ។ កតមេ តយោ ធម្មេ ពហុលីមកំសុ ។ នេក្ខម្មវិតក្កំ អព្យាបាទវិតក្កំ អវិហឹសាវិតក្កំ ។ ឥមេ តយោ ធម្មេ ពហុលីមកំសុ ។ យស្សំ ភិក្ខវេ ទិសាយំ ភិក្ខូ សមគ្គា សម្មោទមានា អវិវទមានា ខីរោទកីភូតា អញ្ញមញ្ញំ បិយចក្ខូហិ សម្បស្សន្តា វិហរន្តិ គន្តុំបិ មេ ឯសា ភិក្ខវេ ទិសា ផាសុ ហោតិ បគេវ មនសិកាតុំ និដ្ឋំ ឯត្ថ គច្ឆាមិ អទ្ធា តេ អាយស្មន្តោ ឥមេ តយោ ធម្មេ បជហឹសុ ឥមេ តយោ ធម្មេ ពហុលីមកំសូតិ ។

[១២៧] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ គោតមកេ ចេតិយេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច អភិញ្ញាយាហំ ភិក្ខវេ ធម្មំ ទេសេមិ នោ អនភិញ្ញាយ

គឺកាមវិតក្កៈ ១ ព្យាបាទវិតក្កៈ ១ វិហឹសាវិតក្កៈ ១ ។ ភិក្ខុទាំងនោះ បានលះបង់ធម៌ ៣ យ៉ាងនេះឯង ។ ចុះភិក្ខុទាំងនោះ បានធ្វើឲ្យ រឿយៗ នូវធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺនេក្ខម្មវិតក្កៈ ១ អព្យាបាទវិតក្កៈ ១ អវិហឹសាវិតក្កៈ ១ ។ អ្នកទាំងនោះបានធ្វើរឿយៗ នូវធម៌ ៣ យ៉ាងនេះ ឯង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងទិសណា ភិក្ខុទាំងឡាយ ព្រមព្រៀង គ្នា រីករាយនឹងគ្នា មិនទាស់ទែងគ្នា ដូចទឹកដោះស្រស់លាយដោយទឹក មើលគ្នាត្រង់ដោយចក្ខុជាទីស្រឡាញ់ ម្នាលភិក្ខុទាំងឡាយ ទិសនុ៎ះជា ទីសប្បាយដល់តថាគត ដើម្បីដើរទៅ មិនបាច់និយាយដល់ការធ្វើទុកក្នុង ចិត្តឡើយ តថាគតចូលចិត្តក្នុងការណ៍នោះថា អ្នកមានអាយុទាំងនោះ បានលះបង់នូវធម៌ ៣ យ៉ាងនេះឯង បានធ្វើឲ្យរឿយៗ នូវធម៌ ៣ យ៉ាង នេះឯង ដោយពិតប្រាកដ ។

[១២៧] សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅ ក្នុង គោតមកចេតិយ[១] ជិតក្រុងវេសាលី ។ ក្នុងទីនោះឯង ព្រះមាន ព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌ ដើម្បីឲ្យចេះដឹង មិនមែនដើម្បីមិនឲ្យចេះដឹងទេ

១ ចេតិយនោះ ជាលំនៅនៃយក្ខឈ្មោះគោតមកៈ ។ អដ្ឋកថា ។

សនិទានាហំ ភិក្ខវេ ធម្មំ ទេសេមិ នោ អនិទានំ សប្បាដិហារិយាហំ ភិក្ខវេ ធម្មំ ទេសេមិ នោ អប្បាដិហារិយំ ។ តស្ស មយ្ហំ ភិក្ខវេ អភិញ្ញាយ ធម្មំ ទេសយតោ នោ អនភិញ្ញាយ សនិទានំ ធម្មំ ទេសយតោ នោ អនិទានំ សប្បាដិហារិយំ ធម្មំ ទេសយតោ នោ អប្បាដិហារិយំ ករណីយោ ឱវាទោ ករណីយា អនុសាសនី ។ អលញ្ច បន វោ ភិក្ខវេ តុដ្ឋិយា អលំ អត្តមនតាយ អលំ សោមនស្សាយ សម្មាសម្ពុទ្ធោ ភគវា ស្វាក្ខាតោ ភគវតា ធម្មោ សុប្បដិបន្នោ សង្ឃោតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ[១] ។ ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ សហស្សី លោកធាតុ អកម្បិត្ថាតិ ។

---

១ អភិនន្ទុន្តិប្បត្តិ ។

ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌សមតាមហេតុ មិនមែនមិនសមតាមហេតុទេ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងធម៌ប្រកបដោយសេចក្តីអស្ចារ្យ មិនមែនមិនប្រកបដោយសេចក្តីអស្ចារ្យទេ ។ ម្នាលភិក្ខុទាំងឡាយ កាលបើតថាគតនោះ សម្តែងធម៌ ដើម្បីចេះដឹង មិនមែនដើម្បីមិនឲ្យចេះដឹង សម្តែងធម៌សមតាមហេតុ មិនមែនមិនសមតាមហេតុ សម្តែងធម៌ប្រកបដោយសេចក្តីអស្ចារ្យ មិនមែនមិនប្រកបដោយសេចក្តីអស្ចារ្យ អ្នកទាំងឡាយ គួរធ្វើតាមឱវាទ គួរធ្វើតាមអនុសាសនី ។ ម្នាលភិក្ខុទាំងឡាយមួយទៀត អ្នកទាំងឡាយ គួរត្រេកអរ គួរពេញចិត្ត គួររីករាយ (ចំពោះគុណព្រះរតនត្រ័យ) ថា ព្រះមានព្រះភាគ ជាព្រះសម្មាសម្ពុទ្ធ ព្រះធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ ព្រះសង្ឃប្រតិបត្តិដោយប្រពៃ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។ ក៏កាលដែលព្រះមានព្រះភាគសម្តែងនូវវេយ្យាករណ៍នេះចប់ហើយ លោកធាតុទាំង ១ ពាន់ក៏កក្រើករញ្ជួយ ។

[១២៨] ឯកំ សមយំ ភគវា កោសលេសុ ចារិកំ ចរមានោ យេន កបិលវត្ថុ តទវសរិ ។ អស្សោសិ ខោ មហានាមោ សក្កោ ភគវា កិរ កបិលវត្ថុំ អនុប្បត្តោតិ ។ អថខោ មហានាមោ សក្កោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ មហានាមំ សក្កំ ភគវា ឯតទវោច គច្ឆ មហានាម កបិលវត្ថុស្មឹ តថារូបំ អាវសថំ ជាន យត្ថជ្ជ មយំ ឯករត្តឹ វិហរេយ្យាមាតិ ។ ឯវំ ភន្តេតិ ខោ មហានាមោ សក្កោ ភគវតោ បដិស្សុណិត្វា កបិលវត្ថុំ បវិសិត្វា កេវលកប្បំ កបិលវត្ថុំ អាហិណ្ឌន្តោ[១] ន អទ្ទស កបិលវត្ថុស្មឹ តថារូបំ អាវសថំ យត្ថ ភគវា ឯករត្តឹ វិហរេយ្យ ។ អថខោ មហានាមោ សក្កោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច នត្ថិ ភន្តេ កបិលវត្ថុស្មឹ តថារូបោ អាវសថោ យត្ថជ្ជ ភគវា ឯករត្តឹ វិហរេយ្យ

១ ឱ. ម. អន្ទាហិណ្ឌន្តោ ។

[១២៨] សម័យមួយ ព្រះមានព្រះភាគទ្រង់ស្តេចទៅកាន់ចារិកក្នុងកោសលជនបទ ក៏ស្តេចទៅដល់ក្រុងកបិលព័ស្តុ ។ មហានាមសក្យរាជបានជ្រាបថា ព្រះមានព្រះភាគទ្រង់ស្តេចមកដល់ក្រុងកបិលព័ស្តុហើយ ។ លំដាប់នោះ មហានាមសក្យរាជ ស្តេចចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមានព្រះភាគ រួចប្រថាប់ក្នុងទីសមគួរ ។ លុះមហានាមសក្យរាជ ប្រថាប់ក្នុងទីសមគួរហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា បពិត្រមហានាម សូមទ្រង់ស្តេចទៅពិនិត្យមើលលំនៅ ក្នុងក្រុងកបិលព័ស្តុ ដែលជាទីគួរតថាគតនៅអស់មួយយប់ក្នុងថ្ងៃនេះ ។ មហានាមសក្យរាជ ទទួលព្រះតម្រាស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយស្តេចយាងក្រឡឹងមើលក្រុងកបិលព័ស្តុទាំងមូល ក៏មិនបានឃើញលំនៅ ក្នុងក្រុងកបិលព័ស្តុ ដែលជាទីគួរព្រះមានព្រះភាគគង់នៅអស់មួយយប់បាន ។ វេលានោះ មហានាមសក្យរាជ ទ្រង់ស្តេចត្រឡប់ចូលមកគាល់ព្រះមានព្រះភាគវិញ លុះចូលមកដល់ហើយបានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន លំនៅក្នុងក្រុងកបិលព័ស្តុ ដែលជាទីគួរព្រះអង្គគង់នៅអស់មួយយប់ក្នុងថ្ងៃនេះមិនមានទេ

អយំ ភន្តេ ភរណ្ឌុ[១] កាលាមោ ភគវតោ បុរាណសព្រហ្មចារី តស្សជ្ជ ភគវា អស្សមេ ឯករត្តឹ វិហរតូតិ ។ គច្ឆ មហានាម សន្ថរំ បញ្ញាបេហីតិ ។ ឯវំ ភន្តេតិ ខោ មហានាមោ សក្កោ ភគវតោ បដិស្សុណិត្វា យេន ភរណ្ឌុស្ស កាលាមស្ស អស្សមោ តេនុបសង្កមិ ឧបសង្កមិត្វា សន្ថរំ បញ្ញាបេត្វា ឧទកំ ឋបេត្វា បាទានំ ធោវនាយ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច សន្ថតោ ភន្តេ សន្ថរោ ឧទកំ ឋបិតំ បាទានំ ធោវនាយ យស្សទានិ ភន្តេ ភគវា កាលំ មញ្ញតីតិ ។ អថខោ ភគវា យេន ភរណ្ឌុស្ស កាលាមស្ស អស្សមោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ និសជ្ជ ខោ ភគវា បាទេ បក្ខាលេសិ ។ អថខោ មហានាមស្ស សក្កស្ស ឯតទហោសិ អកាលោ ខោ អជ្ជ

១ ម. ភទន្ត ។

បពិត្រព្រះអង្គដ៏ចម្រើន តាបសឈ្មោះភរណ្ឌុកាលាមនេះ ជាសព្រហ្មចារីបុគ្គលជាន់ចាស់របស់ព្រះអង្គ សូមព្រះអង្គគង់នៅក្នុងអាស្រមរបស់តាបសនោះអស់មួយយប់ក្នុងថ្ងៃនេះចុះ ។ ព្រះសម្ពុទ្ធត្រាស់ថា បពិត្រមហានាម សូមទ្រង់ស្ដេចទៅឲ្យក្រាលកម្រាលចុះ ។ មហានាមសក្យរាជ បានទទួលព្រះតម្រាស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយស្ដេចចូលទៅឯអាស្រមរបស់ភរណ្ឌុកាលាមតាបស លុះស្ដេចចូលទៅដល់ហើយ ក៏ឲ្យក្រាលកម្រាលលើគ្រែតូចដ៏សមគួរ ហើយឲ្យតម្កល់ទឹកទុក ដើម្បីលាងព្រះបាទ រួចស្ដេចត្រឡប់ចូលមកគាល់ព្រះមានព្រះភាគវិញ លុះចូលមកដល់ហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កម្រាលក្រាលហើយ ទឹកសម្រាប់លាងព្រះបាទ តម្កល់ទុកហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ជ្រាបនូវកាលដ៏គួរនឹងស្ដេចក្នុងកាលឥឡូវនេះចុះ ។ គ្រានោះឯង ព្រះមានព្រះភាគ ស្ដេចចូលទៅឯអាស្រមរបស់ភរណ្ឌុកាលាមតាបស លុះស្ដេចចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលបម្រុងទុក លុះព្រះមានព្រះភាគគង់ហើយក៏លាងជូតព្រះបាទទាំងគូ ។ លំដាប់នោះ មហានាមសក្យរាជ ទ្រង់មានព្រះរាជតម្រិះដូច្នេះថា ថ្ងៃនេះ ជាកាលមិនគួរ

ភគវន្តំ បយិរុបាសិតុំ កិលន្តោ ភគវា សេ្វទានាហំ ភគវន្តំ បយិរុបាសិស្សាមីតិ ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ មហានាមោ សក្កោ តស្សា រត្តិយា អច្ចយេន យេន ភគវា តេនុប-សង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ មហានាមំ សក្កំ ភគវា ឯតទវោច តយោ ខោ មេ មហានាម សត្ថារោ សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ ឥធ មហានាម ឯកច្ចោ សត្ថា កាមានំ បរិញ្ញំ បញ្ញាបេតិ ន រូបានំ បរិញ្ញំ បញ្ញាបេតិ ន វេទនានំ បរិញ្ញំ បញ្ញាបេតិ ។ ឥធ បន មហានាម ឯកច្ចោ សត្ថា កាមានញ្ច បរិញ្ញំ បញ្ញាបេតិ រូបានញ្ច បរិញ្ញំ បញ្ញាបេតិ ន វេទនានំ បរិញ្ញំ បញ្ញាបេតិ ។ ឥធ បន មហានាម ឯកច្ចោ សត្ថា កាមានញ្ច បរិញ្ញំ បញ្ញាបេតិ រូបានញ្ច បរិញ្ញំ បញ្ញាបេតិ វេទនានញ្ច បរិញ្ញំ បញ្ញាបេតិ ។ ឥមេ ខោ មហានាម តយោ សត្ថារោ សន្តោ សំវិជ្ជមានា លោកស្មឹ ។

នឹងចូលទៅគាល់ព្រះមានព្រះភាគទេ ព្រោះព្រះមានព្រះភាគ កំពុងនឿយព្រះកាយ ឥឡូវអាត្មាអញ ចាំចូលទៅគាល់ព្រះមានព្រះភាគក្នុងថ្ងៃស្អែកវិញចុះ មហានាមសក្យរាជក៏ថ្វាយបង្គំលាព្រះមានព្រះភាគធ្វើប្រទក្សិណហើយស្តេចចេញទៅ ។ លំដាប់នោះ មហានាមសក្យ-រាជ លុះកន្លងរាត្រីនោះទៅ ក៏ស្តេចចូលទៅគាល់ព្រះមានព្រះភាគលុះស្តេចចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចប្រថាប់ក្នុងទីសមគួរ ។ លុះមហានាមសក្យរាជ ប្រថាប់ក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា បពិត្រមហានាម សាស្តា ៣ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ សាស្តា ៣ ពួក ដូចម្តេចខ្លះ ។ បពិត្រមហានាម សាស្តាពួកខ្លះ ក្នុងលោកនេះ បញ្ញត្តការកន្លងនូវកាមគឺបឋមជ្ឈាន មិនបញ្ញត្តការកន្លងនូវរូបគឺអរូបាវចរសមាបត្តិ មិនបញ្ញត្តការកន្លងនូវវេទនាគឺនិព្វាន ។ បពិត្រមហានាម មួយទៀត សាស្តាពួកខ្លះ ក្នុងលោកនេះ បញ្ញត្តការកន្លងនូវកាមផង បញ្ញត្តការកន្លងនូវរូបផង តែមិនបញ្ញត្តការកន្លងនូវវេទនា ។ បពិត្រមហានាម មួយវិញទៀត សាស្តាពួកខ្លះ ក្នុងលោកនេះ បញ្ញត្តការកន្លងនូវកាមផងបញ្ញត្តការកន្លងនូវរូបផង បញ្ញត្តការកន្លងនូវវេទនាផង ។ បពិត្រមហានាម សាស្តា ៣ ពួកនេះឯង រមែងមានប្រាកដក្នុងលោក ។

៤៣៩



ឥមេសំ មហានាម តិណ្ណំ សត្ថារានំ ឯកា និដ្ឋា ឧទាហុ បុថុ និដ្ឋាតិ ។ ឯវំ វុត្តេ ភរណ្ឌុ កាលាមោ មហានាមំ សក្កំ ឯតទវោច ឯកាតិ មហានាម វទេហីតិ ។ ឯវំ វុត្តេ ភគវា មហានាមំ សក្កំ ឯតទវោច នានាតិ មហានាម វទេហីតិ ។ ទុតិយម្បិ ខោ ភរណ្ឌុ កាលាមោ មហានាមំ សក្កំ ឯតទវោច ឯកាតិ មហានាម វទេហីតិ ។ ទុតិយម្បិ ខោ ភគវា មហានាមំ សក្កំ ឯតទវោច នានាតិ មហានាម វទេហីតិ ។ តតិយម្បិ ខោ ភរណ្ឌុ កាលាមោ មហានាមំ សក្កំ ឯតទវោច ឯកាតិ មហានាម វទេហីតិ ។ តតិយម្បិ ខោ ភគវា មហានាមំ សក្កំ ឯតទវោច នានាតិ មហានាម វទេហីតិ ។

បពិត្រមហានាម ចុះសាស្តា ៣ ពួកនេះ មានសេចក្តីយល់ដូចគ្នាឬមាន សេចក្តីយល់ផ្សេងគ្នា ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាស់សួរយ៉ាងនេះ ភរណ្ឌុកាលាមតាបស បានបង្គាប់មហានាមសក្យរាជ ដូច្នេះថា បពិត្រមហានាម សូមមហាបពិត្រមានព្រះរាជឱង្ការថា មានសេចក្តីយល់ដូចគ្នា ។ កាលភរណ្ឌុកាលាមតាបស និយាយយ៉ាងនេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងមហានាមសក្យរាជ ដូច្នេះថា បពិត្រមហានាម សូមទ្រង់មានព្រះរាជឱង្ការថា មានសេចក្តីយល់ផ្សេងគ្នាដូច្នេះវិញ ។ ភរណ្ឌុកាលាម-តាបស បានបង្គាប់មហានាមសក្យរាជអស់ ២ ដងថា បពិត្រមហានាម សូមមហាបពិត្រ មានព្រះរាជឱង្ការថា មានសេចក្តីយល់ដូចគ្នា ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងមហានាមសក្យរាជអស់ ២ ដង ទៀតថា បពិត្រមហានាម សូមទ្រង់មានព្រះរាជឱង្ការថា មានសេចក្តីយល់ផ្សេងគ្នាដូច្នេះវិញ ។ ភរណ្ឌុកាលាមតាបស បានបង្គាប់មហានាមសក្យរាជអស់ ៣ ដងថា បពិត្រមហានាម សូមមហាបពិត្រ មានព្រះរាជឱង្ការថា មានសេចក្តីយល់ដូចគ្នា ។ ព្រះមានព្រះភាគបានត្រាស់នឹងមហានាមសក្យរាជអស់ ៣ ដងទៀតថា បពិត្រមហានាម សូមទ្រង់មានព្រះរាជឱង្ការថា មានសេចក្តីយល់ផ្សេងគ្នាដូច្នេះវិញ ។

អថខោ ភរណ្ឌុស្ស កាលាមស្ស ឯតទហោសិ មហេសក្ខស្ស វតម្ហិ មហានាមស្ស សក្កស្ស សម្មុខា សមណេន គោតមេន យាវត-តិយកំ អបសាទិតោ យន្នូនាហំ កបិលវត្ថុម្ហា បក្កមេយ្យន្តិ ។ អថខោ ភរណ្ឌុ កាលាមោ កបិលវត្ថុម្ហា បក្កាមិ(១) តថាបក្កន្តោវ អហោសិ ន បុន បច្ចាគច្ឆីតិ ។

[១២៩] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ ហត្ថកោ ទេវបុត្តោ អភិក្កន្តាយ រត្តិយា អភិក្កន្ត-វណ្ណោ កេវលកប្បំ ជេតវនំ ឱភាសេត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតោ បុរតោ ឋស្សាមីតិ ឱសីទតិ សំសីទតិ ន សក្កោតិ សណ្ឋាតុំ ។

១ ឱ. ឯត្ថន្តរេ យំ កបិលវត្ថុម្ហា បក្កាមីតិ ទិស្សន្តិ ។

លំដាប់នោះ ភរណ្ឌុកាលាមតាបស មានសេចក្តីត្រិះរិះដូច្នេះថា មិនសមបើព្រះសមណគោតម មិនជ្រះថ្លានឹងអញ អស់ ៣ ដង ក្នុងទីចំពោះព្រះភក្ត្រមហានាមសក្យរាជដែលមានសក្តិធំសោះ បើដូច្នោះ អញគួរដើរចេញអំពីក្រុងកបិលព័ស្តុ ។ លំដាប់នោះ ភរណ្ឌុកាលាម-តាបស ក៏ចេញអំពីកបិលព័ស្តុ គឺចេញទៅតែម្តង មិនបានត្រឡប់មកក្រោយវិញឡើយ ។

[១២៩] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រាកាលរាត្រីកន្លងបឋមយាម ទេវបុត្រឈ្មោះ ហត្ថកៈ មានសម្បុរល្អ ធ្វើវត្តជេតពនទាំងមូលឲ្យភ្លឺច្បាស់ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏គិតថា អញនឹងឈរក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគដូច្នេះ ហើយត្រឡប់អន្ទុយស្រពាប អន្ទុយរាបវិញ មិនអាចនឹងឈរនៅបានឡើយ ។

៤៤១



សេយ្យថាបិ នាម សប្បិ វា តេលំ វា វាលិកាយ អាសិត្តំ ឱសីទតិ សំសីទតិ ន សណ្ឋាតិ ឯវមេវ ហត្ថកោ ទេវបុត្តោ ភគវតោ បុរតោ ឋស្សាមីតិ ឱសីទតិ សំសីទតិ ន សក្កោតិ សណ្ឋាតុំ ។ អថខោ ភគវា ហត្ថកំ ទេវបុត្តំ ឯតទវោច ឱឡារិកំ ហត្ថក អត្តភាវំ អភិនិម្មិនា-ហីតិ ។ ឯវំ ភន្តេតិ ខោ ហត្ថកោ ទេវបុត្តោ ភគវតោ បដិស្សុណិត្វា ឱឡារិកំ អត្តភាវំ អភិនិ-ម្មិនិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ ហត្ថកំ ទេវបុត្តំ ភគវា ឯតទវោច យេ តេ ហត្ថក ធម្មា បុព្វេ មនុស្សភូតស្ស បវត្តិនោ អហេសុំ អបិនុ តេ តេ ធម្មា ឯតរហិ បវត្តិនោតិ ។ យេ ច មេ ភន្តេ ធម្មា បុព្វេ មនុស្សភូតស្ស

ទឹកដោះថ្លាឬប្រេង ដែលគេចាក់ស្រោចទៅក្នុងដីខ្សាច់ រមែងជ្រួតជ្រាប លិចចុះបាត់ទៅ មិនដក់នៅ យ៉ាងណាមិញ ហត្ថកទេវបុត្រគិតថា អញ នឹងឈរ ក្នុងទីចំពោះព្រះភក្ត្រព្រះមានព្រះភាគ ដូច្នេះ ហើយត្រឡប់ អន្ទុយស្រពាប អន្ទុយរាបវិញ មិនអាចឈរនៅបាន ក៏យ៉ាងនោះឯង ។ វេលានោះ ព្រះមានព្រះភាគត្រាស់បង្គាប់ហត្ថកទេវបុត្រដូច្នេះថា ម្នាល ហត្ថកៈ អ្នកចូរនិម្មិតនូវអត្តភាពឲ្យធំសម្បើម ។ ហត្ថកទេវបុត្របានទទួល ព្រះតម្រាស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គដូច្នេះហើយ និម្មិត អត្តភាពឲ្យធំសម្បើម ថ្វាយបង្គំព្រះមានព្រះភាគ រួចឈរក្នុងទីដ៏សមគួរ ។ លុះហត្ថកទេវបុត្រ ឈរក្នុងទីសមគួរហើយ ព្រះមានព្រះភាគត្រាស់ សួរដូច្នេះថា ម្នាលហត្ថកៈ ធម៌ណា ដែលអ្នកកាលកើត ជាមនុស្ស ក្នុងភពមុន បានប្រព្រឹត្តហើយ តើធម៌ទាំងនោះ អ្នកបានប្រព្រឹត្ត ក្នុង កាលឥឡូវនេះដែរឬទេ ។ ហត្ថកទេវបុត្រ ក្រាបបង្គំទូលថា បពិត្រ ព្រះអង្គដ៏ចម្រើន ធម៌ណា ដែលខ្ញុំព្រះអង្គកាលកើតជាមនុស្ស ក្នុងភពមុន

បវត្តិនោ អហេសុំ តេ ច មេ ធម្មា ឯតរហិ បវត្តិនោ យេ ច មេ ភន្តេ ធម្មា បុព្វេ មនុស្សភូតស្ស នប្បវត្តិនោ អហេសុំ តេ ច មេ ធម្មា ឯតរហិ បវត្តិនោ សេយ្យថាបិ ភន្តេ ភគវា ឯតរហិ អាកិណ្ណោ វិហរតិ ភិក្ខូហិ ភិក្ខុនីហិ ឧបាសកេហិ ឧបាសិកាហិ រាជូហិ រាជមហាមត្តេហិ តិត្ថិយេហិ តិត្ថិយសាវកេហិ ឯវមេវ ខោ អហំ ភន្តេ អាកិណ្ណោ វិហរាមិ ទេវបុត្តេហិ ទូរតោបិ ភន្តេ ទេវបុត្តា អាគច្ឆន្តិ ហត្ថកស្ស ទេវបុត្តស្ស សន្តិកេ ធម្មំ សោស្សាមាតិ តិណ្ណាហំ ភន្តេ ធម្មានំ អតិត្តោ អប្បដិវានោ កាលកតោ ។ កតមេសំ តិណ្ណំ ។ ភគវតោ អហំ ភន្តេ ទស្សនស្ស អតិត្តោ អប្បដិវានោ កាលកតោ សទ្ធម្មស្សវនស្សាហំ ភន្តេ អតិត្តោ អប្បដិវានោ កាលកតោ សង្ឃស្សាហំ ភន្តេ ឧបដ្ឋានស្ស អតិត្តោ អប្បដិវានោ កាលកតោ ឥមេសំ ខោ អហំ ភន្តេ តិណ្ណំ ធម្មានំ អតិត្តោ អប្បដិវានោ កាលកតោតិ ។

បានប្រព្រឹត្តហើយ ធម៌ទាំងនោះ ខ្ញុំព្រះអង្គបានប្រព្រឹត្ត ក្នុងកាលឥឡូវនេះដែរ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ណាដែលខ្ញុំព្រះអង្គកាលកើត ជាមនុស្សក្នុងភពមុន មិនបានប្រព្រឹត្តទេ ធម៌ទាំងនោះ ក៏ខ្ញុំព្រះអង្គប្រព្រឹត្តក្នុងកាលឥឡូវនេះដែរ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគទ្រង់គង់ប្រឡូកប្រឡំដោយភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ស្តេច អាមាត្យធំរបស់ស្តេច តិរ្ថិយ និងសាវ័ក នៃតិរ្ថិយទាំងឡាយ ក្នុងកាលឥឡូវនេះយ៉ាងណាមិញ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គក៏យ៉ាងនោះដែរ តែងនៅប្រឡូកប្រឡំដោយទេវបុត្រទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន ទេវបុត្រទាំងឡាយ តែងមកអំពីទីឆ្ងាយ ដោយបំណងថា យើងនឹងស្តាប់ធម៌ក្នុងសំណាក់ហត្ថកទេវបុត្រ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឆ្អែតមិនរួញរានឹងធម៌ទាំង ៣ ត្រាតែធ្វើមរណកាល ។ ធម៌ ៣ ដូចម្តេចខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មិនឆ្អែត មិនរួញរានឹងការរមិលមើលព្រះមានព្រះភាគ ត្រាតែធ្វើមរណកាល ១ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មិនឆ្អែត មិនរួញរានឹងការស្តាប់ព្រះសទ្ធម្ម ត្រាតែធ្វើមរណ-កាល ១ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ មិនឆ្អែត មិនរួញរានឹងការបម្រើសង្ឃ ត្រាតែធ្វើមរណកាល ១ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនឆ្អែត មិនរួញរានឹងធម៌ទាំង ៣ នេះឯង ត្រាតែធ្វើមរណកាល ។

៤៤៣



ភគវតោ   ឧស្សូឡស្ស
តិត្ថិ   អទ្ធា   កុឌាចជំ
សង្ឃស្ស   ឧបដ្ឋានស្ស
សទ្ធម្មស្សវេនស្ស   ច   ។
អធិសីលំ   សិក្ខមានោ
សទ្ធម្មស្សវនេ   រតោ
តិណ្ណំ   ធម្មានមតិត្តោ
ហាត្ថកោ   អរិយំ   គតោតិ   ។

[១៣០] ឯកំ សមយំ ភគវា ពារាណសិយំ វិហរតិ ឥសិបតនេ មិគទាយេ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ ពារាណសឹ បិណ្ឌាយ បាវិសិ ។ អទ្ទសា ខោ ភគវា គោយោគមិលក្ខស្មឹ បិណ្ឌាយ ចរមានោ[១] អញ្ញតរំ ភិក្ខុំ រិត្តស្សាទំ ពាហិរស្សាទំ មុដ្ឋស្សតឹ អសម្បជានំ អសមាហិតំ វិព្ភន្តចិត្តំ បាកតិន្ទ្រិយំ ទិស្វា តំ ភិក្ខុំ ឯតទវោច មា ខោ ត្វំ ភិក្ខុ អត្តានំ កដុវិយមកាសិ

១. ម. ចរមានំ ។

(ការផ្អែត ៣ យ៉ាង) គឺ ផ្អែតនឹងការមើលព្រះមានព្រះភាគ ១ ផ្អែតនឹងការបម្រើព្រះសង្ឃ ១ ផ្អែតនឹងការស្តាប់ព្រះសទ្ធម្ម ១ មានក្នុងកាលម្តងៗ តែប៉ុណ្ណោះ ។ ហត្ថកទេវបុត្រ កាលសិក្សានូវអធិសីល ត្រេកអរក្នុងការស្តាប់ព្រះសទ្ធម្ម មិនផ្អែតនឹងធម៌ ៣ ប្រការ ក៏បានទៅកើតក្នុងអវិហាព្រហ្មលោក ។

[១៣០] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាបុព្វណ្ហសម័យ ទ្រង់ចូលទៅកាន់ក្រុងពារាណសី ដើម្បីបិណ្ឌបាត ។ កាលព្រះមានព្រះភាគ ទ្រង់ស្តេចទៅបិណ្ឌបាត ក្នុងសំណាក់នៃមិលក្ខជន អ្នកលក់គោ ទ្រង់បានឃើញភិក្ខុមួយរូប មានសេចក្តីត្រេកអរតិច មានសេចក្តីត្រេកអរខាងក្រៅ ប្រាសចាកសតិ មិនមានប្រាជ្ញា មានចិត្តមិនតាំងមាំ មានចិត្តរវើរវាយ មានឥន្រ្ទិយជាប្រក្រតី (មិនរក្សាឥន្រ្ទិយ) លុះទតឃើញហើយ ទ្រង់មានព្រះវាចានឹងភិក្ខុនោះដូច្នេះថា ម្នាលភិក្ខុ អ្នកកុំធ្វើខ្លួនឲ្យស្អុយឡើយ

តំ វត ភិក្ខុ កដុវិយកតំ អត្តានំ អាមគន្ធេ អវស្សុតំ មក្ខិកា នានុបតិស្សន្តិ នាន្វាស្សវិស្សន្តីតិ[១] នេតំ ឋានំ វិជ្ជតីតិ ។ អថខោ សោ ភិក្ខុ ភគវតា ឥមិនា ឱវាទេន ឱវទិតោ សំវេគមាបាទីតិ ។

អថខោ ភគវា ពារាណសិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ ភិក្ខូ អាមន្តេសិ ឥធាហំ ភិក្ខវេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ ពារាណសឹ បិណ្ឌាយ បាវិសឹ អទ្ទសំ ខោ អហំ ភិក្ខវេ គោយោគបិលក្ខស្មឹ បិណ្ឌាយ ចរមានោ អញ្ញតរំ ភិក្ខុំ រិត្តស្សាទំ ពាហិរស្សាទំ មុដ្ឋស្សតឹ អសម្បជានំ អសមាហិតំ វិព្ភន្តចិត្តំ បាកតិន្ទ្រិយំ ទិស្វា តំ ភិក្ខុំ ឯតទវោចំ មា ខោ ត្វំ ភិក្ខុ អត្តានំ កដុវិយមកាសិ តំ វត ភិក្ខុ កដុវិយកតំ អត្តានំ អាមគន្ធេ អវស្សុតំ មក្ខិកា នានុបតិស្សន្តិ នាន្វាស្សវិស្សន្តីតិ នេតំ ឋានំ វិជ្ជតីតិ

---
១ ម. នានុពន្ធិស្សន្តិ ។

ម្នាលភិក្ខុ ពួករុយ[១] នឹងមិនចោមហើរតាម នឹងមិនតាមចោមស៊ី នូវខ្លួន ដែលធ្វើឲ្យស្អុយ ដែលប្រឡាក់វត្ថុ មានក្លិនឆ្អេះឆ្អាបនោះ[២] ហេតុនុ៎ះមិន មានទេ ។ លំដាប់នោះឯង ភិក្ខុនោះ លុះព្រះមានព្រះភាគទូន្មាន ដោយឱវាទនេះហើយ ក៏ដល់នូវសេចក្តីសំវេគ (បានជាសោតាបន្ន-បុគ្គល) ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅដើម្បី បិណ្ឌបាត ក្នុងក្រុងពារាណសី លុះស្តេចត្រឡប់មក អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុ ទាំងឡាយ ក្នុងទីឯណោះ តថាគតបានស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងពារាណសី ដើម្បីបិណ្ឌបាត ម្នាលភិក្ខុទាំងឡាយ កាលតថាគតត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងសំណាក់ នៃមិលក្ខជន អ្នកលក់គោ ក៏បានឃើញភិក្ខុមួយរូប មានសេចក្តីត្រេកអរ តិច មានសេចក្តីត្រេកអរខាងក្រៅ ប្រាសចាកសតិ មិនមានប្រាជ្ញា មាន ចិត្តមិនតាំងមាំ មានចិត្តរវើរវាយ មានឥន្ទ្រិយជាប្រក្រតី លុះបានឃើញ ហើយ និយាយនឹងភិក្ខុនោះដូច្នេះថា ម្នាលភិក្ខុ អ្នកកុំធ្វើខ្លួនឲ្យស្អុយឡើយ ម្នាលភិក្ខុ ពួករុយនឹងមិនចោមហើរតាម មិនតាមរោមស៊ីនូវខ្លួនដែលធ្វើ ឲ្យស្អុយ ដែលប្រឡាក់វត្ថុ មានក្លិនឆ្អេះឆ្អាបនោះ ហេតុនុ៎ះមិនមានទេ

---

១ បានដល់ពួកកិលេស ។ ២ បានដល់សេចក្តីក្រោធ ។ អដ្ឋកថា ។

៤៤៨



អថខោ សោ ភិក្ខវេ ភិក្ខុ មយា ឥមិនា ឱវាទេន ឱវទិតោ សំវេគមាបាទីតិ ។ ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច កិន្នុខោ ភន្តេ កដុវិយំ កោ អាមគន្ធោ កា មក្ខិកាតិ ។ អភិជ្ឈា ខោ ភិក្ខុ កដុវិយំ ព្យាបាទោ អាមគន្ធោ បាបកា អកុសលា វិតក្កា មក្ខិកា តំ វត ភិក្ខុ កដុវិយកតំ អត្តានំ អាមគន្ធេ អវស្សុតំ មក្ខិកា នានុបតិស្សន្តិ នាន្វាស្សវិស្សន្តីតិ នេតំ ឋានំ វិជ្ជតីតិ ។

អគុត្តំ ចក្ខុសោតស្មឹ
ឥន្ទ្រិយេសុ អសំវុតំ
មក្ខិកានុបតិស្សន្តិ
សង្កប្បា រាគនិស្សិតា ។
កដុវិយកតោ ភិក្ខុ
អាមគន្ធេ អវស្សុតោ
អារកា ហោតិ និព្វានា
វិឃាតស្សេវ ភាគវា ។

ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ភិក្ខុនោះ លុះតថាគតទូន្មានដោយឱវាទនេះហើយ ក៏ដល់នូវសេចក្តីសំវេគ ។ កាលព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូបបានក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជារបស់ស្អុយ អ្វីជារបស់មានក្លិនឆ្អេះឆ្អាប អ្វីជារុយ ។ ម្នាលភិក្ខុ អភិជ្ឈាជារបស់ស្អុយ ព្យាបាទជារបស់មានក្លិនឆ្អេះឆ្អាប អកុសលវិតក្កៈដ៏លាមកជាតួរុយ ។ ម្នាលភិក្ខុ ពួករុយនឹងមិនចោមហើរតាម នឹងមិនតាមចោមស៊ី នូវខ្លួនដែលធ្វើឲ្យស្អុយ ដែលប្រឡាក់វត្ថុមានក្លិនឆ្អេះឆ្អាបនោះ ហេតុនុ៎ះមិនមានទេ ។

ពួករុយគឺសេចក្តីត្រិះរិះដែលអាស្រ័យនូវរាគៈ នឹងតាមរោមនូវបុគ្គលដែលមិនគ្រប់គ្រង ក្នុងចក្ខុទ្វារនិងសោតទ្វារ មិនសង្រួមក្នុងឥន្ទ្រិយ ។ ភិក្ខុដែលធ្វើខ្លួនឲ្យស្អុយប្រឡាក់វត្ថុ មានក្លិនឆ្អេះឆ្អាប ជាអ្នកឆ្ងាយអំពីព្រះនិព្វាន មានចំណែកនៃសេចក្តីចង្អៀតចង្អល់ចិត្តតែម្យ៉ាង ។

កាមេ វា យទិ វា រញ្ញេ
អលទ្ធា សមមត្តនោ
ចរេ ពាលោ ទុម្មេធោ
មក្ខិកាហិ បុរក្ខតោ ។
យេ ច សីលេន សម្បន្នា
បញ្ញាយូបសមេ រតា
ឧបសន្តា សុខំ សេន្តិ
នាសយិត្វាន មក្ខិកាតិ ។

[១៣១] អថខោ អាយស្មា អនុរុទ្ធោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អនុរុទ្ធោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន យេភុយ្យេន បស្សាមិ មាតុគ្គាមំ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជមានំ ។ កតីហិ នុ ខោ ភន្តេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតីតិ ។

បុគ្គលពាល អប្បឥតប្រាជ្ញា ដែលពួករុយតាមរោម (នោះ) មិនបានប្រព្រឹត្តនូវធម៌ ដ៏ស្មោះស្មើដើម្បីខ្លួនក្នុងស្រុកឬក្នុងព្រៃឡើយ ។ ចំណែកខាងជនណាបរិបូណ៌ដោយសីលនិងបញ្ញា ត្រេកអរក្នុងធម៌ជាគ្រឿងរម្ងាប់នូវកិលេស ជាអ្នកស្ងប់ស្ងាត់ ជននោះ រមែងដេកជាសុខ ទាំងពួករុយក៏មិនបានហើរតាមស៊ីជននោះឡើយ ។

[១៣១] គ្រានោះ ព្រះអនុរុទ្ធមានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអនុរុទ្ធមានអាយុគង់ក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងបង់ចក្ខុជារបស់មនុស្សធម្មតា ឃើញមាតុគ្រាម ដែលបែកធ្លាយរាងកាយស្លាប់ទៅ ច្រើនតែទៅកើត ឯអបាយ ទុគ្គតិ វិនិបាត នរក ។ បពិត្រព្រះអង្គដ៏ចម្រើន មាតុគ្រាមប្រកបដោយធម៌ប៉ុន្មានយ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើត ឯអបាយ ទុគ្គតិ វិនិបាត នរក ។

តីហិ ខោ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតិ ។ កតមេហិ តីហិ ។ ឥធ អនុរុទ្ធ មាតុគ្គាមោ បុព្វណ្ហសមយំ មច្ឆេរមលបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ មជ្ឈន្តិកសមយំ ឥស្សាបរិ-យុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ សាយណ្ហសមយំ កាមរាគបរិយុដ្ឋិតេន ចេតសា អគារំ អជ្ឈាវសតិ ។ ឥមេហិ ខោ អនុរុទ្ធ តីហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជតីតិ ។

[១៣២] អថខោ អាយស្មា អនុរុទ្ធោ យេនាយស្មា សារីបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា សារីបុត្តេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អនុរុទ្ធោ អាយស្មន្តំ សារីបុត្តំ ឯតទវោច ឥធាហំ អាវុសោ សារីបុត្ត ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សហស្សំ លោកំ ឱលោកេមិ អារទ្ធំ ខោ បន មេ វីរិយំ

ព្រះមានព្រះភាគត្រាស់តបថា ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៣ យ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។ ប្រកបដោយធម៌ ៣ យ៉ាងដូចម្តេចខ្លះ ។ ម្នាលអនុរុទ្ធ ក្នុងលោកនេះ មាតុគ្រាម រមែងមានចិត្តត្រូវមន្ទិល គឺសេចក្តីកំណាញ់ រួបរឹត នៅគ្រប់គ្រងផ្ទះ ក្នុងបុព្វណ្ហសម័យ ១ រមែងមានចិត្តត្រូវឥស្សា រួបរឹត នៅគ្រប់គ្រងផ្ទះ ក្នុងមជ្ឈន្តិកសម័យ ១ រមែងមានចិត្តត្រូវកាមរាគ រួបរឹត នៅគ្រប់គ្រងផ្ទះក្នុងសាយណ្ហសម័យ ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាម ប្រកបដោយធម៌ ៣ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក ។

[១៣២] គ្រានោះ ព្រះអនុរុទ្ធមានអាយុ ចូលទៅរកព្រះសារីបុត្រមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះសា-រីបុត្រមានអាយុ លុះបញ្ចប់ពាក្យគួររីករាយ និងពាក្យគួររព្ញកហើយគង់ក្នុងទីសមគួរ ។ លុះព្រះអនុរុទ្ធមានអាយុ គង់ក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះសារីបុត្រមានអាយុដូច្នេះថា ម្នាលអាវុសោ សារីបុត្រ ខ្ញុំតែងឃើញសត្វលោកជាច្រើន ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា មួយទៀត សេចក្តីព្យាយាមដែលខ្ញុំប្រារព្ធហើយ

អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា[១] បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គំ អថ ច បន មេ ជានុបាទាជាយ អាសវេហិ ចិត្តំ វិមុច្ចតីតិ ។ យំ ខោ តេ អាវុសោ អនុរុទ្ធ ឯវំ ហោតិ អហំ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សហស្សំ លោកំ ឱលោកេមីតិ ឥទន្តេ មានស្មឹ យម្បិ តេ អាវុសោ អនុរុទ្ធ ឯវំ ហោតិ អារទ្ធំ ខោ បន មេ វីរិយំ អសល្លីនំ ឧបដ្ឋិតា សតិ អប្បម្មុដ្ឋា បស្សទ្ធោ កាយោ អសារទ្ធោ សមាហិតំ ចិត្តំ ឯកគ្គន្តិ ឥទន្តេ ឧទ្ធច្ចស្មឹ យម្បិ តេ អាវុសោ អនុរុទ្ធ ឯវំ ហោតិ អថ ច បន មេ ជានុបាទាជាយ អាសវេហិ ចិត្តំ វិមុច្ចតីតិ ឥទន្តេ កុក្កុច្ចស្មឹ សាធុ វត អាយស្មា អនុរុទ្ធោ ឥមេ តយោ ធម្មេ បហាយ ឥមេ តយោ ធម្មេ អមនសិការិត្វា អមតាយ ធាតុយា ចិត្តំ ឧបសំហរតូតិ ។

១ ឱ. ម. សម្មុដ្ឋា ។

មិនបានរួញរាឡើយ សតិដែលខ្ញុំបានតាំងស៊ប់ហើយ ក៏មិនបានវង្វេងភ្លេច កាយរបស់ខ្ញុំដែលស្ងប់រម្ងាប់ហើយ ក៏មិនបានក្រវល់ក្រវាយ ចិត្តដែលខ្ញុំតម្កល់ខ្ជាប់ហើយ ក៏ជាចិត្តមានអារម្មណ៍មូលតែមួយ កាលបើដូច្នេះ ចិត្តរបស់ខ្ញុំក៏មិនរួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ ។ ព្រះសារីបុត្រតបថា ម្នាលអាវុសោអនុរុទ្ធ ត្រង់ពាក្យដែលអ្នកនិយាយយ៉ាងនេះថា ខ្ញុំតែងឃើញសត្វលោកជាច្រើន ដោយចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតាដូច្នេះ នេះជាមានះរបស់អ្នក ម្នាលអាវុសោអនុរុទ្ធ មួយទៀត ត្រង់ពាក្យដែលអ្នកនិយាយយ៉ាងនេះថា សេចក្តីព្យាយាមដែលខ្ញុំប្រារព្ធហើយ មិនបានរួញរាឡើយ សតិដែលខ្ញុំបានតាំងស៊ប់ហើយ ក៏មិនបានវង្វេងភ្លេច កាយរបស់ខ្ញុំដែលស្ងប់រម្ងាប់ហើយ ក៏មិនបានក្រវល់ក្រវាយ ចិត្តដែលខ្ញុំតម្កល់ខ្ជាប់ហើយ ក៏ជាចិត្តមានអារម្មណ៍មូលតែមួយដូច្នេះ នេះជាឧទ្ធច្ចៈរបស់អ្នកទេ ម្នាលអាវុសោអនុរុទ្ធ មួយទៀត ត្រង់ពាក្យដែលអ្នកនិយាយយ៉ាងនេះថា កាលបើដូច្នេះ ចិត្តរបស់ខ្ញុំក៏មិនរួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់មាំ នេះជាកុក្កុច្ចៈរបស់អ្នក ខ្ញុំសូមរំលឹក សូមអនុរុទ្ធមានអាយុលះបង់ធម៌ទាំង ៣ នេះចេញ កុំធ្វើទុកក្នុងចិត្តនូវធម៌ទាំង ៣ នេះ សូមប្រមូលចិត្តមកក្នុងអមតធាតុវិញ ។

អថខោ អាយស្មា អនុរុទ្ធោ អបរេន សមយេន ឥមេ តយោ ធម្មេ បហាយ ឥមេ តយោ ធម្មេ អមនសិការិត្វា អមតាយ ធាតុយា ចិត្តំ ឧបសំហាសិ ។ អថខោ អាយស្មា អនុរុទ្ធោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ នចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បនាយស្មា អនុរុទ្ធោ អរហតំ អហោសីតិ ។

[១៣៣] តីណិមានិ ភិក្ខវេ បដិច្ឆន្នានិ វហន្តិ[១] នោ វិវដានិ ។ កតមានិ តីណិ ។ មាតុគ្គាមោ ភិក្ខវេ បដិច្ឆន្នោ វហតិ នោ វិវដោ

១ ម. អាវហន្តិ ។

សម័យតមក ព្រះអនុរុទ្ធមានអាយុ បានលះបង់ធម៌ទាំង ៣ នេះ ហើយ មិនធ្វើទុកក្នុងចិត្ត នូវធម៌ទាំង ៣ នេះ ហើយប្រមូលចិត្តក្នុងអមតធាតុ ។ លំដាប់នោះ ព្រះអនុរុទ្ធមានអាយុតែមួយអង្គឯង ចៀសចេញចាកពួក មិនមានសេចក្តីប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្តចេញចាកផ្ទះ ចូលកាន់ផ្នួសដោយប្រពៃ ដើម្បីអនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវអនុត្តរធម៌នោះ ដែលមានព្រហ្មចរិយៈជាទីបំផុត ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្ន បានដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយធម៌ អញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្តទាំងឡាយ ព្រះអនុរុទ្ធមានអាយុ ក៏ជាព្រះអរហន្តមួយអង្គដែរ ។

[១៣៣] ម្នាលភិក្ខុទាំងឡាយ វត្ថុ ៣ យ៉ាងនេះ បិទបាំងទើបប្រសើរ[១] បើកផ្សាយមិនប្រសើរ ។ វត្ថុ ៣ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺមាតុគ្រាមបិទបាំងទើបប្រសើរ បើកផ្សាយ មិនប្រសើរ[២] ១

---

១ វហន្តិ សព្ទនេះ ប្រែថា បានការ គាប់គួរ ប្រសើរ ថ្លៃថ្នូរ ។

២ ស្រីៗ ដែលមិនប្រព្រឹត្តគោរពកោតក្រែងប្តី ឬប្រព្រឹត្តទុច្ចរិតផ្សេងៗ ដែលជាអំពើមិនគាប់ចិត្តប្តីៗ ត្រូវបិទបាំងទោសរបស់ប្រពន្ធនោះទើបគួរ បើកសំញៀងមិនគួរទេ ចំណែកស្ត្រីក្រមុំដែលប្រព្រឹត្តឆ្នាំឆ្គង ក៏ត្រូវតែមាតាបិតាជាដើម ជួយបិទបាំងទើបគួរ បើកសំញៀងមិនគួរ ។ មតិរបស់យើង ។

ព្រាហ្មណានំ ភិក្ខវេ មន្តា បដិច្ឆន្នា វហន្តិ នោ វិវដា មិច្ឆាទិដ្ឋិ ភិក្ខវេ បដិច្ឆន្នា វហតិ នោ វិវដា ។ ឥមានិ ខោ ភិក្ខវេ តីណិ បដិច្ឆន្នានិ វហន្តិ នោ វិវដានិ ។ តីណីមានិ ភិក្ខវេ វិវដានិ វិរោចន្តិ នោ បដិច្ឆន្នានិ ។ កតមានិ តីណិ ។ ចន្ទមណ្ឌលំ ភិក្ខវេ វិវដំ វិរោចតិ នោ បដិច្ឆន្នំ សុរិយមណ្ឌលំ ភិក្ខវេ វិវដំ វិរោចតិ នោ បដិច្ឆន្នំ តថាគតប្បវេទិតោ ធម្មវិនយោ ភិក្ខវេ វិវដោ វិរោចតិ នោ បដិច្ឆន្នោ ។ ឥមានិ ខោ ភិក្ខវេ តីណិ វិវដានិ វិរោចន្តិ នោ បដិច្ឆន្នានីតិ ។

[១៣៤] តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ បាសាណលេខូបមោ បុគ្គលោ បឋវីលេខូបមោ បុគ្គលោ ឧទកលេខូបមោ បុគ្គលោ ។ កតមោ ច ភិក្ខវេ បាសាណលេខូបមោ បុគ្គលោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អភិណ្ហំ កុជ្ឈតិ

ម្នាលភិក្ខុទាំងឡាយ មន្តរបស់ពួកព្រាហ្មណ៍ លាក់ទើបប្រសើរ បើកផ្សាយ មិនប្រសើរ ១ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិ បិទបាំង ទើបប្រសើរ បើកផ្សាយ មិនប្រសើរ ១ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុ ៣ យ៉ាងនេះឯង បិទបាំង ទើបប្រសើរ បើកផ្សាយ មិនប្រសើរទេ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុ ៣ យ៉ាងនេះ បើកទើបរុងរឿង បិទមិនរុងរឿងទេ ។ វត្ថុ ៣ យ៉ាងគឺអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ គឺមណ្ឌលព្រះចន្ទ្រ បើកទើបរុងរឿង បិទមិនរុងរឿង ១ ម្នាលភិក្ខុទាំងឡាយ មណ្ឌលព្រះអាទិត្យ បើកទើបរុងរឿង បិទមិនរុងរឿង ១ ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យដែលតថាគតសម្តែងហើយ បើកទើបរុងរឿង បិទមិនរុងរឿង ១ ។ ម្នាលភិក្ខុទាំងឡាយ វត្ថុ ៣ យ៉ាងនេះឯង បើកទើបរុងរឿង បិទមិនរុងរឿងទេ ។

[១៣៤] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ មានប្រាកដក្នុងលោក ។ បុគ្គល ៣ ពួក ដូចម្តេចខ្លះ ។ គឺបុគ្គលប្រៀបដូចគំនូសថ្ម ១ បុគ្គលប្រៀបដូចគំនូសផែនដី ១ បុគ្គលប្រៀបដូចគំនូសទឹក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលប្រៀបដូចគំនូសថ្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងក្រោធរឿយៗ

សោ ច ខ្វស្ស កោធោ ទីឃរត្តំ អនុសេតិ ។ សេយ្យថាបិ ភិក្ខវេ បាសាណេ លេខា ន ខិប្បំ លុជ្ជតិ វាតេន វា ឧទកេន វា ចិរដ្ឋិតិកា ហោតិ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ អភិណ្ហំ កុជ្ឈតិ សោ ច ខ្វស្ស កោធោ ទីឃរត្តំ អនុសេតិ ។ អយំ វុច្ចតិ ភិក្ខវេ បាសាណលេខូបមោ បុគ្គលោ ។ កតមោ ច ភិក្ខវេ បថវីលេខូបមោ បុគ្គលោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អភិណ្ហំ កុជ្ឈតិ សោ ច ខ្វស្ស កោធោ ន ទីឃរត្តំ អនុសេតិ ។ សេយ្យថាបិ ភិក្ខវេ បថវិយំ លេខា ខិប្បំ លុជ្ជតិ វាតេន វា ឧទកេន វា ន ចិរដ្ឋិតិកា ហោតិ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ អភិណ្ហំ កុជ្ឈតិ សោ ច ខ្វស្ស កោធោ ន ទីឃរត្តំ អនុសេតិ ។ អយំ វុច្ចតិ ភិក្ខវេ បថវីលេខូបមោ បុគ្គលោ ។ កតមោ ច ភិក្ខវេ ឧទកលេខូបមោ បុគ្គលោ ។ ឥធ ភិក្ខវេ ឯកច្ចោ បុគ្គលោ អាគាឡ្ហេនបិ វុច្ចមានោ ផរុសេនបិ វុច្ចមានោ

ឯសេចក្តីក្រោធរបស់គេនោះ រមែងដេកត្រាំនៅអស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ គំនូសថ្ម រមែងមិនឆាប់រលុបដោយខ្យល់ឬដោយទឹកទេ ជាគំនូសតាំងនៅអស់កាលយូរយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងក្រោធរឿយៗ ឯសេចក្តីក្រោធរបស់គេនោះ រមែងដេកត្រាំនៅអស់កាលយូរអង្វែង ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលប្រៀបដូចគំនូសថ្ម ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលប្រៀបដូចគំនូសផែនដី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងក្រោធរឿយៗ តែសេចក្តីក្រោធរបស់គេនោះ មិនបានដេកត្រាំនៅអស់កាលយូរអង្វែង ។ ម្នាលភិក្ខុទាំងឡាយ គំនូសផែនដី រមែងឆាប់រលុបដោយខ្យល់ ឬ ដោយទឹក ជាគំនូសមិនតាំងនៅអស់កាលយូរ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ រមែងក្រោធរឿយៗ តែសេចក្តីក្រោធរបស់គេនោះ មិនបានដេកត្រាំនៅអស់កាលយូរអង្វែង ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា បុគ្គលប្រៀបដូចស្នាមគំនូសផែនដី ។ ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលប្រៀបដូចគំនូសទឹក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលគេនិយាយពាក្យរឹងរូសក្តី និយាយពាក្យអាក្រក់ក្តី

អមនាបេនបិ វុច្ចមានោ សន្ធិយតិយេវ សំសន្ទតិយេវ សម្មោទតិយេវ ។ សេយ្យថាបិ ភិក្ខវេ ឧទកេ លេខា ខិប្បំយេវ បដិវិគច្ឆតិ ន ចិរដ្ឋិតិកា ហោតិ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចោ បុគ្គលោ អាគាឡ្ហេនបិ វុច្ចមានោ ផរុសេនបិ វុច្ចមានោ អមនាបេនបិ វុច្ច-មានោ សន្ធិយតិយេវ សំសន្ទតិយេវ សម្មោទតិ-យេវ ។ អយំ វុច្ចតិ ភិក្ខវេ ឧទកលេខូបមោ បុគ្គលោ ។ ឥមេ ខោ ភិក្ខវេ តយោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

កុសិនារវគ្គោ តតិយោ ។

## តស្សុទ្ទានំ

កុសិនា ភណ្ឌនា ចេវ
គោតមភរណ្ឌុហត្ថកា
កដុវិយង្វេ អនុរុទ្ធា
បដិច្ឆន្នំ លេខេន តេ ទសាតិ ។

និយាយពាក្យមិនជាទីគាប់ចិត្តក្តី តែងឆាប់និយាយតបតទៅវិញ ឆ្លើយឆ្លង ស្រួលវិញ រីករាយទៅរកវិញ ។ ម្នាលភិក្ខុទាំងឡាយ គំនូសទឹក រមែង រលុបឆាប់ មិនតាំងនៅអស់កាលយូរ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ដែលគេនិយាយពាក្យរឹងរូសក្តី និយាយពាក្យ អាក្រក់ក្តី និយាយពាក្យមិនជាទីគាប់ចិត្តក្តី រមែងឆាប់និយាយតបតទៅវិញ ឆ្លើយឆ្លងស្រួលវិញ រីករាយទៅរកវិញ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា បុគ្គលប្រៀបដូចគំនូសទឹក ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះឯង មានប្រាកដក្នុងលោក ។

ចប់ កុសិនារវគ្គ ទី ៣ ។

# ឧទ្ទាននៃកុសិនារវគ្គនោះគឺ

និយាយអំពីព្រះមានព្រះភាគ គង់ជិតក្រុងកុសិនារា ១ អំពីពួកភិក្ខុបង្កហេតុ ទាស់ទែងគ្នា ១ អំពីព្រះដ៏ មានព្រះភាគ គង់នៅក្នុងគោតមកចេតិយ ១ អំពី ភរណ្ឌុកាលាមតាបស ១ អំពីហត្ថកទេវបុត្ត ១ អំពីភិក្ខុ ធ្វើខ្លួនឲ្យស្អុយ ១ អំពីព្រះអនុរុទ្ធ ២ លើក អំពីវត្ថុ ដែលបិទបាំង ១ អំពីគំនូស ១ រួបរួមត្រូវជា ១០ ។

# យោធាជីវវគ្គោ

[១៣៤] តីហិ ភិក្ខវេ អង្គេហិ សមន្នាគតោ យោធាជីវោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេ្វវ សង្ខំ គច្ឆតិ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ យោធាជីវោ ទូរេបាតី ច ហោតិ អក្ខណវេធី ច មហតោ ច កាយស្ស បទាលេតា ។ ឥមេហិ ខោ ភិក្ខវេ តីហិ អង្គេហិ សមន្នាគតោ យោធាជីវោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេ្វវ សង្ខំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ តីហិ ធម្មេហិ(១) សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ ភិក្ខុ ទូរេបាតី ច ហោតិ អក្ខណវេធី ច មហតោ ច កាយស្ស បទាលេតា ។ កថញ្ច ភិក្ខវេ ភិក្ខុ ទូរេបាតី ហោតិ ។

១ ឱ. ម. អង្គេហិ ។

# យោធាជីវវគ្គ

[១៣៥] ម្នាលភិក្ខុទាំងឡាយ យោធាជីវៈ (អ្នករស់នៅដោយឋានៈជាទាហាន) ប្រកបដោយអង្គ ៣ ទើបគួរជាយោធាជីវៈរបស់ព្រះរាជា អ្នកបម្រើរបស់ព្រះរាជា ដល់នូវការរាប់ថាជាអង្គ[១] របស់ព្រះរាជា ។ ប្រកបដោយអង្គ ៣ តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈក្នុងលោកនេះ ជាអ្នកបាញ់បានឆ្ងាយ ១ ជាអ្នកបាញ់មិនខុស ១ ជាអ្នកទម្លាយគំនរធំៗ[២] បាន ១ ។ ម្នាលភិក្ខុទាំងឡាយ យោធាជីវៈប្រកបដោយអង្គ ៣ នេះឯងទើបគួរជារបស់ព្រះរាជា ជាអ្នកបម្រើនៃព្រះរាជា ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ម្នាលភិក្ខុទាំងឡាយ ចំណែកភិក្ខុប្រកបដោយធម៌ ៣ យ៉ាង ទើបជាអ្នកគួរទទួលនូវទានដែលគេនាំមកបូជា ។ បេ ។ ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ក៏យ៉ាងនោះដែរ ។ ប្រកបដោយធម៌ ៣ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកបាញ់បានឆ្ងាយ ១ ជាអ្នកបាញ់មិនខុស ១ ជាអ្នកទម្លាយគំនរធំៗ បាន ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ ជាអ្នកបាញ់បានឆ្ងាយ តើដូចម្ដេច ។

១ ទុកដូចជាអវយវៈគឺព្រះហស្ថទាំង ២ ព្រះបាទទាំង ២ របស់ស្ដេច ។

២ ទម្លាយនូវកងទ័ពមានអាវុធយុទ្ធភណ្ឌ ច្រើនសង្កាត់ ច្រើនស្រទាប់ ។ អដ្ឋកថា ។

តំ កិំ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។

ឥធ ភិក្ខវេ ភិក្ខុ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ យា កាចិ វេទនា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា[១] វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្វា វេទនា នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ យា កាចិ សញ្ញា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា យា ទូរេ សន្តិកេ វា សព្វា សញ្ញា នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ យេ កេចិ សង្ខារា អតីតានាគតប្បច្ចុប្បន្នា អជ្ឈត្តា វា ពហិទ្ធា វា ឱឡារិកា វា សុខុមា វា ហីនា វា បណីតា វា

១ ឱ. អជ្ឈត្តំ ។

ម្នាលភិក្ខុទាំងឡាយ រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី រូបណា ជិតក្តី ឆ្ងាយក្តី ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញ នូវរូបទាំងអស់នុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វេទនាណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វេទនាណា ជិតក្តី ឆ្ងាយក្តី ភិក្ខុពិចារណាឃើញនូវវេទនា ទាំងអស់នុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ សញ្ញាណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី សញ្ញាណា ជិតក្តី ឆ្ងាយក្តី ភិក្ខុពិចារណាឃើញនូវសញ្ញាទាំងអស់នុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ សង្ខារទាំងឡាយណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី

យេ ទូរេ សន្តិកេ វា សព្វេ សង្ខារា នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ ទូរេបាតី ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ អក្ខណវេធី ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ ឯវំ ខោ ភិក្ខវេ ភិក្ខុ អក្ខណវេធី ហោតិ ។ កថញ្ច ភិក្ខវេ ភិក្ខុ មហតោ កាយស្ស បទាលេតា ហោតិ ។ ឥធ ភិក្ខវេ ភិក្ខុ មហន្តំ អវិជ្ជាខន្ធំ បទាលេតិ ។

សង្ខារទាំងឡាយណា ជិតក្តី ឆ្ងាយក្តី ភិក្ខុពិចារណាឃើញនូវសង្ខារទាំងអស់នុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ វិញ្ញាណណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី វិញ្ញាណណា ជិតក្តី ឆ្ងាយក្តី ភិក្ខុពិចារណាឃើញនូវវិញ្ញាណទាំងអស់នុ៎ះ ដោយបញ្ញាដ៏ប្រពៃ តាមសេចក្តីពិតយ៉ាងនេះថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនជាខ្លួនរបស់អញ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបាញ់បានឆ្ងាយយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ ជាអ្នកបាញ់មិនខុស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាសេចក្តីរលត់ទុក្ខ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាសេចក្តីប្រតិបត្តិ ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកបាញ់មិនខុសយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះភិក្ខុ ជាអ្នកទម្លាយគំនរធំៗ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទម្លាយគំនរនៃអវិជ្ជាដ៏ធំបាន ។

ឯវំ ខោ ភិក្ខវេ ភិក្ខុ មហតោ កាយស្ស បធា-លេតា ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[១៣៦] តិស្សោ ឥមា ភិក្ខវេ បរិសា ។ កតមា តិស្សោ ។ ឧក្កាចិតវិនីតា បរិសា បដិបុច្ឆាវិនីតា បរិសា យាវតជ្ឈាវិនីតា បរិសា ។ ឥមា ខោ ភិក្ខវេ តិស្សោ បរិសាតិ ។

[១៣៧] តីហិ ភិក្ខវេ អង្គេហិ សមន្នាគតោ មិត្តោ សេវិតព្វោ ។ កតមេហិ តីហិ[១] ។ ទុទ្ទទំ ទទាតិ ទុក្ករំ ករោតិ ទុក្ខមំ ខមតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ អង្គេហិ សមន្នាគតោ មិត្តោ សេវិតព្វោតិ ។

---

១ ឱ. ម. ឥតោ បរំ ឥធ ភិក្ខវេ ភិក្ខូតិ ទិស្សតិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកទម្លាយគំនរធំៗ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ទើបជាអ្នកគួរទទួលនូវទានដែលបុគ្គលនាំមកបូជា ។ បេ ។ ជាស្រែបុណ្យដ៏ប្រសើររបស់សត្វលោក ។

[១៣៦] ម្នាលភិក្ខុទាំងឡាយ បរិសទ្យនេះ មាន ៣ ពួក ។ បរិសទ្យ ៣ ពួកគឺអ្វីខ្លះ ។ គឺបរិសទ្យ ដែលសិក្សាផ្តេសផ្តាស[១] ១ បរិសទ្យដែលសាកសួររួចទើបសិក្សា ១ បរិសទ្យ ដែលសិក្សាតាមកំណត់[២] ១ ។ ម្នាលភិក្ខុទាំងឡាយ បរិសទ្យមាន ៣ ពួកនេះឯង ។

[១៣៧] ម្នាលភិក្ខុទាំងឡាយ មិត្តប្រកបដោយអង្គ ៣ គួរសេពគប់ ។ ប្រកបដោយអង្គ ៣ គឺអ្វីខ្លះ ។ គឺមិត្តឲ្យវត្ថុដែលគេឲ្យបានដោយក្រ ១ ធ្វើនូវអំពើដែលគេធ្វើបានដោយក្រ ១ អត់ធន់នូវហេតុដែលគេអត់ធន់បានដោយក្រ ១ ។ ម្នាលភិក្ខុទាំងឡាយ មិត្តប្រកបដោយអង្គ ៣ នេះឯង គួរសេពគប់ ។

---

១ បានដល់បរិសទ្យដែលមិនសាកសួរជាមុន ស្រាប់តែប្រតិបត្តិតែម្តង ។

២ បានដល់បរិសទ្យដែលដឹងប្រមាណ ហើយប្រតិបត្តិ ។ អដ្ឋកថា ។

តតិយបណ្ណាសកេ យោធាជីវវគ្គោ

[១៣៨] ឧប្បាទា វា ភិក្ខវេ តថាគតានំ អនុ-
ប្បាទា វា តថាគតានំ ឋិតា វ សា ធាតុ ធម្មដ្ឋិ-
តតា ធម្មនិយាមតា សព្វេ សង្ខារា អនិច្ចាតិ ។ តំ
តថាគតោ អភិសម្ពុជ្ឈតិ អភិសមេតិ អភិសម្ពុជ្ឈិត្វា
អភិសមេត្វា អាចិក្ខតិ ទេសេតិ បញ្ញាបេតិ បដ្ឋបេតិ
វិវរតិ វិភជតិ ឧត្តានីករោតិ សព្វេ សង្ខារា អនិច្ចាតិ ។
ឧប្បាទា វា ភិក្ខវេ តថាគតានំ អនុប្បាទា វា តថា-
គតានំ ឋិតា វ សា ធាតុ ធម្មដ្ឋិតតា ធម្មនិយាមតា
សព្វេ សង្ខារា ទុក្ខាតិ ។ តំ តថាគតោ អភិ-
សម្ពុជ្ឈតិ អភិសមេតិ អភិសម្ពុជ្ឈិត្វា អភិសមេត្វា
អាចិក្ខតិ ទេសេតិ បញ្ញាបេតិ បដ្ឋបេតិ វិវរតិ វិភជតិ
ឧត្តានីករោតិ សព្វេ សង្ខារា ទុក្ខាតិ ។ ឧប្បាទា វា
ភិក្ខវេ តថាគតានំ អនុប្បាទា វា តថាគតានំ ឋិតា
វ សា ធាតុ ធម្មដ្ឋិតតា ធម្មនិយាមតា សព្វេ ធម្មា
អនត្តាតិ ។ តំ តថាគតោ អភិសម្ពុជ្ឈតិ អភិសមេតិ
អភិសម្ពុជ្ឈិត្វា អភិសមេត្វា អាចិក្ខតិ ទេសេតិ
បញ្ញាបេតិ បដ្ឋបេតិ វិវរតិ វិភជតិ ឧត្តានីករោតិ
សព្វេ ធម្មា អនត្តាតិ ។

[១៣៨] ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគតទាំងឡាយកើតឡើងក្តី ព្រះតថាគតទាំងឡាយ មិនទាន់កើតឡើងក្តី ធាតុនោះ ធម្មដ្ឋិតិនោះ ធម្មនិយាមនោះ តែងស្ថិតនៅជាធម្មតា គឺថាសង្ខារទាំងឡាយទាំងពួងមិនទៀង ។ ព្រះតថាគតត្រាស់ដឹង យល់ច្បាស់នូវធាតុជាដើមនោះ លុះត្រាស់ដឹងយល់ច្បាស់ហើយ ក៏ប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើកបង្ហើប ចែករំលែក ធ្វើឲ្យរាក់ថា សង្ខារទាំងពួងមិនទៀង ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគតទាំងឡាយ កើតឡើងក្តី ព្រះតថាគតទាំងឡាយមិនទាន់កើតឡើងក្តី ធាតុនោះ ធម្មដ្ឋិតិនោះ ធម្មនិយាមនោះ តែងស្ថិតនៅជាធម្មតា គឺថាសង្ខារទាំងពួងជាទុក្ខ ។ ព្រះតថាគត រមែងត្រាស់ដឹង យល់ច្បាស់នូវធាតុជាដើមនោះ លុះត្រាស់ដឹង យល់ច្បាស់ហើយ ក៏ប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើកបង្ហើប ចែករំលែក ធ្វើឲ្យរាក់ថា សង្ខារទាំងពួងជាទុក្ខ ។ ម្នាលភិក្ខុទាំងឡាយ កាលព្រះតថាគតទាំងឡាយកើតឡើងក្តី ព្រះតថាគតទាំងឡាយ មិនទាន់កើតឡើងក្តី ធាតុនោះ ធម្មដ្ឋិតិនោះ ធម្មនិយាមនោះ តែងស្ថិតនៅជាធម្មតា គឺថាធម៌ទាំងឡាយទាំងពួងជាអនត្តា ។ ព្រះតថាគត ត្រាស់ដឹង យល់ច្បាស់នូវធាតុជាដើមនោះ លុះត្រាស់ដឹង យល់ច្បាស់ហើយ ក៏ប្រាប់ សម្តែង បញ្ញត្ត តាំងផ្តើម បើកបង្ហើប ចែករំលែក ធ្វើឲ្យរាក់ថា ធម៌ទាំងឡាយទាំងពួងជាអនត្តា ។

[១៣៩] សេយ្យថាបិ ភិក្ខវេ យានិ កានិចិ តន្តាវុតានំ វត្ថានំ កេសកម្ពលោ តេសំ បដិកិដ្ឋោ អក្ខាយតិ កេសកម្ពលោ ភិក្ខវេ សីតេ សីតោ ឧណ្ហេ ឧណ្ហោ ទុព្វណ្ណោ ទុគ្គន្ធោ ទុក្ខសម្ផស្សោ ឯវមេវ ខោ ភិក្ខវេ យានិ កានិចិ បុថុសមណ-ព្រាហ្មណាទានំ(១) មក្ខលិវាទោ តេសំ បដិកិដ្ឋោ អក្ខាយតិ មក្ខលិ ភិក្ខវេ មោឃបុរិសោ ឯវំវាទី ឯវំទិដ្ឋិ នត្ថិ កម្មំ នត្ថិ កិរិយំ នត្ថិ វីរិយន្តិ ។ យេបិ តេ ភិក្ខវេ អហេសុំ អតីតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេបិ ភគវន្តោ កម្មវាទា ចេវ អហេសុំ កិរិយវាទា ច វីរិយវាទា ច ។ តេបិ ភិក្ខវេ មក្ខលិ មោឃបុរិសោ បដិពាហតិ នត្ថិ កម្មំ នត្ថិ កិរិយំ នត្ថិ វីរិយន្តិ ។ យេបិ តេ ភិក្ខវេ ភវិស្សន្តិ អនាគតមទ្ធានំ អរហន្តោ សម្មាសម្ពុទ្ធា តេបិ ភគវន្តោ កម្មវាទា ចេវ ភវិស្សន្តិ កិរិយវាទា ច វីរិយវាទា ច ។

១ ម. បុថុសមណព្រាហ្មណវាទានំ ។

[១៣៩] ម្នាលភិក្ខុទាំងឡាយ សំពត់ទាំងឡាយណាមួយ ដែលគេត្បាញដោយតម្បាញ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ប្រាកដជាអាក្រក់បំផុតជាងសំពត់ទាំងនោះ ម្នាលភិក្ខុទាំងឡាយ សំពត់កម្ពលដែលគេត្បាញដោយសក់មនុស្ស ត្រជាក់ក្នុងពេលត្រជាក់ ក្តៅក្នុងពេលក្តៅ មានសម្បុរអាក្រក់ មានក្លិនអាក្រក់ មានសម្ផស្សអាក្រក់ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ វាទៈនៃសមណៈច្រើននាក់ណាមួយ វាទៈនៃគ្រូឈ្មោះមក្ខលិ ប្រាកដជាអាក្រក់ជាងវាទៈនៃសមណៈទាំងនោះ ក៏យ៉ាងនោះដែរ ម្នាលភិក្ខុទាំងឡាយ មក្ខលិ ជាមោឃបុរស មានសេចក្តីប្រកាន់យ៉ាងនេះ មានការយល់ឃើញយ៉ាងនេះថា កម្មមិនមាន អំពើដែលត្រូវធ្វើមិនមាន សេចក្តីព្យាយាមមិនមាន ។ ម្នាលភិក្ខុទាំង-ឡាយ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា ក្នុងអតីតកាល ព្រះអរហន្តសម្មាសម្ពុទ្ធដ៏មានព្រះភាគទាំងនោះ ជាកម្មវាទផង ជាកិរិយវាទផង ជាវិរិយវាទផង ។ ម្នាលភិក្ខុទាំងឡាយ មក្ខលិ ជាមោឃបុរស ហាមឃាត់នូវព្រះអរហន្តសម្មាសម្ពុទ្ធនោះថា កម្មមិនមាន អំពើដែលត្រូវធ្វើមិនមាន សេចក្តីព្យាយាមមិនមាន ។ ម្នាលភិក្ខុទាំងឡាយ ព្រះអរហន្តសម្មាសម្ពុទ្ធទាំងឡាយណា ក្នុងអនាគតកាល ព្រះអរហន្តសម្មាសម្ពុទ្ធដ៏មានព្រះភាគទាំងនោះ ជាកម្មវាទផង ជាកិរិយវាទផង ជាវិរិយវាទផង ។

តេបិ ភិក្ខវេ មក្ខលិ មោឃបុរិសោ បដិពាហតិ នត្ថិ កម្មំ នត្ថិ កិរិយំ នត្ថិ វីរិយន្តិ ។ អហម្បិ ភិក្ខវេ ឯតរហិ អរហំ សម្មាសម្ពុទ្ធោ កម្មវាទោ កិរិយវាទោ វីរិយវាទោ ។ មម្បិ ភិក្ខវេ មក្ខលិ មោឃបុរិសោ បដិពាហតិ នត្ថិ កម្មំ នត្ថិ កិរិយំ នត្ថិ វីរិយន្តិ ។ សេយ្យថាបិ ភិក្ខវេ នទីមុខេ ខិបំ ឧឌ្ឌេយ្យ ពហុន្នំ មច្ឆានំ អហិតាយ ទុក្ខាយ អនយាយ ព្យសនាយ ឯវមេវ ខោ ភិក្ខវេ មក្ខលិ មោឃបុរិសោ មនុស្ស-ខិបម្មញ្ញេ លោកេ ឧប្បន្នោ ពហុន្នំ សត្តានំ អហិ-តាយ ទុក្ខាយ អនយាយ ព្យសនាយាតិ ។

[១៤០] តិស្សោ ឥមា ភិក្ខវេ សម្បទា ។ កតមា តិស្សោ ។ សទ្ធាសម្បទា សីលសម្បទា បញ្ញាសម្បទា ។ ឥមា ខោ ភិក្ខវេ តិស្សោ សម្បទាតិ ។

ម្នាលភិក្ខុទាំងឡាយ មក្ខលិ ជាមោឃបុរសឈ្មោះថា ហាមឃាត់នូវព្រះអរហន្តសម្មាសម្ពុទ្ធទាំងនោះថា កម្មមិនមាន អំពើដែលត្រូវធ្វើមិនមាន សេចក្តីព្យាយាមមិនមាន ។ ម្នាលភិក្ខុទាំងឡាយ សូម្បីតថាគតដែលជាអរហន្តសម្មាសម្ពុទ្ធក្នុងកាលឥឡូវនេះ ជាកម្មវាទ ជាកិរិយវាទ ជាវីរិយវាទដែរ ។ ម្នាលភិក្ខុទាំងឡាយ មក្ខលិ ជាមោឃបុរស ហាមឃាត់នូវតថាគតដែរថា កម្មមិនមាន អំពើដែលត្រូវធ្វើមិនមាន សេចក្តីព្យាយាមមិនមាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលដាក់លបក្នុងមាត់ស្ទឹង ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីវិនាសដល់ត្រីជាច្រើនយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មក្ខលិ ជាមោឃបុរសកើតឡើងក្នុងលោក ដូចជាលប សម្រាប់ដាក់មនុស្ស ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ដើម្បីសេចក្តីមិនចម្រើន ដើម្បីសេចក្តីវិនាសដល់សត្វមានប្រមាណច្រើន ក៏យ៉ាងនេះដែរ ។

[១៤០] ម្នាលភិក្ខុទាំងឡាយ សម្បទានេះ មាន ៣ យ៉ាង ។ សម្បទា ៣ យ៉ាងដូចម្តេចខ្លះ ។ គឺសទ្ធាសម្បទា ១ សីលសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ សម្បទាមាន ៣ យ៉ាងនេះឯង ។

[១៤១] តិស្សោ ឥមា ភិក្ខវេ វុឌ្ឍិយោ ។ កតមា តិស្សោ ។ សទ្ធាវុឌ្ឍិ សីលវុឌ្ឍិ បញ្ញាវុឌ្ឍិ ។ ឥមា ខោ ភិក្ខវេ តិស្សោ វុឌ្ឍិយោតិ ។

[១៤២] តយោ ច ភិក្ខវេ អស្សខលុង្កេ ទេសេស្សាមិ តយោ ច បុរិសខលុង្កេ[១] តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមេ ច ភិក្ខវេ តយោ អស្សខលុង្កា ។ ឥធ ភិក្ខវេ ឯកច្ចោ អស្សខលុង្កោ ជវសម្បន្នោ ហោតិ ន វណ្ណសម្បន្នោ ន អារោហបរិណាហសម្បន្នោ ឥធ បន ភិក្ខវេ ឯកច្ចោ អស្សខលុង្កោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច ន អារោហបរិណាហសម្បន្នោ ឥធ បន ភិក្ខវេ ឯកច្ចោ អស្សខលុង្កោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។

---

១ ឱ. ឯត្ថន្តរេ ទេសេស្សាមីតិ អត្ថិ ។

[១៨១] ម្នាលភិក្ខុទាំងឡាយ វុឌ្ឍិ (សេចក្តីចម្រើន) នេះ មាន ៣ យ៉ាង ។ វុឌ្ឍិ ៣ យ៉ាង ដូចម្តេចខ្លះ ។ គឺសទ្ធាវុឌ្ឍិ ១ សីលវុឌ្ឍិ ១ បញ្ញាវុឌ្ឍិ ១ ។ ម្នាលភិក្ខុទាំងឡាយ វុឌ្ឍិមាន ៣ យ៉ាងនេះឯង ។

[១៨២] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវគោត្រនៃសេះ ៣ យ៉ាង នូវគោត្រនៃបុរស ៣ យ៉ាង ចូរអ្នកទាំងឡាយស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ក៏ទទួលព្រះតម្រាស់នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះគោត្រនៃសេះ ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គោត្រនៃសេះខ្លះ ក្នុងលោកនេះ ជាវាហនៈ បរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ គោត្រនៃសេះខ្លះ ក្នុងលោកនេះ ជាវាហនៈ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែមិនបរិបូណ៌ដោយកម្ពស់និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ គោត្រនៃសេះខ្លះ ក្នុងលោកនេះ ជាវាហនៈ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់និងមាឌផង ១ ។

៤៦១



ឥមេ ខោ ភិក្ខវេ តយោ អស្សខលុង្កា ។ កតមេ ច ភិក្ខវេ តយោ បុរិសខលុង្កា ។ ឥធ ភិក្ខវេ ឯកច្ចោ បុរិសខលុង្កោ ជវសម្បន្នោ ហោតិ ន វណ្ណសម្បន្នោ ន អារោហបរិណាហសម្បន្នោ ឥធ បន ភិក្ខវេ ឯកច្ចោ បុរិសខលុង្កោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច ន អារោហបរិណាហសម្បន្នោ ឥធ បន ភិក្ខវេ ឯកច្ចោ បុរិសខលុង្កោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ កថញ្ច ភិក្ខវេ បុរិសខលុង្កោ ជវសម្បន្នោ ហោតិ ន វណ្ណសម្បន្នោ ន អារោហបរិណាហសម្បន្នោ ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ ឥទមស្ស ជវស្មឹ វទាមិ ។ អភិធម្មេ ខោ បន អភិវិនយេ បញ្ហំ បុដ្ឋោ សំសាទេតិ[១] នោ វិស្សជ្ជេតិ ។ ឥទមស្ស ន វណ្ណស្មឹ វទាមិ ។

១ ម. សំហិរេតិ ។

ម្នាលភិក្ខុទាំងឡាយ គោត្រនៃសេះមាន ៣ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះគោត្រនៃបុរស ៣ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរសខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរសខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិ-បូណ៌ដោយសម្បុរផង តែមិនបរិបូណ៌ដោយកម្ពស់និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរសខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់និងមាឌផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះគោត្រនៃបុរស ជាអ្នកបរិបូណ៌ដោយល្បឿង តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់និងមាឌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាបដិបទា ជាដំណើរទៅកាន់សេចក្តីរលត់ទុក្ខ ។ តថាគតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ តែបើភិក្ខុនោះត្រូវគេសាកសួរប្រស្នាក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងស្ងៀមស្ងាត់ ដោះស្រាយមិនរួច ។ តថាគតហៅថា នេះមិនមែនជាសម្បុររបស់ភិក្ខុនោះ ។

ន ខោ លាភី ហោតិ ចីវរបិណ្ឌបាតសេនាសន-
គិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ ឥទមស្ស ន
អារោហបរិណាហស្មឹ វទាមិ ។ ឯវំ ខោ ភិក្ខវេ
បុរិសខលុង្កោ ជវសម្បន្នោ ហោតិ ន វណ្ណសម្បន្នោ
ន អារោហបរិណាហសម្បន្នោ ។ កថញ្ច ភិក្ខវេ
បុរិសខលុង្កោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ
ច ន អារោហបរិណាហសម្បន្នោ ។ ឥធ ភិក្ខវេ ភិក្ខុ
ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ
ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។
ឥទមស្ស ជវស្មឹ វទាមិ ។ អភិធម្មេ ខោ បន អភិ-
វិនយេ បញ្ហំ បុដ្ឋោ វិស្សជ្ជេតិ នោ សំសាទេតិ ។
ឥទមស្ស វណ្ណស្មឹ វទាមិ ។ ន ខោ បន លាភី
ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជ-
បរិក្ខារានំ ។ ឥទមស្ស ន អារោហបរិណាហស្មឹ វទាមិ ។

ទាំងភិក្ខុនោះ ក៏ជាអ្នកឆ្អែងលាភ ចំពោះចីវរ បិណ្ឌបាត សេនាសនៈ និង បរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះមិនមែនជា កម្ពស់និងមាឌរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរស ជាអ្នកបរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ ដោយកម្ពស់និងមាឌយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះគោត្រ នៃបុរស ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែមិនបរិបូណ៌ដោយកម្ពស់និងមាឌ តើដូចម្ដេច ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជា ទុក្ខ ។ បេ ។ ដឹងច្បាស់តាមសេចក្ដីពិតថា នេះជាបដិបទា ជា ដំណើរទៅកាន់ទីរលត់ទុក្ខ ។ តថាគតហៅថា នេះជាល្បឿនរបស់ ភិក្ខុនោះ ។ ភិក្ខុនោះកាលបើគេសាកសួរប្រស្នា ក្នុងអភិធម្ម ក្នុង អភិវិន័យ រមែងដោះស្រាយរួច មិនស្ទៀមស្ទាត់ ។ តថាគតហៅថា នេះជាសម្បុររបស់ភិក្ខុនោះ ។ តែភិក្ខុនោះ ជាអ្នកឆ្អែងលាភ ចំពោះ ចីវរ បិណ្ឌបាត សេនាសនៈនិងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះមិនមែនជាកម្ពស់ និងមាឌរបស់ភិក្ខុនោះ ។

៤៦៣

តតិយបណ្ណាសកេ យោធាជីវវគ្គោ

ឯវំ ខោ ភិក្ខវេ បុរិសខលុង្កោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច ន អារោហបរិណាហសម្បន្នោ ។ កថញ្ច ភិក្ខវេ បុរិសខលុង្កោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥធ ភិក្ខវេ ភិក្ខុ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ ។ បេ ។ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ ឥទមស្ស ជវស្មឹ វទាមិ ។ អភិធម្មេ ខោ បន អភិវិនយេ បញ្ហំ បុដ្ឋោ វិស្សជ្ជេតិ នោ សំសាទេតិ ។ ឥទមស្ស វណ្ណស្មឹ វទាមិ ។ លាភី ខោ បន ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ ឥទមស្ស អារោហបរិណាហស្មឹ វទាមិ ។ ឯវំ ខោ ភិក្ខវេ បុរិសខលុង្កោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥមេ ខោ ភិក្ខវេ តយោ បុរិសខលុង្កាតិ ។

ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរស ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែមិនបរិបូណ៌ដោយកម្ពស់និងមាឌយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះគោត្រនៃបុរស ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់និងមាឌផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាទុក្ខ ។ បេ ។ ដឹងច្បាស់តាមសេចក្តីពិតថា នេះជាបដិបទា ជាដំណើរទៅកាន់ទីរលត់ទុក្ខ ។ តថាគតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ ភិក្ខុនោះកាលបើគេសាកសួរប្រស្នា ក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងដោះស្រាយរួច មិនស្ទៀមស្ទាត់ ។ តថាគតហៅថា នេះជាសម្បុររបស់ភិក្ខុនោះ ។ ទាំងភិក្ខុនោះក៏ជាអ្នកស្ទាក់លាភចំពោះចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារគឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថានេះជាកម្ពស់និងមាឌរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរស ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់និងមាឌផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ គោត្រនៃបុរសមាន ៣ យ៉ាងនេះឯង ។

[១៤៣] តយោ ច ភិក្ខវេ អស្សសទស្សេ[១] ទេសេស្សាមិ តយោ ច បុរិសសទស្សេ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមេ ច ភិក្ខវេ តយោ អស្សសទស្សា ។ ឥធ ភិក្ខវេ ឯកច្ចោ អស្សសទស្សោ ជវសម្បន្នោ ហោតិ ន វណ្ណសម្បន្នោ ន អារោហបរិណាហសម្បន្នោ ឥធ បន ភិក្ខវេ ឯកច្ចោ អស្សសទស្សោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច ន អារោហបរិណាហសម្បន្នោ ឥធ បន ភិក្ខវេ ឯកច្ចោ អស្សសទស្សោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥមេ ខោ ភិក្ខវេ តយោ អស្សសទស្សា ។ កតមេ ច ភិក្ខវេ តយោ បុរិសសទស្សា ។ ឥធ ភិក្ខវេ ឯកច្ចោ បុរិសសទស្សោ ជវសម្បន្នោ ហោតិ ន វណ្ណសម្បន្នោ ន អារោហបរិណាហសម្បន្នោ

---

១ម. អស្សបរស្សេ ។

[១៤៣] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេះ រាបសា ៣ ពួកផង នូវបុរសរាបសា ៣ ពួកផង ចូរអ្នកទាំងឡាយ ស្តាប់នូវធម៌នោះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលព្រះតម្រាស់នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះសេះរាបសា ៣ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះរាបសាខ្លះ ក្នុងលោកនេះ បរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ សេះរាបសាខ្លះក្នុងលោកនេះ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែមិនបរិបូណ៌ដោយកម្ពស់និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ សេះរាបសាខ្លះក្នុងលោកនេះ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់និងមាឌផង ១ ។ ម្នាលភិក្ខុទាំងឡាយ សេះរាបសាមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសរាបសា ៣ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុរសរាបសាខ្លះ ក្នុងលោកនេះ ជាអ្នកបរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់និងមាឌ ១

តតិយបណ្ណាសកេយោធាជីវវគ្គោ

ឥធ បន ភិក្ខវេ ឯកច្ចោ បុរិសសទស្សោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច ន អារោហបរិណាហសម្បន្នោ ឥធ បន ភិក្ខវេ ឯកច្ចោ បុរិសសទស្សោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ កថញ្ច ភិក្ខវេ បុរិសសទស្សោ ជវសម្បន្នោ ហោតិ ន វណ្ណសម្បន្នោ ន អារោហបរិណាហសម្បន្នោ ។ ឥធ ភិក្ខវេ ភិក្ខុ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនា នំ បរិក្ខយា ឱបបាតិកោ ហោតិ តត្ថបរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ ឥទមស្ស ជវស្មឹ វទាមិ ។ អភិធម្មេ ខោ បន អភិវិនយេ បញ្ហំ បុដ្ឋោ សំសាទេតិ នោ វិស្សជ្ជេតិ ។ ឥទមស្ស ន វណ្ណស្មឹ វទាមិ ។ ន ខោ បន លាភី ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ ឥទមស្ស ន អារោហបរិណា ហស្មឹ វទាមិ ។ ឯវំ ខោ ភិក្ខវេ បុរិសសទស្សោ ជវសម្បន្នោ ហោតិ ន វណ្ណសម្បន្នោ ន អារោហបរិណាហសម្បន្នោ ។

ម្នាលភិក្ខុទាំងឡាយ បុរសរាបសាខ្ទះ ក្នុងលោកនេះ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែទាស់មិនបរិបូណ៌ដោយកម្ពស់និងមាឌ ១ ម្នាលភិក្ខុទាំងឡាយ បុរសរាបសាខ្ទះ ក្នុងលោកនេះបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុផង បរិបូណ៌ដោយកម្ពស់និងមាឌផង ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសរាបសា ជាអ្នកបរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់និងមាឌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាឱបបាតិកៈកំណើត (កើតក្នុងសុទ្ធាវាស) បរិនិព្វានក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់ចាកលោកនោះមកវិញឡើយ ព្រោះអស់ទៅនៃឱរម្ភាគិយសញ្ញោជនៈ ៥ ។ តថាគតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ តែបើភិក្ខុនោះត្រូវគេសាកសួរប្រស្នាក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងស្ទៀមស្ងាត់ ដោះស្រាយមិនរួច ។ តថាគតហៅថា នេះមិនមែនជាសម្បុររបស់ភិក្ខុនោះ ។ ទាំងភិក្ខុនោះ ជាអ្នកធ្វេងលាភចំពោះចីវរបិណ្ឌបាតសេនាសនៈ និងបរិក្ខារគឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះមិនមែនកម្ពស់និងមាឌរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសរាបសា ជាអ្នកបរិបូណ៌ដោយល្បឿន តែមិនបរិបូណ៌ដោយសម្បុរ មិនបរិបូណ៌ដោយកម្ពស់និងមាឌយ៉ាងនេះឯង ។

កថញ្ច ភិក្ខវេ បុរិសសទស្សោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច ន អារោហបរិណាហសម្បន្នោ ។ ឥធ ភិក្ខវេ ភិក្ខុ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបចាតិកោ ហោតិ តត្ថបរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។ ឥទមស្ស ជវស្មឹ វទាមិ ។ អភិធម្មេ ខោ បន អភិវិនយេ បញ្ហំ បុដ្ឋោ វិស្សជ្ជេតិ នោ សំសាទេតិ ។ ឥទមស្ស វណ្ណស្មឹ វទាមិ ។ ន ខោ បន លាភី ហោតិ ចីវរបិណ្ឌបាត-សេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ ឥទមស្ស ន អារោហបរិណាហស្មឹ វទាមិ ។ ឯវំ ខោ ភិក្ខវេ បុរិសសទស្សោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច ន អារោហបរិណាហសម្បន្នោ ។ កថញ្ច ភិក្ខវេ បុរិសសទស្សោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥធ ភិក្ខវេ ភិក្ខុ បញ្ចន្នំ ឱរម្ភាគិយានំ សញ្ញោជនានំ បរិក្ខយា ឱបចាតិកោ ហោតិ តត្ថ-បរិនិព្វាយី អនាវត្តិធម្មោ តស្មា លោកា ។

ម្នាលភិក្ខុទាំងឡាយ ចុះបុរសរាបសា ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិ-បូណ៌ដោយសម្បុរផង តែមិនបរិបូណ៌ដោយកម្ពស់និងមាឌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយភិក្ខុក្នុងសាសនានេះជាឱបបាតិកៈកំណើត (កើតក្នុងសុទ្ធាវាស) បរិនិព្វានក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់ចាកលោកនោះមកវិញឡើយ ព្រោះអស់ទៅនៃឱរម្ភាគិយសញ្ញោជនៈ ៥ ។ តថា-គតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ ភិក្ខុនោះបើត្រូវគេសាកសួរប្រ-ស្នា ក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងដោះស្រាយរួចមិនស្ទៀមស្ទាត់ ។ តថាគតហៅថា នេះជាសម្បុររបស់ភិក្ខុនោះ ។ តែភិក្ខុនោះឯង ជាអ្នកឆ្មៃលាភចំពោះចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារគឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះមិនមែនជាកម្ពស់និងមាឌរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសរាបសា ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង តែទាស់មិនបរិបូណ៌ដោយកម្ពស់និងមាឌ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសរាបសាជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់និងមាឌផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាឱបបាតិកៈកំណើត (កើតក្នុងសុទ្ធាវាស) បរិនិព្វានក្នុងសុទ្ធាវាសនោះ មានសភាពមិនត្រឡប់ចាកលោកនោះមកវិញឡើយ ព្រោះអស់ទៅនៃឱរម្ភាគិយសញ្ញោជនៈ៥ ។

ឥធមស្ស ជវស្មឹ វទាមិ ។ អភិធម្មេ ខោ បន អភិវិនយេ បញ្ហំ បុដ្ឋោ វិស្សជ្ជេតិ នោ សំសាទេតិ ។ ឥធមស្ស វណ្ណស្មឹ វទាមិ ។ លាភី ខោ បន ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ ឥធមស្ស អារោហបរិណាហស្មឹ វទាមិ ។ ឯវំ ខោ ភិក្ខវេ បុរិសសទស្សោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥមេ ខោ ភិក្ខវេ តយោ បុរិសសទស្សាតិ ។

[១៤៤] តយោ ច ភិក្ខវេ ភទ្រេ អស្សាជានីយេ ទេសេស្សាមិ តយោ ច ភទ្រេ បុរិសាជានីយេ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កតមេ ច ភិក្ខវេ តយោ ភទ្រា អស្សាជានីយា ។ ឥធ ភិក្ខវេ ឯកច្ចោ ភទ្រោ អស្សាជានីយោ ។ បេ ។ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។

តថាគតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ ភិក្ខុនោះ បើត្រូវគេសាកសួរប្រស្នា ក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងដោះស្រាយរួចមិនស្ទៀមស្ទាត់ ។ តថាគតហៅថា នេះជាសម្បុររបស់ភិក្ខុនោះ ។ ទាំងភិក្ខុនោះ ជាអ្នកស្ទាក់លាភចំពោះចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារគឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះជាកម្ពស់និងមាឌរបស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ បុរសរាបសា ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់និងមាឌផងយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសរាបសា មាន ៣ ពួកនេះឯង ។

[១៤៨] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេះអាជានេយ្យដ៏ល្អ ៣ ពួកផង នូវបុរសអាជានេយ្យដ៏ល្អ ៣ ពួកផង ចូរអ្នកទាំងឡាយ ស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្ត ដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះទទួលព្រះតម្រាស់នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ចុះសេះអាជានេយ្យដ៏ល្អ ៣ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អខ្លះ ក្នុងលោកនេះ ។ បេ ។ ជាវាហនៈបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់និងមាឌផង ១ ។

ឥមេ ខោ ភិក្ខវេ តយោ ភទ្ទា អស្សាជានីយា ។ កតមេ ច ភិក្ខវេ តយោ ភទ្ទា បុរិសាជានីយា ។ ឥធ ភិក្ខវេ ឯកច្ចោ ភទ្ទោ បុរិសាជានីយោ ។ បេ ។ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ បេ ។ កថញ្ច ភិក្ខវេ ភទ្ទោ បុរិសាជានីយោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥធ ភិក្ខវេ ភិក្ខុ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥទមស្ស ជវស្មឹ វទាមិ ។ អភិធម្មេ ខោ បន អភិវិនយេ បញ្ហំ បុដ្ឋោ វិស្សជ្ជេតិ នោ សំសាទេតិ ។ ឥទមស្ស វណ្ណស្មឹ វទាមិ ។ លាភី ខោ បន ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ ឥទមស្ស អារោហបរិណាហស្មឹ វទាមិ ។

ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អមាន ៣ ពួកនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសអាជានេយ្យ ៣ ពួក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ល្អខ្លះ ក្នុងលោកនេះ ។ បេ ។ បរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់និងមាឌ ផង ១ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះបុរសអាជានេយ្យដ៏ល្អ ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់និងមាឌផង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះធ្វើឲ្យជាក់ច្បាស់សម្រេចនូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈព្រោះអស់អាសវៈដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្នសម្រេចសម្រាន្តនៅ ។ តថាគតហៅថា នេះជាល្បឿនរបស់ភិក្ខុនោះ ។ ភិក្ខុនោះបើគេសាកសួរប្រស្នាក្នុងអភិធម្ម ក្នុងអភិវិន័យ រមែងដោះស្រាយរួច មិនស្ទៀមស្ទាត់ ។ តថាគតហៅថា នេះជាសម្បុររបស់ភិក្ខុនោះ ។ ទាំងភិក្ខុនោះ ជាអ្នកស្ទាក់លាភចំពោះចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារគឺថ្នាំជាបច្ច័យដល់អ្នកជំងឺ ។ តថាគតហៅថា នេះជាកម្ពស់និងមាឌរបស់ភិក្ខុនោះ ។

ឯវំ ខោ ភិក្ខវេ ភទ្ទោ បុរិសាជានីយោ ជវសម្បន្នោ ច ហោតិ វណ្ណសម្បន្នោ ច អារោហបរិណាហសម្បន្នោ ច ។ ឥមេ ខោ បន ភិក្ខវេ តយោ ភទ្ទា បុរិសាជានីយាតិ ។

[១៤៨] ឯកំ សមយំ ភគវា រាជគហេ វិហរតិ មោរនិវាបេ បរិព្វាជការាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានំ ។ កតមេហិ តីហិ ។ អសេក្ខេន សីលក្ខន្ធេន អសេក្ខេន សមាធិក្ខន្ធេន អសេក្ខេន បញ្ញាក្ខន្ធេន ។ ឥមេហិ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានន្តិ ។

ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ល្អ ជាអ្នកបរិបូណ៌ដោយល្បឿនផង បរិបូណ៌ដោយសម្បុរផង បរិបូណ៌ដោយកម្ពស់និងមាឌផង យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសអាជានេយ្យដ៏ល្អមាន ៣ ពួកនេះឯង ។

[១៤៥] សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងបរិញ្ញជកា-រាម ជាមោរនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះតម្រាស់នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង ឈ្មោះថាជាអ្នកមានសេចក្តីចូលចិត្តដាច់ស្រេច មានសេចក្តីក្សេមចាកយោគៈដាច់ស្រេច មានព្រហ្មចរិយៈដាច់ស្រេច មានទីបំផុតដាច់ស្រេច ប្រសើរបំផុតជាងទេវតានិងមនុស្សទាំងឡាយ ។ ប្រកបដោយធម៌ ៣ យ៉ាង គឺអ្វីខ្លះ ។ គឺប្រកបដោយអសេក្ខសីលក្ខន្ធ ១ អសេក្ខសមា-ធិក្ខន្ធ ១ អសេក្ខបញ្ញាខន្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ឈ្មោះថាជាអ្នកមានសេចក្តីចូលចិត្តដាច់ស្រេច មានសេចក្តីក្សេមចាកយោគៈដាច់ស្រេច មានព្រហ្មចរិយៈដាច់ស្រេច មានទីបំផុតដាច់ស្រេច ជាអ្នកប្រសើរបំផុតជាងទេវតានិងមនុស្សទាំងឡាយ ។

[១៤៦] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានំ ។ កតមេហិ តីហិ ។ ឥទ្ធិប្បាដិហារិយេន អាទេសនាបាដិហារិយេន អនុសាសនីបាដិហារិយេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានន្តិ ។

[១៤៧] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្ត-ព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានំ ។

[១៨៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង ឈ្មោះថា ជាអ្នកមានសេចក្តីចូលចិត្តដាច់ស្រេច មានសេចក្តីក្សេមចាកយោគៈដាច់ស្រេច មានព្រហ្មចរិយៈដាច់ស្រេច មានទីបំផុតដាច់ស្រេច ជាអ្នកប្រសើរបំផុត ជាងទេវតានិងមនុស្សទាំងឡាយ ។ ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺប្រកបដោយឥទ្ធិប្បាដិហារ្យ ១ អាទេសនាបាដិហារ្យ ១ អនុសាសនីបាដិហារ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ឈ្មោះថាជាអ្នកមានសេចក្តីចូលចិត្តដាច់ស្រេច មានសេចក្តីក្សេមចាកយោគៈដាច់ស្រេច មានព្រហ្មចរិយៈដាច់ស្រេច មានទីបំផុតដាច់ស្រេច ជាអ្នកប្រសើរបំផុតជាងទេវតានិងមនុស្សទាំងឡាយ ។

[១៨៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង ឈ្មោះថា ជាអ្នកមានសេចក្តីចូលចិត្តដាច់ស្រេច មានសេចក្តីក្សេមចាកយោគៈដាច់ស្រេច មានព្រហ្មចរិយៈដាច់ស្រេច មានទីបំផុតដាច់ស្រេច ជាអ្នកប្រសើរបំផុត ជាងទេវតានិងមនុស្សទាំងឡាយ ។

៤៧១



កតមេហិ តីហិ ។ សម្មាទិដ្ឋិយា សម្មាញាណេន សម្មាវិមុត្តិយា ។ ឥមេហិ ខោ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អច្ចន្តនិដ្ឋោ ហោតិ អច្ចន្តយោគក្ខេមី អច្ចន្តព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានន្តិ ។

យោធាជីវវគ្គោ ចតុត្ថោ ។

## តស្សុទ្ទានំ

យោធបរិសមិត្តា ច
ឧប្បាទោ កេសកម្ពលោ
សទ្ធា វុឌ្ឍិ តយោ អស្សា
តយោ មោរនិវាបិនោតិ ។

ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺប្រកបដោយសម្មាទិដ្ឋិ (ការយល់ប្រពៃ) ១ សម្មាញាណ (ការដឹងប្រពៃ) ១ សម្មាវិមុត្តិ (ការរួចចាកកិលេសដោយប្រពៃ) ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះឯង ឈ្មោះថាជាអ្នកមានសេចក្ដីចូលចិត្តដាច់ស្រេច មានសេចក្ដីក្សេមចាកយោគៈដាច់ស្រេច មានព្រហ្មចរិយៈដាច់ស្រេច មានទីបំផុតដាច់ស្រេច ជាអ្នកប្រសើរបំផុត ជាងទេវតានិងមនុស្សទាំងឡាយ ។

ចប់ យោធាជីវវគ្គ ទី ៤ ។

# ឧទ្ទាននៃយោធាជីវវគ្គនោះ គឺ

និយាយអំពីយោធាជីវៈ ១ អំពីបរិស័ទ្យ ១ អំពីមិត្ត ១ អំពីព្រះតថាគតកើតឡើង ១ អំពីសំពត់កម្ពលដែលត្បាញដោយសក់មនុស្ស ១ អំពីសម្បទាមានសទ្ធាជាដើម ១ អំពីវុឌ្ឍិ ១ អំពីសេះមាន ៣ លើក ១ អំពីព្រះដ៏មានបុណ្យនៅក្នុងបរិញ្ញជការាម ជាមោរនិវាបស្ថាន មាន ៣ លើក ១ ។

# មង្គលវគ្គោ

[១៤៨] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ តីហិ ។ អកុសលេន កាយកម្មេន អកុសលេន វចីកម្មេន អកុសលេន មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ តីហិ ។ កុសលេន កាយកម្មេន កុសលេន វចីកម្មេន កុសលេន មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

[១៤៩] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ។ បេ ។ សាវជ្ជេន កាយកម្មេន សាវជ្ជេន វចីកម្មេន សាវជ្ជេន មនោកម្មេន ។ បេ ។ អនវជ្ជេន កាយកម្មេន អនវជ្ជេន វចីកម្មេន អនវជ្ជេន មនោកម្មេន ។ បេ ។

# មង្គលវគ្គ

[១៤៨] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺប្រកបដោយកាយកម្ម ជាអកុសល ១ វចីកម្ម ជាអកុសល ១ មនោកម្ម ជាអកុសល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺប្រកបដោយកាយកម្ម ជាកុសល ១ វចីកម្ម ជាកុសល ១ មនោកម្ម ជាកុសល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។

[១៤៩] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង ។ បេ ។ គឺកាយកម្មប្រកបដោយទោស ១ វចីកម្មប្រកបដោយទោស ១ មនោកម្មប្រកបដោយទោស ១ ។ បេ ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមាន ទោស ១ មនោកម្មមិនមានទោស ១ ។ បេ ។

[១៨០] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ។ បេ ។ វិសមេន កាយកម្មេន វិសមេន វចីកម្មេន វិសមេន មនោកម្មេន ។ បេ ។ សមេន កាយកម្មេន សមេន វចីកម្មេន សមេន មនោកម្មេន ។ បេ ។

[១៨១] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ។ បេ ។ អសុចិនា កាយកម្មេន អសុចិនា វចី-កម្មេន អសុចិនា មនោកម្មេន ។ បេ ។ សុចិនា កាយកម្មេន សុចិនា វចីកម្មេន សុចិនា មនោ-កម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។

[១៨២] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ កតមេហិ តីហិ ។ អកុសលេន កាយកម្មេន អកុសលេន វចីកម្មេន អកុសលេន មនោកម្មេន ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ពាលោ អព្យត្តោ អសប្បុរិសោ

[១៥០] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង ។ បេ ។ គឺកាយកម្មមិនរាបសា ១ វចីកម្មមិនរាបសា ១ មនោកម្មមិនរាបសា ១ ។ បេ ។ កាយកម្មរាបសា ១ វចីកម្មរាបសា ១ មនោកម្មរាបសា ១ ។ បេ ។

[១៥១] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង ។ បេ ។ គឺកាយកម្មមិនស្អាត ១ វចីកម្មមិនស្អាត ១ មនោកម្មមិនស្អាត ១ ។ បេ ។ គឺកាយកម្មស្អាត ១ វចីកម្មស្អាត ១ មនោកម្មស្អាត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ដូចជាគេនាំយកទៅតម្កល់ទុក ។

[១៥២] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ជាអ្នកមិនឆ្លៀវឆ្លាស ជាអសប្បុរសប្រកបដោយធម៌ ៣ យ៉ាង រមែងរក្សាខ្លួនដែលខ្លួនគាស់រំលើងផ្តាច់ផ្តិល (នូវគុណ) ជាអ្នកប្រកបដោយទោសផង ប្រកបដោយដំនៀលរបស់អ្នកប្រាជ្ញផង រមែងបាននូវបាបជាច្រើនផង ។ ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺប្រកបដោយកាយកម្ម ជាអកុសល ១ វចីកម្ម ជាអកុសល ១ មនោកម្ម ជាអកុសល ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល ជាអ្នកមិនឆ្លៀវឆ្លាស ជាអសប្បុរស ប្រកបដោយធម៌ ៣ យ៉ាងនេះឯង

ខតំ ឧបហតំ អត្តានំ បរិហរតិ សាវជ្ជោ ច ហោតិ សានុវជ្ជោ វិញ្ញូនំ ពហុញ្ច អបុញ្ញំ បសវតិ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ បណ្ឌិតោ ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ ពហុញ្ច បុញ្ញំ បសវតិ ។ កតមេហិ តីហិ ។ កុសលេន កាយកម្មេន កុសលេន វចីកម្មេន កុសលេន មនោកម្មេន ។ បេ ។

[១៨៣] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ។ បេ ។ សាវជ្ជេន កាយកម្មេន សាវជ្ជេន វចី-កម្មេន សាវជ្ជេន មនោកម្មេន ។ បេ ។ អនវជ្ជេន កាយកម្មេន អនវជ្ជេន វចីកម្មេន អនវជ្ជេន មនោកម្មេន ។ បេ ។

[១៨៤] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ។ បេ ។ វិសមេន កាយកម្មេន វិសមេន វចី-កម្មេន វិសមេន មនោកម្មេន ។ បេ ។ សមេន កាយកម្មេន សមេន វចីកម្មេន សមេន មនោកម្មេន ។ បេ ។

រមែងរក្សាខ្លួន ដែលខ្លួនគាស់រំលើងផ្តាច់ផ្តិល (នូវគុណ) ជាអ្នកប្រកបដោយទោសផង ប្រកបដោយដំនៀលរបស់អ្នកប្រាជ្ញផង រមែងបាននូវបាបជាច្រើនផង ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឆ្លៀវឆ្លាសជាសប្បុរស ប្រកបដោយធម៌ ៣ យ៉ាង រមែងរក្សាខ្លួនដែលមិនគាស់រំលើងមិនផ្តាច់ផ្តិល (នូវគុណ) ជាអ្នកមិនមានទោសផង មិនមានដំនៀលរបស់អ្នកប្រាជ្ញផង រមែងបាននូវបុណ្យជាច្រើនផង ។ ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺប្រកបដោយកាយកម្ម ជាកុសល ១ វចីកម្មជាកុសល ១ មនោកម្ម ជាកុសល ១ ។ បេ ។

[១៥៣] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលប្រកបដោយធម៌ ៣ យ៉ាង ។ បេ ។ គឺកាយកម្មប្រកបដោយទោស ១ វចីកម្មប្រកបដោយទោស ១ មនោកម្មប្រកបដោយទោស ១ ។ បេ ។ គឺកាយកម្មមិនមានទោស ១ វចីកម្មមិនមានទោស ១ មនោកម្មមិនមានទោស ១ ។ បេ ។

[១៥៤] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលប្រកបដោយធម៌ ៣ យ៉ាង ។ បេ ។ គឺកាយកម្មមិនរាបសា ១ វចីកម្មមិនរាបសា ១ មនោកម្មមិនរាបសា ១ ។ បេ ។ គឺកាយកម្មរាបសា ១ វចីកម្មរាបសា ១ មនោកម្មរាបសា ១ ។ បេ ។

តតិយបណ្ណាសកេ មង្គលវគ្គោ

[១៩៥] តីហិ ភិក្ខវេ ។ បេ ។ អសុចិនា កាយ-
កម្មេន អសុចិនា វចីកម្មេន អសុចិនា មនោ-
កម្មេន ។ បេ ។ សុចិនា កាយកម្មេន សុចិនា
វចីកម្មេន សុចិនា មនោកម្មេន ។ ឥមេហិ ខោ
ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ បណ្ឌិតោ
ព្យត្តោ សប្បុរិសោ អក្ខតំ អនុបហតំ អត្តានំ
បរិហរតិ អនវជ្ជោ ច ហោតិ អននុវជ្ជោ វិញ្ញូនំ
ពហុញ្ច បុញ្ញំ បសវតីតិ ។

[១៩៦] តិស្សោ ឥមា ភិក្ខវេ វន្ទនា ។ កតមា
តិស្សោ ។ កាយេន វាចាយ មនសា ។ ឥមា
ខោ ភិក្ខវេ តិស្សោ វន្ទនាតិ ។

[១៩៧] យេ ភិក្ខវេ សត្តា បុព្វណ្ហសមយំ កាយេន
សុចរិតំ ចរន្តិ វាចាយ សុចរិតំ ចរន្តិ មនសា
សុចរិតំ ចរន្តិ សុបុព្វណ្ហោ ភិក្ខវេ តេសំ សត្តានំ

តតិយបណ្ណាសកមង្គលវគ្គ

[១៥៥] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកប ដោយធម៌ ៣ យ៉ាង ។ បេ ។ គឺកាយកម្មមិនស្អាត ១ វចីកម្មមិនស្អាត ១ មនោកម្មមិនស្អាត ១ ។ បេ ។ គឺកាយកម្មស្អាត ១ វចីកម្មស្អាត ១ មនោកម្មស្អាត ១ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតជាអ្នកឆ្លៀវឆ្លាស ជាសប្បុរស ប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងរក្សាខ្លួនដែលមិនបានគាស់រំលើង មិនផ្តាច់ផ្តិល (នូវគុណ) ជាអ្នកមិនមានទោសផង មិនមានដំនៀលរបស់អ្នកប្រាជ្ញផង រមែងបាននូវបុណ្យជាច្រើនផង ។

[១៥៦] ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំនេះ មាន ៣ យ៉ាង ។ ការថ្វាយបង្គំ ៣ យ៉ាងដូចម្តេចខ្លះ ។ គឺថ្វាយបង្គំដោយកាយ ១ ដោយវាចា ១ ដោយចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ការថ្វាយបង្គំមាន ៣ យ៉ាងនេះឯង ។

[១៥៧] ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងបុព្វណ្ហ-សម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះឈ្មោះថា មានបុព្វណ្ហសម័យដ៏ល្អ

យេ ភិក្ខវេ សត្តា មជ្ឈន្តិកសមយំ កាយេន សុចរិតំ ចរន្តិ វាចាយ សុចរិតំ ចរន្តិ មនសា សុចរិតំ ចរន្តិ សុមជ្ឈន្តិកោ ភិក្ខវេ តេសំ សត្តានំ យេ ភិក្ខវេ សត្តា សាយណ្ហសមយំ កាយេន សុចរិតំ ចរន្តិ វាចាយ សុចរិតំ ចរន្តិ មនសា សុចរិតំ ចរន្តិ សុសាយណ្ហោ ភិក្ខវេ តេសំ សត្តានន្តិ ។

សុនក្ខត្តំ សុមង្គលំ
សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច
សុយិដ្ឋំ ព្រហ្មចារិសុ
បទក្ខិណំ កាយកម្មំ
វាចាកម្មំ បទក្ខិណំ
បទក្ខិណំ មនោកម្មំ
បណិធី តេ បទក្ខិណា
បទក្ខិណានិ កត្វាន
លភន្តត្ថេ បទក្ខិណេ ។

ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងមជ្ឈន្តិកសម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះឈ្មោះថា មានមជ្ឈន្តិកសម័យដ៏ល្អ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយណា ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងសាយណ្ហសម័យ ម្នាលភិក្ខុទាំងឡាយ សត្វទាំងនោះឈ្មោះថា មានសាយណ្ហសម័យដ៏ល្អ ។

ពេលណា ដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចាចិត្ត ពេលនោះឈ្មោះថា នក្ខត្តឫក្សល្អ មង្គលល្អ ពេលភ្លឺស្វាងល្អ ពេលនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជា) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថាជាគ្រឿងបូជាល្អ (ក្នុងថ្ងៃនោះ) កាយកម្មឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន វចីកម្ម ក៏ឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន មនោកម្ម ក៏ឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន សេចក្តីប្រាថ្នាទាំងឡាយ របស់អ្នកទាំងនោះ ក៏ឈ្មោះថា នាំឲ្យមានសេចក្តីចម្រើន បុគ្គលដែលបានធ្វើ នូវកាយកម្ម វចីកម្ម មនោកម្ម គួរដល់សេចក្តីចម្រើនហើយ រមែងបាននូវប្រយោជន៍ ដ៏ចម្រើនទាំងឡាយ ។

៤៧៧

តតិយបណ្ណាសកេ មង្គលវគ្គោ

តេ អត្ថលទ្ធា សុខិតា

វិរូឡ្ហា ពុទ្ធសាសនេ

អរោគា សុខិតា ហោថ

សហ សព្វេហិ ញាតិភីតិ ។

មង្គលវគ្គោ បញ្ចមោ ។

## តស្សុទ្ទានំ

អកុសលញ្ច សាវជ្ជំ

វិសមាសុចិនា សហ

ចតុក្ខតា ច វន្ទនា

សុបុព្វណ្ហេន តេ ទសាតិ ។

តតិយោ បណ្ណាសកោ សមត្តោ ។

អ្នកទាំងឡាយនោះ ចូរបានទូវប្រយោជន៍ បានទូវសេចក្ដីសុខ ចូរចម្រើនក្នុងព្រះពុទ្ធសាសនា ចូរកុំឲ្យមានរោគ ឲ្យបានទូវសេចក្ដីសុខ ព្រមទាំងញាតិទាំងឡាយគ្រប់គ្នា ។

ចប់ មង្គលវគ្គ ទី ៥ ។

# ឧទ្ទាននៃមង្គលវគ្គនោះគឺ

និយាយអំពីបុគ្គលដែលប្រកបដោយកម្មជាអកុសល ១ អំពីកម្មប្រកបដោយទោស ១ ព្រមទាំងកម្មមិនរាបសា ១ កម្មមិនស្អាត ១ អំពីបុគ្គលរក្សាខ្លួន ដែលគាស់រំលើង (គុណ) ៤ លើក ១ អំពីការថ្វាយបង្គំ ១ អំពីបុព្វណ្ហសម័យល្អ ១ ត្រូវជា ១០ ។

ចប់ តតិយបណ្ណាសក ។

# បណ្ណាសកាសង្គហិតាសុត្តន្តា

[១៩៨] តិស្សោ ឥមា ភិក្ខវេ បដិបទា ។ កតមា តិស្សោ ។ អាគាឡ្ហា បដិបទា និជ្ឈាមា បដិបទា មជ្ឈិមា បដិបទា ។ កតមា ច ភិក្ខវេ អាគាឡ្ហា បដិបទា ។ ឥធ ភិក្ខវេ ឯកច្ចោ ឯវំវាទី ហោតិ ឯវំទិដ្ឋិ នត្ថិ កាមេសុ ទោសោតិ សោ កាមេសុ បាតព្យតំ អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ អាគាឡ្ហា បដិបទា ។ កតមា ច ភិក្ខវេ និជ្ឈាមា បដិបទា ។ ឥធ ភិក្ខវេ ឯកច្ចោ អចេលកោ ហោតិ មុត្តា-ចារោ ហត្ថាវលេខនោ ន ឯហិភទន្តិកោ ន តិដ្ឋភ-ទន្តិកោ នាភិហតំ ន ឧទ្ទិស្សកតំ ន និមន្តនំ សាទិយតិ ។ សោ ន កុម្ភិមុខា បដិគ្គណ្ហាតិ ន កឡោបិមុខា បដិគ្គណ្ហាតិ ន ឯឡកមន្តរំ

# សូត្រមិនសង្គ្រោះចូលក្នុងបណ្ណាសក

[១៥៨] ម្នាលភិក្ខុទាំងឡាយ បដិបទានេះ មាន ៣ យ៉ាង ។ បដិបទា ៣ យ៉ាងគឺអ្វីខ្លះ ។ គឺអាគាឡ្ហប្បដិបទា (ប្រតិបទ័គ្រោតគ្រាត) ១ និជ្ឈាមប្បដិបទា (ប្រតិប័ទដុតកម្ដៅខ្លួនហួសហេតុ) ១ មជ្ឈិមប្បដិបទា (ប្រតិប័ទយ៉ាងកណ្ដាល) ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះអាគាឡ្ហប្បដិបទា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្ដីប្រកាន់យ៉ាងនេះ មានសេចក្ដីយល់ឃើញយ៉ាងនេះថា ទោសក្នុងកាមទាំងឡាយ មិនមានដូច្នេះ បុគ្គលនោះ រមែងដល់នូវសភាពជាអ្នកធ្លាក់ចុះក្នុងកាមទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា អាគាឡ្ហប្បដិបទា ។ ម្នាលភិក្ខុទាំងឡាយ ចុះនិជ្ឈាមប្បដិបទា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ គ្មានសំពត់ (អាក្រាត) លះបង់មារយាទល្អ ស៊ីលិទ្ធដៃឬជម្រះឧច្ចារៈ ដោយម្រាមដៃ បើគេអញ្ជើញថា ចូលមក ក៏មិនមក គេឃាត់ថាឈប់ ក៏មិនឈប់ មិនត្រេកអរនឹងភត្តដែលគេនាំមកមុន មិនត្រេកអរនឹងភត្តដែលគេនាំមកចំពោះខ្លួន មិនត្រេកអរនឹងការនិមន្ត បុគ្គលនោះ មិនទទួលភត្តអំពីមាត់ឆ្នាំង មិនទទួលភត្តអំពីមាត់កញ្ជើ មិនទទួលភត្តដែលគេនាំមក កន្លងធរណីទ្វារ ។

ន ទណ្ឌមន្តរំ ន មុសលមន្តរំ ន ទ្វិន្នំ ភុញ្ជមានានំ ន គព្ភិនិយា ន បាយមានាយ ន បុរិសន្តរគតាយ ន សំកិត្តីសុ ន យត្ថ សា ឧបដ្ឋិតោ ហោតិ ន យត្ថ មក្ខិកា សណ្ឌសណ្ឌចារិនី ន មច្ឆំ ន មំសំ ន សុរំ ន មេរយំ ន ថុសោទកំ បិវតិ ឯកាគារិកោ វា ហោតិ ឯកាលោបិកោ ទ្វាគារិកោ វា ហោតិ ទ្វាលោ-បិកោ... សត្តាគារិកោ វា ហោតិ សត្តាលោបិកោ ឯកិ-ស្សាបិ ទត្តិយា យាបេតិ ទ្វីហិបិ ទត្តីហិ យាបេតិ... សត្តហិបិ ទត្តីហិ យាបេតិ ឯកាហិកម្បិ អាហារំ អាហារេតិ ទ្វីហិកម្បិ អាហារំ អាហារេតិ... សត្តា-ហិកម្បិ អាហារំ អាហារេតិ ឥតិ ឯវរូបំ អឌ្ឍមាសិកម្បិ បរិយាយភត្តភោជនានុយោគមនុយុត្តោ វិហរតិ ។

ពួកសូត្រមិនសង្គ្រោះចូលក្នុងបណ្ណាសក

មិនទទួលភត្តដែលគេនាំមក កន្ទង់កំណាត់ឈើ មិនទទួលភត្តដែលគេនាំមកកន្ទង់អង្រ្គែ មិនទទួលភត្តរបស់មនុស្សពីរនាក់ ដែលកំពុងបរិភោគ មិនទទួលភត្តរបស់ស្ត្រីមានគភ៌ មិនទទួលភត្តរបស់ស្ត្រីដែលកំពុងបំបៅកូន មិនទទួលភត្តរបស់ស្ត្រីដែលកំពុងនៅរួមនឹងបុរស មិនទទួលភត្តក្នុងទីដែលពួកគ្នាឯងណែនាំ មិនទទួលភត្តក្នុងទីដែលមានឆ្កែនៅចាំ មិនទទួលភត្តក្នុងទីដែលមានរុយរោម មិនស៊ីត្រី មិនស៊ីសាច់ មិនផឹកសុរា មិនផឹកមេរ័យ មិនផឹកទឹកត្រាំថ្នាំ បុគ្គលនោះទទួលភត្តចំពោះតែក្នុងផ្ទះមួយ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយមួយពំនូតខ្លះ ទទួលភត្តចំពោះតែក្នុងផ្ទះពីរ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយពីរពំនូតខ្លះ ទទួលភត្តចំពោះតែក្នុងផ្ទះ ៧ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយដុំបាយ ៧ ពំនូតខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងភាជន៍ ១ ខ្លះ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងភាជន៍ ២ ខ្លះ... ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តក្នុងភាជន៍ ៧ ខ្លះ... ស៊ីអាហាររំលង ១ ថ្ងៃខ្លះ ស៊ីអាហាររំលង ២ ថ្ងៃខ្លះ... ស៊ីអាហាររំលង ៧ ថ្ងៃខ្លះ បុគ្គលនោះប្រកបដោយសេចក្ដីព្យាយាម ក្នុងការផ្លាស់ប្ដូរនូវការបរិភោគភត្តរំលងកន្លះខែ មានសភាព ដូច្នេះឯង ។

សោ សាកភក្ខោបិ ហោតិ សាមាកភក្ខោបិ ហោតិ និវារភក្ខោបិ ហោតិ ទទ្ទុលភក្ខោបិ ហោតិ និយាសភក្ខោបិ ហោតិ ហដភក្ខោបិ ហោតិ កណភក្ខោបិ ហោតិ អាចាមភក្ខោបិ ហោតិ បិញ្ញាកភក្ខោបិ ហោតិ តិណភក្ខោបិ ហោតិ គោមយភក្ខោបិ ហោតិ វនមូលផលាហារោបិ យាបេតិ បវត្តផលភោជី សោ សាណានិបិ ធារេតិ មសា-ណានិបិ ធារេតិ ឆវទុស្សានិបិ ធារេតិ បំសុកូលានិបិ ធារេតិ តិរីដកានិបិ ធារេតិ អជិនានិបិ ធារេតិ អជិនក្ខិបម្បិ ធារេតិ កុសចីរម្បិ ធារេតិ វាកចីរម្បិ ធារេតិ ផលកចីរម្បិ ធារេតិ កេសកម្ពលម្បិ ធារេតិ វាលកម្ពលម្បិ ធារេតិ ឧលូកបក្ខម្បិ ធារេតិ កេសមស្សុលោចកោបិ ហោតិ កេសមស្សុលោច-នានុយោគមនុយុត្តោ ឧព្ភដ្ឋកោបិ ហោតិ អាសន-ប្បដិក្ខិត្តោ ឧក្កុដិកោបិ ហោតិ ឧក្កុដិក-ប្បធានមនុយុត្តោ កណ្ដកាបស្សយិកោបិ ហោតិ

បុគ្គលនោះមានបន្លែស្រស់ជាអាហារខ្លះ មានអង្ករស្រងែជាអាហារខ្លះ មានស្លួយជាអាហារខ្លះ មានកំទេចស្បែកជាអាហារខ្លះ មានជ័រជាអាហារខ្លះ មានស្នៃឬសារាយជាអាហារខ្លះ មានកន្ទក់ជាអាហារខ្លះ មានបាយក្តាំងជាអាហារខ្លះ មានម្សៅជាអាហារខ្លះ មានស្មៅជាអាហារខ្លះ មានអាចម៍គោជាអាហារខ្លះ មានមើមឈើនិងផ្លែឈើ ក្នុងព្រៃជាអាហារខ្លះ បរិភោគតែផ្លែឈើដែលជ្រុះស្រាប់ខ្លះ បុគ្គលនោះស្លៀកដណ្តប់សំពត់សម្បកធ្មៃខ្លះ ស្លៀកដណ្តប់សំពត់ដែលគេត្បាញលាយគ្នាខ្លះ ស្លៀកដណ្តប់សំពត់ដែលបកចេញអំពីសាកសពខ្លះ ស្លៀកដណ្តប់សំពត់បង្សុកូលខ្លះ ស្លៀកដណ្តប់សំបកឈើខ្លះ ស្លៀកដណ្តប់ស្បែកខ្លាខ្លះ ស្លៀកដណ្តប់ស្បែកខ្លាទាំងក្រចកខ្លះ ស្លៀកដណ្តប់ស្បូវក្លាំងខ្លះ ស្លៀកដណ្តប់សំពត់ត្បាញដោយសម្បកក្រចៅខ្លះ ស្លៀកដណ្តប់ចម្រៀកក្តារខ្លះ ស្លៀកដណ្តប់សំពត់កម្ពលដែលត្បាញដោយសក់មនុស្សខ្លះ ស្លៀកដណ្តប់សំពត់កម្ពលដែលត្បាញដោយរោមកន្ទុយសត្វខ្លះ ស្លៀកដណ្តប់សំពត់ដែលត្បាញដោយស្លាបមៀមខ្លះ ទុកសក់និងពុកមាត់ ប្រព្រឹត្តកាន់វត្ត ក្នុងការព្យាយាមទុកសក់និងពុកមាត់ខ្លះ ឈរសម្រឹងហាមឃាត់នូវអាសនៈខ្លះ អង្គុយច្រហោងប្រព្រឹត្តកាន់វត្តក្នុងការព្យាយាមអង្គុយច្រហោងខ្លះ ដេកលើបន្ទា

កណ្ដកាបស្សយេ សេយ្យំ កប្បេតិ សាយតតិយកម្បិ ឧទកោរោហណានុយោគមនុយុត្តោ វិហរតិ ។ ឥតិ ឯវរូបំ អនេកវិហិតំ កាយស្ស អាតាបនបរិតាបនា-នុយោគមនុយុត្តោ វិហរតិ ។ អយំ វុច្ចតិ ភិក្ខវេ និជ្ឈាមា បដិបទា ។ កតមា ច ភិក្ខវេ មជ្ឈិមា បដិបទា ។ ឥធ ភិក្ខវេ ភិក្ខុ កាយេ កាយា-នុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ វេទនាសុ... ចិត្តេ... ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ អយំ វុច្ចតិ ភិក្ខវេ មជ្ឈិមា បដិបទា ។ ឥមា ខោ ភិក្ខវេ តិស្សោ បដិបទាតិ ។

[១៨៩] តិស្សោ ឥមា ភិក្ខវេ បដិបទា ។ កតមា តិស្សោ ។ អាគាឡ្ហា បដិបទា និជ្ឈាមា បដិបទា

សម្រេចការដេកលើកបន្ទាខ្លះ ប្រព្រឹត្តកាន់វត្តចុះត្រាំទឹក ១ ថ្ងៃ ៣ ដងគឺព្រឹក ថ្ងៃត្រង់ ល្ងាចខ្លះ បុគ្គលនោះ ប្រព្រឹត្តកាន់វត្តកម្តៅកាយជាច្រើន មានសភាពយ៉ាងនេះ ដោយប្រការដូច្នេះឯង ម្នាលភិក្ខុទាំងឡាយ នេះហៅថា និជ្ឈាមប្បដិបទា ។ ម្នាលភិក្ខុទាំងឡាយ ចុះមជ្ឈិមប្បដិបទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណានូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានប្រាជ្ញាស្មារតី បន្ទោបង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ក្នុងវេទនាទាំងឡាយ... ក្នុងចិត្ត... ពិចារណានូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានប្រាជ្ញាស្មារតី បន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា មជ្ឈិមប្បដិបទា ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៣ យ៉ាងនេះឯង ។

[១៥៩] ម្នាលភិក្ខុទាំងឡាយ បដិបទានេះ មាន ៣ យ៉ាង ។ បដិបទា ៣ យ៉ាងគឺអ្វីខ្លះ ។ គឺអាគាឡ្ហប្បដិបទា ១ និជ្ឈាមប្បដិបទា ១

មជ្ឈិមា បដិបទា ។ កតមា ច ភិក្ខវេ អាគាឡ្ហា បដិបទា ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ អាគាឡ្ហា បដិបទា ។ កតមា ច ភិក្ខវេ និជ្ឈាមា បដិបទា ។ បេ ។ អយំ វុច្ចតិ ភិក្ខវេ និជ្ឈាមា បដិបទា ។ កតមា ច ភិក្ខវេ មជ្ឈិមា បដិបទា ។ ឥធ ភិក្ខវេ ភិក្ខុ អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ បហានាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ អនុប្បន្នានំ កុសលានំ ធម្មានំ ឧប្បាទាយ ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ ឧប្បន្នានំ កុសលានំ ធម្មានំ ឋិតិយា អសម្មោសាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា ឆន្ទំ ជនេតិ វាយមតិ វីរិយំ អារភតិ ចិត្តំ បគ្គណ្ហាតិ បទហតិ... ឆន្ទសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីរិយសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ

មជ្ឈិមប្បដិបទា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះអាគាឡ្ហប្បដិបទាដូចម្តេច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាអាគាឡ្ហប្បដិបទា ។ ម្នាលភិក្ខុទាំងឡាយ ចុះនិជ្ឈាមប្បដិបទា តើដូចម្តេច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថានិជ្ឈាមប្បដិបទា ។ ម្នាលភិក្ខុទាំងឡាយ ចុះមជ្ឈិមប្បដិបទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ បណ្តុះឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធសេចក្តីព្យាយាម ផ្គងតម្កល់ចិត្តទុក ដើម្បីញុំាងអកុសលធម៌ដ៏លាមកដែលមិនទាន់កើត មិនឲ្យកើតឡើង បណ្តុះឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធសេចក្តីព្យាយាម ផ្គងតម្កល់ចិត្តទុក ដើម្បីលះបង់អកុសលធម៌ដ៏លាមកដែលកើតឡើងហើយ បណ្តុះឆន្ទៈឲ្យកើត ព្យាយាម ប្រារព្ធសេចក្តីព្យាយាម ផ្គងតម្កល់ចិត្តទុក ដើម្បីញុំាងកុសលធម៌ដែលមិនទាន់កើត ឲ្យកើតឡើង បណ្តុះឆន្ទៈឲ្យកើតឡើង ព្យាយាម ប្រារព្ធសេចក្តីព្យាយាម ផ្គង់តម្កល់ចិត្តទុក ដើម្បីឋិតថេរ ដើម្បីមិនវិនាស ដើម្បីលូតលាស់ ដើម្បីធំទូលាយ ដើម្បីចម្រើនឡើង ដើម្បីបរិបូណ៌នៃកុសលធម៌ដែលកើតឡើងហើយ... ចម្រើនឥទ្ធិបាទដែលប្រកបដោយឆន្ទសមាធិ និងបធានសង្ខារ ចម្រើនឥទ្ធិបាទដែលប្រកបដោយវិរិយសមាធិ និងបធានសង្ខារ

ចិត្តសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ វីមំសាសមាធិប្បធានសង្ខារសមន្នាគតំ ឥទ្ធិបាទំ ភាវេតិ... សទ្ធិន្ទ្រិយំ ភាវេតិ វីរិយិន្ទ្រិយំ ភាវេតិ សតិន្ទ្រិយំ ភាវេតិ សមាធិន្ទ្រិយំ ភាវេតិ បញ្ញិន្ទ្រិយំ ភាវេតិ... សទ្ធាពលំ ភាវេតិ វីរិយពលំ ភាវេតិ សតិពលំ ភាវេតិ សមាធិពលំ ភាវេតិ បញ្ញាពលំ ភាវេតិ... សតិសម្ពោជ្ឈង្គំ ភាវេតិ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ វីរិយសម្ពោជ្ឈង្គំ ភាវេតិ បីតិសម្ពោជ្ឈង្គំ ភាវេតិ បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ... សម្មាទិដ្ឋឹ ភាវេតិ សម្មាសង្កប្បំ ភាវេតិ សម្មាវាចំ ភាវេតិ សម្មាកម្មន្តំ ភាវេតិ សម្មាអាជីវំ ភាវេតិ សម្មាវាយាមំ ភាវេតិ សម្មាសតឹ ភាវេតិ សម្មាសមាធឹ ភាវេតិ ។ អយំ វុច្ចតិ ភិក្ខវេ មជ្ឈិមា បដិបទា ។ ឥមា ខោ ភិក្ខវេ តិស្សោ បដិបទាតិ[១] ។

---

១ ម. អចេលកវគ្គោ ឆដ្ឋោ ។

តស្សុទ្ទានំ

សតិប្បដ្ឋានំ ឥទ្ធិ ច ឥន្ទ្រិយេន ពលេន ច
ពោជ្ឈង្គោ ចេវ មគ្គោ ច បដិបទា ច យោជយេតិ ។

ចម្រើនឥទ្ធិបាទដែលប្រកបដោយចិត្តសមាធិនិងបធានសង្ខារ ចម្រើនឥទ្ធិបាទដែលប្រកបដោយវីមំសាសមាធិនិងបធានសង្ខារ... ចម្រើនសទ្ធិន្ទ្រិយ ចម្រើនវីរិយន្ទ្រិយ ចម្រើនសតិន្ទ្រិយ ចម្រើនសមាធិន្ទ្រិយ ចម្រើនបញ្ញិន្ទ្រិយ... ចម្រើនសទ្ធាពលៈចម្រើនវីរិយពលៈចម្រើនសតិពលៈចម្រើនសមាធិពលៈ ចម្រើនបញ្ញាពលៈ... ចម្រើនសតិសម្ពោជ្ឈង្គ ចម្រើនធម្មវិចយសម្ពោជ្ឈង្គ ចម្រើនវីរិយសម្ពោជ្ឈង្គ ចម្រើនបីតិសម្ពោជ្ឈង្គ ចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ ចម្រើនសមាធិសម្ពោជ្ឈង្គ ចម្រើនឧបេក្ខាសម្ពោជ្ឈង្គ... ចម្រើនសម្មាទិដ្ឋិ ចម្រើនសម្មាសង្កប្បៈ ចម្រើនសម្មាវាចា ចម្រើនសម្មាកម្មន្តៈ ចម្រើនសម្មាអាជីវៈ ចម្រើនសម្មាវាយាមៈ ចម្រើនសម្មាសតិ ចម្រើនសម្មាសមាធិ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថាមជ្ឈិមប្បដិបទា ។ ម្នាលភិក្ខុទាំងឡាយ បដិបទាមាន ៣ យ៉ាងនេះឯង[១] ។

---

១ ម. ចប់ អចេលកវគ្គ ទី ៦ ។

ឧទ្ទាននៃអចេលកវគ្គនោះគឺ

និយាយអំពីសតិប្បដ្ឋាន ១ ឥទ្ធិបាទ ១

ឥន្ទ្រិយ ១ ពលៈ ១ ពោជ្ឈង្គ ១ មគ្គ ១

ដែលលោកប្រកបហៅថាបដិបទា (ផ្លូវប្រតិប័ទ) ។

[១៦០] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ កតមេហិ តីហិ ។ អត្តនា ច ចាណាតិចាតី ហោតិ បរញ្ច ចាណាតិចាតេ សមាទបេតិ ចាណាតិចាតេ ច សមនុញ្ញោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ និរយេ ។ តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេ ។ កតមេហិ តីហិ ។ អត្តនា ច ចាណាតិចាតា បដិវិរតោ ហោតិ បរញ្ច ចាណាតិចាតា វេរមណិយា សមា-ទបេតិ ចាណាតិចាតា វេរមណិយា ច សមនុញ្ញោ ហោតិ ។ បេ ។ អត្តនា ច អទិន្នាទាយី ហោតិ បរញ្ច អទិន្នាទានេ សមាទបេតិ អទិន្នាទានេ ច សមនុញ្ញោ ហោតិ... អត្តនា ច អទិន្នាទានា បដិវិរតោ ហោតិ បរញ្ច អទិន្នាទានា វេរមណិយា សមាទបេតិ អទិន្នាទានា វេរមណិយា ច សមនុញ្ញោ ហោតិ... អត្តនា ច កាមេសុ មិច្ឆាចារី ហោតិ

[១៦០] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺបុគ្គល ជាអ្នកសម្លាប់សត្វដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃ ក្នុងការសម្លាប់សត្វ ១ ពេញចិត្តក្នុងការសម្លាប់សត្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក ។ ប្រកបដោយធម៌ ៣ យ៉ាងគឺអ្វីខ្លះ ។ គឺបុគ្គលវៀរចាកការសម្លាប់សត្វដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកការសម្លាប់សត្វ ១ ពេញចិត្តក្នុងការវៀរចាកការសម្លាប់សត្វ ១ ។ បេ ។ កាន់យកទ្រព្យដែលគេមិនបានឲ្យដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ពេញចិត្តក្នុងការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១... ជាអ្នកវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ពេញចិត្តក្នុងការវៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ ... ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយដោយខ្លួនឯង ១

បរញ្ច កាមេសុ មិច្ឆាចារេ សមាទបេតិ កាមេសុ មិច្ឆាចារេ ច សមនុញ្ញោ ហោតិ... អត្តនា ច កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ បរញ្ច កាមេសុ មិច្ឆាចារា វេរមណិយា សមាទបេតិ កាមេសុ មិច្ឆាចារា វេរមណិយា ច សមនុញ្ញោ ហោតិ... អត្តនា ច មុសាវាទី ហោតិ បរញ្ច មុសាវាទេ សមាទបេតិ មុសាវាទេ ច សមនុញ្ញោ ហោតិ... អត្តនា ច មុសាវាទា បដិវិរតោ ហោតិ បរញ្ច មុសាវាទា វេរមណិយា សមាទបេតិ មុសាវាទា វេរមណិយា ច សមនុញ្ញោ ហោតិ... អត្តនា ច បិសុណាវាចោ ហោតិ បរញ្ច បិសុណាយ វាចាយ សមាទបេតិ បិសុណាយ វាចាយ ច សមនុញ្ញោ ហោតិ... អត្តនា ច បិសុណាយ វាចាយ បដិវិរតោ ហោតិ បរញ្ច បិសុណាយ វាចាយ វេរមណិយា សមាទបេតិ បិសុណាយ វាចាយ វេរមណិយា ច សមនុញ្ញោ ហោតិ... អត្តនា ច ផរុសវាចោ ហោតិ បរញ្ច ផរុសាយ វាចាយ សមាទបេតិ

ដឹកនាំបុគ្គលដទៃក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ជាអ្នកពេញចិត្តក្នុងការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១... ជាអ្នកវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១ ជាអ្នកត្រេកអរក្នុងការវៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ១... ជាអ្នកពោលពាក្យកុហកដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការពោលពាក្យកុហក ១ ជាអ្នកពេញចិត្តក្នុងការពោលពាក្យកុហក ១... ជាអ្នកវៀរចាកការពោលពាក្យកុហកដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃ ក្នុងការវៀរចាក ការពោលពាក្យកុហក ១ ជាអ្នកពេញចិត្ត ក្នុងការវៀរចាកការពោលពាក្យកុហក ១... ជាអ្នកពោលពាក្យញុះញង់ ដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការពោលពាក្យញុះញង់ ១ ជាអ្នកពេញចិត្តក្នុងការពោលពាក្យញុះញង់ ១... ជាអ្នកវៀរចាកការពោលពាក្យញុះញង់ដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកការពោលពាក្យញុះញង់ ១ ជាអ្នកពេញចិត្ត ក្នុងការវៀរចាកការពោលពាក្យញុះញង់ ១... ជាអ្នកពោលពាក្យអាក្រក់ដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃ ក្នុងការពោលពាក្យអាក្រក់ ១

ផរុសាយ វាចាយ ច សមាទបេតិ... អត្តនា ច ផរុសាយ វាចាយ បដិវិរតោ ហោតិ បរញ្ច ផរុសាយ វាចាយ វេរមណិយា សមាទបេតិ ផរុសាយ វាចាយ វេរមណិយា ច សមនុញ្ញោ ហោតិ... អត្តនា ច សម្ផប្បលាបី ហោតិ បរញ្ច សម្ផប្បលាបេ សមា-ទបេតិ សម្ផប្បលាបេ ច សមនុញ្ញោ ហោតិ... អត្តនា ច សម្ផប្បលាបា បដិវិរតោ ហោតិ បរញ្ច សម្ផប្បលាបា វេរមណិយា សមាទបេតិ សម្ផប្បលាបា វេរមណិយា ច សមនុញ្ញោ ហោតិ... អត្តនា ច អភិជ្ឈាលុ ហោតិ បរញ្ច អភិជ្ឈាយ សមាទបេតិ អភិជ្ឈាយ ច សមនុញ្ញោ ហោតិ... អត្តនា ច អនភិជ្ឈាលុ ហោតិ បរញ្ច អនភិជ្ឈាយ សមាទបេតិ អនភិជ្ឈាយ ច សមនុញ្ញោ ហោតិ... អត្តនា ច ព្យាបន្នចិត្តោ ហោតិ

ជាអ្នកពេញចិត្ត ក្នុងការពោលពាក្យអាក្រក់ ១... ជាអ្នកវៀរចាកការនិយាយពាក្យអាក្រក់ ១ ដឹកនាំបុគ្គលដទៃ ក្នុងការវៀរចាកការនិយាយពាក្យអាក្រក់ ១ ជាអ្នកពេញចិត្ត ក្នុងការវៀរចាកការនិយាយពាក្យអាក្រក់ ១... ជាអ្នកនិយាយពាក្យឥតប្រយោជន៍ដោយខ្លួនឯង ១ ជាអ្នកដឹកនាំបុគ្គលដទៃក្នុងការនិយាយពាក្យឥតប្រយោជន៍ ១ ជាអ្នកពេញចិត្តក្នុងការនិយាយពាក្យឥតប្រយោជន៍ ១... ជាអ្នកវៀរចាកការនិយាយពាក្យឥតប្រយោជន៍ដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការវៀរចាកការនិយាយពាក្យឥតប្រយោជន៍ ១ ជាអ្នកពេញចិត្តក្នុងការវៀរចាកការនិយាយពាក្យឥតប្រយោជន៍ ១... ជាអ្នកសំឡឹងរំពៃនូវទ្រព្យបុគ្គលដទៃដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការសំឡឹងរំពៃនូវទ្រព្យបុគ្គលដទៃ ១ ជាអ្នកពេញចិត្តក្នុងការសំឡឹងរំពៃនូវទ្រព្យបុគ្គលដទៃ ១... ជាអ្នកមិនសំឡឹងរំពៃនូវទ្រព្យបុគ្គលដទៃដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការមិនសំឡឹងរំពៃទ្រព្យបុគ្គលដទៃ ១ ជាអ្នកពេញចិត្តក្នុងការមិនសំឡឹងរំពៃទ្រព្យបុគ្គលដទៃ ១ . . . ជាអ្នកមានចិត្តគុំកួនដោយខ្លួនឯង ១

បរញ្ច ព្យាបាទេ សមាទបេតិ ព្យាបាទេ ច សមនុញ្ញោ ហោតិ... អត្តនា ច អព្យាបន្នចិត្តោ ហោតិ បរញ្ច អព្យាបាទេ សមាទបេតិ អព្យាបាទេ ច សមនុញ្ញោ ហោតិ... អត្តនា ច មិច្ឆាទិដ្ឋិកោ ហោតិ បរញ្ច មិច្ឆាទិដ្ឋិយា សមាទបេតិ មិច្ឆាទិដ្ឋិយា ច សមនុញ្ញោ ហោតិ... អត្តនា ច សម្មាទិដ្ឋិកោ ហោតិ បរញ្ច សម្មាទិដ្ឋិយា សមាទបេតិ សម្មាទិ-ដ្ឋិយា ច សមនុញ្ញោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ យថាភតំ និក្ខិត្តោ ឯវំ សគ្គេតិ ។(១)

១ ម. កម្មបថបេយ្យាលំ(១) និដ្ឋិតំ ។

តស្សុទ្ទានំ

បាណិអទិន្នមិច្ឆា ច មុសាវាទី ច បិសុណា
ផរុសា សម្ផប្បលា ច អភិជ្ឈា ព្យាបាទទិដ្ឋិ ច
កម្មបថាសុ បេយ្យាលំ តិកកេន និយោជយេតិ ។

១ កម្មបថបេយ្យាលោ និដ្ឋិតោ យុត្តតរោ ។

ដឹកនាំបុគ្គលដទៃក្នុងការគុំកួន ១ ជាអ្នកពេញចិត្តក្នុងការគុំកួន ១... ជាអ្នកមិនមានចិត្តគុំកួនដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃ ក្នុងការមិនគុំកួន ១ ជាអ្នកពេញចិត្តក្នុងការមិនគុំកួន ១... ជាអ្នកមានសេចក្តីយល់ខុសដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងការយល់ខុស ១ ជាអ្នកពេញចិត្តក្នុងការយល់ខុស ១... ជាអ្នកមានសេចក្តីយល់ត្រូវដោយខ្លួនឯង ១ ដឹកនាំបុគ្គលដទៃក្នុងសេចក្តីយល់ត្រូវ ១ ជាអ្នកពេញចិត្ត ក្នុងសេចក្តីយល់ត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយធម៌ ៣ យ៉ាងនេះឯង រមែងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅតម្កល់ទុក[១] ។

---

១ ម. ចប់ កម្មបថបេយ្យាល ។

ឧទ្ទាននៃកម្មបថបេយ្យាលនោះគឺ

និយាយអំពីការសម្លាប់សត្វ ១ កាន់យកទ្រព្យដែលគេមិនឲ្យ ១ ប្រព្រឹត្តខុសក្នុងកាម ១ និយាយកុហក ១ និយាយញុះញង់ ១ និយាយអាក្រក់ ១ និយាយពាក្យឥតប្រយោជន៍ ១ សំឡឹងរំពៃចំពោះទ្រព្យបុគ្គលដទៃ ១ សេចក្តីគុំកួន ១ សេចក្តីយល់ខុស ១ បណ្ឌិតគប្បីបញ្ចូលកម្មបថទាំងឡាយ ឲ្យគ្រប់ជា ៣ ត្រង់បេយ្យាលផងចុះ ។

[១៦១] រាគស្ស ភិក្ខវេ អភិញ្ញាយ តយោ ធម្មា ភាវេតព្វា ។ កតមេ តយោ ។ សុញ្ញតោ សមាធិ អនិមិត្តោ សមាធិ អប្បណិហិតោ សមាធិ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ តយោ ធម្មា ភាវេតព្វា ។ រាគស្ស ភិក្ខវេ បរិញ្ញាយ ។ បេ ។ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ តយោ ធម្មា ភាវេតព្វា ។ ទោសស្ស មោហស្ស កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆ-រិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ តយោ ធម្មា ភាវេតព្វាតិ ។

បណ្ណាសកាសង្គហិតា សុត្តន្តា និដ្ឋិតា ។

[១៦១] ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាង បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៣ យ៉ាង ដូចម្តេច ។ គឺសុញ្ញតសមាធិ ១ អនិមិត្តសមាធិ ១ អប្បណិហិតសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះឯង បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៣ យ៉ាងនេះ បុគ្គលគប្បីចម្រើន ដើម្បីកំណត់ដឹង ។ បេ ។ ដើម្បីអស់រលីង ដើម្បីលះបង់ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីវិនាស ដើម្បីរលត់ ដើម្បីផ្តាច់បង់ ដើម្បីរលាស់ចោល នូវរាគៈ ។ ធម៌ ៣ យ៉ាងនេះ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់រលីង ដើម្បីលះបង់ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីវិនាស ដើម្បីរលត់ ដើម្បីផ្តាច់បង់ ដើម្បីរលាស់ចោលនូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ។

ចប់ ពួកសូត្រដែលមិនសង្គ្រោះក្នុងបណ្ណាសក ។

៤៨៩

បណ្ណាសកាសង្គហិតា សុត្តន្តា

# តស្សុទ្ទានំ[១]

រាគំ   ទោសញ្ច   មោហញ្ច   កោធូបនាហបញ្ចមំ
មក្ខបឡាសឥស្សា   ច   មច្ឆរិយមាយាសាឋេយ្យា
ថម្ភសារម្ភមានញ្ច   អតិមានមទស្សា   ច
បមាទា   សត្តរស   វុត្តា   រាគបេយ្យាលនិស្សិតា ។
ឯតេ   ឱបម្មយុត្តេន   អាទានេន   អភិញ្ញាយ
បរិញ្ញាយ   បរិក្ខយា   បហានក្ខយព្វយេន
វិរាគនិរោធចាគំ   បដិនិស្សគ្គេ   ឥមេ   ទស
សុញ្ញតោ   អនិមិត្តោ   ច   អប្បណិហិតោ ច   តយោ
សមាធិមូលកាបេយ្យ-   លេសុបិ   វវត្តិតា   ចាតិ ។

តិកនិបាតោ និដ្ឋិតោ ។

១ តស្សុទ្ទានំ មរម្មបោត្ថកេ អត្ថិយេវ ។

ពួកសូត្រដែលមិនសង្គ្រោះចូលក្នុងបណ្ណាសក

# ឧទ្ទាននៃរាគបេយ្យាលនោះគឺ[១]

និយាយអំពីធម៌ដែលអាស្រ័យនៅ ក្នុងរាគបេយ្យាល ដែលលោកពោលហើយ ថា មាន ១៧ គឺរាគៈ ១ ទោសៈ ១ មោហៈ ១ កោធៈ ១ ឧបនាហៈ ១ ជាគម្រប់ ៥ មក្ខៈ ១ បឡាសៈ ១ ឥស្សា ១ មច្ឆរិយៈ ១ មាយា ១ សាថេយ្យៈ ១ ថម្ភៈ ១ សារម្ភៈ ១ មានៈ ១ អតិមានៈ ១ មទៈ ១ បមាទៈ ១ ។ អំពីសមាធិ ៣ យ៉ាងគឺសុញ្ញាត-សមាធិ ១ អនិមិត្តសមាធិ ១ អប្បណិហិតសមាធិ ១ ដែលលោកកំណត់ទុក ក្នុងសមាធិមូលកាបេយ្យាល ដោយហេតុជាជំនួយ ដែលប្រកបដោយសេចក្តីឧបមា ដើម្បីដឹងច្បាស់ ១ ដើម្បីកំណត់ដឹង ១ ដើម្បីអស់រលីង ១ ដើម្បីលះបង់ ១ ដើម្បីអស់ទៅ ១ ដើម្បីសូន្យទៅ ១ ដើម្បីវិនាស ១ ដើម្បីរលត់ ១ ដើម្បីផ្តាច់បង់ ១ ដើម្បីរលាស់ចោល ១ រួមត្រូវជា ១០ ។

ចប់ តិកនិបាត ។

---

១ ឧទ្ទាននេះ មានតែងក្នុងច្បាប់អក្សរភូមា ។

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស តិកនិបាតោ

# ទុតិយោ ភាគោ

## មាតិកា អង្កេ

| | | |
|---|---|---|
| *បឋមបណ្ណាសកេ* | *ពាលវគ្គោ* ........................................ | *១* |
| | *រថការវគ្គោ* ........................................ | *១៣* |
| | *បុគ្គលវគ្គោ* ........................................ | *៤១* |
| | *ទេវទូតវគ្គោ* ........................................ | *៧៧* |
| | *ចូឡវគ្គោ* ........................................ | *១២០* |
| *ទុតិយបណ្ណាសកេ* | *ព្រាហ្មណវគ្គោ* ........................................ | *១៣២* |
| | *មហាវគ្គោ* ........................................ | *១៧៩* |
| | *អានន្ទវគ្គោ* ........................................ | *២៨៥* |
| | *សមណវគ្គោ* ........................................ | *៣១៨* |
| | *លោណផលវគ្គោ* ........................................ | *៣៤៦* |

# សុត្តន្តបិដក

# អង្គុត្តរនិកាយ តិកនិបាត

# ទុតិយភាគ

## មាតិកា លេខទំព័រ


| | | |
|---|---|---|
| *បឋមបណ្ណាសក* | *ពាលវគ្គ* | *១* |
| | *រថការវគ្គ* | *១៣* |
| | *បុគ្គលវគ្គ* | *៤១* |
| | *ទេវទូតវគ្គ* | *៧៧* |
| | *ចូឡវគ្គ* | *១២០* |
| *ទុតិយបណ្ណាសក* | *ព្រាហ្មណវគ្គ* | *១៣២* |
| | *មហាវគ្គ* | *១៧៩* |
| | *អានន្ទវគ្គ* | *២៨៥* |
| | *សមណវគ្គ* | *៣១៨* |
| | *លោណផលវគ្គ* | *៣៤៦* |

# មាតិកាបត្តានិ

## មាតិកា អង្កេ

| | | |
|---|---|---|
| *តតិយបណ្ណាសកេ* | *សម្មោធិវគ្គោ* | *៣៩០* |
| | *អាបាយិកវគ្គោ* | *៤០៨* |
| | *កុសិនារវគ្គោ* | *៤២៩* |
| | *យោធាជីវវគ្គោ* | *៤៥៣* |
| | *មង្គលវគ្គោ* | *៤៧២* |
| *បណ្ណាសកាសង្គហិតា* | *សុត្តន្តា* | *៤៧៨* |

# សន្លឹកចង្អុលប្រាប់មាតិកា

## មាតិកា លេខទំព័រ

*តតិយបណ្ណាសក* *សម្មោធិវគ្គ* ............................................ *៣៩០*

*អាបាយិកវគ្គ* ........................................ *៤០៨*

*កុសិនារវគ្គ* ............................................ *៤២៩*

*យោធាជីវវគ្គ* ........................................ *៤៥៣*

*មង្គលវគ្គ* ............................................... *៤៧២*

*ពួកសូត្រមិនសង្គ្រោះចូលក្នុងបណ្ណាសក*................................... *៤៧៨*

## រៀបចំវាយអក្សរឡើងវិញនិងពិនិត្យតាមច្បាប់ដើមដោយ

## គណៈកម្មការពុទ្ធិការវប្បធម៌អង្គការមូលនិធិវត្តបញ្ញាធំ

ការវាយអក្សរ និងបោះពុម្ពសាឡើងវិញនូវសៀវភៅព្រះត្រៃបិដកបាលី និងសេចក្តីប្រែជាភាសាខ្មែរ ដែលជាស្នាដៃ របស់លោកអ្នកប្រាជ្ញជំនាន់មុន គឺអាស្រ័យដោយការមើលឃើញនូវកត្តាចាំបាច់មួយចំនួនដូចខាងក្រោម ៖

- ឯកសារដើម ត្រូវបានថតចម្លងច្រើនសា ធ្វើឲ្យមានលក្ខណៈមិនច្បាស់ពិបាកក្នុងការអាន
- រក្សាស្នាដៃវប្បធម៌ព្រះពុទ្ធសាសនាឲ្យគង់វង្សស្ថិតស្ថេរ
- តម្រូវការរបស់សិក្ខាកាមអ្នកប្រាថ្នាចង់យល់ដឹងនូវខ្លឹមសារពុទ្ធសាសនា
- ផ្សាយនូវធម្មទាន ធ្វើឲ្យព្រះពុទ្ធសាសនាកាន់តែមានភាពរីកចម្រើនរុងរឿងក្នុងលោក

ដោយកុសលផលបុណ្យទាំងអម្បាលមាណ ដែលកើតអំពីធម្មទាននេះ

សូមឲ្យព្រះពុទ្ធសាសនាផ្សាយទៅគ្រប់ទិសទីទូទាំងសកលលោក

សូមឲ្យសព្វសត្វទាំងឡាយទាំងពួងបាននូវសេចក្តីសុខសួស្តី

សូមឲ្យមនុស្សគ្រប់ជាតិសាសន៍មានភាតរភាពនឹងគ្នា

សូមឲ្យពិភពលោកទាំងមូលមានសុខសន្តិភាព ។

MAHA PANNA VIHARA FOUNDATION ORGANIZATION

大般若寺基金會

ក្នុងករណីដែលលោកអ្នកអានបានពើបប្រទះនូវកំហុសឆ្គងណាមួយ ចង់ឲ្យយើងកែតម្រូវ ឬចង់បានសៀវភៅធម៌យកទៅអាន សូមទាក់ទងមកយើងខ្ញុំតាមអាសយដ្ឋានដូចខាងក្រោមៈ

វត្តបញ្ញា សង្កាត់ក្រាំងធ្នង់ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

លេខទូរស័ព្ទ: (៨៥៥) ១២ ៩៦១ ៩២៩, (៨៥៥) ៩៧ ៥១១ ៦៧៨៨

អ៊ីមែល: maha.panna@gmail.com

គេហទំព័រ: http://www.mahapanna.org

*“Wherever the Buddha’s teachings have flourished,*

*either in cities or countrysides,*

*people would gain inconceivable benefits.*

*The land and people would be enveloped in peace.*

*The sun and moon will shine clear and bright.*

*Wind and rain would appear accordingly,*

*and there will be no disasters.*

*Nations would be prosperous*

*and there would be no use for soldiers or weapons.*

*People would abide by morality and accord with laws.*

*They would be courteous and humble,*

*and everyone would be content without injustices.*

*There would be no thefts or violence.*

*The strong would not dominate the weak*

*and everyone would get their fair share.”*

~THE BUDDHA SPEAKS OF
THE INFINITE LIFE SUTRA OF
ADORNMENT, PURITY, EQUALITY
AND ENLIGHTENMENT OF
THE MAHAYANA SCHOOL~

With bad advisors forever left behind,
From paths of evil he departs for eternity,
Soon to see the Buddha of Limitless Light
And perfect Samantabhadra's Supreme Vows.

The supreme and endless blessings
of Samantabhadra's deeds,
I now universally transfer.
May every living being, drowning and adrift,
Soon return to the Pure Land of Limitless Light!

**✻ The Vows of Samantabhadra ✻**

I vow that when my life approaches its end,
All obstructions will be swept away;
I will see Amitabha Buddha,
And be born in His Western Pure Land of
Ultimate Bliss and Peace.

When reborn in the Western Pure Land,
I will perfect and completely fulfill
Without exception these Great Vows,
To delight and benefit all beings.

**✻ The Vows of Samantabhadra Avatamsaka Sutra ✻**